**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

# បច្ចុប្បន្នកម្ម

# ២០០៩-២០១៣

ជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព

ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

# ព្រះរាជក្រម

នស/រកម/០៦១០/០១២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងផែនការ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣

**មាត្រា ១.-**

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៦១០.៥៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

ឆាយ ថន

លេខ: ៤៨០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ឃុន ជិនកេន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគោលនយោបាយសាមគ្គីជាតិ ដើម្បីប្រមូលកម្លាំងប្រជាជាតិទាំងមូលជាធ្លុងមួយ ពីគ្រប់មជ្ឈដ្ឋាន គ្រប់និន្នាការនយោបាយទាំងក្នុង និងនៅក្រៅប្រទេសក្រោមបាវចនា "***ជាតិ សាសនា ព្រះមហាក្សត្រ***" ធ្វើឱ្យប្រទេសមានឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សុខសន្តិភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពថ្កើងថ្កាន ។ ជាមួយនេះកម្ពុជាបាន និងកំពុងទទួលបាននូវ "***ផលចំណេញពីសន្តិភាព***" តាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រក្នុងទសវត្សរ៍កន្លងទៅនេះ និងបានចូលរួមវិភាគទានយ៉ាងថ្លៃថ្លាក្នុងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ ស្ថិរភាពនយោបាយដែលមិនធ្លាប់មានជាច្រើនឆ្នាំមកហើយបានអនុញ្ញាតឱ្យកម្ពុជាអនុវត្តនូវកិច្ចការកំណែ ទម្រង់ក្នុងគ្រប់វិស័យ សំដៅកសាងសមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម- សេដ្ឋកិច្ច និងបង្កើតបរិយាកាសរឹងមាំដើម្បីទាក់ទាញវិនិយោគទុនទាំងក្នុង និងក្រៅប្រទេសក្នុងគោលដៅធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងច្រើនមិនត្រឹមតែក្នុងទិដ្ឋភាពនយោបាយនិងសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការប្រែប្រួលក្នុងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមផងដែរ ។ ស្ថិរភាពនយោបាយសុខសន្តិភាព និងសុវត្ថិភាពបែបនេះគឺជាបុព្វលក្ខខណ្ឌសម្រាប់កម្ពុជាសម្រេចបាននូវសក្តានុពលសង្គម-សេដ្ឋកិច្ចរបស់ខ្លួន ។ ការបោះឆ្នោតសកលនាឆ្នាំ ១៩៩៣ បាននាំមកនូវការអនុវត្តន៍នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនិងសេដ្ឋកិច្ចទីផ្សារ និងការគោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវ*កម្មវិធីជាតិសម្រាប់នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា* នាឆ្នាំ ១៩៩៤ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី១ (១៩៩៦- ២០០០)* សម្រាប់កំណត់ចក្ខុវិស័យនៃការកសាង និងអភិវឌ្ឍប្រទេសជាតិឡើងវិញដោយផ្តោតជាសំខាន់លើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍សង្គម និងការកាត់បន្ថយភាពក្រីក្រ ។

លើសពីនេះទៀតដំណាក់កាលនៃការផ្លាស់ប្តូរមុខមាត់របស់កម្ពុជាដ៏គួរកត់សម្គាល់គឺនៅក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៣ ដែលជារយៈពេលប្រវត្តិសាស្ត្រដ៏សំខាន់មួយដែលមិនត្រឹមតែមានការផ្លាស់ប្តូរនូវទិដ្ឋភាពសង្គម- សេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផ្លាស់ប្តូរនូវទិដ្ឋភាពនយោបាយទៀតផង ។ ជាក់ស្តែងការបោះឆ្នោតសកលនាឆ្នាំ១៩៩៨ ការអនុវត្តន៍ដោយជោគជ័យនូវនយោបាយ «***ឈ្នះ-ឈ្នះ***» ដែលបានរំលាយអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហមបាននាំមកនូវសុខសន្តិភាពពេញផ្ទៃប្រទេស និងការធ្វើសមាហរណកម្មនៃអតីតកងទ័ពខ្មែរក្រហម និងបងប្អូនខ្មែរដែលរស់នៅក្នុងតំបន់អតីតខ្មែរក្រហមកាន់កាប់ចូលមកក្នុងសង្គមកម្ពុជា ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវ*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច ៥ ឆ្នាំលើកទី ២ (២០០១-២០០៥)* ដើម្បីផ្តល់ការតម្រង់ទិសដល់ការបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ព្រមទាំងបានអនុវត្តដោយជោគជ័យនូវ «***យុទ្ធសាស្ត្រត្រី-កោណ***» ដែលបានផ្តោតលើគោលដៅសំខាន់បី គឺ ***(១)•*** *ការធានាឱ្យមានសន្តិភាព ស្ថិរភាព និងសន្តិសុខ* ***(២)•*** *ការធ្វើ*

*សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងការធ្វើឱ្យមានទំនាក់ទំនងល្អឡើងវិញជាមួយនឹងសហគមន៍អន្តរជាតិ* និង**(៣).** *ការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច* ។ ប្រការខាងលើនេះបានប្រែក្លាយកម្ពុជាពីប្រទេសមួយដែលធ្លាប់មានអស្ថិរភាព សង្គ្រាម ជម្លោះផ្ទៃក្នុង និងភាពអន់ថយឱ្យក្លាយទៅជាចំណុចកណ្តាលមួយនៃសន្តិភាពដ៏រឹងមាំ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការគោរពលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស កិច្ចសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍដោយ មានការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ។ ទិដ្ឋភាពមួយទៀតនៃការវិវឌ្ឍជីវិជ្ជមាន និងគួរឱ្យកត់សម្គាល់ដែលបានកើតមានឡើងចាប់តាំងពីឆ្នាំ ២០០៣ រហូតមកដល់បច្ចុប្បន្ន រួមមានការបោះឆ្នោតសកលនាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ដោយមានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតម្លាភាពដែលត្រូវបានទទួលស្គាល់ថា ជា "***អច្ឆរិយហេតុនៃឆន្ទមេគគ្គ***" ម្តងទៀត និងសមិទ្ធផលជាច្រើន ដែលសម្រេចបានតាមរយៈការអនុវត្តន៍ដោយជោគជ័យនូវ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥)* និង "***យុទ្ធសាស្ត្រចតុកោណ***" *ដើម្បីកំណើន ការងារសមធម៌ និងប្រសិទ្ធភាព* ។ តាមរយៈនេះ កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវឌ្ឍនភាពសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក្នុងនោះកំណើនសេដ្ឋកិច្ច ជាមធ្យមប្រចាំឆ្នាំមានកម្រិត ៨,៤% ក្នុងរវាងឆ្នាំ ១៩៩៤-២០០៦ និងពីឆ្នាំ ១៩៩៩-២០០៦ កំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំមានកម្រិតដល់ទៅ ៩% ។ ជាការពិតសមិទ្ធផលទាំងអស់នេះមិនអាចកាត់ផ្តាច់បានទេពីការចូលរួមវិភាគទានដ៏ថ្លៃថ្លាពីដៃគូអភិវឌ្ឍន៍ទាំងឡាយរបស់កម្ពុជា ។ វាក៏ឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិដែលត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការគ្រប់ប្រភេទដែលកម្ពុជាទទួលបានពីដៃគូសហប្រតិបត្តិការក្រៅប្រទេសរបស់ខ្លួន ក្នុងរយៈពេលកន្លងមកនេះ ។ ជារួមការដាក់ចេញ និងការអនុវត្តន៍ដោយជោគជ័យនូវផែនការជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នានាកន្លងមកបានផ្តល់នូវផែនទីតម្រង់ទិសសម្រាប់រាជរដ្ឋាភិបាលកម្ពុជាធ្វើដំណើរឆ្ពោះទៅរកការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ការអនុវត្តន៍ "***យុទ្ធសាស្ត្រចតុកោណ***" គឺជាការបន្តសកម្មភាពពង្រឹងនូវសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងរយៈពេលកន្លងមកដើម្បីសម្រេចបាននូវ "***គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍***" ក្នុងទិសដៅកែលម្អនិងបង្កើនសមត្ថភាពរបស់ស្ថាប័នសាធារណៈ លើកស្ទួយអភិបាលកិច្ចល្អ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិសំដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងរក្សាការពារសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិដែលទាំងអស់នេះគឺសុទ្ធតែជាកត្តាគន្លឹះដ៏សំខាន់បំផុតសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ក្នុងក្របខ័ណ្ឌនៃទស្សនៈនេះតម្រូវឱ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង កែលម្អ និងពង្រឹងនូវអាទិភាពគោលនយោបាយបន្តកែលម្អនូវយុទ្ធសាស្ត្រតាមផ្ទៃកឱ្យឆ្លុះបញ្ចាំងនូវសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា ដោយឈរលើបទពិសោធន៍ជាក់ស្តែងនៃការអនុវត្តន៍នូវ "***យុទ្ធសាស្ត្រចតុកោណ***" សម្រាប់នីតិកាលទី ៣ នៃរដ្ឋសភាក្នុងពេលកន្លងមក ។ បច្ចុប្បន្ន ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២*** នេះត្រូវបានរៀបចំឡើង និងក្លាយជាមូលដ្ឋានគ្រឹះនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ហើយត្រូវបានចាត់ទុកថាជា «***របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច***» នៃ «***កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល***» សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានសម្រេចរៀបចំនូវ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២០០៦-២០១០*** ជាផែនការថ្មី និងត្រូវបានរៀបចំឡើងដោយប្រើទម្រង់របស់***យុទ្ធសាស្ត្រចតុកោណ*** របស់រាជរដ្ឋាភិបាល ។ ចំពោះការរៀបចំផែនការថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ភាពជាម្ចាស់ពេញលេញក្នុងការគ្រប់គ្រងដំណើរការរៀបចំដោយធានាឱ្យមានការចូលរួមពិគ្រោះយោបល់ និងការផ្តល់អនុសាសន៍ពីគ្រប់ភាគីដែលមានចំណែកពាក់-

ព័ន្ធទាំងអស់ ។ ស្ថិតក្នុងជំហរហ្នឹងម៉ាត់ និងឥតងាករេក្នុងការអនុវត្តន៍ «***យុទ្ធសាស្ត្រចតុកោណ***» និង "***ផយអជ ២០០៦-២០១០***" រាជរដ្ឋាភិបាលបានបង្កើតឡើងនូវបរិស្ថានអំណោយផល និងល័ក្ខខ័ណ្ឌចាំបាច់ជាច្រើនដែលអាចនាំកម្ពុជាបោះជំហានទៅមុខប្រកបដោយក្តីសង្ឃឹម និងជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍន៍ស្របគ្នាជាមួយនឹងគោលបំណង ឧត្តមគតិ និងការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពុះពារបម្រើជាតិ និងប្រជាជនក្នុងគ្រប់កាលៈទេសៈ ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជន ។

បច្ចុប្បន្ននេះយើងមាន ***យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** និង***យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ*** ព្រមទាំងឯកសារជាច្រើនទៀតដែលមានលក្ខណៈជាផែនការ គោលនយោបាយ កម្មវិធីវិនិយោគ និងថវិកាជាតិ ។ ក្នុងន័យនេះដើម្បីធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និងលំដាប់លំដោយនៃការអនុវត្តន៍រវាងឯកសារទាំងអស់ខាងលើនេះយើងត្រូវតែបន្សុីអាណត្តិកាលរបស់ ***ផយអជ*** ជាមួយ នឹង***កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល*** ដែលមាន***យុទ្ធសាស្ត្រចតុកោណ*** ជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច ។ ខ្ញុំយល់ថា ***ផយអជ*** គឺជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តន៍ ***យុទ្ធសាស្ត្រ-ចតុកោណ*** ដែលតាមរយៈតួនាទីរបស់ខ្លួននេះធ្វើឱ្យឯកសារ ***ផយអជ*** ក្លាយជាឯកសារគោលនយោបាយសំខាន់ទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា ។

***ផយអជ*** ត្រូវតែធ្វើបច្ចុប្បន្នកម្មនៅខណៈពេលដែលវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោកមានផលប៉ះពាល់មកលើសង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេសបានធ្វើឱ្យមានការថយចុះនូវតម្រូវការទំនិញដែលនាំចេញពីកម្ពុជា និងបានធ្វើឱ្យកើនឡើងនូវហានិភ័យម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការវិវឌ្ឍន៍នានានៅក្រៅប្រទេសនេះបានផ្តល់នូវបញ្ហាប្រឈមនានាដែលមិនបានរំពឹងទុកជាមុន ។ ដោយប្រឈមមុខនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានចាត់វិធានការជាប្រព័ន្ធ និងតាមលំដាប់លំដោយដើម្បីកាត់បន្ថយឱ្យនៅកម្រិតទាបបំផុតនូវផលប៉ះពាល់អវិជ្ជមានរបស់វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោកមកលើប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកម្ពុជា និងការពារនូវបណ្តាសមិទ្ធផលទាំងឡាយរបស់យើងដែលទទួលបានដោយលំបាកក្នុងរយៈពេលកន្លងមក ។ ការវិវឌ្ឍន៍នានានៅក្រៅប្រទេសនេះក៏បានធ្វើឱ្យក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាលចាំបាច់ត្រូវតែពិនិត្យមើលឡើងវិញនូវផែនការរបស់ខ្លួនសម្រាប់អនុវត្តគោលនយោបាយអាទិភាពនៃ ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី*** ២ ។ ក្នុងក្របខ័ណ្ឌនៃបរិការណ៍នេះ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (ផយអជ បច្ចុប្បន្នកម្ម) ២០០៩-២០១៣*** ត្រូវបានរៀបចំឡើងដើម្បីសម្រេចឱ្យបាននូវគោលដៅអាទិភាពចំនួនពីរ គឺ ***គោលដៅទី ១*** ដើម្បីបន្សុីអាណត្តិកាលរបស់ ***ផយអជ បច្ចុប្បន្នកម្ម*** ជាមួយអាណត្តិកាលរបស់រាជរដ្ឋាភិបាលសំដៅធានាថា សកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ក្រសួង-ស្ថាប័នទាំងអស់ត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលប្រានកំណត់ក្នុង ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី*** ២ ហើយ ***គោលដៅទី ២*** គឺដើម្បីធានាថាការងារដែលត្រូវលើកឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់ផលប៉ះពាល់ នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកដែលអាចមានមកលើសេដ្ឋកិច្ចរបស់យើង ។

***ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣*** ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រដែលមានលក្ខណៈល្អប្រសើរជាងមុនពីព្រោះថាវិធីសាស្ត្រនេះបានផ្តោតលើ ***ទី១).*** *តើក្រសួង-ស្ថាប័នណា*ជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍គោលនយោបាយអាទិភាពទាំងឡាយក្នុងមុំនីមួយៗនៃ ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២ ទី២).*** *តើសកម្មភាពជាក់លាក់អ្វីខ្លះ*ដែលក្រសួង-ស្ថាប័នទទួលខុសត្រូវបានគ្រោងឡើងដើម្បីអនុវត្តគោលនយោបាយ អាទិភាពទាំងឡាយ

និង ***ទី៣)*.** *តើតម្លៃប៉ុន្មាន*ដែលក្រសួង-ស្ថាប័នទទួលខុសត្រូវប៉ាន់ស្មានឱ្យបានត្រឹមត្រូវបំផុត ដើម្បីអនុវត្តសកម្មភាពទាំងឡាយដែលបានគ្រោងសម្រាប់អំឡុងឆ្នាំ ២០០៩-២០១៣ ។ ទន្ទឹមនឹងនេះ ***ផែនការ បច្ចុប្បន្នកម្ម ២០០៩-២០១៣*** ត្រូវបានរៀបចំឡើងដោយផ្អែកលើធាតុចូលពីក្រសួង-ស្ថាប័ននីមួយៗរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយបានពិគ្រោះយោបល់ជាមួយតួអង្គដែលមានចំណែកពាក់ព័ន្ធ ។ម្យ៉ាងវិញទៀត ការរៀបចំ ***ផែនការ បច្ចុប្បន្នកម្ម ២០០៩-២០១៣*** ត្រូវបានធ្វើឡើងដោយមានការចូលរួមតាមរយៈវិធីសាស្ត្រ ប្រមូលព័ត៌មានពីក្រោមឡើងលើ និងដោយមានការបង្កើតក្រុមការងារបច្ចេកទេសចម្រុះដឹកនាំដោយក្រសួងផែនការដើម្បីគ្រប់គ្រងនូវដំណើរការពង្រឹងសុខដុមនីយកម្មរវាងការរៀបចំផែនការចំណាយវិនិយោគសាធារណៈ និងធនធានពីគ្រប់ប្រភព ដែលនឹងអាចរកបានសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាមួយគ្នានេះក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង - ស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាថា ការកំណត់គម្រោងវិនិយោគសាធារណៈនានាដោយក្រសួង-ស្ថាប័នជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការរៀបចំ *ក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា* សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយដែលបានជួយគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់រួមចំណែកធ្វើឱ្យកម្ពុជាមានវឌ្ឍនភាពគួរជាទីមោទនៈ ។ ប្រាកដណាស់ថា បច្ចុប្បន្នយើងកំពុងស្ថិតក្នុងយុគសម័យថ្មីមួយដែលក្នុងនោះរាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័នរបស់ខ្លួនត្រូវតែធ្វើជាម្ចាស់លើដំណើរការអភិវឌ្ឍន៍នានា និងត្រូវទទួលខុសត្រូវលើវាសនារបស់ខ្លួនដោយខ្លួនឯង ។ ក្នុងខណៈពេលដែលយើង បាន និងកំពុងបោះជំហានឆ្ពោះទៅមុខរាជរដ្ឋាភិបាលនឹងទទួលខុសត្រូវពេញលេញ ក្នុងដំណើរការអភិវឌ្ឍន៍ទាំងមូល ដើម្បីធានាថា ធនធានទាំងអស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នឹងត្រូវបានផ្តល់ដោយមានទិសដៅច្បាស់លាស់ទៅដល់អាទិភាព និងវិស័យនានាដែលត្រូវបានជ្រើសរើសឡើង ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ខ្ពស់ក្នុងការសម្រេចឱ្យបាននូវ « ***ការផ្ទេរពិត*** » នៃធនធានអភិវឌ្ឍន៍ដើម្បីឱ្យបានទៅដល់អ្នកត្រូវទទួលផលប្រយោជន៍ទាំងឡាយដូចជាក្រុមជនងាយរងគ្រោះ និងអ្នកក្រីក្រនៅក្នុងសហគមន៍ជនបទជាដើម ។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថាដើម្បីភាពជោគជ័យនៃការអនុវត្តន៍គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលដូចបានកំណត់ក្នុង ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២*** សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍វិស័យឯកជន សង្គមស៊ីវិល និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ។ ខ្ញុំសូមជំរុញ និងសង្ឃឹមជឿជាក់ថាក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍វិស័យឯកជនសង្គមស៊ីវិល និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់នឹងប្រកាន់ខ្ជាប់នូវបណ្តាអាទិភាពនានាដែលបានកំណត់ក្នុង ***ផែនការ បច្ចុប្បន្នកម្ម ២០០៩-២០១៣*** ដែលជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តន៍ ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២*** ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០*

**ហ៊ុន សែន**

# សញ្ញាជាតិ និង ទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា





# គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ



# កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

**ព័ត៌មានទូទៅ (២០០៨)**

| | |
|---|---|
| ផ្ទៃដីសរុប: គម² | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៣ |
| ចំនួនស្រុក | ១៥៩ |
| ចំនួនខណ្ឌ | ៨ |
| ចំនួនក្រុង | ២៦ |
| ចំនួនឃុំ | ១ ៤១៧ |
| ចំនួនសង្កាត់ | ២០៤ |
| ចំនួនភូមិ | ១៤ ០៧៣ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល (៛) |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| **១.00** | **កម្រិតនៃភាពក្រីក្រ (២០០៧)** | | | | | | | |
| ១.0១ | សរុបទូទាំងប្រទេស | % នៃប្រជាជន | ៣០.១ (២០០៧) | ពុំមានតួលេខ | ២៥.0 | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ១.0២ | ភ្នំពេញ | % នៃប្រជាជន | 0.៨ (២០០៧) | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ១.0៣ | ទីប្រជុំជនផ្សេងទៀត | % នៃប្រជាជន | ២១.៩ (២០០៧) | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ១.0៤ | ជនបទ | % នៃប្រជាជន | ៣៤.៧ (២០០៧) | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ១.0៥ | ប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ | % នៃប្រជាជន | ១៨.0 (២០០៧) | ពុំមានតួលេខ | ១៣.0 | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| | | | | | | | | |
| **២.00** | **បញ្ហាយេនឌ័រ** | | | | | | | |
| ២.0១ | ស្ត្រីក្នុងកម្លាំងពលកម្ម (ក.ព) : វិស័យកសិកម្ម | % នៃ ក.ព សរុប | ៥២.៥ | ពុំមានតួលេខ | ៥០.0 | ពុំមានតួលេខ | ពុំមានតួលេខ | ៥០.0 |
| ២.0២ | វិស័យឧស្សាហកម្ម | % នៃ ក.ព សរុប | ៥៣.៥ | ពុំមានតួលេខ | ៥០.0 | ពុំមានតួលេខ | ពុំមានតួលេខ | ៥០.0 |
| ២.0៣ | វិស័យសេវាកម្ម | % នៃ ក.ព សរុប | ២៧.0 | ពុំមានតួលេខ | ៣៧.0 | ពុំមានតួលេខ | ពុំមានតួលេខ | ៥០.0 |
| **៣.00** | **ប្រជាជន** | | | | | | | |
| | | | | | | | | |
| ៣.0១ | សរុប : ជំរឿន ខែមីនា ឆ្នាំ២០០៨ | លាននាក់ | ១៣.៤ | ១៣.៩ | ១៤.១ | ១៤.៣ | ១៤.៥ | ១៤.៧ |
| ៣.0២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម² | ៧៥ | ៨១ | ៨៣ | ៨៤ | ៨៦ | ៨៧ |
| ៣.0៣ | បុរសធៀបនឹងស្ត្រី | ស្ត្រី១០០នាក់ | ៩៤.៧ | ៩៤.៨ | ៩៥.0 | ៩៥.១ | ៩៥.៣ | ៩៥.៤ |
| ៣.0៤ | អាយុ 0-១៤ | % នៃប្រជាជន | ៣៣.៧ | ៣៥.១ | ៣៤.៣៤ | ៣៣.៦ | ៣៣.២ | ៣៣.៣៧ |
| ៣.0៥ | អាយុ ១៥-៦៤ | % នៃប្រជាជន | ៦២.0៤ | ៦១.0៩ | ៦១.៨២ | ៦២.៤៧ | ៦២.៨៦ | ៦២.៦២ |
| ៣.0៦ | អាយុ ៦៥ឆ្នាំឡើង | % នៃប្រជាជន | ៤.២៧ | ៣.៨ | ៣.៨៤ | ៣.៨៨ | ៣.៩៤ | ៤.0១ |
| ៣.0៧ | ជនបទ | % នៃប្រជាជន | ៨០.៥ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ៣.0៨ | ទីប្រជុំជន | % នៃប្រជាជន | ១៩.៥ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |

| | **សូចនាករសំខាន់ៗ** | **ឯកតា** | **២០០៨** | **២០០៩** | **២០១០** | **២០១១** | **២០១២** | **២០១៣** |
|---|---|---|---|---|---|---|---|---|
| ៣.០៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ១,៥៤ | ១,៤០ | ១,៣៥ | ១,៣៤ | ១,៣២ | ១,៣០ |
| ៣.១០ | អត្រាបង្កើតកូនសរុប ( ក្នុងស្ត្រីម្នាក់) | កំណើតរស់ | ៣,១១ | ៣,០៤ | ២,៩៧ | ២,៩១ | ២,៨៥ | ២,៨០ |
| ៣.១១ | អាយុកាលមធ្យមសង្ឃឹមរស់ពីកំណើត : ប្រុស | ឆ្នាំ | ៦០,៥ | ៦០,៦៥ | ៦១,៣៥ | ៦២,០៤ | ៦២,៧៣ | ៦៣,៤៣ |
| | ស្ត្រី | ឆ្នាំ | ៦៤,៣ | ៦៦,៩៧ | ៦៧,៦៨ | ៦៨,៣៨ | ៦៩,០៩ | ៦៩,៨០ |
| | | | | | | | | |
| **៤.០០** | **ម៉ាក្រូសេដ្ឋកិច្ច** | | | | | | | |
| ៤.០១ | *ផសស* ថ្លៃថេរឆ្នាំ២០០០ | ពាន់លានរៀល | ២៨ ៦៦៨ | ២៨ ៦៩២ | ៣០ ១២៦ | ៣១ ៩៤១ | ៣៤ ០២៩ | ៣៦ ២៣៥ |
| ៤.០២ | *ផសស* ថ្លៃថេរឆ្នាំ២០០០ | លានដុល្លារ | ៧.០៦១ | ៦.៩១៧ | ៧.២៦៨ | ៧.៧២៥ | ៨.១៨៤ | ៨.៧០៤ |
| ៤.០៣ | អត្រាកំណើន ផសស ពិត | % | ៦,៧ | ០,១ | ៥,០ | ៦,០ | ៦,៥ | ៦,៥ |
| ៤.០៤ | កសិកម្ម | % | ៥,៧ | ៥,៤ | ៤,០ | ៣,២ | ៣,៤ | ៣,២ |
| ៤.០៥ | ឧស្សាហកម្ម | % | ៤,០ | -៩,៥ | ១០,៥ | ៧,៩ | ៨,៤ | ៨,២ |
| ៤.០៦ | សេវាកម្ម | % | ៩,០ | ២,៣ | ៣,៣ | ៧,៣ | ៧,៤ | ៧,៤ |
| ៤.០៧ | ផសស សម្រាប់ប្រជាជនម្នាក់ៗ | ពាន់រៀល | ២.៩៩៨ | ៣.០៣០ | ៣.២៨៤ | ៣.៥២៨ | ៣.៧៩៩ | ៤.០៨៤ |
| ៤.០៨ | *ផសស* សម្រាប់ប្រជាជនម្នាក់ៗ | ដុល្លារ | ៧៣៨ | ៧៣១ | ៧៩២ | ៨៥៣ | ៩១៥ | ៩៨១ |
| ៤.០៩ | អតិផរណា ( ការប្រែប្រួលមធ្យមប្រចាំឆ្នាំ) | % | ១៩,៧ | -០,៦ | ៦,០ | ៤,៥ | ៣,៥ | ៣,០ |
| ៤.១០ | ប្រាក់រៀល ធៀបនឹង ដុល្លារ ( មធ្យមប្រចាំឆ្នាំ) | រៀល/ដុល្លារ | ៤ ០៦០ | ៤ ១៤៨ | ៤ ១៤៥ | ៤ ១៣៥ | ៤ ១៥៣ | ៤ ១៦៣ |
| ៤.១១ | ទុនបម្រុងបរទេសដុល | ចំនួនខែនាំចូល | ៣,៥ | ៤,៦ | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ |
| ៤.១២ | ទុនបម្រុងបរទេសដុល | លានដុល្លារ | ២ ១៦៤ | ២.៣៦៧ | ១.៩៣៥ | ២.១៤២ | ២.៣៦១ | ២.៦០០ |
| ៤.១៣ | ការវិនិយោគផ្ទាល់បរទេស | លានដុល្លារ | ៧៩៥ | ៥១៥ | ៥៩៩ | ៦៧៦ | ៧៤៥ | ៨២១ |
| | | | | | | | | |
| **៥.០០** | **សារពើពន្ធ** | | | | | | | |
| ៥.០១ | ចំណូលថវិកាសរុប | %នៃ *ផសស* | ១៣,៣ | ១១,៨ | ១២,៦ | ១៣,២ | ១៣,៧ | ១៤,២ |
| ៥.០២ | ចំណាយថវិកាសរុប | % នៃ *ផសស* | ១៥,៩ | ១៧,៥ | ១៧,៩ | ១៧,៨ | ១៧,៨ | ១៧,៧ |
| ៥.០៣ | អតិរេកចរន្ត | % នៃ *ផសស* | ៣,០ | ០,១ | ១,៣ | ១,៧ | ២,២ | ២,៨ |
| | | | | | | | | |
| **៦.០០** | **វិស័យហិរញ្ញវត្ថុ** | | | | | | | |
| ៦.០១ | ធនាគារពាណិជ្ជកម្មនិងធនាគារឯកទេស | ចំនួន | ៣០ | ៣៣ | ៣៤ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ៦.០២ | ឥណទានមិនទាន់ទូទាត់សង | ពាន់លានរៀល | ៩ ៦៦៥ | ១០ ០៩៤ | ១១ ១០៤ | ១២ ២១៤ | ១៣ ៤៣៥ | ១៤ ៧៧៩ |
| ៦.០៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ចំនួន | ១៨ | ២០ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ | ពុំមានតួលេខ |
| ៦.០៤ | ឥណទានមិនទាន់ទូទាត់សង | ពាន់លានរៀល | ១ ១៦១ | ១ ២៦៣ | ១ ៥១៦ | ១ ៩៧១ | ២ ៧៦០ | ៣ ៨៦៤ |
| | | | | | | | | |
| **៧.០០** | **ជំនួយអភិវឌ្ឍន៍ផ្លូវការ (រួមទាំងអង្គការក្រៅរដ្ឋាភិបាល)** | | | **ប៉ាន់ស្មាន** | **ព្យាករណ៍** | **ព្យាករណ៍** | **ព្យាករណ៍** | **ព្យាករណ៍** |
| ៧.០១ | សរុប | លានដុល្លារ | ៩៥៧,៣០៨ | ៩៦០,៨៣០ | ១ ០៤៤,៦៣៦ | ៧០៦,៩៦៦ | ៤៩៩,៦០៣ | ២២៧,១២៣ |
| ៧.០២ | ជំនួយបច្ចេកទេស | លានដុល្លារ | ២២២,៤០១ | ២៤១,៣០២ | ២២១,២៣៨ | ១១៨,០៩៦ | ៧៨,០៤៣ | ៣២,៧៧៨ |
| ៧.០៣ | ជំនួយវិនិយោគ | លានដុល្លារ | ៥៩៤,២៨២ | ៥៨៤,៤៨៣ | ៦៩៣,៥៧០ | ៥១៦,៤៥៦ | ៣២៨,៤៩៤ | ១៧៧,៤៤៣ |
| ៧.០៤ | ជំនួយផ្សេងៗទៀត | លានដុល្លារ | ១៤០,៦២៥ | ១៣៥,០៤៥ | ១២៩,៨២៩ | ៧២,៤១៥ | ៥៣,០៦៦ | ១៦,៩០៣ |
| | | | | | | | | |
| **៨.០០** | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | | |
| ៨.០១ | ផ្ទៃដីដំណាំ | ពាន់ហត | ៥៩៦ | ៦៤៥ | ៧៧៤ | ៩៣០ | ១ ០០០ | ១ ០០០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| ៨.០២ | ផ្ទៃដីស្រោចស្រព | ពាន់ហត | ១ ១២០ | ១ ១៤៥ | ១ ១៧០ | ១ ១៩៥ | ១ ២២០ | ១ ២៤៥ |
| ៨.០៣ | ផ្ទៃដីដាំដុះស្រូវ | លានហត | ២,៦១ | ២,៦៣ | ២,៦៥ | ២,៦៥ | ២,៦៥ | ២,៦៥ |
| ៨.០៤ | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | ២,៧៤ | ២,៧៧ | ២,៨០ | ២,៨៣ | ២,៨៧ | ៣,០០ |
| ៨.០៥ | ឡូតិ៍នេសាទ | គម² | ៤១៥ | ៤១៥ | ៤១៥ | ៤១៥ | ៤១៥ | ៤១៥ |
| ៨.០៦ | ក្នុងនោះ -- សម្រាប់សហគមន៍នេសាទ | % | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ |
| ៨.០៧ | ត្រីនេសាទបាន (ពីគ្រប់ប្រភព) | តោន | ៤៧១ | ៥១៥ | ៦១៧ | ៦៦៨ | ៧២៦ | ៧៨៨ |
| ៨.០៨ | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | %នៃផ្ទៃដី | ៥៩,០០ | ៥៧,៥៩ | ៥៧,៩៩ | ៥៨,៣៩ | ៥៨,៧៩ | ៥៩,១៩ |
| ៨.០៩ | ព្រៃឈើដាំដុះឡើងវិញ (សរុបផ្ទៃដីតាំងពីឆ្នាំ១៩៨៥) | ពាន់ហត | ១០,៨១ | ១៨,៩២ | ៧៣ | ៧៣ | ៧៣ | ៧៣ |
| ៨.១០ | ការប្រើប្រាស់អុសសម្រាប់ដុត | %គ្រួសារសរុប | ៧៣ | ៦៧ | ៦១ | ៥៩ | ៥៦ | ៥៤ |
| ៨.១១ | ការបោះបង្គោលព្រំព្រៃ | គម | ៣២១ | ២២៨ | ៤១៣ | ៥០០ | ៥០០ | ៥០០ |
| ៨.១២ | សហគមន៍ព្រៃឈើ | សហគមន៍ | ១២៤ | ២១០ | ៣០០ | ៣៥០ | ៤០០ | ៤៥០ |
| | | | | | | | | |
| **៩.០០** | **ការអភិវឌ្ឍជនបទ** | | | | | | | |
| ៩.០១ | ផ្លូវថ្នល់ដែលបានស្តារ (នៃប្រវែងសរុប ២៨ ០០០គម) | គម | ២៤ ១៤០ | ២៥ ៦៥៨ | ២៦ ៦៥៨ | ២៧ ៦៥៨ | ២៨ ៦៥៨ | ២៩ ៦៥៨ |
| ៩.០២ | ការទទួលបានទឹកស្អាត (ជនបទ) | %នៃប្រជាជន | ៤០,៤៩ | ៤១,៩៩ | ៤៣,៤៩ | ៤៤,៩៩ | ៤៦,៤៩ | ៤៧,៦៩ |
| ៩.០៣ | ការទទួលបានអនាម័យ (ជនបទ) | %នៃប្រជាជន | ២៣,២៤ | ២៤,២៤ | ២៥,០០ | ២៧,០០ | ២៩,០០ | ៣១,០០ |
| | | | | | | | | |
| **១០.០០** | **ឧស្សាហកម្ម** | | | | | | | |
| ១០.០១ | ផលិតផលកម្មន្តសាល | ពាន់លានរៀល | ១៥ ២៨១ | ១២ ៨៧០ | ១៤ ៨១២ | ១៥ ៧៦៩ | ១៦ ២៤២ | ១៦ ៧២៩ |
| ១០.០២ | ក្នុងនោះ - ឧស្សាហកម្មសម្លៀកបំពាក់ : ផលិតផល | ពាន់លានរៀល | ១២ ៣៤៨ | ៩ ៨៧៨ | ១១ ៧៣១ | ១២ ៥៥៥ | ១២ ៩៧៣ | ១៣ ៣៦២ |
| ១០.០៣ | : កម្លាំងពលកម្ម | នាក់ | ៣២៩ ៨៩២ | ៣៣៥ ០០០ | ៣៤០ ០០០ | ៣៥០ ០០០ | ៣៧០ ០០០ | ៤០០ ០០០ |
| ១០.០៤ | ឧស្សាហកម្មធុនតូចនិងមធ្យម | មូលដ្ឋាន | ៣២ ៨០០ | ៣៣ ០០៥ | ៣៣ ២១៤ | ៣៣ ៤៥០ | ៣៣ ៥៧៩ | ៣៣ ៨១៤ |
| ១០.០៥ | ទុនវិនិយោគសរុប | ពាន់ដុល្លារ | ១៦៥ ៩៣២ | ១៦៦ ៦៧៦ | ១៦៨ ៤០៩ | ១៦៩ ៦៩៩ | ១៧១ ២០៦ | ១៧១ ២៨៨ |
| ១០.០៦ | ផលិតផល | ពាន់លានរៀល | ២ ៧០០ | ២ ៧៨១ | ២ ៨៥៨ | ២ ៨៧៨ | ២ ៩០៣ | ២ ៩០៤ |
| ១០.០៧ | កម្មករ | នាក់ | ៩៦ ៨៨៣ | ៩៦ ៣៦២ | ៩៨ ០៣៤ | ៩៨ ៧៣១ | ៩៩ ៦៣៤ | ៩៩ ៦៨៤ |
| ១០.០៨ | កម្មករ ជាស្ត្រី | នាក់ | ៤៣ ៨០៣ | ៤៤ ០៥៣ | ៤៤ ១០៨ | ៤៤ ៣៧៣ | ៤៤ ៦៤៣ | ៤៤ ៩១៨ |
| ១០.០៩ | សហគ្រិន ជាស្ត្រី | នាក់ | ៣ ០០៥ | ៣ ០៥៥ | ៣ ១១០ | ៣ ១៧០ | ៣ ២៣៥ | ៣ ៣០៥ |
| | | | | | | | | |
| **១១.០០** | **ថាមពល** | | | | | | | |
| ១១.០១ | អគ្គិសនីដែលផលិតបាន | លាន គវ៉ម | ១ ៨៥៨,៣៦៤ | ១ ៨៨២,០០៣ | ២ ១៦៤,៣០០ | ២ ៤៨៨,៩៤៥ | ២ ៨៦២,២៨៧ | ៣ ២៩១,៦២៩ |
| ១១.០២ | ចំនួនគ្រួសារប្រើប្រាស់ថាមពល | គ្រួសារ | ៤៨៧ ៤២៦ | ៥៦០ ៥៣៩ | ៦៤៤ ៦២១ | ៧៤១ ៣១៤ | ៨៥២ ៥១១ | ៩៨០ ៣៨៨ |
| ១១.០៣ | ការប្រើប្រាស់ថាមពលរបស់ប្រជាជនម្នាក់ក្នុង១ឆ្នាំ | គវ៉ម | ១៣៩ | ១៣៥ | ១៥៣ | ១៧៤ | ១៩៧ | ២២៤ |
| ១១.០៤ | ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (២២ KV) | គម | ១ ៤៥០ | ១ ៥៩៥ | ១ ៩១៤ | ២ ២០១ | ២ ៥៣១ | ២ ៩១១ |
| ១១.០៥ | ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (១១៥ KV) | គម | ៣២៣ | ៣៩៣ | ៣៩៣ | ៤៧៦ | ៥៤៧,៥ | ៥៤៧,៥ |
| ១១.០៦ | ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (២៣០ KV) | គម | ០ | ១០០ | ១០០ | ២៦៩ | ១ ១៨២ | ១ ៤០៧ |
| | | | | | | | | |
| **១២.០០** | **ដឹកជញ្ជូន** | | | | | | | |
| ១២.០១ | ផ្លូវជាតិ និង ផ្លូវខេត្ត : សរុប | គម | ១១ ៤៩៤ | ១១ ៤៩៤ | ១១ ៦១៨ | ១១ ៦១៨ | ១១ ៦១៨ | ១១ ៦១៨ |
| ១២.០២ | ក្នុងនោះ -- ផ្លូវកៅស៊ូ | គម | ២ ៣៤២ | ២ ៦៦១ | ២ ៧៨១ | ២ ៨០០ | ៣ ៥០០ | ៤ ១០០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| ១២.០៣ | ផ្លូវដែក | គម | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ |
| ១២.០៤ | កំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ | ២ | ២ | ២ |
| ១២.០៥ | អាកាសយានដ្ឋាន : | | | | | | | |
| | ក-អាកាសយានដ្ឋានអន្តរជាតិ | ចំនួន | ២ | ២ | ៣ | ៣ | ៣ | ៣ |
| | ខ- អាកាសយានដ្ឋានក្នុងស្រុក | ចំនួន | ៩ | ៩ | ៨ | ៨ | ៨ | ៨ |
| | | | | | | | | |
| **១៣.០០** | **ទូរគមនាគមន៍** | | | | | | | |
| ១៣.០១ | ទូរសព្ទ័ដែលកំពុងប្រើប្រាស់ (ចល័ត និង អចល័ត) | ពាន់គ្រឿង | ៤ ១៤៣ | ៦ ៤៤៧ | ៧ ១០០ | ៧ ៧០០ | ៨ ៣០០ | ៨ ៩០០ |
| ១៣.០២ | អ្នកប្រើប្រាស់អ៊ិតធ័រណែត | នាក់ | ២០ ១០៨ | ២៩១ ៤១៣ | ៣៥០ ០០០ | ៤០០ ០០០ | ៤៥០ ០០០ | ៥០០ ០០០ |
| ១៣.០៣ | អត្រាអ្នកប្រើប្រាស់ប្រៃសណីយ៏ | % | ០,៣៦ | ០,៣៨ | ០,៤០ | ០,៤២ | ០,៤៤ | ០,៤៦ |
| ១៣.០៤ | អតិថិជនមធ្យមក្នុងមួយស្ថានីយ | ចំនួន | ១៦១ ៤៤៥ | ១៦៣ ៩៣២ | ១៤០ ៩៦៨ | ១២៥ ២៥៦ | ១១១ ២៨៦ | ១០១ ១៤៧ |
| | | | | | | | | |
| **១៤.០០** | **ទេសចរណ៍** | | | | | | | |
| ១៤.០១ | ទេសចរអន្តរជាតិ | លាននាក់ | ២,១២៥ | ២,១៦២ | ២,២៧៦ | ២,៤៤៧ | ២,៦៩១ | ៣,០១០ |
| ១៤.០២ | ទេសចរជាតិ | លាននាក់ | ៦,៧២៩ | ៦,៩៥៧ | ៧,៥៦២ | ៨,០៣៥ | ៨,៥៤៦ | ៩,០៩៩ |
| ១៤.០៣ | ការស្នាក់នៅ (ការស្នាក់នៅតាមបន្ទប់សណ្ឋាគារ និង ផ្ទះសំណាក់) | បន្ទប់ | ៣២ ៨៥៨ | ៣៧ ១៩១ | ៤០ ៩១០ | ៤៤ ១៨៣ | ៤៧ ២៧៦ | ៥០ ១១២ |
| ១៤.០៤ | កម្លាំងពលកម្មក្នុងវិស័យទេសចរណ៏ | នាក់ | ៣០០ ០០០ | ៣០៥ ០០០ | ៣១៥ ០០០ | ៣១៧ ០០០ | ៣២០ ០០០ | ៣៣០ ០០០ |
| ១៤.០៥ | ចំណូលពីវិស័យទេសចរណ៏ | លានដុល្លារ | ១ ៥៩៥ | ១ ៦១៧ | ១ ៦៨២ | ១ ៧៦៦ | ១ ៨៧២ | ២ ០២២ |
| | | | | | | | | |
| **១៥.០០** | **ព័តិមានសាធារណៈ** | | | | | | | |
| ១៥.០១ | អង្គភាពភ្នាក់ងារព័តិមាន រដ្ឋនិងឯកជន (សារព័តិមាន ទស្សនាវដ្ដី ជាភាសាខ្មែរនិងបរទេស) | អង្គភាព | ៥៤៣ | ៥៥១ | ៥៥៦ | ៥៦១ | ៥៦៦ | ៥៧១ |
| ១៥.០២ | រោងពុម្ព | កន្លែង | ១៣៣ | ១៣៤ | ១៣៥ | ១៣៥ | ១៣៦ | ១៣៦ |
| ១៥.០៣ | ចំនួនស្ថានីយ៏វិទ្យុក្នុងស្រុក រដ្ឋនិងឯកជន (ស្ថានីយ កណ្ដាល និងខេត្ត) | ស្ថានីយ៏ | ៥២ | ៥៥ | ៦០ | ៦៣ | ៦៥ | ៦៩ |
| ១៥.០៤ | ចំនួនស្ថានីយ៏ទូរទស្សន៏ក្នុងស្រុក (រដ្ឋនិងឯកជន) និង ទូរ-ទស្សន៏ខ្សែកាប (ស្ថានីយ កណ្ដាលនិងខេត្ត) | ស្ថានីយ៏ | ១០២ | ១០៦ | ១១១ | ១១២ | ១១៥ | ១១៩ |
| | | | | | | | | |
| **១៦.០០** | **សុខាភិបាល** | | | | | | | |
| ១៦.០១ | អត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ | ក្នុង ១ ០០០ កំណើតរស់ | ៦៦ (២០០៦) | ពុំមានតួលេខ | ៦០ | ពុំមានតួលេខ | ពុំមានតួលេខ | ៥៥ |
| ១៦.០២ | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ | ក្នុង ១ ០០០ កំណើតរស់ | ៨២ (២០០៦) | ពុំមានតួលេខ | ៧៥ | ពុំមានតួលេខ | ពុំមានតួលេខ | ៧០ |
| ១៦.០៣ | អត្រាមរណភាពមាតា | ក្នុង ១០០ ០០០ កំណើតរស់ | ៤៦១ | ពុំមានតួលេខ | ៣៥០ | ពុំមានតួលេខ | ពុំមានតួលេខ | ៣០០ |
| ១៦.០៤ | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ | % | ៥៨ | ៦៥ | ៧០ | ៧៥ | ៨០ | ៨៥ |
| ១៦.០៥ | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមាន ជំនាញ នៅមូលដ្ឋានសុខាភិបាលសាធារណៈ | % | ៣៩ | ៤៥ | ៥០ | ៥៥ | ៦០ | ៦៥ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| ១៦.០៦ | អត្រាជំងឺគ្រុនចាញ់ស្លាប់ ក្នុងចំណោមប្រជាជន ១០០០០០នាក់ | ១០០ ០០០ នាក់ | ២,១០ | ១,៥០ | ១,២០ | ១,១០ | ០,៩៩ | ០,៥០ |
| ១៦.០៧ | អត្រាប្រេវ៉ាឡង់ជំងឺរបេងគ្រប់សណ្ឋាន ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ | ១០០ ០០០ នាក់ | ៦១៧ | ៥៩៣ | ៥៦៤ | ៥៤៤ | ៥២៣ | ៥០២ |
| ១៦.០៨ | ហ៊ីវ/អេដស៍ : អត្រាប្រេវ៉ាឡង់ក្នុងចំណោមមនុស្សពេញវ៉ីយ | %(១៥-៤៩ឆ្នាំ) | ០,៧ | ០,៧ | ០,៧ | ០,៦ | ០,៦ | ០,៦ |
| ១៦.០៩ | ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប | % | ២៦ | ៣៧ | ៤០ | ៤៥ | ៤៦ | ៤៩ |
| ១៦.១០ | ការទទួលបានទឹកស្អាត (ទីប្រជុំជន) | %នៃប្រជាជន | ៥១ | ៥៣ | ៥៤ | ៥៥ | ៥៧ | ៦០ |
| | | | | | | | | |
| **១៧.០០** | **អប់រំ** | | **២០០៨/០៩** | **២០០៩/១០** | **២០១០/១១** | **២០១១/១២** | **២០១២/១៣** | **២០១៣/១៤** |
| ១៧.០១ | សាលាបឋមសិក្សា (ថ្នាក់ទី ១-៦) | ចំនួន | ៦ ៥៦៥ | ៦ ៦៣៥ | ៦ ៦៨៥ | ៦ ៧៨៥ | ៦ ៨៦៥ | ៦ ៩៤៥ |
| ១៧.០២ | អត្រាពិតនៃការសិក្សា : សរុប | % | ៩៤,៤ | ៩៥,០ | ៩៦,០ | ៩៧,០ | ៩៧,៥ | ៩៨,០ |
| ១៧.០៣ | ប្រុស | % | ៩៤,៨ | ៩៥,០ | ៩៥,៥ | ៩៦,០ | ៩៦,៥ | ៩៧,០ |
| ១៧.០៤ | ស្រី | % | ៩៤,០ | ៩៥,០ | ៩៦,០ | ៩៧,០ | ៩៨,០ | ៩៩,០ |
| ១៧.០៥ | អត្រាបញ្ចប់ការសិក្សា ថ្នាក់ទី៦ | % | ៨៥,៦ | ៨៦,០ | ៨៨,០ | ៩០,០ | ៩២,០ | ៩៤,០ |
| ១៧.០៦ | ចំនួននៃសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ១ ៤៥១ | ១ ៥២១ | ១ ៦០០ | ឃុំ១មានសាលារៀន ១ | ឃុំ១ មានសាលារៀន ១ | ឃុំ១ មានសាលារៀន ១ |
| ១៧.០៧ | អត្រាពិតនៃការសិក្សា : សរុប | % | ៣៣,៩ | ៤០,០ | ៤៣,០ | ៤៦,០ | ៤៨,០ | ៥១,០ |
| ១៧.០៨ | ប្រុស | % | ៣២,០ | ៣៨,០ | ៤១,០ | ៤៣,០ | ៤៦,០ | ៤៩,០ |
| ១៧.០៩ | ស្រី | % | ៣៥,០ | ៤២,០ | ៤៥,០ | ៤៨,០ | ៥១,០ | ៥៤,០ |
| ១៧.១០ | អត្រាបញ្ចប់ការសិក្សា ថ្នាក់ទី៩ | % | ៤៩,១ | ៥១,០ | ៥៣,០ | ៥៥,០ | ៥៧,០ | ៥៩,០ |
| ១៧.១១ | ចំនួនអក្ខរជនសរុបអាយុ ១៥-២៤ឆ្នាំ | % | ៨៧,៥ | ៨៨,០ | ៨៩,០ | ៩០,០ | ៩១,០ | ៩២,០ |
| | | | | | | | | |
| **១៨.០០** | **កម្មវិធីសម្អាតមីន** | | | | | | | |
| ១៨.០១ | ជនរងគ្រោះដោយសារ មីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ប្រចាំឆ្នាំ (ស្លាប់និងរបួស) | នាក់ | ២៧១ | ២៤៣ | ២១២ | ១៩១ | ១៧២ | ១៥៥ |
| ១៨.០២ | សរុបផ្ទៃដីដែលបានបោសសម្អាត មីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម | ហត | ៤៧ ៦៥០ | ៥២ ៩១៨ | ៥៨ ២៩២ | ៦៣ ៧៧២ | ៦៩ ៣៦៣ | ៧៥ ០៦៥ |
| | | | | | | | | |

# មាតិកា


អារម្ភកថា ..... i

សញ្ញាជាតិ និង ទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ..... v

គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ..... vi

សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ ..... vii

មាតិកា ..... xii

បញ្ជី តារាង ប្រអប់ និង ឧបសម្ព័ន្ធ ..... xvi

១. ជំពូកទី១ : សេចក្ដីផ្ដើម ..... ១

២. ជំពូកទី២ : សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (ផយអជ ២០០៦-២០១០) ..... ៩

១. អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ ..... ២០

១.១ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ..... ២១

១.២ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ..... ២៤

១.៣ កំណែទម្រង់រដ្ឋបាលសាធារណៈ ..... ២៧

១.៤ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ..... ៣២

២. បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ..... ៣៤

២.១ សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្ដាប់ធ្នាប់សង្គម ..... ៣៤

២.២ សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក ..... ៣៨

២.៣ បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ ..... ៣៩

២.៤ ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ ..... ៤៩

៣. ការលើកស្ទួយវិស័យកសិកម្ម ..... ៥៣

៣.១ ការលើកកម្ពស់ផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម ..... ៥៣

៣.២ កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន ..... ៥៨

៣.៣ កំណែទម្រង់ជលផល ..... ៦៤

៣.៤ កំណែទម្រង់ព្រៃឈើ ........ ៦៥

**៤. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** ........ ៧៣

៤.១ ការបន្តស្តារនិងកសាង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ........ ៧៤

៤.២ ការគ្រប់គ្រង ធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ ........ ៨៣

៤.៣ ការអភិវឌ្ឍ វិស័យថាមពលនិងបណ្តាញអគ្គិសនី ........ ៨៧

៤.៤ ការអភិវឌ្ឍ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ........ ៨៩

**៥. ការអភិវឌ្ឍវិស័យឯកជននិងការងារ** ........ ៩០

៥.១ ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ ........ ៩១

៥.២ ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិត ........ ៩៩

៥.៣ ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម ........ ១០១

៥.៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម ........ ១០២

**៦. ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស** ........ ១០៥

៦.១ ការពង្រឹងគុណភាពវិស័យអប់រំ ........ ១០៥

៦.២ ការលើកកម្ពស់សេវាសុខាភិបាល ........ ១១២

៦.៣ ការអនុវត្តគោលនយោបាយយេនឌ័រ ........ ១៣០

៦.៤ ការអនុវត្តគោលនយោបាយប្រជាជន ........ ១៣៥

**៣. ជំពូកទី៣ : ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ........ ១៣៨

**១. ស្ថានភាពសេដ្ឋកិច្ច នាពេលចាប់ផ្តើម ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ........ ១៣៨

**២. ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០០៩-២០១៣** ........ ១៤៥

**៣. ទស្សនវិស័យសេដ្ឋកិច្ច ឆ្នាំ២០០៩-២០១៣** ........ ១៥៦

**៤. ការវិនិយោគមូលធនដែលចាំបាច់ ដើម្បីសម្រេចបាននូវកំណើន ផសស ដែលបានគ្រោងទុក** ........ ១៦០

**៥. ចំណូលនិងចំណាយថវិកា : ឆ្នាំ២០០៩-២០១៣** ........ ១៦៣

**៤. ជំពូកទី៤ : គោលនយោបាយ និង សកម្មភាព អាទិភាព : ២០០៩-២០១៣** ........ ១៦៧

**១. អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ** ........ ១៧៥

១.១ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ..... ១៧៥
១.២ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ..... ១៧៩
១.៣ កំណែទម្រង់រដ្ឋបាលសាធារណៈ ..... ១៨២
១.៤ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ..... ១៨៥
**២. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ** ..... ១៨៦
២.១ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ..... ១៨៧
២.២ សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក ..... ១៩១
២.៣ បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ ..... ១៩៣
២.៤ ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ ..... ១៩៥
**៣. ការលើកស្ទួយវិស័យកសិកម្ម** ..... ២០៣
៣.១ ការលើកកម្ពស់ផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម ..... ២០៤
៣.២ កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន ..... ២០៩
៣.៣ កំណែទម្រង់ជលផល ..... ២១៦
៣.៤ កំណែទម្រង់ព្រៃឈើ ..... ២១៩
**៤. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** ..... ២៣០
៤.១ ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ..... ២៣០
៤.២ ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ ..... ២៣៩
៤.៣ ការអភិវឌ្ឍវិស័យថាមពល ..... ២៤៧
៤.៤ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ..... ២៥២
**៥. ការអភិវឌ្ឍវិស័យឯកជននិងការងារ** ..... ២៥៦
៥.១ ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ ..... ២៥៦
៥.២ ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរ ..... ២៦១
៥.៣ ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម ..... ២៦៥
៥.៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម ..... ២៦៩

៦. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស ..... ២៧៦

៦.១ ការពង្រឹងគុណភាពវិស័យអប់រំ ..... ២៧៦

៦.២ ការលើកកម្ពស់សេវាសុខាភិបាល ..... ២៨៥

៦.៣ ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ..... ២៩៣

៦.៤ ការអនុវត្តគោលនយោបាយជាតិប្រជាជន ..... ៣០១

៥. ជំពូកទី៥ : តម្លៃដែលត្រូវចំណាយ ធនធាន និង ការកំណត់កម្មវិធីចំណាយ ..... ៣០៤

៥.១ តម្រូវការធនធានសម្រាប់វិនិយោគសាធារណៈ ..... ៣០៤

៥.២ ប្រភពធនធានដែលអាចមាន សម្រាប់ហិរញ្ញប្បទានចំណាយវិនិយោគសាធារណៈ ..... ៣០៩

៥.៣ ការកំណត់ចំណាយ : ចំណាយវិនិយោគសាធារណៈ និង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ..... ៣១១

៦. ជំពូកទី៦ : ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និង សូចនាករ-ចំណុចដៅសំខាន់ៗ ៣១៦

៧. ជំពូកទី៧ : សេចក្ដីសន្និដ្ឋាន ..... ៣២៣

# បញ្ជី តារាង ប្រអប់ និង ឧបសម្ព័ន្ធ

## បញ្ជីតារាង


តារាងទី១ : សូចនាករម៉ាក្រូសេដ្ឋកិច្ច ២០០៣-២០០៨ ... ៤០

តារាងទី២ : វឌ្ឍនភាពក្នុងការងារអភិវឌ្ឍន៍ជនបទ... ៧២

តារាងទី៣ : ការអភិវឌ្ឍក្នុងវិស័យអប់រំ ២០០៥/០៦-២០០៨/០៩ ... ១០៧

តារាងទី៤ : សូចនាករសំខាន់ៗ នៃកម្មវិធីសុខភាពបន្តពូជ មាតា-ទារក និងកុមារ ... ១១៤

តារាងទី៥ : សូចនាករសំខាន់ៗ នៃកម្មវិធីជំងឺឆ្លង ... ១២២

តារាងទី៦ : ការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័ វិស័យសុខាភិបាល ... ១២៥

តារាងទី៧ : សូចនាករស្នូលសម្រាប់ហិរញ្ញប្បទានវិស័យសុខាភិបាល( គិតត្រឹមខែឆ្នូ ២០០៨) ... ១២៥

តារាងទី៨ : សូចនាករម៉ាក្រូសេដ្ឋកិច្ច ១៩៩៤ ១៩៩៩ ២០០១-២០០៨ ... ១៤១

តារាងទី៩ : ការព្យាករណ៍សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ : ២០០៩-២០១៣ ... ១៥៧

តារាងទី១០ : ផលិតផលក្នុងស្រុកសរុបពិត ( ថ្លៃថេរឆ្នាំ២០០០) អត្រាកំណើននៃសកម្មភាពសេដ្ឋកិច្ចឆ្នាំ : ២០០៨-២០១៣ ... ១៥៩

តារាងទី១១ : ការវិនិយោគចាំបាច់ ដើម្បីសម្រេចបានកំណើនផលិតផលសរុបក្នុងស្រុកដែលបានគ្រោងទុក និង ធនធានដែលអាចមាន សម្រាប់ធ្វើហិរញ្ញប្រទានដល់ការវិនិយោគចាំបាច់ ឆ្នាំ ២០០៩-២០១៣ ... ១៦១

តារាងទី១២ : វិនិយោគមូលធន ដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន*ផសស* .. ១៦២

តារាងទី១៣ : ចំណាយមូលធន និងចំណាយចរន្ត : ២០០៨-២០១៣ ... ១៦៤

តារាងទី១៤ : ចំណាយថវិកាចរន្ត ដែលបានស្នើឡើង សម្រាប់ក្រសួង-ស្ថាប័ននីមួយៗ ២០០៨-២០១៣ ... ១៦៥

តារាងទី១៥ : សូចនាករសំខាន់ៗរបស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ... ២០៩

តារាងទី១៦ : សូចនាករសំខាន់ៗ របស់ *ក្រសួងអភិវឌ្ឍន៍ជនបទ*... ២២៩

តារាងទី១៧ : សូចនាករសំខាន់ៗ នៃ *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* ... ២៥១

តារាងទី១៨ : ចំណុចដៅសម្រាប់ពង្រីកវិស័យទូរគមនាគមន៍ ... ២៥៤

តារាងទី១៩ : សូចនាកររបស់ *ក្រសួងព័ត៌មាន* ... ២៥៥

តារាងទី២០ : សូចនាករសំខាន់ៗ នៃវិស័យពាណិជ្ជកម្ម ... ២៥៨

តារាងទី២១ : សូចនាករ និងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និង កីឡា ... ២៨៤

តារាងទី២២ : សូចនាករសំខាន់ៗ ( ធាតុចេញ និង លទ្ធផល) និងចំណុចដៅរបស់វិស័យសុខាភិបាល ... ២៩២

តារាងទី២៣ : សូចនាករនិងចំណុចដៅយេនឌ័រ ... ៣០០

តារាងទី២៤ : វិនិយោគមូលធនចាំបាច់ ដើម្បីសម្រេចបាននូវចំណុចដៅកំណើនសេដ្ឋកិច្ច និង ប្រភពធនធានដែលអាចមាន សម្រាប់ការធ្វើហិរញ្ញប្បទាន វិនិយោគសាធារណៈ សម្រាប់ឆ្នាំ ២០០៩-២០១៣ .................... ៣០៦

តារាងទី២៥ : ចំណុចដៅនៃការកៀរគរធនធាន សម្រាប់ការវិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០០៩-២០១៣ .. ៣០៨

តារាងទី២៦ : វិភាជន៍របស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* តាមវិស័យ ............................................ ៣១៤

តារាងទី២៧ : គោលដៅជាតិ និង សូចនាករសំខាន់ៗរបស់ *ផយអជ ២០០៦-២០១០* (ចំណុចដៅ) .................... ៣២០

**ប្រអប់**

ប្រអប់ទី១ : សមិទ្ធផលសំខាន់ៗ និង បញ្ហាប្រឈម ក្នុងការកាត់បន្ថយភាពក្រីក្រ ...................................... ១៣

ប្រអប់ទី២ : ការតម្រឹមតម្រង់ ការប្រើប្រាស់ និង គណនេយ្យភាព នូវធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស . ៥២

ប្រអប់ទី៣ : អាទិភាពខ្ពស់បំផុតរបស់ *រាជរដ្ឋាភិបាលកម្ពុជា* គឺបន្តកាត់បន្ថយភាពក្រីក្រ និង អាទិភាពដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចសកលលោក .................... ១៦៩

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ : ពាក្យបំព្រួញ ............................................................................................................ ៣២៥

ឧបសម្ព័ន្ធទី២ : គេហទំព័ររបស់ *ក្រសួង និង ស្ថាប័ន* របស់ *រាជរដ្ឋាភិបាលកម្ពុជា* ............................................ ៣២៦

# ជំពូកទី១

# សេចក្តីផ្តើម

១. *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងដំណើរការប្រកបដោយជោគជ័យ តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការស្តារប្រទេសឡើងវិញ ឱ្យងើបផុតពីស្ថានភាពមួយ នៃវិនាសកម្មស្ទើរតែទាំងស្រុង ដែលបានកើតមានមកលើធនធានទាំងអស់របស់ប្រជាជាតិទាំងមូល រួមមាន ធនធានមនុស្ស ស្ថាប័នសេដ្ឋកិច្ច ស្ថាប័នអប់រំ និងស្ថាប័នសង្គមកិច្ច ព្រមទាំង ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ។ នៅលើមូលដ្ឋាននៃការផ្សះផ្សាជាតិ នៅក្នុងចំណោមភាគីជម្លោះទាំងឡាយ នា *សន្និសីទសន្តិភាពទីក្រុងប៉ារីស* ក្នុងខែតុលា ឆ្នាំ១៩៩១ *ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី១* ត្រូវបានរៀបចំឡើង ក្នុងឆ្នាំ១៩៩៣ ដែលបាននាំទៅដល់ ការអនុម័ត រដ្ឋធម្មនុញ្ញថ្មី និង ការបង្កើតឡើងនូវ *រាជរដ្ឋាភិបាលកម្ពុជា* ។ ចាប់តាំងពីពេលនោះមក អាទិភាពចម្បងបំផុតរបស់ *រាជរដ្ឋាភិបាល* គឺត្រូវខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការជំរុញឱ្យមានវឌ្ឍនភាពសង្គម-សេដ្ឋកិច្ចយ៉ាងឆាប់រហ័ស សំដៅ រំដោះប្រជាជនក្រខ្សត់ឱ្យរួចផុតពីភាពក្រីក្រ និង ដឹកនាំប្រជាជាតិទាំងមូល ឱ្យស្ថិតលើមាគ៌ាមួយនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

២. ការបង្កើតឡើងនូវ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងឆ្នាំ១៩៩៣ បាននាំទៅដល់ ការបញ្ចប់នូវការហ៊ុំព័ទ្ធសេដ្ឋកិច្ច ដែលបានដាក់មកលើ *កម្ពុជា* នៅក្នុងឆ្នាំ១៩៧៩ ហើយបានធ្វើឱ្យមានការហូរចូលនូវ *ការវិនិយោគផ្ទាល់ពីបរទេស* និង *ជំនួយអភិវឌ្ឍន៍ផ្លូវការ* សម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ ។ ដើម្បីចាប់ផ្តើមដំណើរការស្តារនិងកសាងឡើងវិញនូវ ហេដ្ឋារចនាសម្ព័ន្ធសង្គម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន *រាជរដ្ឋាភិបាល* បានលើកឡើងនូវ ចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន សម្រាប់ពេលអនាគត នៅក្នុង *កម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* ដែលត្រូវបានអនុម័ត ក្នុងឆ្នាំ១៩៩៤ ។ ដោយផ្អែកលើចក្ខុវិស័យនេះ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី១* ត្រូវបានរៀបចំឡើង ដោយកំណត់នូវគោលដៅច្បាស់លាស់ ដែលត្រូវធ្វើឱ្យសម្រេចបាន នាឆ្នាំ២000 ។ ផែនការនេះ ផ្តោតលើ កំណើនម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ក្នុងពេលជាមួយគ្នានោះដែរ *កម្មវិធីវិនិយោគសាធារណៈ រំកិលពាឆ្នាំ* ( *កវស* ) ត្រូវបានរៀបចំបង្កើតឡើង សម្រាប់ដំណាក់កាលឆ្នាំ១៩៩៦-១៩៩៨ ដើម្បីឱ្យ ធនធានក្នុងស្រុក និង ធនធានបានមកពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្រៅប្រទេស អាចត្រូវបានយកទៅប្រើប្រាស់ ទៅតាមវិស័យអាទិភាពនានា ។ ចាប់តាំងពីពេលនោះមក *កវស* ត្រូវបានធ្វើបច្ចុប្បន្នកម្ម ជារៀងរាល់ឆ្នាំ ។ នៅក្នុងចន្លោះឆ្នាំ១៩៩៣-១៩៩៨ *កម្ពុជា* បានស្ថិតនៅក្នុងស្ថានភាពមួយ ដែលមានសន្តិភាពផង និង សង្គ្រាមផង ។

៣. បន្ទាប់ពី *ការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រ លើកទី២* ក្នុងឆ្នាំ១៩៩៨ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី២នៃរដ្ឋសភា* បានចូលកាន់តំណែង ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ "**នយោបាយឈ្នះ-ឈ្នះ**" របស់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** បាននាំទៅដល់ការរំលាយចោលនូវអង្គការ ចាត់តាំងនយោបាយនិងយោធា របស់*ខ្មែរក្រហម* និង ការធ្វើសមាហរណកម្ម*កងកម្លាំងខ្មែរក្រហម* ចូលមកក្នុងសង្គមជាតិ ក្នុងឆ្នាំ១៩៩៩ ។ *រាជរដ្ឋាភិបាល* សម្រេចបាននូវសមិទ្ធផលជាច្រើន តាមរយៈ ការអនុវត្ត *យុទ្ធសាស្ត្រត្រីកោណ* ដែលត្រូវបានស្នើឡើងដោយ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** ។ *យុទ្ធសាស្ត្រត្រីកោណ* បានផ្តោតលើ *(១) ការធានាឱ្យមាន សន្តិភាព ស្ថិរភាព និង សន្តិសុខ (២) ការធ្វើសមាហរណកម្មកម្ពុជានៅក្នុងតំបន់ និងការធ្វើឱ្យមានទំនាក់ទំនងឡើងវិញជាមួយនឹងសហគមន៍អន្តរជាតិ* និង *(៣) ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច* ។ ជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះ បានប្រែក្លាយ*កម្ពុជា* ពីប្រទេសមួយ ដែលធ្លាប់មាន អស្ថិរភាព សង្គ្រាម ជម្លោះផ្ទៃក្នុង និងភាពអន់ថយ ឱ្យក្លាយទៅជា ចំណុចកណ្តាលមួយនៃ សន្តិភាពដ៏រឹងមាំ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ការគោរពលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិនិងភាពថ្លៃថ្នូររបស់មនុស្ស កិច្ចសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍន៍ដោយមានការចូលរួម ។ ទើបតែចាប់តាំងពី ឆ្នាំ១៩៩៩ មកប៉ុណ្ណោះ ដែលប្រជាជនកម្ពុជាបានទទួលយ៉ាងពេញលេញនូវបរិយាកាសមួយ ដែលមាន សន្តិភាព ស្ថិរភាពនយោបាយ ច្បាប់និងសណ្តាប់ធ្នាប់ លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និង ស្ថិរភាពសេដ្ឋកិច្ច ។ ស្ថិរភាពនយោបាយបច្ចុប្បន្ន ត្រូវបានធានានិងពង្រឹង តាមរយៈ កិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីយកចិត្តទុកដាក់របស់*រាជរដ្ឋាភិបាល* បន្ទាប់ពីបានឆ្លងកាត់នូវវិបត្តិជាច្រើន ដែលបានកើតមានឡើងអស់ជាច្រើន ទសវត្សរ៍កន្លងមក ។ ស្ថានភាពថ្មីនេះ បានធ្វើឱ្យ *រាជរដ្ឋាភិបាលកម្ពុជា* អាចបោះជំហានទៅមុខ នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់ខ្លួនលើគ្រប់វិស័យ ដើម្បីកសាងឡើងវិញនូវ សមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច និង បង្កើតឡើងនូវបរិយាកាសអំណោយផលមួយ សំដៅទាក់ទាញការវិនិយោគ ពីប្រភពក្នុងនិងក្រៅប្រទេស ក្នុងទិសដៅធ្វើឱ្យសម្រេចបាននូវ កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ។

៤. នាចុងដំណាក់កាលនៃ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច លើកទី១ ១៩៩៦-២០០០ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច លើកទី២ ២០០១-២០០៥* ត្រូវបានរៀបចំឡើង ដោយផ្តោតលើ កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ បញ្ហាប្រឈមចម្បងបំផុត សម្រាប់*រាជរដ្ឋាភិបាល* គឺការអភិវឌ្ឍវិស័យឯកជន ដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដើម្បីសម្រេចបាននូវ ការកាត់បន្ថយភាពក្រីក្រ និង ការលើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិត របស់ប្រជាជនកម្ពុជា ដែលកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស ។ *រាជរដ្ឋាភិបាល* ចាត់ទុកភាពក្រីក្រ ថាជា ការខ្វះខាតនូវធនធានសេដ្ឋកិច្ចដ៏មានតម្លៃ ដែលមិនត្រឹមតែមិនអាចទទួលយកបាន ក្នុងផ្នែកសីលធម៌ ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងអាចធ្វើឱ្យមាន ការបែកបាក់ក្នុងសង្គម និង អស្ថិរភាព ។ បន្ទាប់ពីការរៀបចំ *ផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ច លើកទី២* ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍សំខាន់ៗពីរ ត្រូវបានរៀបចំ

បង្កើតឡើង ។ *ទី១* បន្ទាប់ពី *សន្និសីទកំពូលជាប្រវត្តិសាស្ត្រ* របស់ *អង្គការសហប្រជាជាតិ* *ក្នុងឆ្នាំ២០០០* ដែលបានប្រកាសចេញនូវ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* ដែលប្រទេសជាសមាជិកទាំងអស់ ត្រូវសម្រេចឱ្យបាន នៅឆ្នាំ២០១៥ ។ *កម្ពុជា* បានរៀបចំនូវ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* ផ្ទាល់របស់ខ្លួន ដែលមានឈ្មោះថា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលផ្តោតលើ ការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍមនុស្ស ។ *ទី២ រាជរដ្ឋាភិបាល* បានរៀបចំនិងអនុម័តលើ *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* នៅខែធ្នូ ឆ្នាំ២០០២ តាមរយៈ ដំណើរការដែលមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ។

៥. បន្ទាប់ពី *ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ លើកទី៣* នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ *រាជរដ្ឋាភិបាល*ថ្មីដែលបានជាប់ឆ្នោត បានផ្សព្វផ្សាយនូវ *យុទ្ធសាស្ត្រចតុកោណ* ដែលជាយុទ្ធសាស្ត្របន្តពី *យុទ្ធសាស្ត្រត្រីកោណ* របស់ *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់ *នីតិកាលទី២ នៃរដ្ឋសភា* ។ យុទ្ធសាស្ត្រនេះ កំណត់នូវរបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនៃ*កម្មវិធីនយោបាយ* របស់ *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់ *នីតិកាលទី៣ នៃរដ្ឋសភា* (២០០៣-២០០៨)។ *យុទ្ធសាស្ត្រចតុកោណ* វិភាគផ្សំបញ្ចូលគ្នានូវសមាសធាតុសំខាន់ៗរបស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច លើកទី២ ២០០១-២០០៥* *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* រួមទាំង *គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទម្រង់* សំខាន់ៗជាច្រើនផ្សេងទៀត ដែលត្រូវបានរៀបចំឡើង តាមរយៈ ការពិគ្រោះយោបល់ដ៏ទូលំទូលាយ ជាមួយអ្នកមានចំណែកពាក់ព័ន្ធ ជាតិនិងអន្តរជាតិ ។ ទិសដៅចម្បងរបស់ *យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* គឺសំដៅជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារដល់ពលករកម្ពុជា ធានាឱ្យមានសមធម៌និងយុត្តិធម៌សង្គម ព្រមទាំង ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពរបស់*វិស័យសាធារណៈ* តាមរយៈ ការអនុវត្ត *ផែនការសកម្មភាពអភិបាលកិច្ច* និង*កំណែទម្រង់នានា* ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា និង មានសង្គតិភាពនៅ គ្រប់កម្រិត និង គ្រប់វិស័យ ។

៦. *ផែនការអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ លើកទី៣* សម្រាប់ដំណាក់កាលឆ្នាំ *២០០៦-២០១០* ត្រូវបានរៀបចំឡើងជាឯកសារ *គោលនយោបាយជាតិ* តែមួយគត់ ដែលគ្របដណ្តប់លើគ្រប់វិស័យ សម្រាប់ធ្វើជា ឯកសារយោងនិងតម្រង់ទិស ដល់ការធ្វើឱ្យសម្រេចបាននូវ គោលដៅ ចំណុចដៅ និងសកម្មភាព ទាំងឡាយ សម្រាប់រយៈពេលប្រាំឆ្នាំ ខាងមុខ ។ *ផែនការប្រាំឆ្នាំ* ថ្មីនេះ មានឈ្មោះថា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* (*ផយអជ ២០០៦-២០១០*) ត្រូវបានរៀបចំឡើង ទៅតាមទម្រង់របស់ *យុទ្ធសាស្ត្រចតុកោណ* ។ *រាជរដ្ឋាភិបាល* បានប្រកាន់យកនូវ ភាពជាម្ចាស់និងភាពជាអ្នកដឹកនាំយ៉ាងពេញលេញ នៅក្នុងដំណើរការរៀបចំ *ផយអជ ២០០៦-២០១០* ដោយធានាឱ្យមាន ការចូលរួមនិងការពិគ្រោះយោបល់ ជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ។

៧. ដោយប្រកាន់ខ្ជាប់នូវជំហរឥតងាករេ ក្នុងការអនុវត្ត*យុទ្ធសាស្ត្រចតុកោណ* *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់ *នីតិកាលទី៣* នៃ*រដ្ឋសភា* បានបង្កឱ្យមានបរិយាកាសអំណោយផល និងលក្ខខណ្ឌចាំបាច់នានា ដែលអាចធ្វើឱ្យ

*កម្ពុជា* បោះជំហានឆ្ពោះទៅមុខ ដោយមានក្តីសង្ឃឹមនិងភាពជឿជាក់ច្រើនជាងមុន នៅលើមាគ៌ានៃការបន្តធ្វើកំណែទម្រង់និងការអភិវឌ្ឍ ។ *រាជរដ្ឋាភិបាល* បានប្រកាន់ខ្ជាប់នូវគោលការណ៍សាមគ្គីភាពជាតិ ដើម្បីរួបរួមពួតដៃគ្នារវាងប្រជាជនកម្ពុជាទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស ពីគ្រប់មជ្ឈដ្ឋាននិងនិន្នាការនយោបាយ ក្រោមបាវចនា **"ជាតិ សាសនា ព្រះមហាក្សត្រ"** សំដៅកសាងនិងការពារជាតិ និង សមិទ្ធផលសង្គម ព្រមជាមួយគ្នា នឹងការធានាឱ្យមាន ឯករាជភាពជាតិ បូរណភាពទឹកដី អធិបតីភាពជាតិ សន្តិភាព លទ្ធិប្រជាធិបតេយ្យ និង វឌ្ឍនភាព ។

៨. បន្ទាប់ពី*ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ* ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ *រាជរដ្ឋាភិបាលកម្ពុជា* បានប្រកាសចេញនូវ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនៃ*កម្មវិធីនយោបាយ* របស់ខ្លួន សម្រាប់ *នីតិកាលទី៤* នៃ*រដ្ឋសភា* (២០០៨-២០១៣) ។ *កម្មវិធីគោលនយោបាយ* នេះ ត្រូវបានផ្សព្វផ្សាយ ដោយ*គណបក្សប្រជាជន* ដល់ប្រជាជនទាំងអស់ សម្រាប់ការពិចារណារបស់ពួកគេ នៅមុនពេលបោះឆ្នោត ។ ប្រជាជនកម្ពុជា ភាគច្រើនលើសលប់ពីគ្រប់មជ្ឈដ្ឋាន បានបង្ហាញការគាំទ្រជាថ្មីម្តងទៀតចំពោះ*គណបក្សប្រជាជន* នៅក្នុងការដឹកនាំប្រទេសជាតិ សំដៅឆ្ពោះទៅរកការអភិវឌ្ឍ និង ការធ្វើកំណែទម្រង់នានា នៅក្នុងគ្រប់វិស័យ ។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា* បានប្រកាសនូវយុទ្ធសាស្ត្រនេះ នៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ *គណៈរដ្ឋមន្ត្រី* នៃ*រាជរដ្ឋាភិបាល* ថ្មី ហើយ បានគូសបញ្ជាក់ថា *កម្មវិធីនយោបាយ* របស់ *រាជរដ្ឋាភិបាល* សម្រាប់ *នីតិកាលទី៤ នៃរដ្ឋសភា* ត្រូវបានតាក់តែងឡើងនិងអនុម័ត ដោយផ្អែក លើការវាយតម្លៃលទ្ធផលការងារ ដែលត្រូវបានអនុវត្តនៅក្នុង*នីតិកាលទី៣* លើឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជន លើបរិការណ៍ជាតិនិងអន្តរជាតិ ព្រមទាំង លើអាទិភាពវិនិយោគកម្មអាទិភាពទាំងឡាយ សម្រាប់វិស័យគន្លឹះនានា ។ នៅក្នុងឱកាសនោះ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ត្រូវបានបង្ហាញឱ្យឃើញថា ជាឯកសារមួយដែលត្រូវបានរៀបចំឡើងដោយ ការធ្វើបច្ចុប្បន្នកម្ម ការសម្រិតសម្រាំង និង ការសម្រួចបន្ថែម នូវគោលនយោបាយទាំងឡាយដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ* ដំណាក់កាលទី១ សំដៅរំលេចឱ្យ ចេញជា កញ្ចប់អាទិភាពនៅតាមបណ្តាវិស័យគន្លឹះ ដែលមានលក្ខណៈ ជាប្រព័ន្ធ ស៊ីចង្វាក់ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក ។ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* លើកឡើងជាលម្អិតនូវគោល-នយោបាយជាអាទិភាព សម្រាប់ការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់*រាជរដ្ឋាភិបាលកម្ពុជា* សំដៅលើកកម្ពស់សមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច និង បង្កើតបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគពីប្រភពក្នុងនិងក្រៅប្រទេស ក្នុងទិសដៅ បង្កើតកាលានុវត្តភាពការងារសម្រាប់ប្រជាជនកម្ពុជា កាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍវិស័យសំខាន់ៗរបស់សេដ្ឋកិច្ចជាតិ ។ ទន្ទឹមនឹងនេះ **សម្តេចនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា *"រាជរដ្ឋាភិបាល ក៏ទទួលស្គាល់នូវភាពចាំបាច់ នៃការធានាសង្គតិភាពនៃ ឋានានុក្រម តួនាទី ខ្លឹមសារ និង លំដាប់លំដោយនៃការអនុវត្តរវាង* ***យុទ្ធសាស្ត្រចតុកោណ*** *ជាមួយនឹង* ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** *ក៏ដូចជា*

មួយនឹង **យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ** ព្រមទាំងជាមួយនឹងឯកសារ ដែលមានលក្ខណៈជា ផែនការ គោលនយោបាយ និង កម្មវិធីវិនិយោគ និង ថវិកាជាតិ ។ ប្រការនេះ តម្រូវឱ្យរាជរដ្ឋាភិបាល ពិនិត្យឡើងវិញនូវសង្គតិភាពនៃអាណត្តិកាលរបស់ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាមួយនឹង **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល** ដែលមាន **យុទ្ធសាស្ត្រចតុកោណ** *ជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច*" [១] ។ ដើម្បីធានាសង្គតិភាពនៃឋានុក្រមនេះ **សម្តេចនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា *"យុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្តតាមរយៈ* **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**" [២] ។ **សម្តេចនាយករដ្ឋមន្ត្រី** បានវាយតម្លៃជារួមថា ការអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយអាទិភាពទាំងនេះ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ពីសំណាក់ក្រសួង-ស្ថាប័ននានា របស់ *រាជរដ្ឋាភិបាលកម្ពុជា* នៅក្នុងអាណត្តិរបស់ខ្លួន សម្រាប់នីតិកាលទី៤ នៃ រដ្ឋសភា (២០០៨ ដល់ ២០១៣) ។

៩. វិបត្តិហិរញ្ញវត្ថុពិភពលោក និង ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលកំពុងបន្តកើតមាន និង ដែលបានបង្កកលិយុគ នៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក បានបណ្តាលឱ្យមានការធ្លាក់ចុះនូវតម្រូវការ លើការនាំចេញទំនិញរបស់*កម្ពុជា* ហើយ បានបង្កើនហានិភ័យផ្នែកហិរញ្ញវត្ថុ និង ម៉ាក្រូសេដ្ឋកិច្ច ។ កត្តាក្រៅប្រទេសទាំងនេះ បាននាំមកដល់*កម្ពុជា* នូវបញ្ហាប្រឈមថ្មីៗ ដែលមិនបានរំពឹងទុកជាមុន ។ *រាជរដ្ឋាភិបាល* បាននិងកំពុងរៀបចំជាប្រព័ន្ធ និង ជាលំដាប់លំដោយ នូវវិធានការជាច្រើន ដើម្បីបន្ធូរបន្ថយឥទ្ធិពលអវិជ្ជមាននៃ វិបត្តិហិរញ្ញវត្ថុអន្តរជាតិ និងដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក មកលើប្រព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់*កម្ពុជា* ព្រមទាំង ដើម្បីការពារនូវសមិទ្ធផលដែលយើងសម្រេចបានដោយលំបាក កន្លងមក ។ ការប្រែប្រួលនៃស្ថានភាពក្រៅប្រទេសទាំងនេះ គឺជាហេតុផលដ៏ចាំបាច់មួយ ដែលតម្រូវឱ្យគ្រប់ក្រសួង-ស្ថាប័ន ពិនិត្យមើលឡើងវិញនូវផែនការនានារបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* សម្រាប់*នីតិកាលទី៤ នៃ រដ្ឋសភា* ។ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវរៀបចំឡើង ដើម្បីសម្រេចគោលដៅចម្បងពីរ ។ *គោលដៅទី១* គឺ ដើម្បីបន្សុីអាណត្តិកាលរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ជាមួយអាណត្តិរបស់ *រាជរដ្ឋាភិបាល* សម្រាប់ *នីតិកាលទី៤ នៃរដ្ឋសភា* សំដៅធានាថា សកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដែលត្រូវបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ។ *គោលដៅទី២* គឺ ដើម្បីធានាថា ការងារដែលត្រូវលើកឡើង ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះ ត្រូវបានរៀបចំដោយមានការគិតគូរដល់ ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលអាចមានមកលើសេដ្ឋកិច្ចកម្ពុជា ។

---

[១] *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* - កឋាខណ្ឌទី១៥ - ទំព័រទី១៧

[២] *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* - កឋាខណ្ឌទី១១១ - ទំព័រទី៧១

១០. ដើម្បីរៀបចំ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* វិធីសាស្ត្រនៃការធ្វើផែនការ ត្រូវបានកែលម្អបន្ថែមទៀត ។ ដូចបានគូសបញ្ជាក់ពីខាងដើមរួចមកហើយ *ផយអជ បច្ចុប្បន្នកម្ម* គឺជា ឧបករណ៍ឬផែនទី ចង្អុលផ្លូវមួយសម្រាប់ការអនុវត្តនូវ បណ្តាគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលបានលើកឡើងនៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ។ វិធីសាស្ត្រនៃការកែលម្អ ផ្តោតលើគោលគំនិតសំខាន់ៗ ដូចខាងក្រោម :

- ការកំណត់ថា (១) **តើក្រសួង-ស្ថាប័នណា** ជាអ្នកទទួលខុសត្រូវ ក្នុងការអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ នៅក្នុងមុំនីមួយៗនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* (២) **តើសកម្មភាពជាក់លាក់អ្វីខ្លះ** ដែលក្រសួង-ស្ថាប័នទទួលខុសត្រូវ បានគ្រោងឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ និង (៣) **តើតម្លៃប៉ុន្មាន** ដែលក្រសួង-ស្ថាប័នទទួលខុសត្រូវ ត្រូវប៉ាន់ស្មានឱ្យបានត្រឹមត្រូវបំផុត ដើម្បី អនុវត្តសកម្មភាពទាំងឡាយ ដែលបានគ្រោង សម្រាប់អំឡុងឆ្នាំ២០០៩-២០១៣ ។ ព័ត៌មានដែលប្រមូលបាន តាមរយៈវិធីសាស្ត្រពីក្រោមឡើងលើនៃការធ្វើផែនការនេះ គឺជា សមាសភាគដ៏សំខាន់មួយ នៃព័ត៌មានដែលចាំបាច់សម្រាប់ការផ្សារភ្ជាប់នូវ កិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងការងារផែនការ តម្រូវការក្នុងវិនិយោគសាធារណៈ និងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ នៅក្នុងបរិការណ៍រួមនៃ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច សម្រាប់ដំណាក់កាលរបស់ផែនការ ។ ប៉ុន្តែ ប្រការសំខាន់ ដែលយើងត្រូវកត់សម្គាល់ នោះ គឺថា ព័ត៌មានដែលត្រូវផ្តល់ឱ្យ ដោយក្រសួង-ស្ថាប័នទទួលខុសត្រូវ ត្រូវផ្អែកលើការវិភាគផ្នែកបច្ចេកទេស ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ របស់វិស័យនីមួយៗ ដែលត្រូវរួមបញ្ចូលផងដែរនូវ ការធ្វើអាទិភាវូបនីយកម្ម និង ការកំណត់លំដាប់លំដោយ នៃសកម្មភាពទាំងឡាយដែលត្រូវបានគ្រោងទុក សម្រាប់ការអនុវត្ត ។
- ការលើកឡើងនូវ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ *ផយអជ បច្ចុប្បន្នកម្ម* ដើម្បីរំលេចឡើងនូវវិធីសាស្ត្រពីលើចុះក្រោមនៃការធ្វើផែនការ ដែលត្រូវបានរៀបចំឡើង ដោយផ្អែកលើការវិភាគ តាមរបៀបសេដ្ឋកិច្ចមាត្រ អំពីស្ថានភាពមួយដែលអាចមានសម្រាប់កំណើនសេដ្ឋកិច្ច អំពីតម្រូវការវិនិយោគ "មូលធន" ដើម្បីសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចដែលបានគ្រោងទុក និងអំពីស្ថានភាពចំណូល និងចំណាយថវិកា សម្រាប់ដំណាក់កាលរបស់ផែនការ ។
- ការរៀបចំកម្មវិធី ឬ ការវិភាជ ចំណាយអភិវឌ្ឍន៍សរុប ដោយផ្អែកលើ (១) ព័ត៌មានដែលប្រមូលបាន តាមរយៈវិធីសាស្ត្រពីក្រោមឡើងលើនៃការធ្វើផែនការ ដែលគ្របដណ្តប់លើទិដ្ឋភាពទាំងអស់ នៃតម្រូវការសម្រាប់ការអភិវឌ្ឍ (២) ព័ត៌មានដែលប្រមូលបាន តាមរយៈវិធីសាស្ត្រពីលើចុះក្រោមនៃការធ្វើផែនការ ដែលកំណត់នូវកត្តាជាច្រើន នៃលទ្ធភាពរួមនៃធនធានមកពីប្រភពថវិកាជាតិ និង ព័ត៌មានស្តីពីការវិនិយោគ "មូលធន" ដែលចាំបាច់ សម្រាប់ការធ្វើឱ្យសម្រេចបាននូវចំណុចដៅទាំងឡាយនៃកំណើនសេដ្ឋកិច្ចដែលបានគ្រោងទុក និង (៣) ការប៉ាន់ស្មាននូវបរិមាណសរុបនៃធនធានពីគ្រប់ប្រភពទាំងអស់ ដែលអាចមាន ឬ ដែលចាំបាច់ត្រូវធ្វើការកៀរគរ ដើម្បីសម្រេចបាននូវចំណុចដៅទាំងឡាយ របស់ផែនការ ។

១១. ទន្ទឹមនឹងនេះ ដើម្បីធានាឱ្យការពិភាក្សាពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព ជាមួយ ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល ក្នុងការរៀបចំធាតុចូលដោយក្រសួង-ស្ថាប័ន *ក្រសួងផែនការ* បានអនុវត្តកិច្ចការសំខាន់ពីរ ដែលត្រូវបានធ្វើឡើង ជាពីរជំហាន ។ នៅក្នុងជំហានទី១ *ក្រសួងផែនការ* បានបង្ហាញពីការណែនាំលម្អិត ផ្នែកគោលនយោបាយនិងផ្នែកបច្ចេកទេស អំពីរបៀបរៀបចំធាតុចូលសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម* ដល់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅក្នុងពិធីផ្សព្វផ្សាយ *សារាចររបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដែលត្រូវបានប្រារព្ធធ្វើឡើង កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ដោយមានការចូលរួមពី សំណាក់ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល ជាច្រើន ផ្សេងទៀត។ សេចក្តីណែនាំផ្នែកគោលនយោបាយ ដ៏សំខាន់មួយ ដែលត្រូវបានលើកឡើង នៅក្នុងពិធីផ្សព្វផ្សាយនោះ តម្រូវឱ្យគ្រប់ក្រសួង-ស្ថាប័ន ដែលដឹកនាំ *ក្រុមការងារបច្ចេកទេសចម្រុះរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* គួរតប្បីរៀបចំធាតុចូល ដោយមានការពិគ្រោះយោបល់ជាមួយ ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ។ *រាជរដ្ឋាភិបាលកម្ពុជា* មានជំនឿយ៉ាងមុតមាំថា ការចំណាយពេលវេលា និង កម្លាំងកាយចិត្តរបស់មន្ត្រី *រាជរដ្ឋាភិបាល* និងដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើការពិភាក្សាពិគ្រោះយោបល់ នឹងទទួលបានផ្លែផ្កា ប្រសិនបើកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ ត្រូវបានផ្តោតនៅកម្រិតក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវ ក្នុងការរៀបចំធាតុចូលសម្រាប់ *ផយអជ* ។ នៅក្នុងជំហានទី២ បន្ទាប់ពីពិធីផ្សព្វផ្សាយសារាចរ នាកិច្ចប្រជុំមួយរបស់ *ក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ* ដែលមាន *ក្រសួងផែនការ* ជាប្រធាន អ្នកសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍នៃក្រុមការងារនេះ ត្រូវបានប្រគល់ភារកិច្ចជូន ដើម្បីធ្វើកិច្ចសហការជាមួយ ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់សំដៅធានាថា ដៃគូអភិវឌ្ឍន៍ទាំងនោះ មានការត្រៀមលក្ខណៈ ក្នុងការផ្តល់ ការគាំទ្រផ្នែកបច្ចេកទេសនិងសម្ភារៈ ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំធាតុចូលសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម* តាមរយៈ យន្តការក្រុមការងារបច្ចេកទេស នៅក្នុងករណីដែលមានតម្រូវការ ។ ដោយហេតុថា ក្រសួង-ស្ថាប័នទាំងអស់ ត្រូវប្រកាន់យកនូវភាពជាម្ចាស់យ៉ាងពេញលេញលើធាតុចូលទាំងឡាយរបស់ខ្លួន ដែលត្រូវផ្ញើមកជូន *ក្រសួងផែនការ* ការពិគ្រោះយោបល់ប្រកបដោយផ្លែផ្ការវាង ក្រសួង-ស្ថាប័ននិងដៃគូអភិវឌ្ឍន៍ នៅក្នុងក្របខ័ណ្ឌក្រុមការងារបច្ចេកទេស គួរតែជំរុញឱ្យមានការរៀបចំធ្វើឡើង សំដៅរួមចំណែកលើកកម្ពស់គុណភាពនៃធាតុចូលទាំងឡាយរបស់ក្រសួង-ស្ថាប័ន សម្រាប់ការរៀបចំ *ផយអជ បច្ចុប្បន្នកម្ម* ។

១២. *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* មានប្រាំពីរជំពូក ។ បន្ទាប់ពីសេចក្តីផ្តើម ដែលលើកឡើងនៅក្នុង *ជំពូកទី១* ការបង្ហាញដោយសង្ខេបមួយ អំពីសមិទ្ធផលនិងបញ្ហាប្រឈមធំៗ ដែលបានកើតមានឡើង នៅក្នុងការអនុវត្ត *ផយអជ ២០០៦-២០១០* ត្រូវបានបង្ហាញនៅក្នុង *ជំពូកទី២* ។ *ជំពូកទី៣* បង្ហាញអំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ព្រមទាំង សូចនាករ/ចំណុចដៅ សម្រាប់អាណត្តិកាលរបស់ផែនការនេះ ។ *ជំពូកទី៤* លើកឡើងអំពី គោលនយោបាយនិងសកម្មភាពគន្លឹះរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែល

នឹងត្រូវអនុវត្ត ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយអាទិភាព ដូចបានកំណត់ នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* របស់ *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់ *នីតិកាលទី៤ នៃរដ្ឋសភា* ។ *ជំពូកទី៥* បង្ហាញអំពី តម្លៃដែលត្រូវចំណាយ ធនធាន និង ការកំណត់កម្មវិធីចំណាយ ។ ទិដ្ឋភាពពាក់ព័ន្ធ នឹងការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានបង្ហាញ នៅក្នុង *ជំពូកទី៦* ។ *ជំពូកទី៧* ដែលជាជំពូកចុងក្រោយ បង្ហាញអំពីការ សន្និដ្ឋានរួមមួយ ។

# ជំពូកទី២

# សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ នៅក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០

១៣. ដោយប្រកាន់ខ្ជាប់នូវជំហរតឹងរាករេ ក្នុងការអនុវត្ត*យុទ្ធសាស្ត្រចតុកោណ* *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់ *នីតិកាលទី៣ នៃរដ្ឋសភា* បានបង្កឱ្យមានបរិយាកាសអំណោយផល និងលក្ខខណ្ឌចាំបាច់នានា ដែលអាចធ្វើឱ្យ*កម្ពុជា* បោះជំហានឆ្ពោះទៅមុខ ដោយមានក្ដីសង្ឃឹមនិងភាពជឿជាក់ច្រើនជាងមុន នៅលើមាគ៌ានៃការបន្តធ្វើកំណែទម្រង់ និងការអភិវឌ្ឍ ។

១៤. *កម្ពុជា* បាននិងកំពុងទទួលផ្លែផ្កាពី សន្តិភាព និង ឯកភាពទឹកដីដ៏ពេញលេញ និងបូរណភាពទឹកដី ដែលកើតចេញពី **"នយោបាយឈ្នះ-ឈ្នះ"** របស់ **សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** ដែលសម្ដែងឱ្យឃើញ តាមរយៈ កំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងទសវត្សរ៍កន្លងទៅនេះ ។ កម្ពុជាបានធ្វើសមាហរណកម្មខ្លួន ចូលទៅក្នុងតំបន់និងពិភពលោក ហើយ កំពុងដើរតួនាទីមួយយ៉ាងសកម្ម ក្នុងឋានៈជាសមាជិកស្មើភាពនិងស្មើសិទ្ធិ ក្នុងអង្គការនានា នៅកម្រិត អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ។ ជារួម ទោះបីជាមានបញ្ហាប្រឈមថ្មីៗ ដែលបានលេចចេញ ដោយមិនបានរំពឹងទុកជាមុន ក្នុងរូបភាពជាបច្ច័យអាក្រក់មួយ នៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងកលិយុគនៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក ដែលបណ្ដាលមកពី បរាជ័យនៃប្រព័ន្ធគ្រប់គ្រងទីផ្សារ នៅក្នុងសេដ្ឋកិច្ចរីកចម្រើនមួយចំនួនក៏ដោយ ក៏*រាជរដ្ឋាភិបាលកម្ពុជា* បានពង្រឹងបន្ថែមទៀត នូវសមិទ្ធផលទាំងឡាយរបស់ខ្លួន ដោយបន្តការអនុវត្តប្រកបដោយការប្ដេជ្ញាចិត្តខ្ពស់ នូវ*យុទ្ធសាស្ត្រចតុកោណ* តាមរយៈ *ផយអជ ២០០៦-២០១០* ។ សមិទ្ធផលសំខាន់ៗ ដ៏គួរឱ្យកត់សម្គាល់ រួមមាន :

- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្ដាប់ធ្នាប់សង្គម ត្រូវបានពង្រឹង នៅលើមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទីពីរ ដោយសេរីនិងយុត្តិធម៌ ត្រូវបានរៀបចំឡើង ក្នុងឆ្នាំ២០០៧ ។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី៤ ត្រូវបានរៀបចំឡើង ក្នុងខែកក្កដា ឆ្នាំ២០០៨ ។
- ការគោរពសិទ្ធិនិងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ក្នុងនោះរួមមាន សិទ្ធិខាងផ្នែក នយោបាយ សេដ្ឋកិច្ច និង សង្គមកិច្ច ត្រូវបានលើកកម្ពស់ ហើយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ក្នុងគោលដៅពង្រឹងលទ្ធិប្រជាធិបតេយ្យនិងប្រសិទ្ធភាពនៃសេវាកម្មសាធារណៈ នៅថ្នាក់ក្រោមជាតិ ត្រូវបានចាប់ផ្ដើមអនុវត្ត ។
- អភិបាលកិច្ចល្អ តាមរយៈ កំណែទម្រង់រដ្ឋ ជាពិសេស កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំង កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ត្រូវបានពង្រឹង ដើម្បីធានាថា រាល់កិច្ចដំណើរការ របស់*រាជរដ្ឋាភិបាល* មាន តម្លាភាព គណនេយ្យភាព ភាពអាចដឹងជាមុនបាន ភាពស័ក្ដិសិទ្ធិ និងប្រសិទ្ធភាព ច្រើនជាងមុន ។

- ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងកម្រិតពីរខ្ទង់ដែលមិនធ្លាប់មានពីមុន ត្រូវបានធានាឱ្យ មានព្រមគ្នា នឹងការរក្សា អតិផរណាឱ្យមានកម្រិតទាប និង អត្រាប្តូរប្រាក់ឱ្យមានស្ថិរភាព ។ ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ត្រូវបានពង្រឹង តាមរយៈ ការបង្កើនផលិតភាពកសិកម្ម ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ ការពង្រីកវិស័យឧស្សាហកម្ម ជាពិសេស ដើម្បីពង្រីកបន្ថែមទៀតនូវជវភាពនៃវិស័យឧស្សាហកម្មកាត់ដេរ ។ វិស័យសេវាកម្មទាំងមូល ក៏ត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ផងដែរ ។ ប្រការទាំងអស់នេះ បានបង្កើតឱ្យមាន ការងារនិងការបណ្តុះបណ្តាលមុខជំនាញ ជាច្រើន ដល់យុវជន និងយុវនារី ជាច្រើនសែននាក់ ។
- តាមរយៈ *"កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"* ភាពអាចជឿទុកចិត្តបាននៃថវិកា ត្រូវបានបង្កើន ដូចដែលបានសម្តែងឱ្យឃើញ តាមរយៈ ការបង្កើនចំណូល និង ការធ្វើវិចារណកម្មចំណាយរបស់ *រាជរដ្ឋាភិបាល* ជាពិសេស ការបង្កើនអតិរេកចរន្តនៃថវិកាជាតិ ដែលបានរួមចំណែកក្នុង ការពង្រីកការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមកិច្ច សំដៅការលើកកម្ពស់សេវាកម្មសាធារណៈ និងការកាត់បន្ថយភាពក្រីក្រ ។
- វិស័យឯកជនបានក្លាយទៅជា *"ក្បាលម៉ាស៊ីនពិតប្រាកដនៃកំណើនសេដ្ឋកិច្ច"* ហើយបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ទាំងក្នុង វិស័យសេដ្ឋកិច្ចរូបវន្ត ទាំងក្នុង វិស័យហិរញ្ញវត្ថុ ។
- ការស្តារនិងកសាងបណ្តាញផ្លូវជាតិសំខាន់ៗ ត្រូវបានបញ្ចប់ស្ទើរតែទាំងស្រុង ហើយការលើកកម្ពស់គុណភាពផ្លូវខេត្ត និងផ្លូវលំជនបទ កំពុងត្រូវបានយកចិត្តទុកដាក់អនុវត្ត ។ សេវាកម្មដឹកជញ្ជូនគ្រប់ផ្នែក រួមទាំងសេវាភ្នាក់ងារនាវា ការបញ្ជូនទំនិញ ការដឹកជញ្ជូនពហុរូបភាព ការផ្គត់ផ្គង់ទំនិញនិងព័ស្តុភារកម្ម បានដើរតួនាទីយ៉ាងសកម្ម និងមានប្រសិទ្ធភាព ក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ។ ហេដ្ឋារចនាសម្ព័ន្ធ ធារាសាស្ត្រ ថាមពល និង ទូរគមនាគមន៍ បាននិងកំពុងមានការរីកចម្រើន គួរឱ្យកត់សម្គាល់ ។
- សមត្ថភាពស្ថាប័ន និង សមត្ថភាពធនធានមនុស្ស ត្រូវបានពង្រឹង ដោយប្រមូលផ្តុំលើការអភិវឌ្ឍវិស័យអប់រំនិងសុខាភិបាល ។ វិស័យសង្គមកិច្ច បាននិងកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ៖ នៅក្នុងវិស័យអប់រំ អត្រានៃការសិក្សាបានកើនឡើង ហើយអត្រានៃការបោះបង់ចោលការសិក្សា និងអត្រាត្រួតថ្នាក់ បានធ្លាក់ចុះ ចំណែកឯ នៅក្នុងវិស័យសុខាភិបាល អត្រាមរណភាពទារកនិងកុមារ និងអត្រាអ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ ក៏បានធ្លាក់ចុះផងដែរ ។
- ភាពជាដៃគូជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ជាពិសេស ជាមួយដៃគូអភិវឌ្ឍន៍ផ្លូវការ វិស័យឯកជន និងសង្គមស៊ីវិល ត្រូវបានពង្រឹង តាមរយៈ ការដាក់ឱ្យដំណើរការនូវយន្តការនានា ដែលមានប្រសិទ្ធភាពសម្រាប់ ការកៀរគរនិងការសម្របសម្រួល ហិរញ្ញប្បទានសហប្រតិបត្តិការ និង ការវិនិយោគ ។

## ការកាត់បន្ថយភាពក្រីក្រ

១៥. អាទិភាពមួយ ក្នុងចំណោមអាទិភាពខ្ពស់បំផុតរបស់ *រាជរដ្ឋាភិបាល* គឺត្រូវកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតំបន់ជនបទ ។ តាមរយៈ ការអនុវត្តប្រកបដោយជោគជ័យនូវ ផែនការសកម្មភាពរបស់ខ្លួន ដែលមានចែង យ៉ាងច្បាស់នៅក្នុង *ចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០០១-២០១០* ដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម ទៅជា *យុទ្ធសាស្ត្រវិស័យហិរញ្ញវត្ថុ ២០០៦-២០១៥ រាជរដ្ឋាភិបាលកម្ពុជា* មិនត្រឹមតែ ធ្វើឱ្យមានស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ច ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងធ្វើឱ្យមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ នាអំឡុងទសវត្សរ៍ចុងក្រោយនេះ នៅក្នុងអត្រាមធ្យមប្រមាណ ១០ភាគរយ ក្នុងមួយឆ្នាំ ។ សមិទ្ធផលទាំងអស់នេះ បានជួយបង្កលក្ខណៈឱ្យ *រាជរដ្ឋាភិបាលកម្ពុជា* អាចកាត់បន្ថយកម្រិតនៃភាពក្រីក្របាន នៅក្នុងកម្រិតមួយដ៏គួរជាទីមោទនៈ ។ អង្កេត លើកទី១ អំពីអត្រាភាពក្រីក្រនៅ*កម្ពុជា* ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៩៣-១៩៩៤ ។ អង្កេតនេះ មិនបានគ្រប ដណ្តប់ពេញទូទាំងប្រទេសទេ ដោយសារមិនមានលទ្ធភាពចូលទៅដល់តំបន់មួយចំនួន ដោយព្រោះតែមូលហេតុ សន្តិសុខ ។ លទ្ធផលនៃ *អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ឆ្នាំ២០០៧* ដែលត្រូវបានប្រកាសចេញ ក្នុងពេលថ្មីៗ កន្លងទៅនេះ បានបង្ហាញឱ្យឃើញថា អត្រាភាពក្រីក្រ នៅក្នុងតំបន់ដែលត្រូវបានគ្របដណ្តប់ ដោយអង្កេតឆ្នាំ ១៩៩៣-១៩៩៤ ស្មើនឹង ៣៩ភាគរយ ហើយបានធ្លាក់ចុះមកត្រឹម ២៨ភាគរយ ក្នុងឆ្នាំ២០០៤ និង ២៤,៧ភាគរយ ក្នុងឆ្នាំ២០០៧ ។ នៅក្នុងតំបន់ជនបទនៃតំបន់ទាំងនេះ អត្រាភាពក្រីក្រ បានធ្លាក់ចុះពី ៤៣,១ ភាគរយ ក្នុងឆ្នាំ ១៩៩៣-១៩៩៤ មកនៅត្រឹម ៣៣,៧ភាគរយ ក្នុងឆ្នាំ២០០៤ និង ៣០,៦ភាគរយ ក្នុងឆ្នាំ២០០៧ ។

១៦. បច្ចុប្បន្ននេះ ទិន្នន័យដែលគ្របដណ្តប់ទូទាំងប្រទេស គឺអាចមាន សម្រាប់ ឆ្នាំ២០០៤ និង ឆ្នាំ២០០៧ ។ ទិន្នន័យទាំងនេះ បានបង្ហាញថា អត្រាភាពក្រីក្រសម្រាប់ទូទាំងប្រទេស ធៀបនឹងខ្សែបន្ទាត់រួមនៃភាពក្រីក្រ បានធ្លាក់ ចុះពី ៣៤,៧ ភាគរយ នៅឆ្នាំ២០០៤ មកនៅត្រឹម ៣០,១ ភាគរយ នៅឆ្នាំ២០០៧ ដែលជាការថយចុះយ៉ាងច្រើន គឺស្មើនឹង ៤,៦ ភាគរយ គិតចាប់ពី ឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៧ ដោយបង្ហាញឱ្យឃើញពីការថយចុះ ក្នុងកម្រិត ច្រើនជាង ១ ភាគរយ ក្នុងមួយឆ្នាំ ។ ទន្ទឹមនឹងនេះ លទ្ធផល បានបង្ហាញថា អត្រាភាពក្រីក្រ បានថយចុះ នៅថ្នាក់ ក្រោមជាតិ គ្រប់កម្រិត ។ នៅភ្នំពេញ អត្រាភាពក្រីក្រ បានថយចុះពី ៤,៦ភាគរយ នៅក្នុងឆ្នាំ ២០០៤ មកនៅត្រឹម ០,៨ភាគរយ នៅក្នុងឆ្នាំ២០០៧ ។ ចំណែកឯនៅតំបន់ទីប្រជុំជនផ្សេងៗទៀត អត្រាភាពក្រីក្រ បានថយចុះពី ២៥,៨ ភាគរយ មកត្រឹម ២១,៩ ភាគរយ ហើយ បានថយចុះពី ៣៩,១ ភាគរយ មកត្រឹម ៣៤,៧ ភាគរយ នៅ តំបន់ជនបទនានា ។ ការថយចុះនៃភាពក្រីក្រ នៅក្នុងអំឡុងឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៧ បានឆ្លុះបញ្ចាំងឱ្យឃើញ ពីកំណើនដ៏គួរឱ្យកត់សម្គាល់នៃ *ការប្រើប្រាស់ពិតតាមគ្រួសារសម្រាប់មនុស្សម្នាក់ៗ* ដែលត្រូវបានគេប្រើប្រាស់ ជា

ទូទៅ សម្រាប់វាស់វែងស្តង់ដារនៃការរស់នៅ ។ ការកើនឡើងនៃការប្រើប្រាស់ ត្រូវបានគេរកឃើញថាពិតជាបានកើតមាននៅក្នុង ក្រុមបញ្ចភាគដែលក្រីក្របំផុត និង ក្រុមបញ្ចភាគដែលក្រីក្របំផុតបន្ទាប់ ។ ការប្រើប្រាស់គិតតាមថ្លៃថេរ បានកើនឡើងដល់ ១០,៧ ភាគរយ នៅក្នុងក្រុមបញ្ចភាគដែលក្រីក្របំផុត និង ១១,៥ ភាគរយ នៅក្នុងក្រុមបញ្ចភាគដែលក្រីក្របំផុតបន្ទាប់ ។

១៧. ការវិភាគទិន្នន័យពី *អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ និង ឆ្នាំ២០០៧* ក៏បានបង្ហាញផងដែរថា "រូបភាពនៃការធ្វើឱ្យប្រសើរឡើងនៃសុខុមាលភាព ក្នុងក្រុមបញ្ចភាគដែលក្រីក្របំផុត និង ក្រុមបញ្ចភាគដែលក្រីក្របំផុតបន្ទាប់ ត្រូវបានពង្រឹង តាមរយៈការធ្វើឱ្យប្រសើរឡើងនៃកត្តាជាច្រើន ដែលពាក់ព័ន្ធជាមួយនឹងការផ្តល់សេវាកម្ម និង លទ្ធផលនានានៃការអភិវឌ្ឍមនុស្ស ។ សមិទ្ធផលជាច្រើន ត្រូវបានគេសង្កេតឃើញមាននៅក្នុងវិស័យ អប់រំ សុខាភិបាល ផលិតកម្មកសិកម្ម និងអាហារូបត្ថម្ភ ។ លទ្ធភាពទទួលបានជារូបវន្ត នូវសេវាកម្មសាធារណៈផ្សេងៗ ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយគិតជាចម្ងាយមធ្យមទៅកាន់មណ្ឌលសុខភាព ឬ សាលារៀនដែលនៅជិតបំផុត ។ ប្រការទាំងនេះ ដោយរួមផ្សំជាមួយនឹង ការលើកកម្ពស់ទាំងបរិមាណនិងគុណភាពនៃបណ្តាញផ្លូវថ្នល់ និង ការកើនឡើងនៃប្រាក់ចំណូលពិត បង្ហាញឱ្យឃើញពីមូលហេតុនៃការធ្វើឱ្យប្រសើរឡើងនូវអត្រានៃការសិក្សា ឬ ឥរិយាបថ នៃការគិតគូរដល់សុខភាព ។ ជាមួយគ្នានេះ លទ្ធផលការងារជាច្រើន ត្រូវបានបន្តធ្វើឱ្យប្រសើរឡើង ដូចជា កម្រិតមធ្យមនៃការទទួលបានការអប់រំ និង ស្ថានភាពសុខភាពដែលត្រូវបានរាយការណ៍ដោយសាមីខ្លួនផ្ទាល់" ។

១៨. *ផយអជ ២០០៦-២០១០* បានបង្ហាញអំពី សកម្មភាពអាទិភាព និង ការបែងចែកធនធានទាំងឡាយដែលមានលក្ខណៈសរុប ដើម្បីអនុវត្ត *យុទ្ធសាស្ត្រចតុកោណ* ។ ដើម្បីធានានូវប្រសិទ្ធភាព នៃការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ ២០០៦-២០១០ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ* ត្រូវបាន រៀបចំយ៉ាងទៀងទាត់ និង ផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយ*ក្រសួងផែនការ* ។ *របាយការណ៍ពាក់កណ្តាលអាណត្តិ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* ត្រូវបាន រៀបចំឡើង និង ធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយ *ក្រសួងផែនការ* ក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ ។ *របាយការណ៍ពាក់កណ្តាលអាណត្តិ* បានលើកឡើងយ៉ាងច្បាស់នូវផលប៉ះពាល់អវិជ្ជមាន មកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេស មកលើក្រុមជនងាយរងគ្រោះនិងជនក្រីក្រ នៃកលិយុគនៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក ដែលបានចាប់ផ្តើម នាចុងឆ្នាំ២០០៧ ហើយ បានបង្កឱ្យមានដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ។

## ប្រអប់ទី១

## សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ ក្នុងការកាត់បន្ថយភាពក្រីក្រ

**១.** អត្រានៃភាពក្រីក្រនៅក្នុងតំបន់នៃប្រទេស*កម្ពុជា* ដែលត្រូវបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ បានថយចុះពី ៣៩ភាគរយ ក្នុងឆ្នាំ១៩៩៣-១៩៩៤ មកត្រឹម ២៨ភាគរយ ក្នុងឆ្នាំ២០០៤ និង ២៤,៧ភាគរយ នៅឆ្នាំ២០០៧ ។ នៅតំបន់ជនបទ នៃតំបន់ដែលត្រូវបានគ្របដណ្តប់ដោយអង្កេតខាងលើនេះ អត្រានៃភាពក្រីក្របានថយចុះពី ៤៣,១ភាគរយ ក្នុងឆ្នាំ ១៩៩៣-១៩៩៤ មកត្រឹម ៣៣,៧ភាគរយ ក្នុងឆ្នាំ២០០៤ និង ៣០,៦ភាគរយ ក្នុងឆ្នាំ២០០៧ ។

**២.** នៅក្នុងចន្លោះពី ឆ្នាំ២០០៤ដល់២០០៧ អត្រានៃភាពក្រីក្រ នៅក្នុងទូទាំងប្រទេស ធៀបនឹងខ្សែបន្ទាត់នៃភាពក្រីក្រជាតិ បានធ្លាក់ចុះពី ៣៤,៨ភាគរយ ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ៣០,១ភាគរយ ក្នុងឆ្នាំ២០០៧ (មានការថយចុះ ៤,៧ភាគរយ) ដែលបង្ហាញឱ្យឃើញថា ភាពក្រីក្រ បានថយចុះជាមធ្យម ជាង ១ភាគរយក្នុងមួយឆ្នាំ នៅក្នុងអំឡុងពេលនោះ ។ ពិសេសជាងនេះទៅទៀត ភាពក្រីក្របានថយចុះ នៅគ្រប់កម្រិតទាំងអស់ នៃថ្នាក់ក្រោមជាតិ ។

**៣.** នៅក្នុងចន្លោះពី ឆ្នាំ២០០៤ដល់២០០៧ ការប្រើប្រាស់របស់ ក្រុមបញ្ចភាគដែលក្រីក្របំផុត បានកើនឡើង ១០,៧ ភាគរយ ហើយ ក្រុមបញ្ចភាគដែលក្រីក្របំផុតបន្ទាប់ បានកើនឡើង ១១,៥ភាគរយ (ការប្រើប្រាស់របស់ក្រុមជនក្រីក្រទាំងពីរក្រុមនេះ គឺវាស់វែងពីស្តង់ដារនៃជីវភាពរស់នៅ ដែលត្រូវបានប្រើប្រាស់ជាទូទៅ) ។

**៤.** ស្ថានភាពនៃភាពប្រសើរឡើងនៃសុខុមាលភាពរបស់ប្រជាជន ក្នុងចំណោមក្រុមបញ្ចភាគខាងក្រោមបំផុតទាំងពីរ ត្រូវបានជំរុញបន្ថែម តាមរយៈ កត្តាទាំងឡាយដែលពាក់ព័ន្ធនឹង ការលើកកម្ពស់លទ្ធផលនៃការផ្តល់សេវាកម្ម និង ការអភិវឌ្ឍមនុស្ស ។ សមិទ្ធផលជាច្រើន ត្រូវបានកត់សម្គាល់ឃើញមាន នៅក្នុងវិស័យអប់រំ សុខាភិបាល ផលិតកម្មកសិកម្ម និង អាហារូបត្ថម្ភ ។ លទ្ធភាពទទួល បានជារូបវន្តនូវសេវាកម្មសាធារណៈផ្សេងៗ ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយគិតជាចម្ងាយមធ្យមឆ្ពោះទៅកាន់ មណ្ឌលសុខភាព ឬ សាលារៀន ដែលនៅជិតបំផុត និងការលើកកម្ពស់ទាំងបរិមាណនិងគុណភាពនៃបណ្តាញផ្លូវថ្នល់ និង ការកើនឡើងនៃប្រាក់ចំណូលពិត ។

**៥.** ការការពារសមិទ្ធផលដែលសម្រេចបានដោយលំបាក និង ការប្រកាន់យកនូវមាគ៌ាដែលត្រូវធានានូវជោគជ័យនាពេលអនាគត ក្នុងការកាត់បន្ថយភាពក្រីក្រ ឥឡូវនេះ បានបន្ថែមនូវបញ្ហាប្រឈមជាច្រើនថែមទៀត ដោយសារវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក ។ ជាការពិតណាស់ ប្រសិនបើស្ថានភាពបច្ចុប្បន្ន នៅតែបន្តអូសបន្លាយ សម្រាប់រយៈពេលមួយវែង នោះប្រជាជនទាំងឡាយ ដែលទើបនឹងបានរស់នៅក្នុងជីវភាពមួយ ដែលស្ថិតនៅលើខ្សែបន្ទាត់ភាពក្រីក្រនាពេលបច្ចុប្បន្ន អាចនឹងធ្លាក់មក នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រវិញ ។ បច្ចុប្បន្ននេះ *រាជរដ្ឋាភិបាលកម្ពុជា* កំពុងចាត់វិធានការចម្រុះផ្នែកសារពើពន្ធ និង អនុវត្តកម្មវិធីការគាំពារសង្គម និង បណ្តាញសុវត្ថិភាពសង្គម ដើម្បីបង្ការមិនឱ្យស្ថានភាពខាងលើនេះ កើតឡើងបានឡើយ ។

**៦.** ដើម្បីបោះជំហានទៅមុខ *រាជរដ្ឋាភិបាល* នឹងចាត់វិធានការបន្ថែមទៀត ដើម្បីធានា ឱ្យការផ្ទេរសុទ្ធ នូវធនធានក្រៅប្រទេសដ៏មានកម្រិត ដែលមានសម្រាប់ការប្រើប្រាស់ បានទៅដល់ ក្រុមជនងាយរងគ្រោះ និង អ្នកក្រីក្រ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ក្នុងកម្រិតអតិបរមា ។ ឥឡូវនេះ ការងារចាំបាច់បន្ទាន់ដែលត្រូវគិតគូរដល់នោះ គឺត្រូវ ចាប់ផ្តើមអនុវត្តសកម្មភាពជាក់ស្តែងឱ្យបានទូលំទូលាយ នៅកម្រិតមូលដ្ឋាន និង កាត់បន្ថយឱ្យបានច្រើនបំផុតនូវការចំណាយសម្រាប់ ការសិក្សាស្រាវជ្រាវ និង ជំនួយបច្ចេកទេស ទាំងឡាយដែលចិតបុំងអ្វីៗគ្រប់បែបយ៉ាង ក្រោមស្លាកនៃ "ភាពក្រីក្រ" ។ ការសិក្សាស្រាវជ្រាវនិងសិក្ខាសាលានានា ដែលត្រូវចំណាយច្រើន នៅក្នុងសណ្ឋាគារទំនើបៗ ដើម្បីពិភាក្សាពីបញ្ហារបស់អ្នកក្រីក្រ ហាក់ដូចជាមិនមានភាពសមស្របទេ នៅពេលដែល ជាក់ស្តែង ប្រជាជនជាច្រើនលាននាក់ ពុំមានអាហារបរិភោគគ្រប់គ្រាន់ សម្រាប់ការរស់រានមានជីវិត ។ កម្មវិធីថ្មីៗដែលផ្តួចផ្តើមសម្រាប់សកម្មភាពផ្ទាល់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ គឺជាការងារបន្ទាន់ចាំបាច់ ដែលនឹងអាចជួយផងដែរ ដល់ការជំរុញល្បឿននៃ "ការផ្ទេរនូវធនធានសុទ្ធ" ដែលចាំបាច់យ៉ាងខ្លាំង សម្រាប់ប្រជាជនក្រីក្រ ។

**៧.** លទ្ធផល ដ៏គួរឱ្យកត់សម្គាល់ ដែលអាចទទួលបានឆាប់រហ័ស និង ដ៏គួរជាទីពេញចិត្តយ៉ាងខ្លាំង អាចនឹងសម្រេចបាន តាមរយៈ ការផ្តល់សេវាកម្មនានា ទៅដល់កម្រិតមូលដ្ឋាន ហើយ ពុំមានការសិក្សាស្រាវជ្រាវណាមួយដែលត្រូវបានរំពឹងទុកថា អាចនឹងបង្កើតបាននូវលទ្ធផលបែបនេះ បានឡើយ ។

១៩. វិបត្តិហិរញ្ញវត្ថុពិភពលោក ដែលបានកើតឡើងនៅក្នុងទីក្រុងញូយ៉ក ដោយមួយផ្នែក បណ្តាលមកពីបរាជ័យនៃប្រព័ន្ធគ្រប់គ្រងទីផ្សារ របស់សហរដ្ឋអាមេរិក បានបង្កឱ្យកើតមានវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក និងការថយចុះដ៏ធ្ងន់ធ្ងរមួយនៃកំណើនសេដ្ឋកិច្ច នៅក្នុងប្រទេសជឿនលឿន ។ វិបត្តិហិរញ្ញវត្ថុពិភពលោក និងការថយចុះនៃក្នុងកំណើនសេដ្ឋកិច្ច ដែលកំពុងបន្តមាន នៅក្នុងបណ្តាប្រទេសជឿនលឿន បានបណ្តាលឱ្យមានឱនភាពសេដ្ឋកិច្ច ដ៏គួរឱ្យកត់សម្គាល់ នៅក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើន ។ ចាប់តាំងពីចុងឆ្នាំ២០០៧ ទន្ទឹមជាមួយនឹងវិបត្តិហិរញ្ញវត្ថុពិភពលោក ក៏កើតមានភាពប្រែប្រួលយ៉ាងខ្លាំង នៃថ្លៃ ប្រេងឆៅ ម្ហូបអាហារ និង ទំនិញផ្សេងៗទៀត ផងដែរ ។ នៅក្នុងខែមេសា ឆ្នាំ២០០៧ ថ្លៃប្រេងឆៅ ៦៦,៤៧ដុល្លារ ក្នុង១ធុង បានកើនឡើងរហូតដល់កម្រិតខ្ពស់បំផុតគឺ ១៤៧ដុល្លារ ក្នុង១ធុង នៅក្នុងខែកក្កដា ឆ្នាំ២០០៨ ហើយបន្ទាប់មក ថ្លៃប្រេងឆៅ បានធ្លាក់ចុះយ៉ាងខ្លាំង មកនៅត្រឹម ចន្លោះពី ៣០ ទៅ ៤០ ដុល្លារ ក្នុង១ធុង ។ ប៉ុន្តែ ថ្លៃប្រេងឆៅ បានកើនឡើងជាថ្មីម្តងទៀត ដល់ជាង៧០ដុល្លារ ក្នុង១ធុង ហើយត្រូវបានលក់ ក្នុងថ្លៃប្រហែល ៦០ដុល្លារ ក្នុង១ធុង នៅក្នុងខែកក្កដា ឆ្នាំ២០០៩ ។ ចំពោះប្រទេសកម្ពុជា ដែលនាំចូលទាំងស្រុងនូវប្រេងឥន្ធនៈ ដើម្បីបំពេញតម្រូវការរបស់ខ្លួន ការកើនឡើងយ៉ាងលឿន និងភាពប្រែប្រួលយ៉ាងខ្លាំងនៃថ្លៃ បានបង្កើតឱ្យមានបញ្ហាប្រឈមធ្ងន់ធ្ងរជាច្រើនសម្រាប់សេដ្ឋកិច្ច កម្ពុជា ។ ការកើនឡើងនៃថ្លៃប្រេង ដែលបានធ្វើឱ្យតម្លៃនៃការដឹកជញ្ជូនសម្រាប់អាជីវកម្មនានា កើនឡើងខ្ពស់ជាងមុន បានបណ្តាលឱ្យមានការ ឡើងថ្លៃទំនិញសំខាន់ៗ ដូចជាថ្លៃ ប្រេងឆា សម្ភារសំណង់ (ឧទាហរណ៍ ដែកនិងស៊ីម៉ង់ត៍) និងថ្លៃទំនិញផ្សេងៗទៀត ដោយបានបណ្តាលឱ្យ មានការកើនឡើងនូវ តម្លៃនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងអគារនានា ។ ថ្លៃទំនិញជាម្ហូបអាហារ ក៏មានការកើនឡើងផងដែរ ។ ថ្លៃអង្ករ បានកើនឡើងទ្វេដង នៅក្នុងទីផ្សារអន្តរជាតិ នៅក្នុងចន្លោះរវាង ត្រីមាសទី១ ឆ្នាំ២០០៧ និង ត្រីមាសទី១ ឆ្នាំ២០០៨ ហើយបានកើនឡើងទ្វេដង ជាថ្មីម្តងទៀត តែនៅក្នុង ៤ខែដំបូង នៃឆ្នាំ២០០៨ ។ ចាប់តាំងពីពេលនោះមក ថ្លៃអង្ករបានធ្លាក់ចុះមកវិញ ដោយបានបង្កឡើងជាបញ្ហាប្រឈមថ្មីៗមួយចំនួន សម្រាប់ កសិករនិងសហគមន៍ជនបទ ។

២០. ការសិក្សាជាច្រើន ត្រូវបានធ្វើឡើង ដោយស្ថាប័នជាតិនិងអន្តរជាតិជាច្រើន ដើម្បីវាយតម្លៃលើផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលលោក និង ភាពប្រែប្រួលយ៉ាងខ្លាំងនៃតម្លៃប្រេងនិងស្បៀងអាហារ មកលើប្រជាជនក្រីក្រនៅទូទាំងពិភពលោក រួមទាំង នៅ*កម្ពុជា* ផងដែរ ។ នាពិធីបើក *សន្និសីទស្តីអំពីទស្សនវិស័យសម្រាប់កម្ពុជាក្រោមប្រធានបទស្តីពី "កម្ពុជា និង វិបត្តិសេដ្ឋកិច្ចពិភពលោក : ផលប៉ះពាល់ គោលនយោបាយឆ្លើយតប និង វិធានការ"* នៅខែមីនា ឆ្នាំ២០០៩ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់ថា *"វិបត្តិទូទាំងតំបន់និងពិភពលោកនេះ មិនមែនកើតចេញពីកម្ពុជាទេ ។ វិបត្តិនេះកើតឡើងដោយកត្តាខាងក្រៅ ហួសពីការគ្រប់គ្រងរបស់កម្ពុជា ប៉ុន្តែ ជាវិបត្តិដែលជះឥទ្ធិពលមកដល់យើងទាំងអស់គ្នា ។ ខ្ញុំធ្លាប់បានគូសបញ្ជាក់ នៅក្នុងវេទិកាកន្លងមកជាហូរហែ ហើយថា យើងត្រូវធ្វើការរួមគ្នា ដើម្បីឆ្លងឱ្យ*

*ផុតពីវិបត្តិនេះ ធានារក្សាមិនឱ្យបាត់បង់នូវការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ ដែលកម្ពុជាសម្រេចបាន ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក និង ពង្រឹងបន្ថែមទៀតនូវ វិស័យសំខាន់ៗសម្រាប់កំណើន និង ការអភិវឌ្ឍរបស់កម្ពុជា នាពេលអនាគត ដើម្បីធ្វើឱ្យកម្ពុជា អាចងើបចេញផុតពីវិបត្តិនេះ និង មានសេដ្ឋកិច្ចអភិវឌ្ឍប្រកបដោយចីរភាព មានក្របខ័ណ្ឌស្ថាប័នរឹងមាំខ្លាំងជាងពេលមុន និង មានសង្គមដែលពោរពេញដោយ សន្តិភាព ស្ថិរភាព និង ភាពសកម្ម រស់រវើក" ។*

២១. **សម្តេចនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ ផងដែរថា "*យើងមានភ័ព្វសំណាង ដោយយើងប្រឈមមុខនឹងវិបត្តិទាំងនេះ នៅពេលដែលសេដ្ឋកិច្ចនៅមានភាពខ្លាំងក្លា ដោយបានសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរ ។ ការសិក្សារបស់ធនាគារពិភពលោកនាពេលថ្មីៗនេះ បានចាត់កម្ពុជាក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដប់ ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ គិតពីឆ្នាំ១៩៩៨ ដល់ ២០០៧ ជាមួយនឹងកំណើនជាមធ្យមនៅក្នុងទសវត្សរ៍កន្លងមក ឈានដល់តួលេខពីរខ្ទង់ ប៉ុន្តែ បានធ្លាក់ចុះបន្តិចក្នុងរង្វង់ ៧ ភាគរយ នៅឆ្នាំ ២០០៨ ដែលនៅតែជាកំណើនមួយខ្ពស់ បើប្រៀបធៀបទៅនឹងកំណើននៅក្នុងពិភពលោក ។ ទន្ទឹមនឹងនេះដែរ កម្ពុជាបានកាត់បន្ថយនូវភាពក្រីក្រ ពី ៤៥ ភាគរយ នៅឆ្នាំ១៩៩៤ មកនៅត្រឹម ៣០ ភាគរយ នៅឆ្នាំ២០០៧ ។ យើងអាចសម្រេចបាន នូវលទ្ធផលទាំងអស់នេះ តាមរយៈ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាមួយនឹង ជវភាពរបស់វិស័យឯកជន និង ការខិតខំប្រឹងប្រែង និង ផលិតភាពរបស់ប្រជាជនកម្ពុជា ។ យើងបានសម្រេចនូវវឌ្ឍនភាពជាច្រើន នៅក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន ធារាសាស្ត្រ ការដឹកជញ្ជូន និង ទូរគមនាគមន៍ និង អនុវត្តនូវស្តង់ដារពលកម្មអន្តរជាតិ នៅក្នុងឧស្សាហកម្មកាត់ដេរ ការធ្វើឱ្យប្រសើរឡើងនូវ វិស័យទេសចរណ៍ និង បរិយាកាសជាវិជ្ជមាន សម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និង វិនិយោគ" ។*

២២. ទោះបីជា *រាជរដ្ឋាភិបាល* បានដាក់ចេញនូវវិធានការមួយចំនួនដើម្បីទប់ទល់នឹងវិបត្តិនេះ ក៏ដោយ ក៏ភាពវឹកវរនេះ នៅតែបន្តអូសបន្លាយ និងមានសភាពធ្ងន់ធ្ងរ សម្រាប់ប្រទេសមួយចំនួន ហើយពេលវេលានៃការចប់នៃសភាពការណ៍អាក្រក់នេះ គឺមិនអាចប៉ាន់ស្មានដឹងជាមុនបានទេ ។ វិបត្តិនេះ នឹងជះឥទ្ធិពលមកលើវិស័យសេដ្ឋកិច្ចសំខាន់ៗ មួយចំនួន និងនាំឱ្យឈានដល់ការធ្លាក់ចុះនូវកំណើននៃវិស័យធំៗ ដូចជា វិស័យកាត់ដេរ វិស័យទេសចរណ៍ និងវិស័យសំណង់ ដែលនឹងមានផលប៉ះពាល់អវិជ្ជមាន មកលើប្រជាជននិងសេដ្ឋកិច្ចរបស់យើង ។ ដូច្នេះ *រាជរដ្ឋាភិបាល* បានផ្តល់អាទិភាពខ្ពស់ ក្នុងការដោះស្រាយជាមួយនឹងបញ្ហាប្រឈមតាមវិស័យសំខាន់ៗ ដូចខាងក្រោម :

- ធ្វើពិពិធភាវូបនីយកម្មទីផ្សារ សម្រាប់វិស័យកាត់ដេរ និងទំនិញកម្មន្តសាលផ្សេងៗទៀត ទៅក្នុងទីផ្សារ អាស៊ី-បូព៌ា មជ្ឈិមបូព៌ា និង អាហ្វ្រិក ជាដើម ។

- បង្កើនការកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យទេសចរណ៍ និងអភិវឌ្ឍតំបន់ទេសចរណ៍ថ្មីៗបន្ថែមទៀត ព្រមទាំង យកចិត្តទុកដាក់រៀបចំកញ្ចប់ទេសចរណ៍ ឱ្យមានលក្ខណៈសម្បូរបែប និងប្រកបដោយភាពទាក់ទាញ ។
- ធ្វើអាទិភាវូបនីយកម្ម ក្នុងការប្រើប្រាស់ធនធាននិងជំនាញ របស់រាជរដ្ឋាភិបាល និង របស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីពង្រីកនិងធ្វើពិពិធភាវូបនីយកម្មវិស័យកសិកម្មរបស់យើង សំដៅទាក់ទាញឱ្យបានច្រើនថែមទៀត នូវការវិនិយោគប្រកបដោយគុណភាព នៅក្នុងវិស័យកសិ-ពាណិជ្ជកម្ម និង កែលម្អប្រព័ន្ធពាណិជ្ជកម្មក្នុងវិស័យកសិកម្ម កំណែទម្រង់ដីធ្លី ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និង ការកែច្នៃផលិតផលកសិកម្ម ។
- ពង្រីកការវិនិយោគបន្ថែមទៀត លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស លើវិស័យថាមពល ដើម្បីកាត់បន្ថយថ្លៃដើមផលិត សម្រាប់បំពេញតម្រូវការរបស់ វិស័យឯកជន និង សហគមន៍ ។
- បន្តលើកកម្ពស់ កម្រិតជីវភាពរស់នៅរបស់ប្រជាជន ជាជំហានៗ ដោយអនុលោមទៅតាម នីតិវិធី និង គោលការណ៍ ដែលបានកំណត់នៅក្នុង *រដ្ឋធម្មនុញ្ញកម្ពុជា* ។

២៣. ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារឱ្យមាននូវ កិច្ចសហប្រតិបត្តិការ ប្រកបដោយភាពស័ក្តិសិទ្ធិ និងជវភាព រវាង*រាជរដ្ឋាភិបាលកម្ពុជា* ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន រួមទាំង ការសម្របសម្រួល និង កិច្ចសហ-ប្រតិបត្តិការ ដែលមានភាពស័ក្តិសិទ្ធិខ្លាំងជាងមុន នៅក្នុងចំណោមក្រសួង-ស្ថាប័នរបស់*រាជរដ្ឋាភិបាល* និងសហគមន៍ ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ផងដែរ ។ នៅក្នុងកិច្ចការសំខាន់ៗមួយចំនួន ដូចជា *ការអភិវឌ្ឍកសិកម្មនិងជនបទ រួមនឹង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ ការគ្រប់គ្រងធារាសាស្ត្រនិងធនធានទឹក* ព្រមទាំង *ការសម្រួលពាណិជ្ជកម្ម* កិច្ចការ បន្ទាន់ដែលត្រូវធ្វើ គឺត្រូវពង្រឹង ទំនាក់ទំនង ការសម្របសម្រួល និង កិច្ចសហប្រតិបត្តិការ រវាង ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ដើម្បីធានាថា កម្មវិធីអភិវឌ្ឍន៍ ត្រូវបាន រៀបចំឡើង និង អនុវត្ត ដោយឆាប់រហ័ស និងមានប្រសិទ្ធភាព ព្រមទាំង ដើម្បីធានាថា ធនធានទាំងឡាយ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍របស់យើង អាចត្រូវបានផ្តល់ឱ្យ តាម រូបភាពមួយ ឆាប់រហ័សនិងមានភាពស័ក្តិសិទ្ធិ ជាងមុន សម្រាប់ការអនុវត្តគម្រោង នានា ។

២៤. សម្រាប់*រាជរដ្ឋាភិបាលកម្ពុជា* វិបត្តិហិរញ្ញវត្ថុសាកលលោកនាពេលបច្ចុប្បន្ននេះ ផ្តល់នូវកាលានុវត្តភាព ដល់យើងទាំងអស់គ្នា ក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មនៅក្នុងតំបន់ ដើម្បីទទួលបានផលប្រយោជន៍ជាអតិបរមា ពីសក្តានុពលភាពសេដ្ឋកិច្ចដ៏ធំធេងរបស់យើង តាមរយៈ ការពង្រីកវិសាលភាព នៃទីផ្សារ ក៏ដូចជា ការជំរុញការធ្វើពាណិជ្ជកម្មនិងការវិនិយោគ នៅក្នុងតំបន់ ។ ប្រការសំខាន់ ដែលយើងត្រូវគិតគូរដល់ គឺត្រូវកាត់បន្ថយឱ្យបានច្រើនបំផុតនូវ ភាពពឹងអាស្រ័យយ៉ាងលើសលប់របស់យើង ទៅលើទីផ្សារអន្តរជាតិ ហើយត្រូវលើកកម្ពស់ភាពប្រកួតប្រជែងរបស់យើង ក្នុងការទាក់ទាញការវិនិយោគពីខាងក្រៅ មកក្នុងតំបន់ ។

២៥. ទោះបីជា ត្រូវបានទទួលរងនូវផលប៉ះពាល់ ពីការប្រែប្រួលយ៉ាងឆាប់រហ័សនៃ ស្ថានភាពក្រៅប្រទេស ដែលបានលេចឡើង ដោយមិនបានរំពឹងទុកជាមុនក៏ដោយ ក៏*រាជរដ្ឋាភិបាលកម្ពុជា* បានឆ្លើយតបយ៉ាងទាន់ពេលវេលា ដោយបង្កើតឱ្យមានយន្តការឆ្លើយតបមួយ ហើយ បានចាត់ទុកស្ថានភាពវិវត្តន៍នៅក្រៅប្រទេស ជាបញ្ហាប្រឈមមួយ សម្រាប់ការវាយតម្លៃពី សមត្ថភាពទប់ទល់នឹងផលប៉ះពាល់ ដែលអាចមានពីស្ថានភាពទាំងនោះរបស់មូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ។ យន្តការឆ្លើយតបរបស់*រាជរដ្ឋាភិបាលកម្ពុជា* បានប្រើប្រាស់វិធីសាស្ត្រមួយ ដែលមានមុខព្រួញពីរ ដោយផ្តោតទៅលើសកម្មភាព រយៈពេលខ្លី និង រយៈពេលវែង ។ សកម្មភាពសម្រាប់រយៈពេលខ្លី បានផ្តោតលើ ការអនុវត្តវិធានការសារពើពន្ធ ដើម្បីលើកទឹកចិត្តដល់ ផលិតករនិងអ្នកប្រើប្រាស់ទាំងឡាយ សំដៅធ្វើឱ្យមានសន្ទុះខ្លាំងក្លាឡើងវិញ នៃល្បឿនសេដ្ឋកិច្ច ដែលកំពុងមានការថយចុះ ព្រមទាំង ផ្តោតលើការអនុវត្តគោលនយោបាយរូបិយវត្ថុមួយ ដែលបានឆ្លើយតបយ៉ាងឆាប់រហ័ស ទៅនឹងស្ថានភាពដែលកំពុងវិវត្តប្រែប្រួល ។ វិធីសាស្ត្រនេះ មានសារប្រយោជន៍ដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការធានានូវភាពអាចជឿទុកចិត្តបាននៃប្រព័ន្ធធនាគារ ។ ការដោះស្រាយបញ្ហារយៈពេលវែង តាមរយៈការធ្វើឱ្យប្រសើរឡើងនូវ ភាពប្រកួតប្រជែងរបស់កម្ពុជា ដែលជាវិធានការសម្រាប់រយៈពេលយូរអង្វែងទៅខាងមុខ គឺនៅតែបន្ត ជាអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ដើម្បីធ្វើឱ្យមានភាពទន់ភ្លន់ ទប់ទល់នឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន និង ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច *កម្ពុជា* នឹងពិនិត្យសិក្សារកមើលលទ្ធភាពនានា ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងរបស់ខ្លួន នៅក្នុងតំបន់និងនៅលើឆាកអន្តរជាតិ ព្រមទាំង ដើម្បីស្វែងរកកាលានុវត្តភាពនានា ក្នុងគោលបំណងធ្វើពិពិធកម្មនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ច ។ *កម្ពុជា* នឹងបន្តស្វែងរកមើល ដោយយកចិត្តទុកដាក់ នូវមូលដ្ឋានសេដ្ឋកិច្ចថ្មីៗទៀត ទន្ទឹមគ្នានឹង ការបន្តជំរុញការអភិវឌ្ឍវិស័យទាំងឡាយ ដែលកំពុងមានការរីកលូតលាស់ ដូចជា វិស័យ ទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន កម្មន្តសាលធុនស្រាល ទីផ្សារហិរញ្ញវត្ថុនិងមូលបត្រ ព្រមទាំង វិស័យជាសក្តានុពលជាច្រើនទៀត ដូចជា ប្រភពថាមពលដែលអាចជំនួសគ្នាបាន ការរុករកប្រេងកាត អាជីវកម្មរ៉ែ ហើយនិង បច្ចេកវិទ្យាកែច្នៃ ដើម្បីគាំទ្រដល់ផលិតភាពនិងភាពប្រកួតប្រជែង។

២៦. ការធានាឱ្យបាននូវជោគជ័យ ក្នុងការកាត់បន្ថយភាពក្រីក្រ នាពេលអនាគត បានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនថែមទៀត ដែលបណ្តាលមកពីភាពចាំបាច់ ក្នុងការការពារសមិទ្ធផលដែលយើងសម្រេចបាន ដោយលំបាក ដែលបច្ចុប្បន្ននេះ កំពុងត្រូវបានយាយី ដោយវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ជាការពិតណាស់ ប្រសិនបើស្ថានភាពបច្ចុប្បន្ន នៅតែបន្តអូសបន្លាយ សម្រាប់រយៈពេលមួយវែង នោះប្រជាជនទាំងឡាយ ដែលទើបនឹងបានរស់នៅក្នុងជីវភាពមួយ ស្ថិតនៅលើខ្សែបន្ទាត់ ភាពក្រីក្រ នាពេលបច្ចុប្បន្ន អាចនឹងធ្លាក់មកនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រវិញ ។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងចាត់វិធានការបន្ទាន់ ដើម្បីពង្រីកប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះបំផុត តាមរយៈ ការឧបត្ថម្ភធនផ្សេងៗ និងការបង្កើតការងារអតិពលកម្ម ដូចជា កម្មវិធីស្បៀងនិងប្រាក់ពលកម្ម ជាដើម ។

២៧. ទោះបីជា តាមរយៈ ការអនុវត្តប្រកបដោយថាមភាពនូវ *យុទ្ធសាស្ត្រត្រីកោណ* និង *យុទ្ធសាស្ត្រចតុកោណ* នៅក្នុងទសវត្សរ៍ចុងក្រោយនេះ *រាជរដ្ឋាភិបាល* អាចកែប្រែប្រជាជាតិទាំងមូលបាន ក្នុងរយៈពេលមួយដ៏ខ្លី ធៀបនឹងពេលវេលាដ៏វែង ដែលប្រទេសរីកចម្រើនជឿនលឿននានា បានឆ្លងកាត់ក៏ដោយ ក៏កម្ពុជា នៅតែជួបប្រទះនឹងបញ្ហាប្រឈម មួយចំនួន ដូចជា :

- ទោះបីជាមានវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ នៅក្នុងកំណែទម្រង់សំខាន់ៗ ក្នុងគោលបំណងពង្រឹងអភិបាលកិច្ចល្អក៏ដោយ ក៏គុណភាព ប្រសិទ្ធភាព និងការផ្តល់សេវាកម្មសាធារណៈ នៅតែជាបញ្ហាប្រឈម ហើយនៅតែមិនទាន់បានឆ្លើយតបបានពេញលេញទៅនឹងតម្រូវការពិតរបស់ប្រជាជននៅឡើយ ។ ប្រព័ន្ធ តុលាការនៅតែពុំទាន់អាចទទួលបាន នូវការជឿទុកចិត្តទាំងស្រុង ពីសំណាក់មជ្ឈដ្ឋានសាធារណៈ នៅឡើយ ។ ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក៏នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ នៅឡើយ ហើយការអនុវត្តច្បាប់ ក៏ត្រូវតែបន្តធ្វើ ឱ្យប្រសើរឡើងថែមទៀត ផងដែរ ។
- សេដ្ឋកិច្ចកម្ពុជា មានមូលដ្ឋានតូចចង្អៀតដោយផ្អែកលើ និងត្រូវបានជំរុញដោយវិស័យ ៤ សំខាន់ៗ គឺវិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់ ។ វិស័យឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ គឺជាវិស័យដែលងាយរងគ្រោះ បណ្តាលមកពីហានិភ័យ ពីខាងក្រៅប្រទេស ។ វិស័យកសិកម្មដែលមានចំណែក ៣០ភាគរយ នៃផលិតផលក្នុងស្រុកសរុប និង ប្រើប្រាស់ពលកម្មច្រើនជាង ៦០ ភាគរយនៃការងារសរុប នៅតែមិនទាន់ត្រូវបានប្រើប្រាស់ ឱ្យអស់សក្តានុពលរបស់វា នៅឡើយ ។
- បម្រែបម្រួលអាកាសធាតុ អតុល្យភាពនៃសេដ្ឋកិច្ចសាកល និង វិបត្តិហិរញ្ញវត្ថុដែលនៅតែបន្តកើតមាន និងកាន់តែមានសភាពធ្ងន់ធ្ងរ ដោយធ្វើឱ្យមានដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចសាកល ក៏ដូចជា ការកើនឡើងនៃថ្លៃប្រេង ការកើនឡើងនៃថ្លៃម្ហូបអាហារ ការធ្លាក់ចុះនៃតម្លៃប្រាក់ដុល្លារអាមេរិក បានធ្វើឱ្យមានសម្ពាធអតិផរណា មកលើសេដ្ឋកិច្ចកម្ពុជា សម្រាប់រយៈពេលខ្លី និងមធ្យម ។ ការកើនឡើងនៃតម្រូវការក្នុងស្រុកដែលជាលទ្ធផលនៃកំណើនសេដ្ឋកិច្ចខ្ពស់ នាពេលថ្មីៗនេះ ក៏បានធ្វើឱ្យសម្ពាធអតិផរណានេះ កាន់តែមានសភាពធ្ងន់ធ្ងរ ផងដែរ ។ ស្ថានភាពទាំងនេះ បានក្លាយជាការគំរាមកំហែងដល់អនាគតនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ។
- ទោះបីជាយើងបានកាត់បន្ថយភាពក្រីក្រ ពីអត្រា ៤៧ភាគរយ ក្នុងឆ្នាំ២០០៣ មក ៣៥ភាគរយ ក្នុងឆ្នាំ២០០៤ តាមរយៈ កំណើនសេដ្ឋកិច្ចខ្ពស់ និង គោលនយោបាយគាំទ្រអ្នកក្រីក្រ ហើយ ការព្យាករលើកដំបូងបានបង្ហាញពីការថយចុះជាបន្តទៀតនៃអត្រាភាពក្រីក្រ មកនៅត្រឹម ៣០,១ ភាគរយ ក្នុងឆ្នាំ២០០៧ ក៏ដោយ ក៏អត្រានៃភាពក្រីក្រនៅជនបទ នៅតែមានកម្រិតខ្ពស់ នៅឡើយ ។ ទន្ទឹមនឹងនេះ គម្លាតរវាងអ្នកមាន និងអ្នកក្រ ជាពិសេស វិសមភាពរវាងទីប្រជុំជននិងជនបទ នៅតែជាបញ្ហាប្រឈម នៅឡើយ ។

- សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានភាពប្រសើរឡើងជាលំដាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយបញ្ហាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃចំពោះកុមារអាយុក្រោម ៥ឆ្នាំ បានថយពី ៤៩,៧ ភាគរយ នៅឆ្នាំ២០០០ មកត្រឹម ៤៣,២ ភាគរយ នៅឆ្នាំ២០០៥ *(ការអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨)* ។ ទោះបីជា ដូចនេះក្តី វឌ្ឍនភាពក្នុងស្ថានភាពអាហារូបត្ថម្ភ នៅមានភាពយឺតយ៉ាវ ដោយសារតែមានការកើនឡើងនៃថ្លៃស្បៀង និងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលនាពេលបច្ចុប្បន្ន មកលើកម្លាំងទិញរបស់ប្រជាពលរដ្ឋក្រីក្រ ហើយ បញ្ហាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ នៅតែមានកម្រិតខ្ពស់ គឺ ៣៩,៥ ភាគរយ *(ការអង្កេតមនុស្សមាត្រ ឆ្នាំ ២០០៨)* ។ ប្រសិនបើបញ្ហានេះ នៅតែបន្តកើតមាន ឬ មានលក្ខណៈធ្ងន់ធ្ងរជាងនេះ នោះស្ថានភាព អាហារូបត្ថម្ភ អាចនឹងកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ។
- ការប្រមូលផ្តុំដីធ្លី និងប្រជាជនដែលគ្មានដី គឺស្ថិតនៅក្នុងនិន្នាការមួយដែលកំពុងមានការកើនឡើង ដោយ បង្កើតជាផលប៉ះពាល់អវិជ្ជមានមកលើ សមធមិនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីធ្លី ។ ជាមួយគ្នានេះ ផ្ទៃដីដ៏ធំនៃតំបន់ដីសម្បទានសេដ្ឋកិច្ច ពុំទាន់ត្រូវបានប្រើប្រាស់ឱ្យមានប្រសិទ្ធភាព ទៅតាមគោលដៅដោយ តម្រូវឱ្យមានវិធានការដ៏តឹងរ៉ឹងរបស់*រដ្ឋាភិបាល* ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។
- ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីខុសច្បាប់ ការទាមទារយកដោយខុសច្បាប់នូវដីរដ្ឋនិងតំបន់ការពារ ធ្វើជាកម្មសិទ្ធិឯកជន និងការកាប់ឈើខុសច្បាប់ នៅតែបន្តកើតមាននៅឡើយ ។ ជាមួយគ្នានេះដែរ ភាព ក្រីក្រ និងការផ្លាស់ទីលំនៅនៃប្រជាជនក្នុងប្រទេស បានបន្ថែមសម្ពាធទៅលើធនធានធម្មជាតិ ហើយ បានធ្វើឱ្យធនធានទាំងនោះ ប្រឈមនឹងហានិភ័យខ្ពស់ នៃការរេចរឹលបាត់បង់ ។
- ដោយសម្រេចបាននូវវឌ្ឍនភាពដ៏ធំធេង ក្នុងការស្តារនិងការសាងសង់ឡើងវិញ នូវបណ្តាញផ្លូវជាតិទូទាំង ប្រទេស បញ្ហាប្រឈមនានាចំពោះមុខរបស់យើងទាំងអស់គ្នា គឺត្រូវធានាឱ្យមាន សុវត្ថិភាពក្នុងការធ្វើ ចរាចរ និងការថែទាំឱ្យបានត្រឹមត្រូវនូវបណ្តាញផ្លូវថ្នល់នៅទូទាំងប្រទេស ។
- វិស័យអាកាសចរណ៍ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ។ ការអភិវឌ្ឍបន្ថែមទៀត នូវហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ រួមបញ្ចូលទាំងការកែលម្អជាប្រចាំនូវអាកាសយានដ្ឋាននានានៅទូទាំង ប្រទេស និងសុវត្ថិភាពនៃការហោះហើរ នៅតែបន្តជាអាទិភាពចម្បង ដើម្បីធ្វើឱ្យមានការអភិវឌ្ឍវិស័យ ទេសចរណ៍ និង ការទាក់ទាញចំនួនភ្ញៀវទេសចរមកកម្ពុជា ដែលកំពុងមានការកើនឡើង ។
- ថ្លៃអគ្គិសនីនៅមានកម្រិតខ្ពស់ បើប្រៀបធៀបនឹងប្រទេសជិតខាង ហើយក៏ជាឧបសគ្គមួយដ៏ធំ ក្នុងការ ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ក៏ដូចជា ការទាក់ទាញការវិនិយោគ និងការធ្វើឱ្យប្រសើរឡើងនូវ ការរស់នៅរបស់ប្រជាជន ។ លទ្ធភាពមានអគ្គិសនីសម្រាប់ប្រើប្រាស់ នៅតំបន់ទីប្រជុំជន នៅមានកម្រិត នៅឡើយ ។
- ប្រព័ន្ធធារាសាស្ត្រ មិនទាន់ត្រូវបានអភិវឌ្ឍឱ្យបានពេញលេញ និង ប្រើប្រាស់ឱ្យអស់សក្តានុពលនៅឡើយ ដោយតម្រូវឱ្យមាន ការគ្រប់គ្រង និងការវិនិយោគ ដែលមានប្រសិទ្ធភាពជាងមុន ។

- ហិរញ្ញប្បទាន ការគ្រប់គ្រង និង បច្ចេកវិទ្យា គឺជា បញ្ហាប្រឈមចម្បង សម្រាប់សហគ្រាសខ្នាតតូច និង មធ្យម នៅកម្ពុជា ។
- បណ្តាញសុវត្ថិភាពសង្គម សម្រាប់កម្មករ និងប្រជាជនក្រីក្រ ពុំទាន់បានក្លាយជាប្រព័ន្ធមួយ ដែលមាន ប្រសិទ្ធភាពខ្ពស់ នៅឡើយ ។
- គុណភាពអប់រំនៅកម្រិត បឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សា នៅមានកម្រិត ។ ផលិតកម្ម និង ចរាចរណ៍ ថ្នាំញៀនខុសច្បាប់ បានក្លាយជាបញ្ហាសង្គម ដែលធ្វើឱ្យមានគ្រោះថ្នាក់ ដល់សុខុមាលភាព យុវជនកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត ។
- កង្វះអ្នកបច្ចេកទេស និងកម្មករជំនាញ គឺជា ឧបសគ្គចម្បងមួយ ក្នុងការពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច ទាំង នៅទីប្រជុំជន ទាំងនៅជនបទ ។
- ការផ្តល់សេវាសុខាភិបាលសាធារណៈដែលមានគុណភាព នៅតែមានកម្រិតនៅឡើយ ។ អត្រាមរណភាពមាតា នៅតែមានកម្រិតខ្ពស់នៅឡើយ ទោះបីជាមានសមិទ្ធផលដ៏ច្រើន ក្នុងវិស័យសុខាភិបាល ក៏ដោយ ។ វឌ្ឍនភាពក្នុងការជំរុញឱ្យមាន សេវាថែទាំសុខភាព អនាម័យ និង ទឹកស្អាតនៅតំបន់ជនបទ ត្រូវតែបានបង្កើនល្បឿន ដើម្បីឈានទៅសម្រេចចំណុចដៅទាំងឡាយ ដែលបានកំណត់នៅក្នុង *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ។
- កង្វះខាតការអប់រំ អំពើហឹង្សាក្នុងគ្រួសារ និង អំពើជួញដូរមនុស្ស គឺជា កត្តាចម្បង ដែលរាំង មិនឱ្យស្ត្រី អាចប្រើប្រាស់បានពេញលេញនូវសក្តានុពលរបស់ខ្លួន ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។
- ជារួម សមត្ថភាពស្ថាប័នរបស់*រាជរដ្ឋាភិបាល* នៅមានកម្រិតនៅឡើយ ដោយសារប្រាក់បៀវត្សរ៍ និង ប្រាក់លាភការទាំងឡាយ មានកម្រិតទាប ។ កិច្ចសហការ រវាងស្ថាប័នទាំងឡាយរបស់*រាជរដ្ឋាភិបាល* នៅមានលក្ខណៈខ្វះចន្លោះ ហើយក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋាននានា នៅមានភាពចន្លោះប្រហោង ជាច្រើន ហើយ ធនធានដើម្បីអនុវត្តគោលនយោបាយរបស់យើង ក៏នៅមានកម្រិត នៅឡើយ ។

២៨. ការពិភាក្សាលើ សមិទ្ធផល និងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្ត *ផយអជ ២០០៦-២០១០* នឹងត្រូវ បង្ហាញនៅខាងក្រោមនេះ ទៅតាមទម្រង់នៃយុទ្ធសាស្ត្រចតុកោណ ដូចគ្នានឹង *ផយអជ ២០០៦-២០១០* ដែរ ។

## ១. អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

២៩. អភិបាលកិច្ចល្អ ដែលជាស្នូលនៃ *យុទ្ធសាស្ត្រចតុកោណ* ត្រូវការជាចម្បង នូវការចូលរួមរបស់សាធារណជន ប្រកបដោយសមធម៌និងភាពត្រឹមត្រូវ ក្នុងគ្រប់បញ្ហាទាំងអស់ តាមបែបប្រជាធិបតេយ្យនិងគ្មានអំពើហឹង្សា ដើម្បី ធានាថា ឆន្ទៈសេរីនិងការសម្រេចចិត្តដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់ ត្រូវបានឯកភាពទទួលយកនិងអនុវត្ត ស្រប គ្នានឹង ការការពារសិទ្ធិនិងសុខុមាលភាព របស់ប្រជាជនជនជាតិដើមភាគតិច ។ ស្ថិរភាពនយោបាយ សន្តិសុខ

ផ្ទៃក្នុង ការប្រកាន់ខ្ជាប់នូវវិធានការច្បាប់ តម្លាភាព ភាពអាចដឹងជាមុនបាន និង គណនេយ្យភាពនៃស្ថាប័នសាធារណៈ មានសារៈសំខាន់យ៉ាងខ្លាំង ចំពោះវឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច ដែលមានលក្ខណៈជាប្រព័ន្ធ និង ចំពោះការ ធានាថា សមិទ្ធផលសាធារណៈនានា នឹងមិនត្រូវបានធ្វើឱ្យបាត់បង់ទៅវិញ ដោយរបាំងណាមួយឡើយ ។ កំណែទម្រង់ ធំៗទាំងបួន ដើម្បីជំរុញលើកកម្ពស់អភិបាលកិច្ចល្អ នៅតែបន្តជាអាទិភាព របស់*រាជរដ្ឋាភិបាលកម្ពុជា* នៅក្នុងកិច្ច ខិតខំប្រឹងប្រែងរបស់ខ្លួន សំដៅធ្វើឱ្យសម្រេចបាននូវ ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចមួយ ប្រកបដោយចីរភាព និង ស្ថិរភាព សមធម៌ កាលានុវត្តភាពដូចគ្នា ស្មើភាពគ្នាចំពោះមុខច្បាប់ និងយុត្តិធម៌សង្គម ។ កំណែទម្រង់ទាំងនោះ រួមមាន : *(ក) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (ខ) កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (គ) កំណែ ទម្រង់រដ្ឋបាលសាធារណៈគ្រប់ទិដ្ឋភាពទាំងអស់ (រួមបញ្ចូលទាំងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ) និង (ឃ) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ* ។ ការវិវត្តសំខាន់ៗ ដែលបានកើតមានឡើង នៅក្នុងវិស័យទាំងនេះ នឹង ត្រូវលើកយកមកបង្ហាញ ដោយសង្ខេប ដូចខាងក្រោម ។

## ១.១ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ :

៣០. ប្រសិនបើធ្វើការប្រៀបធៀបទៅនឹងអំពើឧក្រិដ្ឋកម្ម ដែលមានអ្នករងគ្រោះ និង អ្នករំលោភបំពាន អំពើពុករលួយ គឺជាបទឧក្រិដ្ឋមួយ ដែលជាទូទៅ ភាគីពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើពុករលួយ ទទួលបានផលប្រយោជន៍ពីទង្វើរបស់ខ្លួន ។ រីឯភាគីរងគ្រោះ គឺជាសង្គមទាំងមូល ដែលទទួលរងការខាតបង់ ដោយសារ ការបាត់បង់ចំណូលសាធារណៈ ការបាត់បង់កាលានុវត្តភាពនៃការវិនិយោគដែលអាចផ្តល់នូវការងារធ្វើថ្មីៗ និងចំណូលបន្ថែម និង ការផ្តល់ដោយមិនមានប្រសិទ្ធភាពនូវសេវាសាធារណៈ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានអនុម័តយកនូវ ផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ទន្ទឹមនឹងជោគជ័យក្នុងការងារបង្ការទប់ស្កាត់ និងប្រឆាំងអំពើពុករលួយកន្លងមក *រាជរដ្ឋាភិបាលកម្ពុជា* ក៏យល់ឃើញថា ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត និង សមត្ថភាពរបស់ស្ថាប័ន នៅមានកម្រិតនៅឡើយ ។ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ទាមទារនូវសមត្ថភាព ដើម្បីគ្រប់គ្រងនិងជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវច្បាប់ទាំងឡាយ ដែលមានប្រការចែងអំពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់រួចហើយ ។ ទន្ទឹមនឹងនេះ កង្វះខាតអ្នកជំនាញការជាតិផ្នែកច្បាប់ និងកង្វះខាតយន្តការសម្របសម្រួល ក្នុងការរៀបចំសេចក្តីព្រាងច្បាប់នានា មិនបានធ្វើឱ្យមានសង្គតិភាពនៅក្នុងប្រការជាច្រើន ។ ប្រការ ខ្វះខាតនូវសង្គតិភាពទាំងនេះ បានធ្វើឱ្យមានភាពយឺតយ៉ាវ នៅក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ហើយបាន ធ្វើឱ្យការជំរុញការអនុវត្តច្បាប់ កាន់តែជួបប្រទះនូវការលំបាកខ្លាំងឡើង ។ ការជំរុញការអនុវត្តច្បាប់ នៅតែជា បញ្ហាប្រឈមមួយ ដោយសារមូលហេតុជាច្រើន ក្នុងនោះកម្រិតទាបនៃប្រាក់បៀវត្សរ៍របស់មន្ត្រី ដែលទទួលខុសត្រូវ ក្នុងការជំរុញការអនុវត្តច្បាប់ ។

៣១. អំពើពុករលួយ គឺជាបាតុភូតមួយ ដែលកើតមាននៅក្នុងគ្រប់សង្គម ក្នុងនោះរួមមានទាំង ប្រទេសអភិវឌ្ឍ ប្រទេសកំពុងអភិវឌ្ឍ និង ស្ថាប័នអន្តរជាតិនានា ផងដែរ ។ ការលុបបំបាត់អំពើពុករលួយ គឺជាអាទិភាពខ្ពស់របស់ *រាជរដ្ឋាភិបាលកម្ពុជា* ព្រោះថា បញ្ហានេះ គឺជាឧបសគ្គ ដែលរារាំងដល់ការធ្វើឱ្យសម្រេចបាននូវគោលដៅរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចខ្ពស់ តាមរយៈ ការជំរុញការអភិវឌ្ឍវិស័យឯកជន ដើម្បីកាត់បន្ថយភាពក្រីក្រ ។

៣២. ស្ថាប័នមួយចំនួនរបស់*រាជរដ្ឋាភិបាលកម្ពុជា* មានការពាក់ព័ន្ធនឹង ការបង្ការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមមាន : *អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* និង *អង្គភាពសវនកម្មផ្ទៃក្នុង* តាមបណ្តាក្រសួង-ស្ថាប័ន ។ *អង្គភាពប្រឆាំងអំពើពុករលួយ នៃទីស្តីការគណៈរដ្ឋមន្ត្រី* មានភារកិច្ច ទទួលពាក្យបណ្តឹងពីសាធារណជន ដែលពាក់ព័ន្ធនឹងអំពើពុករលួយ និង ចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនប្រព្រឹត្តអំពើពុករលួយ ។ អង្គភាពនេះ ក៏មានភារកិច្ចក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលនយោបាយ របស់ *រាជរដ្ឋាភិបាលកម្ពុជា* ស្តីពី ការបង្ការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ផងដែរ ។ ទន្ទឹមនឹងនេះ *អង្គភាពប្រឆាំងនឹងអំពើពុករលួយ* មានភារកិច្ចសម្របសម្រួល ការរៀបចំតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំង លើកឡើងនូវ វិធានការនានាដែលចាំបាច់សម្រាប់ការអនុវត្តគោលនយោបាយទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ស្តីពី ការបង្ការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ តាមរយៈ កម្មវិធីអធិការកិច្ចរបស់ខ្លួន *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* ធ្វើការតាមដានត្រួតពិនិត្យលើ ការងារគ្រប់គ្រងរបស់ស្ថាប័ន ក្នុងវិស័យសាធារណៈ និង ធ្វើការស៊ើបអង្កេតរាល់សកម្មភាពទាំងឡាយណា ដែលមានភាពមិនប្រក្រតី ។ ស្ថាប័ននេះ ក៏ធ្វើការតាមដានត្រួតពិនិត្យផងដែរ ពីការជំរុញការអនុវត្តច្បាប់ របស់ក្រសួងនិងស្ថាប័នសាធារណៈពាក់ព័ន្ធ និង ធ្វើការស៊ើបអង្កេតនូវរាល់ពាក្យបណ្តឹងនានា ដែលទទួលបានពីសាធារណជន ។ *ក្រសួងយុត្តិធម៌* មានភារកិច្ចទទួលខុសត្រូវ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ទាំងអស់ រួមទាំង *ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ* ផងដែរ ។

៣៣. នៅក្នុងខែសីហា ឆ្នាំ២០០៦ រចនាសម្ព័ន្ធរបស់ *អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ* ត្រូវបានធ្វើការកែសម្រួល និងត្រូវបានប្តូរឈ្មោះមកជា *អង្គភាពប្រឆាំងអំពើពុករលួយ* វិញ ។ *"ការិយាល័យទទួលពាក្យបណ្តឹង"* ត្រូវបានបង្កើតឡើង ដើម្បីបង្កើនការចូលរួមរបស់ សាធារណជន ក្នុងការផ្តល់និងទទួលព័ត៌មាន ដែលពាក់ពន្ធ័នឹងអំពើពុករលួយ ។ វិធានការដាក់វិន័យនានា ត្រូវបានអនុវត្តចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីគយ មន្ត្រីនគរបាល និង មន្ត្រីតុលាការ ដែលត្រូវបានរកឃើញថា បានឃុបឃិត ក្នុងការប្រព្រឹត្តអំពើពុករលួយ ។ ការងារលទ្ធកម្មសាធារណៈ ត្រូវបានធានាឱ្យមានតម្លាភាពប្រសើរជាងមុន ដោយមានកិច្ចដំណើរការដេញថ្លៃ ប្រកបដោយលក្ខណៈប្រកួតប្រជែង ។ យុទ្ធនាការជាច្រើន ត្រូវបានរៀបចំឡើង ដើម្បី ផ្តល់ព័ត៌មាន និង ដើម្បីអប់រំដល់សាធារណជន ព្រមទាំង ដើម្បី

ផ្សព្វផ្សាយ នូវការយល់ដឹងអំពីគ្រប់ទិដ្ឋភាពទាំងអស់ នៃអំពើពុករលួយ ក្នុងនោះរួមទាំង មូលហេតុ ឥទ្ធិពល និង ផលវិបាក នៃអំពើពុករលួយ ផងដែរ ។ ទោះជាដូចនេះក្តី *អង្គភាពប្រឆាំងអំពើពុករលួយ* បាននិងកំពុងជួបប្រទះនឹង បញ្ហាប្រឈមជាច្រើន ក្នុងការអនុវត្តភារកិច្ច របស់ខ្លួន ។ អង្គភាពនេះ កំពុងប្រឈមនឹងការលំបាក ក្នុងការប្រយុទ្ធ ប្រឆាំងនឹងអំពើពុករលួយ ប្រកបដោយប្រសិទ្ធភាព ដោយសារ ពុំមានសិទ្ធិអំណាចធ្វើការស៊ើបអង្កេត ភាពមានកម្រិត នៃចំណេះដឹងជំនាញនិងបទពិសោធន៍ ព្រមទាំង កង្វះខាត ឧបករណ៍ សម្ភារៈ និង បច្ចេកទេស ចាំបាច់ៗ ។ រហូតមក ទល់ពេលបច្ចុប្បន្ននេះ ដើម្បីរក្សានូវឯករាជភាព *អង្គភាពប្រឆាំងអំពើពុករលួយ* មិនសូវបើកទ្វារទទួលការគាំទ្រ ពីដៃគូ អភិវឌ្ឍន៍ទេ ។

៣៤. តាមរយៈកម្មវិធីអធិការកិច្ចរបស់ខ្លួន *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* បាន អនុវត្តការងារអធិការកិច្ចជាច្រើន នៅតាមស្ថាប័នសាធារណៈនានា ក្នុងនោះរួមទាំង ការចុះធ្វើអធិការកិច្ចលើភាព មិនប្រក្រតី នៃការអនុវត្តគម្រោង៤ ដែលគាំទ្រដោយធនាគារពិភពលោក ។ ជាមួយគ្នានេះ ក្រសួងបានទទួល ពាក្យបណ្តឹងចំនួន ២៩៨ករណី ដែលនៅក្នុងនេះ ពាក្យបណ្តឹងចំនួន ៩២ ករណី ត្រូវបានចុះអង្កេតស្រាវជ្រាវ ដោយ *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* ហើយ ពាក្យបណ្តឹងដែលនៅសល់ ត្រូវបានពិនិត្យ ចាត់ការ ដោយស្ថាប័នសាធារណៈពាក់ព័ន្ធ ផ្សេងៗទៀត ។ *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* ក៏មានបញ្ហាប្រឈម ផងដែរ ដែលទាក់ទងនឹង កង្វះខាតសមត្ថភាពនិងធនធាន សម្រាប់អនុវត្តមុខងារ របស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ។

៣៥. *ក្រសួងយុត្តិធម៌* ដែលមានភារកិច្ចក្នុងការរៀបចំសេចក្តីព្រាងច្បាប់ទាំងអស់ បានធ្វើបច្ចុប្បន្នកម្មសេចក្តីព្រាង *ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ* ស្របពេលគ្នា នឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។ សេចក្តីព្រាង *ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ* ដែលជាមូលដ្ឋានគតិយុត្តមួយមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ ត្រូវបាន ទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ និង ការអនុម័តពី រដ្ឋសភានៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ និង ពីព្រឹទ្ធសភា នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ។ នៅក្នុងដំណាក់កាលដែលច្បាប់នេះ មិនទាន់ចូលជា ធរមាន ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងយន្តការដែលមានស្រាប់ ត្រូវបន្តអនុវត្ត ដើម្បីបង្ការទប់ស្កាត់ និងប្រឆាំងនឹងអំពើពុករលួយ ។

៣៦. បច្ចុប្បន្ននេះ ប្រទេសកម្ពុជា ជាសមាជិកគាំទ្រផែនការសកម្មប្រឆាំងនឹងអំពើពុករលួយ *របស់ធនាគារ អភិវឌ្ឍន៍អាស៊ី និង អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក* ជារដ្ឋ ភាគីនៃ *អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ការប្រឆាំងនឹងអំពើពុករលួយ* និងជាភាគីនៃ *អនុស្សរណៈនៃការ យោគយល់គ្នាស្តីពី ការបង្ការទប់ស្កាត់និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ* ( ក្នុងក្របខ័ណ្ឌសមាជិក *អាស៊ាន*) ។

## ១.២ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

៣៧. *រាជរដ្ឋាភិបាលកម្ពុជា* បានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការជំរុញដំណើរការកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។ *ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* ដែលត្រូវបានបង្កើតឡើង ក្នុងខែមិថុនា ឆ្នាំ២០០២ មានបេសកកម្ម ក្នុងការ *"ផ្តួចផ្តើមគំនិតនិងជំរុញលើកទឹកចិត្តដល់ដំណើរការកំណែទម្រង់ និង ពិនិត្យមើលជាប្រចាំនូវការអនុវត្ត គោលនយោបាយនិងកម្មវិធី របស់កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ស្របទៅតាមទិសដៅនៃ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ"* ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៥មក *ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* បាន និងកំពុងអនុវត្ត ផែនការសកម្មភាពរបស់ខ្លួន ដើម្បីអនុវត្តតាម *យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* របស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ផែនការសកម្មភាពនេះ បានកំណត់នូវ អាទិភាពនិងសកម្មភាពសំខាន់ៗ សម្រាប់អនុវត្ត ក្នុងរយៈពេលខ្លីទៅមធ្យម (២០០៤-២០០៨) និង រយៈពេលវែង (ក្រោយឆ្នាំ២០០៨) ។ *យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* មានទិសដៅជាយុទ្ធសាស្ត្រ ចំនួនប្រាំពីរ ដូចខាងក្រោម ៖

- *ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន* ដោយបង្កើតនិងគាំទ្រវិធានការ សម្រាប់ការពារសិទ្ធិ និង បង្កើនការយល់ដឹងក្នុងចំណោមមហាជននិងស្ថាប័នពាក់ព័ន្ធ សំដៅជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយសមធម៌ និងចីរភាព ដែលជាផ្នែកមួយមិនអាចខ្វះបាន ក្នុងការធ្វើឱ្យសម្រេចបាន នូវសិទ្ធិពេញលេញ ។
- *ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់* ដោយកសាងក្របខ័ណ្ឌច្បាប់មួយ សមស្រប តាមរយៈកិច្ចដំណើរការរៀបចំច្បាប់ដែលផ្តល់លទ្ធផលល្អ ស៊ីចង្វាក់គ្នា និងមានការចូលរួម សំដៅធានាឱ្យបាននូវ ច្បាប់មួយដែលមានតុល្យភាព និង ការអនុវត្តដោយពេញលេញ នូវនីតិរដ្ឋ ។
- *ផ្តល់លទ្ធភាពទទួលបានព័ត៌មានអំពី ច្បាប់និងតុលាការ* ឱ្យបានកាន់តែប្រសើរឡើង ដោយជំរុញការផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋាន តាមរយៈ ការបោះពុម្ពផ្សាយជាផ្លូវការ ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច និងបណ្ណដ្ឋានព័ត៌មាន និង ធានានូវភាពងាយស្រួលក្នុងការទទួលបានព័ត៌មានអំពី ច្បាប់និងតុលាការ ដល់អ្នកប្រកបមុខវិជ្ជាជីវៈផ្នែកច្បាប់ និងអ្នកដែលយកចិត្តទុកដាក់ផ្សេងៗទៀត ។
- *ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ* ដោយពង្រឹងវិជ្ជាជីវៈផ្នែកច្បាប់ ធ្វើឱ្យប្រសើរឡើងនូវជំនួយការផ្នែកច្បាប់ ហើយនិងសម្រួលនីតិវិធីតុលាការ ដើម្បីធានានូវ យុត្តិធម៌ និង ដំណើរការត្រឹមត្រូវសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ។
- *ពង្រឹងសេវាកម្មយុត្តិធម៌ រួមមាន អំណាចតុលាការ និងសេវាផ្នែកអយ្យការ* ដោយរួមបញ្ចូលនូវវិធានការចាំបាច់នានាផ្នែក អប់រំ ច្បាប់ នីតិវិធី និងរចនាសម្ព័ន្ធ ដើម្បីធានាឱ្យបាននូវយុត្តិធម៌មួយ ដែលត្រឹមត្រូវគួរឱ្យជឿទុកចិត្តបាន ឯករាជ្យ និង ទទួលបានការគោរពពីសាធារណជនទូទៅ ។
- *បង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ* ដើម្បីផ្តល់ដំណោះស្រាយវិវាទឱ្យបានឆាប់រហ័ស និងងាយស្រួលដល់ភាគីពាក់ព័ន្ធ ហើយនិង ជួយសម្រាលដល់បន្ទុករបស់ប្រព័ន្ធតុលាការ ។

- *ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់និងតុលាការ* ឱ្យអាចបំពេញអាណត្តិរបស់ខ្លួនបានដោយជោគជ័យ តាមរយៈ ការពង្រឹងការគ្រប់គ្រង ការរៀបចំផែនការ យន្តការត្រួតពិនិត្យនានា និងសមត្ថភាពទូទៅ សំដៅ ផ្តល់នូវសេវាកម្មសាធារណៈមួយពេញលេញ និង ធានាឱ្យការធ្វើសេចក្តីសម្រេចចិត្តបានស្របទៅនឹងគោលការណ៍នៃ អភិបាលកិច្ចល្អ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព ។

៣៨. នៅក្នុងអំឡុងឆ្នាំ២០០៦-២០០៨ *ក្រសួងយុត្តិធម៌* បានរៀបចំសេចក្តីព្រាងច្បាប់ និង បានពិនិត្យមើលឡើងវិញនូវ សេចក្តីព្រាងច្បាប់នានា ដែលត្រូវបានរៀបចំឡើងដោយស្ថាប័ននានារបស់ *រាជរដ្ឋាភិបាលកម្ពុជា* ហើយក្រមនិងច្បាប់សំខាន់ៗដែល ត្រូវបាន ពិនិត្យ និង អនុម័ត ដោយ*រដ្ឋសភា*រួមមាន ៖

- *ក្រមនីតិវិធីរដ្ឋប្បវេណី* ត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។
- *ក្រមនីតិវិធីព្រហ្មទណ្ឌ* ត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។
- *ក្រមរដ្ឋប្បវេណី* ត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ។
- *ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម* ត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ។
- *ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ* ត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។
- *ក្រមសីលធម៌របស់ចៅក្រមនិងព្រះរាជអាជ្ញា* ត្រូវបានអនុម័ត ដោយ*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម* នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៧ ។

៣៩. *ក្រសួងយុត្តិធម៌* បានរៀបចំ និង បញ្ជូន សេចក្តីព្រាងច្បាប់និងក្រមមួយចំនួន ទៅ*គណៈរដ្ឋមន្ត្រី* ដើម្បីសុំការពិនិត្យពិភាក្សា និង ការអនុម័ត ក្នុងនោះរួមមាន ៖

- សេចក្តីព្រាង ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនិងអយ្យការ ។
- សេចក្តីព្រាង ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា ។

៤០. សេចក្តីព្រាង*ក្រមព្រហ្មទណ្ឌ* ត្រូវបានអនុម័តដោយ *គណៈរដ្ឋមន្ត្រី* កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ហើយត្រូវបានអនុម័តដោយ *រដ្ឋសភា* កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ។ ក្រមនេះ ត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

៤១. *តុលាការគំរូ* ត្រូវបានរៀបចំបង្កើតឡើងដោយ *ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* និងកំពុងត្រូវបានសហការអនុវត្ត ដោយ *ក្រសួងយុត្តិធម៌* ។ *តុលាការគំរូ*នេះ កំពុងត្រូវបានអនុវត្ត នៅក្នុងសាលាដំបូង ចំនួន ៤ ៖

- សាលាដំបូងខេត្តកណ្តាល ។
- សាលាដំបូងរាជធានីភ្នំពេញ ។
- សាលាដំបូងខេត្តកំពង់ចាម ។
- សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៤២. គម្រោងបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានអនុវត្ត ដោយ *ក្រសួងយុត្តិធម៌* និង *ក្រសួងមហាផ្ទៃ* ដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿង នៅសាលាដំបូងខេត្ត និង ដើម្បីជំរុញល្បឿននៃការដោះ-ស្រាយវិវាទ ជូនប្រជាពលរដ្ឋនិងជនក្រីក្រ ឱ្យបានឆាប់រហ័ស ។ *ក្រសួងយុត្តិធម៌* និង *ក្រសួងមហាផ្ទៃ* បានសហការបង្កើត *មជ្ឈមណ្ឌលសេវាយុត្តិធម៌* ថ្នាក់ស្រុកសាកល្បង ចំនួន ២០ កន្លែង ដែលបានដំណើរការ ចាប់តាំងពីឆ្នាំ ២០០៧ ។ ក្នុងករណីដែលយន្តការទាំងនេះ ដំណើរការទៅប្រកបដោយជោគជ័យ នោះយន្តការទាំងនេះ នឹងអាចពង្រីកនៅទូទាំងប្រទេស ។

៤៣. ច្បាប់ទាំងឡាយ ត្រូវបានផ្សព្វផ្សាយ ដល់សហគមន៍នានា និងប្រជាជនក្រីក្រ ។ ចាប់ពីឆ្នាំ២០០៧ មក *ក្រសួងយុត្តិធម៌* បានធ្វើការផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ តាមទូរទស្សន៍និងវិទ្យុ ចំនួន ៥២០លើក ។ សិក្ខាសាលាស្ដីពីច្បាប់នានា ត្រូវបានធ្វើឡើង ចំនួន ២៤លើក នៅរាជធានី និងតាមបណ្ដាខេត្ត ហើយ ឯកសារច្បាប់ចំនួន ៤.២០០ក្បាល ត្រូវបានបោះពុម្ពផ្សាយ ។

៤៤. ការបណ្ដុះបណ្ដាលស្ដីពីច្បាប់នានា ត្រូវបានរៀបចំធ្វើឡើងចំនួន ២៤វគ្គ ដើម្បីពង្រឹង សមត្ថភាពនិងសីលធម៌របស់ ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីច្បាប់ និងក្រឡាបញ្ជី ។

៤៥. ទោះបីជា កិច្ចខិតខំប្រឹងប្រែងក្នុងកំណែទម្រង់នេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈ *កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ* ក៏ដោយ ក៏ការងារកំណែទម្រង់នេះ បានជួបប្រទះនឹងបញ្ហាជាច្រើនផងដែរ ។ ការរៀបចំធ្វើសេចក្ដីព្រាងច្បាប់មួយចំនួន ដូចជា *ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា* និង *ច្បាប់ស្ដីពីការចាត់តាំងអង្គការតុលាការនិងអយ្យការ* នៅមិនទាន់សម្រេចបាន តាមផែនការដែលបានគ្រោងទុក នៅឡើយ ដោយសារច្បាប់ទាំងនេះ មានទំនាក់ទំនងជាមួយគ្នា ហើយ ត្រូវយកទៅធ្វើការពិភាក្សាបន្ថែមទៀត ។ ការរៀបចំ *សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ច្បាប់ស្ដីពីលក្ខន្តិកៈសារការី* និង *ច្បាប់ស្ដីពីអាជ្ញាសាលា* អាចដំណើរការទៅបាន លុះត្រាតែច្បាប់គោលបានចូលជាធរមាន ជាមុនសិន ។ បញ្ហាប្រឈមផ្សេងៗទៀត ដែលវិស័យនេះបានជួបប្រទះ កន្លងមក រួមមាន :

- ការលំបាកផ្នែកថវិកា ដើម្បីពង្រីកកម្មវិធីនានា ក្នុងគោលដៅ បង្កើនការយល់ដឹងអំពីច្បាប់របស់សហគមន៍ និងក្រុមជនងាយរងគ្រោះទាំងឡាយ ក៏ដូចជា បង្កើតកម្មវិធីបណ្ដុះបណ្ដាល ដើម្បីពង្រឹងសមត្ថភាពរបស់ចៅក្រមនិងព្រះរាជអាជ្ញា ។
- *ក្រសួងយុត្តិធម៌* ពុំមានធនធានគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់នូវតម្រូវការផ្នែក សម្ភារបរិក្ខារ អគារ និងបន្ទប់សវនាការ ឱ្យដល់តុលាការនិងអយ្យការ ទៅតាមតម្រូវការ នៅតាមបណ្ដាខេត្ត ។

- ការបង្កើតតុលាការឯកទេសពិសេស មានភាពយឺតយ៉ាវ ដោយសារការរង់ចាំ ការអនុម័តលើ *ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនិងអយ្យការ* ។
- ធនធាន មានពុំគ្រប់គ្រាន់ សម្រាប់កិច្ចដំណើរការរបស់តុលាការគំរូ ។
- ធនធាន មានពុំគ្រប់គ្រាន់ សម្រាប់ការបោះពុម្ពផ្សព្វផ្សាយ ច្បាប់និងសេចក្តីសម្រេចរបស់តុលាការ ។

## ១.៣ កំណែទម្រង់រដ្ឋបាលសាធារណៈ

៤៦. អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ មានសារៈសំខាន់ណាស់ នៅក្នុងការឈានទៅសម្រេចបាននូវការងារអាទិភាពនានា របស់*រាជរដ្ឋាភិបាល* ។ រដ្ឋបាលសាធារណៈ គឺជាឧបករណ៍យុទ្ធសាស្ត្រមួយ ក្នុងចំណោមយុទ្ធសាស្ត្រដទៃទៀត នៅក្នុងការអនុវត្ត ការងារកំណែទម្រង់របស់*រាជរដ្ឋាភិបាល* ។ ចាប់តាំងពីឆ្នាំ ២000 មក *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល* បានអនុវត្តជាបន្តបន្ទាប់នូវ *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល* ដើម្បីបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង ។

៤៧. កិច្ចខិតខំប្រឹងប្រែងនៅក្នុងការងារកំណែទម្រង់នេះ ត្រូវបានធ្វើឱ្យលេចឡើងជាផ្លែផ្កា នៅក្នុងបរិបទនៃការអនុវត្ត *ផែនការសកម្មភាពអភិបាលកិច្ច* ជាបន្តបន្ទាប់ សំដៅជួយសម្រួលឱ្យមានកិច្ចសហការ នៅក្នុងចំណោមការងារកំណែទម្រង់ថ្នាក់ជាតិ និង កំណែទម្រង់តាមវិស័យ ។ *ផែនការសកម្មភាពអភិបាលកិច្ច* បានគ្របដណ្តប់យ៉ាងទូលំទូលាយ លើការងារកំណែទម្រង់នានា រួមមាន *កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* និង កំណែទម្រង់នានាដែលពាក់ព័ន្ធនឹង ការវិនិយោគនិងពាណិជ្ជកម្ម ការអភិវឌ្ឍ-សង្គមកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ ។ ជាច្រើនឆ្នាំកន្លងមកនេះ សមិទ្ធផលចម្បងៗជាច្រើន ត្រូវសម្រេចបាន ដោយផ្អែកលើគោលការណ៍អភិបាលកិច្ចលើគ្រប់វិស័យ ដូចដែលបានកំណត់នៅក្នុង *ផែនការសកម្មភាពអភិបាលកិច្ច* ដើម្បីគាំទ្រឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព យុត្តិធម៌សង្គម និងការកាត់បន្ថយភាពក្រីក្រ ។ ដោយមានកិច្ចសហការជាមួយ បណ្តាក្រសួង-ស្ថាប័ន *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល* កំពុងរៀបចំ *ផែនការសកម្ម-ភាពអភិបាលកិច្ចទី៣* ដែលនឹងត្រូវផ្តោតទៅលើវិធីសាស្ត្រក្នុងការកែលម្អការផ្តល់សេវាកម្មសាធារណៈ និងកិច្ចសម្របសម្រួលរវាង កំណែទម្រង់អន្តរវិស័យ និង កំណែទម្រង់តាមវិស័យ ។

៤៨. ប្រការសំខាន់ដែលយើងទាំងអស់គ្នាត្រូវកត់សម្គាល់ នោះគឺថា រដ្ឋបាលសាធារណៈឯកភាពជាតិក្នុងឯកត្តរដ្ឋនាពេលបច្ចុប្បន្ននេះ ទើបតែមានអាយុ ១០ឆ្នាំប៉ុណ្ណោះ និងជាលទ្ធផលដែលបានមកពីសន្តិភាព និងការផ្សះផ្សាបង្រួបបង្រួមជាតិ ។ នៅដើមនីតិកាលទី២ នៃរដ្ឋសភា (១៩៩៨-២០០៣) *រាជរដ្ឋាភិបាលកម្ពុជា* បានសម្រេចដោយជោគជ័យ ក្នុងការធ្វើសមាហរណកម្មរដ្ឋបាលនៃភាគីនយោបាយដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាព

ទីក្រុងប៉ារីស បញ្ចូលទៅក្នុងរដ្ឋបាលសាធារណៈតែមួយរបស់ជាតិ និងមានលក្ខណៈឯកភាពជាតិ ។ ប្រការនេះបានអនុញ្ញាតឱ្យ *រាជរដ្ឋាភិបាលកម្ពុជា* អាចធ្វើការគ្រប់គ្រង និងដឹកនាំប្រទេសបានពេញលេញជាលើកដំបូងបង្អស់ក្នុងអំឡុងពេលជាង ៤០០ឆ្នាំ ចុងក្រោយនេះ ព្រមទាំងបានចាប់ផ្តើមអនុវត្តផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន ។

៤៩. នៅក្នុង *នីតិកាលទី៣ នៃរដ្ឋសភា* (២០០៣-២០០៨) *រាជរដ្ឋាភិបាលកម្ពុជា* បានពន្លឿនការអនុវត្តកម្មវិធីកំណែទម្រង់នានាឱ្យកាន់តែលឿនថែមទៀត ដើម្បីឱ្យសមស្របតាមតម្រូវការរបស់ប្រទេស ។ តាមរយៈការអនុវត្តប្រកបដោយភាពម៉ឺងម៉ាត់នូវ *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល* *រាជរដ្ឋាភិបាលកម្ពុជា* បានខិតខំប្រឹងប្រែង ក្នុងការប្រែក្លាយរដ្ឋបាលសាធារណៈឱ្យក្លាយទៅជាអ្នកផ្តល់សេវាសាធារណៈដ៏ស័ក្តិសិទ្ធិ ។ *រាជរដ្ឋាភិបាលកម្ពុជា* មានជំនឿយ៉ាងមុតមាំថា រដ្ឋបាលសាធារណៈមួយដែលដំណើរការល្អ និងមានគណនេយ្យភាព ពិតជាមានសារៈសំខាន់ និងមានភាពចាំបាច់ក្នុងការធានាបាននូវ សុខសន្តិភាព ស្ថិរភាពនយោបាយ ការអភិវឌ្ឍប្រកបដោយចីរភាព យុត្តិធម៌សង្គម និង ការកាត់បន្ថយភាពក្រីក្រ ។ រហូតមកទល់ពេលនេះ កម្ពុជាបានទទួលនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការប្រែក្លាយរដ្ឋបាលសាធារណៈឱ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងការងារប្រឈមជាច្រើន នៅក្នុងចរន្តនៃសកលភាវូបនីយកម្ម ។ នៅពេលដែលវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសកលលោក កំពុងនៅតែបន្តកើតមាន ហើយបាននិងកំពុងជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជានោះ ការពង្រឹងរដ្ឋបាលសាធារណៈឱ្យកាន់តែល្អប្រសើរថែមទៀត គឺជាការងារដែលត្រូវធ្វើជាបន្ទាន់ ផងដែរ ។

៥០. ដោយមានកិច្ចសហប្រតិបត្តិការជាមួយ ក្រសួង-ស្ថាប័ននិងដៃគូអភិវឌ្ឍន៍នានា *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល* បានសម្រេចបាននូវ សមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ ដូចជា :

- ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងប្រព័ន្ធតែមួយ ដែលមានលក្ខណៈអំណោយផល ក្នុងការលើកទឹកចិត្ត និង ការវិវត្តអាជីព ។
- ប្រាក់បៀវត្សរ៍មធ្យម និងប្រាក់ឧបត្ថម្ភ នៅក្នុងមុខងារសាធារណៈ បានកើនឡើងចំនួន ៤ ដង ចាប់តាំងពីដើមនីតិកាលទី២ នៃរដ្ឋសភា ។
- បង្កើតប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារនិងគណនេយ្យភាព ដើម្បីគាំទ្រដល់ការអនុវត្តឧបករណ៍គ្រប់គ្រង ប្រសិទ្ធភាពការងារនិងគណនេយ្យភាព ដូចជា *ទីភ្នាក់ងារប្រតិបត្តិការពិសេស* ជាដើម ។
- *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល* កំពុងតែដើរតួយ៉ាងសំខាន់ ក្នុងការធ្វើសុខដុមនីយកម្ម និងការតម្រឹម ដើម្បីអនុវត្ត *សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស* និង *ផែនការសកម្មភាពទីក្រុងអាក់ក្រា* ។
- ការតម្រង់ទិសច្បាស់លាស់ និងការព្រមព្រៀងគ្នាយ៉ាងទូលំទូលាយ ក្នុងការរិះរកវិធីសាស្ត្រល្អៗ សម្រាប់យកមកអនុវត្ត ។

៥១. លទ្ធផលដូចខាងក្រោមនេះ បង្ហាញពីសមិទ្ធផលនានា ដែលបានរួមចំណែកក្នុងការកសាងសមត្ថភាព ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន នៅក្នុងរដ្ឋបាលសាធារណៈ :

- ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិនានា ដែលត្រូវបានប្រើប្រាស់ នៅក្នុងមុខងារសាធារណៈ រួមមាន *ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល* និង *លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំង២១*។
- ប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យ ដែលមានលក្ខណៈប្រតិបត្តិការនិងមានប្រសិទ្ធភាព (ដូចជា ការជ្រើសរើស ការតែងតាំង និងការចូលនិវត្តន៍ ជាដើម) ។
- ការដាក់ឱ្យប្រើប្រាស់តារាងទូទាត់បៀវត្សរ៍តាមប្រព័ន្ធព័ត៌មានវិទ្យា ។
- ប្រព័ន្ធលាភការថ្មីត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្ត ហើយប្រាក់បៀវត្សរ៍មធ្យមរបស់មន្ត្រីរាជការស៊ីវិល បានកើនឡើង ដល់ ៨១,៤ ដុល្លារ នៅក្នុងខែឧសភា ឆ្នាំ២០០៩ ។
- យន្តការអនុវត្ត ការដំឡើងប្រាក់បៀវត្សរ៍មូលដ្ឋាន ២០ភាគរយ ប្រចាំឆ្នាំ ជូនមន្ត្រីរាជការស៊ីវិល ត្រូវបានដាក់ឱ្យដំណើការ តាមគោលនយោបាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។
- ដាក់ឱ្យអនុវត្តយន្តការផ្តល់សេវាសាធារណៈ សំដៅពង្រឹង តម្លាភាព គុណភាព ប្រសិទ្ធភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈ ( *ទីភ្នាក់ងារប្រត្តិបត្តិការពិសេស*) ។
- ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីកៀរគរធនធានមនុស្សឱ្យបានល្អប្រសើរ និងកំណត់អំពីតម្រូវការអាទិភាព នៅក្នុងការអភិវឌ្ឍសមត្ថភាព ។
- គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ត្រូវបានអនុម័ត និងកំពុងជំរុញការអនុវត្ត ។
- កម្រងព័ត៌មានសេវាសាធារណៈ កំពុងរៀបចំចងក្រងឡើង និងត្រូវធ្វើការផ្សព្វផ្សាយ ដើម្បីកែលម្អលទ្ធភាពទទួលបានសេវាសាធារណៈ និង ដើម្បីលើកកម្ពស់តម្លាភាព ។
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានដាក់ឱ្យដំណើរការ ហើយយន្តការគ្រប់គ្រងបុគ្គលិក ត្រូវបានពង្រឹងជាបន្តបន្ទាប់ ។
- ដាក់ឱ្យអនុវត្តប្រព័ន្ធប្រាក់បំណាច់មុខងារ សម្រាប់ថ្នាក់ដឹកនាំគ្រប់គ្រង និងមន្ត្រីជំនាញ ។
- ឧបករណ៍ទំនាក់ទំនងព័ត៌មាន (ព្រឹត្តិបត្រព័ត៌មាន គេហទំព័រ សិក្ខាសាលា) ត្រូវបានបង្កើតឡើង និងដាក់ឱ្យ ដំណើរការ ដើម្បីផ្តល់ព័ត៌មានអំពីការងារកំណែទម្រង់រដ្ឋបាល ។

## កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

៥២. គោលដៅអភិវឌ្ឍន៍រយៈពេលវែងនៃ *យុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ* របស់*រាជរដ្ឋាភិបាល* គឺការអភិវឌ្ឍយ៉ាងទូលំទូលាយ និងប្រកបដោយចីរភាព ការពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ខឿនសេដ្ឋកិច្ច ប្រកបដោយភាពស្វាហាប់នៅមូលដ្ឋាន ដែលប្រជាពលរដ្ឋគ្រប់រូប មានកាលានុវត្តភាពស្មើៗគ្នា ក្នុងការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍

មូលដ្ឋាន ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព ដើម្បីឆ្លើយតបនឹងតម្រូវការ របស់ប្រជាពលរដ្ឋ និងការចូលរួមកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ដោយផ្តោតជាសំខាន់ទៅលើក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច ស្ត្រី និង កុមារ ។ *រាជរដ្ឋាភិបាល* ជឿជាក់ថា ការបង្កើត និង ការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ នឹងអាចសម្រេចបានយ៉ាងប្រសើរនូវការពង្រឹងអភិបាលកិច្ច តាមបែបប្រជាធិបតេយ្យនៅកម្ពុជា ។ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ មានគោលដៅជាយុទ្ធសាស្ត្រ ពីរ យ៉ាងគឺ (១) ការពង្រឹងនិងពង្រីក លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន (២) ការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និង ការកាត់បន្ថយភាពក្រីក្រ ។

៥៣. *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងអនុវត្ត *កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* ក្នុងគោលបំណងសម្រេច ឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការពង្រឹង និងពង្រីកនូវការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ។ ដើម្បីអនុវត្ត *កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* គណៈកម្មាធិការអន្តរក្រសួងមួយ គឺ *គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)* ដែលដឹកនាំដោយក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ ការណែនាំរួមនិងការសម្របសម្រួល ដល់ការអនុវត្តកំណែទម្រង់នេះ ។ នៅក្នុងខែឧសភា ឆ្នាំ២០០៨ កន្លងមកនេះ *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ* និង *ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ* ត្រូវបានអនុម័ត ។ បច្ចុប្បន្ននេះ *គ.ជ.អ.ប* កំពុងរៀបចំក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តមួយ ដើម្បីអនុវត្តច្បាប់នេះ ជាពិសេស ក្នុងការរៀបចំលិខិតបទដ្ឋាននានា សម្រាប់ការកំណត់ព្រំប្រទល់ថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានសម្រាប់កំណត់ចំនួនសមាជិកក្រុមប្រឹក្សាតាមលំដាប់ថ្នាក់ ដែលត្រូវបោះឆ្នោតជ្រើសរើស ។

៥៤. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី១ បានធ្វើឡើង កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ ។ ពិធីប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សាអាណត្តិទី១ និងគណៈអភិបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ក៏បានប្រារព្ធធ្វើជាផ្លូវការ នៅដើមខែមិថុនា ឆ្នាំ២០០៩ ដើម្បីធានា និរន្តរភាពនិងប្រសិទ្ធភាព និងភាពរឹងមាំ របស់រដ្ឋបាលសាធារណៈ ។ គោលបំណងនៃការបង្កើត ក្រុមប្រឹក្សារដ្ឋបាលនានា នៅថ្នាក់ក្រោមជាតិ តាមរយៈការបោះឆ្នោតសកលនិងអសកល គឺ (ទី១) បង្កើតកាលានុវត្តភាពនិងយន្តការ សម្រាប់ក្រុមប្រឹក្សាទាំងនោះ ធ្វើការសម្រេចលើអនាគតនៃសហគមន៍របស់ខ្លួន តាមរយៈ ការពិគ្រោះយោបល់ ដោយមានការចូលរួម ជាមួយនឹងប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន និង (ទី២) ធានាឱ្យមានការផ្តល់នូវ សេវាកម្ម សាធារណៈ សម្ភារៈ មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធ ជាមូលដ្ឋាននានា ដែលមានលក្ខណៈល្អប្រសើរជាងមុន ទាំងបរិមាណ

និងគុណភាព និងមានការឆ្លើយតបប្រសើរជាងមុន ដើម្បីបំពេញបានយ៉ាងឆាប់រហ័ស និងប្រកបដោយសមធម៌ ចំពោះតម្រូវការក្នុងការអភិវឌ្ឍមូលដ្ឋាន និង ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ។ មកទល់ពេលនេះ *រាជរដ្ឋាភិបាល* បានបង្កើតឡើងនូវ រចនាសម្ព័ន្ធស្ថាប័នរដ្ឋបាល នៅគ្រប់កម្រិតទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈ គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ។

៥៥. ទន្ទឹមនឹងនេះ *គ.ជ.អ.ប* កំពុងធ្វើការសម្របសម្រួល ការគាំទ្រនិងជំនួយផ្នែកបច្ចេកទេស សំដៅពង្រឹងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីឱ្យគាត់អាចគ្រប់គ្រងការងារនៅក្នុងមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព ស្របតាមគោលបញ្ញត្តិទាំងឡាយ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ-សង្កាត់ ។ ជាមួយគ្នានេះ *គ.ជ.អ.ប* ក៏កំពុងរៀបចំ *កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* ដែលនឹងកំណត់នូវផែនការសកម្មភាពសម្រាប់ការអនុវត្ត *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* និង គោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ សម្រាប់ រយៈពេលខ្លី រយៈពេលមធ្យម និង រយៈពេលវែង ដែលនឹងត្រូវអនុវត្ត ពី ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៩ ។ ដំណើរការនៃការរៀបចំកម្មវិធីជាតិនេះ ត្រូវបានបញ្ចប់នាដំណាច់ឆ្នាំ២០០៩ ។ *កម្មវិធីជាតិ* នេះ នឹងកំណត់នូវក្របខ័ណ្ឌពេលវេលា សម្រាប់ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការអនុវត្ត *ច្បាប់គ្រប់គ្រងរដ្ឋបាលថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* ។

៥៦. ទោះបីជា មានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និង ការសម្រេចបាននូវសមិទ្ធផលធំៗ នៅក្នុងការបំពេញភារកិច្ចកន្លងមកក៏ដោយ ក៏យើងនៅតែជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដែលត្រូវបន្តដោះស្រាយ ក្នុងនោះមានជាអាទិ៍ គុណភាពនិងប្រសិទ្ធភាពនៃការងារសម្របសម្រួល ការផ្តល់សេវាកម្មសាធារណៈ ដែលនៅតែមានកម្រិត និង មិនទាន់អាចឆ្លើយតបបានសមស្រប ទៅនឹងតម្រូវការជាក់ស្តែង នៅឡើយ ។ ធនធានមនុស្ស និងសម្ភារៈ សម្រាប់ការបំពេញភារកិច្ចដែលបានកំណត់ នៅមានកម្រិតនៅឡើយ ។ ការកសាងក្របខ័ណ្ឌច្បាប់ ដែលចាំបាច់សម្រាប់ កំណែទម្រង់នេះ នៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ នៅឡើយ ។

៥៧. តាមគោលការណ៍អភិបាលកិច្ចវិមជ្ឈការតាមបែបប្រជាធិបតេយ្យ ទស្សនវិស័យរយៈពេលវែង សម្រាប់ប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សថ្មីមួយ សម្រាប់រដ្ឋបាលមូលដ្ឋាន គឺត្រូវរៀបចំឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នីមួយៗមានលទ្ធភាពទទួលខុសត្រូវទាំងស្រុង ក្នុងការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដោយប្រើប្រាស់នូវប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សមួយ មានប្រសិទ្ធភាពនិងសមត្ថភាពគ្រប់គ្រាន់ ដែលត្រូវបង្កើតឡើង ដោយក្រុមប្រឹក្សានីមួយៗផ្ទាល់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្នុងទិដ្ឋភាពជាក់ស្តែង យើងត្រូវប្រើប្រាស់ពេលវេលាយ៉ាងហោចណាស់ក៏មួយទសវត្សរ៍ ឬ ច្រើនជាងនេះ ដើម្បីឱ្យក្រុមប្រឹក្សានីមួយៗ អាចមានលទ្ធភាពពេញលេញ ក្នុងការទទួលខុសត្រូវ លើការអភិវឌ្ឍធនធានមនុស្ស ដល់មន្ត្រីក្រោមឱវាទរបស់ខ្លួនបាន។ អាស្រ័យហេតុនេះ តួនាទីរបស់ *គ.ជ.អ.ប* នៅតែមានជាបន្ត ក្នុងការគាំទ្រដល់ការកសាងសមត្ថភាពធនធានមនុស្ស របស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ សម្រាប់រយៈពេលយ៉ាងតិចមួយទសវត្សរ៍ទៅមុខ ។

## ១.៤ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

៥៨. កំណែទម្រង់*កងយោធពលខេមរភូមិន្ទ* ដែលជាមុំមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ទាមទារនូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ពីសំណាក់*កងយោធពលខេមរភូមិន្ទ* នៅក្នុងកំណែទម្រង់របស់ខ្លួន ដើម្បីធានាឱ្យបានទាំងស្រុងនូវ សន្តិភាព ស្ថិរភាព សន្តិសុខ អធិបតីភាព បូរណភាពទឹកដី និងការអភិវឌ្ឍប្រទេស ជាតិ ។ ដោយផ្អែកលើ គោលនយោបាយការពារជាតិរបស់*រាជរដ្ឋាភិបាលកម្ពុជា* កំណែទម្រង់និងការបន្តលើកកម្ពស់សមត្ថភាពកងយោធពលខេមរភូមិន្ទ កំពុងត្រូវបានដំណើរការទៅតាមផែនការ ប្រកបដោយប្រសិទ្ធភាព ។ សមាមាត្ររបស់វិស័យសន្តិសុខនិងការពារជាតិ ក្នុងផលិតផលក្នុងស្រុកសរុប មានស្ថិរភាពក្នុងកម្រិតប្រហែល ២ភាគរយ (១,៨ ភាគរយ នៅក្នុង ឆ្នាំ២០០៥ ឆ្នាំ២០០៦ និង ឆ្នាំ២០០៧) ហើយត្រូវបានរំពឹងថា នឹងមានកម្រិត ១,៧ ភាគរយ នៅក្នុងឆ្នាំ២០១០ ។ សមាមាត្ររបស់វិស័យសន្តិសុខនិងការពារជាតិ ក្នុងថវិកាជាតិ បានថយចុះជាបន្តបន្ទាប់ (ពី ២២,៩៣ ភាគរយ ក្នុងឆ្នាំ២០០៥ មកត្រឹម ១៨,៨៧ ភាគរយ ក្នុងឆ្នាំ២០០៧) ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធានាថា ជានិច្ចកាល កងកម្លាំងប្រដាប់អាវុធ ត្រូវបានត្រៀមខ្លួនរួចជាស្រេច ដើម្បីការពារបូរណភាពទឹកដី របស់*ព្រះរាជាណាចក្រកម្ពុជា* តាមរយៈ ការបែងចែកថវិកាដែលចាំបាច់សម្រាប់វិស័យនេះ ដោយមិនមានការកាត់បន្ថយនូវសមាមាត្រនៃចំណាយថវិកា ដែលកំពុងកើនឡើង សម្រាប់ការអភិវឌ្ឍនិងសម្រាប់វិស័យសង្គមកិច្ច ។

៥៩. នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទិដ្ឋភាពផ្នែកសន្តិសុខរបស់*ព្រះរាជាណាចក្រកម្ពុជា* មានការផ្លាស់ប្តូរ ដោយសារឥទ្ធិពលនៃការវិវត្តរបស់សភាពការណ៍ សន្តិសុខពិភពលោកនិងក្នុងតំបន់ ។ នៅក្នុងស្ថានភាពបច្ចុប្បន្ននៃកត្តាក្រៅប្រទេស *កងយោធពលខេមរភូមិន្ទ* កាន់តែដើរតួនាទីសំខាន់ខ្លាំងឡើងៗ ជាកម្លាំងឈានមុខនៅក្នុងការការពារ ឯករាជភាព អធិបតីភាព និងបូរណភាពទឹកដីនៃ*ព្រះរាជាណាចក្រកម្ពុជា* និង ការរួមចំណែកក្នុងការធានាឱ្យមាន ស្ថិរភាព សុវត្ថិភាព និងសន្តិសុខ ។ លើសពីនេះទៅទៀត *កងយោធពលខេមរភូមិន្ទ* បានរួមចំណែក នៅក្នុងការលើកតម្កើងកិត្យានុភាពរបស់កម្ពុជា នៅលើឆាកអន្តរជាតិ តាមរយៈ ការចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពមនុស្សធម៌អន្តរជាតិ នៅក្នុងក្របខ័ណ្ឌនៃសំណូមពររបស់*អង្គការសហប្រជាជាតិ* ការត្រៀមរៀបចំធ្វើជាម្ចាស់ផ្ទះ សម្រាប់ *លំហាត់ហ្វឹកហ្វឺនប្រតិបត្តិការសន្តិភាពពហុសាសន៍ ឆ្នាំ២០១០* ព្រមទាំង ការប្តេជ្ញាចិត្តយ៉ាងមុះមុត ក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ។ ក្រោយពេលដែលមានសន្តិភាពពេញលេញ ចាប់តាំងពីចុងឆ្នាំ១៩៩៨ មក *កងយោធពលខេមរភូមិន្ទ* បាននិងកំពុងរួមចំណែកយ៉ាងច្រើន នៅក្នុងការពង្រឹង ស្ថិរភាព និងសន្តិសុខផ្ទៃក្នុង សំដៅគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិ។

៦០. *កំណែទម្រង់កងយោធពលខេមរភូមិន្ទ* នៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ បាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន នៅក្នុងស្ថានភាពមួយដែលមិនមានអំណោយផលល្អ ក្នុងការធ្វើឱ្យសម្រេចបាននូវ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល នៅក្នុងការងារកំណែទម្រង់នេះ ។ នៅក្នុងខណៈដែលទើបតែងើបចាកផុតពីសង្គ្រាម

ដំណើរការនៃកំណែទម្រង់ បាននិងកំពុងជួបប្រទះនឹងការលំបាកដែលកើតមានឡើងជាបន្តបន្ទាប់ ដូចជា កង្វះខាតធនធាន រចនាសម្ព័ន្ធមិនទាន់សមស្រប ការិយាធិបតេយ្យស្មុគ្រស្មាញ ការលំបាកនានាជុំវិញ បញ្ហាជំរំជម្រកនិងជីវភាពរស់នៅ របស់យោធិន ជាដើម ។

៦១. ទោះជាដូចនេះក្តី ក៏ *កងយោធពលខេមរភូមិន្ទ* សម្រេចបាននូវជោគជ័យមួយចំនួនធំ នៅក្នុងដំណើរការនៃកំណែទម្រង់របស់ខ្លួន ។ ក្រៅពីការធានាបាននូវសុខសន្តិភាពជូនប្រទេសជាតិ *កងយោធពលខេមរភូមិន្ទ* បានរួមចំណែកយ៉ាងសកម្ម នៅក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលជួបគ្រោះមហន្តរាយ ហើយ ចាប់ពីខែមេសា ឆ្នាំ២០០៦ មក បាននិងកំពុងរួមចំណែក នៅក្នុងបេសកកម្មសន្តិភាពមនុស្សធម៌របស់អង្គការសហប្រជាជាតិ ។ ថ្វីត្បិតតែសមត្ថភាពនិងធនធានរបស់*កងយោធពលខេមរភូមិន្ទ* នៅមានកម្រិត *កម្ពុជា* នឹងបន្តខិតខំចូលរួមជាមួយ អង្គការសហប្រជាជាតិ នៅក្នុងបេសកកម្មរក្សាសន្តិភាព ដែលមានលក្ខណៈមនុស្សធម៌ផ្សេងៗទៀត នាពេលអនាគត ។ នៅពេលដែលវិវាទអំពីបញ្ហាព្រំដែន ការគំរាមកំហែងពីសំណាក់ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែន និងអំពើភេរវកម្មអន្តរជាតិ បានក្លាយជាកង្វល់ចម្បងមួយ ក្នុងពេលថ្មីៗនេះ នោះ *កងយោធពលខេមរភូមិន្ទ* បានពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការការពារព្រំដែននៃ*ព្រះរាជាណាចក្រកម្ពុជា* និង ក្នុងការរក្សាសន្តិសុខសម្រាប់ប្រជាជាតិទាំងមូល ផងដែរ ។ សមត្ថភាពរបស់កងកម្លាំងការពារព្រំដែន ត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈ វត្តមានរបស់កម្លាំងប្រដាប់អាវុធនៅគ្រប់គោលដៅជាយុទ្ធសាស្ត្រទាំងអស់ ការពង្រឹងចំណេះដឹងជំនាញ ក្នុងការទប់ស្កាត់ការជ្រៀតចូលនៃភេរវកម្មអន្តរជាតិនិងឧក្រិដ្ឋកម្មឆ្លងដែន ការចល័តកម្លាំងការទាក់ទង ការប្រមូលព័ត៌មាន និងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ។ ការពង្រឹងនូវ វត្តមាននិងសមត្ថភាពរបស់ *កងយោធពលខេមរភូមិន្ទ* សម្រាប់ការការពារព្រំដែន ត្រូវបានធ្វើឡើង ទៅតាមគោលនយោបាយរបស់*រាជរដ្ឋាភិបាល* តាមរយៈ ការកសាង ជំរំជម្រកនិងបន្ទាយកងទ័ព ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងភូមិដ្ឋានសម្រាប់គ្រួសារកងទ័ពនិងប្រជាជនដើម្បីការអភិវឌ្ឍនៅតាមព្រំដែន ។ ការងារទាំងនេះ មិនមែនគ្រាន់តែដើម្បីការពារប្រទេសជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង រក្សាបាននូវ សន្តិភាព ស្ថិរភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសជិតខាង ដែលនៅតែជាអាទិភាពចម្បងនៃនយោបាយការបរទេសរបស់*ព្រះរាជាណាចក្រកម្ពុជា* ។

៦២. បើទោះជាមានវឌ្ឍនភាពគួរជាទីមោទនៈ នៅក្នុងដំណើរការនៃកំណែទម្រង់របស់ខ្លួនក៏ដោយ ក៏*កងយោធ-ពលខេមរភូមិន្ទ* នៅមានកិច្ចការធំៗជាច្រើនទៀត ដែលត្រូវបំពេញ ដើម្បីអនុវត្តវិធានការយុទ្ធសាស្ត្រទាំងឡាយដែលមានចែង នៅក្នុង *សៀវភៅសការពារជាតិ ឆ្នាំ២០០៦* ។

៦៣. ទន្ទឹមនឹងនេះ *ក្រសួងមហាផ្ទៃ* ក៏បានយកចិត្តទុកដាក់លើការងារពង្រឹង*កងកម្លាំងនគរបាលជាតិ* ក្នុងនោះរួមទាំង *កងកម្លាំងនគរបាលជាតិការពារព្រំដែន* ឱ្យមានសមត្ថភាពជំនាញវិជ្ជាជីវៈច្រើនជាងមុន ក្នុងកិច្ចការពារអធិបតេយ្យជាតិ និង ការធានានូវសន្តិសុខនិងសណ្តាប់ធ្នាប់ នៅក្នុងសង្គមជាតិទាំងមូល សំដៅរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ សមត្ថភាពជំនាញវិជ្ជាជីវៈ របស់កងកម្លាំងនគរបាលជាតិ

ទាំងមូល ត្រូវបានកែលម្អជាបន្តបន្ទាប់ តាមរយៈ ការរៀបចំវគ្គបណ្តុះបណ្តាលនានា ដល់មន្ត្រីនគរបាលជាតិ នៅ *បណ្ឌិតសភានគរបាលកម្ពុជា* ។ ទោះបីជា ការងារពង្រឹងសមត្ថភាពកងកម្លាំងនគរបាលជាតិ សម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ការលើកកម្ពស់បន្ថែមទៀតនូវសមត្ថភាពរបស់មន្ត្រីនគរបាលជាតិ នៅតែជាបញ្ហាប្រឈមមួយដែលត្រូវបន្តដោះស្រាយ ដើម្បីឆ្លើយតបនឹងការវិវត្តនៃសភាពការណ៍សន្តិសុខ ដែលកំពុងកើតមាន នៅក្នុងសង្គមជាតិទាំងមូល ក៏ដូចជា នៅក្នុងតំបន់និងក្នុងពិភពលោក ផងដែរ ។

## ២. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

៦៤. មានទិដ្ឋភាពសំខាន់ៗចំនួនបួន សម្រាប់ដោះស្រាយបញ្ហាទាំងនេះ គឺ *(១) សុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម (២) ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ (៣) បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និង (៤) សមាហរណកម្មប្រទេសកម្ពុជាក្នុងតំបន់និងពិភពលោក* ។

### ២.១ សុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម

៦៥. ទើបតែបានឆ្លងកាត់យុគសម័យនៃជម្លោះផ្ទៃក្នុងនិងវិនាសកម្ម អស់រយៈពេលជាងមួយទសវត្សរ៍ប៉ុណ្ណោះ *រាជរដ្ឋាភិបាលកម្ពុជា* ក៏អាចធានាបាននូវបរិយាកាស សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ដែលជាបុរេលក្ខខណ្ឌ សម្រាប់ធ្វើឱ្យសម្រេចបាននូវ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្រ ។ ការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់ *រាជរដ្ឋាភិបាលកម្ពុជា* ចំពោះ របបប្រជាធិបតេយ្យសេរីពហុបក្ស ការពិភាក្សាផ្លាស់ប្តូរយោបល់គ្នា និងការសម្របសម្រួលគ្នារវាងក្រុមជនដែលមានទស្សនៈ និងការយល់ដឹងខុសៗគ្នា កំពុងទទួលបានផ្លែផ្កាល្អប្រសើរ ។ ដំណើរការទាំងនេះ កំពុងចាក់ឫសយ៉ាងជ្រៅ នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។ ការលើកកម្ពស់ស្ថិរភាពនយោបាយ បានត្រួសត្រាយផ្លូវ សម្រាប់ការធ្វើឱ្យមានអភិបាលកិច្ចល្អប្រសើរជាងមុន ជាពិសេសដោយសារ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្នុងឆ្នាំ២០០៦ ដែលអនុញ្ញាតឱ្យច្បាប់ទាំងអស់ អាចត្រូវបានអនុម័តដោយសម្លេងឆ្នោតគាំទ្រភាគច្រើនដាច់ខាត ។ ដូច្នេះ ស្ថានភាពនេះ បានបំបាត់ចោលនូវឧបសគ្គដ៏ចម្បងមួយ ដែលបានរារាំង ដល់ការប្រព្រឹត្តទៅនៃដំណើរការអនុម័តច្បាប់នានា សំដៅធ្វើឱ្យមានលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវការជាបន្ទាន់សម្រាប់អភិបាលកិច្ចល្អ និងសំដៅបង្កើតឡើងនូវបរិស្ថានមួយ ដែលមានអំណោយផលល្អសម្រាប់ការអភិវឌ្ឍវិស័យឯកជន។ ក្រសួង-ស្ថាប័នទាំងអស់របស់*រាជរដ្ឋាភិបាលកម្ពុជា* បានរួមចំណែកគ្នា ធ្វើឱ្យមាន ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម ។ *ក្រសួងមហាផ្ទៃ* បានផ្តល់ការរួមចំណែកយ៉ាងច្រើន ក្នុងការធានានូវស្ថិរភាព ដូចដែលយើងមាន នាពេលបច្ចុប្បន្ននេះ ។ ដើម្បីពង្រឹងបន្ថែមទៀតនូវតួនាទីជាសារវន្ត នៃក្រុមគ្រួសារ និងសាសនា នៅក្នុងការកសាងរចនាសម្ព័ន្ធគ្រឹះរបស់សង្គមជាតិ *ក្រសួងធម្មការនិងសាសនា* បានបន្តផ្តល់ការរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់តម្លៃរបស់ក្រុមគ្រួសារ និងសាសនា ។

៦៦. បច្ចុប្បន្ននេះ ប្រពៃណីនៃការរៀបចំបោះឆ្នោត ដោយសេរីនិងយុត្តិធម៌ ត្រូវបានបង្កើតឡើង ឱ្យមានសភាពរឹងមាំល្អ ។ រហូតមកទល់នឹងពេលនេះ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានរៀបចំធ្វើឡើង បួនដងរួចមកហើយ ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយបង្អស់ ត្រូវបានរៀបចំធ្វើឡើង កាលពីថ្ងៃ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។ ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំងប្រទេស ត្រូវបានរៀបចំធ្វើឡើង ពីរដង រួចមកហើយ លើកទី១ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០២ និង លើកទី២ នៅក្នុងខែមេសា ឆ្នាំ២០០៧ ។ ព្រឹទ្ធសភាត្រូវបានបង្កើតឡើង ជាសភាជាន់ខ្ពស់ តាមរយៈ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៅខែមីនា ឆ្នាំ១៩៩៩ ។ ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា លើកទី១ ត្រូវបានធ្វើឡើង នៅក្នុងខែមករា ឆ្នាំ២០០៦ ។ បច្ចុប្បន្ននេះ យុគសម័យនៃស្ថិរភាពដ៏រឹងមាំមួយ ត្រូវបានបង្កើតឡើង ដោយមានការគិតគូរជាចម្បងលើ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ នៅក្នុងបរិស្ថានមួយ ដែលមានការទទួលខុសត្រូវចំពោះអ្វីទាំងឡាយ ដែលបុគ្គលម្នាក់ៗបានសម្តែងចេញមក ទាំងនៅក្នុងរង្វង់*រាជរដ្ឋាភិបាល* ទាំងនៅក្នុងរង្វង់សាធារណជន ។ *រាជរដ្ឋាភិបាល* នឹងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីធានាថា សមិទ្ធផលដែលសម្រេចបានដោយលំបាកនេះ បន្តរីកចម្រើន និងត្រូវបានធ្វើឱ្យជ្រួតជ្រាបយ៉ាងពេញលេញ នៅក្នុងសង្គមជាតិកម្ពុជា និង ផ្នត់គំនិតរបស់ប្រជាជនកម្ពុជា ។

៦៧. *ក្រសួងមហាផ្ទៃ* មានតួនាទីចម្បងបី : (១) គ្រប់គ្រងស្ថាប័នរដ្ឋបាលសាធារណៈ នៅថ្នាក់ក្រោមជាតិ (២) ការធានានូវសន្តិសុខផ្ទៃក្នុងរបស់សង្គមជាតិ តាមរយៈ កងកម្លាំងនគរបាលជាតិ និង (៣) ដឹកនាំនិងសម្របសម្រួលការអនុវត្ត*កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* របស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងឋានៈជាប្រធានរបស់*គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)* ។ រហូតមកទល់ពេលនេះ *ក្រសួងមហាផ្ទៃ* បានធ្វើឱ្យមានវឌ្ឍនភាពជាច្រើន នៅក្នុង ការពង្រឹងស្ថាប័នរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ការធានានូវសន្តិសុខផ្ទៃក្នុងរបស់សង្គមជាតិ និងការដាក់ឱ្យដំណើរការនូវយន្តការជាច្រើន ដើម្បីដឹកនាំដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ សំដៅធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍ តាមបែបប្រជា-ធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ។

៦៨. តាមរយៈ *កងកម្លាំងនគរបាលជាតិ ក្រសួងមហាផ្ទៃ* បានចូលរួមយ៉ាងសកម្ម នៅក្នុងការបញ្ជៀសនូវសកម្មភាពភេរវកម្មទាំងឡាយ ការរក្សាបាននូវសេចក្តីសុខក្សេមក្សាន្តជូនប្រជាពលរដ្ឋ ការទប់ស្កាត់នូវរាល់ឧបាយកលទាំងឡាយ ដែលប៉ុនប៉ងបំបែកបំបាក់សាមគ្គីភាពជាតិ និងបង្កអស្ថិរភាពនយោបាយនិងភាពចលាចលវឹកវរក្នុងសង្គម ព្រមទាំង ការរារាំងប្រកបដោយប្រសិទ្ធភាព នូវមហិច្ឆតាប៉ុនប៉ងប្រើប្រាស់ទឹកដី*កម្ពុជា* ដើម្បីបំផ្លិចបំផ្លាញប្រទេសជិតខាង ។ សមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ គឺ ការការពារបានទាំងស្រុង នូវសុវត្ថិភាពនិង សន្តិសុខសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ និង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ កន្លងទៅ ព្រមទាំង ការការពារបាននូវសុវត្ថិភាពនៃដំណើរការនៃ *អង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជា* ។

៦៩. តាមរយៈ *អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ* បានសហការជាមួយ *ក្រសួងយុត្តិធម៌* ដើម្បីរៀបចំសារាចរបស់ *រាជរដ្ឋាភិបាល-ក្រសួងមហាផ្ទៃ* និង ផែនការសកម្មភាព សម្រាប់ការទប់ស្កាត់និង ការបង្ក្រាបសកម្មភាព *"ក្រុមក្មេងទំនើង"* ។ តាមរយៈស្ថាប័នចំណុះនេះ *ក្រសួងមហាផ្ទៃ* ក៏បានរៀបចំ ផងដែរ នូវផែនការយុទ្ធសាស្ត្រស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ការធ្វើអាជីវកម្មលើពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងការពង្រឹងយន្តការដឹកនាំការអនុវត្តផែនការនេះ នៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ *ក្រសួងមហាផ្ទៃ* បានជំរុញការអនុវត្ត *ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក* សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។ *ក្រសួងមហាផ្ទៃ* បាននិងកំពុងអនុវត្ត *ប្រកាសអន្តរក្រសួង រវាង ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពី ការប្រមូល ការបែងចែក និង ការបង់ចូលថវិការដ្ឋ នូវចំណែកផាកពិន័យអន្តរកាលលើបទល្មើសចរាចរណ៍ផ្លូវគោក* ហើយបានសហការជាមួយនឹង *ក្រសួងសាធារណការនិងដឹកជញ្ជូន* រៀបចំសេចក្តីព្រាង *អនុក្រឹត្យស្តីពីការត្រួតពិនិត្យការដ្ឋាន ជួសជុល កែច្នៃ និងដំឡើងយានយន្តគ្រប់ប្រភេទ* ។

៧០. ទោះបីមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និង សមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ជាច្រើនក៏ដោយ ក៏ការអនុវត្តភារកិច្ចខាងលើនេះ នៅតែបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដែលត្រូវបានបង្កឡើងជាចម្បង ដោយភាពមានកម្រិតនៃសមត្ថភាពផ្នែកស្ថាប័ន ក្នុងនោះរួមមាន ធនធានមនុស្សនិងសម្ភារៈ និង ភាពមានកម្រិតនៃក្របខ័ណ្ឌច្បាប់ សម្រាប់តម្រង់ទិសដល់ការអនុវត្តភារកិច្ច ។ ការការពារបង្ការទប់ទល់នឹង អំពើភេរវកម្មអន្តរជាតិមកលើស្ថានទូត ស្ថានបេសកកម្ម គណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ ទេសចរបរទេស និងសហគ្រាសវិនិយោគ ដែលជាគោលដៅមួយចំនួន គឺជាអាទិភាពចម្បងមួយ របស់ *រាជរដ្ឋាភិបាលកម្ពុជា* ។ ភាពខ្វះចន្លោះ ដែលនៅមាននៅក្នុងប្រព័ន្ធការងាររបស់យើង ងាយនឹងអនុញ្ញាតឱ្យពួកឧក្រិដ្ឋជនឆ្លងដែន ដែលមានអង្គការចាត់តាំង ឆ្លៀតឱកាសប្រើប្រាស់គ្រប់រូបភាព ដើម្បីឆ្លងកាត់និងលាក់ខ្លួននៅ *កម្ពុជា* ដើម្បីគេចពីសំណាញ់ច្បាប់និងបន្តធ្វើសកម្មភាពឧក្រិដ្ឋនានា ។ ការងារគ្រប់គ្រងត្រួតពិនិត្យជនបរទេស នៅមិនទាន់ត្រូវបានអនុវត្តស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានឱ្យបានដល់កម្រិតមួយ ដែលការងារគ្រប់គ្រងត្រួតពិនិត្យនេះត្រូវតែមាន ដើម្បីរួមចំណែកដល់ការរក្សា សន្តិសុខជាតិ និងការទាញយកអត្ថប្រយោជន៍ ពីវត្តមានជនបរទេសនៅក្នុងប្រទេស សម្រាប់ការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ចរបស់ *កម្ពុជា* នៅឡើយ ។ ទោះបីជា បទល្មើសព្រហ្មទណ្ឌ បានថយចុះជាលំដាប់ក៏ដោយ ក៏សកម្មភាពប្លន់ប្រដាប់អាវុធ អំពើឃាតកម្ម ចរាចរណ៍ជួញដូរគ្រឿងញៀនខុសច្បាប់ ការរំលោភសេពសន្ថវៈ ការជួញដូរស្ត្រីនិងកុមារ ព្រមទាំងបទល្មើសប្រភេទផ្សេងៗទៀត ដូចជា បទល្មើសផ្នែកបច្ចេកវិទ្យា និងការលាងលុយកខ្វក់ ជាដើម នៅតែកើតមានឡើងជាញឹកញាប់ នៅឡើយ ។ គ្រោះថ្នាក់ចរាចរណ៍ នៅតែបានបន្តកើតឡើងជាញឹកញាប់ គួរឱ្យព្រួយបារម្ភ ។ ការងារគ្រប់គ្រងរដ្ឋបាល មានលក្ខណៈប្រឈមខ្លាំង នៅតាមទីប្រជុំជនធំៗ ដោយសារបាតុភាព បាត់សណ្តាប់ធ្នាប់ ដែលត្រូវបានបង្កឡើង ដោយក្រុម *ក្មេងទំនើង* នៅតាមទីសាធារណៈ អាហារដ្ឋាន និងក្លឹបកម្សាន្តរាត្រី ។ ប្រការនេះ បានជះឥទ្ធិពលអាក្រក់ដល់ស្រទាប់យុវជន ដោយធ្វើឱ្យមានការកើនឡើង នូវសកម្មភាពខុសឆ្គង ជាច្រើន និងបានធ្វើឱ្យពួកយុវជនទាំងនោះ បោះបង់ចោលការសិក្សារៀនសូត្ររបស់ខ្លួន ហើយឈានទៅដល់ការប្រព្រឹត្តនូវបទល្មើសផ្សេងៗ ។

## ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន

៧១. ដោយអនុវត្តតាម *ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២០០៥-២០១០* និងអនុសាសន៍ ណែនាំដ៏មានតម្លៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង ដោយមានការគាំទ្រពី លោកជំទាវបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* បានដឹកនាំនិងបង្កើន កិច្ចសហការជាពហុវិស័យជាមួយនឹង ស្ថាប័នជាតិ អន្តរជាតិ និង កម្លាំងសរុបរបស់សង្គម ដោយធ្វើឱ្យសម្រេចបាននូវសមិទ្ធផលមួយចំនួនគួរឱ្យកត់សម្គាល់ ដូចជា (១) ការយល់ដឹងអំពីបញ្ហាគ្រឿងញៀន (២) ការបង្ក្រាបបានទាន់ពេលវេលានូវការប៉ុនប៉ងប្រើប្រាស់ប្រទេសកម្ពុជាធ្វើជាកន្លែងផលិតគ្រឿងញៀន ព្រមទាំង ការបង្ក្រាប ការជួញដូរ ការចែកចាយ ការស្តុកទុក ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន (៣) ការបង្កើតមជ្ឈមណ្ឌលបណ្តោះអាសន្នសម្រាប់ អប់រំ បន្សាប ព្យាបាល អ្នកញៀនគ្រឿងញៀន មួយចំនួន ដោយមានការគាំទ្រពីមជ្ឈដ្ឋានប្រជាពលរដ្ឋទូទៅ និង សហគមន៍អន្តរជាតិ ។

៧២. ទន្ទឹមនឹងការសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* បាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ក្នុងនោះ រួមមាន :

- សមត្ថភាពធនធានមនុស្ស និងលទ្ធភាពផ្នែក មធ្យោបាយ សម្ភារៈ និងថវិកា របស់ស្ថាប័ន នៅមានកម្រិតនៅឡើយ ។
- សកម្មភាពនៃការលើកកម្ពស់ការយល់ដឹងអំពី បញ្ហាគ្រឿងញៀន និងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន (ការចាក់) នៅមិនទាន់បានអនុវត្តចំគោលដៅល្អ ។
- អ្នកប្រើប្រាស់គ្រឿងញៀនមួយចំនួន នៅពុំទាន់មានការភ្ញាក់រលឹកចូលរួមសហការ ក្នុងសកម្មភាពកាត់បន្ថយការប្រើប្រាស់គ្រឿងញៀន ។
- កង្វះយន្តការមួយសមស្រប សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ពីប្រសិទ្ធភាពនៃសកម្មភាពអប់រំផ្សព្វផ្សាយ ។
- ការយល់ដឹង និងសមត្ថភាព របស់មន្ត្រីអនុវត្តច្បាប់ នៅមានកម្រិត ។
- វិធីសាស្ត្រអប់រំ បន្សាប ព្យាបាល នៅក្នុងមណ្ឌលបណ្តោះអាសន្ន ពុំទាន់មានការឯកភាពគ្នា ជាពិសេស វិធីសាស្ត្រក្នុងផ្នែកវេជ្ជសាស្ត្រ ហើយ សមត្ថភាពនៃមណ្ឌល ក៏មិនទាន់ឆ្លើយតបចំពោះចំនួនអ្នក ដែលនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន ។
- យន្តការដើម្បីតាមដានត្រួតពិនិត្យ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្ម ចំនួនអ្នកលាប់ ចំនួនអ្នកវិលចូលទៅមណ្ឌលវិញ និងចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅមិនទាន់ដំណើរបានល្អ នៅឡើយ ។

## ២.២ សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក

៧៣. សមាហរណកម្មកម្ពុជានៅក្នុងក្របខ័ណ្ឌតំបន់ អនុតំបន់ និងសកលលោក បានចូលរួមចំណែក យ៉ាងសំខាន់ ក្នុងការលើកស្ទួយកិត្យានុភាពព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ និង បង្កលក្ខណៈអំណោយផលដល់ការស្វែងរកជំនួយអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជាផងដែរ ។ ក្នុងក្របខ័ណ្ឌ*សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)* កម្ពុជាបានរួមចំណែកយ៉ាងសកម្ម ដោយស្មើភាព ក្នុងគ្រប់សកម្មភាពនៃសមាគមនេះ សំដៅសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព សន្តិភាព សន្តិសុខ ស្ថិរភាព និង វិបុលភាពរួម ក្នុងតំបន់ ។ ជាមួយគ្នានេះ ក្នុងឋានៈជាសមាជិកនៃ *អង្គការពាណិជ្ជកម្មពិភពលោក* កម្ពុជា បានទទួលអត្ថប្រយោជន៍ពី ភាពជា*ប្រជាជាតិទទួលបាននូវការអនុគ្រោះបំផុត* និង ភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម ដែលទទួលបានពីប្រទេសមួយចំនួន (ឧទាហរណ៍ដូចជា "*គំនិតផ្តួចផ្តើមគ្រប់ទំនិញទាំងអស់ក្រៅពីអាវុធ*" នៅក្នុងប្រព័ន្ធអនុគ្រោះទូទៅរបស់សហគមន៍អឺរ៉ុប) ដែលតាមរយៈនេះ *កម្ពុជា* អាចនាំចេញផលិតផលរបស់ខ្លួន ទៅទីផ្សារសំខាន់ៗក្នុងពិភពលោក ដែលជាប្រការរួមចំណែកក្នុងការជំរុញ និងការពង្រឹងថែមទៀត នូវការបង្កើនទីផ្សារអន្តរជាតិសម្រាប់ទំនិញ*កម្ពុជា* ។ ក្រៅពីនេះ *កម្ពុជា* ក៏បាននិងកំពុងចូលរួមយ៉ាងសកម្ម ក្នុងកិច្ចសហប្រតិបត្តិការជាច្រើនទៀត ទាំងក្នុងក្របខ័ណ្ឌតំបន់ អនុតំបន់ និង សកលលោក ដូចជា *កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន កិច្ចសហប្រតិបត្តិការប្រទេសទន្លេមេគង្គខាងក្រោម-សហរដ្ឋអាមេរិក មហាអនុតំបន់មេគង្គ កិច្ចប្រជុំអាស៊ី-អឺរ៉ុប អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ចលនាមិនចូលបក្សសម្ព័ន្ធ* និង *អង្គការសហប្រជាជាតិ* ជាដើម ។

៧៤. ទន្ទឹមនឹងនេះ ដើម្បីជំរុញនិងពង្រីកបន្ថែមទៀត នូវការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់ អនុតំបន់ និងសកលលោក និង បន្តស្វែងរកជំនួយអភិវឌ្ឍន៍សម្រាប់កម្ពុជា ដែលនៅតែជាអាទិភាពដ៏សំខាន់របស់ *រាជរដ្ឋាភិបាល* ស្ថាប័នជាច្រើនរបស់*រាជរដ្ឋាភិបាលកម្ពុជា* ជាពិសេស *ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ* បាននិងបន្តខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយ ប្រទេសជាច្រើន ។ បច្ចុប្បន្ននេះ កម្ពុជាមានទំនាក់ទំនងការទូតជាមួយប្រទេសរហូតដល់ ១៤១ នៅទូទាំងសកលលោក ។

៧៥. អត្រាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ក៏ជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្ម ទៅក្នុង តំបន់ អនុតំបន់ និង សកលលោក កន្លងមករបស់ *រាជរដ្ឋាភិបាលកម្ពុជា* ផងដែរ ។ ក៏ប៉ុន្តែ វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក ដែលកើតចេញពីភាពបរាជ័យ ក្នុងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ ក្នុងបណ្តាប្រទេសជឿនលឿន ហើយដែលនៅតែកំពុងបន្តផ្តល់ផលប៉ះពាល់ លើបណ្តាប្រទេស នៅទូទាំងសកលលោក បានបង្កឱ្យមានបញ្ហាប្រឈមថ្មីៗ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច មិនចំពោះតែកម្ពុជាប៉ុណ្ណោះទេ គឺថែមទាំងចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍទាំងអស់ នៅទូទាំងសកលលោក ផងដែរ ។

## ២.៣ បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ

### ក. ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច : ២០០៦-២០០៨

៧៦. កិច្ចខិតខំរួមគ្នា ដើម្បីធានាស្ថិរភាពនយោបាយនិងសង្គម ជាមួយនឹង ការគ្រប់គ្រងសេដ្ឋកិច្ច ប្រកបដោយភាពត្រឹមត្រូវនិងមានភាពជឿនលឿន បានធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា អាចសម្រេចបាននូវអត្រាខ្ពស់ប្រកបដោយចីរភាពនៃកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេលជាង មួយទសវត្សរ៍ចុងក្រោយនេះ ។ នៅក្នុង *នីតិកាលទី៣ នៃរដ្ឋសភា* ឆ្នាំ២០០៣-២០០៨ អត្រាកំណើនសេដ្ឋកិច្ចជា មធ្យមប្រចាំឆ្នាំ មានប្រមាណ ១០ ភាគរយ ដោយមានអត្រាកំណើនប្រចាំឆ្នាំខ្ពស់បំផុត ១៣,៣ភាគរយ នៅក្នុង ឆ្នាំ២០០៥ ។ ដោយទទួលរងនូវឥទ្ធិពលពីវិបត្តិហិរញ្ញវត្ថុសាកលលោកដែល បានចាប់ផ្តើមឡើង នាចុងឆ្នាំ២០០៧ និងបានបណ្តាលឱ្យមានឱនភាពសេដ្ឋកិច្ចសាកលលោក នៅក្នុងបណ្តាប្រទេសជឿនលឿន ស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០៨ មានការធ្លាក់ចុះធៀបនឹង ឆ្នាំ២០០៣-២០០៧ ។ ក្នុងឆ្នាំ២០០៨ សេដ្ឋកិច្ចកម្ពុជា បានកើនឡើង នៅក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៦,៧ភាគរយ (តារាងទី១) ។

៧៧. លក្ខណៈសំខាន់ពីរនៃការងារគ្រប់គ្រងសេដ្ឋកិច្ច ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ គឺការកើនឡើងនៃចំនួនវិស័យនានាដែលជាមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច និងការរួមចំណែកយ៉ាងច្រើនរបស់វិស័យកសិកម្ម នៅក្នុងកំណើនសេដ្ឋកិច្ច ។ ការងារគ្រប់គ្រងសេដ្ឋកិច្ចនេះ ត្រូវបានបង្ហាញឱ្យឃើញតាមរយៈ ការពង្រីកការគាំទ្រដល់ វិស័យកសិកម្ម វិស័យកាត់ដេរ និងសកម្មភាពជំរុញវិស័យទេសចរណ៍ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ការពង្រីកសេដ្ឋកិច្ច បានធ្វើឱ្យមានការកើនឡើង យ៉ាងឆាប់រហ័សនៃវិស័យសំណង់ ដែលត្រូវបានជំរុញដោយការកើនឡើងនៃឥណទានក្នុងស្រុកដែលវិស័យឯកជនអាចមានលទ្ធភាពទទួលបាន ។ នៅក្នុងរយៈពេលពីឆ្នាំ២០០៣ ដល់ ២០០៥ ការផ្តល់ឥណទានដល់វិស័យឯកជន បានកើនជាមធ្យមប្រចាំឆ្នាំ ក្នុងកម្រិត ៣១ភាគរយ ។ ការផ្តល់ឥណទាន ដល់វិស័យឯកជនបានកើនឡើង ៥២ភាគរយ ក្នុងឆ្នាំ២០០៦ និង ៧៦ភាគរយ ក្នុងឆ្នាំ២០០៧ ។

៧៨. នៅក្នុងអំឡុងពេលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* រចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជា មានការប្រែប្រួល ដូចមានគូសបញ្ជាក់ខាងក្រោម :

- សមាមាត្រនៃវិស័យកសិកម្ម ក្នុង*ផសស* សរុប បានកើនឡើងពី ៣០,៧ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ៣២,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។
- សមាមាត្រនៃវិស័យឧស្សាហកម្ម ក្នុង*ផសស* សរុប បានថយចុះពី ២៥,០ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ២២,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។ សមាមាត្រនៃអនុវិស័យទាំងឡាយនៃវិស័យឧស្សាហកម្ម មានការប្រែប្រួល ដូចខាងក្រោម :

- អនុវិស័យវាយនភ័ណ្ឌនិងសម្លៀកបំពាក់ បានថយចុះពី ១២,៣ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ១០,៣ ភាគរយ ក្នុងឆ្នាំ២០០៨ ។
- អនុវិស័យធនធានរ៉ែ ពុំមានការប្រែប្រួលពីកម្រិត ០,៤ភាគរយ ក្នុងឆ្នាំ២០០៥ ទេ (ក្នុងឆ្នាំ ២០០៨ ក៏មានកម្រិត ០,៤ភាគរយ ដែរ) ។
- អនុវិស័យសំណង់ មានការថយចុះបន្តិចបន្តួច ពី ៦,៣ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ៦,១ភាគរយ ក្នុងឆ្នាំ២០០៨ ។

• សមាមាត្រនៃវិស័យសេវាកម្ម បានថយចុះតិចតួចពី ៣៩,១ ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ៣៨,៨ ភាគរយ ក្នុងឆ្នាំ២០០៨ ។ សមាមាត្រនៃអនុវិស័យទាំងឡាយនៃវិស័យសេវាកម្ម មានការប្រែប្រួល ដូចខាងក្រោម ៖

- អនុវិស័យទេសចរណ៍និងសណ្ឋាគារ បានកើនឡើងពី ៤,៣ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ៤,៥ភាគរយ ក្នុងឆ្នាំ២០០៨ ។
- អនុវិស័យដឹកជញ្ជូន និង ទូរគមនាគមន៍ មិនមានការប្រែប្រួលពី ៧,៤ភាគរយ ក្នុងឆ្នាំ២០០៥ ទេ (ក្នុងឆ្នាំ២០០៨ ក៏មានកម្រិត ៧,៤ភាគរយ ដែរ) ។
- អនុវិស័យហិរញ្ញវត្ថុ បានកើនឡើងពី ១,១ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ១,៣ភាគរយ ក្នុងឆ្នាំ២០០៨ ។
- អនុវិស័យអចលនទ្រព្យ បានថយចុះពី ៦,៦ភាគរយ ក្នុងឆ្នាំ២០០៥ ដល់ ៦,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។

**តារាងទី១ ៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០០៣-២០០៨**

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|
| អត្រាកំណើន *ផសស ពិត* (%) | ៨,៥ | ១០,៣ | ១៣,៣ | ១០,៨ | ១០,២ | ៦,៧ |
| -កសិកម្ម (%) | ១០,៥ | -០,៩ | ១៥,៧ | ៥,៥ | ៥,០ | ៥,៧ |
| -ឧស្សាហកម្ម (%) | ១២,០ | ១៦,៦ | ១២,៧ | ១៨,៣ | ៨,៤ | ៤,០ |
| -សេវាកម្ម (%) | ៥,៩ | ១៣,២ | ១៣,១ | ១០,១ | ១០,១ | ៩,០ |
| *ផសស* សម្រាប់ម្នាក់ៗ (ដុល្លារ) | ៣៥៦ | ៤០២ | ៤៦៨ | ៥៣៤ | ៦២៣ | ៧៣៨ |
| សញ្ជ័យជាតិ (% នៃ*ផសស*) | ១៦,៣ | ១៦,៤ | ១៧,៣ | ២៣,១ | ២៣,៨ | ១៦,៩ |
| សញ្ជ័យរបស់រដ្ឋបាលថ្នាក់កណ្តាល(% នៃ*ផសស*) | ០,៨ | ១,៦ | ១,៧ | ១,០ | ៣,១ | ៣,០ |
| សញ្ជ័យឯកជន (% នៃ*ផសស*) | ១៥,៦ | ១៤,៨ | ១៥,៦ | ២២,១ | ២០,៧ | ១៣,៩ |
| វិនិយោគក្នុងស្រុក (% នៃ*ផសស*) | ១២,២ | ១១,៨ | ១១,១ | ១១,២ | ១១,១ | ១១,៣ |
| វិនិយោគសាធារណៈ (% នៃ*ផសស*) | ៦,៥ | ៥,៨ | ៥,៣ | ៥,៩ | ៦,២ | ៦,៥ |
| វិនិយោគឯកជន (% នៃ*ផសស*) | ១២,៨ | ១២,៩ | ១៦,៣ | ១៦,៩ | ២០,៤ | ១៨,០ |

*__ប្រភព__ ៖ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ*

៧៩. ដូចបានធ្វើការកត់សម្គាល់រួចហើយ នៅដើមជំពូកនេះ អាទិភាពមួយក្នុងចំណោមអាទិភាពខ្ពស់បំផុត របស់ *រាជរដ្ឋាភិបាលកម្ពុជា* គឺការកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតំបន់ជនបទ ។ កំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់ ដែលមានកម្រិតមធ្យមប្រចាំឆ្នាំ ប្រមាណ ១០ភាគរយ នៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ បានលើកកម្ពស់កម្រិតជីវភាពរស់នៅ និងបានកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន នៅទូទាំងប្រទេស ។ លទ្ធភាពទទួលបានជារូបវន្ត នូវសេវាកម្មសាធារណៈផ្សេងៗ ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយគិតជា ចម្ងាយមធ្យមឆ្ពោះទៅកាន់មណ្ឌលសុខភាព ឬ សាលារៀន ដែលនៅជិតបំផុត ។ ប្រការទាំងនេះ ដោយរួមផ្សំជាមួយនឹង ការលើកកម្ពស់ ទាំងបរិមាណនិងគុណភាពនៃបណ្ដាញផ្លូវថ្នល់ និងការកើនឡើងនៃប្រាក់ចំណូលពិត បង្ហាញឱ្យឃើញពីមូលហេតុនៃការធ្វើឱ្យប្រសើរឡើង នូវអត្រានៃការសិក្សា ឬ ឥរិយាបថនៃការគិតគូរដល់សុខភាព ។ ជាមួយគ្នានេះ លទ្ធផលការងារជាច្រើនត្រូវបានបន្តធ្វើឱ្យប្រសើរឡើង ដូចជា កម្រិតមធ្យមនៃការទទួលបានការអប់រំ និងស្ថានភាពសុខភាព ដែលត្រូវបានរាយការណ៍ ដោយសាមីខ្លួនផ្ទាល់ ។

## ខ. ចំណូលនិងចំណាយថវិកា

៨០. ជាមួយគ្នានឹងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ការប្រមូលពន្ធលើប្រាក់ចំណូល ក៏ត្រូវបានធ្វើការកែលម្អគួរឱ្យកត់សម្គាល់ដែរ នៅក្នុងអំឡុងឆ្នាំ២០០៦ ដល់ ២០០៨ ។ ប្រាក់ចំណូលដែលប្រមូលបាន គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប បានកើនឡើងពី ១១,៤ភាគរយ ក្នុងឆ្នាំ២០០៦ ដល់ ១២,១ភាគរយ ក្នុងឆ្នាំ២០០៧ និងកើនដល់ ១៣,៣ភាគរយ ក្នុងឆ្នាំ២០០៨ ។ ទន្ទឹមនឹងនេះ ចំណាយថវិកា បានកើនឡើងយឺតជាង ធៀបនឹងចំណូល ដែលបណ្ដាលឱ្យឱនភាពទូទៅនៃថវិកា បានធ្លាក់ចុះពី ៣,៣ភាគរយនៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០០៦ មកនៅត្រឹម ២,៨ភាគរយ ក្នុងឆ្នាំ២០០៧ និងមកត្រឹម ២,៧ភាគរយ ក្នុងឆ្នាំ២០០៨ ។

៨១. ចាប់តាំងពីឆ្នាំ២០០៤ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងអនុវត្ត *កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ* ។ ទស្សនវិស័យរយៈពេលវែងនៃកម្មវិធីកំណែទម្រង់នេះ គឺត្រូវបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដែលមានស្តង់ដារអន្តរជាតិ នៅត្រឹមឆ្នាំ២០១៥ ។ នៅក្នុងការរៀបចំយុទ្ធសាស្ត្រនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារកំណែទម្រង់ជាច្រើន ត្រូវបានធ្វើឡើងជាលំដាប់លំដោយទៅតាមដំណាក់កាលនីមួយៗ ។ ជាការពិត អ្វីៗទាំងឡាយ មិនអាចធ្វើឡើងក្នុងពេលតែមួយបានទេ ប៉ុន្តែការងារជាមូលដ្ឋាន និងការងារគន្លឹះមួយចំនួន ចាំបាច់ត្រូវធ្វើឡើង មុនពេលដែលការងារដទៃទៀត អាចដំណើរការទៅ ប្រកបដោយប្រសិទ្ធភាព ។ ក្នុងការរៀបចំលំដាប់លំដោយនៃកម្មវិធីកំណែទម្រង់ សកម្មភាពការងារដែលត្រូវបំពេញ ត្រូវបានចងក្រងជាក្រុមទៅតាមជំហាន ដែលជំហាននីមួយៗ បង្ហាញនូវការកែលម្អជាក់ស្តែង និងអាចវាយតម្លៃបាននៅក្នុងសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយក៏បង្កើតបានជាឈ្នាន់សម្រាប់ជំហានបន្ទាប់ផងដែរ ។ បណ្ដាជំហានទាំងនោះត្រូវបានរៀបចំឡើង ដូចមានបង្ហាញ ក្នុងគំនូសដូចខាងក្រោម ។

៨២. ទន្ទឹមនឹងនេះ ប្រការសំខាន់ដែលត្រូវយកចិត្តទុកដាក់នោះ គឺ ផែនការទាំងឡាយសម្រាប់អនុវត្តជំហាននីមួយៗ ត្រូវគ្របដណ្តប់ មិនត្រឹមតែការអភិវឌ្ឍផ្នែកបច្ចេកទេស និង របៀបរបបអនុវត្តការងារ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ត្រូវរួមបញ្ចូលទាំង ការកសាងស្ថាប័ន ការកសាងសមត្ថភាព និង ការលើកទឹកចិត្ត ។ ដូច្នេះ ប្រសិនបើទិដ្ឋភាពដោយឡែកៗពីគ្នាខាងលើនេះ មិនត្រូវបានយកចិត្តទុកដាក់ និង មិនបានជួយគាំទ្រគ្នាទៅវិញទៅមក នោះទេនោះ ជំហាននីមួយៗ មិនត្រឹមតែ មិនអាចក្លាយជាឈ្នាន់ដ៏រឹងមាំ ដើម្បីឈានទៅជំហានបន្ទាប់បានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ធ្វើឱ្យកំណែទម្រង់ទាំងឡាយ ពុំមានភាពស៊ីជម្រៅ ហើយ អាចជួបប្រទះនឹងភាពថមថយ ផងដែរ ។

៨៣. ទោះបីជាមានតម្រូវការបន្តពង្រឹងកម្មវិធីកែទម្រង់ សម្រាប់ជំហានទី១ ក៏ដោយ ក៏យើងបានធ្វើឱ្យមានវឌ្ឍនភាព ដ៏គួរឱ្យកត់សម្គាល់ជាច្រើន ក្នុងការធ្វើឱ្យសម្រេចបាននូវការកែលម្អភាពជឿទុកចិត្តនៃថវិកា ដែលជាឧបករណ៍មួយនៃ គោលនយោបាយនិងការផ្តល់សេវាកម្ម ។ ចំណូលបានកើនឡើង គួរឱ្យកត់សម្គាល់ ហើយ លំហូរនៃធនធាន ទៅបណ្តាក្រសួងជំនាញ និង ស្ថាប័នទាំងឡាយដែលជាអ្នកអនុវត្តគោលនយោបាយនិងផ្តល់សេវាកម្ម ត្រូវបានកែលម្អ ។ ស្ថិរភាពសារពើពន្ធ ត្រូវបានធ្វើឱ្យមានលក្ខណៈរឹងមាំជាងមុន ដោយមានការធ្វើឱ្យមានភាពប្រសើរឡើង ក្នុង ការកែលម្អ ការព្យាករការគ្រប់គ្រងតុល្យភាពសាច់ប្រាក់ និង ការលុបបំបាត់បំណុលកកស្ទះ ។

៨៤. លទ្ធផលនៃការអនុវត្តជំហានទី១ របស់កម្មវិធីកំណែទម្រង់ ដែលផ្តោតលើ *ភាពអាចជឿទុកចិត្តបានរបស់ថវិកា* រួមមាន :

- *ការកែលម្អនិងការពង្រឹង ការគ្រប់គ្រង ការព្យាករណ៍ និងគោលនយោបាយចំណូល និងការប្រមូលពន្ធ* ។ ជាលទ្ធផល ចំណូល បានកើនឡើងជាមធ្យមប្រចាំឆ្នាំ ប្រមាណ ២៦ ភាគរយ ហើយ ក្របខ័ណ្ឌគោលនយោបាយ ត្រូវបាន ពង្រីក កែលម្អ និង លើកកម្ពស់ ។ ក្របខ័ណ្ឌចំណូលរយៈពេលមធ្យម រួមមាន ប្រេង ឧស្ម័ន និង រ៉ែ ត្រូវបានបង្កើតឡើង ។ លើសពីនេះ វិធានការមួយចំនួនត្រូវបានដាក់ឱ្យដំណើរការ ដើម្បីកែលម្អនិងពង្រឹងលើការប្រមូលចំណូល ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។
- *ការកែលម្អនិងការពង្រឹង ការរៀបចំថវិកា :* បច្ចុប្បន្ននេះ ថវិកា ត្រូវបានធ្វើឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ សុក្រឹត្យ និងឆ្លើយតបទៅនឹងគោលនយោបាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ច្រើនជាងមុន ។ ដំណើរការនៃការរៀបចំថវិកា ត្រូវបានកែលម្អ ហើយ ត្រូវបានធ្វើឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ច្រើនជាងមុន តាមរយៈ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ការដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រថវិកា ការធ្វើចំណាត់ថ្នាក់ថវិកាថ្មីមួយ ការអនុវត្តសាកល្បងការធ្វើថវិកាកម្មដល់កម្មវិធី ការអនុវត្តការពិនិត្យមើលឡើងវិញជាប្រព័ន្ធនាពេលពាក់កណ្តាល លើថវិកា ព្រមទាំង ការរៀបចំផែនការចំណូលនិងចំណាយប្រចាំត្រីមាស ។ *ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ* ត្រូវបានរៀបចំឡើង និងអនុម័ត ។ ជំហានបន្ទាប់ គឺត្រូវធានាឱ្យមាន សង្គតិភាព និង សុខដុមនីយកម្ម រវាង *ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ* និង *ច្បាប់គ្រប់គ្រងរដ្ឋបាលថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* ដើម្បីសម្រេចបាននូវគោលដៅទាំងឡាយរបស់ *កម្មវិធី*

*កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* និង *កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* ។ *ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ* សម្រាប់ថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងជាសេចក្ដីព្រាង និងកំពុងត្រូវបានដាក់ឱ្យពិភាក្សា ។

- *ការកែលម្អការអនុវត្តនិងប្រសិទ្ធភាពថវិកា* : ជាលទ្ធផល ការត្រួតពិនិត្យថវិកា ត្រូវបានធ្វើឱ្យមានលក្ខណៈសាមញ្ញ និង មានភាពស័ក្ដិសិទ្ធិ ជាងមុន ។ ការផ្ដល់ថវិកាដល់ការចំណាយ និង ការទូទាត់ចំណាយ មានភាពរលូន និង ទាន់ពេលវេលា ជាងមុន ។ ការកត់ត្រាបញ្ជី មានតម្លាភាព និង សុក្រឹត្យភាព ជាងមុន ។ កិច្ចការទាំងនេះ ត្រូវបានធ្វើឡើង តាមរយៈ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើត *គណនីរតនាគារជាតិទោល* ការដាក់ឱ្យអនុវត្តនូវ *ប្លង់គណនីថ្មី* ការដាក់ឱ្យអនុវត្តនូវការទូទាត់តាមប្រព័ន្ធធនាគារ ការកាត់បន្ថយដំណើរការនិងនីតិវិធីសម្រាប់ការអនុវត្តថវិកា ក្នុងនោះរួមមាន ការធ្វើវិមជ្ឈការ អធិការកិច្ចហិរញ្ញវត្ថុ និង ការងារលទ្ធកម្ម ។ លើសពីនេះ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានពង្រឹង តាមរយៈ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង នៅក្នុងគ្រប់ក្រសួង-ស្ថាប័ន រួមទាំង ការកែលម្អលើការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ផងដែរ ។ ក្រៅពីនេះ ការរៀបចំបង្កើតឡើងនូវរបៀបរបបការងារថ្មីមួយ នឹងត្រូវបញ្ចប់ ក្នុងពេលឆាប់ៗនេះ ។ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានរៀបចំឡើង ហើយ ការរៀបចំសម្រាប់ការអនុវត្ត ជំហានទី១ ក៏កំពុងដំណើរការ ផងដែរ ។
- *ការលើកកម្ពស់សមត្ថភាពស្ថាប័នរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* : ជាលទ្ធផល តួនាទី មុខងារ និងការទទួលខុសត្រូវ របស់នាយកដ្ឋាននិងមន្ត្រីទាំងឡាយ បច្ចុប្បន្ននេះត្រូវបានកំណត់យ៉ាងច្បាស់លាស់។ សមត្ថភាពរបស់មន្ត្រី និងនាយកដ្ឋានត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈ ការផ្ទេរចំណេះដឹង និងចំណេះធ្វើពីទីប្រឹក្សា ការបណ្ដុះបណ្ដាលក្នុងការងារ សិក្ខាសាលាលើប្រធានបទជាក់លាក់ ទស្សនកិច្ចសិក្សា ការបណ្ដុះបណ្ដាលវគ្គខ្លីៗនៅក្នុងនិងក្រៅប្រទេស និងកម្មវិធីសិក្សារយៈពេលវែង សម្រាប់ជំនាញច្បាស់លាស់ដែលភាគច្រើន ផ្ដោតលើគោលនយោបាយសាធារណៈ និងព័ត៌មានវិទ្យា ។

៨៥. ការអនុវត្តជំហានទី១ ឆ្លុះបញ្ចាំងឱ្យឃើញនូវ ការប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់ ភាពជាម្ចាស់ និងការទទួលស្គាល់នូវគណនេយ្យភាព របស់*រាជរដ្ឋាភិបាល* ។ *រាជរដ្ឋាភិបាល* នឹងបន្តពង្រឹងនូវសមិទ្ធផលទាំងឡាយ ដែលសម្រេចបាននៅក្នុងជំហានទី១ ។ ការងាររៀបចំផែនការលម្អិត សម្រាប់ការអនុវត្តជំហានទី២ ដែលបានចាប់ផ្ដើមឡើងនៅក្នុងឆ្នាំ២០០៧ បានផ្ដោតលើ *"មូលដ្ឋាននៃថវិកាដែលអាចជឿទុកចិត្តបានឆ្ពោះទៅការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង"* ។ ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តជំហានទី២ ដែលត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ កំពុងត្រូវបានដាក់ឱ្យអនុវត្ត នាពេលបច្ចុប្បន្ននេះ ។ ការងារសំខាន់នៃជំហានទី២ គឺការបង្កើនគណនេយ្យភាពរបស់អ្នកទាំងឡាយណា ដែលទទួលខុសត្រូវលើការគ្រប់គ្រងធនធានសាធារណៈ ប្រកបដោយ សុវត្ថិភាព ប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិ ។ ជំហានទី១ ត្រូវគិតគូរដល់ ក្របខ័ណ្ឌរួម នៃការគ្រប់គ្រងធនធាន ហើយ ត្រូវដោះស្រាយបញ្ហាចម្បងៗ នៅក្នុងប្រព័ន្ធទាំងមូល ។ ជំហានទី២ នឹងព្យាយាម

ជំរុញឱ្យមានការប្តេជ្ញាចូលរួម ពីអង្គភាពថវិកាទាំងអស់ និងពីអ្នកគ្រប់គ្រងអង្គភាពទាំងនោះ ក្នុងការកែលម្អការងារគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់ខ្លួន នៅក្នុងក្របខ័ណ្ឌរួម ។ ផែនការសកម្មភាពទាំងឡាយដែលត្រូវបានរៀបចំឡើង គឺសំដៅបង្កើតឱ្យមានក្របខ័ណ្ឌរួមមួយ តាមរយៈ ការផ្តុំបញ្ចូលគ្នានូវ ការងារជាច្រើនដែលពាក់ព័ន្ធនឹងលិខិតបទដ្ឋានគតិយុត្តិ ដំណើរការ និងការកសាងសមត្ថភាព ដោយគិតគូរដល់តុល្យភាពសមស្របមួយ ក្នុងការផ្តល់ការលើកទឹកចិត្ត សំដៅសម្រេចបាននូវ ការអនុវត្តល្អក្នុងការ *គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* និង ការបង្ការមិនឱ្យមានភាពអសកម្ម ក្នុងការអនុវត្តការងារ ។

## លំដាប់លំដោយនៃជំហានទាំងបួន

- ផ្តល់រង្វាន់ចំពោះសមិទ្ធកម្មព្រមទាំងវិន័យ
- មានមូលដ្ឋានសម្រាប់វិសហមជ្ឈការកាន់តែស៊ីជម្រៅ
- មានតម្លាភាពផ្ទៃក្រៅកាន់តែប្រសើរឡើង

**ជំហានទី៤**

សមាហរណកម្មគណនេយ្យភាព និង ការពិនិត្យឡើងវិញ ទាំងផ្នែកហិរញ្ញវត្ថុ និង សមិទ្ធកម្ម

កតលីករ

គណនេយ្យភាពចំពោះសមិទ្ធកម្ម

-កាលានុវត្តភាពដើម្បីប្រសិទ្ធភាព
-ការតម្រែតម្រង់ឡើងវិញនូវធនធានជាមួយនឹងអាទិភាព
-វិសាលភាពត្រួតពិនិត្យឡើងវិញដោយស៊ីជម្រៅ

**ជំហានទី៣**

កែលម្អការផ្សារភ្ជាប់រវាងអាទិភាព និងគោលដៅសេវាទៅនឹងការធ្វើផែនការ និងការអនុវត្តថវិកា

កតលីករ

មានសកម្មភាពច្បាស់លាស់ចំពោះការប្រើប្រាស់ថវិកា

- ឈានទៅរកស្តង់ដារក្នុងតំបន់
- បង្កើនថវិកាគាំទ្រដោយដៃគូអភិវឌ្ឍន៍

**ជំហានទី២**

ការកែលម្អជាបឋមផ្នែកត្រួតពិនិត្យផ្ទៃក្នុង និងធ្វើឱ្យអ្នកគ្រប់គ្រងថវិកាមានគណនេយ្យភាព

កតលីករ

មូលដ្ឋានសម្រាប់គណនេយ្យភាព

**ជំហានទី១**

ថវិកាកាន់តែអាចជឿទុកចិត្តបាន ដោយអ្នកគ្រប់គ្រងថវិកាទទួលបានធនធានដែលអាចព្យាករ និង ជឿជាក់បាន

៨៦. ការលើកកម្ពស់ ការប្រគល់សិទ្ធិអំណាច និងគណនេយ្យភាព លើប្រព័ន្ធព័ត៌មានវិទ្យានិងតម្លាភាពឱ្យល្អប្រសើរជាងមុន នឹងត្រូវបានគាំទ្រដោយវិធានការជាច្រើន ដើម្បីជំរុញបន្ថែម នូវ កាតព្វកិច្ចគ្រប់គ្រងហិរញ្ញវត្ថុ ដែលកំពុងអនុវត្តជាក់ស្តែងដោយស្ថាប័នឬអ្នកគ្រប់គ្រងថវិកា ។ នៅពេលដែលការអនុវត្តដំណាក់កាលទី២ ចាប់ផ្តើម ការងារក្នុងឆ្នាំ២០០៩ ផ្តោតលើទិសដៅចំនួន ៣ គឺ (១) *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវរៀបចំគម្រោងនៃការ អនុវត្តលម្អិតសម្រាប់បញ្ហាបច្ចេកទេសមួយចំនួន ដែលរំពឹងថានឹងមាននៅក្នុងដំណាក់កាលទី២ ដូចជា ថវិកាដែលនឹង តវធ្លាក់ទៅដល់ដៃអ្នកផ្តល់សេវានិងត្រូវបានប្រើប្រាស់ ការអនុវត្តនូវប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុដែលល្អប្រសើរ និងវិធីសាស្ត្រសម្រាប់គ្រប់គ្រងស្ថាប័នអនុវត្តថវិកា ឱ្យកាន់តែមានគណនេយ្យភាព (២) ស្វែងរកទំនាក់ទំនងជាវិជ្ជមាន ជាមួយនឹង ក្រសួង-ស្ថាប័ន អនុវត្តថវិកាផ្សេងៗ ដែលស្ថិតក្នុងគោលបំណងកំណែទម្រង់ ក្នុងដំណាក់កាលទី២ និង (៣) រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពនានា ដែលមានសារៈសំខាន់ដល់ការធ្វើឱ្យសម្រេចគោលបំណង របស់ដំណាក់កាលទី២ ។ វឌ្ឍនភាពសំខាន់ៗ នៅក្នុងឆ្នាំ២០០៩ ត្រូវបានសម្រេចដោយជោគជ័យ ទោះបីជា ការងារលម្អិតនៅក្នុងផ្នែកនីមួយៗ នឹងបន្តអនុវត្តនៅឆ្នាំ២០១០ ក៏ដូចជា ការអភិវឌ្ឍសកម្មភាពដទៃទៀត ក៏ដោយ ។ ការងារធ្វើ លទ្ធកម្មប្រព័ន្ធកុំព្យូទ័រដែលនឹងក្លាយជាការងារដ៏សំខាន់បំផុត សម្រាប់ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុនោះ កំពុងតែឆ្ពោះទៅមុខយ៉ាងល្អប្រសើរ ។ អភិក្រមយុទ្ធសាស្ត្របន្ថែមក្នុងការគ្រប់គ្រងធនធាន ក៏កំពុងតែឈានទៅមុខមួយជំហាន ។ ក្របខ័ណ្ឌនៃការអភិវឌ្ឍសកម្មភាពសវនកម្មផ្ទៃក្នុង ក៏ត្រូវបានរៀបចំឡើង ហើយ ក្រសួង-ស្ថាប័នទាំងអស់ ក៏បានចូលរួមក្នុងសិក្ខាសាលា និងក្នុងគម្រោងកម្មវិធីការកសាងសមត្ថភាពផងដែរ ។ ក្រសួង-ស្ថាប័នទាំងនោះ បានបង្កើត នូវក្រុមកំណែទម្រង់តូចៗរៀងៗខ្លួន ហើយក្រសួង-ស្ថាប័នភាគច្រើន បានរៀបចំផែនការរបស់ខ្លួនរួចជាស្រេចហើយ ដើម្បីចូលរួមចំណែកដល់យុទ្ធសាស្ត្រកំណែទម្រង់ទាំងមូល ។

## គ. អតិផរណានិងស្ថានភាពរូបិយវត្ថុ

៨៧. ក្នុងសភាពជាសេដ្ឋកិច្ចមួយតូចនិងបើកចំហ ដែលមានដុល្លារូបនីយកម្មកម្រិតខ្ពស់នោះ កម្ពុជា ត្រូវបានទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ពីការផ្លាស់ប្តូរនៃថ្លៃ ប្រេងឆៅ ម្ហូបអាហារ និងថ្លៃទំនិញប្រើប្រាស់ផ្សេងៗទៀតនៅក្នុងទីផ្សារអន្តរជាតិ ។ ការកើនយ៉ាងគំហុកនៃប្រេងឆៅក្នុងមួយធុង ដែលបានកើនឡើងពី ៦៦,៤៧ដុល្លារ នៅខែមេសា ឆ្នាំ២០០៧ ដល់ ១៤៧ដុល្លារ ជាកម្រិតខ្ពស់ដែលមិនធ្លាប់មាន នៅខែកក្កដា ឆ្នាំ២០០៨ ក៏ដូចជា ថ្លៃអង្ករដែលបានកើនឡើងពីរដង នៅក្នុងទីផ្សារអន្តរជាតិ នៅចន្លោះត្រីមាសទី១ ឆ្នាំ២០០៧ និង ត្រីមាសទី១ ឆ្នាំ២០០៨ ហើយ បានកើនឡើងពីរដង ជាថ្មីម្តងទៀត នៅក្នុងបួនខែដំបូង នៃឆ្នាំ២០០៨ បានបណ្តាលឱ្យមានការកើនឡើងនៃអតិផរណា ដល់ ២៥,៧ ភាគរយ នៅខែឧសភា ឆ្នាំ២០០៨ ។ ទោះជាដូចនេះក្តី វិធានការដ៏សកម្មដែលត្រូវបានអនុវត្តជាមុន ដោយ *ធនាគារជាតិនៃកម្ពុជា* បានកាត់បន្ថយសម្ពាធអតិផរណា ហើយបានថយចុះដល់ ១៣,៥ ភាគរយនៅចុងឆ្នាំ២០០៨ ។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក មានស្ថិរភាព នៅក្នុងដំណាក់កាលឆ្នាំ ២០០៦-២០០៨ ដោយបានប្រែប្រួលចន្លោះពី ៤ ០០០ រៀល ដល់ ៤ ១២៥ រៀល ក្នុង ១ដុល្លារ ។ ទុនបម្រុងបរទេសដុល បានកើនដល់ ២១៦៤ លានដុល្លារអាមេរិក ដែលអាចទ្រទ្រង់ សម្រាប់ការនាំចូលរយៈពេល ៣,៤ ខែ ។

៨៨. ប្រព័ន្ធធនាគារកម្ពុជា មិនបានទទួលរងនូវការខាតបង់ដោយផ្ទាល់ ដោយសារ ឥណទាននិក្ខេប ដែលបានជះឥទ្ធិពលជាអវិជ្ជមានលើស្ថាប័នហិរញ្ញវត្ថុនៅក្នុងប្រទេសដទៃទៀត ។ ទោះជាដូចនេះក្តី ដើម្បីបង្កើនការជឿទុកចិត្តលើប្រព័ន្ធធនាគារ និង ដើម្បីបន្ថយឥទ្ធិពលទាំងឡាយដែលអាចមាន *ធនាគារជាតិនៃកម្ពុជា* បានចាត់វិធានការជាច្រើន រួមមាន (១) ការចាត់វិធានការសកម្មជាមុន ដើម្បីពង្រឹងការគ្រប់គ្រងដោយប្រុងប្រយ័ត្នលើប្រព័ន្ធធនាគារ (២) ការបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ច ពី ៨ ភាគរយ ដល់ ១៦ ភាគរយ នៅក្នុងប្រព័ន្ធធនាគារ (៣) ការកំណត់ពិដានឥណទានសម្រាប់វិស័យអចលនទ្រព្យឱ្យនៅត្រឹម ១៥ ភាគរយ (៤) ការកែលម្អប្រព័ន្ធចំណាត់ថ្នាក់ឥណទាននៃវិស័យធនាគារ និង (៥) ការពង្រឹងប្រព័ន្ធចែកចាយព័ត៌មានឥណទាន ។ ទន្ទឹមនឹងនេះ *ធនាគារជាតិនៃកម្ពុជា* បានតម្រូវឱ្យធនាគារទាំងឡាយ ធ្វើការអភិវឌ្ឍយន្តការប្រតិបត្តិការមួយ ដែលផ្អែកលើ ប្រព័ន្ធសហគ្រាសទំនើប ដោយធ្វើ ការកែលម្អក្រមប្រតិបត្តិការ ការលើកទឹកចិត្តឱ្យមានអភិបាលកិច្ចសាជីវកម្មល្អ និងការផ្តល់សេចក្តីណែនាំដល់ធនាគារទាំងឡាយ ស្តីពីការគ្រប់គ្រងហានិភ័យ ។

៨៩. នៅក្នុងដំណាក់ឆ្នាំ២០០៦-២០០៨ វឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឱ្យកើតមានឡើង ដើម្បីប្រែក្លាយស្ថាប័នហិរញ្ញវត្ថុទាំងឡាយ ឱ្យទៅជា វិស័យមួយ ដែលផ្អែកលើទីផ្សារ និង ដែលគ្រប់គ្រងដោយវិស័យឯកជន ។ វិធានការកំណែទម្រង់ជាច្រើន និង ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ បានរួមចំណែកនៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដ៏រឹងមាំ ។ សូចនាករជាច្រើនដែលមានលក្ខណៈប្រាកដនិយម បានបង្ហាញឱ្យឃើញពីលទ្ធផលវិជ្ជមានជាច្រើន ។ អនុបាតភាពគ្រប់គ្រាន់នៃដើមទុនជាមធ្យម សម្រាប់ធនាគារពាណិជ្ជ មានកម្រិត ២៨ ភាគរយ ក្នុងខែធ្នូ ឆ្នាំ២០០៨ បើប្រៀបធៀបទៅនឹងកម្រិតគោល ១៥ ភាគរយ ។ ទ្រព្យសកម្មសរុប បានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងប្រព័ន្ធធនាគារ ។ បើគិតតាមគុណភាពទ្រព្យសកម្ម ឥណទានមិនដំណើរការ បានកើនដល់កម្រិត ១៤,៦ ភាគរយ នៅចុងឆ្នាំ២០០២ និង ៩,៩ ភាគរយ នៅចុងឆ្នាំ២០០៦ ប៉ុន្តែ បានថយចុះយ៉ាងច្រើនមកនៅត្រឹម ៣,៧ភាគរយ ក្នុងខែធ្នូ ឆ្នាំ២០០៨ ។ ការផ្គត់ផ្គង់រូបិយវត្ថុ ធៀបនឹង*ផសស* បានកើនឡើងដល់ ២៨,៣ ភាគរយ នៅចុងឆ្នាំ២០០៨ ។ ឥណទានសម្រាប់វិស័យឯកជន បានកើនឡើងដល់ ២៣,៦ ភាគរយ នៃ*ផសស* ហើយប្រាក់បញ្ញើសរុប បានកើនឡើងដល់ ២២,៨ ភាគរយ នៃ *ផសស* ។

៩០. *ធនាគារជាតិនៃកម្ពុជា* បានផ្តល់ការគាំទ្រយ៉ាងសកម្មដល់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងក្នុងនិងដែលមកពីក្រៅប្រទេស ដើម្បីផ្សារភ្ជាប់សេវាកម្មធនាគារ ទៅតំបន់ជនបទ ។ ដោយសារកំណើនដ៏ឆាប់រហ័ស និងការកើនឡើងនៃភាពស្មុគស្មាញនៃប្រពន្ធធនាគារ *ធនាគារជាតិនៃកម្ពុជា* បានធ្វើការកែសម្រួលច្បាប់នានា ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សំដៅធ្វើឱ្យក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត មានលក្ខណៈបច្ចុប្បន្នកម្ម សមស្របទៅតាមការផ្លាស់ប្តូររបស់ទីផ្សារ ។ *ធនាគារជាតិនៃកម្ពុជា* បានបង្កើត*អង្គភាពស៊ើបការហិរញ្ញវត្ថុ* ដើម្បីអនុវត្ត *ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម* ដែលត្រូវបានអនុម័ត នៅក្នុងឆ្នាំ២០០៧ ។

៩១. *រាជរដ្ឋាភិបាលកម្ពុជា* បានបន្តអនុវត្តយ៉ាងសកម្មនូវ *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥* ។ កិច្ចខិតខំប្រឹងប្រែងជាច្រើន ត្រូវបានធ្វើឡើងរួមគ្នា ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ដោយ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បាននាំមុខ លើការងារក្នុងវិស័យមិនមែនធនាគារ ហើយ *ធនាគារជាតិនៃកម្ពុជា* បាននាំមុខលើការងារក្នុងវិស័យធនាគារ ។

៩២. ចំពោះវិស័យមិនមែនធនាគារ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ក៏បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីអភិវឌ្ឍវិស័យនេះឱ្យមានការរីកចម្រើនជឿនលឿន ស្របទៅតាមការអភិវឌ្ឍរបស់ប្រទេសជាតិ ។ វឌ្ឍនភាពក្នុងវិស័យមិនមែនធនាគារ មានដូចខាងក្រោម :

- *វិស័យមូលបត្រ :*
  - ការបង្កើតទីផ្សារមូលបត្រ នឹងនាំឱ្យមាន ការធ្វើពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុថ្មីជាច្រើនទៀត និងពង្រីកជម្រើសនៃវិនិយោគ សម្រាប់អ្នកវិនិយោគកម្ពុជានិងបរទេស ។ ទីផ្សារមូលបត្រ គឺជាយន្តការមួយ ដែលអាចកៀរគរមូលធន ដែលស្ថិតនៅជាបំណែកតូចៗរាយប៉ាយ មកពូនឱ្យទៅជាមូលធនប្រមូលផ្តុំធំមួយ សម្រាប់ការវិនិយោគក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការលក់មូលបត្រ ជាពិសេសបណ្ណភាគហ៊ុនសហគ្រិន ។ កន្លងមក *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បានរៀបចំបង្កើត*ទីផ្សារមូលបត្ររដ្ឋ* ដើម្បីប្រមូលហិរញ្ញប្បទានបន្ថែម សម្រាប់គាំទ្រដល់គម្រោងអភិវឌ្ឍន៍នានារបស់*រាជរដ្ឋាភិបាល* ។ *ច្បាប់ស្តីពីមូលបត្ររដ្ឋ* ត្រូវបានអនុម័តនិងប្រកាសឱ្យប្រើប្រាស់រួចហើយ ។
  - ទន្ទឹមនឹងនេះដែរ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ក៏បានប្រឹងប្រែងអភិវឌ្ឍ*ទីផ្សារមូលបត្រមហាជន* ហើយ ច្បាប់គោលជាសារវន្តមួយចំនួន ត្រូវបានអនុម័តនិងដាក់ឱ្យប្រើប្រាស់ សម្រាប់ដំណើរការទីផ្សារនេះ ដែលក្នុងនោះ រួមមាន *ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន* និង*អនុក្រឹត្យស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន* ជាដើម ។ *គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)* ត្រូវបានបង្កើតឡើង ដើម្បីធ្វើជាបញ្ញត្តិករនៃទីផ្សារមូលបត្រ ដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការគ្រប់គ្រង ទីផ្សារមូលបត្រ និង អ្នកពាក់ព័ន្ធក្នុងទីផ្សារ ក្នុងគោលបំណង ធានាឱ្យទីផ្សារអាចដំណើរការបានប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និង មានសណ្តាប់ធ្នាប់ល្អ ។ *ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា* ដែលជាប្រតិបត្តិករទីផ្សារមូលបត្រ ក៏ត្រូវបានបង្កើតឡើងផងដែរ ។
  - ជាមួយនេះដែរ ការអភិវឌ្ឍធនធានមនុស្ស គឺជាការកសាងមូលដ្ឋានគ្រឹះចាំបាច់និងរឹងមាំ សម្រាប់បម្រើឱ្យការបង្កើត និងដំណើរការទីផ្សារមូលបត្រ ប្រកបដោយជោគជ័យ ។ *ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ* បានគាំទ្រដល់ការងារនេះ ដោយបានផ្តល់ការបណ្តុះបណ្តាលរយៈពេល២ឆ្នាំ (២០០៧-២០០៩) ដល់មន្ត្រីស្នូលរបស់*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* មន្ត្រីរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រី

ស្ថាប័នតុលាការ និង បុគ្គលិកមកពីស្ថាប័នឯកជននានា ដូចជា ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនច្បាប់ ក្រុមហ៊ុនសវនកម្ម ក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានសក្តានុពល ក្នុងការបោះផ្សាយ និងលក់ បណ្ណភាគហ៊ុន ។ ទន្ទឹមនឹងនេះ សិក្ខាសាលាមួយចំនួន ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ចំណេះដឹងជាសាធារណៈ ពីទីផ្សារមូលបត្រ នៅក្នុងមជ្ឈដ្ឋានសាធារណជនទូទៅ និងនិស្សិត ។

- *វិស័យធានារ៉ាប់រង :*
  - *ច្បាប់ស្តីពីធានារ៉ាប់រង* ត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ ក្នុងឆ្នាំ២០០០ ។ ដើម្បីអនុវត្តច្បាប់នេះ បទប្បញ្ញត្តិ សំខាន់ៗមួយចំនួន ដូចជា *បទប្បញ្ញត្តិនៃការផ្តល់អាជ្ញាបណ្ណ លក្ខខណ្ឌតម្រូវលើដើមទុន* និង*អភិបាលកិច្ចសាជីវកម្ម* ជាដើម ត្រូវបានអនុម័តជាបន្តបន្ទាប់ ចាប់តាំងពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៨ ។ បច្ចុប្បន្ន ក្រុមហ៊ុនធានារ៉ាប់រងឯកជន មានចំនួន ៥ និង ក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន ១ ដែលជា ក្រុមហ៊ុនចម្រុះ កំពុងប្រកបអាជីវកម្មធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា ដែលភាគលាភដុលប្រចាំ ឆ្នាំ២០០៨ មានប្រមាណជាង ២០លានដុល្លារអាមេរិក ។
- *វិស័យមីក្រូហិរញ្ញវត្ថុ :*
  - មីក្រូហិរញ្ញវត្ថុ បានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជាពិសេស ក្នុងការផ្តល់នូវធនធាន ហិរញ្ញវត្ថុ ដល់សហគ្រាសធុនតូចនិងមធ្យម ។ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បានធ្វើឱ្យមានវឌ្ឍនភាព ជាច្រើន នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយបានរៀបចំ គោលនយោបាយនិងយុទ្ធសាស្ត្រមួយចំនួន ដើម្បីរួមចំណែកអនុវត្ត *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥* ។ ព្រមជាមួយ គ្នានេះដែរ ក្រសួង ក៏បានរៀបចំសិក្សាថ្នាក់ជាតិមួយ សម្រាប់ចុះអង្កេត ពីចំនួនប្រាក់កម្ចីសរុបដែល ត្រូវការពិតប្រាកដ ពីចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនបានចុះបញ្ជី និង ពីផលប៉ះពាល់នៃមីក្រូ-ហិរញ្ញវត្ថុ ទៅលើសេដ្ឋកិច្ចជាតិ ។
  - ក្រោមវិសាលភាពនៃ*ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ* សម្រាប់ការគ្រប់គ្រង ឆ្នាំ២០០៩ រាជរដ្ឋាភិបាលបានបង្កើត *មូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម* ដើម្បី ជំរុញការអភិវឌ្ឍ វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម នៅកម្ពុជាឱ្យកាន់តែរីកលូតលាស់ បន្ថែម ទៀត ។ មិនតែប៉ុណ្ណោះ *អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់និងការអភិវឌ្ឍ វិស័យកសិកម្ម* ក៏ត្រូវបានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការ រួចហើយដែរ ។ តាមរយៈអនុក្រឹត្យនេះ ក្រសួងរៀបចំប្រកាសចំនួនបី រួមមាន (១) *ការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាគោល-នយោបាយ* (២) *ការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈកម្មការឥណទាន* (៣) *នីតិវិធីនៃការស្នើសុំ និងអនុម័ត ផ្តល់ឥណទាន* ។ ទន្ទឹមនឹងនេះ *សេចក្តីព្រាងច្បាប់ស្តីពី ជំនឿទុកចិត្តលើហិរញ្ញវត្ថុ* កំពុង ត្រូវបានរៀបចំ និងកែសម្រួល ដើម្បីពង្រីកវិសាលភាព ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ ។

- *ការគ្រប់គ្រងការជួញដូរអចលនវត្ថុ :*
  - ក្នុងទិសដៅគ្រប់គ្រង ការជួញដូរអចលនវត្ថុប្រកបដោយប្រសិទ្ធភាព *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បានរៀបចំ : (១) *ប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និង អាជ្ញាបណ្ណផ្នែកសេវាកម្មវាយតម្លៃ និង សេវាកម្មអចលនវត្ថុ* (២) *សារាចរណែនាំអនុវត្តប្រកាសស្តីពី ការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និង អាជ្ញាបណ្ណផ្នែក សេវាកម្មវាយតម្លៃ និង សេវាកម្មអចលនវត្ថុ* (៣) ក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈសេវាកម្មវាយតម្លៃ និង សេវាកម្មអចលនវត្ថុ និង (៤) ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ។
  - ទន្ទឹមនឹងនេះ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ក៏បានរៀបចំ (១) *សៀវភៅបន្ទុកស្តីពី លក្ខខណ្ឌអនុវត្តអាជ្ញាបណ្ណ សម្រាប់ សេវាកម្មវាយតម្លៃ និង សេវាកម្មអចលនវត្ថុ* (២) *សៀវភៅបន្ទុកស្តីពីលក្ខខណ្ឌអនុវត្តវិញ្ញាបនបត្រវិជ្ជាជីវៈសម្រាប់ សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ* និង (៣) *បង្កើតសមាគម អ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា* និងបានបញ្ចូលសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា ទៅជាសមាជិកពេញសិទ្ធិរបស់ *សមាគមអ្នកវាយតម្លៃអាស៊ាន* ព្រមទាំងបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ។

## ២.៤ ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ

៩៣. *<u>ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ</u>* : ទិដ្ឋភាពទាំងបីនៃភាពជាដៃគូរវាង*រាជរដ្ឋាភិបាលកម្ពុជា* និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងទៀត រួមមានទំនាក់ទំនងជាមួយ (១) សង្គមស៊ីវិល (២) ផ្នែកឯកជន និង (៣) ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ ចំពោះភាគីពីរខាងដើម :

- កិច្ចខិតខំប្រឹងប្រែងដ៏សកម្ម ត្រូវបានធ្វើជាបន្ត ដើម្បីធ្វើឱ្យមានការពាក់ព័ន្ធនិងការផ្សារភ្ជាប់ជាមួយនឹងគ្រប់ផ្នែកទាំងអស់នៃសង្គមស៊ីវិលនៅក្នុងគ្រប់ទិដ្ឋភាពសមស្របទាំងអស់ នៃកិច្ចដំណើរការរៀបចំផែនការនិងធ្វើសេចក្តីសម្រេចចិត្តរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដើម្បីរុញឱ្យប្រទេសកម្ពុជារីកចម្រើនឡើង ។ សង្គមស៊ីវិលគឺជាដៃគូដ៏សំខាន់មួយ ហើយអង្គការក្រៅរដ្ឋាភិបាលជាច្រើន ទាំងថ្នាក់ជាតិនិងអន្តរជាតិ បំពេញតួនាទីមួយដ៏សកម្ម និងប្រកបដោយការយកចិត្តទុកដាក់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចក៏ដូចជា ក្នុងការជំរុញលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ។ អង្គការទាំងនេះ មានតំណាង និងរួមចំណែកនៅក្នុងវេទិកាសហប្រតិបត្តិការនិងការពិគ្រោះយោបល់ជាន់ខ្ពស់ជាច្រើន ដូចជា វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេស ។ ច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវអនុម័តបន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ។
- នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ផ្នែកឯកជនមានតួនាទីចម្បង ជាក្បាលម៉ាស៊ីននិងជាកម្លាំងនាំមុខ សម្រាប់វិនិយោគនិងកំណើនសេដ្ឋកិច្ច ។ ដើម្បីសម្រួលនិងជួយដល់កិច្ចអភិវឌ្ឍន៍និង

វឌ្ឍនភាពប្រកបដោយសណ្តាប់ធ្នាប់របស់ផ្នែកឯកជន យន្តការមួយចំនួនត្រូវបានបង្កើតឡើង ។ ដូចដែលបានអនុវត្តរួចមកហើយ កិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការងារសហប្រតិបត្តិការ ដូចជាតាមរយៈ វេទិកាពិគ្រោះយោបល់រវាងរដ្ឋាភិបាលនិងផ្នែកឯកជន ត្រូវបានវាយតម្លៃខ្ពស់ដោយផ្នែកឯកជន ហើយ ទទួលបានផ្លែផ្កា ដូចដែលស្តែងឡើងតាមរូបភាពកំណើនដ៏មាំមួននៃការវិនិយោគរបស់ផ្នែកឯកជន ។ កិច្ចខិតខំប្រឹងប្រែងដ៏ពេញលេញ នឹងត្រូវបន្តធ្វើដើម្បីពង្រឹងនិងធ្វើឱ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងល្អនិង ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកជាមួយផ្នែកឯកជន ដោយផ្អែកលើការគោរពច្បាប់និងបទប្បញ្ញត្តិទាំងឡាយយ៉ាងខ្ជាប់ខ្ជួន និងដោយផ្តោតលើអាទិភាពអភិវឌ្ឍន៍ ។

៩៤. <u>*ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស*</u> : ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសប្រកបដោយសប្បុរសធម៌ ពីដៃគូអភិវឌ្ឍន៍ បានជួយប្រទេសកម្ពុជាយ៉ាងច្រើន ក្នុងការធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាព ដ៏គួរឱ្យកត់សម្គាល់មកដល់ពេលនេះ ។ *រាជរដ្ឋាភិបាលកម្ពុជា* វាយតម្លៃខ្ពស់ចំពោះជំនួយនេះ ។ ទំនាក់ទំនងសហប្រតិបត្តិការរវាងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និង*រាជរដ្ឋាភិបាលកម្ពុជា* បានរីកចម្រើនជាលំដាប់ និង កាន់តែមានភាពស៊ីជម្រៅ ក្នុងបណ្តាឆ្នាំកន្លងមកនេះ ហើយកំពុងតែមានលក្ខណៈរឹងមាំ ដោយផ្អែកលើការយល់ដឹងអំពីតួនាទីនិងតម្រូវការទាំងសងខាង ។ ការរីកចម្រើនជាច្រើននៅក្នុងកិច្ចដំណើរការពិគ្រោះយោបល់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រួមមាន :

- ដើម្បីណែនាំដៃគូអភិវឌ្ឍន៍ និងធានាឱ្យបានកាន់តែប្រសើរឡើងនូវការសម្របសម្រួលសមស្របនូវជំនួយទាំងអស់ពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ក្របខ័ណ្ឌយុទ្ធសាស្ត្រមួយសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ ២០០៦ ។
- វេទិកាពិភាក្សាពិគ្រោះយោបល់ធំៗប្រចាំឆ្នាំ ត្រូវបានរៀបចំធ្វើឡើង នៅក្រោមភាពជាម្ចាស់ដ៏ពេញលេញរបស់កម្ពុជា ហើយត្រូវបានដូរឈ្មោះទៅជា *វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា* ដែលត្រូវបានប្រារព្ធធ្វើជាលើកទី១ ក្នុងឆ្នាំ២០០៧ ។
- គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ជួបប្រជុំគ្នាក្នុងមួយឆ្នាំបីដង ដើម្បីពិភាក្សាបញ្ហារួម និងពិនិត្យមើលសូចនាករតាមដានរួមគ្នា ដើម្បីតាមដានត្រួតពិនិត្យពីវឌ្ឍនភាពនៃទិដ្ឋភាពផ្សេងៗរបស់ *ផយអជ* ។
- ក្រុមការងារបច្ចេកទេស ដំណើរការងាររបស់ខ្លួន ដើម្បីសម្របសម្រួលនិងតាមដានត្រួតពិនិត្យវឌ្ឍនភាព ឱ្យបានប្រសើរជាងមុន នៅកម្រិតវិស័យ ។ បន្ទាប់ពីការពិនិត្យមើលឡើងវិញនូវការអនុវត្តតួនាទីដំបូងរបស់ក្រុមការងារបច្ចេកទេស និងដោយមានការពិគ្រោះយោបល់ ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ គោលការណ៍ណែនាំដ៏ច្បាស់លាស់មួយចំនួន ត្រូវបានប្រកាសចេញ នៅក្នុងឆ្នាំ២០០៦ ។
- នីតិវិធីនិងកិច្ចដំណើរការនៃការប្រមូលទិន្នន័យជំនួយរបស់ដៃគូអភិវឌ្ឍន៍ ត្រូវបានធ្វើការកែសម្រួលឱ្យរលូន ហើយ មូលដ្ឋានទិន្នន័យនៃជំនួយអភិវឌ្ឍន៍ផ្លូវការ របស់ *គណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* ត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ។

- ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស កំពុងតែសហការគ្នាច្រើនជាងមុន នៅក្នុងចំណោមពួកគេ ហើយបានលើកជូន *រាជរដ្ឋាភិបាលកម្ពុជា* នូវបញ្ហាបារម្ភមទាំងឡាយរបស់ពួកគេ ។
- *រាជរដ្ឋាភិបាល* ប្តេជ្ញាអនុវត្ត *"ផែនការសកម្មភាពទីក្រុងអាក់ក្រា"* ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍[១] ។

៩៥. ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេសសរុបដែលបានផ្តល់មក*កម្ពុជា* មានការកើនឡើង ភាគច្រើនដោយសារការបញ្ចូលនូវជំនួយពីដៃគូ *"មិនមែនប្រពៃណី"* ទាំងឡាយ ដែលមានរហូតមកទល់ពេលនេះ ។ ទោះជាដូចនេះក្តី ជាលក្ខណៈអន្តរជាតិ ជំនួយអភិវឌ្ឍន៍ពីបណ្តាប្រទេសជឿនលឿន មិនបានបង្ហាញឱ្យឃើញពីសញ្ញាណាមួយ នៃការកើនឡើងទៅដល់កម្រិតដែលបានប្រកាន់យកដោយកិច្ចព្រមព្រៀងទីក្រុងម៉ុងតេរ៉េ ឆ្នាំ២០០១ ទេ ពោលគឺ ០,៧ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងមួយឆ្នាំ ផ្ទុយទៅវិញត្រូវបានប៉ាន់ស្មានថាបានធ្លាក់ចុះ ៨,៤ភាគរយ ក្នុង ឆ្នាំ២០០៧ បន្ទាប់ពីធ្លាក់ចុះ ៤,៧ភាគរយ ក្នុងឆ្នាំ២០០៦[២] ហើយជាមធ្យមជំនួយនេះមានតែ ០,៤៥ភាគរយ នៃ ផលិតផលក្នុងស្រុកសរុបរបស់បណ្តាប្រទេសអភិវឌ្ឍ ។ នៅប្រទេស*កម្ពុជា* កង្វះខាតមួយចំនួនដែលត្រូវដោះស្រាយ និងជំនះឱ្យបានត្រូវបានសង្កេតឃើញ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាព ជំនួយឆ្នាំ២០០៧ (*គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*) ។ លើសពីនេះទៀត ការងារដែលត្រូវធ្វើ :

- លើកលែងតែករណីមួយចំនួនតូច ដែលនៅក្នុងនោះ ការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងវិស័យ ត្រូវបានអនុវត្ត (*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា*) ការតម្រឹមតម្រង់ធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទៅនឹង *ផយអជ* មិនបានដំណើរការល្អទេ ទោះបីជាមានការសន្យាច្បាស់លាស់នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនិងទីក្រុងរ៉ូម និងកិច្ចព្រមព្រៀងកម្រិតប្រទេសដែលធ្វើឡើងដោយស្ថាប័នផ្តល់ជំនួយធំៗក្តី ។
- ក្រុមការងារបច្ចេកទេសជាច្រើន នៅមិនទាន់បានចាប់ផ្តើមពិនិត្យឡើងវិញនូវកម្មវិធីកំពុងដំណើរការទាំងអស់នៅឡើយទេ ដើម្បីតម្រឹមតម្រង់និងកែតម្រូវទិសដៅនៃកម្មវិធីទាំងនេះទៅនឹងអាទិភាពទាំងឡាយរបស់*ផយអជ* ក៏ដូចជា ទៅតាមកម្មវិធីវិនិយោគសាធារណៈ ទោះបីជាមានការអំពាវនាវច្បាស់លាស់ពីថ្នាក់ដឹកនាំខ្ពស់បំផុតនៅក្នុង*រាជរដ្ឋាភិបាលកម្ពុជា*ក្តី[៣] ។ ក្នុងន័យនេះ ធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលត្រូវការចាំបាច់នៅតែត្រូវបានបន្តចំណាយតាមរបៀបដែលធ្លាប់បានធ្វើរួចមកហើយ និងដែលត្រូវបានកំណត់ជាមុន ដោយបង្កើតបានតែការសិក្សាស្រាវជ្រាវជាច្រើន និងជំនួយបច្ចេកទេសដែលត្រូវបាន ធ្វើត្រួតគ្នា[៤] និងដោយមិនបានបន្ថែមឱ្យបានច្រើននូវ *"ការផ្ទេរធនធានសុទ្ធ"* ដែលត្រូវការយ៉ាងខ្លាំង សម្រាប់អាទិភាពរបស់ប្រទេសកម្ពុជាឡើយ ។

---

[១] បញ្ហានេះត្រូវបានពិភាក្សានៅក្នុងវេទិកាកម្រិតខ្ពស់ទី៣ ក្នុងខែកញ្ញា ឆ្នាំ២០០៨ (វេទិកាពីរមុន ត្រូវបានប្រារព្ធធ្វើនៅទីក្រុងប៉ារីស និងទីក្រុងរ៉ូម)

[២] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៨ ។

[៣] **អារម្ភកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុង *ផយអជ* និង *របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ* និង សុន្ទរកថាមួយចំនួននៅក្នុងវេទិកាជាតិនិងអន្តរជាតិ ។

[៤] *គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* បានរៀបចំ *"សេចក្តីណែនាំសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេសនៅកម្ពុជា"* និងកត់សម្គាល់នៅក្នុងឯកសារគោលជំហរសម្រាប់ការពិគ្រោះយោបល់ (មិថុនា ២០០៨) ថា កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅតែជា "បញ្ហា" ហើយស្រូបយករហូតដល់ពាក់កណ្តាលនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ព្រមទាំងអាចជាប់គាំងនៅក្នុង "លក្ខខណ្ឌស្ថានក្នុងដំណាក់កាលក្រោយវិបត្តិ" ដែលលែងសមស្របនិងហួសសម័យទៅហើយនោះ ហើយបរិមាណដ៏ច្រើននៃកិច្ចសហប្រតិបត្តិការបច្ចេកទេស គឺត្រូវតែ "ទទួលយក" ដោយការបង្ខំចិត្ត ។

## ប្រអប់ទី២

## ការកម្រិតតម្រង់ ការប្រើប្រាស់ និងគណនេយ្យភាព នូវធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស

១. *ផយអជ* បានអំពាវនាវយ៉ាងច្បាស់លាស់ឱ្យមានការកែប្រែធំៗនៅក្នុងអភិក្រមរបស់ដៃគូអភិវឌ្ឍន៍ ពោលគឺ (១) ងាកចេញពីការសិក្សាកម្រិតខ្ពស់ ដែលត្រូវចំណាយច្រើនទៅកាន់សកម្មភាពជាក់ស្តែង (២) កាត់បន្ថយជំនួយបច្ចេកទេសឱ្យបានដល់កម្រិតតិចបំផុត តាមការចាំបាច់ និង (៣) ធ្វើឱ្យមាន "ការផ្ទេរធនធានសុទ្ធ" ។ គួរឱ្យស្តាយ វឌ្ឍនភាពមកដល់ពេលនេះ នៅលើចំណុចទាំងបីនេះ មិនទាន់ត្រូវបានជំរុញលើកទឹកចិត្តឱ្យបានខ្លាំងក្លានៅឡើយ ។

២. *ផយអជ* បានណែនាំឱ្យក្រុមការងារបច្ចេកទេសចូលរួមជាបន្ទាន់នៅក្នុងការពិនិត្យមើលឡើងវិញនូវកម្មវិធីនិងគម្រោងកំពុងដំណើរការ ដែលត្រូវបានជួយដោយដៃគូអភិវឌ្ឍន៍ ដើម្បីមើលឱ្យឃើញថា តើកម្មវិធីនិងគម្រោងទាំងនេះស្របគ្នាជាមួយនឹងអាទិភាពទាំងឡាយដែលមានលើកឡើងនៅក្នុង *ផយអជ* ដែរឬទេ ។ ក្រុមការងារបច្ចេកទេសទាំងនេះ ក៏ត្រូវបានស្នើសុំឱ្យពិនិត្យមើលឡើងវិញផងដែរនូវជំនួយបច្ចេកទេសកំពុងដំណើរការទាំងអស់ (ឧទាហរណ៍ ជំនាញការនិងការសិក្សា) និងធ្វើកិច្ចខិតខំប្រឹងប្រែងប្រកបដោយមនសិការ ដើម្បីជៀសវាង ការងារត្រួតគ្នា និងដើម្បីកាត់បន្ថយការបែងចែកមូលនិធិដែលនឹងអាចត្រូវបានបញ្ចេញ សម្រាប់សកម្មភាពដែលដោះស្រាយបញ្ហាសំខាន់ៗជាងមុន ។ ប៉ុន្តែ រហូតមកទល់នឹងពេលនេះ ស្ទើរតែមិនមានក្រុមការងារបច្ចេកទេសណាមួយ ដែលបានធ្វើកិច្ចការនេះទេ មួយផ្នែកដោយសារ ក្រុមការងារបច្ចេកទេសមិនមានព័ត៌មាន គ្រប់គ្រាន់អំពីកម្រិតនិងប្រភេទនៃជំនួយដែល*ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស*ផ្តល់ឱ្យ ។

៣. គម្រោងជាច្រើននៃមូលដ្ឋានទិន្នន័យស្តីពី*ជំនួយអភិវឌ្ឍន៍ផ្លូវការ* របស់*គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* ដែលជាធាតុចូលបានមកតែពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អាចមិនត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ ២០០៩-២០១១ ទេ ដោយសារតែក្រសួងនានាដែលពាក់ព័ន្ធនឹងកម្មវិធីវិនិយោគសាធារណៈ មិនបានដឹងពីគម្រោងទាំងនោះ ។ ដូចគ្នានេះដែរ ក្រសួងផែនការមិនស្គាល់គម្រោងជាច្រើននៅក្នុងមូលដ្ឋាន ទិន្នន័យស្តីពី*ជំនួយអភិវឌ្ឍន៍ផ្លូវការ* ដែលទាក់ទងនឹងក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ ។ ការលុបបំបាត់នូវភាពខុសគ្នាទាំងនេះ គឺជាការងារបន្ទាន់ចំពោះមុខ ។ ការងារនេះ ក៏ជាប្រការចាំបាច់ផងដែរ ដើម្បីធ្វើឱ្យ*រាជរដ្ឋាភិបាលកម្ពុជា* អាចបំពេញនូវការទទួលខុសត្រូវរបស់ខ្លួន ចំពោះប្រជាជនកម្ពុជា ដើម្បីបកស្រាយពីការប្រើប្រាស់ជំនួយពីក្រៅប្រទេសដែលត្រូវបានផ្តល់ឱ្យ*កម្ពុជា* និងដើម្បីតាមដានត្រួតពិនិត្យ "ធនធានសរុប" ដែលនឹងត្រូវចំណាយឱ្យស្របទៅតាមអាទិភាពរបស់*ផយអជ* ។

៤. *ផយអជ* បានបញ្ជាក់នៅក្នុងកឋាខ័ណ្ឌ៥.១៧ ថា "ការគាំទ្រថវិកា" អាចជាយន្តការដែលចង់បានជាងគេនៃការគាំទ្រពីបរទេស ។ បន្ថែមលើប្រាក់កម្ចី និងគម្រោងជំនួយបច្ចេកទេសមួយចំនួនរបស់ *មូលនិធិរូបិយវត្ថុអន្តរជាតិ* *ធនាគារពិភពលោក* និង *ធនាគារអភិវឌ្ឍន៍អាស៊ី* ដែលត្រូវបានអនុវត្តដោយ*រាជរដ្ឋាភិបាលកម្ពុជា* វឌ្ឍនភាពបន្ថែមទៀតនៅក្នុងការប្រើប្រាស់យន្តការនេះ បានចាប់ផ្តើមតាមរយៈ ជំនួយដែលមានឈ្មោះថា *ការកាត់បន្ថយភាពក្រីក្រនិងប្រតិបត្តិការកំណើន* ដែលបានគាំទ្រដោយដៃគូអភិវឌ្ឍន៍ជាច្រើនរួមគ្នា ។ ទោះជាដូចនេះក្តី ភាគច្រើនបំផុតនៃជំនួយពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស នៅតែត្រូវបានគ្រប់គ្រង និងអនុវត្តដោយផ្ទាល់ដោយស្ថាប័នទាំងឡាយដែលពាក់ព័ន្ធដល់ការផ្តល់ជំនួយ ។ ដោយឡែក ក្រសួង-ស្ថាប័ននានារបស់*រាជរដ្ឋាភិបាលកម្ពុជា* មិនដឹងអំពីការងារជាក់ស្តែងដែលកំពុងត្រូវបានអនុវត្ត និងអំពីចំណាយរបស់ការងារទាំងនោះឡើយ ។

៥. សូចនាករតាមដានត្រួតពិនិត្យរួមគ្នា ត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្ត ដើម្បីតាមដានត្រួតពិនិត្យវឌ្ឍនភាពក្នុងដំណើរការឆ្ពោះទៅសម្រេចគោលដៅរួមនានា ។ ការបង្កើតឱ្យមានសូចនាករតាមដានត្រួតពិនិត្យរួមគ្នា សម្រាប់ឱ្យដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រេចឱ្យបាននូវ គណនេយ្យភាពការតម្រឹមតម្រង់ និងសុខុដុមនីយកម្ម គឺជាប្រការចាំបាច់ ដែលត្រូវយកចិត្តទុកដាក់ ដូចគ្នានឹងសូចនាករដទៃទៀត សម្រាប់*រាជរដ្ឋាភិបាល*ដែរ ។

៦. តម្រូវការបន្ទាន់ចំពោះមុខគឺ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដើម្បីតម្រឹមតម្រង់ធនធានរបស់ពួកគេឱ្យបានល្អប្រសើរជាងមុនទៅនឹងអាទិភាពរបស់*ផយអជ* និងដើម្បីទាញយកប្រយោជន៍ឱ្យបានច្រើនជាងមុនពីកាលានុវត្តភាពក្នុងក្រុមការងារបច្ចេកទេស សំដៅផ្តល់ដំណឹងជូន*រាជរដ្ឋាភិបាលកម្ពុជា*អំពីការងាររបស់ពួកគេ និងធ្វើការសម្របសម្រួលឱ្យបានប្រសើរជាមុនក្នុងចំណោមពួកគេ ។

## ៣. ការលើកស្ទួយវិស័យកសិកម្ម

៩៦. ផ្នែកទាំងបួននៃមុំនេះរបស់យុទ្ធសាស្ត្រចតុកោណ គឺ (១) ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មវិស័យកសិកម្ម (រួមទាំង ការបង្កាត់ពូជ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការអភិវឌ្ឍជនបទ) (២) កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន (៣) កំណែទម្រង់ជលផល និង (៤) កំណែទម្រង់ព្រៃឈើ (ដោយ រាប់បញ្ចូលការថែរក្សាបរិស្ថាននិងអភិរក្ស) ។ ប្រការដែលគួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅនេះ រួមមាន : (ក) កិច្ចខិតខំប្រឹងប្រែងជាបន្តរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការទប់ស្កាត់ការបំផ្លាញធនធានធម្មជាតិ និងបរិស្ថាន (ខ) ការស្តារនិងបង្កើនសក្តានុពលនៃការស្រោចស្រព (គ) លក្ខខណ្ឌអំណោយផលនៃធម្មជាតិ (ឃ) ការធ្វើពិពិធកម្មដំណាំឧស្សាហកម្ម (ង) ការបន្តផ្តល់បណ្ណកម្មសិទ្ធិដីជូនកសិករ និង (ច) ការបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធជនបទ ។ *យុទ្ធសាស្ត្រជាតិសម្រាប់វិស័យកសិកម្មនិងទឹក ឆ្នាំ២០០៦-២០១០* ត្រូវបានរៀបចំឡើងដោយមាន ការចូលរួមនិងការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយអ្នកមានចំណែកពាក់ព័ន្ធ ហើយ ត្រូវបានអនុម័ត ក្នុងឆ្នាំ២០០៧ ។

### ៣.១ ការលើកកម្ពស់ ផលិតភាពនិងពិពិធកម្ម វិស័យកសិកម្ម

៩៧. គោលដៅរួមរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺដើម្បី "ការកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចតាមរយៈ ការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម" ។ គោលដៅសំខាន់សម្រាប់អភិវឌ្ឍវិស័យកសិកម្ម គឺដើម្បីធានាបាននូវសន្តិសុខស្បៀង បង្កើនចំណូល បង្កើតឱ្យមានការងារធ្វើ និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភសម្រាប់ប្រជាជនទាំងអស់ តាមរយៈ ការបង្កើនផលិតភាពកសិកម្មនិងការធ្វើពិពិធភាវូបនីយកម្ម និង ការធ្វើពាណិជ្ជ-ភាវូបនីយកម្មវិស័យកសិកម្ម ដោយគិតគូរដល់ ការការពារបរិស្ថានប្រកបដោយចីរភាព និង សន្តិសុខស្បៀង ។

៩៨. *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៦-២០១០"* ត្រូវបានរៀបចំឡើងដោយ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* នៅខែតុលា ឆ្នាំ២០០៥ គឺសំដៅធ្វើឱ្យ សម្រេចបាននូវគោលដៅយុទ្ធសាស្ត្ររបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក៏ដូចជា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* ។ ទន្ទឹមនឹងនេះ *យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក* ដែលរៀបចំឡើងដោយ *ក្រុមការងារបច្ចេកទេសចម្រុះអន្តរស្ថាប័នកសិកម្មនិងទឹក* និងមានការសម្របសម្រួលពីដៃគូអភិវឌ្ឍន៍ ត្រូវបានអនុម័តនៅខែមីនា ឆ្នាំ២០០៧ ។ ប៉ុន្តែ កម្មវិធីលម្អិតសម្រាប់ទូទាំងវិស័យ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ កំពុងតែស្ថិតនៅក្នុងដំណើរការសុំការអនុម័ត ហើយរំពឹងថា នឹងហើយរួចរាល់នៅក្នុងឆ្នាំ ២០១០ នេះ ។

៩៩. *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០០៦-២០១០* បានកំណត់គោលដៅជាយុទ្ធសាស្ត្រ ចំនួនប្រាំពីរ សម្រាប់ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានដូចខាងក្រោម :

- សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្មភាវូបនីយកម្ម ។
- បង្កើន និងពង្រឹងប្រព័ន្ធស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម ។
- លទ្ធភាពចូលដល់ទីផ្សារនៃផលិតផលកសិកម្ម ។
- ក្របខ័ណ្ឌនៃការអភិវឌ្ឍស្ថាប័ន និងបញ្ញត្តិច្បាប់ ។
- កំណែទម្រង់ដីធ្លី- (ការអភិវឌ្ឍទីផ្សារដីធ្លី និងលទ្ធភាពទទួលបានដីធ្លីប្រើប្រាស់របស់អ្នកក្រ) ។
- កំណែទម្រង់វិស័យជលផល- (លទ្ធភាពប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព) ។
- កំណែទម្រង់វិស័យព្រៃឈើ- (ជំរុញការអភិរក្ស និងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងធានាឱ្យមានការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រសើរជាងមុន) ។

១០០. ដើម្បីសម្រេចបានគោលដៅនៃយុទ្ធសាស្ត្រទាំងប្រាំពីរ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានរៀបចំកម្មវិធីសកម្មភាពចំនួនប្រាំ ដូចខាងក្រោម :

*កម្មវិធីទី ១ : លើកកម្ពស់ផលិតភាព និងធ្វើពិពិធកម្មកសិកម្ម ។*

*កម្មវិធីទី ២ : លើកកម្ពស់លទ្ធភាពចូលដល់ទីផ្សារនៃផលិតផលកសិកម្ម។*

*កម្មវិធីទី ៣ : ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និងការអភិវឌ្ឍធនធានមនុស្ស ។*

*កម្មវិធីទី ៤ : គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព ។*

*កម្មវិធីទី ៥ : គ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ។*

១០១. សមិទ្ធផលគួរឱ្យកត់សម្គាល់ដែល *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* សម្រេចបាន រួមមាន : ការបង្កើនផ្ទៃដីដាំដុះដំណាំកសិកម្ម ផ្ទៃដីដាំដុះស្រូវ ទិន្នផលក្នុងមួយហិកតា តំបន់ឡូត៍នេសាទ និងតំបន់ឡូត៍ នេសាទសម្រាប់សហគមន៍នេសាទ ត្រីនេសាទបាន (ពីគ្រប់ប្រភព) ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ និង ភាគរយនៃផ្ទៃដីដែលបានដាំដុះព្រៃឈើឡើងវិញ ។ ទន្ទឹមនឹងនេះ ការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម សម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ជាពិសេស ការលើកកម្ពស់ចំណេះដឹងបច្ចេកវិទ្យាកសិកម្ម ក្នុងផ្នែកសំខាន់ៗដែលរួមមាន : (១) ការអភិវឌ្ឍពូជដំណាំអតិផលខ្ពស់ និងគុណភាពល្អ (២) វិធីសាស្ត្រក្នុងការរៀបចំដី (៣) ប្រសិទ្ធភាពនៃការប្រើប្រាស់កាកសំណល់ដំណាំគម្រប (៤) ការគ្រប់គ្រងជីជាតិដី និងការប្រើប្រាស់ជីខនិជជីសរីរាង្គ (៥) ការកំណត់ពេលវេលាប្រមូលផល និង វិធីសាស្ត្រហាលសម្ងួតនិងទុកដាក់ផលដំណាំ ។ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ ដើម្បីជំរុញការអភិវឌ្ឍ នៅក្នុងវិស័យនេះ ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ត្រូវបានរៀបចំបង្កើតឡើង ដែលក្នុងនោះរួមមាន :

- *ច្បាប់ស្តីពី ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ។*

- អនុក្រឹត្យស្ដីពី ការត្រួតពិនិត្យភូតតាមអនាម័យ ។
- អនុក្រឹត្យស្ដីពី ការបង្កើត និងការគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ ។
- អនុក្រឹត្យស្ដីពី ការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ។
- អនុក្រឹត្យស្ដីពី ការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យ អនាម័យសត្វ និងផលិតផលសត្វសាច់ ។
- ច្បាប់ស្ដីពី ជលផល ។
- អនុក្រឹត្យស្ដីពី ការគ្រប់គ្រងសហគមន៍នេសាទ ។
- អនុក្រឹត្យស្ដីពី ប្រភេទផលិតផលជលផលកំពុងរងគ្រោះថ្នាក់ ។
- អនុក្រឹត្យស្ដីពី នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬ ការជួលតាមការព្រមព្រៀង និង ការបង់ថ្លៃឈ្នួលនេសាទ ។
- អនុក្រឹត្យស្ដីពី ការតែងតាំងសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។
- អនុក្រឹត្យស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។
- អនុក្រឹត្យស្ដីពី ការធ្វើពាណិជ្ជកម្មអន្តរជាតិលើ ប្រភេទសត្វនិងរុក្ខជាតិព្រៃ ដែលកំពុងរងគ្រោះថ្នាក់ ។
- អនុក្រឹត្យស្ដីពី យថាប្រភេទនៃ ផលនិងអនុផលព្រៃឈើ ដែលអនុញ្ញាតឱ្យនាំចេញ-នាំចូល ។
- អនុក្រឹត្យស្ដីពី ការចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការធ្វើអនុបយោគ ការប្រគល់អាណត្តិកាន់កាប់ នៅ តំបន់ដីរំផុង ឃុំត្រពាំងភ្លាំង ស្រុកឈូក និង ឃុំស្ទឹងកែវ ស្រុកកំពត ខេត្តកំពត ។
- អនុក្រឹត្យស្ដីពី ការបង្កើតតំបន់គ្រប់គ្រងនិងអភិរក្ស ដែនបម្រុងសត្វក្រៀលនិងសត្វស្លាបផ្សេងៗទៀត នៅបឹងព្រែកល្ពៅ ស្រុកបូរីជលសា និង ស្រុកកោះអណ្តែត ខេត្តតាកែវ ។
- អនុក្រឹត្យស្ដីពី ការកាត់ផ្ទៃដីចេញពីតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិករបស់រុក្ខជាតិនិង សត្វព្រៃ ក្នុងខេត្តមណ្ឌលគិរី ។
- អនុក្រឹត្យស្ដីពី វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីសម្បទានរបស់រដ្ឋសម្រាប់ដាំឈើ ។
- អនុក្រឹត្យស្ដីពី ការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើង រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើ អគ្គនាយកដ្ឋាន ការតំឡើង នាយកដ្ឋានកសិកម្មត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- អនុក្រឹត្យស្ដីពី ការបង្កើតតំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់អូរយ៉ាដាវ ខេត្តរតនគិរី ។
- អនុក្រឹត្យស្ដីពី ការបង្កើតនិងអភិរក្ស តំបន់ព្រៃការពារនិងជីវៈចម្រុះ "សីមា" នៅ ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ។

១០២. ទន្ទឹមនឹងការរួមចំណែកក្នុងការបង្កើនផលិតភាពដំណាំ បច្ចេកវិទ្យាទាំងនេះ ក៏បានរួមចំណែកផងដែរ ក្នុងការធ្វើពិពិធកម្មដំណាំ តាមប្រព័ន្ធកសិកម្ម ដោយបានប្រែក្លាយពី ការធ្វើដំណាំស្រូវតែមួយមុខក្នុងមួយឆ្នាំ មកជាការដាំដំណាំចម្រុះនិងការចិញ្ចឹមសត្វ ដោយធ្វើការកំណត់នូវ ប្រភេទដី ប្រភេទដំណាំ ពេលវេលា និងវិធីសាស្ត្រដាំដុះសមស្រប នៅមុននិងក្រោយពេលដាំដុះស្រូវវស្សា ក៏ដូចជា ការកំណត់នូវប្រភេទដំណាំឆ្លាស់សម្រាប់តំបន់ចម្ការជាដើម ។ លើសពីនេះទៀត *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានថែរក្សាអភិរក្សពូជស្រូវ ចំនួន ២.៥៩៧ បញ្ជីក និងបានកំណត់នូវ ពូជស្រូវដែលធន់ទ្រាំទៅនឹង ទឹកជំនន់ ការរាំងស្ងួត និងមមាចត្នោត ព្រមទាំង បានចាប់ផ្តើមធ្វើការអភិរក្សពូជដំណាំ ផ្សេងៗទៀត ដូចជា ចេក ដំឡូងមី ម្ទេស និងល្ហុង ជាដើម ដើម្បីធានាការប្រើប្រាស់ប្រកបដោយចិរភាពនូវ ធនធានធម្មជាតិរបស់ប្រទេស*កម្ពុជា* ។ ទន្ទឹមនឹងនេះ ការផ្សព្វផ្សាយនូវចំណេះដឹងបច្ចេកវិទ្យាទាំងនេះ ត្រូវបានលើកកម្ពស់ តាមរយៈ ការធ្វើឱ្យប្រសើរឡើងនូវការផ្សារភ្ជាប់គ្នារវាង ការស្រាវជ្រាវ និងការផ្សព្វផ្សាយតាមរូបភាព ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ក្នុងនោះរួមមាន ទិវាស្រែកសិករ សិក្ខាសាលាសន្និបាត សន្និសីទ វគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យម ទាំងក្នុងនិងក្រៅប្រទេស ។

១០៣. ក្នុងអំឡុងពេលពី ឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៨ ផលិតផលកសិកម្ម មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយស្ថាប័នជំនាញពាក់ព័ន្ធទាំងឡាយ បានខិតខំប្រឹងប្រែង ធ្វើឱ្យមានការផ្លាស់ប្តូរទម្លាប់របស់កសិករ ក្នុងការដាំដុះការថែទាំ និងការប្រមូលផល ដំណាំ និង ធ្វើឱ្យមានការកើនឡើងសមត្ថភាពស្រោចស្រពផលដំណាំ រួមជាមួយនឹងកត្តា អំណោយផលពីធម្មជាតិ ។ ចំណែកនៃវិស័យកសិកម្មក្នុង *ផសស* សរុប មាន ៥,៥ ភាគរយ ក្នុងឆ្នាំ២០០៦ ៥,០ ភាគរយ នៅក្នុងឆ្នាំ២០០៧ និង ៥,៧ ភាគរយ នៅឆ្នាំ២០០៨ ។ នៅឆ្នាំ២០០៨ ផ្ទៃដីដាំដុះដំណាំស្រូវសរុបមានប្រមាណ ២,៦១ លានហិកតា ដោយទទួលបាន ផលស្រូវប្រមាណ ៧,១៥ លានតោន ដោយមានទិន្នផលស្រូវមធ្យម ២,៧៤ តោន ក្នុងមួយហិកតា ហើយមាន ផលិតផលលើស គិតជាអង្ករ ប្រមាណ ២,០២ លានតោន ។

១០៤. នៅក្នុងអំឡុងពេលពី ឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៨ ផលិតកម្មសត្វ មានការកើនបង្គួរ ហើយ ចំនួនសត្វគោ-ក្របី មានការកើនឡើងប្រមាណ ២,៥ ភាគរយ ក្នុងមួយឆ្នាំ ។ ចំនួនសត្វជ្រូក មានការថយចុះ ពី ២,៤២ លានក្បាលនៅឆ្នាំ២០០៤ មកនៅត្រឹមតែ ២,២១ លានក្បាល នៅឆ្នាំ២០០៨ ដោយសារ ការកើនឡើងនៃលំហូរចូលនូវផលិតផលសត្វជ្រូក ពីបណ្តាប្រទេសជិតខាង ។ ការរួមចំណែករបស់អនុវិស័យចិញ្ចឹមសត្វក្នុងសេដ្ឋកិច្ចជាតិ មានការកើនឡើងជាលំដាប់ ហើយមានអត្រាប្រមាណ ៤ ភាគរយ ។ អនុវិស័យនេះ ចាំបាច់ត្រូវធ្វើឱ្យមានការកើនឡើងដើម្បីឆ្លើយតបបានទៅនឹង តម្រូវការក្នុងស្រុក សំដៅលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និង សំដៅបម្រើដល់ឧស្សាហកម្មទេសចរណ៍ ។ ការងារដែលជាអាទិភាពខ្ពស់របស់*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* រួមមាន : (១) ការកសាងក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងការអភិវឌ្ឍធនធានមនុស្ស (២) ការកាត់បន្ថយអត្រាសត្វឈឺនិងស្លាប់ (៣) ការធ្វើឱ្យប្រសើរឡើងនូវសុខភាពសាធារណៈ ជាពិសេស បញ្ហាសុខភាពដែលពាក់ព័ន្ធ

នឹងជំងឺមានប្រភពមកពីសត្វនិងបញ្ហាសុវត្ថិភាពម្ហូបអាហារ (៤) ការជំរុញផលិតកម្មចំណីសត្វ (៥) ការកែលម្អគុណភាពពូជសត្វ (៦) ការជំរុញការកែច្នៃលាមកសត្វដើម្បីការផលិតជីវឧស្ម័ន (៧) ការបង្កើននិងការពង្រឹងការស្រាវជ្រាវនិងការផ្សព្វផ្សាយ អំពីការងារផលិតកម្មសត្វនិងបសុព្យាបាល (៨) ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់ឥណទានដល់ផលិតកម្មសត្វ (៩) ការលើកទឹកចិត្តដល់ការវិនិយោគលើការចិញ្ចឹមសត្វនិងបសុព្យាបាល និង (១០) ការជំរុញលើកទឹកចិត្តដល់ទីផ្សារសត្វនិងផលិតផលដែលមានប្រភពពីសត្វ ។

១០៥. ទោះបីជាមានវឌ្ឍនភាព ដូចបានរៀបរាប់ខាងលើក៏ដោយ ក៏ វិស័យនេះ នៅតែជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម :

- បញ្ហាប្រឈមក្នុងផលិតកម្មកសិកម្ម រួមមាន (១) ការបង្កើនផលិតភាពដំណាំស្រូវនិងដំណាំផ្សេងៗទៀត (២) ការបង្កើននិងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន សេវាផ្សព្វផ្សាយ ឥណទាន និង កត្តាផលិតកម្ម (៣) ការបង្កើនការស្រោចស្រព (៤) ការធានាឱ្យមានផលប្រយោជន៍ប្រសើរជាងមុនសម្រាប់កសិករ តាមរយៈ ការរកទីផ្សារ និង (៥) កង្វះការយល់ដឹងរបស់កសិករ ក្នុងការប្រើប្រាស់កត្តាផលិតកម្មកសិកម្ម ការគ្រប់គ្រងបច្ចេកទេស និងការកែលម្អដី ។
- ការបង្កើតឧបករណ៍ផ្នែកច្បាប់និងបទប្បញ្ញត្តិសមស្រប និងការលើកកម្ពស់សមត្ថភាពក្នុងការអនុវត្តច្បាប់ សម្រាប់ការតាមដាននិងត្រួតពិនិត្យកត្តាផលិតកម្មកសិកម្ម និង ការគ្រប់គ្រងដីកសិកម្មនិងជីជាតិដី ដូចជា *ច្បាប់ស្តីពីដីកសិកម្ម* ដែលកំណត់នូវតំបន់ដីដែលត្រូវរក្សាទុកសម្រាប់ ផលិតកម្មកសិកម្មនិងការគ្រប់គ្រងជីជាតិដីឱ្យបានល្អ ។
- បញ្ហាប្រឈមនៅក្រោយពេលប្រមូលផល រួមមាន (១) ការកែលម្អការគ្រប់គ្រងក្រោយពេលប្រមូលផល (២) ការជំរុញទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញសម្រាប់កសិផល (រួមមាន អង្ករ ផ្លែឈើ និង បន្លែ) (៣) ការជំរុញកសិ-ឧស្សាហកម្ម រួមមាន ការកែច្នៃក្រោយពេលប្រមូលផល ការកែលម្អគុណភាពនៃស្តង់ដារកសិផល ការបង្កើតសមាគមកសិករដើម្បីបង្កើនអំណាចតថ្លៃ (៤) ការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវជីធម្មជាតិ និងធនធានផ្សេងៗទៀត និង (៥) ការលើកទឹកចិត្តនិងការបង្កើន នូវការវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជន ។
- បញ្ហាប្រឈមក្នុងការផ្តល់ការគាំទ្រដល់កសិករ រួមមាន (១) បង្កើតយន្តការនានានៅថ្នាក់មូលដ្ឋាន ដែលអាចផ្តល់បច្ចេកទេសនិងសេវាកម្មដល់កសិករផ្ទាល់ (២) ការជំរុញកម្មវិធីផ្សព្វផ្សាយកសិកម្មនៅថ្នាក់មូលដ្ឋាន (៣) ការជំរុញការរៀបចំបង្កើតអង្គការនានា សម្រាប់កសិករ ដើម្បីធ្វើជាដៃគូដ៏មានប្រសិទ្ធភាព ជាមួយផ្នែកឯកជន ។

១០៦. ផលិតកម្មសត្វនៅកម្ពុជា ត្រូវបានទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ដែលបណ្តាលមកពី :

- ការគំរាមកំហែងផ្ទួនៗពី ការរាលដាលជាសាកលនៃជំងឺឆ្លងសត្វដ៏កាចសាហាវផ្សេងៗ ជាពិសេស ជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយប្រភេទថ្មី និង ពីគ្រោះមហន្តរាយធម្មជាតិ ដូចជា ខ្យល់ព្យុះ*កេតសាណា* ដែលបានធ្វើឱ្យមានការបាត់បង់នូវធនធាន និង ជីវិតមនុស្ស-សត្វ ជាច្រើន ។
- ធនធាន សម្រាប់ទប់ស្កាត់ការរាលដាលនៃជំងឺឆ្លងសត្វ និងសម្រាប់ការពារនិងថែទាំសុខភាពសត្វ នៅមានកម្រិត នៅឡើយ ។
- ការស្ទាក់ស្ទើររបស់វិនិយោគិនមួយចំនួន ក្នុងការវិនិយោគលើផលិតកម្មសត្វ ក្រោយពេលមានជំងឺផ្តាសាយបក្សី និង ឥទ្ធិពលនៃផលិតផលសត្វ នាំចូលពីក្រៅប្រទេស ។
- ពុំទាន់មានការប្រកួតប្រជែងក្នុងទីផ្សារសត្វ និងចំណីសត្វ ដែលធ្វើឱ្យចំណីសត្វមានតម្លៃខ្ពស់ ។
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងអនុវិស័យនេះ ពុំទាន់បានរៀបចំឱ្យបានគ្រប់គ្រាន់ និងពេញលេញ សម្រាប់ការអនុវត្ត ប្រកបដោយប្រសិទ្ធភាព នៅឡើយ ។

## ៣.២ កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន

១០៧. ដី គឺជាប្រភពធនធានដ៏មានតម្លៃរបស់ប្រជាជនកម្ពុជា សម្រាប់ការអភិវឌ្ឍ ។ គោលនយោបាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺធានាថា ដីទាំងអស់ត្រូវបាន គ្រប់គ្រង រៀបចំប្រើប្រាស់ និងបែងចែក ប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និង ចីរភាព ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាន ការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ កិច្ចការពារជាតិ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ ។ សេចក្តីថ្លែងការណ៍របស់*រាជរដ្ឋាភិបាលកម្ពុជា* ស្តីពីគោលនយោបាយដីធ្លី បានលើកឡើងពីបញ្ហាដែលទាក់ទងនឹង *រដ្ឋបាលដីធ្លី* (ដើម្បីបញ្ជាក់ និងកត់ត្រានូវម្ចាស់កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត លើដីធ្លី) *ការគ្រប់គ្រងដី* (ដើម្បីធានាថាដីធ្លី និងធនធានធម្មជាតិត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព) និង *ការបែងចែកដីធ្លី* (ដើម្បីបែងចែកដីរដ្ឋ សម្រាប់គោលបំណង សាធារណៈ និង ឯកជន តាមរូបភាពមួយ ដែលមានតម្លាភាព សមធម៌ មានលក្ខណៈវិមជ្ឈការ និង មានភាពយុត្តិធម៌) ។

១០៨. នៅក្នុងផ្ទៃដីសរុបប្រមាណ ១៨,១លានហិកតា ផ្ទៃដីដែលគ្រប់គ្រងដោយរដ្ឋមានប្រមាណ ១៤,៥លានហិកតា និងគ្រប់គ្រងដោយឯកជនមានប្រមាណ ៣,៦លានហិកតា (ស្មើនឹង ២០ភាគរយ) ។ *ច្បាប់ភូមិបាល* បានបញ្ជាក់លម្អិតអំពី ម្ចាស់កម្មសិទ្ធិដីធ្លី ការប្រើប្រាស់ដីធ្លី និង ការគ្រប់គ្រងដីធ្លី ។ *ច្បាប់ភូមិបាល* នេះ បានបែងចែកកម្មសិទ្ធិជាបីប្រភេទ គឺ :

- *កម្មសិទ្ធិសាធារណៈ* រួមមាន កម្មសិទ្ធិលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង កម្មសិទ្ធិលើទ្រព្យឯកជនរបស់រដ្ឋ ។ កម្មសិទ្ធិសាធារណៈ គឺជាទ្រព្យដែលមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះ

មិនអាចកំណត់អាជ្ញាយុកាលបានទេ ពោលគឺត្រូវគ្រប់គ្រងនិងប្រើប្រាស់ ក្នុងគោលបំណងសាធារណៈ ដូចជា អគាររបស់រដ្ឋ ហេដ្ឋារចនាសម្ព័ន្ធ ឬផលប្រយោជន៍បរិស្ថាន (ការអភិរក្ស ព្រៃធម្មជាតិ ស្ទឹង បឹង ទន្លេ ដីឆ្នេរសមុទ្រ និងផ្សេងៗទៀត) ប៉ុន្តែ នៅពេលដែលទ្រព្យនោះបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈ*ច្បាប់អនុបយោគ* ។ រីឯ កម្មសិទ្ធិឯកជនរបស់រដ្ឋ រួមមាន ដីសម្បទានសេដ្ឋកិច្ច (ដីសម្រាប់ ការដាំដុះទ្រង់ទ្រាយធំ ការធ្វើកសិដ្ឋានជាលក្ខណៈ ពាណិជ្ជកម្ម ការធ្វើអាជីវកម្មរ៉ែ) និង ដីសម្បទានសង្គមកិច្ច ។

- *កម្មសិទ្ធិសមូហភាព* រួមមាន កម្មសិទ្ធិលើទ្រព្យទីអារាម និងកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ។
- *កម្មសិទ្ធិឯកជន* រួមមាន កម្មសិទ្ធដែលត្រូវគ្រប់គ្រងដោយបុគ្គលម្នាក់ៗ ជាលក្ខណៈឯកត្តជនឬនីតិបុគ្គល ។

១០៩. *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ថា កំណែទម្រង់ដីធ្លីមានសារៈសំខាន់ណាស់ សម្រាប់ ការលើកកម្ពស់ស្ថិរភាពសង្គម ការអភិវឌ្ឍទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធភាព ចីរភាពបរិស្ថាន និងសម្រាប់ការបង្កើន ផលិតកម្មកសិកម្ម តាមរយៈ ការផ្តល់បណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ជាពិសេស ជូនដល់ប្រជាកសិករដែលកំពុងធ្វើការដាំដុះលើដីធ្លី ដែលពួកគាត់កំពុងកាន់កាប់ ។ ការផ្តល់បណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ មានសារៈសំខាន់ណាស់ សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងការប្រើប្រាស់ដី ជាពិសេស ការគ្រប់គ្រងដីកម្មសិទ្ធិរដ្ឋ ដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី តាមរូបភាពមួយ ដែលមាន តម្លាភាព និង សមធម៌ ព្រមទាំង ដើម្បីបន្តកាត់បន្ថយភាពក្រីក្រដោយជួយឱ្យប្រជាពលរដ្ឋអាចមានលទ្ធភាព ប្រើប្រាស់ទីផ្សារហិរញ្ញវត្ថុ ដោយប្រើប្រាស់បណ្ណកម្មសិទ្ធិជាវត្ថុបញ្ចាំក្នុងការខ្ចីបុល ។ តាមការប៉ាន់ស្មាន ក្នុងឆ្នាំ២០០១ ក្បាលដីជាទ្រព្យឯកជន នៅទូទាំងប្រទេស ដែលត្រូវធ្វើការចុះបញ្ជី សរុបមានប្រមាណ ៦ ទៅ ៧លាន ក្បាលដី ។ ផ្អែកលើមូលដ្ឋាននេះ *រាជរដ្ឋាភិបាលកម្ពុជា* បានកំណត់រយៈពេល ១៥ឆ្នាំ ដើម្បីជំរុញការចុះបញ្ជីក្បាលដីទាំងនោះ នៅក្រោម *កម្មវិធីកំណែទម្រង់ដីធ្លី* មួយ ដែលប្រមូលផ្តុំលើការពង្រឹងអនុវិស័យចំនួន ៣ គឺ *រដ្ឋបាលដីធ្លី ការរៀបចំដែនដី* និង *ការបែងចែកដីធ្លី* ។ ដើម្បីអនុវត្តកម្មវិធីផែនការ ៥ឆ្នាំ លើកទី១ សម្រាប់ដំណាក់កាលឆ្នាំ ២០០២-២០០៧ ត្រូវបានរៀបចំឡើង ដើម្បីធ្វើការចុះបញ្ជីដីឱ្យបាន ១លានក្បាលដី ។

១១០. *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តល់អាទិភាពខ្ពស់ដល់កំណែទម្រង់ដីធ្លី សម្រាប់ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព ។ អាទិភាពនោះ ផ្តោតលើ ការពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ទាំងដីរដ្ឋ ដីឯកជន និង ដីសហគមន៍ជនជាតិដើមភាគតិច តាមរយៈ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងដាច់ដោយដុំ ដើម្បីផ្តល់បណ្ណកម្មសិទ្ធិ ជូន ប្រជាពលរដ្ឋទូទៅ ស្ថាប័ន និង សហគមន៍ជនជាតិដើមភាគតិចដែលមានសិទ្ធិកាន់កាប់ ។ ដើម្បីពង្រឹងការគ្រប់គ្រងដីធ្លី ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ *ច្បាប់ភូមិបាល* ត្រូវបានរៀបចំឡើងនិងអនុម័តដាក់ឱ្យប្រើប្រាស់ ជាបន្តបន្ទាប់ ដែលក្នុងនោះ រួមមាន :

- *អនុក្រឹត្យស្តីពី ការគ្រប់គ្រង ដីរដ្ឋ ។*
- *អនុក្រឹត្យស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ។*
- *អនុក្រឹត្យស្តីពី នីតិធីនៃការធ្វើ ផែនការប្រើប្រាស់ដីនៅក្នុង ឃុំ-សង្កាត់ ។*
- *អនុក្រឹត្យស្តីពី ការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ ។*
- *សារាចរស្តីពី ការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ។*
- *ប្រកាសរួមស្តីពី ការកំណត់អត្តសញ្ញាណកម្ម ការចាត់ថ្នាក់ និង ការគូសផែនទី ដីរដ្ឋ ។*
- *ប្រកាសរួមស្តីពី យន្តការសម្រាប់ការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្ម ដល់កសិករប្រើប្រាស់ដីសម្បទានសង្គមកិច្ច ។*
- *សេចក្តីណែនាំរួមស្តីពី ការពង្រឹងការងាររបស់គណៈកម្មការសុរិយោដី នៅគ្រប់កម្រិត ។*
- *សេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស* (កំពុងសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ) ។

១១១. សមិទ្ធផលធំៗជាច្រើន ត្រូវបានបង្កើតឡើង នៅក្នុងការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ។ បណ្ណចំនួន ១ ៦៦៤ ២៩៧ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ក្នុងនោះមាន ៣/៤ ជាដីនៅតំបន់ជនបទ និង ១/៤ ជាដីតំបន់ទីក្រុង ទីប្រជុំជន ហើយ បណ្ណកម្មសិទ្ធិដីធ្លីចំនួន ១០៧០៦៦៥ ត្រូវបានផ្តល់តាមរយៈ ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និង៥៩៣៦៤៥ បណ្ណ តាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ពោលគឺ ប្រមាណ ២៣ភាគរយ ទៅ ២៤ភាគរយ នៃចំនួនក្បាលដីឯកជនសរុបទូទាំងប្រទេសត្រូវបានចុះបញ្ជី ។ ចំណុចដៅដែលកំណត់នៅក្នុង *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* សម្រាប់ឆ្នាំ២០១០ គឺការចុះបញ្ជីដីឱ្យបាន ៣២ភាគរយ ដែលក្នុងនោះមាន ២៤ភាគរយ ជាដីដែលត្រូវកាន់កាប់ដោយប្រជាកសិករ ហើយ ៦៥ភាគរយ ដល់ឆ្នាំ២០១៥ ដែលក្នុងនោះ ៤៨,៧៥ភាគរយ ជាដីដែលត្រូវកាន់កាប់ដោយប្រជាកសិករ ។ ក្នុងចំណោមបណ្ណកម្មសិទ្ធិដីធ្លី ដែលបានផ្តល់ជូនរហូតមកដល់បច្ចុប្បន្ននេះ មាន ៧០ភាគរយជាប្រភេទទ្រព្យរួមប្តីប្រពន្ធ ២០ភាគរយជាទ្រព្យផ្ទាល់របស់ស្ត្រី ៥ភាគរយជាទ្រព្យផ្ទាល់របស់បុរស និង ៥ភាគរយផ្សេងទៀត ជាទ្រព្យផ្ទាល់របស់ទីអារាម ។ ដើម្បីពង្រឹងរដ្ឋបាលដីធ្លីឱ្យដំណើរការប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងក្នុងភាពជាដៃគូជាមួយផ្នែកឯកជន ក្នុងការវាស់វែងនិងការវាយតម្លៃថ្លៃដី *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយច្បាប់មួយ ដែលក្នុងនោះរួមមាន : *ច្បាប់ស្តីពីការវាស់វែងនិងផែនទី ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស គោលនយោបាយវាយតម្លៃថ្លៃដីនិងផែនទីថ្លៃដី* ការធ្វើវិសោធនកម្ម *ច្បាប់ភូមិបាល* លើចំណុច *"ការចុះបញ្ជីអចលនវត្ថុ"* ដែលពាក់ព័ន្ធនឹង *ក្រមនីតិវិធីរដ្ឋប្បវេណី* និង *ក្រមរដ្ឋប្បវេណី* ។ល។

១១២. ចំពោះការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ នៅក្នុងតំបន់អនុវត្តសាកល្បងចំនួនបីសហគមន៍ ក្រុមការងារបានបញ្ចប់ដំណាក់កាលនៃការធ្វើអត្តសញ្ញាណកម្មដី និង ការកំណត់

ព្រំប្រទល់ដី ដោយបានធ្វើការពិគ្រោះយោបល់ពីបញ្ហាព្រំប្រទល់ដី ជាមួយអ្នកពាក់ព័ន្ធនានា ។ ការងារក្នុងជំហានបន្ទាប់ គឺ ការឈានទៅបោះបង្គោលទីតាំង និង ការបញ្ចប់ជាស្ថាពរនូវការចុះបញ្ជីតំបន់សាកល្បងទាំង ៣ នេះ នៅដើម ឆ្នាំ២០១០ ក៏ដូចជា ការបន្តអនុវត្ត*អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច* សម្រាប់សហគមន៍ដែលមានការទទួលស្គាល់ជាផ្លូវការរួចហើយ ក្នុងក្របខណ្ឌទូទាំងប្រទេស ជាពិសេស សហគមន៍ជនជាតិដើមភាគតិច នៅខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី ។

១១៣. នៅក្នុងការងារដោះស្រាយវិវាទដីធ្លី ដែលមានចំនួនសរុប ៥១៩៣ ករណី *គណៈកម្មាធិការសុរិយោដី* គ្រប់ថ្នាក់ បានសម្រេចលទ្ធផលការងារ ដូចខាងក្រោម :

- វិវាទចំនួន ១៨១០ ករណី ពាក់ព័ន្ធនឹង ៨៥៦០ គ្រួសារ និង ផ្ទៃដីទំហំ ៣០៥៧,២ ហិកតា ត្រូវបាន ដោះស្រាយ ជាស្ថាពរ ។
- សំណុំរឿងដែលបានដកពាក្យបណ្តឹងវិញ មានចំនួន ២៧២ ករណី ។
- វិវាទចំនួន ១៣៦៩ ករណី មិនត្រូវបានទទួលយកមកដោះស្រាយទេ ដោយសារ មិនមានលក្ខណៈសមស្របទៅតាមយុត្តាធិការរបស់ *គណៈកម្មការសុរិយោដី* ។
- វិវាទចំនួន ១ ៧៤២ ករណី ត្រូវបានព្យួរទុកមិនទាន់ដោះស្រាយ ។

១១៤. ចំនួនករណីវិវាទដែលត្រូវបានបញ្ជូនមក *គណៈកម្មាធិការសុរិយោដី* បានថយចុះ ពីមួយឆ្នាំ ទៅ មួយឆ្នាំ ប្រមាណ ២០ ភាគរយ ហើយ ការដោះស្រាយ មានការកើនឡើងជិត ៥៦ ភាគរយ ។ តាមរយៈនីតិវិធីដោះស្រាយវិវាទចល័ត សំណុំរឿងវិវាទដីធ្លី ដែលកកស្ទះនៅស្រុកចំនួន ១០ ( *ស្រុក មេមត់ ពញាក្រែក ជើងព្រៃ កោះសូទិន ស្ទឹងត្រង់ ពាមជ័រ បារាយណ៍ ប៉ោយប៉ែត ល្វេក និង ក្រុងបាត់ដំបង*) ត្រូវបានដោះស្រាយបញ្ចប់ ទាំងស្រុង ។

១១៥. ដើម្បីពង្រឹង*ការរៀបចំដែនដី* ដំណើរការកសាង ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យនេះ ដូចជា *គោលនយោបាយរៀបចំដែនដី គោលនយោបាយជាតិស្តីពីលំនៅឋាន សារាចរណែនាំស្តីពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នក្នុងទីក្រុងឬទីប្រជុំជន* និង *ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* កំពុងតែប្រព្រឹត្តទៅ ក្នុងក្របខ័ណ្ឌនៃក្រុមការងារអន្តរក្រសួង ។ ដើម្បីជំរុញការអនុវត្តនូវដំណើរការអភិវឌ្ឍន៍ការប្រើប្រាស់ដីនៅទីក្រុងនិងទីប្រជុំជន *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* បាននិងកំពុងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដល់អាជ្ញាធររដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីប្រមូល ផ្ទៀងផ្ទាត់ វិភាគ និងពិភាក្សាពិគ្រោះយោបល់លើទិន្នន័យ ពីខេត្តចំនួន ១០ និងពីគ្រប់ភាគីពាក់ពន្ធ័ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅទីក្រុងនិងទីប្រជុំជននិងខេត្ត ។ ជាលទ្ធផល ការរៀបចំផែនការប្រើប្រាស់ដីធ្លីសម្រាប់ *ក្រុងស្ទឹងហាវ* និង *ក្រុងបាវិត* ត្រូវបានបញ្ចប់ជាស្ថាពរ ដោយឡែក សម្រាប់ *ក្រុងក្រចេះ ក្រុងអ្នកលឿង*

និង *ក្រុងអន្លង់វែង* កំពុងស្ថិតនៅក្នុងដំណាក់កាលនៃការពិភាក្សាបញ្ចប់ ។ ទន្ទឹមនឹងនេះ ការរៀបចំផែនការប្រើប្រាស់ដីធ្លី សម្រាប់ក្រុងផ្សេងៗទៀត កំពុងស្ថិតនៅក្នុងដំណាក់កាល នៃការបន្តប្រមូលទិន្នន័យ ពីស្ថាប័នពាក់ព័ន្ធ ។ ជាមួយគ្នានេះ ប្លង់យុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ *រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពង់ចាម* និង ខេត្តមួយចំនួនទៀត ដែលមានសក្តានុពលសេដ្ឋកិច្ច ក៏កំពុងត្រូវបានធ្វើការការសិក្សាបញ្ចប់ និង ត្រូវបានចាត់ចែងជាបន្តទៀតសម្រាប់ការអនុម័ត ។

១១៦. *រាជរដ្ឋាភិបាល* បាននិងកំពុងអនុវត្តគោលនយោបាយបែងចែកដី ដល់ ប្រជាជនក្រីក្រ និងគ្រួសារកងកម្លាំងប្រដាប់អាវុធកំពុងឈរជើងការពារទឹកដីនៅភាគខាងលិចនិងពាយ័ព្យនៃប្រទេស ដែលគ្មានដីនិងខ្វះដី តាមរយៈកម្មវិធីផ្តល់សម្បទានដីសង្គមកិច្ច ដែលផ្តួចផ្តើមដោយថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។ *ផយអជ ២០០៦-២០១០* បានកំណត់ផ្តល់ដី ដល់គ្រួសារប្រជាពលរដ្ឋក្រីក្រ ដែលគ្មានដី ចំនួន ១០ ០០០គ្រួសារ នៅក្រោមកម្មវិធីនេះ ។ ដើម្បីសម្រេចបាននូវចំណុចដៅនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានដាក់ចេញនូវ*សារាចរណែនាំស្តីពីផែនការបែងចែកសម្បទានដីសង្គមកិច្ច* ដោយតម្រូវឱ្យរាជធានីនិងខេត្តនីមួយៗរកដី ដើម្បីធ្វើផែនការអនុវត្តឱ្យបានចំនួន ៤១៦ គ្រួសារក្នុងមួយឆ្នាំ ។ ក្នុងស្មារតីនេះ ខេត្តចំនួន ១២ បានកំណត់រួចហើយ នូវមុខសញ្ញាដី សរុបទំហំ ៣៦ ៩១៧ ហិកតា និងមុខសញ្ញាគ្រួសារប្រជាពលរដ្ឋក្រីក្រគ្មានដី ចំនួន ១៤ ៧៩១ គ្រួសារ ។ នៅក្នុងចំណោមខេត្តទាំងនេះ ខេត្តដែលបានអនុវត្តការបែងចែកដីរួចហើយ រួមមាន :

- *ខេត្តកំពង់ចាម* : ផ្ទៃដីទំហំ ៨៦៣,៦៥ ហិកតា ដល់ ២៤៦ គ្រួសារក្រីក្រ ។
- *ខេត្តក្រចេះ* : ផ្ទៃដីទំហំ ៣៩០៦ ហិកតា ដល់ ២៤៦ គ្រួសារក្រីក្រ និងបន្តពិនិត្យផ្តល់ដល់ ៣៥០ គ្រួសារទៀត ។
- *ខេត្តឧត្តរមានជ័យ* : ផ្ទៃដីដោះមីនរួច ទំហំ ១២៩ ហិកតា ដល់ ៩៥ គ្រួសារក្រីក្រ ។
- *ខេត្តកំពត* : ផ្ទៃដីទំហំ ១ ០១៩ ហិកតា ដល់ ៣១៧ គ្រួសារអតីតយុទ្ធជនពិការក្រីក្រ ។
- *ខេត្តកំពង់ចាម* : ផ្ទៃដីទំហំ ១៥៥ ហិកតា ដល់ ១០០ គ្រួសារក្រីក្រ ។
- *ខេត្តព្រះវិហារ* : ផ្ទៃដីទំហំជាង ១៨០០០ ហិកតា ដល់គ្រួសារកងកម្លាំងប្រដាប់អាវុធនិងប្រជាពលរដ្ឋនៅតំបន់ប្រាសាទព្រះវិហារ តំបន់ភាគខាងលិច និងតំបន់ពាយ័ព្យនៃប្រទេសតាមបណ្តោយព្រំដែន*កម្ពុជា-ថៃ* សរុបចំនួន ១ ៨០២ គ្រួសារ ដោយរៀបចំជាភូមិអភិវឌ្ឍន៍ថ្មី ( *ជាកម្មវិធីផ្តួចផ្តើមដោយថ្នាក់ជាតិ* ) ។

១១៧. ទោះបីជាមានវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមាននូវកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីបង្កើនទំនុកចិត្តរបស់ប្រជាជន លើការងារគ្រប់គ្រងដីធ្លី :

- ការកសាងវប្បធម៌នៃការចុះបញ្ជី និងការពង្រឹងជំនឿរបស់ប្រជាពលរដ្ឋលើប្រព័ន្ធសុរិយោដី គឺជាប្រការចាំបាច់ដែលត្រូវធ្វើឡើង តាមរយៈ ការពិនិត្យមើលឡើងវិញនូវស្ថានភាពបច្ចុប្បន្ននៃ ការផ្តល់សេវាផ្នែក

ស៊ិរិយោដី និងសេវាពាក់ព័ន្ធនឹងការងារសំណង់ ដែលត្រូវអនុវត្តតាមរូបមន្តច្រកចេញ-ចូលតែមួយ ដែលមានតម្លាភាព គណនេយ្យភាព ភាពឆាប់រហ័ស តម្លៃថោក និង ភាពត្រឹមត្រូវយុត្តិធម៌ ក៏ដូចជា ការពិនិត្យមើលឡើងវិញនូវ អត្រាសម្រាប់វាយតម្លៃពន្ធប្រថាប់ត្រាលើការចុះបញ្ជីបន្ត ដោយបង្កើតឡើងដោយមានការចូលរួម នូវ ប្រព័ន្ធវាយតម្លៃថ្លៃដី ផែនទីថ្លៃដី និងប្រព័ន្ធព័ត៌មានដីធ្លីមួយ ដែលអាចជឿទុកចិត្តបាន និងដឹងឮជាសាធារណៈ និងសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននីមួយៗ មុននឹងឈានទៅធ្វើ ការប្រមូលពន្ធលើដីធ្លីនិងផ្ទះសម្បែង ដែលចាប់ពីឆ្នាំ២០១០ និងការប្រមូលពន្ធលើដីធ្លីទាំងឡាយដែលមិនមែនជាដីកសិកម្មជាលក្ខណៈគ្រួសាររបស់ប្រជាកសិករ ។

- ជំរុញល្បឿនដោះស្រាយវិវាទដីធ្លី ជាពិសេស វិវាទពហុភាគី ដោយបង្កើត*ក្រុមដោះស្រាយវិវាទដីធ្លីចល័ត* នៅក្រុង ស្រុក ខណ្ឌ ទាំងឡាយណា ដែលមានវិវាទកកស្ទះច្រើន និងបង្កើនល្បឿនចុះបញ្ជីដីធ្លី តាមរយៈនីតិវិធីទាំងពីរ នៅក្នុងតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច ជាពិសេស ដីដែលគ្មានទំនាស់ ។
- ជំរុញដំណើរការនៃ ការគ្រប់គ្រង ការប្រើប្រាស់ និងការបែងចែក ដីរដ្ឋ តាមរយៈ នីតិវិធីដែលមាន តម្លាភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយពង្រឹងការគ្រប់គ្រងដីរដ្ឋ របស់គ្រប់ស្ថាប័នពាក់ព័ន្ធ ដែលមានអាណត្តិកាន់កាប់ដីរដ្ឋនៅរាជធានី និងគ្រប់ខេត្ត ដោយប្រើប្រាស់ឧបករណ៍មួយចំនួន ដូចជា :
  - ➢ *អនុក្រឹត្យ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ* ដើម្បីកំណត់អត្តសញ្ញាណ ធ្វើចំណាត់ថ្នាក់ ចុះបញ្ជី និង កសាងបញ្ជីសារពើភ័ណ្ឌ ដីរដ្ឋ ដីព្រៃ ដីតំបន់ការពារ ឱ្យបានច្បាស់លាស់ ។
  - ➢ ការរៀបចំផែនការគ្រប់គ្រងដីធ្លីនៅគ្រប់កម្រិត សម្រាប់ធ្វើជាការតម្រង់ទិសដល់ការអភិវឌ្ឍដី និងការតាមដានត្រួតពិនិត្យការអភិវឌ្ឍដី ។
  - ➢ ការទប់ស្កាត់ការប្រមូលដីបង្កកទុក ដោយមិនប្រើប្រាស់ និងមិនធ្វើផលិតកម្មលើដីទាំងនោះ ។
  - ➢ ការកំណត់ដីសមស្រប សម្រាប់ផ្តល់ដល់គ្រួសារក្រីក្រ គ្រួសារកងកម្លាំងប្រដាប់អាវុធដែលកំពុងការពារបូរណភាពទឹកដី អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលគ្មានដី ក្នុងគោលដៅសម្បទានដីសង្គមកិច្ច កិច្ចការពារជាតិ និងការតាំងលំនៅថ្មីរបស់ប្រជាជន ដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍នានា របស់រដ្ឋ ។
  - ➢ ការអនុវត្តវិធានការដកហូតមកវិញនូវដីរដ្ឋ ដែលត្រូវគេកាន់កាប់ដោយខុសច្បាប់ ដែលមិនត្រូវបានប្រើប្រាស់ត្រឹមត្រូវតាមកិច្ចសន្យាផ្តល់សម្បទានដីសេដ្ឋកិច្ច និង ដែលត្រូវបានកាន់កាប់ក្នុងទំហំមួយលើសពីការកំណត់នៃច្បាប់ភូមិបាលឆ្នាំ២០០១ តាមរយៈ ការពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដែលបានចូលជាធរមាន ដូចជា *សារាចរណែនាំស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច* ជាដើម ។

- ការធ្វើប្រតិភូកម្មមុខងារ ដល់ប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត នៅក្នុងការធ្វើសេចក្តីសម្រេចលើការដោះស្រាយករណីវិវាទដីធ្លី ជាពិសេស លើការដោះស្រាយវិវាទពហុភាគី និងការបង្កើត *ក្រុមដោះស្រាយវិវាទដីធ្លីចល័ត* ដើម្បីជំរុញការស៊ើបអង្កេតស្រាវជ្រាវសំណុំរឿងវិវាទដែលនៅកកស្ទះនៅតាម ក្រុង ស្រុក ខណ្ឌ ក្រោមរូបភាពជា *ទីភ្នាក់ងារប្រតិបត្តិការពិសេស* ។

១១៨. **ការបោសសម្អាតមីន** : វិបត្តិផ្ទៃក្នុងកាលពីអតីតកាល បានបន្សល់ទុក នូវជនពិការជាច្រើនម៉ឺននាក់ និងផ្ទៃដីដែលត្រូវបានសង្ស័យថាមានគ្រាប់មីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាមជាច្រើនម៉ឺនហិកតា ដែល ជាឧបសគ្គដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង បន្តផ្តល់គ្រោះថ្នាក់ដល់ប្រជាជន ជារៀងរាល់ថ្ងៃ ។ ការបោសសម្អាតមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម គឺជាតម្រូវការចាំបាច់ ដើម្បីកាត់បន្ថយចំនួនអ្នករបួសនិងស្លាប់ និង ដើម្បីដោះស្រាយនូវឧបសគ្គចម្បងមួយ ដែលរារាំងដល់ ការសង់លំនៅឋាន ការងារកសិកម្ម និងការអភិវឌ្ឍ នៅក្នុងតំបន់ដែលមានគ្រាប់មីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ។ ជាក់ស្តែង ការបោសសម្អាតមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាមត្រូវបានចាប់ផ្តើមអនុវត្ត តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ប៉ុន្តែពុំមានការកត់ត្រាច្បាស់លាស់ ហើយត្រូវបានអនុវត្តជាបន្តទៀត ដោយមានការគាំទ្រពីសហគមន៍អន្តរជាតិ ចាប់តាំងពីឆ្នាំ១៩៩២ មក ដោយបានកាត់បន្ថយយ៉ាងលឿននូវករណីគ្រោះថ្នាក់ដោយសារមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម និង ធ្វើឱ្យមានការកើនឡើងជាលំដាប់នូវផ្ទៃដីបោសសម្អាតរួច ។ យោងតាមរបាយការណ៍ប្រចាំឆ្នាំ ចំនួនអ្នករងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាមបានថយចុះពី ចំនួន ៤៣២០ ករណី ក្នុងឆ្នាំ១៩៩៦ មកនៅត្រឹម ២៧១ ករណី នាឆ្នាំ២០០៨ ។ ផ្ទៃដីបោសសម្អាតរួច បានកើនឡើង ពី ៣៣០៣៦ ហិកតា ក្នុងឆ្នាំ២០០៥ ដល់ ៤៧៦៥០ ហិកតា នាឆ្នាំ២០០៨ ។

## ៣.៣ កំណែទម្រង់ជលផល

១១៩. ត្រី មានតួនាទីសំខាន់ជាប្រភពនៃ ការផ្តល់ជាស្បៀង អាហារូបត្ថម្ភ និងផ្តល់នូវប្រាក់ចំណូលដល់ប្រជាជនកម្ពុជារាប់លាននាក់ ។ ត្រីចូលរួមចំណែក ប្រមាណ ៨០ ភាគរយ នៃប្រូតេអ៊ីនដែលបានមកពីសាច់សត្វ សម្រាប់ប្រជាជនកម្ពុជា ហើយប្រជាជនប្រមាណជាង ៤,៥ លាននាក់ បាននិងកំពុងចូលរួមដោយផ្ទាល់ នៅក្នុងវិស័យជលផល ។ ស្ថិតិផ្លូវការបានបង្ហាញថា ផលត្រីសរុបបានកើនឡើងជាង ៤៧១ ០០០ តោន នៅក្នុងឆ្នាំ២០០៨ ជាពិសេស កើនឡើងពីផលចាប់តាមវាលស្រែ និង ផ្នែកវារីវប្បកម្ម ។ *ច្បាប់ស្តីពីជលផល* ត្រូវបានប្រកាសឱ្យប្រើ កាលពីខែឧសភា ឆ្នាំ២០០៦ ។ ចាប់តាំងពីមាន កំណែទម្រង់វិស័យជលផលមក ការអភិវឌ្ឍវិស័យជលផល ត្រូវបានបោះជំហានយ៉ាងខ្លាំង ដោយត្រូវផ្តោតការយកចិត្តទុកដាក់ ទៅលើប្រជាជនក្រីក្រ ។ លទ្ធផលទាំងអស់នេះ គឺទទួលបានតាមរយៈ ការអភិវឌ្ឍនៅក្នុងក្របខ័ណ្ឌ *ផែនការយុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ ២០០៩-២០១៨* និង *ផែនការវិកិលរយៈពេល ៣ឆ្នាំ ស្តីពីសកម្មភាពអភិវឌ្ឍន៍វិស័យជលផលលើកទី១ ២០០៩-២០១១* ។ ផែនការទាំងនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើ *ក្រុមប្រតិបត្តិសម្រាប់ការនេសាទ ប្រកបដោយការទទួលខុសត្រូវសម្រាប់វិស័យជលផលកម្ពុជា "កាំកូដ"* ។ ចាប់តាំងពីមានកំណែទម្រង់ឡូត៍នេសាទមក មានសហគមន៍នេសាទ ចំនួន ៤៦៩

ត្រូវបានរៀបចំឡើង (ទឹកសាប ៤៣៤ និងសមុទ្រ ៣៥) ហើយក្នុងនោះសហគមន៍នេសាទចំនួន ១៧៣ ត្រូវបានចុះបញ្ជីជាផ្លូវការកាលពីខែតុលា ឆ្នាំ២០០៨ កន្លងទៅនេះ ។ ជាមួយនោះដែរ *ស្រះជម្រកត្រីសហគមន៍* ចំនួន ២៣៥ ត្រូវបានរៀបចំឡើង ដែលភាគច្រើននៅតំបន់ដាច់ស្រយាលឆ្ងាយពីប្រភពទឹក ។ ចំពោះផ្នែកវារីវប្បកម្ម មានស្ថានីយបង្កាត់ភ្ញាស់កូនត្រីរបស់រដ្ឋចំនួន ១៣កន្លែង និងស្ថានីយភ្ញាស់កូនត្រីឯកជន ចំនួន ១៥២កន្លែង បាននិងកំពុងដំណើការ ហើយមានកសិករប្រមាណជាង ១៥ ០០០ គ្រួសារ បាននិងកំពុងចូលរួម ក្នុងសកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារ ។ ការគ្រប់គ្រងវិស័យជលផល ត្រូវបានពង្រឹងដោយរាប់បញ្ចូលនូវការបង្កើនចំនួននៃការចុះបញ្ជីសហគមន៍នេសាទ នៅជុំវិញ *បឹងទន្លេសាប* ការបង្កើនសកម្មភាពវារីវប្បកម្ម និង ការបង្កើនការស៊ើបអង្កេតទៅលើការនេសាទខុសច្បាប់ ។ *រដ្ឋបាលជលផល* ក៏បានរឹតបន្តឹង និង បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការការពារ និងទប់ស្កាត់ការរំលោភកាន់កាប់តំបន់ព្រៃលិចទឹក ។

១២០. ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានគួរឱ្យកត់សម្គាល់ វិស័យជលផលនៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដែលស្តែងឡើងជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ មកលើធនធានវិស័យជលផល ដូចជា ការកាប់ទន្រ្ទានព្រៃលិចទឹក ការរំាតយកដីធ្វើជាកម្មសិទ្ធិ និងការលើកទំនប់ក្នុងដែននេសាទ ពីសំណាក់ ជនខិលខូចនិងអ្នកមានអំណាច ។ ជាមួយគ្នានេះ វិស័យជលផលក៏ទទួលរងនូវផលប៉ះពាល់ ដូចជា បម្រែបម្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនីនៅតំបន់មេគង្គលើ និង នៅមានបញ្ហាប្រឈមមួយចំនួនទៀត ដូចខាងក្រោម :

- ខ្វះខាត ថវិកានិងមធ្យោបាយត្រួតពិនិត្យបទល្មើសនេសាទ (សម្ភារៈ ទូក កាណូត) ប្រេងឥន្ធនៈ ក្នុងការចាត់វិធានការការពារនិងគ្រប់គ្រង ការសិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍនិងអភិរក្សធនធានជលផលឱ្យមានចីរភាព ។
- ខ្វះខាតថវិកា ដើម្បីអភិរក្សតំបន់បឹងទន្លេសាប ជម្រកផ្សោត នៅតំបន់ទន្លេមេគង្គលើ ក្នុងខេត្ត ក្រចេះ ស្ទឹងត្រែង រួមជាមួយ ការអភិរក្សនៅតំបន់សមុទ្រ និង កំណត់ព្រំប្រទល់ព្រៃលិចទឹក និងដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ ។
- សមត្ថភាពរបស់សហគមន៍នេសាទនៅមានកម្រិត ដោយសហគមន៍នេសាទភាគច្រើន នៅពុំទាន់មានការគាំទ្រ ពីដៃគូអភិវឌ្ឍន៍ និង អង្គការក្រៅរដ្ឋាភិបាល ។
- បទល្មើសនេសាទដោយប្រើឧបករណ៍ឆក់ និង ស្បៃមុង ការកាប់បំផ្លាញព្រៃលិចទឹក ក្នុងដែននេសាទ នៅតែបន្តកើតមាន ។

## ៣.៤ គំរែទម្រង់ព្រៃឈើ

១២១. ការអនុវត្ត *ច្បាប់ស្តីពីព្រៃឈើ* និងបទប្បញ្ញត្តិនានា ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធនធានព្រៃឈើត្រូវបានគ្រប់គ្រងដោយហ្មត់ចត់ ការការពារត្រូវបានបង្កើន និងទប់ស្កាត់បានការទន្ទ្រាន

កាន់កាប់ដីព្រៃដោយខុសច្បាប់ ។ ចាប់ពីឆ្នាំ២០០៨ មក *រដ្ឋបាលព្រៃឈើ* បានធ្វើការរៀបចំតំបន់ព្រៃគុបចំនួន ៩ កន្លែង ដែលស្ថិតនៅក្រៅតំបន់ព្រៃសម្បទាន សម្រាប់ដោះស្រាយ តម្រូវការប្រើប្រាស់អនុផលព្រៃឈើក្នុងស្រុក របស់ប្រជាជន ដែលមានប្រមាណ ២៦១ ២៧០ ម៣ ។ ការដាំដុះដើមឈើស្តារព្រៃឈើឡើងវិញ ការអភិវឌ្ឍ សហគមន៍ព្រៃឈើ ការកំណត់ព្រំប្រទល់ព្រៃឈើ ការសិក្សាស្រាវជ្រាវអភិរក្សព្រៃឈើ សត្វព្រៃ និងការអភិវឌ្ឍ *កម្មវិធីព្រៃឈើជាតិ* បានដំណើរការសម្រេចតាមផែនការកំណត់ ហើយ*រដ្ឋបាលព្រៃឈើ* ក្នុងនាមជាតំណាង*រាជរដ្ឋាភិបាលកម្ពុជា* បានរៀបចំបង្កើត និងកំពុងចាត់ចែងធ្វើពាណិជ្ជកម្ម*ឥណទានកាបូនព្រៃឈើកម្ពុជា* តាមរយៈ ការអនុវត្តគម្រោងគំរូនៃ*ឥណទានកាបូន* សម្រាប់សហគមន៍ព្រៃឈើ នៅក្នុង ខេត្តឧត្តរមានជ័យ ដើម្បីចូលរួមចំណែក ក្នុងការកាត់បន្ថយ ភាពក្រីក្រជនបទ ការប្រែប្រួលអាកាសធាតុ និង ការឡើងកំដៅរបស់ភពផែនដី ។ ក៏ប៉ុន្តែ ការកាប់បំផ្លាញព្រៃដើម្បីកាន់កាប់ដីដោយខុសច្បាប់នៅបន្តកើតមាន ។ *ក្រសួងមហាផ្ទៃ* បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការណែនាំដល់អាជ្ញាធរមូលដ្ឋានគ្រប់កម្រិត ដើម្បី ពង្រឹងស្ថិតិ ការផ្លាស់ប្តូរទីលំនៅនិងការតាំងទីលំនៅថ្មី និង ហាមមិនឱ្យបែងចែកដីព្រៃ សម្រាប់គោលបំណងណាផ្សេង ។ ការអនុវត្ត*អនុក្រឹត្យស្តីពី វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ* នឹងរួមចំណែកដើម្បី ឈានទៅសម្រេចបាន *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលដីគ្របដណ្តប់ដោយព្រៃឈើមានទំហំ ៦០ភាគរយ នៅឆ្នាំ២០១៥ ។

១២២. ទទ្ទឹមនឹងវឌ្ឍនភាព ដែល*រដ្ឋបាលព្រៃឈើ*សម្រេចបាន នៅមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម :

- ខ្វះខាតធនធានមនុស្ស និងការលើកទឹកចិត្តដល់មន្ត្រីបម្រើការនៅតំបន់ដាច់ស្រយាល ។
- ខ្វះខាតនូវថវិកាសម្រាប់ដំណើរការគ្រប់គ្រង និងអភិរក្ស ស្រាវជ្រាវ និងអភិវឌ្ឍធនធានព្រៃឈើ ។
- ខ្វះខាតទីស្នាក់ការ និងមធ្យោបាយសម្រាប់បម្រើការងារ ។
- ទទួលរងការគំរាមកំហែងពីជនល្មើសអ្នកមានអំណាច ។
- ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងជិត តំបន់ព្រៃឈើ នៅតែពឹងអាស្រ័យលើព្រៃឈើ ដែលជាសម្ពាធធ្ងន់ធ្ងរ ចំពោះធនធានព្រៃឈើធម្មជាតិ ។
- ការងារបង្រ្កាប បទល្មើស និង ការកាប់រានដីព្រៃឈើយកដីធ្វើជាកម្មសិទ្ធិល្មើសច្បាប់ មានការលំបាក ពីព្រោះជនប្រព្រឹត្តបទល្មើសតែងតែ ផ្លាស់ប្តូរវិធីសាស្ត្រក្នុងការដឹកជញ្ជូន និងបំផ្លាញព្រៃឈើ ក្រោមរូបភាពផ្សេងៗ ។
- ការកំណត់ព្រំប្រទល់ព្រៃ និងការបោះបង្គោល តែងជួបប្រទះការលំបាក និងមានវិវាទជាមួយជនល្មើស ព្រមទាំង មានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួច ។ល ។

## កិច្ចការពារ ការអភិរក្ស បរិស្ថាន និង ការប្រែប្រួលអាកាសធាតុ

១២៣. កិច្ចការពារនិងការអភិរក្ស ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ដែលកម្ពុជាមាន និង ការប្រើប្រាស់ប្រកបដោយចីរភាព នូវធនធានធម្មជាតិ សម្រាប់ជាប្រយោជន៍ដល់ប្រជាជនទាំងអស់ និងការឆ្លើយតបទៅនឹងការប្រែ-

ប្រែប្រួលអាកាសធាតុ គឺជាអាទិភាពចម្បងមួយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។ វឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ ត្រូវបាន ធ្វើឱ្យកើតមានឡើងនៅក្នុងការបង្កើតក្របខ័ណ្ឌ លិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងធនធានទាំងឡាយ និងដើម្បី ពង្រឹងសមត្ថភាព*ក្រសួងបរិស្ថាន* និងស្ថាប័ននានា របស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការគ្រប់គ្រងការអនុវត្តច្បាប់និង លិខិតបទដ្ឋាន ទាំងឡាយ ។ នៅក្នុង ខែមេសា ឆ្នាំ២០០៦ *គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួល អាកាសធាតុ* ត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យមួយរបស់*រាជរដ្ឋាភិបាល* ហើយ នៅឆ្នាំ២០០៩ **សម្តេចនាយករដ្ឋមន្ត្រី** បានទទួល ធ្វើជាប្រធានកិត្តិយសរបស់ គណៈកម្មាធិការជាតិនេះ ។ ក្នុងឆ្នាំ២០០៨ ច្បាប់ចំនួន២ ត្រូវបានអនុម័ត : *ច្បាប់ស្តីពី ជីវសុវត្ថិភាព* និង *ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ* ។

១២៤. *ក្រសួងបរិស្ថាន* កំពុងដំណើរការអនុវត្តកម្មវិធីមួយចំនួន ដូចខាងក្រោមនេះ ដើម្បីដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន :

- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។
- ការត្រួតពិនិត្យការបំពុលបរិស្ថាន ក្នុងនោះរួមមាន ការគ្រប់គ្រងសំណល់រឹង សារធាតុប្រកបដោយគ្រោះថ្នាក់ ការត្រួតពិនិត្យគុណភាពខ្យល់ និង ការត្រួតពិនិត្យការបំពុលទឹកនិងដី ។
- ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ។
- ការអប់រំ និងការផ្សព្វផ្សាយ ព័ត៌មាន ស្តីពីបញ្ហាបរិស្ថាន ។

១២៥. ដោយមានកិច្ចសហការជាមួយបណ្តាក្រសួង និង ភាគីពាក់ព័ន្ធ នៅឆ្នាំ២០០៨ *ក្រសួងបរិស្ថាន* បានពិនិត្យ និងផ្តល់យោបល់លើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គម សម្រាប់គម្រោងសាធារណៈ និងឯកជន ចំនួន ៣៧គម្រោង ប៉ុន្តែ មានតែរបាយការណ៍ សម្រាប់គម្រោងចំនួន ១៥ នៅក្នុងវិស័យ កសិកម្ម ឧស្សាហកម្ម ថាមពល ទេសចរណ៍ និង ហេដ្ឋារចនាសម្ព័ន្ធ ប៉ុណ្ណោះ ដែលត្រូវបានទទួលការឯកភាព ។ លើសពីនេះ *ក្រសួងបរិស្ថាន* បានចុះហត្ថលេខាជាមួយម្ចាស់គម្រោង លើកិច្ចសន្យា ស្តីពី កិច្ចការពារបរិស្ថាន សម្រាប់គម្រោង ចំនួន ៦១ ។

១២៦. ការបង្កើនការប្រមូលសំណល់រឹងនៅទូទាំងប្រទេស មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ចំនួននៃតំបន់ ប្រមូលសំណល់រឹង បានកើនឡើងពី ៤៣ទីតាំង ក្នុងឆ្នាំ២០០៥ ដល់ ៦៩ទីតាំង ក្នុងឆ្នាំ២០០៩ ។ បរិមាណ សំណល់រឹង និងសំរាមដែលបានប្រមូល បានកើនឡើងពី ៣៥២៥៤២តោន ក្នុងឆ្នាំ២០០៥ ដល់ ៥៦៣០៣៤ តោន ក្នុងឆ្នាំ២០០៩ ។ បច្ចុប្បន្ននេះ នៅក្នុងខេត្ត កំពត ពោធិ៍សាត់ បាត់ដំបង សៀមរាប និង ព្រះសីហនុ សំណល់រឹងនិង សំរាមដែលត្រូវបានប្រមូល មានប្រមាណពី ៤៥-៨៥ភាគរយ។ នៅក្នុងរាជធានីភ្នំពេញ សំរាមនិងសំណល់រឹង ដែលត្រូវបានប្រមូលដោយក្រុមហ៊ុនឯកជន មានប្រមាណពី ៩០-១០០ភាគរយ នៅក្នុងខណ្ឌចំនួន ៤ និង ប្រមាណ ពី ៤៥-៧០ភាគរយ ក្នុងខណ្ឌ ចំនួន៣ ផ្សេងទៀត ។

១២៧. ទីតាំងត្រួតពិនិត្យគុណភាពខ្យល់ ចំនួន៣កន្លែង ត្រូវបានបង្កើតឡើង នៅរាជធានីភ្នំពេញ គឺនៅ រង្វង់មូលក្បាលថ្នល់ រង្វង់មូលពហុកីឡដ្ឋានអូឡាំពិក និង ផ្លូវបំបែកទួលគោក សម្រាប់ធ្វើការតាមដានត្រួតពិនិត្យ លើកម្រិតនៃឧស្ម័ន *កាបូនម៉ូណូអុកស៊ីត អាសូតឌីអុកស៊ីត* និង *ស្ពាន់ធ័រឌីអុកស៊ីត* ។ សារធាតុក្នុងខ្យល់ ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពនិងបរិស្ថាន កំពុងត្រូវបានពិនិត្យពិចារណា ដើម្បីដាក់បញ្ចូលបន្ថែម ក្នុងការងារតាមដានត្រួតពិនិត្យគុណភាពខ្យល់ នេះ ។

១២៨. ដើម្បីតាមដាន គុណភាពទឹកសាធារណៈ សម្រាប់ការអភិរក្សជីវៈចម្រុះ ជារៀងរាល់ខែ *ក្រសួងបរិស្ថាន* បានចុះយកសំណាក នៅតាម ១៥ចំណុចដៅ រួមមាន : ៤ចំណុចដៅ នៅតាមបណ្តោយដងទន្លេ ក្នុងរាជធានីភ្នំពេញ (កៀនស្វាយ ជ្រោយចង្វា កំពង់ផែភ្នំពេញ និងស្ពានថ្មព្រែកព្នៅ) ២ចំណុចដៅ នៅខេត្តកណ្តាល (ស្ទឹងជ្រៅព្រែកត្នោត និងកំពង់ចម្លងតាខ្មៅ) ១ចំណុចដៅ នៅខេត្តបាត់ដំបង ២ចំណុចដៅ នៅខេត្តពោធិ៍សាត់ ២ចំណុចដៅ នៅខេត្តកំពង់ឆ្នាំង ១ចំណុចដៅ នៅខេត្តសៀមរាប ២ចំណុចដៅនៅខេត្តកំពង់ធំ និង ១ចំណុចដៅ នៅខេត្តកំពង់ចាម ។ លើសពីនេះ *ក្រសួងបរិស្ថាន* ក៏បានចុះយកសំណាកទឹកសមុទ្រ នៅ៤ចំណុចដៅ ក្នុងខេត្តព្រះសីហនុ នៅ៥ចំណុចដៅក្នុងខេត្តកោះកុង (ក្នុងនោះមានទឹកព្រែកដៃសមុទ្រទាំង៤) នៅ១ចំណុចដៅ ក្នុងខេត្តកែប ហើយគ្រោងចុះយកសំណាកទឹកសមុទ្រ នៅ១ចំណុចដៅ ក្នុងខេត្តកំពត បន្ថែមទៀត ។

១២៩. *ក្រសួងបរិស្ថាន* បានរៀបចំ ផែនការមេស្តីពីតំបន់ការពារធម្មជាតិ ដែលកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ ហើយបានធ្វើផែនទី តំបន់ការពារធម្មជាតិចំនួន ១៨កន្លែង ។ *ក្រសួងបរិស្ថាន* ក៏បានធ្វើការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យ ស្តីពី ពពួករុក្ខជាតិ រុក្ខជាតិឱសថ និងសត្វ ផងដែរ ។

១៣០. *ក្រសួងបរិស្ថាន* ក៏បានគាំទ្រ ដល់សហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ ព្រមទាំង បានរៀបចំ បង្កើតជាសហគមន៍តំបន់ការពារធម្មជាតិ ។ ចំនួនសហគមន៍តំបន់ការពារធម្មជាតិ បានកើនឡើងពី ៥៩ នៅក្នុង ឆ្នាំ២០០៥ ទៅ ៨២ នៅក្នុងឆ្នាំ២០០៨ ។

១៣១. *ក្រសួងបរិស្ថាន* បាននិងកំពុងធ្វើការងារជាច្រើន ក្នុងនាមជា *លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ* ដើម្បីសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ ។ *ក្រសួងបរិស្ថាន* កំពុងរៀបចំ*របាយការណ៍ជាតិលើកទី២* ក្រោម *អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ* ព្រមទាំង *យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ* ។

១៣២. *ក្រសួងបរិស្ថាន* បានចូលរួមក្នុងការផ្តល់ព័ត៌មានស្តីពី ការអប់រំនិងការពិភាក្សា លើបញ្ហាបរិស្ថាន ក៏ដូចជាការផ្សព្វផ្សាយព័ត៌មាននេះ ជាសាធារណៈ ។ នៅក្នុងបរិបទនៃការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ *ក្រសួងបរិស្ថាន* បាននឹងកំពុងយកចិត្តទុកដាក់ ចាត់វិធានការទប់ស្កាត់ កាត់បន្ថយហេតុប៉ះពាល់នៃសំណល់ទាំងនោះ លើបរិស្ថាន និង សុខភាពសាធារណៈ ។

១៣៣. បញ្ហាប្រឈមដ៏ធំចំពោះមុខ គឺ សមត្ថភាពនិងភាពចាំបាច់របស់ប្រទេស ក្នុងការសម្របទៅនឹង ការថយចុះនៃបម្រែបម្រួលកម្រិតទឹកនៅក្នុងទន្លេសំខាន់ៗ នាចន្លោះរដូវវស្សានិងរដូវប្រាំង ក៏ដូចជា ការកើនឡើងនៃការបំពុលទឹក ដែលអាចបណ្តាលមកពីការគ្រប់គ្រងលំហូរទឹកដោយប្រទេស នៅលើដើមខ្សែទឹក ដែលបានដំឡើងរបាំងជាបន្តបន្ទាប់ សម្រាប់ បង្កើតថាមពលអគ្គិសនីនិងយកទឹកមកប្រើប្រាស់ក្នុងការងារស្រោចស្រព និងការបង្ហូរកាកសំណល់ឧស្សាហកម្មទៅក្នុងប្រព័ន្ធទន្លេ ។ បម្រែបម្រួលទាំងនេះ នឹងធ្វើឱ្យមានការផ្លាស់ប្តូរ និងជះឥទ្ធិពលអវិជ្ជមានមកលើប្រព័ន្ធអេកូឡូស៊ីទាំងមូលនៅកម្ពុជា ហើយ នឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើដំណាំនិងការនេសាទ ។ ការឃ្លាំមើលនិងការផ្លាស់ប្តូរយោបល់គ្នាជាប្រចាំ នឹងត្រូវធ្វើឡើង តាមរយៈ*គណៈកម្មការទន្លេមេគង្គ* ។ ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងប្រព័ន្ធអេកូ ប្រកបដោយប្រសិទ្ធភាព គឺ ស្ថិតនៅក្នុងដំណាក់កាលដំបូង នៅឡើយ ។ កង្វះការសម្របសម្រួលនិងកិច្ចសហការ រវាងរដ្ឋអំណាច រាជធានី និង ខេត្ត ក៏ដូចជា រវាងក្រសួង-ស្ថាប័ននានា នៅតែជាឧបសគ្គចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការគ្រប់គ្រងសកម្មភាពខុសច្បាប់នានា ។

## ការគ្រប់គ្រងគ្រោះមហន្តរាយ

១៣៤. គ្រោះថ្នាក់ធម្មជាតិ ដូចជា ទឹកជំនន់ ការរាំងស្ងួត ខ្យល់ព្យុះ ការរាតត្បាតនៃជំងឺនានា ដែលប្រទេសកម្ពុជាបានជួបប្រទះកន្លងមក បានបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ការខូចខាតដល់ផលដំណាំកសិកម្ម និង ទ្រព្យសម្បត្តិរបស់ប្រជាជន និង ប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ ផងដែរ ។ ដើម្បីត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយធម្មជាតិទាំងនោះ *រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើត *គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* នៅឆ្នាំ១៩៩៥ និង មានរចនាសម្ព័ន្ធគ្រប់គ្រង ចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ នៅឆ្នាំ២០០២ ។ ទន្ទឹមនឹងនេះ *រាជរដ្ឋាភិបាល* បានរៀបចំ ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីប្រឆាំងទប់ទល់ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយទាំងនោះ ។ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ទាំងនោះ រួមមាន :

- *ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* ។
- *អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ។
- ចូលរួមអនុម័តលើក្របខ័ណ្ឌការងារយូហ្គោ ឆ្នាំ២០០៥-២០១៥ ។
- *ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ* ។
- *គោលនយោបាយជាតិស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ* ។

១៣៥. *ការរីកចម្រើនក្នុងការបញ្ច្រាបហានិភ័យគ្រោះមហន្តរាយនៅកម្ពុជា : រាជរដ្ឋាភិបាលកម្ពុជា* ដែលជាហត្ថលេខីមួយ ក្នុងចំណោមហត្ថលេខីទាំង ១៦៨ប្រទេស លើ *ក្របខ័ណ្ឌការងារយូហ្គោ ២០០៥-២០១៥* ដែលជា បទដ្ឋានច្បាប់ដ៏រឹងមាំ សម្រាប់ ផ្តល់ចំណេះដឹង និង អនុវត្តលើការគ្រប់គ្រងគ្រោះមហន្តរាយ នៅជុំវិញពិភពលោក ។ ផ្អែក

តាមស្មារតីនៃ*សន្និសិទនៅទីក្រុងប៉េកាំង* ដែលផ្តោតលើ *សកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅតំបន់អាស៊ី រាជរដ្ឋាភិបាលកម្ពុជា* បានរៀបចំ *"ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣"* ហើយ បានប្តេជ្ញាចិត្តអនុវត្ត និង តាមដានត្រួតពិនិត្យដំណើរការ នៃការអនុវត្តផែនការសកម្មភាពនេះ ផងដែរ ។ *រាជរដ្ឋាភិបាលកម្ពុជា* ក៏បានបង្កើត *មូលនិធិ អាស៊ានសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ* ដែលជាការផ្តោតការយកចិត្តទុកដាក់លើ ការកាត់បន្ថយគ្រោះមហន្តរាយ និង ការត្រៀមលក្ខណៈសម្រាប់ឆ្លើយតបគ្រោះអាសន្ន នៅកម្ពុជា ។

## ការអភិវឌ្ឍជនបទ

១៣៦. អភិវឌ្ឍន៍ជនបទ មានសារៈសំខាន់បំផុត សម្រាប់ ការលើកស្ទួយវិស័យកសិកម្ម និង ការកាត់បន្ថយភាពក្រីក្រ ។ អភិវឌ្ឍន៍ជនបទ គឺជា ការងារអន្តរវិស័យដ៏ធំមួយ ដែលគ្របដណ្តប់លើវិស័យ ហេដ្ឋារចនាសម្ព័ន្ធជនបទ សុខាភិបាល អប់រំ កសិកម្ម ការផ្គត់ផ្គង់ទឹកនិងអនាម័យ និង វិស័យផ្សេងៗទៀត នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅតំបន់ជនបទ ។ ការងារអន្តរវិស័យនេះ មានសារៈសំខាន់បំផុត សម្រាប់ការកាត់ន្ថយភាពក្រីក្រ នៅជនបទ ដោយហេតុថា អត្រាភាពក្រីក្រ មានកម្រិតខ្ពស់ នៅក្នុងចំណោមប្រជាជន ៨៥ភាគរយ ដែលកំពុងរស់នៅតំបន់ជនបទ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានសម្រេចយកវិធីសាស្ត្រដែលមានមុខព្រួញច្រើន ដើម្បីជំរុញការអភិវឌ្ឍជនបទ និង ការបង្កើនលទ្ធភាពនិងសមត្ថភាព ដល់សហគមន៍មូលដ្ឋាន ជាពិសេស *គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ* ក្នុង ការរៀបចំផែនការ និង ការគ្រប់គ្រងលើការអភិវឌ្ឍមូលដ្ឋានផ្ទាល់របស់ខ្លួន ។ ការធ្វើវិមជ្ឈការនិងវិសហមជ្ឈការលើការផ្តល់សេវាកម្មសាធារណៈ ការគាំទ្រដល់កម្មវិធីទាំងឡាយ ដែលមានការចូលរួមជាលក្ខណៈវិមជ្ឈការ និង ដែលផ្តោតទៅតាមវិស័យ និង ការផ្តល់ឥណទានដល់ គ្រួសារនិងអាជីវកម្មធុនតូចៗ គឺជា ឧទាហរណ៍មួយចំនួន ដែលបង្ហាញ ឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែង របស់ *រាជរដ្ឋាភិបាល* នៅក្នុងវិស័យនេះ ។

១៣៧. ចាប់តាំងពីឆ្នាំ២០០៦ មក ការអភិវឌ្ឍជនបទ ត្រូវបានជ្រើសរើសជាវិស័យអាទិភាព នៅក្នុងចំណោមវិស័យអាទិភាព៦ផ្សេងទៀត របស់ *រាជរដ្ឋាភិបាលកម្ពុជា* នៅក្នុង *កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ* សម្រាប់ការវិភាជ និង ការបញ្ចេញថវិកា ឱ្យទាន់ពេលវេលា ។

១៣៨. ការពង្រឹងសមត្ថភាពស្ថាប័ននិងការអភិវឌ្ឍធនធានមនុស្ស នៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ ត្រូវបាន និងកំពុងអនុវត្ត តាមរយៈការរៀបចំឱ្យមាន ក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត ដែលចាំបាច់សម្រាប់ជំរុញការអនុវត្ត សកម្មភាពអភិវឌ្ឍន៍ជនបទ ក្នុងនោះរួមមាន គោលនយោបាយជាតិ យុទ្ធសាស្ត្រ-ជាតិ និងលិខិតបទដ្ឋានគតិយុត្ត មួយចំនួន ដូចខាងក្រោម ៖

- គោលនយោបាយជាតិ ស្តីពី ផ្លូវជនបទ ។
- យុទ្ធសាស្ត្រជាតិ ស្តីពី ផ្លូវជនបទ ។

- គោលនយោបាយជាតិ ស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។
- យុទ្ធសាស្ត្រជាតិ ស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- គោលនយោបាយជាតិ ស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច ។
- គោលនយោបាយជាតិស្តីពី អភិវឌ្ឍន៍ជនបទ ។
- យុទ្ធសាស្ត្រជាតិ ស្តីពី អភិវឌ្ឍន៍ជនបទ ។

១៣៩. *ការធ្វើផែនការមូលដ្ឋានចម្រុះ* គឺជាយន្តការមួយ ដើម្បីធ្វើការកំណត់ឱ្យបានប្រសើរជាងមុន នូវអាទិភាពទាំងឡាយ និង ដើម្បីរៀបចំកសាងសំណើគម្រោងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំង ដើម្បីគាំទ្រដល់កម្មវិធីវិនិយោគនៅតំបន់ជនបទ ។ យន្តការនេះ ធ្វើចំណាត់ថ្នាក់ឱ្យសហគមន៍ទាំងឡាយ ទៅតាមកម្រិតនៃលទ្ធភាពទទួលបាន នូវសេវាកម្មនិងតម្រូវការមូលដ្ឋានអប្បបរមា ដើម្បីឱ្យមានការផ្តោតការយកចិត្តទុកដាក់ ជាពិសេស ទៅលើសហគមន៍ទាំងនោះ សម្រាប់ការអភិវឌ្ឍជនបទ ។ *ការធ្វើផែនការមូលដ្ឋានចម្រុះ* ត្រូវបាននិងកំពុងអនុវត្ត នៅក្នុងខេត្តមួយចំនួន ដូចជា ក្រចេះ ស្ទឹងត្រែង សៀមរាប បាត់ដំបង បន្ទាយមានជ័យ និង ឧត្តរមានជ័យ ។

១៤០. សមិទ្ធផលធំៗក្នុងសកម្មភាពអភិវឌ្ឍន៍ជនបទ រួមមាន ដូចខាងក្រោម :

- *ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទ :* ពីឆ្នាំ២០០៦ ដល់ ២០០៨ ការសាងសង់ផ្លូវថ្មី សម្រេចបាន ប្រវែង ១ ៤៤០ គ.ម ។ ការជួសជុលផ្លូវ សម្រេចបានប្រវែង ២ ៩៤៥ គ.ម ហើយ ការថែទាំផ្លូវ សម្រេចបាន ប្រវែង ៥ ៩២៦ គ.ម ។ ការសាងសង់ ស្ពានថ្មី សម្រេចបាន ចំនួន ១៣៤ កន្លែង និង លូថ្មី សម្រេចបានចំនួន ១ ១៤៨ កន្លែង ។ ជារួម គិតមកដល់ឆ្នាំ ២០០៨ *ក្រសួងអភិវឌ្ឍន៍ជនបទ* បានស្តារ និងសាងសង់ផ្លូវជនបទ បានប្រវែង ២៤ ១៤០ គ.ម ។
- *ការផ្គត់ផ្គង់ទឹកជនបទ :* ពីឆ្នាំ២០០៦ ដល់ ២០០៨ ការផ្គត់ផ្គង់ទឹកសម្រាប់ *បរិភោគនិងទឹកប្រើប្រាស់* ត្រូវបាន ធ្វើឡើងតាមរូបភាព ដូចខាងក្រោម :
  - ➢ ការផ្តល់អណ្តូងទឹកថ្មីគ្រប់ប្រភេទ សម្រេចបានចំនួន ៥៩៥៦ អណ្តូង ។
  - ➢ ការជួសជុលអណ្តូងទឹក សម្រេចបានចំនួន ២៩៧៧ អណ្តូង ។
  - ➢ ការជីកស្រះទឹក សម្រេចបានចំនួន ១១០ ស្រះ ។
  - ➢ ការកសាងពាងយក្ស សម្រេចបានចំនួន ១៧៩ ពាង ។
  - ➢ ការធ្វើតេស្តអាសេនិចលើទឹកអណ្តូង សម្រេចបានចំនួន ៨៩២១ អណ្តូង ។
  - ➢ ការផ្គត់ផ្គត់ *ទឹកសម្រាប់ស្រោចស្រព* ត្រូវបានធ្វើឡើង តាមរយៈ (១) ការជួសជុលអាងទឹកចំនួន ២៩១កន្លែង (២) ការសាងសង់ទំនប់ថ្មី ប្រវែង ២៦ ៣៩២ ម (៣) ការជួសជុលទំនប់ ប្រវែង ៥៧១៩ ម (៤) ការសាងសង់ប្រឡាយ ប្រវែង ៦៦ ០១៨ ម (៥) ការជួសជុលប្រឡាយ ប្រវែង ១៦៤ ៤៤១ ម និង (៦) ការសាងសង់ទ្វារទឹកថ្មី ចំនួន ៦កន្លែង ។

- *សុខភាពនិងអនាម័យជនបទ :* ការសាងសង់បង្គន់អនាម័យ សម្រេចបានចំនួន ៥១ ៣១៩ ហើយ ចានបង្គន់ចំនួន ៨000 ត្រូវបានផ្តល់ជូន ដល់សហគមន៍ជនបទ ។ ការអប់រំសុខភាពនិងអនាម័យ ត្រូវបានរៀបចំឡើងជូនប្រជាជន បានចំនួន ១៨៥ ៨២៨ នាក់ ។
- *ការអភិវឌ្ឍសហគមន៍ :* ការសាងសង់អគារសិក្សាថ្មី សម្រេចបានចំនួន ៨៥ខ្នង ហើយ ការជួសជុលអគារសិក្សាសម្រេចបាន ចំនួន ៥ខ្នង ។
- *ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ :* ការបង្កើននូវការផ្តល់ឥណទានជនបទ និង ការបង្កើតឡើងនូវធនាគារស្រូវ ធនាគារគោ/ក្របី បានរួមចំណែកយ៉ាងច្រើន ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។
- ទន្ទឹមនឹងសមិទ្ធផលនៃការអភិវឌ្ឍជនបទ ដែលបានរៀបរាប់ខាងលើនេះ សមិទ្ធផលជាច្រើនផ្សេងទៀត ត្រូវបានបង្កើតឡើង តាមរយៈ វប្បធម៌នៃការចែករំលែក ដែល*រាជរដ្ឋាភិបាល* បានបំផុសមន្ត្រីរាជការ មហាជនឱ្យចូលរួមចំណែក ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅតំបន់ជនបទ ដូចជា ការកសាងផ្លូវជនបទ ប្រឡាយទឹក ស្រះ អណ្តូងទឹក មណ្ឌលសុខភាព សាលារៀន ។ល។

## តារាងទី២ : វឌ្ឍនភាពក្នុងការអភិវឌ្ឍន៍ជនបទ

| សូចនាករ | ២០០៦ | ២០០៧ | ២០០៨ | ២០១០ប៉ាន់ស្មាន |
|---|---|---|---|---|
| ការស្តារផ្លូវជនបទ (គ.ម ក្នុងចំណោមផ្លូវជនបទ សរុបប្រវែង ២៨000 គ.ម) | ២២ ៩៦៤ | ២៣៧២៩ | ២៤១៤0 | ២៦៦៥៨ |
| ការទទួលបានទឹកស្អាតនៅជនបទ (%នៃប្រជាជននៅជនបទ) | ៤២.៦ | ៤៥.៥ | ៤0.៤៩ | ៤៣.៤៩ |
| ការទទួលបានអនាម័យនៅជនបទ (%នៃប្រជាជននៅជនបទ) | ១៦.៥ | ១៦.៧ | ២៣.២៤ | ២៥.0 |
| គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ-គ.អ.ភ ( គ.អ.ភ ក្នុងចំណោមចំនួនភូមិសរុប ១៤0៧៣ ភូមិ) | ៨៩៣៨ | ៨៩២៦ | ៨៦៩៧ | ៩៧២៣ |

១៤១. ទោះបីជា វិស័យអភិវឌ្ឍន៍ជនបទមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ ក៏វិស័យនេះ នៅមានការងារមួយចំនួនដែលត្រូវធ្វើបន្ទាន់ចំពោះមុខ ក៏ដូចជា បញ្ហាប្រឈមមួយចំនួន រួមមាន ដូចខាងក្រោម :

- ការបង្កើតឡើងនូវក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ សម្រាប់ ការអនុវត្តសកម្មភាពនានា ក្នុងវិស័យអភិវឌ្ឍន៍ជនបទ ។
- ការបន្តការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីរៀបចំផែនការនិងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ការស្តារនិងសាងសង់ ផ្លូវជនបទនិងសំណង់សិល្បការ្យ អណ្តូងទឹក ប្រព័ន្ធស្រោចស្រពខ្នាតតូច សាលារៀន មណ្ឌលសុខភាព ជាដើម ។
- ការស្តារនិងសាងសង់ផ្លូវជនបទ បច្ចុប្បន្ននេះ កំពុងប្រឈមមនឹងកង្វះខាតគ្រួសក្រហមដែលមានគុណភាពល្អ ដែលទាមទារឱ្យ*ក្រសួងអភិវឌ្ឍន៍ជនបទ* គិតគូរដល់ការធ្វើឱ្យប្រសើរឡើងនូវការក្រាលផ្លូវ ដោយ ឈានពីការកាលគ្រួសក្រហម ឱ្យទៅជា ការក្រាលកម្រាលប្រសើរជាងនេះ ជាពិសេស ការក្រាលកៅស៊ូ ។

- ថវិកាសម្រាប់ការជួសជុលនិងការថែទាំផ្លូវទូទាំងប្រទេស មានកម្រិត ត្រឹមតែ ១០ភាគរយ នៃតម្រូវការសម្រាប់ផ្លូវជនបទ នៅទូទាំងប្រទេសប៉ុណ្ណោះ ។ ប្រការនេះ គឺជាហេតុធ្វើឱ្យផ្លូវ ដែលខូចការថែទាំ កាន់តែខូចខ្លាំងឡើងៗ ដែលទាមទារនូវថវិកាវិនិយោគច្រើន ដើម្បីជួសជុលឡើងវិញ ។
- ការជំរុញការផ្តល់ ទឹកស្អាតនិងអនាម័យជនបទ ដើម្បីឆ្លើយតបឱ្យបាន នូវចំណុចដៅ របស់*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ។
- ការជំរុញឱ្យដំណើរការ *"ភូមិមួយផលិតផលមួយ"* ដើម្បីបង្កើតមុខរបរ និងវិជ្ជាជីវៈមូលដ្ឋានច្បាស់លាស់ជូនប្រជាជននៅតំបន់ជនបទ ។
- ការជំរុញការបង្កើតនិងពង្រឹងឡើងវិញ នូវតួនាទី *គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ* ដើម្បីលើកទឹកចិត្តឱ្យមានការអភិវឌ្ឍដោយមានការចូលរួមពីសហគមន៍នៅមូលដ្ឋាន និងដើម្បីធានាឱ្យមានការអភិវឌ្ឍជនបទប្រកបដោយចីរភាព ។
- ការជំរុញការបង្កើតភូមិគំរូ ដើម្បីផ្សព្វផ្សាយ នូវបទពិសោធន៍ នៃការងារអភិវឌ្ឍន៍ជនបទចម្រុះ ។
- ការផ្តល់ការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ ដល់ប្រជាជនជនបទ និង ការជំរុញការប្រើប្រាស់ឥណទានជនបទឱ្យមានប្រសិទ្ធភាព តាមរយៈ ការពង្រីកកម្មវិធីមីក្រូហិរញ្ញវត្ថុ ដោយមានអត្រាការប្រាក់ទាប ។
- ការជំរុញការអភិរក្សនិងការអភិវឌ្ឍ សហគមន៍ជនជាតិដើមភាគតិច ប្រកបដោយចីរភាព ។

## ៤. ការបន្តស្តារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១៤២. ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយដែលមានដំណើរការល្អ គឺជាបុរេលក្ខខណ្ឌមួយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយចីរភាព ។ ជាក់ស្តែង ភាពរឹងមាំនិងភាពសម្បូរបែបនៃហេដ្ឋារចនាសម្ព័ន្ធ មានឥទ្ធិពលទៅលើរចនាសម្ព័ន្ធនៃកំណើនសេដ្ឋកិច្ច ប៉ុន្តែ កង្វះហេដ្ឋារចនាសម្ព័ន្ធ នឹងរារាំងដល់ការទទួលបាននូវសេវាសុខាភិបាលនិងអប់រំ ការបើកទូលាយពាណិជ្ជកម្ម និង ភាពងាយស្រួល ចូលដល់ទីផ្សារ ទាំងនៅក្នុងនិងក្រៅប្រទេស ។ អាទិភាពសំខាន់ៗរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានការជួសជុល ការថែទាំ និងការកែលម្អ បណ្តាញផ្លូវថ្នល់ ពីថ្នាក់ជាតិរហូតដល់ជនបទ ការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកនិងអនាម័យ ការបង្កើតឡើងនូវវិស័យថាមពលមួយដែលមានប្រសិទ្ធភាព ការធ្វើអគ្គិសនីភាវូបនីយកម្មនៅជនបទ ការធ្វើឱ្យមានបណ្តាញទូរគមនាគមន៍ល្អជាងមុន ។ល។ នៅក្នុងក្របខ័ណ្ឌនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ចតុកោណនេះ នឹងផ្តោតការយកចិត្តទុកដាក់ដោះស្រាយបញ្ហាសំខាន់ៗបួន គឺ *(១) ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក ផ្លូវទឹក ផ្លូវដែក កំពង់ផែ ផ្លូវអាកាស និង សេវាកម្មដឹកជញ្ជូនរួមទាំង សេវាភ្នាក់ងារនាវា និងភ័ស្តុភារកម្ម) (២) ការគ្រប់គ្រង ធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ (៣) ការអភិវឌ្ឍវិស័យថាមពល (រួមមាន ប្រេងកាត និងឧស្ម័នធម្មជាតិ) និងបណ្តាញអគ្គិសនី និង (៤) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍* ។

## ៤.១ ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

១៤៣. ការស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា បណ្តាញផ្លូវថ្នល់ កំពង់ផែ និងអាកាសយានដ្ឋានសំខាន់ៗ សម្រេចបានលទ្ធផលធំៗគួរឱ្យកត់សម្គាល់ នៅក្នុងការង្កើតឡើងនូវបណ្តាញដឹកជញ្ជូនមួយ ដែលតភ្ជាប់គ្នារវាងតំបន់នានា នៅទូទាំងប្រទេស ក៏ដូចជា ជាមួយបណ្តាប្រទេសជិតខាង ។ *រាជរដ្ឋាភិបាលកម្ពុជា* ក៏បានផ្តល់អាទិភាពខ្ពស់ ក្នុងការធានាឱ្យមានការថែទាំយ៉ាងត្រឹមត្រូវនូវប្រព័ន្ធគមនាគមន៍ ហើយ បានជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់វិស័យឯកជន ក្នុងការដាក់ឱ្យដំណើរការ និងការថែទាំនូវប្រព័ន្ធគមនាគមន៍ ផងដែរ ។ ការស្តារ ការសាងសង់ និងការអភិវឌ្ឍ បណ្តាញផ្លូវដែក ដែលតភ្ជាប់ពីរាជធានីភ្នំពេញ ទៅបណ្តាខេត្ត មួយចំនួន និងតភ្ជាប់ទៅបណ្តាញផ្លូវដែកនៃប្រទេសជិតខាង ដែលជាផ្នែកមួយនៃបណ្តាញផ្លូវដែកអាស៊ី នោះ ក៏ជាអាទិភាពខ្ពស់មួយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ផងដែរ ។ ដើម្បីបង្កើនល្បឿន នៃការអភិវឌ្ឍបណ្តាញផ្លូវដែក *រាជរដ្ឋាភិបាលកម្ពុជា* បានសម្រេចផ្តល់សម្បទានដល់វិស័យឯកជន ទាំងការសាងសង់ ដំណើរការ និង ការថែទាំ ។ *ក្រសួងសាធារណការ និងដឹកជញ្ជូន* ជាស្ថាប័នទទួលខុសត្រូវក្នុង ការស្តារ ការសាងសង់ និង ការថែទាំជាប្រចាំ នូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។

១៤៤. **បណ្តាញផ្លូវថ្នល់ :** ការស្តារនិងការសាងសង់នូវ *បណ្តាញផ្លូវជាតិ* មួយលេខ ត្រូវបានបញ្ចប់ស្ទើរតែទាំងស្រុង ។ បច្ចុប្បន្ននេះ *ផ្លូវជាតិសំខាន់ៗ* (ផ្លូវក្រាលកៅស៊ូ) បានតភ្ជាប់ពីរាជធានីភ្នំពេញ ទៅទីរួមខេត្តស្ទើរតែទាំងអស់ ហើយ បានតភ្ជាប់ទៅនឹងច្រកទ្វារព្រំដែនសំខាន់ៗជាមួយប្រទេសជិតខាង ។ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ត្រូវបានធ្វើឱ្យកើតមានឡើង នៅក្នុងការកសាងបណ្តាញផ្លូវថ្នល់ ថ្នាក់តំបន់ និងអនុតំបន់ (ដូចជា *តំបន់អាស៊ីប៉ាស៊ីហ្វិក អាស៊ាន មហាអនុតំបន់ទន្លេមេគង្គ*) ដែលដើរតួនាទីជាផ្លូវរបៀងសេដ្ឋកិច្ច និងជាផ្លូវឆ្លងកាត់អន្តរជាតិ សម្រាប់សម្រួលដល់ការដឹកជញ្ជូន ការផ្គត់ផ្គង់ភស្តុភារ ការធ្វើពាណិជ្ជកម្ម និងទេសចរណ៍ឆ្លងដែនអន្តរជាតិ និងដើម្បីការការពារប្រទេសថែមទៀត ។

១៤៥. នៅចុងឆ្នាំ២០០៨ ប្រទេសកម្ពុជាមានផ្លូវថ្នល់សរុបប្រវែង ៣៩ ៦១៨ គ.ម ក្នុងនោះរួមមាន :

- ផ្លូវជាតិមួយលេខ ប្រវែង ២១១៩ គ.ម ។
- ផ្លូវជាតិពីរលេខ ប្រវែង ៣០៨៦ គ.ម ។
- ផ្លូវខេត្ត ប្រវែង ៦៤១៣ គ.ម (ក្នុងនោះ មាន ១១៣ គ.ម ជាផ្លូវក្រាលកៅស៊ូ) ។
- ផ្លូវជនបទ ប្រវែង ២៨០០០ គ.ម ។

១៤៦. ក្នុងដំណាក់កាលនៃការអនុវត្ត *ផយអជ ២០០៦-២០១០* (២០០៦-២០០៨) ផ្លូវថ្នល់សរុបប្រវែង ២ ៣៤២ គ.ម (ដោយមិនរាប់បញ្ចូលផ្លូវខេត្ត និងផ្លូវទីរួមខេត្តទេ) ត្រូវបានស្តារ និងសាងសង់ឡើងវិញដោយក្រាលកៅស៊ូ ។ ផ្លូវថ្នល់ទាំងនោះ រួមមាន :

- ផ្លូវជាតិ មួយលេខ ប្រវែង ១៧៣១ គ.ម ។
- ផ្លូវជាតិ ពីរលេខ ប្រវែង ៤៩៨ គ.ម ។
- ផ្លូវខេត្ត ប្រវែង ១១៣ គ.ម ។
- ភាគច្រើននៃផ្លូវជាតិពីរលេខ និង ផ្លូវខេត្ត ត្រូវបានក្រាលដោយគ្រួសក្រហម ។
- រហូតមកដល់ឆ្នាំ២០០៩ ផ្លូវក្រាលកៅស៊ូរួច មានប្រវែងសរុប ២ ៦៦១ គ.ម ស្មើនឹង ៥១ ភាគរយ នៃ ផ្លូវជាតិមួយលេខ និងពីរលេខ ដែលមានប្រវែង ៥ ២០៥ គ.ម ។
- *គម្រោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់នៅកម្ពុជា* សម្រាប់រយៈពេល ៥ឆ្នាំ ដែលត្រូវបានចាប់ផ្តើមអនុវត្ត កាលពីខែធ្នូ ឆ្នាំ២០០៨ បានជួយដល់ *ក្រសួងសាធារណការនិងដឹកជញ្ជូន* ក្នុងការថែទាំប្រព័ន្ធផ្លូវថ្នល់ ដែលរួមមាន ផ្លូវជាតិ និងផ្លូវខេត្ត តាមរយៈ កម្មវិធីការងារថែទាំខួបនិងថែទាំជាប្រចាំ ។ លទ្ធផលរំពឹងទុក បន្ទាប់ពីគម្រោងបានបញ្ចប់ រួមមាន :
  - ➢ ការថែទាំជាប្រចាំលើផ្លូវជាតិប្រវែង ២ ១០០ គ.ម នឹងអាចសម្រេចបាន ១០០ភាគរយ ហើយ ការថែទាំជាប្រចាំលើផ្លូវខេត្តប្រវែង ២ ៧០០ គ.ម នឹងអាចសម្រេចបាន ៣០ភាគរយ ។
  - ➢ ការថែទាំខួបលើផ្លូវជាតិប្រវែង ១០០ គ.ម នឹងអាចសម្រេចបាន ៥ភាគរយ ហើយ ការថែទាំខួប លើផ្លូវខេត្តប្រវែង ៣៨០ គ.ម នឹងអាចសម្រេចបាន ៤ភាគរយ ។
  - ➢ ការទប់ស្កាត់ស្ថានភាពអាក្រក់ ដែលអាចកើតមានមកលើផ្លូវថ្នល់ល្អ នឹងអាចសម្រេចបាន ៦៥ ភាគរយ សម្រាប់ផ្លូវជាតិ និង ៤៥ ភាគរយ សម្រាប់ផ្លូវខេត្ត ។

១៤៧. ដើម្បីការពារទប់ទល់នឹងការប្រើប្រាស់មិនត្រឹមត្រូវ នូវបណ្តាញផ្លូវថ្នល់ និងដើម្បីលើកកម្ពស់សុវត្ថិភាព ការធ្វើដំណើរតាមផ្លូវថ្នល់ *ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក* ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។ ការបង្កើតឱ្យមាន ប្រព័ន្ធច្បាប់មួយដែលមានប្រសិទ្ធភាពសម្រាប់ វិស័យដឹកជញ្ជូននិងការជំរុញការអនុវត្តច្បាប់ គឺនៅតែបន្តជាអាទិភាព មួយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ *អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (គ.ស.ច.គ)* ត្រូវបានបង្កើត និងមានការទទួលខុសត្រូវ ដូចខាងក្រោម :

- រៀបចំ និងផ្សព្វផ្សាយ ព័ត៌មានស្តីពី *ផែនការជាតិសុវត្ថិភាពចរាចរណ៍* ។
- រៀបចំសិក្ខាសាលា ដើម្បីបង្កើនសុវត្ថិភាពចរាចរណ៍ផ្លូវថ្នល់ ។
- រៀបចំឈុតអប់រំខ្លីៗ ស្តីពី *សុវត្ថិភាពចរាចរណ៍ផ្លូវគោក* សម្រាប់ការផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍ ។
- រៀបចំវគ្គបណ្តុះបណ្តាលការងារសវនកម្ម និងបោះពុម្ពផ្សាយអំពី *សុវត្ថិភាពចរាចរណ៍ផ្លូវគោក* ។
- រៀបចំ*សប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក* ដែលធ្វើឡើងជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៤ ខែមេសា ។

- រៀបចំជាវគ្គបណ្តុះបណ្តាលច្បាប់ចរាចរណ៍ផ្លូវគោក ជូនដល់ប្រជាពលរដ្ឋ សម្រាប់ *ការប្រឡងយកបណ្ណបើកបរទោចក្រយានយន្ត* នៅតាម មន្ទីរសាធារណការខេត្ត-រាជធានី ។
- រៀបចំជាកម្មវិធី ចុះជួយបង្រៀនច្បាប់ចរាចរណ៍ផ្លូវគោក ជូនដល់ប្រជាពលរដ្ឋក្រីក្រ នៅតាមបណ្តាឃុំ ស្រុកឆ្ងាយៗ ដាច់ស្រយាលសម្រាប់ *ការប្រឡងយកបណ្ណបើកបរទោចក្រយានយន្ត* ។
- រៀបចំកម្មវិធីបង្រៀន និង កម្មវិធី *ប្រឡងផ្តល់បណ្ណបើកបរទោចក្រយានយន្ត* ដល់យុវជនគ្រប់អាយុ នៅតាម បណ្តាសាលារៀននានា នៅក្នុងរាជធានី-ខេត្ត ទាំងអស់ ទូទាំងប្រទេស ។
- រៀបចំសិក្ខាសាលា ដើម្បីរៀបចំ *ផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍* និង យុទ្ធនាការដើម្បីលើកកម្ពស់ការពាក់មួកសុវត្ថិភាពចរាចរណ៍ ។

១៤៨. តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ *គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់អតិបរមា* ដោយមានកិច្ចសហការជាមួយ ក្រុមហ៊ុនដឹកជញ្ជូននិងម្ចាស់រថយន្តដឹកជញ្ជូនទាំងឡាយ ការកំណត់ទម្ងន់អតិបរមា នៃយានយន្តដឹកជញ្ជូនតាមបណ្តាផ្លូវជាតិ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដោយប្រកាសរបស់ *ក្រសួងសាធារណការនិងដឹកជញ្ជូន* នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ។ បន្ទាប់ពីប្រកាសនេះត្រូវបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដល់ ក្រុមហ៊ុន និង អ្នកពាក់ព័ន្ធ រួចមក ការដឹកជញ្ជូនលើសទម្ងន់កំណត់តាមផ្លូវជាតិ ត្រូវបានកាត់បន្ថយ ។ ដើម្បីទប់ស្កាត់បទល្មើសទាំងនេះ *ក្រសួងសាធារណការនិងដឹកជញ្ជូន* បានរៀបចំដំឡើង ស្ថានីយថ្លឹងរថយន្តនិងជញ្ជីងចល័ត លើកំណាត់ផ្លូវមួយចំនួន រួមមាន ជញ្ជីងថ្លឹងរថយន្តបង្កប់ ចំនួន ៨កន្លែង និង ជញ្ជីងចល័តចំនួន ១៨ ។ ស្ថានីយថ្លឹងរថយន្តអចិន្ត្រៃយ៍ ចំនួន ៧កន្លែង ត្រូវបានសាងសង់លើកំណាត់ផ្លូវមួយចំនួន និង ជញ្ជីងចល័តចំនួន ២០ ត្រូវបានដាក់ឱ្យដំណើរការនៅក្នុង ឆ្នាំ២០០៩ ។

១៤៩. *អនុក្រឹត្យស្តីពី ការគ្រប់គ្រងយានដ្ឋានជួសជុល ដំឡើង និងកែច្នៃយានយន្ត* ត្រូវបានអនុម័ត ហើយកំពុងត្រូវបានផ្សព្វផ្សាយ ដើម្បីទប់ស្កាត់ការកែច្នៃខុសលក្ខណៈបច្ចេកទេស ដែលធ្វើឱ្យយានយន្តមួយចំនួន អាចដឹកជញ្ជូន លើសទម្ងន់កំណត់ ។

១៥០. **ផ្លូវដែក :** បច្ចុប្បន្ន ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញនានាតាមផ្លូវដែក នៅមានកម្រិតនៅឡើយ ។ ផែនការមួយចំនួន ត្រូវបាននិងកំពុងរៀបចំឡើង ដើម្បីស្តារនិងពង្រីកមធ្យោបាយដឹកជញ្ជូនផ្លូវដែក និងធ្វើសមា-ហរណកម្ម ផ្លូវដែកនេះ ទៅក្នុងប្រព័ន្ធផ្លូវដែកតំបន់ ។ *គណៈកម្មាធិការកំណែទម្រង់និងការស្តារផ្លូវដែកឡើងវិញ* និង *គណៈកម្មាធិការគ្រប់គ្រងការធ្វើសម្បទានផ្លូវដែក* ត្រូវបានបង្កើតឡើង និងដំណើរការ ។ សមិទ្ធផល និង វឌ្ឍនភាព ក្នុងវិស័យផ្លូវដែកមានដូចខាងក្រោម :

- កិច្ចព្រមព្រៀងសម្បទានរយៈពេល ៣០ឆ្នាំ រវាង *រាជរដ្ឋាភិបាលកម្ពុជា* និង *ក្រុមហ៊ុនឯកជន ថុល រ៉ូយ៉ាល់ ខាំបូឌា របស់អូស្ត្រាលី* ត្រូវបានចុះហត្ថលេខា នាខែមិថុនា ឆ្នាំ២០០៩ ។ កិច្ចព្រមព្រៀងនេះ បានចូលជាធរមាន ហើយដំណាក់កាលអន្តរកាល បានចាប់ផ្តើមពី ចុងខែកញ្ញា ឆ្នាំ២០០៩ ហើយ *រាជរដ្ឋាភិបាលកម្ពុជា* បានផ្ទេរ ទ្រព្យសម្បត្តិ មន្ត្រី បុគ្គលិក និងកម្មករ របស់អតីត*រាជាយស្ម័យយានកម្ពុជា* ទៅឱ្យក្រុមហ៊ុន *ថុល រ៉ូយ៉ាល់ ខាំបូឌា* និង បានបង្កើតនាយកដ្ឋានផ្លូវដែកថ្មី ។
- គម្រោងនីតិសម្បទាមួយ ដែលមានទឹកប្រាក់សរុបចំនួន ៧៣ លានដុល្លារ ត្រូវបានផ្តល់ហិរញ្ញប្បទានរួមគ្នាដោយ *ធនាគារអភិវឌ្ឍន៍អាស៊ី* OPEC/OFID[1] *ប្រទេសម៉ាឡេស៊ី* រួមជាមួយ ថវិកាបដិភាគរបស់ *រាជរដ្ឋាភិបាល* កំពុងដំណើរការអនុវត្តបានល្អ ។ តាមរយៈគម្រោងនេះ ផ្នែកមួយចំនួននៃប្រព័ន្ធផ្លូវដែក នឹងត្រូវបានធ្វើការស្តារឡើងវិញ ដែលក្នុងនោះ រួមមាន (១) កំណាត់ផ្លូវដែកដែលបាត់មិនទាន់មាន ដែលតភ្ជាប់ពី*ក្រុងសិរីសោភ័ណ* ទៅ *ប៉ោយប៉ែត* (តភ្ជាប់ទៅនឹង*ផ្លូវដែកថៃ*) ប្រវែង ៤៨ គ.ម *(២)* កំណាត់ផ្លូវដែលតភ្ជាប់ពី *រាជធានីភ្នំពេញ* ទៅ *កំពង់ផែក្រុងព្រះសីហនុ* ប្រវែង ២៦៤ គ.ម និង *(៣)* កំណាត់ផ្លូវដែលតភ្ជាប់ពី *រាជធានីភ្នំពេញ* ទៅ *ក្រុងសិរីសោភ័ណ* ប្រវែង ៣៣៨ គ.ម ។
- ការរៀបចំផ្តល់សហហិរញ្ញប្បទានមួយផ្សេងទៀត ដែលសន្យាផ្តល់ទុន តាមរយៈ ឥណទានកម្ចីពី*ធនាគារអភិវឌ្ឍន៍អាស៊ី* និងជំនួយឥតសំណងពី *ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី* (ទឹកប្រាក់សរុបចំនួន ៦៨,៤ លានដុល្លារអាមេរិក) នឹងផ្តល់ហិរញ្ញប្បទាន សម្រាប់ការសាងសង់ឃ្លាំង និងស្ថានីយទំនិញថ្មីមួយនៅ*សំរោង* (ចម្ងាយប្រមាណ ៩ គ.ម ពី *រាជធានីភ្នំពេញ*) និងសម្រាប់ការកែលម្អបន្ថែមនូវបណ្តាញផ្លូវដែកដោយរាប់បញ្ចូលទាំង ផ្លូវបំបែក ទៅឃ្លាំងរបស់ *ត្រីនត្រេត* (ចម្ងាយ ៦ គ.ម ពី*រាជធានីភ្នំពេញ*) និងខ្សែផ្លូវដែកផ្នែកខាងជើង ។ ទិសដៅនៃគម្រោងស្តារឡើងវិញ គឺដើម្បីបំពេញបន្ថែមនិងលើកម្ពស់សមត្ថភាពទ្ររបស់អ័ក្សភ្លៅនៃទូររថភ្លើងឱ្យបានដល់ទម្ងន់ ២០ តោន និងល្បឿន ៥០ គ.ម ក្នុងមួយម៉ោង នៅលើផ្លូវដែកទិសខាងជើង ។ តាមផែនការការងារ ការស្តារផ្លូវដែកទាំងពីរគម្រោងខាងលើនេះ នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៣ ។
- *រាជរដ្ឋាភិបាលកម្ពុជា* ក៏កំពុងស្វែងរកការវិនិយោគ តាមរយៈ ដៃគូអភិវឌ្ឍន៍ និង ផ្នែកឯកជន ដើម្បីសាងសង់*កំណាត់ផ្លូវដែក ដែលមិនទាន់មាន* ប្រវែងសរុប ២៥៥គ.ម *ដើម្បីតភ្ជាប់ពី បាត់ដឹង ទៅ ត្រពាំងស្រែ* (ដែលជាចំណុចតភ្ជាប់រវាងកម្ពុជា ជាមួយព្រំដែនវៀតណាម) ជាផ្នែកមួយនៃគម្រោងផ្លូវដែកអាស៊ី សម្រាប់អាស៊ី-ប៉ាស៊ីហ្វិក និង ផ្លូវដែកតំបន់ (*ផ្លូវដែកតភ្ជាប់សឹង្ហបុរី-គុនមីង*) សម្រាប់អាស៊ាន និង មហាអនុតំបន់មេគង្គ ។

---

១ OPEC: *អង្គការនៃប្រទេសនាំចេញប្រេងកាត* -- OFID: *មូលនិធិសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិរបស់* OPEC

- *ក្រសួងសាធារណការនិងដឹកជញ្ជូន* កំពុងរៀបចំការសិក្សា ពីលទ្ធភាពដែលអាចធ្វើទៅបានផ្នែកវិស្វកម្ម ។ បន្ទាប់ពីការផ្លាស់ប្តូរទំនាក់ទំនងគ្នាតាមលិខិតរវាង *រាជរដ្ឋាភិបាលកម្ពុជា* និង *រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន* កាលពី ថ្ងៃទី២៤ កញ្ញា និង ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ មក *រដ្ឋាភិបាលចិន* បានឯកភាពធ្វើការសិក្សាពីផ្នែកផ្លូវដែកដែលមិនទាន់មាន នៃគម្រោងផ្លូវដែកតំបន់ (*ផ្លូវដែកតភ្ជាប់សិង្ហបុរី-គុនមីង*) នៅកម្ពុជា ។ ការសិក្សាដែលត្រូវបានរៀបចំធ្វើឡើង ដោយ*វិទ្យាស្ថានរៀបចំគម្រោងនិងអង្កេត ផ្លូវដែកទី៣* បានចាប់ផ្តើមឡើង កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ហើយ នឹងអាចបញ្ចប់ក្នុង ខែតុលា ឆ្នាំ២០១០ ។
- *រាជរដ្ឋាភិបាលកម្ពុជា* ក៏បានចុះហត្ថលេខាលើ *អនុស្សរណៈយោគយល់គ្នា* លើការតភ្ជាប់ផ្លូវដែក រវាងកម្ពុជា និង វៀតណាម ត្រង់ចំណុចត្រពាំងស្រែ (កម្ពុជា) និង វ៉ាលី (វៀតណាម) នៅក្នុងឆ្នាំ២០០៨ ។
- សេចក្តីព្រាង*កិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវដែកឆ្លងកាត់ព្រំប្រទល់ប្រទេស រវាង កម្ពុជា និង ថៃ* ត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់ប្រទេសទាំងពីរ (*រាជាយស្វ័យយានកម្ពុជា និង ផ្លូវដែករដ្ឋថៃ*) ។ សេចក្តីព្រាងទីមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានយកមកបង្ហាញ និងពិភាក្សាក្នុងខែមករា ឆ្នាំ២០០៧ ។ កិច្ចប្រជុំចុងក្រោយរវាងក្រុមការងារទាំងពីរ ត្រូវបានរៀបចំធ្វើឡើងកាលពីខែមីនា ឆ្នាំ២០០៨ ។ ថ្មីៗនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានប្រគល់ភារកិច្ចជូន *ក្រសួងសាធារណការនិងដឹកជញ្ជូន* ដើម្បីបន្តធ្វើការចរចាបញ្ចប់ *កិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់តាមផ្លូវដែក រវាងកម្ពុជា-ថៃ នៅច្រកប៉ោយប៉ែត-អារញ្ញប្រាថេត* ជាមួយភាគីថៃ ។

១៥១. **កំពង់ផែ :** *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រ *"បើកចំហជើងសមុទ្រ"* ។ តាមរយៈយុទ្ធសាស្ត្រនេះ *កំពង់ផែក្រុងព្រះសីហនុ* បានសាងសង់ចំណតផែកុងតឺន័រ បន្ថែមបានប្រវែង ៤០០ម ដែលអាចទទួលបរិមាណនាវាដែលមានជម្រៅទឹក៩ម បាន ១៣៥គ្រឿង ក្នុងមួយខែ ។ ចំណតផែកុងតឺន័រនេះ មានសមត្ថភាពអាចស្តុកកុងតឺន័រ ក្នុងចំនួនអតិបរមាបាន ៧ ៥០០ TEUs[១] ក្នុងមួយពេល ឬ ៣៤០ ០០០ TEUs ក្នុងមួយឆ្នាំ (មានសមត្ថភាពលើកដាក់ទំនិញ ជាមធ្យមបានប្រមាណ ២៥កុងតឺន័រ ក្នុងមួយម៉ោង សម្រាប់ដងយោងមួយ) ។ នៅក្នុងឆ្នាំ២០០៨ បរិមាណទំនិញឆ្លងកាត់សរុបមានប្រមាណ ២ ០៥៧ ៥៦៧តោន និង កុងតឺន័រប្រមាណ ២៥៨ ០០០ TEUs កើនលើសពី បរិមាណទំនិញឆ្លងកាត់សរុប នៅឆ្នាំ២០០៧ ដែលមានតែប្រមាណ ១ ៨១៨ ៨៧៧ តោន និង កុងតឺន័រប្រមាណ ២៥៣ ២៧១ TEUs ។

១៥២. ការងារកែលម្អ*កំពង់ផែស្វយ័តភ្នំពេញ* រួមមាន (១) ការបន្ថែមគ្រឿងចក្រសម្រាប់លើកដាក់កុងតឺន័រមួយគ្រឿង ដែលមានសមត្ថភាពលើកដាក់បាន ៤៥តោន (២) ឧបករណ៍សម្រាប់លើកដាក់សំបកកុងតឺន័រទំហំ ៤០ហ្វីត ក្នុងមួយគ្រឿង (៣) ធ្វើការបោះពោងសញ្ញានាវាចរណ៍ពីព្រំប្រទល់ប្រទេសវៀតណាមមកភ្នំពេញ (៤)

---

[១] Twenty Equivalent Units: កត្តាបម្លែងជាខ្នាត ២០ហ្វីតរបស់កុងតឺន័រ

ការរៀបចំប្រព័ន្ធសុវត្ថិភាព ដោយប្រើប្រាស់ម៉ាស៊ីនកាមេរ៉ាតាមដាននិងបណ្ណសម្គាល់ខ្លួន (៥) ការបំពាក់ម៉ាស៊ីនកាំរស្មីអ៊ិចស្កែនណឺមួយគ្រឿង (៦) រៀបចំបើកសាលាបណ្តុះបណ្តាលនាវាចរណ៍ សម្រាប់មន្ត្រីមកពីកំពង់ផែអន្តរជាតិទាំងពីរ និង (៧) ការដាក់សម្ភោធឱ្យប្រើប្រាស់នូវអគាររដ្ឋបាល ដែលផ្តល់សេវាច្រកចេញ-ចូលតែមួយ ។ ក្នុងឆ្នាំ២០០៨ បរិមាណនាវាសរុបចូលចតនៅកំពុងផែស្វយ័ត ភ្នំពេញមានចំនួន ១ ៥៤៣គ្រឿង លើសពីឆ្នាំ២០០៧ ដែលមានតែប្រមាណ ១ ៣៩៨គ្រឿង ។ បរិមាណទំនិញឆ្លងកាត់កំពុងផែនេះ មានប្រមាណ ១ ២៤០ ៣៣៩តោន កើនឡើង១២ភាគរយ ប្រៀបធៀបនឹងឆ្នាំ២០០៧ ដែលមានត្រឹមតែ ១ ១០៦ ៧០១តោន ។ ក្នុងឆ្នាំ២០០៨ បរិមាណកុងតឺន័រឆ្លងកាត់ មានប្រមាណ ៤៧ ៥០៧ TEUs កើនឡើងតិចតួច បើប្រៀបធៀបនឹងឆ្នាំ២០០៧ ដែលមាន ៤៧ ៥០៤ TEUs ។ បរិមាណនាវាដឹកអ្នកដំណើរ ចូលចតនៅកំពង់ផែនេះ ក្នុងឆ្នាំ២០០៨ មានចំនួន ១ ៨៧៨គ្រឿង ថយចុះ ៣ភាគរយ បើប្រៀបធៀបនឹង ឆ្នាំ២០០៧ ដែលមាន ១ ៩៣១ គ្រឿង ។

១៥៣. *សេវាភ្នាក់ងារនាវា-ព័ស្តុភារកម្ម* : ស្របតាមយុទ្ធសាស្ត្រ *"បើកចំហជើងសមុទ្រ"* របស់*រាជរដ្ឋាភិបាលកម្ពុជា* សេវាភ្នាក់ងារនាវា-ព័ស្តុភារកម្ម បានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម នៅក្នុងការអភិវឌ្ឍកំពង់ផែអន្តរ-ជាតិ ខេត្តព្រះសីហនុនិងរាជធានីភ្នំពេញ និង បានបម្រើសេវានាវា នៅកំពង់ផែឯកជន (*ឧកញ៉ាម៉ុង ស្រែអំបិល កោះកុង និង កំពត*) ព្រមទាំង បានវិនិយោគលើការបំពាក់មធ្យោបាយ លើកដាក់កុងតឺន័រមួយគ្រឿង នៅកំពង់ផែភ្នំពេញ ។ ទោះបីជា ចំនួននាវាគ្រប់ប្រភេទ ដែលទទួលបានសេវាបម្រើ មានការថយចុះតិចតួច ប្រមាណ ០,៣៨ ភាគរយ ក៏ដោយ ក៏បរិមាណនៃទំនិញលើកដាក់សរុប ក្នុងឆ្នាំ២០០៨ មានការកើនឡើង ប្រមាណ ២៧,៥៧ ភាគរយ ធៀបនឹង ឆ្នាំ២០០៧ ។

១៥៤. **សេវាកម្មអាកាសចរណ៍ស៊ីវិល :** *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រ *"បើកចំហជើងមេឃ"* ។ វិស័យអាកាសចរណ៍ស៊ីវិល មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបានរួមចំណែកជំរុញឱ្យមានការអភិវឌ្ឍវិស័យទេសចរណ៍ ។ ទោះជាដូចនេះក្តី វិស័យនេះ បាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗ ដែលត្រូវបន្តដោះស្រាយ ក្នុងរយៈពេលមធ្យមនិងវែង ។ សមិទ្ធផល និង បញ្ហាប្រឈម ទាំងនោះ រួមមាន :

- វឌ្ឍនភាពក្នុង *ផ្នែកដឹកជញ្ជូនតាមផ្លូវអាកាស* អាចកត់សម្គាល់ឃើញ តាមរយៈ ការកើនឡើងនៃ ចំនួនក្រុមហ៊ុនអាកាសចរណ៍បរទេស (មានចំនួន ១៧ក្រុមហ៊ុន នៅឆ្នាំ២០០៩) ដែលធ្វើប្រតិបត្តិការហោះហើរទៀតទាត់ មកកាន់ប្រទេសកម្ពុជា និងចំនួនក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក (មានចំនួន ៣ក្រុមហ៊ុន នៅឆ្នាំ ២០០៩) ដែលកំពុងធ្វើប្រតិបត្តិការហោះហើរ ទៅតំបន់នានា នៅក្នុងប្រទេស ។
- *ផ្នែកហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន* ក៏សម្រេចបាននូវវឌ្ឍនភាពធំៗ ផងដែរ ដូចជា ការពង្រីកអាកាសយានដ្ឋានអន្តរជាតិទាំងបី ការកែលម្អស្ថានីយសម្រាប់អ្នកដំណើរ អគារបច្ចេកទេស ការពង្រីកបន្ថែមចំណតយន្តហោះ ការជួសជុលផ្លូវរត់ ការបំពាក់ឧបករណ៍បរិក្ខារសម្រាប់ត្រួតពិនិត្យសន្តិសុខ លិខិតឆ្លងដែនទិដ្ឋាការ ព្រមទាំង ការពង្រីកសមត្ថភាពផ្នែកសង្គ្រោះ-ពន្លត់អគ្គីភ័យ និង ការកែលម្អសោភ័ណភាពទូទៅ ។

- *ផ្នែកប្រព័ន្ធត្រួតពិនិត្យចរាចរណ៍ផ្លូវអាកាស* ត្រូវបានធ្វើឱ្យប្រសើរឡើង និងត្រូវបានពង្រឹងជាលំដាប់ផងដែរ ។ សុវត្ថិភាពក្នុងការហោះហើរ ត្រូវបានធានាបានល្អ នៅទូទាំងដែនអាកាសកម្ពុជា តាមរយៈ ការពង្រឹងការគ្រប់គ្រងការផ្តល់សេវាត្រួតពិនិត្យចរាចរណ៍និងការនាំផ្លូវអាកាស ការធ្វើទំនើបកម្មឧបករណ៍បរិក្ខារនិងបច្ចេកវិទ្យា និង ការកែសម្រួលជាជំហានទូវផ្លូវអាកាស ក្នុងនោះមាន *ផែនការមេស្តីពី ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យចរាចរណ៍ផ្លូវអាកាសថ្មីតាមផ្កាយរណប* ដែលកំពុងត្រូវបានសិក្សា សម្រាប់តំបន់ឥណ្ឌូចិន (កម្ពុជា-ឡាវ-វៀតណាម) ដើម្បីឱ្យស្របទៅតាម *អនុសាសន៍សម្រាប់ការអនុវត្តរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ* ។
- ការរៀបចំ *ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត* សម្រាប់វិស័យអាកាសចរណ៍ស៊ីវិល ក៏ សម្រេចបានលទ្ធផលធំៗ ផងដែរ ។ ច្បាប់និងបទប្បញ្ញត្តិ ជាច្រើន ដូចជា *ច្បាប់អាកាសចរណ៍ស៊ីវិល* ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ ក្នុងខែមករា ឆ្នាំ២០០៨ បទប្បញ្ញត្តិនានាទាក់ទងនឹងសុវត្ថិភាព ដែលត្រូវបានកំណត់ដោយ *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* ព្រមទាំង សេចក្តីព្រាង *កម្មវិធីសន្តិសុខអាកាសចរណ៍ស៊ីវិលជាតិ* និង *កម្មវិធីសុវត្ថិភាពជាតិ* ដែលកំពុងត្រូវបានបញ្ចប់ដោយ *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* ផងដែរ ។
- *ការចូលរួមពីវិស័យឯកជន និងការធ្វើឯកជនភាវូបនីយកម្ម* បានក្លាយជាយុទ្ធសាស្ត្រគ្រឹះ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មអាកាសចរណ៍ស៊ីវិល ។ ក្រុមហ៊ុនឯកជន SCA បាននិងកំពុងចូលរួមក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និង ខេត្តព្រះសីហនុ ហើយ *ក្រុមហ៊ុនសេវាចរាចរណ៍ផ្លូវអាកាសកម្ពុជា* បាននិងកំពុងដំណើរការគ្រប់គ្រងប្រព័ន្ធសេវានាំផ្លូវអាកាស ។
- ទន្ទឹមនឹងសមិទ្ធផលធំៗទាំងនេះ វិស័យអាកាសចរណ៍ស៊ីវិល បាននិងកំពុងជួបប្រទះបញ្ហាប្រឈមចម្បងៗ ដូចជា (១) ការធ្លាក់ចុះដ៏គួឱ្យកត់សម្គាល់ នៃចំនួនអ្នកដំណើរនិងបរិមាណទំនិញតាមផ្លូវអាកាសអន្តរជាតិ និងផ្លូវអាកាសក្នុងស្រុក ដោយសារ វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោកនិងការសាយភាយជំងឺផ្តាសាយថ្មី ដែលកំពុងបន្តកើតមាន និង (២) ភាពចាំបាច់ក្នុងការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្រាប់វិស័យអាកាស-ចរណ៍ស៊ីវិលទាំងមូល ជាដើម ។

១៩៥. **កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ទន្លេមេគង្គ** : កិច្ចព្រមព្រៀងនេះ ដោយរាប់បញ្ចូល ទាំងឧបសម្ព័ន្ធ និងពិធីសារទាំង ២០ នៃកិច្ចព្រមព្រៀងនេះផង បានចូលជាធរមាន នាពេលបច្ចុប្បន្ននេះ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តល់សច្ចាប័ន និងតម្កល់ទុកលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន លើពិធីសារចំនួន ៣ និងឧបសម្ព័ន្ធ ចំនួន ១៧ ។ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានចុះហត្ថលេខាទ្វេភាគីលើ *អនុស្សរណៈយោគយល់គ្នា* ជាមួយ *ប្រទេសថៃ* និង *វៀតណាម* ស្តីពី *ការផ្តួចផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ទន្លេមេគង្គ* ។ វឌ្ឍនភាព ដែលមានមកដល់បច្ចុប្បន្ន រួមមាន :

- *រវាងកម្ពុជា និងថៃ :*
  - ➢ *អនុស្សរណៈយោគយល់គ្នា* ចំនួន២ ត្រូវបានចុះហត្ថលេខា ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន នៅចំណុចត្រួតពិនិត្យ *ប៉ោយប៉ែត-អរញ្ញប្រាថេត* ។
    - *អនុស្សរណៈយោគយល់គ្នាស្តីពីការផ្តួចផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ ទន្លេមេគង្គ នៅចំណុចច្រកទ្វារព្រំដែនប៉ោយប៉ែត-អរញ្ញប្រាថេត ។*
    - *អនុស្សរណៈយោគយល់គ្នាស្តីពីការផ្លាស់ប្តូរសិទ្ធិធ្វើចរាចរណ៍ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ ទន្លេមេគង្គ នៅចំណុចច្រកទ្វារព្រំដែនប៉ោយប៉ែត-អរញ្ញប្រាថេត ។*
  - ➢ កូតានៃយានយន្តចំនួន៤០គ្រឿង ធ្វើចរាចរឆ្លងកាត់ព្រំដែន ពីប្រទេសនីមួយៗ ត្រូវបានទទួលការឯកភាពព្រមព្រៀងគ្នា ដោយភាគីទាំងពីរ ។ ការកំណត់ប៉ុស្តិ៍ត្រួតពិនិត្យបន្ថែម កំពុងត្រូវបានពិចារណា និងពិភាក្សាគ្នាជាបន្តបន្ទាប់ ។
  - ➢ ដោយសារ ការកំណត់ និងការសាងសង់ តំបន់ត្រួតពិនិត្យរួមគ្នា ដើម្បីអនុវត្តការត្រួតពិនិត្យរួមគ្នាឈប់តែមួយលើក និងការត្រួតពិនិត្យរួមគ្នានៅបញ្ជរតែមួយ មិនអាចធ្វើទៅបាន ភាគីទាំងពីរបានឯកភាពគ្នា ក្នុងការផ្តាច់ចេញពីគ្នា នូវ *អនុស្សរណៈយោគយល់គ្នា* ទាំងពីរ ដើម្បីឱ្យ *អនុស្សរណៈយោគយល់គ្នាស្តីពីការផ្លាស់ប្តូរសិទ្ធិធ្វើចរាចរណ៍* (កូតា ៤០គ្រឿង) អាចអនុវត្តទៅបាននៅចំណុចត្រួតពិនិត្យច្រកទ្វារ *ប៉ោយប៉ែត- អរញ្ញប្រាថេត* ។

- *រវាងកម្ពុជា និងវៀតណាម:*
  - ➢ *អនុស្សរណៈយោគយល់គ្នា* ចំនួន១ ត្រូវបានចុះហត្ថលេខា : *អនុស្សរណៈយោគយល់ គ្នាស្តីពីការផ្តួចផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ទន្លេមេគង្គ នៅ ចំណុចច្រកទ្វារព្រំដែនបាវិត-ម៉ុកបាយ* ។ ការកំណត់និងការសាងសង់ តំបន់ត្រួតពិនិត្យរួមគ្នា និងការបង្កើតនីតិវិធីគយ សម្រាប់ត្រួតពិនិត្យទំនិញ និងយានយន្តឆ្លងកាត់ ព្រំដែន កំពុងត្រូវបានអនុវត្ត ។
  - ➢ *អាជ្ញាធរគយ* នៃភាគីទាំងពីរ បានឯកភាពនិងចុះហត្ថលេខាលើ *អនុស្សរណៈយោគយល់គ្នាស្តីពី នីតិវិធីគយ* ដើម្បីផ្តួចផ្តើមអនុវត្ត *កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់មហាអនុតំបន់ទន្លេមេគង្គ* នៅត្រង់ចំណុចត្រួតពិនិត្យ *បាវិត-ម៉ុកបៃ* ។
  - ➢ នៅក្នុងដំណាក់កាលដំបូង *រដ្ឋាភិបាល* ទាំងពីរ បានឯកភាពគ្នា អនុវត្ត *កិច្ចព្រមព្រៀងទ្វេភាគីដឹកជញ្ជូនផ្លូវគោក* ពីឆ្នាំ២០០៦ មក ។

១៥៦. **កិច្ចព្រមព្រៀងទ្វេភាគី និងត្រីភាគី ដឹកជញ្ជូន** ជាមួយបណ្តាប្រទេសជិតខាង រួមមាន :

- *កិច្ចព្រមព្រៀងទ្វេភាគី ដឹកជញ្ជូនផ្លូវគោក កម្ពុជា-ឡាវ :*

- ➢ *កិច្ចព្រមព្រៀងពិធីសារ និង អនុស្សរណៈយោគយល់គ្នា* ត្រូវបានចុះហត្ថលេខា ជាមួយភាគី *ឡាវ* ។
- ➢ កូតា របស់រថយន្តដឹកទំនិញ មានចំនួន ៤០គ្រឿង ។ ទោះជាដូចនេះក្តី ក៏ការធ្វើប្រតិបត្តិការ ខាងដឹកទំនិញ មិនទាន់បានអនុវត្តនៅឡើយ ។
- ➢ *កិច្ចព្រមព្រៀងនៃភាពជាដៃគូ* ដាច់ដោយឡែកមួយចំនួន ស្តីពីការដឹកជញ្ជូនអ្នកដំណើរ ត្រូវបានធ្វើឡើងរវាង សមាគមឬក្រុមហ៊ុនក្នុងស្រុកនៃទីក្រុងពីរ ដែលជាគោលដៅកំណត់ ។ កិច្ចព្រមព្រៀង នៃភាពជាដៃគូនេះត្រូវមានការឯកភាពពី *ក្រសួងសាធារណការនិងដឹកជញ្ជូន* នៃប្រទេសទាំងពីរ ផងដែរ ។
- ➢ រហូតដល់ពេលបច្ចុប្បន្ន កិច្ចព្រមព្រៀងនៃភាពជាដៃគូ ចំនួន០២ ត្រូវបានអនុវត្ត នៅលើគន្លងផ្លូវ : *ភ្នំពេញ-ប៉ាក់សេ ស្ទឹងត្រែង-ប៉ាក់សេ* និង *សៀមរាប-ភ្នំពេញ-ប៉ាក់សេ* ។

- *កិច្ចព្រមព្រៀងទ្វេភាគី ដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹក រវាង កម្ពុជា-វៀតណាម* :
  - ➢ *កិច្ចព្រមព្រៀង ដឹកជញ្ជូនផ្លូវគោក ត្រូវបានចុះហត្ថលេខា* កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៩៨ ហើយ *ពិធីសារនៃកិច្ចព្រមព្រៀង* នេះ ត្រូវបានចុះហត្ថលេខា នៅថ្ងៃ ទី១០ ខែតុលា ឆ្នាំ២០០៥ ។ កូតារបស់រថយន្តដឹកទំនិញ និងរថយន្តក្រុងដឹកអ្នកដំណើរចំនួន ៤០ គ្រឿង ដែលឆ្លងកាត់ព្រំដែនតាមច្រកទ្វារ *ព្រំដែនបាវិត* ត្រូវបានទទួលការឯកភាពព្រមព្រៀងគ្នា ដោយភាគីទាំងពីរ ។ កិច្ចព្រមព្រៀងគ្នាមួយត្រូវបានធ្វើឡើង ដើម្បីបង្កើនកូតារបស់រថយន្តឆ្លងកាត់ព្រំដែន ពីចំនួន ៤០ គ្រឿង ដល់ ១៥០ គ្រឿង ហើយ ចំណុចត្រួតពិនិត្យតាមច្រកទ្វារព្រំដែន ចំនួន ៤កន្លែង ក្នុងចំណោម ៧កន្លែង ដែលបានឯកភាពគ្នា ត្រូវបានធ្វើពិធីបើកឱ្យដំណើរការ សម្រាប់ការដឹកជញ្ជូន ឆ្លងកាត់ព្រំដែន ក្នុងឆ្នាំ២០០៩ ។
  - ➢ *កិច្ចព្រមព្រៀងទ្វេភាគី ដឹកជញ្ជូនផ្លូវទឹក រវាងកម្ពុជា និងវៀតណាម* : កិច្ចព្រមព្រៀងទ្វេភាគី ថ្មីមួយ រវាង *កម្ពុជា* និង *វៀតណាម* ស្តីពីការដឹកជញ្ជូនផ្លូវទឹក ត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៩ ដើម្បីជំនួសឱ្យកិច្ចព្រមព្រៀង និងសេចក្តីព្រាងពិធីសារ ឆ្នាំ១៩៩៨ ។
- *កិច្ចព្រមព្រៀងត្រីភាគី កម្ពុជា ឡាវ និងវៀតណាម :* ប្រទេសទាំងបីបានឯកភាពគ្នា បង្កើត *ក្រុមការងារមួយ* សម្រាប់រៀបចំកិច្ចព្រមព្រៀងត្រីភាគី *កម្ពុជា-ឡាវ-វៀតណាម ស្តីពី ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន* ដែលនឹង ចាប់ផ្តើមនៅឆ្នាំ២០១០ ។

១៩៧. **ប្រព័ន្ធលូបង្ហូរទឹកនិងចម្រោះទឹកកខ្វក់ :** *ក្រសួងសាធារណការនិងដឹកជញ្ជូន* ក៏ទទួលខុសត្រូវផងដែរ ក្នុងការស្តារឡើងវិញ សាងសង់ និងថែរក្សា ប្រព័ន្ធលូបង្ហូរនិងចម្រោះទឹកកខ្វក់ ។ បច្ចុប្បន្ននេះ ប្រព័ន្ធលូបង្ហូរទឹក គឺជាបញ្ហាចម្បង នៅរាជធានីភ្នំពេញ ក្រុងព្រះសីហនុ និងទីក្រុងសៀមរាប ។ កង្វះខាតធនធាន គឺជាបញ្ហាប្រឈមចម្បង សម្រាប់ ការបន្តស្តារឡើងវិញនិងការសាងសង់នូវប្រព័ន្ធលូបង្ហូរទឹក និងស្ថានីយចម្រោះទឹកកខ្វក់ នៅទូទាំងប្រទេស ។ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធលូបង្ហូរទឹកនៅរាជធានីភ្នំពេញ ត្រូវបានលើកកម្ពស់កែលម្អ ចំណែកឯនៅក្រុងព្រះសីហនុវិញ ស្ថានីយចម្រោះទឹកកខ្វក់ ក៏ត្រូវបានសាងសង់បញ្ចប់ជាស្ថាពរ ហើយដែរ ។

ការសាងសង់ស្ថានីយចម្រោះទឹកកខ្វក់នៅទីក្រុងសៀមរាប ត្រូវបានបញ្ចប់ក្នុងជំហានទី១ ហើយ *ក្រសួងសាធារណការ និងដឹកជញ្ជូន* ក៏មានគម្រោង ពង្រីកវិសាលភាពការងារប្រព័ន្ធលូបង្ហូរទឹកនិងចម្រោះទឹកកខ្វក់ ដោយរួមបញ្ចូលទាំងការបូមសម្អាតស្ទឹងសៀមរាប ថែមទៀត ។ ជាមួយគ្នានេះដែរ ផែនការជាច្រើន សម្រាប់សាងសង់ស្ថានីយចម្រោះទឹកកខ្វក់ នៅខេត្តកំពត កំពុងត្រូវបានធ្វើការសិក្សា ។

១៥៨. *ក្រសួងសាធារណការ និងដឹកជញ្ជូន* កំពុងជួបប្រទះនឹងបញ្ហាប្រឈម ជាច្រើន ក្នុងនោះ រួមមាន :

- ដំណើរការនៃការពិនិត្យមើលឡើងវិញនូវផែនការទាំងឡាយ សម្រាប់ការស្តារ និងការសាងសង់នូវ អនុវិស័យមួយចំនួននៃវិស័យដឹកជញ្ជូន ត្រូវការពេលវេលាយូរអង្វែង។
- ច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ដែលចាំបាច់សម្រាប់ការដោះស្រាយបានប្រកបដោយប្រសិទ្ធភាពនូវបញ្ហាទាំងឡាយ ដែលកំពុងកើតមាន នៅមិនទាន់មានគ្រប់គ្រាន់ នៅឡើយ ។
- ផ្លូវ-ស្ពានទាំងឡាយ មានការខូចខាត លឿនជាងសមត្ថភាពបច្ចុប្បន្នសម្រាប់ ការស្តារ ការកែលម្អ និងការងារថែទាំជាប្រចាំ ឱ្យបានទាន់ពេលវេលា ។
- វិស័យឯកជន មិនមានការចាប់អារម្មណ៍ ក្នុងការចូលរួមថែទាំផ្លូវថ្នល់ ។
- ផ្លូវជាតិទាំងឡាយ កំពុងតែបន្តរងគ្រោះយ៉ាងខ្លាំង ដោយសារចរាចរណ៍នៃការដឹកជញ្ជូនលើសទម្ងន់កំណត់ ។
- បញ្ហាកកស្ទះចរាចរណ៍ និងការបំពុលបរិយាកាសទីក្រុង ព្រមទាំង ការគ្រប់គ្រងចរាចរណ៍ និងការរៀបចំការដឹកជញ្ជូនសាធារណៈក្នុងក្រុង បានក្លាយជាបញ្ហាប្រឈម ដែលត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយ ។
- សមត្ថភាពមន្ត្រីនិងស្ថាប័ន ក្នុងការរៀបចំផែនការផ្គត់ផ្គង់ព័ស្តុភារនិងការដឹកជញ្ជូនពហុរូបភាព ការរចនាប្លង់វិស្វកម្ម និង ការគ្រប់គ្រងទឹកកខ្វក់ នៅមានកម្រិតនៅឡើយ ។
- ថវិកាសម្រាប់ការរៀបចំប្រព័ន្ធទឹកកខ្វក់ នៅមានកម្រិតនៅឡើយ ហើយផ្នែកឯកជនមិនមានការចាប់អារម្មណ៍ក្នុងការចូលរួមវិនិយោគលើផ្នែកនេះ ។
- ការយល់ដឹងពីផលប៉ះពាល់អវិជ្ជមានដែលអាចមានដល់ សុខភាពនិងអនាម័យដែលបណ្តាលមកពីទឹកកខ្វក់ នៅមានកម្រិតទាបនៅឡើយ ហើយការបន្តកែលម្អយន្តការគ្រប់គ្រងទឹកកខ្វក់ គឺជាប្រការចាំបាច់ដែលត្រូវយកចិត្តទុកដាក់អនុវត្ត។

## ៤.២ ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ

១៥៩. *ក្រសួងធនធានទឹកនិងឧតុនិយម* បានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងអំឡុងពេល ពីឆ្នាំ២០០៦-២០០៨ នៅក្នុងផ្នែកនៃការស្តារឡើងវិញ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងផ្តល់ការការពារពីគ្រោះមហន្តរាយធម្មជាតិ (គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់) ដែលក្លាយជាបញ្ហាមិនអាចព្យាករ ជាមុនបានដោយសារការប្រែប្រួលអាកាសធាតុ ។ *ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក* ត្រូវបានអនុម័ត កាលពីខែមិថុនា ឆ្នាំ២០០៧ ។

១៦០. *ក្រសួងធនធានទឹកនិងឧតុនិយម* បានអនុវត្តគម្រោងជាច្រើន នៅទូទាំងប្រទេស ។ សកម្មភាពទាំងនេះរួមមាន :

- ជួសជុល-ស្តារឡើងវិញ ថែទាំ និង សាងសង់ ប្រព័ន្ធធារាសាស្ត្រ ចំនួន ១៤១គម្រោង ដែលផ្តល់ទឹកដល់ការស្រោចស្រពលើ ផ្ទៃដីស្រែកសិកម្ម ចំនួន ២៦៧ ២២៤ហិកតា (ក្នុងនោះ ដីស្រែវស្សា ចំនួន ១៩១ ២០២ហិកតា និង ដីស្រែប្រាំង ចំនួន ៧៦ ០២២ហិកតា) ។ នៅចុងឆ្នាំ២០០៨ សមត្ថភាពស្រោចស្រពផ្ទៃដីកសិកម្ម របស់ប្រព័ន្ធធារាសាស្ត្រ បានកើនឡើងដល់ ៨២៧ ៣៧៣ហិកតា ស្មើនឹង ៣១,៦ភាគរយ នៃផ្ទៃដីដាំដុះទាំងអស់ (២ ៦១៥ ៧៤១ហិកតា) ក្នុងនោះ លទ្ធភាពស្រោចស្រពលើផ្ទៃដីស្រូវវស្សាមាន ៥៨២ ០៨៥ ហិកតា និង ផ្ទៃដីស្រូវប្រាំងមាន ២៤៥ ២៨៨ហិកតា ។
- ជីកអណ្តូងខួង ចំនួន ៣០អណ្តូង ដើម្បីប្រើប្រាស់ទឹកក្រោមដី សម្រាប់ការស្រោចស្រពដំណាំ ។
- កាត់បន្ថយភាពងាយរងគ្រោះដោយសារ គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត តាមរយៈ :
    - ➢ ការជួសជុល-ស្តារឡើងវិញនូវ ទំនប់ការពារទឹកជំនន់ ចំនួន ៧គម្រោង ដែលមានលទ្ធភាពការពារផ្ទៃដីដាំដុះ បានចំនួន ១៣០ ៧៩៩ហិកតា ។ មកដល់ឆ្នាំ២០០៨ ផ្ទៃដីដែលបានការពារពីទឹកជំនន់ បានកើនឡើងដល់ ២៤៤ ២៩៩ហិកតា ។
    - ➢ ការជួសជុល-ស្តារឡើងវិញនូវ ទំនប់ការពារទឹកប្រៃ ចំនួន ៦គម្រោង ដែលអាចការពារផ្ទៃដីដាំដុះពីទឹកប្រៃ បាន ចំនួន ១៤ ៣២៨ហិកតា ។ រហូតមកដល់ឆ្នាំ២០០៨ ផ្ទៃដីសរុប ដែលបានទទួលការការពារពីទឹកប្រៃ មាន ៣១ ០០៨ហិកតា ។
    - ➢ ដំឡើងស្ថានីយបូមទឹក ចំនួន ១២ស្ថានីយ និងជួសជុលមួយស្ថានីយ ដែលអាចសង្គ្រោះស្រូវ ដែលរងផលប៉ះពាល់ពីភាពរាំងស្ងួត បានចំនួន ៣០៥ ២២៥ហិកតា (ក្នុងនោះ ១៣៧ ១២២ហិកតា ក្នុងរដូវប្រាំង និង ១៦៨ ១០៣ហិកតា ក្នុងរដូវវស្សា ។
- រៀបចំសហគមន៍កសិករប្រើប្រាស់ទឹក បានចំនួន ៣៥០សហគមន៍ ដោយមានការចូលរួមពីកសិករចំនួន ៣០៥ ៥៥០គ្រួសារ ។ ស្ត្រីបានចូលរួមយ៉ាងសកម្ម នៅក្នុងការដឹកនាំគណៈកម្មាធិការ របស់សហគមន៍កសិករប្រើប្រាស់ទឹកនេះ ។
- ធ្វើឱ្យប្រសើរឡើងនូវ ផ្នែកជលសាស្ត្រ តាមរយៈ :
    - ➢ ការជួសជុលនិងការដំឡើង ស្ថានីយជលសាស្ត្រ ចំនួន ២០ស្ថានីយ នៅតាមបណ្តោយ *ទន្លេមេគង្គ ទន្លេសាប* និង *ទន្លេបាសាក់* ។
    - ➢ ការដំឡើងក្តារវាស់កម្ពស់ទឹក បានចំនួន ៣៩កន្លែង នៅតាមចំណុចត្រួតពិនិត្យ តាមបណ្តោយទន្លេសំខាន់ៗ ។
    - ➢ ការដំឡើងម៉ាស៊ីនកត់ត្រាកម្ពស់ទឹក ដោយស្វ័យប្រវត្តិ ចំនួន ១៣កន្លែង នៅតាមចំណុចត្រួតពិនិត្យតាមបណ្តោយ ទន្លេនិងស្ទឹង សំខាន់ៗ ។

- ➢ ការដំឡើងឧបករណ៍វាស់ធារទឹក បានចំនួន ៤កន្លែង នៅ *ស្ទឹងសៀមរាបខេត្តសៀមរាប ស្ទឹងសង្កែខេត្តបាត់ដំបង ស្ទឹងពោធិ៍សាត់ខេត្តពោធិ៍សាត់* និង *ស្ទឹងសំបូរខេត្តកំពង់ឆ្នាំង* ។

- ពង្រឹងសមត្ថភាព ក្នុងការផ្តល់ព័ត៌មានអំពី អាកាសធាតុ ឱ្យបានទាន់ពេលវេលា តាមរយៈ :
  - ➢ ការជួសជុលកែលម្អស្ថានីយត្រួតពិនិត្យសង្កេតធាតុអាកាស នៅរាជធានីនិងតាមបណ្តាខេត្ត សរុបបាន ចំនួន ៨កន្លែង ។
  - ➢ ការដំឡើងស្ថានីយពិនិត្យសង្កេតធាតុអាកាស ថ្មី បានចំនួន ៥កន្លែង នៅតាមបណ្តាខេត្ត ។
  - ➢ ការដំឡើងស្ថានីយសម្រាប់ វាស់ទិស-ល្បឿនខ្យល់ក្នុងរយៈកម្ពស់១០-១០០ម៉ែត្រ និងសម្រាប់ពិនិត្យអង្កេត កម្តៅនិងពន្លឺព្រះអាទិត្យ នៅរាជធានីនិងតាមបណ្តាខេត្ត សរុប ចំនួន ៥កន្លែង ។
  - ➢ ការដំឡើងស្ថានីយទទួលព័ត៌មាន តាមរយៈផ្កាយរណប MTSAT ដើម្បីពិនិត្យមើលស្ថានភាពពពកនៅរយៈកម្ពស់ខ្ពស់ បានចំនួន ១កន្លែង ។
  - ➢ ការដំឡើងប្រព័ន្ធទូរគមនាគមន៍ សម្រាប់ទទួលនិងបញ្ជូនទិន្នន័យឧតុនិយម ក្នុងក្របខ័ណ្ឌជាតិ និងក្នុងក្របខ័ណ្ឌ *ប្រព័ន្ធទូរគមនាគមន៍សាកលលោក* (GTS) ចំនួន១កន្លែង ។

- ធ្វើការសិក្សាពី អាងទន្លេ-ស្ទឹង នៅជុំវិញ *បឹងទន្លេសាប*និងស្ទឹងសំខាន់ៗ មួយចំនួនទៀត ដូចជា *អាងស្ទឹងបរិបូរណ៍ អាងស្ទឹងជួនទ្រី អាងស្ទឹងមង្គលបូរី អាងស្ទឹងសង្កែ អាងស្ទឹងស្វាយចេក អាងស្ទឹងព្រែកត្នោត* និង *អាងស្ទឹងក្រាំងពង្លៃ* ដើម្បីធ្វើការ គ្រប់គ្រងអភិរក្សនិងអភិវឌ្ឍវិស័យធនធានទឹក ឱ្យមានប្រសិទ្ធភាព និង ចីរភាព ព្រមទាំង ធ្វើការរៀបចំ *ផែនការមេស្តីពីការគ្រប់គ្រងធនធានទឹក* នៅក្នុង *ព្រះរាជាណាចក្រកម្ពុជា* ផងដែរ ។

១៦១. ទោះបីជាមានវឌ្ឍនភាព ដូចបានលើកឡើងនេះក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាច្រើន ដែលទាមទារឱ្យមានការដោះស្រាយ ដូចជា :

- *ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក* ត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់រួចហើយ ប៉ុន្តែ អនុក្រឹត្យមួយចំនួនមិនទាន់ត្រូវបានរៀបចំនៅឡើយ ហើយចាំបាច់ត្រូវតែបង្កើតឡើង ដើម្បីកំណត់យន្តការនិងសមត្ថកិច្ចសម្រាប់អនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព ជាពិសេស ការគ្រប់គ្រងអាងទន្លេ អាជ្ញាបណ្ណទឹក សហគមន៍កសិករប្រើប្រាស់ទឹក និងការការពារគុណភាពទឹក ។
- យន្តការសម្របសម្រួលអន្តរក្រសួង មិនទាន់ដំណើរការល្អ ដែលចាំបាច់ត្រូវតែពង្រឹងនិងជំរុញ ។
- មូលដ្ឋានទិន្នន័យព័ត៌មាន ស្តីពី ហេដ្ឋារចនាសម្ព័ន្ធ ដែលទាក់ទងនឹង ការគ្រប់គ្រងទឹក និង ការកែលម្អការកាត់បន្ថយផលប៉ះពាល់ ដោយទឹកជំនន់និងគ្រោះរាំងស្ងួត គឺជាប្រការចាំបាច់ ដែលត្រូវរៀបចំបង្កើតឡើង ។
- ការគ្រប់គ្រង ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ គឺជាប្រការចាំបាច់ ដែលត្រូវពង្រឹង ដើម្បី :

- ជ្រើសរើសតំបន់អាទិភាពសម្រាប់ ការស្តារឡើងវិញនិងការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលមានសក្តានុពលខ្ពស់ ដើម្បីបង្កើតចំណូលក្នុងសហគមន៍ជនបទ ។
- បាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាឃុំ ក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រក្នុងឃុំ ។
- ចាត់វិធានការ ដើម្បីលើកកម្ពស់ការគ្រប់គ្រងធនធានទឹក សំដៅរួមចំណែកក្នុងការបង្កើនជាអតិបរមា នូវផលិតផលកសិកម្ម ។
- បង្កើនការចូលរួមរបស់ កសិករនិងសហគមន៍កសិករ ក្នុងការដោះស្រាយបញ្ហានានា ដែលទាក់ទងនឹង ការប្រើប្រាស់និងការថែទាំ ប្រព័ន្ធធារាសាស្ត្រ ។
- កំណត់តម្លៃនៃធនធានហិរញ្ញវត្ថុ សម្រាប់ថែទាំប្រព័ន្ធធារាសាស្ត្រ ។

## ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

១៦២. *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* មានភារកិច្ចទទួលខុសត្រូវ លើការផ្គត់ផ្គង់ទឹកស្អាត ។ សមត្ថភាពផ្គត់ផ្គង់ទឹកស្អាត បានកើនឡើងគួរឱ្យកត់សម្គាល់ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ។ បច្ចុប្បន្ននេះ តំបន់ទីប្រជុំជនចំនួន ១១១ មានលទ្ធភាពទទួលបានទឹកស្អាត ពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ។ នៅ*រាជធានីភ្នំពេញ* ផលិតកម្មទឹកស្អាតបានកើនឡើង ពី ៧៩ ៤០០ ០៣១ម៣ ក្នុងឆ្នាំ២០០៧ ដល់ ៨៥ ៥៣១ ៦៤៩ម៣ ក្នុងឆ្នាំ២០០៨ ។ ក្នុងឆ្នាំ ២០០៩ ប្រជាជននៅរាជធានីភ្នំពេញ ប្រមាណ ៩០ភាគរយ មានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ពេញ ២៤ម៉ោង ។ គ្រួសារចំនួន ១៧ ៩៩០ ក្នុងនោះភាគច្រើន ជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ បានទទួលនូវគោលនយោបាយឧបត្ថម្ភលើតម្លៃសិទ្ធិជាវទឹកប្រើប្រាស់តាមស្ថានភាពជាក់ស្តែងនៃកម្រិតជីវភាពរស់នៅ ។

១៦៣. ក្នុងឆ្នាំ២០០៨ ប្រមាណ ៥១ ភាគរយ នៃប្រជាជនដែលរស់នៅ ក្នុងតំបន់ទីប្រជុំជនទូទាំងប្រទេស បានទទួលទឹកស្អាតប្រើប្រាស់ អាស្រ័យដោយរដ្ឋាករទឹក រាជធានី-ខេត្ត-ក្រុង បានបង្កើនសមត្ថភាពផលិតរបស់ខ្លួន ពី ១១ ៩៦៥ ៦៤៩ ម៣ ក្នុងឆ្នាំ២០០៧ បានកើនឡើងដល់ទៅ ១៣ ៧៥៤ ៧៦៩ម៣ ក្នុងឆ្នាំ២០០៨ ដើម្បីផ្គត់ផ្គង់តាមតម្រូវការរបស់ប្រជាជន ។

១៦៤. ទោះបីជាមានការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់ក៏ដោយ ក៏បញ្ហាប្រឈមក្នុងការផ្គត់ផ្គង់ទឹកស្អាត នៅតែបន្តមាន លើទិដ្ឋភាពមួយចំនួន ដូចខាងក្រោម :

- អត្រានៃប្រជាជន ដែលទទួលបានទឹកស្អាតប្រើប្រាស់ នៅតែមានកម្រិតទាបនៅឡើយ ។
- ការទទួលបានទឹកស្អាតប្រើប្រាស់របស់ប្រជាជនក្រីក្រ នៅតែមានកម្រិតនៅឡើយ ។
- ធនធានហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាតបន្តទៀត នៅតែមានកម្រិត នៅឡើយ ។

## ៤.៣ ការអភិវឌ្ឍវិស័យថាមពលនិងបណ្តាញអគ្គិសនី

១៦៥. វឌ្ឍនភាពគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឱ្យកើតមានឡើង នៅក្នុងការបង្កើតលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងការពង្រីកបណ្តាញអគ្គិសនី ។ ដើម្បីតម្រែតម្រង់ទិសដៅ នៃការអភិវឌ្ឍក្នុងវិស័យថាមពល *ផែនការអភិវឌ្ឍន៍វិស័យថាមពល ២០០៥-២០២៤* ត្រូវបានរៀបចំឡើង ។ *ផែនការមេ អគ្គិសនីកម្មជនបទ* ដែលផ្តោតលើការប្រើប្រាស់ថាមពលកកើតឡើងវិញ ក៏ត្រូវបានរៀបចំឡើងនិងកំពុងត្រូវបានអនុវត្ត នាពេលបច្ចុប្បន្ននេះ ។ សមិទ្ធ-ផលចម្បងៗ មានដូចខាងក្រោម :

- ខ្សែបញ្ជូនថាមពលអគ្គិសនី កម្លាំង ១១៥ គីឡូវ៉ុល ដែលតភ្ជាប់ពីព្រំដែនថៃ មកផ្គត់ផ្គង់ នៅក្នុងខេត្ត *បន្ទាយមានជ័យ សៀមរាប និង បាត់ដំបង* ត្រូវបានដំឡើងចប់សព្វគ្រប់ និងត្រូវបានដាក់ឱ្យដំណើរការ ។
- *ស្ថានីយមីក្រូវ៉ារីអគ្គិសនី អូររមិស និងអូរម្លេង* ដែលមាន អានុភាពសរុប ៣៧០គីឡូវ៉ាត់ និង ម៉ាស៊ីនភ្លើងបម្រុង កម្លាំង ៣០០ គីឡូវ៉ាត់ ត្រូវបានដាក់ឱ្យដំណើរការពេញលេញនៅទីរួម *ខេត្តមណ្ឌលគីរី* ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល ពីព្រំដែនកម្ពុជា-វៀតណាម មករាជធានីភ្នំពេញ (១១០ គីឡូម៉ែត្រ) និងអនុស្ថានីយតាកែវ នៅដើមឆមាសទី២ ឆ្នាំ២០០៩ ។
- បន្ថែមខ្សែបញ្ជូន ១១៥ គីឡូវ៉ុល (២៣ គីឡូម៉ែត្រ) នៅរាជធានីភ្នំពេញ និង បង្កើតអនុស្ថានីយភាគខាងលិច រាជធានីភ្នំពេញ នៅឆ្នាំ២០០៩ ។
- ដើម្បីអនុវត្តគោលនយោបាយ*អគ្គិសនីភាវូបនីយកម្មជនបទ រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើត *មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (មអជ)* ដើម្បីជំរុញឱ្យមានសមធមិក្នុងការទទួលសេវាកម្មអគ្គិសនី និងបានលើកទឹកចិត្តផ្នែកឯកជន ឱ្យចូលរួមវិនិយោគក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅជនបទ ប្រកបដោយចិរភាពជាពិសេស ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញ ។
- ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់ នៅក្នុងក្របខ័ណ្ឌ*មហាអនុតំបន់ទន្លេមេគង្គ កម្ពុជា* បានចូលរួមនៅក្នុងការអនុវត្ត *ផែនការពាណិជ្ជកម្មថាមពលក្នុងមហាអនុតំបន់ទន្លេមេគង្គ* ហើយក្នុងក្របខ័ណ្ឌ *អាស៊ាន* កម្ពុជាបានចូលរួមនៅក្នុងការអនុវត្តផែនការ *ប្រព័ន្ធបញ្ជូនថាមពលអាស៊ាន* ។

១៦៦. ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឱ្យកើតមានឡើងក៏ដោយ ក៏វិស័យថាមពលនៅតែជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗ ជាច្រើន :

- ការធានាឱ្យមានប្រសិទ្ធភាពនិងចិរភាព នៅក្នុង ផលិតកម្ម ការផ្គត់ផ្គង់ថាមពល និងការថែទាំយ៉ាងត្រឹមត្រូវនូវហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនី នៅទូទាំងប្រទេស ។
- ការបញ្ចុះថ្លៃដើមខ្ពស់នៃការផលិតថាមពលអគ្គិសនី នាពេលបច្ចុប្បន្ននេះ ដែលមិនត្រឹមតែជួយជំរុញដល់ការអភិវឌ្ឍវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង អាចធ្វើឱ្យមានថាមពលអគ្គិសនី ក្នុងតម្លៃមួយ ដែលប្រជាជនក្រីក្រអាចប្រើប្រាស់បាន ។

- ការទាក់ទាញការវិនិយោគ និងការចូលរួម របស់វិស័យឯកជន ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធថាមពល អគ្គិសនីសំដៅឆ្លើយតបទៅនឹង តម្រូវការដែលកំពុងកើនឡើង ជាពិសេស ការផ្គត់ផ្គង់ទៅសហគមន៍ជនបទ ។ នៅក្នុងឆ្នាំ២០០៨ មានប្រមាណតែ ១០ ភាគរយ នៃគ្រួសារនៅតំបន់ជនបទប៉ុណ្ណោះ ដែលបានទទួលថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ នៅពេលដែលប្រមាណជា ៧៥ ភាគរយ នៃគ្រួសារនៅតំបន់ទីប្រជុំជន បានទទួលថាមពលសម្រាប់ប្រើប្រាស់ ។

១៦៧. *ធនធានប្រេងកាតនិងឧស្ម័ន* កម្ពុជា គឺជាទ្រព្យសម្បត្តិរួមរបស់ប្រជាជនកម្ពុជាទាំងអស់គ្នា ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាបានខួងអណ្តូងស្វែងរកប្រេងកាតចំនួន ២៨កន្លែង ដែលស្ថិតនៅក្នុងដែនសមុទ្រកម្ពុជា ក្នុងគោលបំណងស្វែងរុករកសក្តានុពលប្រេងកាត និងឧស្ម័ន ។ នៅក្នុងឆ្នាំ២០០៤ កម្ពុជាបានរកឃើញប្រេងកាតនៅក្នុង *ប្លុកអា* នៃដែនសមុទ្រកម្ពុជា ។ ប៉ុន្តែ ការសិក្សាបន្ថែមទៀត ចាំបាច់ត្រូវធ្វើឡើង ដើម្បីធ្វើការវាយតម្លៃឱ្យមានភាពប្រាកដនិយម ទៅលើបរិមាណប្រេងកាត ដែលអាចទាញយកបានពីធនធានប្រេងកាតនៅក្រោមដី មុននឹងឈានទៅដល់ កិច្ចដំណើរការផលិតកម្មនិងអាជីវកម្ម លើធនធានប្រេងទាំងនោះ ។ *អាជ្ញាធរប្រេងកាតជាតិកម្ពុជា* គឺជាស្ថាប័នរដ្ឋ ដែលទទួលខុសត្រូវលើការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័ននៅកម្ពុជា ។ *រាជរដ្ឋាភិបាលកម្ពុជា* តាមរយៈអាជ្ញាធរនេះ បានចុះហត្ថលេខាជាមួយ ក្រុមហ៊ុនប្រេងកាត មកពីប្រទេសជាច្រើន ដើម្បីស្វែងរុករកប្រេងកាតនិងឧស្ម័ន នៅក្នុងប្លុកដែនសមុទ្រចំនួន ៦ និងក្នុងប្លុកដែនគោកចំនួន ២ ផ្សេងទៀត ។ ការស្វែងរុករកប្រេងកាតនៅកម្ពុជា កំពុងបន្តទៅមុខយ៉ាងសកម្ម តាមការគ្រោងទុកក្នុងកិច្ចព្រមព្រៀងប្រេងកាត ដែលបានចុះហត្ថលេខារួចហើយ ។ នៅពេលដែលធនធានប្រេងកាតនិងឧស្ម័ន ត្រូវបានរកឃើញថា មានបរិមាណគ្រប់គ្រាន់នោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ អាចនឹងត្រូវធ្វើឡើង មុននឹងឈានទៅ ដំណើរការផលិតកម្ម និងអាជីវកម្ម ប្រេងកាត ។ ផែនការរយៈពេលវែងមួយ ដែលមានលក្ខណៈទូលំទូលាយ នឹងត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្ន ដើម្បីធានាថាធនធានប្រេងកាតនិងឧស្ម័ន និងការទាញយកផលពីធនធានទាំងនេះ ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព សំដៅធ្វើឱ្យ ផលប្រយោជន៍ដែលបានមកពីធនធានទាំងនេះ មានកម្រិតខ្ពស់សមស្រប សម្រាប់ប្រជាជាតិកម្ពុជាទាំងមូល ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងទាញយកឱ្យបានជាអតិបរមា នូវចំណូលដែលទទួលបានពី ផលិតកម្មប្រេងកាត និងឧស្ម័ន ហើយ ក៏នឹងផ្តល់នូវអត្ថប្រយោជន៍សមហេតុផលផងដែរ ដល់វិនិយោគិន ។ ការងារជាអាទិភាព របស់ *អាជ្ញាធរប្រេងកាតជាតិកម្ពុជា* រួមមាន :

- ខិតខំប្រឹងប្រែងរកចំណូលឱ្យបានជាអតិបរមាជូនដល់ *រាជរដ្ឋាភិបាលកម្ពុជា* ។ បន្ទាប់ពីបានសិក្សាលើជម្រើសជាច្រើន *អាជ្ញាធរប្រេងកាតជាតិកម្ពុជា* និង *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បានធ្វើការពិចារណាយ៉ាងល្អិតល្អន់ទៅលើរបបសារពើពន្ធ និងកិច្ចព្រមព្រៀងប្រេងកាត ដែលមានតុល្យភាព និងយុត្តិធម៌ ដល់ វិនិយោគិនព្រមគ្នានឹងការរក្សានូវផលប្រយោជន៍របស់កម្ពុជា ។

- សិក្សាពីការចូលរួមរបស់ *កម្ពុជា* នៅក្នុង *ការផ្តួចផ្តើមគំនិតនៃតម្លាភាពក្នុងឧស្សាហកម្មទាញយកផល* ដែលជាមូលដ្ឋានមួយសម្រាប់អភិបាលកិច្ចល្អនៅក្នុងការប្រើប្រាស់ធនធានទាំងនេះ ។
- បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់រៀបចំផែនការសកម្មភាព និងតាមដានការអនុវត្ត ការងារកៀរគរ និងគ្រប់គ្រងចំណូលពីប្រេងកាត ឧស្ម័ន និងធនធានរ៉ែដទៃទៀត ។

## ៤.៤ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

១៦៨. បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ រួមបញ្ចូលនូវ ទូរស័ព្ទ និងប្រព័ន្ធទូរគមនាគមន៍ផ្សេងៗទៀត ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ដោយមានការកើនឡើងនៃការប្រកួតប្រជែង ដែលភាគច្រើនដឹកនាំដោយវិស័យឯកជន *កម្ពុជា* បានបោះជំហានទៅមុខយ៉ាងលឿន ក្នុងការប្រើប្រាស់ទូរស័ព្ទចល័ត ។ សមិទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមមួយចំនួន រួមមានដូចខាងក្រោម :

- បន្ទាប់ពីការបើកទូលាយវិស័យទូរគមនាគមន៍ ក្នុងខែមករា ឆ្នាំ២០០៦ មក វិនិយោគិនឯកជនកាន់តែច្រើនឡើង បានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍវិស័យនេះ ។ *ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* បាននិងកំពុងគ្រប់គ្រង គម្រោងការងារធំៗជាច្រើន ដែលមានទឹកប្រាក់ប្រមាណ ២៣៥,៨លានដុល្លារអាមេរិក ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាបអុបទិក សំដៅពង្រីកសេវាកម្មទូរគមនាគមន៍ នៅទូទាំងប្រទេស ។
- មកទល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ចំនួនទូរស័ព្ទសរុប ដែលកំពុងត្រូវបានប្រើប្រាស់ បានកើនឡើងដល់ ៤ ១៤៣ ៤១៧គ្រឿង (ដែលក្នុងនោះ ទូរស័ព្ទចល័តមានចំនួន ៤ ១០០ ០០០គ្រឿង និងទូរស័ព្ទអចល័ត មានចំនួន ៤៣ ៤១៧ គ្រឿង) ។ នៅក្នុងឆ្នាំ២០០៥ ទូរស័ព្ទអចល័ត និងចល័ត មានចំនួន ៨៨២ ០២០ គ្រឿង ។ កំណើនយ៉ាងលឿននៃចំនួនទូរស័ព្ទប្រើប្រាស់នេះ បានកើតមានឡើង ជាពិសេស នៅតំបន់ជនបទ ស្របពេលដែល អ៊ីម៉ែលនិងអ៊ិនធឺណែត ត្រូវបានប្រើប្រាស់កាន់តែច្រើនជាងមុន នៅទូទាំង២៤ រាជធានី-ខេត្ត និងក្រុង ។
- ចំនួនអ្នកចុះឈ្មោះប្រើប្រាស់អ៊ិនធឺណែត មាន ២០ ១០០នាក់ ក្នុងឆ្នាំ២០០៨ បើប្រៀបធៀបនឹងចំនួន នៅក្នុងឆ្នាំ២០០៥ ដែលមានតែ ៨ ៦៣០នាក់ ប៉ុណ្ណោះ ។
- ចំនួនទូរស័ព្ទអចល័តសាធារណៈ បានកើនឡើងពី ៤៣៩គ្រឿង ក្នុងឆ្នាំ២០០៥ ដល់ ៤៥៦គ្រឿង ក្នុងឆ្នាំ ២០០៨ ។
- ការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ និងអ៊ិនធឺណែត ក៏បានរីកសាយយ៉ាងលឿន ជាមួយនឹងការកើនឡើង យ៉ាងឆាប់រហ័សនៃចំណេះដឹងជំនាញក្នុងវិស័យនេះ នៅក្នុងចំណោមស្រទាប់យុវជន ផងដែរ ។
- ពីឆ្នាំ២០០៦ រហូតមកដល់ពេលបច្ចុប្បន្ននេះ សេវាកម្មវិស័យប្រៃសណីយ៍ ត្រូវបានធ្វើឱ្យប្រសើរឡើង ដូចជា (១) ការកាត់បន្ថយរយៈពេលចែកបញ្ញើ (២) ការដាក់ឱ្យដំណើរការនូវសេវាបញ្ញើឆាប់រហ័សនៅ

រាជធានី-ខេត្ត ទាំងអស់ (៣) ការពង្រីកសេវាកម្មប្រៃសណីយ៍ទៅដល់តំបន់ទីប្រជុំជនសំខាន់ៗ (៤) ការបង្កើតប្រព័ន្ធគ្រប់គ្រង-តាមដានត្រួតពិនិត្យបញ្ញើ ដោយប្រើប្រាស់ប្រព័ន្ធ អាយភីអេស (IPS) ចំពោះបញ្ញើប្រៃសណីយ៍ឆាប់រហ័ស ប្រៃសណីយភ័ណ្ឌ និងបញ្ញើអនុសិដ្ឋ ជាដើម ។

- *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្ត *ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល* និង *រដ្ឋាភិបាល-អេឡិចត្រូនិក* ។
- *ក្រសួងព័ត៌មាន* បានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់និងពង្រីកការគ្របដណ្ដប់ ប្រសិទ្ធភាព និងគុណភាព របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (វិទ្យុ ទូរទស្សន៍ និងភ្នាក់ងារសារព័ត៌មាន) ។ នៅពេលបច្ចុប្បន្ននេះ ប្រមាណ ៨០ភាគរយនៃប្រជាជនកម្ពុជា អាចទទួលបាននូវព័ត៌មាន ការអប់រំ និងការកម្សាន្ត តាមរយៈ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានស្រាប់ ទាំងរបស់រដ្ឋនិងឯកជន ដែលតាមរយៈនេះ អាចជួយលើកតម្កើងអត្តសញ្ញាណជាតិ និងសាមគ្គីភាពជាតិ ។
- បញ្ហាប្រឈមចម្បងនៅក្នុងវិស័យនេះ រួមមាន : (១) ប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យទូរគមនាគមន៍ នៅមានកម្រិត ដោយសារ *ច្បាប់ស្ដីពីទូរគមនាគមន៍* ពុំទាន់បានអនុម័តពីរដ្ឋសភានៅឡើយ (២) សេវាមាត់ច្រកទូរគមនាគមន៍អន្តរជាតិខុសច្បាប់ នៅតែបន្តកើតមាន ទោះបីជា មានកិច្ចខិតខំប្រឹងប្រែងលុបបំបាត់ពី *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍* ក៏ដោយ ដែលជាហេតុនាំឱ្យមានផលប៉ះពាល់ដល់សេវាកម្មមាត់ច្រកអន្តរជាតិ និងចំណូលរដ្ឋ (៣) កិច្ចសហការរវាង *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍* និងប្រតិបត្តិករ-ភ្នាក់ងារអភិវឌ្ឍន៍ នៅពុំទាន់មានភាពល្អប្រសើរនៅឡើយ (៤) តម្លៃប្រើប្រាស់សេវាអ៊ិនធឺណែត នៅតែមានតម្លៃខ្ពស់នៅឡើយ (៥) សេវាប្រៃសណីយ៍ របស់ក្រុមហ៊ុនឯកជន មានលក្ខណៈប្រកួតប្រជែងខ្លាំងជាងសេវាប្រៃសណីយ៍របស់រដ្ឋ ហើយ សមត្ថភាពធនធានមនុស្សក្នុងវិស័យប្រៃសណីយ៍ នៅមានកម្រិតនៅឡើយ ។

## ៥. ការអភិវឌ្ឍវិស័យឯកជននិងការងារ

១៦៩. *រាជរដ្ឋាភិបាលកម្ពុជា* បានទទួលស្គាល់និងឯកភាពលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់ សម្រាប់ការវិនិយោគនិងកំណើនក្នុងប្រទេស ។ តួនាទីរបស់ *រាជរដ្ឋាភិបាល* គឺជាអ្នកជំរុញ អ្នកលើកទឹកចិត្ត អ្នកជួយបង្កលក្ខណៈ អ្នកជួយសម្របសម្រួល និងជានិយ័តករ ។ កម្រិតដ៏ធំនៃការវិនិយោគ គឺជាតម្រូវការចាំបាច់ ក្នុងពីរ-បីឆ្នាំខាងមុខ ដើម្បីថែរក្សា និងបង្កើនល្បឿនសន្ទុះនៃកំណើនសេដ្ឋកិច្ច ដែលត្រូវផ្អែកលើមូលដ្ឋានច្រើន ។ ផ្នែកឯកជនដែលមានកំណើនដ៏រឹងមាំ បំពេញបន្ថែមវិនិយោគសាធារណៈក្នុងវិស័យសង្គមកិច្ច ស្រូបយកអ្នកចូលរួមក្នុងកម្លាំងពលកម្មដែលចេះតែកើនឡើង និងបង្កើតជំនាញផ្សេងៗ ជាច្រើន ។ មុំទាំង៤ នៃចតុកោណនេះគឺ *(១) ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (រួមមាន វិស័យកាត់ដេរសម្លៀកបំពាក់ និងទេសចរណ៍) (២) ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរ ជូនដល់កម្មករនិងនិយោជិត (៣) ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និង (៤) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់មន្ត្រីបុគ្គលិក*

*កម្មករ* ។ *រាជរដ្ឋាភិបាលកម្ពុជា* បានកាត់បន្ថយចំណាយក្នុងការធ្វើធុរកិច្ច បានពង្រីកលទ្ធភាពប្រើប្រាស់ទីផ្សារ បានកាត់បន្ថយចំណាយក្នុងការដឹកជញ្ជូនក្នុងស្រុក ហើយបានលើកកម្ពស់សុវត្ថិភាព តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដែលជំរុញឱ្យមានផងដែរ នូវការបញ្ចូលគ្នារវាងសេដ្ឋកិច្ចទីប្រជុំជននិងសេដ្ឋកិច្ចជនបទ ។ វឌ្ឍនភាពដែលធ្វើឱ្យកើតមានឡើងមកទល់ពេលនេះ ដើម្បីឈានទៅសម្រេចបានអាទិភាពទាំងនេះ បានចូលរួមចំណែកយ៉ាងធំធេង ចំពោះការអភិវឌ្ឍថ្មីៗក្នុងវិស័យជាច្រើនផ្សេងទៀត និងចំពោះការពង្រឹងស្ថានភាព សេដ្ឋកិច្ចសង្គមកិច្ច របស់ប្រជាជនជនបទ ជាពិសេស អ្នកក្រីក្រ ។

## ៥.១ ការពង្រឹងវិស័យឯកជន និង ការទាក់ទាញការវិនិយោគ

១៧០. ការវិនិយោគក្នុង*វិស័យឯកជន* បាននិងកំពុង មានការកើនឡើងយ៉ាងឆាប់រហ័ស ដែលអាចពិនិត្យឃើញនៅក្នុងសូចនាករម៉ាក្រូសេដ្ឋកិច្ចនិងរូបិយវត្ថុ ដោយតាមរយៈនេះ បានបង្កើនការជឿជាក់ និងភាពកក់ក្ដៅ ក្នុងចំណោមអ្នកវិនិយោគឯកជនជាតិ និងអន្តរជាតិ នានា ក្នុងសេដ្ឋកិច្ចកម្ពុជា ។ ប្រការនេះ គឺជា ភស្តុតាងដ៏ធំនៃជោគជ័យរបស់គោលនយោបាយ ដែលជួយជំរុញឱ្យមានលទ្ធផលវិជ្ជមាន និងដែលមានលក្ខណៈជឿនលឿនរបស់*រាជរដ្ឋាភិបាលកម្ពុជា* (ការធានាឱ្យមានសន្តិភាព ស្ថិរភាពគោលនយោបាយ ច្បាប់និងសណ្ដាប់ធ្នាប់ ការគ្រប់គ្រងដោយច្បាប់ កំណើនម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុ និងការបង្កើតនូវបរិយាកាសអំណោយផលមួយសម្រាប់ការអភិវឌ្ឍវិស័យឯកជន ។ *រាជរដ្ឋាភិបាលកម្ពុជា* បានជំរុញយុទ្ធសាស្ត្រកំណើន ដែលនាំមុខដោយការនាំចេញ និង ដែលសម្រាប់គាំទ្រប្រជាជនក្រីក្រ ដោយផ្ដោតលើ ការធ្វើពិពិធកម្ម និងការពង្រីកឱ្យបានទូលំទូលាយនូវមូលដ្ឋានសេដ្ឋកិច្ច ហើយ បានលើកទឹកចិត្ត ជួយសម្រួល និងផ្ដល់ការគាំទ្រដល់ ការវិនិយោគរបស់វិស័យឯកជនក្នុងវិស័យអាទិភាពមួយចំនួន ។

១៧១. វេទិកាពិភាក្សា រវាងផ្នែកឯកជន និង*រាជរដ្ឋាភិបាលកម្ពុជា* ហៅថា *វេទិការាជរដ្ឋាភិបាល-វិស័យឯកជន* ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលប្រារព្ធធ្វើឡើង ជារៀងរាល់ ៦ខែម្ដង និងការងាររបស់*គណៈកម្មាធិការ ពិគ្រោះយោបល់* និងគណៈកម្មាធិការផ្សេងៗទៀត បានផ្ដល់នូវយុត្តាធិការយ៉ាងសំខាន់ សម្រាប់កិច្ចសហប្រតិបត្តិការដ៏មានអត្ថន័យ និង ការយល់ដឹងគ្នាទៅវិញទៅមក រវាង *រាជរដ្ឋាភិបាលកម្ពុជា* និងវិស័យឯកជន ។ ក្រុមការងារមួយផ្សេងទៀត សម្រាប់ធ្វើឱ្យប្រសើរឡើងនូវ ទំនាក់ទំនងរវាង និយោជិត និងនិយោជក ត្រូវបានរៀបចំឡើង ។ ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និង ការពង្រឹងនិងការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ត្រូវបានបញ្ចូលក្នុងវិស័យអាទិភាពសម្រាប់ពិចារណាផងដែរ ។

១៧២. ដើម្បីកាត់បន្ថយនូវរបាំង ក្នុងការស្វែងរកសេចក្ដីអនុម័តនានា ពីបណ្ដាក្រសួង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ *រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើតនូវយន្តការ *ច្រកចេញ-ចូលតែមួយ* ដែលអនុញ្ញាតឱ្យបណ្ដាអ្នកវិនិយោគ អាចទទួល

បានការអនុម័តជាកញ្ចប់ ក្នុងការស្នើសុំការវិនិយោគ ។ *គណៈកម្មការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* ជាអ្នកគ្រប់គ្រងលើ ការអនុវត្តយន្តការ *ច្រកចេញ-ចូលតែមួយ* នេះ ។ ក្នុងស្មារតីកាត់បន្ថយពេលវេលាសម្រាប់ការអនុម័តលើការស្នើសុំការវិនិយោគ និង បង្កលក្ខណៈឱ្យកាន់តែងាយស្រួលថែមទៀត ដល់អ្នកវិនិយោគ *រាជរដ្ឋាភិបាលកម្ពុជា* បានសម្រេចផ្តល់សិទ្ធិជូន អនុគណៈកម្មការ រាជធានី-ខេត្ត ពិនិត្យសម្រេច លើគម្រោងវិនិយោគនានា ដែលមានទុនវិនិយោគ តិចជាង ២លានដុល្លារអាមេរិក ។

១៧៣. *គណៈកម្មការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* បានបង្កើតនូវយន្តការ *"ការយកចិត្តទុកដាក់ចំពោះវិនិយោគិន"* និង *"ប្រព័ន្ធតាមដាននិងត្រួតពិនិត្យការវិនិយោគ"* ដើម្បីដោះស្រាយបញ្ហាប្រឈមនានា របស់វិនិយោគិន និង ដើម្បីតាមដានពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនានា ដែលទទួលបានការអនុម័តរួចហើយ ។ *រាជរដ្ឋាភិបាលកម្ពុជា* ប្តេជ្ញាធានានូវ តម្លាភាព គណនេយ្យភាព និង ប្រសិទ្ធភាព ក្នុងការផ្តល់នូវសេវាកម្មទាំងឡាយ ដល់វិនិយោគិន ។ ទន្ទឹមនេះដែរ អាទិភាពចម្បងមួយ របស់*រាជរដ្ឋាភិបាល* គឺ បន្តធ្វើឱ្យមានប្រសិទ្ធភាព និង ធ្វើឱ្យប្រសើរឡើង ក្នុងការផ្តល់សេវាកម្មដល់វិនិយោគិន តាមរយៈ ការពង្រឹងសមត្ថភាពបច្ចេកទេសរបស់មន្ត្រី ជាពិសេស មន្ត្រីថ្នាក់មធ្យម នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

១៧៤. *រាជរដ្ឋាភិបាល* បានចុះហត្ថលេខាទ្វេភាគី លើកិច្ចព្រមព្រៀងស្តីពី ការជំរុញនិងការការពារ ការវិនិយោគចំនួន ២៤ និង កំពុងបន្តការចរចាជាបន្តបន្ទាប់ទៀត ជាមួយបណ្តាប្រទេសផ្សេងៗ ក្នុងក្របខ័ណ្ឌ *អាស៊ាន អេប៊ិក សហរដ្ឋអាមេរិក អ៊ឺរ៉ុប និង តំបន់មជ្ឈឹមបូពា៌* ដើម្បីជំរុញការអភិវឌ្ឍវិស័យឯកជន ឱ្យបានទូលំទូលាយជាងមុន និងកិច្ចព្រមព្រៀង ចំនួន ១៧ផ្សេងទៀត ជាមួយ បណ្តាប្រទេសក្នុង*តំបន់មជ្ឈឹមបូពា៌ អាស៊ីខាងកើត និងអ៊ឺរ៉ុប* ។

១៧៥. *ក្រសួងពាណិជ្ជកម្ម* កំពុងបន្តធ្វើការងារលើ ការធ្វើឱ្យមានប្រសិទ្ធភាពនូវដំណាក់កាលសម្រាប់ ការចុះបញ្ជីពាណិជ្ជកម្ម ការផ្តល់ព័ត៌មានទីផ្សារ ការរៀបចំសហគមន៍ផលិតផល ការអនុវត្តកម្មវិធីរោងចក្រល្អប្រសើរ ការសម្របសម្រួលនិងជំរុញពាណិជ្ជកម្ម និង ការពង្រឹងឡើងវិញនូវ*ច្បាប់កម្មសិទ្ធិបញ្ញា* ទាំងឡាយ ។ ដូច្នេះ ដើម្បីសម្រួលដល់ការចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងខែកញ្ញា ឆ្នាំ២០០៧ *ក្រសួងពាណិជ្ជកម្ម* បានបង្កើតការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៅតាមសាខាថ្នាក់ខេត្ត ដូចជា សាខា*ខេត្តបាត់ដំបង* ជាដើម សម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្មដល់ *ខេត្តបាត់ដំបង* ផ្ទាល់ *ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន* និង *ខេត្តបន្ទាយមានជ័យ* ។ ទន្ទឹមនេះ ក្រសួងពាណិជ្ជកម្មនៅមានផែនការក្នុងការបើកការិយាល័យចុះបញ្ជីពាណិជ្ជកម្មបន្ថែមទៀត នៅក្នុងខេត្តមួយចំនួនទៀត ដូចជា :

- ក្នុងឆ្នាំ២០១០ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយ នឹងត្រូវបង្កើតក្នុងសាខាខេត្តព្រះសីហនុ សម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្ម ក្នុង *ខេត្តព្រះសីហនុ* ផ្ទាល់ *ខេត្តតាកែវ ខេត្តកំពត* និង *ខេត្តកោះកុង* ។
- ក្នុងឆ្នាំដដែលនេះដែរ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយ នឹងត្រូវបង្កើតក្នុងសាខា*ខេត្តក្រចេះ* សម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្ម *ខេត្តក្រចេះ* ផ្ទាល់ *ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី* និង *ខេត្តរតនគីរី* ។

- នៅក្នុងឆ្នាំ២០១២ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយ នឹងត្រូវបង្កើតក្នុងសាខា*ខេត្តសៀមរាប* សម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្មដល់ *ខេត្តសៀមរាប* ផ្ទាល់ និង *ឧត្តរមានជ័យ* ។
- ដោយឡែក សម្រាប់ឆ្នាំ២០១៣ *ក្រសួងពាណិជ្ជកម្ម* នឹងរៀបចំប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្តល់ការងាយស្រួលក្នុងការចុះបញ្ជីពាណិជ្ជកម្ម ។

១៧៦. រហូតមកដល់ពេលបច្ចុប្បន្ន *ក្រសួងពាណិជ្ជកម្ម* បានផ្តល់ព័ត៌មានទីផ្សារពាណិជ្ជកម្ម តាមរយៈ ព្រឹត្តិបត្រ និងទូរទស្សន៍ តែប៉ុណ្ណោះ ។ ដូច្នេះ ក្នុងឆ្នាំ២០០៨ ដើម្បីជំរុញការលើកកម្ពស់ព័ត៌មានទីផ្សារពាណិជ្ជកម្ម *ក្រសួង* បានរៀបចំ *ប្រព័ន្ធទំនាក់ទំនងទីផ្សារអេឡិចត្រូនិក* ដែលនឹងសង្ឃឹមថា អាចផ្តល់នូវព័ត៌មានលឿន និងប្រសើរជាងមុន ។ គ្រប់ព័ត៌មានដែលមានក្នុង*ប្រព័ន្ធទំនាក់ទំនងទីផ្សារអេឡិចត្រូនិក* អាចទទួលបាន តាមរយៈ ការប្រើប្រាស់ជាមួយនឹងទូរស័ព្ទចល័ត ដូចជា ព័ត៌មានអំពីតម្លៃកសិផល ផលិតផលម្ហូបអាហារ អត្រាប្តូរប្រាក់ និងតម្រូវការផ្សេងៗរបស់ទីផ្សារ ។

១៧៧. *ក្រសួងពាណិជ្ជកម្ម* ក៏បានផ្តល់ជំនួយផងដែរ ក្នុងការរៀបចំសមាគមអាជីវកម្ម ដើម្បីលើកកម្ពស់សមត្ថភាពផលិតកម្ម និងដើម្បីធ្វើសមាហរណកម្មផលិតផលទំនិញ ចូលទៅក្នុង ទីផ្សារក្នុងស្រុក ទីផ្សារផលិតផលពិសេស និង ទីផ្សារពិភពលោក ។ ជាក់ស្តែង រវាងឆ្នាំ២០០៧-២០០៩ *ក្រសួង* បានជួយរៀបចំសមាគមអាជីវកម្មក្នុងនោះរួមមាន *សមាគមអភិវឌ្ឍន៍ម្រេច សមាគមអភិវឌ្ឍន៍ស្ករត្នោត សមាគមអភិវឌ្ឍន៍កសិកម្មតំបន់ពាយ័ព្យ និងសមាគមអភិវឌ្ឍន៍ប្រហុកអប់នៅកំពង់ឃ្លាំង* ។ បច្ចុប្បន្ននេះ *ក្រសួង* កំពុងជួយរៀបចំ *សមាគមអាជីវកម្មស្វាយចន្ទី* នៅ *ខេត្តកំពង់ចាម និង ខេត្តកំពង់ធំ* ថែមទៀតផង ។ ដូច្នេះ ការរៀបចំសមាគមអាជីវកម្ម អាចជួយប្រែក្លាយពី ការធ្វើពាណិជ្ជកម្មគ្រួសារ ឱ្យទៅជា ការធ្វើពាណិជ្ជកម្មដោយមានយុទ្ធសាស្ត្រសម្រាប់ទីផ្សារដែលមានចីរភាព និងមានសមត្ថភាពប្រកួតប្រជែងខ្ពស់ ក្នុងទីផ្សារពិភពលោក ។

១៧៨. ដើម្បីសម្រួលដល់ការជំរុញពាណិជ្ជកម្ម *ក្រសួងពាណិជ្ជកម្ម* បានអនុវត្តយ៉ាងសកម្ម នូវ*អនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈ ការគ្រប់គ្រងហានិភ័យ* ដែលត្រូវបានអនុម័ត ក្នុងខែមីនា ឆ្នាំ២០០៦ និងអនុវត្ត*មូលនិធិបើកច្រកទីផ្សារនាំចេញ* ដែលគាំទ្រដោយ *ធនាគារពិភពលោក* ។ ដោយឡែក *ក្រសួង* បានរៀបចំ "*ពិពណ៌ពាណិជ្ជកម្ម*" និងបានរៀបចំកិច្ចប្រជុំជំនួញពាណិជ្ជកម្ម ជាច្រើនលើកច្រើនសារ ជាមួយដៃគូបរទេស ដើម្បីជំរុញឱ្យអាជីវកម្មក្នុងស្រុក ដាក់តាំងបង្ហាញនូវផលិតផលរបស់ខ្លួន ក្នុងន័យរកដំណោះស្រាយនូវការរាំងស្ទះផលិតផល និងសម្រួលដល់លំហូរទំនិញ ទៅកាន់ទីផ្សារបរទេស ។

១៧៩. ដើម្បីពង្រឹងវិស័យឯកជន សម្រាប់ការអភិវឌ្ឍពាណិជ្ជកម្មនិងសេដ្ឋកិច្ច និង ការជំរុញសកម្មភាពពាណិជ្ជកម្មក្នុងស្រុក *ក្រសួងពាណិជ្ជកម្ម* បានរៀបចំបង្កើត*សភាពាណិជ្ជកម្មខេត្ត* បានចំនួន ១១ ចាប់ពីឆ្នាំ២០០៦ ដល់ ឆ្នាំ

២០០៧ ដែលមានទីតាំង នៅក្នុងខេត្ត *បាត់ដំបង សៀមរាប ពោធិសាត់ បន្ទាយមានជ័យ កណ្ដាល តាកែវ កំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ* និង *កំពង់ចាម* ។ នៅឆ្នាំ២០០៨ *សភាពាណិជ្ជកម្មកម្ពុជា* មានតួនាទី ធ្វើជាតំណាងឱ្យវិស័យឯកជនកម្ពុជាក្នុង ការចរចាអំពីការធ្វើពាណិជ្ជកម្ម និងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា ។ ដោយឡែក *សភាពាណិជ្ជកម្មរាជធានីភ្នំពេញ* ដែលបានបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៩៥ មក កំពុងមានតួនាទីដ៏សំខាន់ ជួយដល់ការបណ្ដុះបណ្ដាល និងការជួយជ្រោមជ្រែង ដល់ *សភាពាណិជ្ជកម្មខេត្ត* ផ្សេងៗទៀត ឱ្យដំណើរការបានល្អប្រសើរ ។

១៨០. *ក្រសួងពាណិជ្ជកម្ម* ក៏បានខិតខំផងដែរ ក្នុងការពង្រឹងការអនុវត្ត*ច្បាប់កម្មសិទ្ធិបញ្ញា* ដើម្បីទប់ស្កាត់ ការផលិត ការនាំចូល និងការចែកចាយ ផលិតផលក្លែងក្លាយ ។ មន្ត្រី*កាំកុងត្រូល* បានធ្វើការត្រួតពិនិត្យជាប្រចាំ តាមច្រកចេញ-ចូល ដើម្បីទប់ស្កាត់ឱ្យបានទាន់ពេលវេលា រាល់ចរាចរណ៍ ទិញ-លក់ ទំនិញខូចគុណភាព ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកប្រើប្រាស់ ។

១៨១. ដើម្បីរក្សាការប្រកួតប្រជែងវិស័យកាត់ដេរសម្លៀកបំពាក់ ក្នុងទីផ្សារអន្តរជាតិ *ក្រសួងពាណិជ្ជកម្ម* ដោយមានកិច្ចសហការជាមួយ *ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ* បាននិងកំពុងអនុវត្តកម្មវិធី *"រោងចក្រល្អប្រសើរជាងមុន"* ដើម្បីធានាលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរជាងមុន ស្របតាមស្តង់ដារអន្តរជាតិ ក៏ដូចជាផ្ដល់ការអប់រំបណ្ដុះបណ្ដាលកម្មករនិងសហជីព អំពី *ច្បាប់ស្ដីពីការងារ* ដោយផ្សារភ្ជាប់នឹងលក្ខខណ្ឌពាណិជ្ជកម្ម ហើយ លើកទឹកចិត្តឱ្យមានការកែច្នៃម៉ូត ដើម្បីជំរុញការផលិតទំនិញកែច្នៃនៅប្រទេស*កម្ពុជា* ។

១៨២. ដើម្បីជំរុញការធ្វើសមាហរណកម្មក្នុងតំបន់ ក្នុងឆ្នាំ២០០៨ *គណៈកម្មការគ្រប់គ្រងផ្សារតំរូព្រំដែន កម្ពុជា-វៀតណាម* បានរៀបចំអភិវឌ្ឍន៍ប្លង់មេ សាងសង់ផ្សារតាមព្រំដែន*កម្ពុជា-វៀតណាម* នៅ*មេមត់* និង រៀបចំចុះកិច្ចព្រមព្រៀងអនុគ្រោះពន្ធគយ លើ ការនាំចេញផលិតផលកសិផលរបស់ *កម្ពុជា* ទៅលើទីផ្សារ *វៀតណាម* ។

១៨៣. *ក្រសួងពាណិជ្ជកម្ម* បានកត់សម្គាល់នូវបញ្ហាប្រឈមមួយចំនួន លើការនាំចេញកសិផលរបស់កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ ។ បញ្ហាទាំងនោះ មានដូចជា :

- ទំនិញភាគច្រើនមិនអាចឆ្លើយតបបានតាមស្តង់ដាររបស់អ្នកបញ្ជាទិញ ដោយហេតុថា ម៉ាស៊ីនកែច្នៃជាពិសេស ម៉ាស៊ីនកិនអង្ករភាគច្រើន ជាម៉ាស៊ីនចាស់ៗ មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ នាពេលបច្ចុប្បន្ន មានម៉ាស៊ីនកែច្នៃអង្ករតាមស្តង់ដារចំនួន ២ ប៉ុណ្ណោះ ដែលមានសមត្ថភាពអាចកែច្នៃបានពី ១២ ០០០ តោន ទៅ ១៥ ០០០ តោន ក្នុងមួយឆ្នាំ ។

- ថ្លៃដើមរបស់ទំនិញខ្ពស់ ដោយបណ្តាលមកពី ការចំណាយផ្លូវការនិងក្រៅផ្លូវការខ្ពស់ រួមមាន តម្លៃនៃការដឹកជញ្ជូនខ្ពស់ ដែលមកពីតម្លៃខ្ពស់របស់ប្រេងនិងថាមពល និងការចំណាយក្រៅផ្លូវការជាច្រើនដំណាក់ ។
- ផលិតផល និងទំនិញភាគច្រើន មិនស្របតាមស្តង់ដារ អនាម័យ និងភូតគាម ដែលផ្តល់ជាលក្ខខណ្ឌដំបូង សម្រាប់ការនាំទំនិញពីប្រទេសកម្ពុជា ទៅកាន់បណ្តាប្រទេសផ្សេងៗ ។

១៨៤. *ច្បាប់ពាណិជ្ជកម្ម* ដូចដែលមានរៀបរាប់ខាងក្រោម ត្រូវបានបង្កើតឡើង និងកំពុងត្រូវបានអនុវត្តដោយ *ក្រសួងពាណិជ្ជកម្ម* ដើម្បីទទួលបាននូវទំនុកចិត្តពីអ្នកវិនិយោគ និងសហគមន៍ពាណិជ្ជកម្ម :

- *ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម* ។
- *ច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា* ។
- *ច្បាប់ស្តីពី ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់* ។
- *ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម* ។
- *ច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម* ។
- *ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា* ។
- *ច្បាប់ ស្តីពីក្ស័យធន* ។

១៨៥. ការវិនិយោគវិស័យឯកជន ដែលមានប្រភពមកពីបរទេសនិងក្នុងស្រុក បានក្លាយទៅជាយានដ៏សំខាន់មួយនៃនិរន្តរភាពអត្រាខ្ពស់នៃកំណើនសេដ្ឋកិច្ច ដែលសម្រេចបាននាចុងទសវត្សរ៍នេះ ។ វិស័យសេដ្ឋកិច្ច ដែលភាគច្រើន ទទួលបានមកពីការវិនិយោគឯកជនទាំងអស់នេះ រួមមាន : វិស័យទេសចរណ៍ វិស័យកាត់ដេរ វិស័យសំណង់ និងការរុករកប្រេង ឧស្ម័ន និងធនធានរ៉ែ នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ ។ ម្យ៉ាងវិញទៀត វិបត្តិហិរញ្ញវត្ថុសាកលលោក និងការធ្លាក់ចុះនៃសេដ្ឋកិច្ច ដែលបានចាប់ផ្តើមឡើង នៅចុងឆ្នាំ២០០៧ បានបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ មិនត្រឹមតែលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសប៉ុណ្ណោះទេ ថែមទាំងការវិនិយោគវិស័យឯកជនក្នុងស្រុក ផងដែរ ។ រាជរដ្ឋាភិបាល កំពុងអនុវត្ត កញ្ចប់ជំរុញសារពើពន្ធមួយ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចពិត ក៏ដូចជា ការចាត់វិធានការ ដើម្បីជួយសម្រាលនូវផលប៉ះពាល់អវិជ្ជមាន នៃវិបត្តិទាំងឡាយនេះ មកលើប្រជាជនក្រីក្រ និង ជនងាយរងគ្រោះ ។ *រាជរដ្ឋាភិបាលកម្ពុជា* បន្តបង្កើត នូវបរិយាកាសមួយដែលជួយជំរុញនិងលើកទឹកចិត្តដល់ ការវិនិយោគក្នុងស្រុកនិងការវិនិយោគបរទេស នៅក្នុង គ្រប់វិស័យអាទិភាពដើម្បីពង្រីកនិងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ។ ការរំលេចឡើងនូវការងារ និងបញ្ហាប្រឈមទាំងឡាយ ដែលបានកើតមាននៅក្នុង វិស័យអាទិភាពនានាដែលបានទាក់ទាញការវិនិយោគក្នុងស្រុកនិងបរទេសក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ត្រូវបានសង្ខេប ដូចខាងក្រោម ។

១៨៦. **វិស័យទេសចរណ៍ :** ទេសចរណ៍ គឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលបានរួមចំណែកក្នុង ការកសាងសេដ្ឋកិច្ចនិងសង្គមកិច្ច ការបង្កើតឱកាសការងារនិងប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ជាពិសេស រួមចំណែកក្នុង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និង ការជំរុញការអភិវឌ្ឍ *សេដ្ឋកិច្ចបៃតង* ។ ទេសចរណ៍នៅកម្ពុជា ជាទេសចរណ៍ "*វប្បធម៌និងធម្មជាតិ* " ដែលបានរួមចំណែកយ៉ាងសកម្ម ក្នុង ការអភិវឌ្ឍ ការថែរក្សាការពារ និង ការអភិរក្សសម្បត្តិវប្បធម៌-ប្រវត្តិសាស្ត្រ និង ធនធានធម្មជាតិ ក៏ដូចជា ការប្រើប្រាស់សក្តានុពលនៃធនធានទាំងនេះ ប្រកបដោយនិរន្តរភាព។ សមិទ្ធផលសំខាន់ៗ មួយចំនួន ដែលបានគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ រួមមាន :

- គោលនយោបាយបើកចំហជើងមេឃរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដើម្បីបង្កលក្ខណៈងាយស្រួល និងជំរុញលើកទឹកចិត្តភ្ញៀវទេសចរឱ្យធ្វើដំណើរតាមផ្លូវអាកាស បានជួយជំរុញឱ្យមានការកែលម្អអាកាសយានដ្ឋានឱ្យកាន់តែមានភាពប្រសើរឡើង ហើយ បច្ចុប្បន្ននេះ អាកាសយានដ្ឋានខេត្តព្រះសីហនុត្រូវបានដាក់ឱ្យដំណើរការហោះហើរ ។ ក្នុងឆ្នាំ២០០៩ ក្រុមហ៊ុនអាកាសចរណ៍ជាតិមួយ ត្រូវបានបង្កើតឡើង ហើយបាន ចាប់ផ្តើមដំណើរការជើងហោះហើររបស់ខ្លួន រវាងទីក្រុងភ្នំពេញ និង ខេត្តសៀមរាប ។
- ការផ្តល់ទិដ្ឋាការ ត្រូវបានបង្កឱ្យមានលក្ខណៈងាយស្រួល នៅគ្រប់ច្រកទ្វារអន្តរជាតិទាំងអស់ ។ ទិដ្ឋាការត្រូវបានផ្តល់ជូនភ្ញៀវទេសចរ នៅពេលមកដល់ ជាពិសេស ទិដ្ឋាការអេឡិចត្រូនិក ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ផងដែរ ។ នៅក្នុងក្របខ័ណ្ឌ *អាស៊ាន រាជរដ្ឋាភិបាលកម្ពុជា* បានចុះកិច្ចព្រមព្រៀងជាមួយ *ប្រទេសសិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឡាវ និង ប្រទេសវៀតណាម* ក្នុងការលើកលែងទិដ្ឋាការចំពោះប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋប្រទេសទាំង៥ នេះ។ ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច *អាយ៉េយ៉ាវ៉ាឌី-ចាវប្រាយ៉ា-មេគង្គ* កិច្ចព្រមព្រៀងមួយ ត្រូវបានចុះហត្ថលេខា សម្រាប់ការប្រើប្រាស់ទិដ្ឋាការទោល សម្រាប់ពលរដ្ឋនៃប្រទេសទី៣ ដែលធ្វើដំណើរ មកប្រទេសកម្ពុជា និង ទៅប្រទេសថៃ ។ បញ្ជរព័ត៌មានទេសចរណ៍ ត្រូវបានរៀបចំបង្កើតឡើង នៅរាជធានីនិងខេត្តចំនួន១៣ ជាពិសេស ខេត្តដែលមានច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីផ្តល់ព័ត៌មានជូនភ្ញៀវទេសចរ ក៏ដូចជា ការផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍នៅកម្ពុជា ។ *ក្រសួងទេសចរណ៍* បានចុះហត្ថលេខា លើអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ ជាមួយ *រដ្ឋគូវ៉ែត* ដើម្បីទាក់ទាញ ភ្ញៀវទេសចរ និងអ្នកវិនិយោគរបស់ *រដ្ឋគូវ៉ែត* ។
- សកម្មភាពប្រឆាំងនឹងទេសចរណ៍ផ្លូវភេទកុមារ កំពុងត្រូវបានតាមដានត្រួតពិនិត្យ ហើយវិធានការជាច្រើនកំពុងត្រូវបានអនុវត្តប្រឆាំងនឹងជនល្មើស ដោយ *គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍* របស់ *ក្រសួងទេសចរណ៍* ដោយមានកិច្ចសហការល្អជាមួយ ក្រសួង-ស្ថាប័ន អង្គការជាតិ និង អង្គការអន្តរជាតិពាក់ព័ន្ធនានា ។ បច្ចុប្បន្ននេះ សម្ភារៈផ្សព្វផ្សាយអំពីទេសចរណ៍ជាច្រើន ត្រូវបានផលិត ដូចជា

វីដេអូខ្លីៗ កម្មវិធីអប់រំតាមវិទ្យុ រូបភាពបិទផ្សព្វផ្សាយ បណ្ណផ្ទត់ ផ្ទាំងរូបភាពតូច-ធំ សារព័ត៌មាន និង ទស្សនាវដ្ដី ក្នុងគោលបំណង អប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពកុមារក្នុងវិស័យ ទេសចរណ៍ និង ធានាឱ្យមានសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

- វិស័យទេសចរណ៍នៅកម្ពុជា ធ្លាប់មានកំណើនខ្ពស់លើសពី ២០ ភាគរយ នៅចន្លោះពី ឆ្នាំ២០០០-២០០៧ និង មានការកើនឡើង ៥,៥ ភាគរយ នៅឆ្នាំ២០០៨ ។

១៨៧. ទោះជាយ៉ាងណាក៏ដោយ ក៏ការអភិវឌ្ឍវិស័យទេសចរណ៍ នៅកម្ពុជា ជួបបញ្ហាប្រឈមជាច្រើន ដូចជាៈ

- កញ្ចប់ទស្សនកិច្ចនៅកម្ពុជា មានថ្លៃខ្ពស់ ។
- ការប្រកួតប្រជែងក្នុងទីផ្សារសេវាទេសចរណ៍ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ (ឧ. សេវាស្នាក់នៅ មធ្យោបាយធ្វើដំណើរ ការឃោសនាផ្សព្វផ្សាយទេសចរណ៍ ជាដើម) ។
- គុណភាពរបស់ រមណីយដ្ឋាន សម្បទា និងសេវាកម្មទេសចរណ៍ មួយចំនួន ពុំទាន់មានលក្ខណៈស្តង់ដារ សមស្របតាមតម្រូវការ នៅឡើយ ដែលទាមទារឱ្យមានការកែលម្អ។
- ការអភិវឌ្ឍទេសចរណ៍ ត្រូវបានផ្តោតការយកចិត្តទុកដាក់ តែនៅតំបន់ទីប្រជុំជន ដែលជាហេតុធ្វើឱ្យ ប្រជាជនក្រីក្រ ដែលរស់នៅតំបន់ដាច់ស្រយាល ពុំបានទទួលផលប្រយោជន៍ ពីការអភិវឌ្ឍនេះ។
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ជាពិសេស ផ្លូវថ្នល់ ការផ្គត់ផ្គង់ អគ្គិសនីនិងទឹកស្អាត និង ប្រព័ន្ធគ្រប់គ្រងកាក សំណល់រឹងនិងរាវ) ដែលចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ពុំទាន់មានលក្ខណៈសមស្រប នៅឡើយ ដែលទាមទារឱ្យមានការកែលម្អ បន្ថែមទៀត។
- ចំណូលដែលទទួលបានពីវិស័យទេសចរណ៍ ពុំបានរួមចំណែកឱ្យបានខ្លាំងក្លា ក្នុងការជំរុញឱ្យផលិតកម្មនិង ការប្រើប្រាស់ផលិតផលក្នុងស្រុក ដោយហេតុថា ចំណូលមួយភាគធំ ត្រូវបានចំណាយសម្រាប់ការនាំចូល នូវទំនិញនិងសេវាកម្មពីបរទេស ។
- ការអនុវត្តគម្រោងអភិវឌ្ឍវិស័យទេសចរណ៍ របស់ក្រុមហ៊ុនវិនិយោគឯកជនមួយចំនួន ដែលទទួលបាន ការអនុញ្ញាតពី*រាជរដ្ឋាភិបាលកម្ពុជា* រួចហើយ មានភាពយឺតយ៉ាវ ហើយ គម្រោងមួយចំនួនទៀត គ្មាន សកម្មភាព ។
- កលិយុគហិរញ្ញវត្ថុនិងវិបត្តិសេដ្ឋកិច្ចសកល វិបត្តិនយោបាយនៅប្រទេសថៃ និង ការរីករាលដាលនៃ ជំងឺគ្រុនផ្តាសាយថ្មី បានជះឥទ្ធិពលអវិជ្ជមាន មកលើវិស័យទេសចរណ៍ នៅកម្ពុជា ។
- គុណភាពធនធានមនុស្សដែលបម្រើការងារ នៅក្នុងវិស័យទេសចរណ៍ ទាំងផ្នែកឯកជន និងផ្នែកសាធារណៈ នៅមានកម្រិតទាប នៅឡើយ ។

១៨៨. ការអភិរក្ស និងការជំរុញលើកកម្ពស់ នូវមតិកវប្បធម៌ *ខ្មែរ* ដ៏រុងរឿង និងទំនៀមទម្លាប់ប្រពៃណី គឺជាអាទិភាពខ្ពស់មួយរបស់ *រាជរដ្ឋាភិបាល* ។ ប្រាសាទបុរាណ សារមន្ទីរ និងស្នាដៃដ៏ប៉ិនប្រសប់ផ្សេងៗទៀត រួមមាន ការបង្ហាញនូវរបាំប្រពៃណីខ្មែរ ចម្រៀង និងគំនូរ បានរួមចំណែកនិងគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ។ *ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ* បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការធានាឱ្យបាននូវ ការការពារតំបន់មតិកវប្បធម៌ និង ការជំរុញ នូវគ្រប់សកម្មភាព ដែលគ្របដណ្តប់លើទិដ្ឋភាពខុសៗគ្នានៃ *វិចិត្រសិល្បៈ* ។

១៨៩. **វិស័យកាត់ដេរ** ៖ ជាកត្តាសំខាន់មួយ ដែលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចនិងភាពមានការងារធ្វើ កំពុងបង្ហាញជាសញ្ញានៃការបាត់បង់ភាពប្រកួតប្រជែងរបស់ខ្លួន ដោយសារតែ ប្រាក់ឈ្នួលកម្មករមានកម្រិតខ្ពស់ (ត្រូវបានធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ ដោយសារវិបត្តិអតិផរណាក្នុងពេលកន្លងមកថ្មីៗនេះ) ធៀបជាមួយនឹង ប្រាក់ឈ្នួលកម្មករ ក្នុងបណ្តាប្រទេសដែលផលិត ផលិតផលដូចគ្នា ហើយ ថ្លៃដឹកជញ្ជូនខ្ពស់ និង ការកើនឡើងនៃភាពប្រកួតប្រជែង នៅខណៈពេលដែលតម្រូវការក្នុងទីផ្សារពិភពលោក កំពុងធ្លាក់ចុះ ។ ម្យ៉ាងទៀត នៅមានកត្តាជាច្រើន ដែលមានឥទ្ធិពលទៅលើកំណើនជាបន្តទៀតក្នុងវិស័យនេះ ជាឧទាហរណ៍ ៖ ភាពមានកម្រិត ក្នុងការចូលរួមនៃវិស័យដទៃទៀត ទៅក្នុងការប្រែប្រួលអនុក្រមតម្លៃនៃវិស័យកាត់ដេរ និង ការកើនឡើងនៃ ចំនួនសហជីពកម្មករក្នុងរោងចក្រ ដោយសារភាពមិនច្បាស់លាស់នៅក្នុង*ច្បាប់ស្តីពីការងារ* ។ ដើម្បីបន្ធូរបន្ថយដល់វិស័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តល់ការលើកលែងពន្ធ និងបានចាប់ផ្តើមផ្តល់ ប្រាក់ឧបត្ថម្ភធនបន្ថែមពីលើប្រាក់ខែរបស់កម្មករ ចំនួន ៦ដុល្លារអាមេរិក ក្នុងមួយខែ ចាប់ពីចុងខែមេសា ឆ្នាំ២០០៨ មក ។

១៩០. **វិស័យសំណង់** ៖ ដែលជាកត្តាសំខាន់មួយផ្សេងទៀតដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ច ក៏ត្រូវបានទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយសារ វិបត្តិហិរញ្ញវត្ថុពិភពលោក ក៏ដូចជា ការប្រែប្រួលខ្លាំងនៃតម្លៃសម្ភារសំណង់នាំចូលដែរ ដូចជា ស៊ីម៉ងត៍ និងដែក ជាដើម ។ ដើម្បីទប់ទល់នឹងបញ្ហាប្រឈម និងឥទ្ធិពលនៃវិបត្តិទាំងនេះ ក៏ដូចជា ដើម្បីទាក់ទាញការវិនិយោគ លើទីផ្សារសំណង់ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងជំរុញរៀបចំសេចក្តីព្រាងច្បាប់ថ្មី រួមមាន *ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស* *ច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្មនិងសំណង់* និង ពង្រឹងការរៀបចំច្រកចេញចូលតែមួយ លើការងារផ្តល់សេវាសុំការអនុញ្ញាតសាងសង់ ។

១៩១. **ការរុករក ប្រេង ឧស្ម័ន និង រ៉ែ** ៖ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការរុករកប្រេងកាត ឧស្ម័នធម្មជាតិ និង រ៉ែ បានទាក់ទាញចំណាប់អារម្មណ៍អ្នកវិនិយោគបរទេសជាច្រើន ។ បច្ចុប្បន្ន ការងាររុករកប្រេងនិងឧស្ម័នបម្រុង មានដំណើរការវិវត្តបានយ៉ាងល្អ ហើយការងារនេះក៏ត្រូវបានរំពឹងទុកថា នឹងឈានទៅដល់ដំណាក់កាលនៃការផលិតមួយ ដែលនឹងបង្កើតជាចំណូលថ្មីសម្រាប់រដ្ឋ នាពេលអនាគត ។ ការស្វែងរុករករ៉ែ ដែក មាស បុកស៊ីត ត្បូងថ្ម ត្បូងថ្មមានតម្លៃ ។ល។ ដែលនឹងអាចក្លាយជាសក្តានុពលរ៉ែដ៏សំខាន់មួយសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ កំពុងតែ

ដំណើរការ នៅតាមតំបន់សម្បទានរ៉ែនានា នៅតាមបណ្តាខេត្តដែលស្ថិតនៅក្នុង ភាគឧត្តរនិងភាគឦសាន ។ ទន្ទឹម នឹងនេះ ការធ្វើអាជីវកម្មរ៉ែថ្មកំបោរ សម្រាប់ប្រើប្រាស់ជាវត្ថុធាតុដើម ក្នុងការផលិតស៊ីម៉ង់ត៍នៅកម្ពុជា កំពុងតែ ដំណើរការ និង បានចូលរួមយ៉ាងសកម្ម ក្នុងការកាត់បន្ថយការនាំចូលផលិតផលស៊ីម៉ង់ត៍ពីក្រៅប្រទេស ។ បទប្បញ្ញត្តិ និងនីតិវិធីនានា ត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្ន ដើម្បីធានាឱ្យមាន ចីរភាពបរិស្ថាន ការកែច្នៃនៅក្នុងស្រុកដែល បង្កើតឡើងនូវតម្លៃបន្ថែម និង ការបង្កើនជាអតិបរមានូវចំណូលរដ្ឋ ។

១៩២. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញយ៉ាងសកម្មលើការវិនិយោគវិស័យឯកជន សម្រាប់ការពង្រីក និងការ ធ្វើពិពិធកម្មនៃកម្មន្តសាល និងផលិតកម្មឧស្សាហកម្ម ដើម្បីទាញយកប្រយោជន៍ពីធនធានធម្មជាតិក្នុងប្រទេស ។ ឧស្សាហកម្មដែលផ្អែកលើធនធានធម្មជាតិជាមូលដ្ឋាន ជាពិសេស ឧស្សាហកម្មដែលប្រើប្រាស់វត្ថុធាតុដើមពីរ៉ែ អលោហៈ ត្រូវបានពង្រីកនិងអភិវឌ្ឍ ដើម្បីផលិតនូវមុខទំនិញឧស្សាហកម្មថ្មីៗ ហើយ ឧស្សាហកម្មដែលមាន ប្រភពធនធានពីកសិកម្ម គឺជាឧស្សាហកម្មដែលមានសក្តានុភាពខ្ពស់ក្នុងការអភិវឌ្ឍ ដោយជំនួសឱ្យវិស័យឧស្សាហកម្ម ផ្សេងទៀតដែលងាយទទួលរងផលប៉ះពាល់ ។

## ៥.២ ការបង្កើតការងារ និង ការធានាលក្ខខណ្ឌការងារល្អប្រសើរ ជូនកម្មករនិងនិយោជិត

១៩៣. ការបង្កើតការងារ និង ការធានាកែលម្អលក្ខខណ្ឌការងារ គឺជាគោលដៅបន្តរយៈពេលវែងរបស់ *រាជរដ្ឋា-ភិបាលកម្ពុជា* ក្នុង ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន ការកាត់បន្ថយភាពក្រីក្រ និង ការពន្លឿន កំណើនសេដ្ឋកិច្ច ។ ទោះជាដូចនេះក្តី ការបង្កើតឱកាសការងារថ្មី ក៏អាស្រ័យលើកម្រិតនៃការវិនិយោគរបស់ផ្នែក ឯកជន ក្នុងវិស័យ ផ្លូវការ និង ក្រៅផ្លូវការ នៅតំបន់ទីប្រជុំជន និង តំបន់ជនបទ ផងដែរ ។ ការធានាឱ្យអ្នកចូល បម្រើការងារថ្មី មានជំនាញសមស្របទៅនឹងតម្រូវការរបស់ការងារថ្មី គឺជាបញ្ហាប្រឈមមួយ ដែលទាមទារឱ្យ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនថែមទៀត ដែលផ្តោតលើការពង្រីក ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ។ ការធ្វើឱ្យសម្រេចបាន នូវការបង្កើតការងារឱ្យបានច្រើនជាងមុនថែមទៀត និង ការធ្វើឱ្យប្រសើឡើង នូវ ផលិតភាពនិងពិពិធកម្មក្នុងវិស័យកសិកម្ម គឺ អាស្រ័យទៅនឹង ពលកម្មជំនាញ និង មីក្រូឥណទាន ដែលអាចត្រូវ បានបង្កើតឱ្យមានឡើង តាមរយៈ ការអប់រំបណ្តុះបណ្តាល វិជ្ជាជីវៈ បច្ចេកទេស និង ការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ ។

១៩៤. *ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* បានផ្តល់សេវាកម្មរកការងារឱ្យធ្វើ ដើម្បីជួយដល់អ្នកស្វែងរក ការងារធ្វើ នៅក្នុងវិស័យឯកជន ទាំងក្នុងនិងក្រៅប្រទេស ។

១៩៥. ក្នុងឆ្នាំ២០០៧-២០០៨ *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* ក៏បានផ្តល់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈ គ្រឹះស្ថានបណ្តុះបណ្តាលកម្រិត បឋម មធ្យម និង ឧត្តម ចំនួន ២៩៤ (គ្រឹះស្ថានក្រោម ឱវាទក្រសួង ចំនួន ៥៨) ដល់សិស្ស-និស្សិតចំនួនប្រមាណ ១១៣ ៦៤៨ នាក់ (ស្រីចំនួន ៥៣ ៩០៣ នាក់) ។

ដោយឡែកនៅចុងឆ្នាំ២០០៨ ក្រសួង បានប្រើប្រាស់ *មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី* ដែលមានថវិកាសរុបចំនួន ៣១,២០ ពាន់លានរៀល ដើម្បីបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លី ជូនដល់ កម្មករ កម្មការិនី និង យុវជន យុវនារី ដែលបាត់បង់និងគ្មានការងារធ្វើ សរុបចំនួន ៤០ ១៤០នាក់ (ស្រីចំនួន ២២ ៥៨៦ នាក់) នៅ រាជធានី និង ២៣ខេត្ត លើមុខជំនាញសំខាន់ៗពីរ គឺ (១) ជំនាញផ្នែកកសិកម្ម និង (២) ជំនាញផ្នែកឧស្សាហកម្ម បច្ចេកទេសសិប្បកម្ម និង បច្ចេកទេសសេវាកម្ម ។ ទន្ទឹមនេះ ក្រសួង ក៏បានហ្វឹកហ្វឺនកូនជាងនិងកម្មករចំនួន ៤ ៥០១ នាក់ (ស្រី ៤ ០៨២ នាក់) នៅតាមសហគ្រាស ចំនួន ៦៩ ហើយ បានបង្កើត *ភ្នាក់ងារជាតិមុខរបរ* ដើម្បីជួយដល់សិក្ខាកាមរកការងារធ្វើ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដែលជាស្ពានតភ្ជាប់ទៅរកទីផ្សារការងារ និង ជាស្ពានភ្ជាប់រវាង កម្លាំងពលកម្មនិងគ្រឹះស្ថានបណ្តុះបណ្តាល ។

១៩៦. ដើម្បីធានាលក្ខខណ្ឌការងារឱ្យបានប្រសើរឡើង ក្រសួងបានបន្តផ្តោតការយកចិត្តទុកដាក់លើ ការពង្រឹងការអនុវត្ត*ច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តនានា* ដែលពាក់ព័ន្ធនឹងការងារ ការអប់រំផ្សព្វផ្សាយ ការធ្វើ អធិការកិច្ចការងារ អធិការកិច្ចលើសុខភាពនិងសុវត្ថិភាពការងារ អធិការកិច្ចការងារកុមារ និង ការគ្រប់គ្រងជនបរទេសនៅតាមសហគ្រាសគ្រឹះស្ថាន ។ ការងារនេះបានជួយសម្រួលដោះស្រាយវិវាទការងារ និង ការពារសេរីភាពសមាគមអង្គការវិជ្ជាជីវៈ ស្របតាម*បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ* និងបទដ្ឋានអន្តរជាតិ ស្តីពីការងារ ។ បច្ចុប្បន្ន ក្រសួងបាន និងកំពុងរៀបចំ *សេចក្តីព្រាងច្បាប់ស្តីពីសហជីព* តាមយន្តការត្រីភាគី ដែលរួមមាន តំណាងមកពី*រាជរដ្ឋាភិបាលកម្ពុជា* តំណាងមកពីអង្គការកម្មករនិយោជិត និងតំណាងអង្គការនិយោជក ។ នៅក្នុងឆ្នាំ២០០៨ ចំនួនវិវាទការងារនិងអំពើហិង្សា ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ មានការថយចុះច្រើន ។ នៅក្នុងឆ្នាំ២០០៨ វិវាទការងារចំនួន ៩០ ករណី ក្នុងចំណោម ១៧៤ ករណី នៅក្នុងសហគ្រាសគ្រឹះស្ថានចំនួន ១៧១ ត្រូវបានដោះស្រាយ ។

១៩៧. *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* បានអនុវត្ត ការចុះធ្វើអធិការកិច្ចចំនួន ៣ ១៣៣ លើក ក្នុងនោះបានដាក់កម្រិតដល់សហគ្រាសគ្រឹះស្ថានល្មើសច្បាប់ ចំនួន ៩២៧ និងបានផាកពិន័យសហគ្រាសគ្រឹះស្ថាន ចំនួន ១២ ។ ជាមួយនេះដែរ ក្រសួងក៏បានធ្វើអធិការកិច្ចលើ សុខភាពនិងសុវត្ថិភាពការងារ បានចំនួន ១ ៣៣៨ លើក នៅក្នុង ៥៨៦ សហគ្រាសគ្រឹះស្ថាន ផងដែរ ។ ក្រសួងបានដកហូតកុមារចំនួន ៨ ២២១ នាក់ ដែលបានចូលបម្រើការងារប្រភេទគ្រោះថ្នាក់ និងបានបង្ការទប់ស្កាត់កុមារចំនួន ១០ ០៩៥ នាក់ ពីការងារប្រភេទគ្រោះថ្នាក់ទាំងនេះ ។

១៩៨. ទន្ទឹមនឹងសមិទ្ធផលធំៗខាងលើនេះ យើងនៅមានបញ្ហាប្រឈមជាច្រើន ដែលត្រូវដោះស្រាយ តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីទាក់ទាញឱ្យមានការវិនិយោគថ្មីៗពីផ្នែកឯកជន ។ បញ្ហាប្រឈមទាំងនោះ រួមមាន :

- វិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក បាននិងកំពុងធ្វើឱ្យប៉ះពាល់មកលើវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ព្រមទាំង វិស័យផ្សេងៗទៀត ដែលធ្វើឱ្យកម្មករ កម្មការិនីបាត់បង់ការងារ ។

- កំណើនច្រើនហួសហេតុ នៃអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត បានបង្កឱកាសឱ្យជនមួយចំនួន ប្រើប្រាស់អង្គការទាំងនេះ ដើម្បីទាញយកផលប្រយោជន៍សម្រាប់ផ្ទាល់ខ្លួន ហើយ បានធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពទំនាក់ទំនងវិជ្ជាជីវៈ ។
- ប្រព័ន្ធព័ត៌មានទីផ្សារការងារនៅមានកម្រិត ដែលទាមទារឱ្យមានការពង្រីក ។
- កម្មវិធីអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការ ទីផ្សារការងារនៅឡើយ ។
- ការគ្រប់គ្រងទិន្នន័យកម្មករ និយោជិត ទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស ពុំទាន់សមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន ។
- សហគ្រាសគ្រឹះស្ថានមួយចំនួនតូច នៅមានការយឺតយ៉ាវក្នុងការមកបង់ *វិភាគទានចូលបេឡាជាតិរបបសន្តិសុខសង្គម* ដោយសារវិបត្តិហិរញ្ញវត្ថុនៅលើពិភពលោក និងមួយចំនួនទៀតដោយសារ ការងារនេះជាការងារថ្មី ដែលជាហេតុធ្វើឱ្យការអនុវត្ត *របបសន្តិសុខសង្គម* នៅមិនទាន់មានលក្ខណៈពេញលេញ និងទូលំទូលាយនៅទូទាំងប្រទេសនៅឡើយ ។

## ៥.៣ ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម

១៩៩. ការអភិវឌ្ឍដ៏វែងឆ្ងាយក្នុងវិស័យនេះ បានផ្តល់នូវអត្ថប្រយោជន៍ដល់សហគមន៍ជនបទទាំងឡាយ ក្នុងដំណើរការកែច្នៃ ព្រមទាំងការបង្កើតការងារ ហើយក៏បានបង្កើតនូវទំនាក់ទំនងដ៏ល្អប្រសើរ ជាមួយនឹង វិស័យពាណិជ្ជកម្ម ក៏ដូចជា ជាមួយសហគ្រាសខ្នាតធំដទៃទៀត ។ ការងារដែលបានគ្រោងទុក សម្រាប់ពេលខាងមុខ នឹងផ្តោតលើ ទិដ្ឋភាពដ៏សំខាន់បី ដូចជា : (១) ក្របខ័ណ្ឌច្បាប់ និងការកែសម្រួលឱ្យប្រសើរឡើង ពោលគឺ ការកំណត់នីតិវិធីនៃ អធិការកិច្ចនិងការបង្ហាញភស្តុតាង ផលិតផលសម្រាប់ការនាំចូលនិងនាំចេញ ដោយគ្មានការបង្ហាញនូវស្ថានភាពនៃ គុណភាពជាសារវន្ត ។ ការរៀបចំនិងអនុម័តអនុក្រឹត្យស្តីពី *ការសម្របសម្រួលធុរកិច្ច* តាមរយៈការគ្រប់គ្រងហានិភ័យ និងការបើកទូលាយនៃការ ចុះបញ្ជីពាណិជ្ជកម្មតាមអ៊ិនធឺណែតឬប្រព័ន្ធព័ត៌មានវិទ្យា (២) ការផ្តល់ហិរញ្ញប្បទាន ការបង្កើតក្រុមហ៊ុនធ្វើភតិសន្យា ការចំណាត់ថ្នាក់ក្រុមហ៊ុនដោយពិន្ទុផ្តល់កិត្តិយស និងការពង្រឹងអភិបាលកិច្ចនិងរបាយការណ៍ហិរញ្ញវត្ថុ (៣) សកម្មភាពគាំទ្រ*សម្រាប់សហគ្រាសធុនតូចនិងមធ្យម* ទាំងអស់ ពោលគឺ ការបង្កើតសេវាកម្មអភិវឌ្ឍន៍ពាណិជ្ជកម្មថ្មីមួយ ការបង្ការគ្រប់រូបភាពនៃ ការគេចពន្ធលួចលាក់ទំនិញនាំចូល ការទំនុកបម្រុង ដោយការធ្វើឧបត្ថម្ភធន សម្រាប់*សហគ្រាសធុនតូចនិងមធ្យម*ទាំងអស់ ក្នុងការនាំចេញ និង ការបញ្ចូលសហគ្រាសធុនតូចនិងមធ្យមទៅក្នុងខ្សែច្រវ៉ាក់តម្លៃសកលមួយ ។ ការទទួលយកមកអនុវត្ត និងការពន្លឿន *"ចលនាភូមិមួយ ផលិតផលមួយ"* គឺជាវិធានការមួយដែលត្រូវយកចិត្តទុកដាក់ ។

២០០. *ក្រសួងពាណិជ្ជកម្ម* បានយកចិត្តទុកដាក់អនុវត្តកំណែទម្រង់នីតិវិធីនានានៃ *ការចុះបញ្ជីពាណិជ្ជកម្ម* សម្រាប់*សហគ្រាសធុនតូចនិងមធ្យម* ទាំងអស់ ។ រយៈពេលកំណត់ដែលទាមទារសម្រាប់ *ការចុះបញ្ជីពាណិជ្ជកម្ម* ត្រូវបានកាត់

បន្ថយ ពី ២-៣សប្តាហ៍ ទៅ ១សប្តាហ៍វិញ ។ ដំណើរការបំពេញឯកសារក្នុងការចុះបញ្ជី*សហគ្រាសធុនតូចនិងមធ្យម* មួយ ត្រូវបានកាត់បន្ថយ ។ ការតម្រូវឱ្យមានរបាយការណ៍ស្តីពីការផ្តន្ទាទោសបទល្មើសឧក្រិដ្ឋ និងដំណោះស្រាយ បញ្ជាក់ការយល់ព្រម មិនចាំបាច់ប្រើពេលវេលាយូរ ។ តម្រូវការទុនទាំងអស់ក្នុងទម្រង់នៃ*បញ្ជីធនាគារ* សម្រាប់ *ការចុះបញ្ជីពាណិជ្ជកម្ម* ត្រូវបានកាត់បន្ថយពី ២០ លានរៀល ទៅ ៤ លានរៀល ។ ថ្លៃរដ្ឋបាលសម្រាប់ការចុះបញ្ជី ត្រូវបានកាត់បន្ថយទៅដល់ ១៧៧ ដុល្លារអាមេរិក ។ បន្ទាប់ពីកំណែទម្រង់ក្នុងឆ្នាំ២០០៥ ចំនួនក្រុមហ៊ុន ដែលត្រូវ បានចុះបញ្ជី បានកើនឡើងរៀងរាល់ឆ្នាំ ហើយ ក្នុងឆ្នាំ២០០៨ បានកើនឡើងពីរដងនៃឆ្នាំ២០០៥ ។

## ៥.៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម

២០១. *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* មានភារកិច្ច រៀបចំដំណើរការការងារ និង គ្រប់គ្រងប្រព័ន្ធ សន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃ*ច្បាប់ស្តីពីការងារ* ។ កន្លងមក ក្រសួង បានដាក់ឱ្យដំណើរការ ការធានារ៉ាប់រងហានិភ័យការងារ ដែលកំពុងធានារ៉ាប់រងកម្មករនិយោជិត ប្រមាណ ៤០ ម៉ឺននាក់ ដែលធ្វើការងារនៅតាមសហគ្រាសគ្រឹះស្ថាន គ្រប់ប្រភេទ ហើយនឹងបន្តពង្រីកវិសាលភាពរបបនេះ ឱ្យបានទូទាំងប្រទេស ។ ការអនុវត្តប្រព័ន្ធសន្តិសុខសង្គម សម្រាប់កម្មករនិយោជិត ក្នុងផ្នែកឯកជន គឺជារបត់ថ្មី នៃប្រវត្តិសាស្ត្រសន្តិសុខសង្គមនៅកម្ពុជា ដែលបង្ហាញឱ្យឃើញកាន់តែច្បាស់ ពីការយកចិត្តទុកដាក់របស់ *រាជរដ្ឋា-ភិបាលកម្ពុជា* មកលើកម្មករ និយោជិត ក្នុងផ្នែកឯកជន ។

២០២. *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* មានតួនាទីអភិវឌ្ឍន៍ និងរៀបចំគ្រប់គ្រងរបប សន្តិសុខសង្គម និងបេឡាជាតិសន្តិសុខសង្គម ដែលត្រូវបង្កើតឡើង និងដាក់ឱ្យដំណើរការនាពេលខាងមុខ សម្រាប់ មន្ត្រីរាជការស៊ីវិល ។ ដូច្នេះ នៅពេលដែលប្រព័ន្ធសន្តិសុខសង្គមទាំងពីរនេះ ត្រូវបានអនុវត្តពេញលេញ នោះប្រព័ន្ធនេះ នឹងផ្តល់មកនូវអត្ថប្រយោជន៍ជាច្រើនដល់ មន្ត្រីចូលនិវត្តន៍ មន្ត្រីបាត់បង់សម្បទាវិជ្ជាជីវៈ មន្ត្រីសម្រាកមាតុភាព មន្ត្រីគ្រោះថ្នាក់ដោយការងារ មន្ត្រីមរណៈ និង អ្នកនៅក្នុងបន្ទុក ។ ប្រាក់សោធននិវត្តន៍របស់មន្ត្រីចូលនិវត្តន៍ និង ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានកែសម្រួល ជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹង ការរីកចម្រើននៃ សេដ្ឋកិច្ចជាតិ ។ ទន្ទឹមនេះ *សមាគមមនុស្សចាស់ជរា* ត្រូវបានបង្កើតឡើង ដើម្បីឱ្យជនចាស់ជរា អាចជួយសម្រាល ទុក្ខលំបាកគ្នា ទៅវិញទៅមក ។

២០៣. *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* ក៏មានតួនាទីផងដែរ ដើម្បីធានាដល់សុខុមាលភាព របស់ជនពិការ និង អតីតយុទ្ធជន ដែលរួមមាន គ្រួសារ ជនពលី ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងមន្ត្រីមរណៈ ។ គ្រួសារដែលទទួលបានរបបគោលនយោបាយទៀងទាត់ ពី *រាជរដ្ឋាភិបាល* មានចំនួនសរុប ៨៧ ៨៧៥ គ្រួសារ ។ របបឧបត្ថម្ភសម្រាប់អតីតយុទ្ធជន ត្រូវបានកែសម្រួលជាបន្តបន្ទាប់ ស្របតាមការដំឡើង បៀវត្សរ៍របស់មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ ។ សមាគមអតីតយុទ្ធជនកម្ពុជា ត្រូវបានបង្កើតឡើង

ដើម្បីជួយលើកស្ទួយផលប្រយោជន៍អតីតយុទ្ធជននិងគ្រួសាររបស់ពួកគាត់ ការពារសិទ្ធិ លើកកម្ពស់កម្រិតជីវភាពរស់នៅ និង បង្កើតស្មារតីសាមគ្គីជួយគ្នាទៅវិញទៅមក ។ កំណែទម្រង់វិស័យអតីតយុទ្ធជន បានជួយលើកកម្ពស់កម្រិតជីវភាពរស់នៅ របស់អតីតយុទ្ធជន ។

២០៤. *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* ក៏បាន ផ្តល់នូវសេវាកម្មសង្គមដល់ជនគ្មានទីជម្រក និងជនអនាថា និង ផ្តល់នូវកម្មវិធីជំនួយសង្គ្រោះបន្ទាន់ដល់ ប្រជាជនដែលបានទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិ និង ជនរងគ្រោះដោយសារការជួញដូរផ្លូវភេទនិងការជួញដូរមនុស្សឆ្លងដែន ព្រមទាំង អនុវត្តកម្មវិធីផ្សេងៗទៀត ដើម្បី ការពារសិទ្ធិជាមូលដ្ឋានទាំង ៤ របស់កុមារ លើកតម្កើងតម្លៃគ្រួសារ និង ថែទាំ ទារកនិងកុមារកំព្រា កុមារពិការ និង កុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។

២០៥. គណៈកម្មាធិការជាតិមួយ សម្រាប់ដោះស្រាយបញ្ហាជនអនាថានៅថ្នាក់ជាតិ និង អនុគណៈកម្មាធិការមួយ សម្រាប់ដោះស្រាយបញ្ហាជនអនាថានៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើង ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រ ៦ ចំណុច កំពុងត្រូវដាក់ឱ្យអនុវត្ត ដើម្បីផ្តល់ ជម្រកស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសង្គមកិច្ច សេវាអប់រំផ្នែកចិត្តសាស្ត្រ សេវាថែទាំសុខភាព សេវាបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និង ដើម្បីធ្វើសមាហរណកម្មក្រុមជនងាយរងគ្រោះ ទៅរួមរស់ក្នុងសហគមន៍វិញ ដោយ មានការគាំទ្រឧបត្ថម្ភធនជាជំហានដំបូង និង មានការតាមដានត្រួតពិនិត្យ ពីមន្ត្រីមូលដ្ឋានរបស់ *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា* ។

២០៦. ការងារសង្គ្រោះសង្គម បានជួយសម្រាលស្ថានភាពលំបាករបស់ប្រជាជន បានប្រមាណជាង ១០ ០០០ គ្រួសារក្នុងមួយឆ្នាំ តាមរយៈ កម្មវិធីជំនួយសង្គ្រោះ ក្នុងទ្រង់ទ្រាយតូចនិងមធ្យម ។ ទន្ទឹមនឹងនេះ ជនរងគ្រោះដោយសារការជួញដូរផ្លូវភេទនិងការជួញដូរមនុស្សឆ្លងដែន ជាង ១ ០០០ នាក់ ត្រូវបានទទួលការជួយសង្គ្រោះ ក្នុងមួយឆ្នាំៗ តាមរយៈ ការប្រឆាំងនិងទប់ស្កាត់ការជួញដូរមនុស្ស និង ធ្វើសមាហរណកម្មជនរងគ្រោះ ទាំងនោះ ទៅរួមរស់ក្នុងសហគមន៍វិញ ។

២០៧. សិទ្ធិជាមូលដ្ឋានទាំង ៤ របស់កុមារ ត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីជាច្រើន របស់ *រាជរដ្ឋាភិបាល* និង អង្គការក្រៅរដ្ឋាភិបាល នានា ។ *ផែនការជាតិ ៥ឆ្នាំ ប្រយុទ្ធប្រឆាំងនឹងការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ* ត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយលទ្ធផលគួរឱ្យកត់សម្គាល់ ។ *គោលនយោបាយថែទាំជំនួសចំពោះកុមារ និង បទដ្ឋានអប្បបរមា* ត្រូវបាននិងកំពុងអនុវត្ត ។ *ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ* បានបន្តពង្រឹងសកម្មភាព ក្នុងនាមជាស្ថាប័នសម្របសម្រួល ដើម្បីជំរុញការធ្វើឱ្យប្រសើរឡើង នូវកិច្ចសហប្រតិបត្តិការ នៅក្នុងចំណោមស្ថាប័ននានា ដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់កុមារ ។ ជាលទ្ធផល ទារកនិងកុមារកំព្រាចំនួន ១០ ៩១៣ នាក់ ត្រូវបានចិញ្ចឹមបីបាច់ថែរក្សា នៅតាមមណ្ឌលទាំង ២២៣ កន្លែង ដែលក្នុងនោះ មណ្ឌលរដ្ឋ ២០ កន្លែង បានទទួល ទារកកំព្រា កុមារកំព្រា កុមារពិការ កុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ សរុបចំនួន ២ ១៥៤ នាក់ ។ កម្មវិធីបណ្តុះការការពារកុមារ នៅតាមសហគមន៍ ត្រូវបានពង្រីក ហើយ សកម្មភាពរបស់កម្មវិធីនេះ ក៏ត្រូវបានបង្កើនផងដែរ ។

២០៨. *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* បានផ្តល់នូវកម្មវិធីអប់រំ ទៅលើការប្រព្រឹត្តបទល្មើស និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ចំពោះកុមារ និងក្មេងជំទង់ បានអនុវត្តជាបន្តបន្ទាប់ ។ កុមារនិងក្មេងជំទង់ ដែលបានប្រព្រឹត្តបទល្មើស និងប្រើប្រាស់គ្រឿងញៀន ត្រូវបានទទួលឱ្យចូលក្នុងមណ្ឌលដែលផ្តល់ សេវាសុខភាព ការអប់រំផ្នែកសីលធម៌ ចំណេះដឹងទូទៅ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យពួកគាត់ អាចធ្វើសមាហរណកម្មខ្លួនឯង ទៅក្នុងសហគមន៍វិញ ។ កិច្ចការពារកុមារនៅតាមពន្ធនាគារ ត្រូវបានយកចិត្តទុកដាក់អនុវត្ត ។ គោលនយោបាយសម្រាប់ជនពិការ ត្រូវបានអនុវត្ត ប្រកបដោយជោគជ័យ ។ សេវាស្តារលទ្ធភាពពលកម្មជនពិការ ត្រូវបានពង្រឹងនិងពង្រីកជាបន្តបន្ទាប់ ។ ការរើសអើងចំពោះជនពិការ ត្រូវបានកាត់បន្ថយជាលំដាប់ ។ ប្រទេសកម្ពុជា បានចូលរួមក្នុង *អនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ* ។ *ច្បាប់ស្តីពី កិច្ចការពារនិងការលើកកម្ពស់សិទ្ធិជនពិការ* ត្រូវបានប្រកាសឱ្យប្រើប្រាស់ កាលពី ខែកក្កដា ឆ្នាំ២០០៩ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ជនពិការទូទៅ ។ ជនពិការជាច្រើន បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងមជ្ឈមណ្ឌលជាច្រើន ហើយ កំពុងប្រកបមុខរបរចិញ្ចឹមជីវិត ។ ការជំរុញចលនា កីឡា សិល្បៈ វប្បធម៌ ជនពិការ កំពុងតែមានការរីកចម្រើន ។

២០៩. ទោះបីជា ការឆ្លើយតបទៅនឹងតម្រូវការ របស់ក្រុមជនងាយរងគ្រោះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ ការរៀបចំឱ្យមានប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈទូលំទូលាយ គឺជាការងារដែលត្រូវបន្តគិតគូរដោះស្រាយ នៅពេលខាងមុខ ។ លទ្ធភាពផ្នែកធនធាន សម្រាប់ដោះស្រាយបញ្ហាដ៏ច្រើនដែលកំពុងបន្តកើតមាន នៅតែជាកង្វល់ចម្បង មួយ ។ ប្រហែល ៣០ភាគរយ នៃចំនួនប្រជាជនសរុប កំពុងរស់នៅក្រោមខ្សែបន្ទាត់ក្រីក្រ ។ ប្រជាជនក្រីក្រភាគច្រើន ដែលកំពុងរស់នៅក្នុងតំបន់ជនបទ ដោយប្រកបរបរធ្វើស្រែចំការសម្រាប់ការចិញ្ចឹមជីវិត អាចប្រឈមមុខនឹងគ្រោះមហន្តរាយធម្មជាតិ ដែលអាចកើតមានឡើងដោយមិនអាចដឹងមុនបាន ស្ទើរតែរៀងរាល់ឆ្នាំ ហើយ អាចជួបការលំបាកក្នុងការរើខ្លួនឱ្យរួចផុតពីភាពក្រីក្រ ។ ប្រជាជនក្រីក្រ ខ្លះទៀតត្រូវបង្ខំចិត្ត ផ្លាស់ទីលំនៅទៅទីក្រុងនិងតំបន់ទីប្រជុំជនធំៗ ដើម្បីស្វែងរកការងារធ្វើ ដែលបណ្តាល ឱ្យកើតមានកង្វល់ ជាច្រើន សម្រាប់តំបន់ទីក្រុងនិងតំបន់ទីប្រជុំជនទាំងនោះ ។ ក្មេងកំព្រា និង ក្មេងដែលគេ បោះបង់ចោលនៅបន្តជាបន្ទុកមួយរបស់សង្គមជាតិទាំងមូល ។ អំពើហិង្សានិងអំពើអនាចារ ដែលត្រូវបានប្រព្រឹត្តទៅលើកុមារព្រមទាំង ការប្រព្រឹត្តបទល្មើសនិងការប្រើប្រាស់គ្រឿងញៀន របស់ក្មេងជំទង់ ដែលមានការកើនឡើងដ៏គួរឱ្យចាប់អារម្មណ៍ បានក្លាយជាកង្វល់ចម្បងមួយរបស់សង្គម ដែលត្រូវតែមាន វិធានការដោះស្រាយ ។ ក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ ជំនួយឧបត្ថម្ភពីអន្តរជាតិសម្រាប់វិស័យនេះ មានការថយចុះគួរឱ្យកត់សម្គាល់ ដែលបណ្តាលឱ្យមានការលំបាក ក្នុងការផ្តល់សេវាកម្មស្តារលទ្ធភាពពលកម្ម ដែលជាតម្រូវការចាំបាច់ចំពោះមុខ ។

## ៦. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

២១០. ចតុកោណចុងក្រោយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលផ្តោតលើវិស័យសង្គមកិច្ច មានដូចជា ១) ការពង្រឹងគុណភាពសេវាអប់រំ ២) ការលើកកម្ពស់សេវាសុខាភិបាល ៣) ការអនុវត្តគោលនយោបាយ យេនឌ័រ និង ៤) ការអនុវត្តគោលនយោបាយប្រជាជន ។ វឌ្ឍនភាពគួរកត់សម្គាល់បានសម្តែងឱ្យឃើញលើ វិស័យអប់រំ និងសុខាភិបាល ដែលក្នុងនោះកិច្ចសហការ និងសម្របសម្រួលរវាងអ្នកពាក់ព័ន្ធទាំងឡាយបាន ចាប់ផ្តើមតាំងពីមុនពេលនៃការបង្កើតក្រុមការងារនានាឆ្នាំ២០០៣ មកម្ល៉េះ ។ យុទ្ធសាស្ត្ររបស់វិស័យទាំងពីរ នេះបានអភិវឌ្ឍជាថ្មី និងកំពុងអនុវត្ត ដោយមានការត្រួតពិនិត្យជាប្រចាំ និងជារៀងរាល់ឆ្នាំពីវឌ្ឍនភាព ។

### ៦.១ ការពង្រឹងគុណភាពវិស័យអប់រំ

២១១. ការពង្រឹងគុណភាពសេវាអប់រំ គឺជាអាទិភាពចម្បងមួយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ការងារនេះមានសារៈសំខាន់ និងជាគន្លឹះចាំបាច់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងកាត់បន្ថយភាពក្រីក្រ ។ ដើម្បីប្រឈមមុខនឹងបញ្ហាទាំងឡាយនៅក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានជំរុញឱ្យអនុវត្តនូវ *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* តាមរយៈការ បង្កើតភាពជាដៃគូក្នុងការកសាងផែនការនិងកម្មវិធីសម្រាប់វិស័យអប់រំ ។ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០១-២០០៥* និង*កម្មវិធីគាំទ្រវិស័យអប់រំ ឆ្នាំ២០០១-២០០៥* ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០០១ និងបានធ្វើការពិនិត្យឡើងវិញ និងវាយតម្លៃរួមគ្នាក្នុងខែមិថុនា ឆ្នាំ២០០១ ។ ក្នុងខែកញ្ញា ឆ្នាំ២០០៤ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-២០០៨* ត្រូវបានកែលម្អឡើងវិញ ដោយមានការឯកភាពជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ។ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ ឆ្នាំ២០០៦-២០១០* ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបនឹង *ផយអជ ២០០៦-២០១០ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា* និងដើម្បីរួមចំណែកសម្រេចបាន ចំណុចដៅដែលបានកំណត់នៅក្នុង *ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣-២០១៥* ។ ការអនុវត្ត*ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៦-២០១០* បានរួមចំណែកបង្កើនសមធម៌នៃការចូលរៀនរបស់កុមារកម្ពុជា ដើម្បីជួយពួកគេឱ្យក្លាយជា សិស្សល្អ កូនល្អ និង ពលរដ្ឋល្អ ដែលនឹងក្លាយទៅជាកម្លាំងស្នូលដ៏សំខាន់ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជានាពេលអនាគត ។

២១២. *អភិក្រមគ្រប់គ្រងទូទាំងវិស័យអប់រំ* បានរួមចំណែកលើកកត្តាសំខាន់ពីរគឺ ទី១ ផ្តល់ដល់ក្រសួងអប់រំ នូវយន្តការមួយ សម្រាប់ធ្វើការតម្រឹមជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍ ឱ្យស្របទៅតាមតម្រូវការរបស់ក្រសួង ទី២ កាត់បន្ថយចំណាយប្រតិបត្តិការ ក្នុងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ នានា ។ ដៃគូអភិវឌ្ឍន៍មួយចំនួនធំ

កំពុងចូលរួមក្នុងការកសាងផែនការ ការពិនិត្យឡើងវិញ និងធ្វើហិរញ្ញប្បទានរួមគ្នា ក្រោមរូបភាព*អភិក្រមគ្រប់គ្រងទូទាំងវិស័យអប់រំ* ។ ទោះជាដូចនេះក្តី ការផ្តល់ហិរញ្ញប្បទានក្នុងវិស័យអប់រំ តាមលក្ខណៈ ឬតាមគំរូថវិកាគាំទ្រដោយផ្ទាល់ នៅមានកម្រិតទាបនៅឡើយ ។ ក្នុងឆ្នាំ២០០៨ ការផ្តល់ហិរញ្ញប្បទាន តាមលក្ខណៈថវិកាគាំទ្រ មានចំនួនតែ ៣,៥ភាគរយនៃជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍វិស័យអប់រំប៉ុណ្ណោះ ។ វិស័យអប់រំគឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំងអស់របស់ *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* របស់ *រាជរដ្ឋាភិបាលកម្ពុជា* ។ *រាជរដ្ឋាភិបាលកម្ពុជា* នៅតែបន្តប្តេជ្ញាលើកកម្ពស់គុណភាពសេវាអប់រំ និងបន្តបង្កើនការបែងចែកថវិកាចរន្តរបស់ថវិកាជាតិទៅឱ្យវិស័យអប់រំ ព្រមទាំងធានាឱ្យមានការបញ្ចេញសាច់ប្រាក់បានទាន់ពេលវេលា ។ ជាក់ស្តែង ថវិកាចរន្តរបស់វិស័យអប់រំ ត្រូវបានបង្កើនពី ១៨៣,២ពាន់លានរៀល ក្នុងឆ្នាំ ២០០០ ទៅដល់ ៧៤២,៥ពាន់លានរៀល ក្នុងឆ្នាំ២០០៩ ។

២១៣. គោលនយោបាយជាអាទិភាពនៅក្នុង*ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* បានផ្តោតជាសំខាន់លើ *ទី១* ការធានាសមធម៌នៃការចូលរៀន *ទី២* ការកែលម្អគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ និង *ទី៣* ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីអនុវត្តវិមជ្ឈការ ។ វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត*ផែនការយុទ្ធ-សាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* បានបង្ហាញឱ្យឃើញជាក់ស្តែងតាមរយៈ ការធានាកុមារអាយុ ៦ឆ្នាំ បានចូលរៀននៅសាលាបឋមសិក្សា និងការកាត់បន្ថយឧបសគ្គចំណាយរបស់មាតាបិតាសិស្សនៅគ្រប់សាលារៀន និងគ្រប់កម្រិតទូទាំងប្រទេស ។ ការអនុវត្តកម្មវិធីសាលាកុមារមេត្រី ការអភិវឌ្ឍកម្មវិធីសិក្សា និងការវាយតម្លៃស្តង់ដារនៃការសិក្សា បានរួមចំណែកយ៉ាងច្រើន ក្នុងការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាព នៃសេវាអប់រំ ជាក់ស្តែង គឺមានការកើនឡើងនៃចំនួនសាលាបឋមសិក្សានិងសាលាមធ្យមសិក្សាបឋមភូមិ ការកើនឡើងនៃចំនួនសិស្សនៅសាលាមធ្យមសិក្សា និងកំណើនអត្រាអក្ខរជន (អាយុ ១៥-២៤) ជាដើម ។ ទោះជាដូចនេះក្តី ក៏នៅមានគម្លាតមួយចំនួន ដែលតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការអនុវត្តយុទ្ធសាស្ត្រនានាឱ្យបានជោគជ័យ ជាពិសេស ការអប់រំកុមារតូច ការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា ការអភិវឌ្ឍសម្ភាររូបវន្ត និងការអប់រំនៅឧត្តមសិក្សា សម្រាប់សិស្ស-និស្សិតមកពីគ្រួសារក្រីក្រ និងតំបន់ដាច់ស្រយាល ។ តារាងទី៣ បង្ហាញពីទិន្នន័យបច្ចុប្បន្នភាព ក្នុងវិស័យអប់រំ ។

## តារាងទី៣ : ការអភិវឌ្ឍក្នុងវិស័យអប់រំ ២០០៥/០៦-២០០៨/០៩

| | សូចនាករសំខាន់ៗក្នុងវិស័យអប់រំ | ឯកតា | ២០០៥-០៦ | ២០០៦-០៧ | ២០០៧-០៨ | ២០០៨-០៩ |
|---|---|---|---|---|---|---|
| ១ | សាលាបឋមសិក្សា (១-៦) | ចំនួន | ៦ ២៧៧ | ៦ ៣៦៥ | ៦ ៤៧៦ | ៦ ៥៦៥ |
| ២ | អត្រាពិតនៃការសិក្សា : សរុប | % | ៩១,៣ | ៩២,១ | ៩៣,៣ | ៩៤,៤ |
| ៣ | ប្រុស | % | ៩៣,០ | ៩៣,២ | ៩៣,២ | ៩៤,៨ |
| ៤ | ស្រី | % | ៨៩,៧ | ៩១,០ | ៩៣,៣ | ៩៤,០ |
| ៥ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន | % | ៩១,២ | ៩៣,២ | ៩២,៧ | ៩៤,០ |
| ៦ | ជនបទ | % | ៩១,៧ | ៩២,២ | ៩៣,៦ | ៩៤,៧ |
| ៧ | តំបន់ដាច់ស្រយាល | % | ៨៣,៧ | ៨៦,០ | ៨៨,៤ | ៩០,៣ |
| ៨ | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា : សរុប | % | ៩០,៣ | ៩០,១ | ៨៦,២ | ៨៥,៦ |
| ៩ | ប្រុស | % | ៩១,៨ | ៩០,៤ | ៨៤,៧ | ៨៥,៤ |
| ១០ | ស្រី | % | ៨៨,៧ | ៨៩,៨ | ៨៨,០ | ៨៥,៧ |
| ១១ | ចំនួនសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ៩១១ | ១ ១១២ | ១ ៣០៣ | ១ ៤៥១ |
| ១២ | អត្រាពិតនៃការសិក្សា : សរុប | % | ៣១,៣ | ៣៣,៧ | ៣៤,៨ | ៣៣,៩ |
| ១៣ | ប្រុស | % | ៣២,១ | ៣៤,៣ | ៣៣,៧ | ៣២,៩ |
| ១៤ | ស្រី | % | ៣០,៤ | ៣៣,១ | ៣៥,៩ | ៣៥,០ |
| ១៥ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន | % | ៥០,១ | ៥៣,៥ | ៥៥,៩ | ៥៤,០ |
| ១៦ | ជនបទ | % | ២៨,៦ | ៣០,៧ | ៣១,៥ | ៣០,៩ |
| ១៧ | តំបន់ដាច់ស្រយាល | % | ៦,០ | ៩,០ | ១១,១ | ១១,៣ |
| ១៨ | អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ : សរុប | % | ៣៥,៨ | ៤១,៩ | ៤៨,៧ | ៤៩,១ |
| ១៩ | ប្រុស | % | ៤០,៨ | ៤៨,៨ | ៥២,៩ | ៥២,២ |
| ២០ | ស្រី | % | ៣០,៨ | ៣៥,២ | ៤៤,២ | ៤៥,៩ |
| ២១ | អត្រាអក្ខរជនអាយុ ១៥-២៤ឆ្នាំ | % | ៨៤,៧ | ៨៤,៧ | ៨៧,៨ | ៨៧,៥ |

ប្រភព : *EMIS ក្រសួងអប់រំ យុវជន និងកីឡា*

២១៤. សកម្មភាពសំខាន់ៗដែលក្រសួងអប់រំ យុវជន និងកីឡាអនុវត្ត ដើម្បីទទួលបានផលសម្រេចនៅក្នុងគោលនយោបាយជាយុទ្ធសាស្ត្រទាំងបីរបស់ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ* រួមមាន :

- នៅក្នុងគោលនយោបាយជាយុទ្ធសាស្ត្រទី១ របស់ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៦-២០១០* មានគោលដៅធានាសមធម៌នៃការចូលរៀន ។ សកម្មភាពដែលបានអនុវត្ត និងលទ្ធផលសំខាន់ៗរួមមាន :
  - ➢ *ចំនួនសាលារៀន :* ក្រសួងបានបង្កើនចំនួនសាលារៀនបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យពី ៨ ៦២៨ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ដល់ចំនួន ៩ ៨៣៤សាលា ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។

ក្នុងនោះសាលាបឋមសិក្សា បានកើនឡើង ពី ៦ ២៧៧ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ដល់ចំនួន ៦ ៥៦៥សាលា ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។ ចំនួនសាលាមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៩១១ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ដល់ចំនួន ១ ១២២សាលា ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។ ចំនួនសាលាមធ្យមសិក្សាទុតិយភូមិកើនឡើងពី ២៥២ ក្នុង ឆ្នាំសិក្សា២០០៥-២០០៦ ដល់ចំនួន ៣៤៩សាលា ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។ ដើម្បីកាត់បន្ថយគម្លាតនៃការទទួលបានសេវាអប់រំ របស់កុមារមកពីគ្រួសារក្រីក្របំផុត និងគ្រួសារនៅតំបន់ដាច់ស្រយាល សាលាបឋមសិក្សាត្រូវបាន សាងសង់កាន់តែច្រើនឡើងនៅតំបន់ទាំងនោះ ។ ក្នុងឆ្នាំសិក្សា២០០៨-២០០៩ មានសាលាបឋម សិក្សាចំនួន ៥៤៧ នៅតាមតំបន់ដាច់ស្រយាល ។

- *ចំនួនបុគ្គលិកបង្រៀន :* ឆ្លើយតបនឹងការកើនឡើងនៃចំនួនសាលារៀន ក្រសួងបានបង្កើនចំនួន បុគ្គលិកបង្រៀនសរុប ពី ៧៨ ៦០៦នាក់ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ទៅដល់ ៨១ ៣៥០នាក់ ក្នុង ឆ្នាំសិក្សា២០០៨-២០០៩ ជាពិសេស នៅកម្រិតមធ្យមសិក្សា ក្នុងនោះ គ្រូបង្រៀននៅមត្តេយ្យ សិក្សាកើនឡើងពី ២ ៧០៨នាក់ ដល់ ៣ ០៩២នាក់ នៅបឋមសិក្សាបានថយចុះពី ៥០ ៣៧៨នាក់ មកត្រឹម ៤៥ ៥១១នាក់ (ការថយចុះនេះ ដោយសារការថយចុះនៃចំនួនសិស្សចូលរៀន) នៅមធ្យម សិក្សាបឋមភូមិកើនឡើងពី ១៨ ៥៧៩នាក់ ដល់ ២៣ ៥៧៦នាក់ (គ្រូបង្រៀនមួយភាគធំបានប្តូរ មកពីកម្រិតបឋមសិក្សា) និងនៅមធ្យមសិក្សាទុតិយភូមិ បានកើនឡើងពី ៦ ៩៤១នាក់ ទៅដល់ ៩ ១៧១នាក់ ។ អត្រាគ្រូបង្រៀនជាស្ត្រីនៅបឋមសិក្សាបានកើនឡើងដល់ ៤៤,៨ភាគរយ នៃចំនួនគ្រូ បង្រៀនសរុប ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។ គ្រូបង្រៀនថ្មីប្រមាណ ៥ ០០០នាក់ ត្រូវបានជ្រើសរើស ជារៀងរាល់ឆ្នាំ ។ គ្រូបង្រៀនចេញថ្មីប្រមាណ ៥៩ភាគរយ ត្រូវបានពង្រាយទៅកាន់តំបន់ដាច់ ស្រយាល និងតំបន់ជួបការលំបាក (ធៀបនឹងចំណុចដៅ ៣០ភាគរយ) ។
- *ការពង្រីកសម្ភាររូបវន្តអប់រំ :* ក្រសួងបានពង្រីកសម្ភាររូបវន្តអប់រំ ដូចជា ចំនួនថ្នាក់រៀនបានកើន ឡើងប្រមាណ ៨,០ភាគរយ ពីចំនួន ៥៤ ៣២២ថ្នាក់ ដល់ ៥៨ ៨៧២ថ្នាក់ ។ ជាលទ្ធផល ផលធៀប សិស្ស-ថ្នាក់រៀន ត្រូវបានកែលម្អ ពី ៦៣,១ មកត្រឹម ៥៥,២ ។ ក្រសួងក៏បានសាងសង់អន្តេវាសិក-ដ្ឋាននៅតាមមជ្ឈមណ្ឌល បណ្តុះបណ្តាលគ្រូ ដែលអាចទទួលគរុសិស្សឱ្យស្នាក់នៅបានចំនួន ៣ ៧០០ នាក់ ។ ក្រសួងក៏បានសាងសង់ អន្តេវាសិកដ្ឋានសម្រាប់សិស្សស្រីនៅសាលាមធ្យមសិក្សា (ចំណេះ ទូទៅ) ក្នុងខេត្តសៀមរាប កំពង់ធំ ក្រចេះ រតនគិរី និងមណ្ឌលគិរី ដែលអាចទទួលសិស្សស្នាក់នៅបាន ៣៥៦ នាក់ និង អន្តេវាសិកដ្ឋាននៅរាជធានីភ្នំពេញ សម្រាប់និស្សិតស្រីនៅឧត្តមសិក្សា ស្នាក់នៅ ប្រមាណ ៥០០ នាក់ ។ ការពង្រីកសេវាអប់រំ បានបញ្ចូលនូវសម្ភាររូបវន្តសម្រាប់កុមារពិការ ដូចជា ការបង្កើតផ្លូវជម្រាល បង្គន់អនាម័យ ជាដើម ។

- *ចំនួនសិស្ស :* ចំនួនសិស្សនៅកម្រិត បឋមសិក្សានិងមធ្យមសិក្សា បានថយចុះពីចំនួន ៣ ៤២៧ ៣៩៤ នាក់ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ មកត្រឹម ៣ ២៥១ ០០០ នាក់ ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។ មូលហេតុនៃការថយចុះនេះ ដោយសារ ចំនួនសិស្សនៅកម្រិតបឋមសិក្សាបានថយចុះ ពី ២ ៥៥៨ ៤៦៧ នាក់ មកត្រឹម ២ ២៦២ ៨៣៤ នាក់ ជាពិសេស ការថយចុះនៃចំនួនកុមារក្នុងវ័យសិក្សា ។ ចំនួនសិស្សនៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៥៨៨ ៣៣៣នាក់ ដល់ ៦០៥ ៧០៧នាក់ ។ ចំនួនសិស្សនៅមធ្យមសិក្សាទុតិយភូមិបានកើនឡើង ពី ២០៤ ៩២៥ នាក់ ដល់ ២៩២ ៤២៣ នាក់ ។ អត្រាចូលរៀនរបស់សិស្សស្រី និងសិស្សប្រុស មានការកើនឡើងគួរឱ្យកត់សម្គាល់ ។ នៅកម្រិតបឋមសិក្សា អត្រាពិតនៃការសិក្សា បានកើនឡើងពី ៩១,៣ ភាគរយ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ទៅដល់ ៩៤,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០០៨-២០០៩ ។ នៅកម្រិតមធ្យមសិក្សាបឋមភូមិ អត្រាពិតនៃការសិក្សា បានកើនឡើងពី ៣១,៣ ភាគរយ ទៅដល់ ៣៤,០ ភាគរយ ។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ អត្រាពិតនៃការសិក្សា បានកើនឡើង ពី ១១,៣ ភាគរយ ទៅដល់ ១៦,៤ភាគរយ ។
- ដើម្បីកាត់បន្ថយឧបសគ្គចំណាយរបស់មាតាបិតាសិស្ស និងរក្សាសិស្សឱ្យនៅក្នុងសាលារៀន កិច្ចខិតខំប្រឹងប្រែងមួយចំនួនត្រូវបានធ្វើឡើង ដូចជា ការបង្កើនថវិកាដំណើរការសាលារៀន ការលុបបំបាត់ចំណាយក្រៅផ្លូវការ និងការផ្តល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេស ដល់សិស្សស្រីនៅថ្នាក់ទី៧-៩ បានចំនួន ១៧ ៦៦៧នាក់ ក្នុងមួយឆ្នាំ ។
- ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្ររយៈពេលវែង ការវិនិយោគ និងកិច្ចខិតខំប្រឹងប្រែងបន្តត្រូវបានយកចិត្តទុកដាក់នៅកម្រិតឧត្តមសិក្សា រួមទាំងការកសាងអន្តេវាសិកដ្ឋាន ជាដើម ។ ឱកាសនៃការទទួលបានសេវាអប់រំនៅឧត្តមសិក្សា ត្រូវបានកែលម្អ តាមរយៈ ការផ្តល់អាហារូបករណ៍ សម្រាប់ និស្សិតពូកែ និស្សិតក្រីក្រ និស្សិតមកពីតំបន់ដាច់ស្រយាល និងនិស្សិតស្រី ។ នាពេលបច្ចុប្បន្ននេះ គ្រឹះស្ថានឧត្តមសិក្សាចំនួន ៧៧ កំពុងដំណើរការ ដែលក្នុងនោះ គ្រឹះស្ថានរបស់រដ្ឋចំនួន ៣៣ និងគ្រឹះស្ថានឯកជនចំនួន ៤៤ ។

• នៅក្នុងគោលនយោបាយជាយុទ្ធសាស្ត្រទី២ ស្តីពី ការកែលម្អគុណភាពនិងប្រសិទ្ធភាពសេវាអប់រំ ថ្វីបើវឌ្ឍនភាពសំខាន់ៗក្នុងកម្មវិធីមួយចំនួន ដូចជា កម្មវិធីសាលាកុមារមេត្រី កម្មវិធីសិក្សានិងការវាយតម្លៃស្តង់ដារ ត្រូវបានធ្វើឱ្យកើតមានឡើងក៏ដោយ ក៏ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ជាពិសេស លើការអភិវឌ្ឍកុមារតូច ការកាត់បន្ថយអត្រាបោះបង់ការសិក្សានិងអត្រាត្រួតថ្នាក់ ការអភិវឌ្ឍសម្ភាររូបវន្ត និងឧត្តមសិក្សា ។ សកម្មភាព ដែលបានអនុវត្ត និង លទ្ធផលសំខាន់ៗ រួមមាន :

- អត្រាឡើងថ្នាក់នៅគ្រប់កម្រិតត្រូវបានកែលម្អ ជាពិសេស នៅបឋមសិក្សាបានកើនឡើងពី ៧៦,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០០៤-២០០៥ ទៅដល់ ៨១,១ ភាគរយ ក្នុងឆ្នាំសិក្សា២០០៧-២០០៨ ។

ដើម្បីបង្កើនល្បឿន នៃនិន្នាការនេះ ក្រសួងបានកែលម្អបទបញ្ជាផ្ទៃក្នុង សម្រាប់សាលាបឋមសិក្សា ដើម្បីកែលម្អអត្រាឡើងថ្នាក់ របស់សិស្ស នៅគ្រប់កម្រិត ។

- ➢ ក្រសួងបានពង្រីកវិសាលភាពនៃកម្មវិធីសាលាកុមារមេត្រី ដើម្បីបង្កើនគុណភាពអប់រំ ។ ក្រសួងបាន អនុម័ត *គោលនយោបាយស្តីពី សាលាកុមារមេត្រី* និង *ផែនការមេសម្រាប់អនុវត្តកម្មវិធីសាលាកុមារមេត្រី* ។ ក្រសួងក៏បានអនុម័ត *គោលនយោបាយស្តីពី ការអប់រំកុមារពិការ ការអនុវត្តថ្នាក់ពន្លឿនការសិក្សា* និង *ផែនការសកម្មភាពសម្រាប់សាកល្បងកម្មវិធីសាលាកុមារមេត្រី* នៅសាលាមធ្យមសិក្សាបឋមភូមិ ។
- ➢ ក្រសួងបានធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដោយបានចេញសេចក្តីណែនាំស្តីពី ការអនុវត្តកម្មវិធីសិក្សាថ្មី សម្រាប់ការអប់រំមូលដ្ឋាន រួមទាំងស្តង់ដារកម្មវិធីសិក្សា និងផែនការសកម្មភាពសម្រាប់ណែនាំគ្រូបង្រៀន ស្តីពី គោលនយោបាយកម្មវិធីសិក្សាថ្មី ព្រមទាំងសេចក្តីណែនាំស្តីពីការរៀបចំមុខវិជ្ជា និងការណែនាំសម្រាប់សិស្សានុសិស្ស ជ្រើសរើសមុខវិជ្ជានៅសាលាមធ្យមសិក្សាទុតិយភូមិ ។ ក្រសួងកំពុងរៀបចំកែលំអក្របខ័ណ្ឌអភិវឌ្ឍ និងផ្គត់ផ្គង់ សៀវភៅសិក្សាគោល ។
- ➢ គ្រឹះស្ថានឧត្តមសិក្សា សាធារណៈនិងឯកជន មួយចំនួន ត្រូវបានធ្វើការវាយតម្លៃ និងប្រកាសទទួលស្គាល់ សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ។
- ➢ ក្រសួងបានអភិវឌ្ឍកម្មវិធីចូលរៀនឡើងវិញ គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ និង កម្មវិធីសមមូលសម្រាប់អប់រំក្រៅប្រព័ន្ធ។
- ➢ អភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍។
- ➢ ធ្វើតេសសមត្ថភាពសិស្សថ្នាក់ទី៣ ទី៦ និងទី ៩ លើមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ។

- នៅក្នុងគោលនយោបាយជាយុទ្ធសាស្ត្រទី៣ ស្តីពីការអភិវឌ្ឍស្ថាប័ននិងសមត្ថភាពដើម្បីអនុវត្តវិមជ្ឈការ *ក្រសួងអប់រំ យុវជន និងកីឡា* បានផ្តោតការយកចិត្តទុកដាក់លើការបញ្ចប់ និងអនុវត្ត*ច្បាប់អប់រំ*និង កិច្ចដំណើរការ*គណៈកម្មការគ្រប់គ្រងថវិកា* ។ *ច្បាប់ស្តីពីការអប់រំ* ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយ*រាជរដ្ឋាភិបាលកម្ពុជា* កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។ ក្រសួងកំពុងរៀបចំផែនការសកម្មភាព ដើម្បីកែលម្អលិខិតបទដ្ឋានដទៃទៀត។ សកម្មភាពដែលបានអនុវត្ត និង លទ្ធផលសំខាន់ៗរួមមាន :
    - ➢ ក្រសួងបានកសាង*ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០* និង បំប៉នសមត្ថភាពស្តីពីចំណេះដឹងយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។
    - ➢ ក្រសួងបានចេញ*សេចក្តីណែនាំលេខ ៤៨០ អយក.សជណ* ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់*ក្រសួងអប់រំ យុវជន និងកីឡា* ស្តីពីមុខងារភារកិច្ចនិងការរៀបចំឯកសារលិខិតយុត្តិការរបស់អង្គភាព

ដែលគ្រប់គ្រងនិងប្រើប្រាស់ថវិកា តាមកម្មវិធីនៅរដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ។

- *អនុក្រឹត្យលេខ ១២៦ អនក្រ.បក* ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ។
- *អនុក្រឹត្យលេខ ៨៤ អនក្រ.បក* ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ *ក្រសួងអប់រំ យុវជន និងកីឡា*។
- ក្រសួងបានរៀបចំសេចក្តីព្រាង *ផែនការយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការការងារអប់រំ*។
- ក្រសួងកំពុងខិតខំប្រឹងប្រែងថែមទៀត ជាពិសេស ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន ។

២១៥. ថ្វីបើវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឱ្យកើតមានដូចនេះក្តី ក៏ផែនការសកម្មភាពចាំបាច់មួយចំនួនទៀត ចាំបាច់ត្រូវរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ ។ បញ្ហាប្រឈមទាំងនោះ ទាក់ទងនឹងការសម្រេចឱ្យបាន គោលនយោបាយជាអាទិភាពក្នុងគោលដៅជំរុញការទទួលបានសេវាអប់រំ ។ នាពេលបច្ចុប្បន្ននេះ លទ្ធភាពទទួលបានសេវាអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ មិនទាន់ធានាបានសមធម៌ពេញលេញនៅឡើយ ជាពិសេស សម្រាប់កុមារនៅក្នុងក្រុមផ្សេងៗគ្នា ។ កុមារភាគច្រើនក្នុងចំណោមកុមារដែលពុំទាន់បានទទួលសេវាអប់រំ រួមមានដូចជា កុមារជួបការលំបាកផ្នែកសេដ្ឋកិច្ចគ្រួសារ ជនជាតិភាគតិច និងប្រជា-ពលរដ្ឋនៅតំបន់ដាច់ស្រយាល ។ កត្តាផ្សេងៗទៀត ដែលរាំងមិនឱ្យទទួលបានការអប់រំ រួមមាន :

- ចំណាយសម្រាប់ការសិក្សា ដូចជា ការធ្វើដំណើរ សម្ភារសិក្សា ឯកសណ្ឋាន អាហារ ។ល។
- ពលកម្មកុមារចំណាកស្រុក (ស្ត្រីធ្វើការក្នុងរោងចក្រ) ដែលភាគច្រើនប៉ះពាល់ដល់សិស្សនៅមធ្យមសិក្សាបឋមភូមិ ។
- បញ្ហាសង្គម ពិការភាព និងភាពក្រីក្រ ។
- សុខភាពកុមារ និងអាហារូបត្ថម្ភ ។

២១៦. បញ្ហាប្រឈមផ្សេងៗទៀតដែលត្រូវដោះស្រាយរួមមាន :

- ប្រព័ន្ធអប់រំត្រូវធ្វើវិមជ្ឈការនិងវិសហមជ្ឈការ ឱ្យស្របទៅនឹងច្បាប់អង្គការ និងកម្មវិធីថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ ។
- សាលារៀនមិនគ្រប់កម្រិតថ្នាក់នៅមានប្រមាណ ១៨ភាគរយ ទៀតដែលត្រូវធ្វើការកាត់បន្ថយ ។
- ការពង្រីកអនុវិទ្យាល័យពុំទាន់បានគ្រប់ឃុំ-សង្កាត់នៅឡើយ (នៅខ្វះប្រមាណ ៤០០សាលាទៀត បន្ទាប់ពីគម្រោង *ធនាគារអភិវឌ្ឍន៍អាស៊ី* និង *ធនាគារពិភពលោក* ត្រូវបានបញ្ចប់) ។

- កង្វះគ្រូ និងផ្ទះស្នាក់នៅសម្រាប់គ្រូបង្រៀននៅតំបន់ជនបទដាច់ស្រយាល ជាពិសេស គ្រូបង្រៀន កម្រិតឧត្តមសិក្សា ។
- ការផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សិស្សានុសិស្សពុំទាន់ពេលវេលា និងមិនទាន់គ្រប់គ្រាន់តាមតម្រូវការរបស់សាលារៀន។
- ការអនុវត្តកម្មវិធីសិក្សាថ្មីសម្រាប់មធ្យមសិក្សាទុតិយភូមិ ពុំទាន់ឆ្លើយតបទៅនឹងផែនការគោល។
- អត្រាត្រួតថ្នាក់និងបោះបង់ការសិក្សា នៅមានកម្រិតខ្ពស់ ដែលត្រូវខិតខំកាត់បន្ថយ ។
- ការបាត់ម៉ោងបង្រៀននិងរៀន ដោយសារគ្រឹះស្ថានសិក្សាខ្លះខ្វះបន្ទប់រៀន និងការមិនយកចិត្តទុកដាក់ចំពោះបុគ្គលិកអប់រំមួយចំនួន។
- ការគ្រប់គ្រងតាមបែបទម្លាប់ ពុំទាន់ឆ្លើយតបទៅនឹងការរីកចម្រើននៃប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា ។
- នាយកសាលាពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តវិមជ្ឈការ ដូចជាការគ្រប់គ្រងសាលារៀនតាមបែបការគ្រប់គ្រងផ្តោតលើលទ្ធផល ការគ្រប់គ្រងថ្នាក់រៀន ការរៀននិងបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការប្រើប្រាស់ថវិកា ។
- ថ្នាក់រៀនសម្រាប់សិស្សពិការនៅមានតិចតួច ។
- កែលម្អតេស្តស្តង់ដារ ដើម្បីវាស់វែងពីលទ្ធផលនៃការសិក្សារបស់សិស្សនៅថ្នាក់ទី៣ ទី៦ ទី៩ និង ទី១២។
- កែលម្អភាពទាក់ទងរបស់កម្មវិធីសិក្សា ដែលជាផ្នែកមានសារៈសំខាន់មួយក្នុងការកាត់បន្ថយការបោះបង់ការសិក្សា។
- កង្វះឱកាសការងារសម្រាប់គ្រូបង្រៀន រួមបញ្ចូលទាំង ស្តង់ដារក្នុងការជ្រើសរើស ដំឡើងឋានៈ ដំឡើងបៀវត្សរ៍ និង ការអភិវឌ្ឍវិជ្ជាជីវៈទូទៅ ដែលនឹងត្រូវដោះស្រាយ ក្នុងពេលឆាប់ៗនេះ។
- ការឧបត្ថម្ភរបស់រដ្ឋាភិបាលក្នុងការចូលរៀននៅឧត្តមសិក្សា ជាបរិមាណនៅមានសភាពទ្រើង ថ្វីបើចំនួននិស្សិតចូលរៀនមានការកើនឡើង ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ក៏ដោយ។

## ៦.២ ការលើកកម្ពស់សេវាសុខាភិបាល

២១៧. វឌ្ឍនភាពក្នុងការលើកកម្ពស់ការផ្តល់សេវាសុខភាព មានសភាពធំធេង គួរឱ្យកោតសរសើរ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានប្រកាន់យកនូវ *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* ដើម្បីតម្រង់ទិសដល់ការអភិវឌ្ឍនៃវិស័យ ។ ដំណើរការនៃការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ បានចាប់ផ្តើម ក្នុងឆ្នាំ១៩៩៩ ហើយ *ការពិនិត្យរួមគ្នាលើវិស័យសុខាភិបាល* បានចាប់ផ្តើម នៅខែធ្នូ ឆ្នាំ២០០០ ។ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០០៣-២០០៧* ត្រូវបានរៀបចំឡើងដោយផ្តល់នូវក្របខ័ណ្ឌមួយ សម្រាប់ដៃគូអភិវឌ្ឍន៍បី -- *ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិចក្រភពអង់គ្លេស ធនាគារពិភពលោក* -- ដើម្បីធ្វើការសម្របសម្រួលជំនួយហិរញ្ញវត្ថុរបស់ពួកគេ ដល់វិស័យសុខា-

ភិបាល តាមរយៈ *គម្រោងទ្រទ្រង់វិស័យសុខាភិបាល (២០០៣-២០០៧)* ។ ការពិនិត្យវាយតម្លៃគ្រប់ជ្រុងជ្រោយនៃ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧* ត្រូវបានធ្វើឡើង ហើយ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ (ផ.យ.ស.២)* ត្រូវបានរៀបចំឡើង ដោយផ្អែកលើរបកគំហើញនៃការពិនិត្យវាយតម្លៃ។ ការអនុវត្ត *ផ.យ.ស.២* បានចាប់ផ្តើម ក្នុងឆ្នាំ២០០៨ ។ ការពិនិត្យរួមគ្នាលើសមិទ្ធផលប្រចាំឆ្នាំ ត្រូវបានរៀបចំយ៉ាងទៀងទាត់ រៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០០២ ដើម្បីត្រួតពិនិត្យតាមដានការអនុវត្ត*ផែនការយុទ្ធសាស្ត្រ* ។

២១៨. ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧* រួមមាន កម្មវិធីចម្បងបីរបស់*ក្រសួងសុខាភិបាល* :

- *សុខភាពបន្តពូជ មាតា-ទារកនិងកុមារ* ។
- *ជំងឺឆ្លង* ។
- *ជំងឺឆ្លងមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត* ។

២១៩. សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ នៅក្នុងការអនុវត្តគោលនយោបាយអាទិភាពនៃ *ផយអជ ២០០៦-២០១០* នៅតាមផ្នែកនៃកម្មវិធីទាំងបី ត្រូវបានធ្វើការសង្ខេប ដូចខាងក្រោមនេះ :

### កម្មវិធីទី១ : សុខភាពបន្តពូជ មាតា-ទារកនិងកុមារ

២២០. វឌ្ឍនភាពគួរឱ្យកត់សម្គាល់កំពុងកើតមាន លើការពង្រីកការផ្តល់សេវានៅក្រោម កម្មវិធីសុខភាពបន្តពូជ មាតា-ទារក និងកុមារ ដែលបានឆ្លុះបញ្ចាំងពីភាពប្រសើរឡើងនៃសូចនាករស្នូល នៃកម្មវិធីសុខភាពបន្តពូជ មាតា-ទារកនិងកុមារ ក្នុងអំឡុងពេលពី ឆ្នាំ២០០៦-២០០៨ (តារាងទី១) ។ សមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ រួមមាន :

- សមាមាត្រនៃស្ត្រីបានសម្រាលកូន ដោយបុគ្គលិកសុខាភិបាលមានការបណ្តុះបណ្តាលបានកើនឡើងពី ៣៩ ភាគរយ ក្នុងឆ្នាំ ២០០៦ ដល់ ៥៨ ភាគរយ ក្នុងឆ្នាំ ២០០៨ ។
- សមាមាត្រនៃស្ត្រីបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល បានកើនឡើងពី ១៩.៣ ភាគរយ ក្នុងឆ្នាំ ២០០៦ ដល់ ៣៩ ភាគរយ ក្នុងឆ្នាំ២០០៨ ។
- ការកើនឡើងគួរឱ្យកត់សម្គាល់នៃការសម្រាលកូននៅមណ្ឌលសុខភាព ។
- ក្នុងឆ្នាំ២០០៨ ៨១ ភាគរយ នៃស្ត្រី បានទទួលការពិនិត្យផ្ទៃពោះមុនសម្រាល ២ដង ឬ ច្រើនដង ដោយបុគ្គលិកសុខាភិបាល ក្នុងអំឡុងពេលមានគភ៌ ប្រៀបធៀបនឹងឆ្នាំ ២០០៦ ដែលមានតែ ៦០ ភាគរយ ។
- ការកើនឡើង នៃសមាមាត្រមាតាដែលសម្រាលកូន ដោយធ្វើការវះកាត់ ។ អត្រានៃការវះកាត់នេះគឺជាសូចនាករតំណាង សម្រាប់ការចូលមកទទួលយក *សេវាសង្គ្រោះផ្ទៃទាំសម្ភពបន្ទាន់និងផ្ទៃទាំទារក* ហើយ កំណើននេះក៏បញ្ជាក់ផងដែរថា ចំនួនស្ត្រីកាន់ច្រើនឡើង ត្រូវបានបញ្ជូនមកកាន់មន្ទីរពេទ្យបង្អែក

ដែលនៅទីនោះ មានសេវាសង្គ្រោះជីវិត ។ ទោះជាដូចនេះក្តី ក៏ការពង្រាយមិនទាន់សព្វ នៅទូទាំងប្រទេស នៃ សេវាវះកាត់និងសេវាសង្គ្រោះថែទាំសម្ភពបន្ទាន់និងថែទាំទារក នេះ គឺជាបញ្ហាប្រឈមមួយ ហើយការត្រួតពិនិត្យតាមដានអត្រាវះកាត់យកទារក នៅតាមស្រុកប្រតិបត្ត គឺជា ការងារសំខាន់ ដែលត្រូវដោះស្រាយ នៅពេលអនាគត ។

- សុខភាពកុមារ ត្រូវបានលើកកម្ពស់យ៉ាងច្រើន ក្នុងរយៈពេល ពីឆ្នាំ២000 ដល់ ២០០៥ ។ អត្រាស្លាប់របស់កុមារអាយុក្រោម១ឆ្នាំ និងក្រោម៥ឆ្នាំ បានថយចុះប្រមាណ ៣0ភាគរយ ។ កំណើនជាបន្តបន្ទាប់នៃការគ្របដណ្តប់ការផ្តល់ថ្នាំបង្ការ បានធ្វើឱ្យ ការគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការជំងឺកញ្ជ្រឹល កើនឡើងលើសពី ៨0 ភាគរយ ។ ការសម្រេចចិត្តក្នុង ការប្រើប្រាស់វ៉ាក់សាំង Hib ក្នុងឆ្នាំ២០១០ និង ការបន្ថែមវ៉ាក់សាំងការពារជំងឺរលាកស្រោមខួរក្បាល នឹងត្រូវធ្វើឡើង ក្នុងពេលអនាគតដ៏ខ្លីខាងមុខ ។ ការផ្តល់វិញ្ញាបនបត្របញ្ជាក់ពីការលុបបំបាត់ជំងឺតេតាណុស នឹងអាចធ្វើឡើងនៅឆ្នាំក្រោយ ។
- ការគ្របដណ្តប់នៃមណ្ឌលសុខភាព ដែលអនុវត្ត *យុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារ* ត្រូវបានបង្កើន ។ ចំនួនសរុបនៃបុគ្គលិកសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលអំពី *យុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារ* បានកើនឡើងជាលំដាប់ ហើយការគ្របដណ្តប់ សម្រេចបាន៦៥ភាគរយ នៅក្នុងឆ្នាំ២០០៨ ទៅតាមចំណុចដៅដែលបានគ្រោងទុក ។ ទោះបីជា ចំនួនមណ្ឌលសុខភាពដែលមានបុគ្គលិក២នាក់ ឬ ច្រើននាក់ ដែលបានទទួលការបណ្តុះបណ្តាល អំពី *យុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារ* បានកើនឡើងពី ៥៨ ភាគរយ ក្នុងឆ្នាំ២០០៧ ដល់ ៦៩ ភាគរយ ក៏ដោយ ក៏ការរក្សានូវគុណភាពសេវាកម្មរបស់ *យុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារ* គឺជាប្រការចាំបាច់ ។

**តារាងទី៤ : សូចនាករស្តែលនៃកម្មវិធីសុខភាពបន្តពូជ មាតា-ទារក និងកុមារ**

| សូចនាករ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|
| %នៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាល | ១៩.៣ | ២៥.៥ | ៣៩ |
| %នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលបានទទួលការបណ្តុះបណ្តាល | ៣៩ | ៤៦ | ៥៨ |
| ពិនិត្យផ្ទៃពោះមុនសម្រាល ២ដង ឬ ច្រើនដងដោយបុគ្គលិក សុខាភិបាល(%) | ៦0 | ៦៨ | ៨១ |
| % នៃការសម្រាលកូនដោយវះកាត់ | - | ១.១៣ | ២ |
| អត្រាប្រើប្រាស់វិធីពន្យារកំណើតទំនើប % | ២៣ | ២៤ | ២៦ |
| % សមាមាត្រនៃកុមារអាយុក្រោមមួយឆ្នាំដែលបានទទួលថ្នាំបង្ការ DPT3-HepB | ៨១ | ៨២ | ៩២ |
| % សមាមាត្រនៃកុមារអាយុក្រោមមួយឆ្នាំដែលបានទទួលថ្នាំបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណុស និងរលាកថ្លើមប្រភេទបេ លើកទី៣ | ៧៨ | ៩0 | ៩១ |
| ការពិគ្រោះជំងឺ (ករណីថ្មី) លើ កុមារក្រោម៥ ឆ្នាំ ម្នាក់ ក្នុងមួយឆ្នាំ | ១ | ១ | ១.១ |
| ចំនួនមណ្ឌលសុខភាពអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារ | ៤៥៦ | ៥៥៦ | ៦៦0 |

*ប្រភព: របាយការណ៍ស្ថិតិសុខាភិបាលប្រចាំឆ្នាំ ២០០៨ - ក្រសួងសុខាភិបាល*

២២១. បញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្ត *កម្មវិធីសុខភាពបន្តពូជ មាតា-ទារក និងកុមារ* រួមមាន ៖

- ស្ថានភាពសុខភាព និងអត្រាប្រើប្រាស់សេវាសុខភាព នៅក្នុងក្រុមប្រជាជន ដែលមានស្ថានភាពសង្គម-សេដ្ឋកិច្ចខុសៗគ្នា បង្ហាញឱ្យឃើញអំពីបញ្ហាសមធម៌ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ថែមទៀត ។
- ការពង្រាយមិនទាន់សព្វ នៅទូទាំងប្រទេស នៃ*សេវាសង្គ្រោះថែទាំសម្ភពបន្ទាន់និងថែទាំទារក* និងភាពចាំបាច់ក្នុងការបង្កើនគុណភាពនៃសេវាថែទាំបន្តសម្រាប់ *កម្មវិធីសុខភាពបន្តពូជ មាតា-ទារក និងកុមារ* ។
- អត្រាស្លាប់របស់មាតា នៅតែខ្ពស់មិនទាន់អាចទទួលយកបាន ហើយ ត្រូវការចាំបាច់នូវការវិនិយោគជាបន្តបន្ទាប់ថែមទៀតក្នុងការផ្តល់សេវា និងក្នុងអន្តរាគមន៍បន្ទាន់ ។ ទោះជាដូច្នេះក្តី ក៏មានការទទួលស្គាល់ថា ការស្លាប់របស់មាតា គឺជាបញ្ហាអន្តរវិស័យដែលរងឥទ្ធិពលពី ការអប់រំនិងអក្ខរកម្មរបស់ស្ត្រី ការអភិវឌ្ឍ-ហេដ្ឋារចនាសម្ព័ន្ធ និង កម្រិតនៃការចូលរួមរបស់ស្ត្រី ព្រមទាំង បញ្ហាសមធម៌ផ្នែកយេនឌ័រ ។
- អន្តរាគមន៍ដែលចេញពីផ្នែកតម្រូវការ មានសារៈសំខាន់ ក្នុងការបង្កើនការប្រើប្រាស់សេវានានា ដែលបានកែលម្អរួចហើយ តាមរយៈ ការផ្តល់សេវាថែទាំបន្តដែលបានកំណត់ច្បាស់លាស់ ។
- ភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៃស្ថានភាពសុខភាពរបស់មាតានិងកុមារ ព្រមទាំង វិសមធម៌ ក្នុងការប្រើប្រាស់សេវា និងលទ្ធភាពចូលមកទទួលយកសេវា រវាងក្រុមប្រជាជនអ្នកមានធូរធាបំផុត និងក្រុមប្រជាជនអ្នកក្រីក្របំផុត ។

### កម្មវិធីទី២ : ជំងឺឆ្លង

២២២. ប្រទេសកម្ពុជាបានឆ្លងកាត់ការអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង ដែលបានបង្ហាញថា សមិទ្ធផលដ៏ធំធេងអាចសម្រេចបាន នៅពេលដែលមានធនធានគ្រប់គ្រាន់ ។ វឌ្ឍនភាពបច្ចុប្បន្ន កំពុងស្ថិតនៅលើផ្លូវត្រូវ ឆ្ពោះទៅសម្រេចបាននូវ *គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា* ផ្នែកជំងឺឆ្លង ។ នៅខណៈពេលដែលសារៈសំខាន់នៃជំងឺឆ្លងនៅក្នុងក្រខណ្ឌ័ទូលំទូលាយនៃជំងឺ បានថយចុះក៏ដោយ ក៏ការប្រុងប្រយ័ត្ន នៅតែជាប្រការ ដែលត្រូវបន្តយកចិត្តទុកដាក់ជាប្រចាំ ។ ការត្រៀមលក្ខណៈក្នុងកម្រិតខ្ពស់ ត្រូវតែបន្តយកចិត្តទុកអនុវត្ត ដើម្បីកាត់បន្ថយជាអប្បបរមានូវហានិភ័យពីការលេចឡើងនៃជំងឺថ្មីៗ និងការលេចឡើងសារជាថ្មីនៃជំងឺចាស់ដែល បានកើតមានរួចមកហើយ ។

២២៣. ប្រទេសកម្ពុជាមានអាំងស៊ីដង់នៃជំងឺរបេងខ្ពស់ ក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច គឺ ៤៩៥ ករណី លើប្រជាជន ១០០ ០០០នាក់ ក្នុងមួយឆ្នាំ ។ ការគ្របដណ្តប់នៃ *វិធីសាស្ត្រព្យាបាលដោយត្រួតពិនិត្យផ្ទាល់ពីមូលដ្ឋាន* នៃជំងឺរបេង (Basic Directly Observed Treatments- DOTS) បានឈានដល់ ១០០ភាគរយ នៃមណ្ឌលសុខភាព រីឯ DOTS តាមសហគមន៍ត្រូវបានពង្រីក ដល់មណ្ឌលសុខភាពចំនួន ៥០៦ ។ ភាពជាដៃគូរវាងផ្នែកសាធារណៈនិងឯកជន ក្នុងវិធីសាស្ត្រ DOTS កំពុងត្រូវបានពង្រីក ដល់ ១១ខេត្ត ហើយសកម្មភាពសហការលើផ្នែកជំងឺរបេង

មានផ្ទុកកមេរោគអេដស៍ មាននៅ ៥៧ស្រុកប្រតិបត្តិ ។ អត្រាព្យាបាលជាសះស្បើយនៃជំងឺរបេង ត្រូវបានរក្សាបានខ្ពស់ជាង ៨៥ភាគរយ ក្នុងរយៈពេល ១២ឆ្នាំ ជាប់ៗគ្នា ។ អត្រានៃការស្រាវជ្រាវករណីរបេងបានកើនឡើងពី ៦៥.៤ភាគរយ ទៅ ៦៩ភាគរយ ក្នុងឆ្នាំ២០០៨ ។ គម្រោងសម្រាប់ជំងឺរបេងស៊ាំនឹងឱសថ កំពុងត្រូវបានអនុវត្តសាកល្បង ។

២២៤. ការគ្របដណ្តប់នៃយុទ្ធសាស្ត្រមុងជ្រលក់ថ្នាំ បច្ចុប្បន្ន គ្របដណ្តប់ ៧៥.៦ភាគរយ នៃប្រជាជនរស់នៅក្នុងតំបន់ជំងឺគ្រុនចាញ់ ខ្ពស់មានលំនៅឋានស្ថិតនៅ ២គ.ម ពីព្រៃ ។ ចំនួនអ្នកស្ម័គ្រចិត្តភូមិ បានកើនឡើងពី ១ ៧៣៤ នាក់ ក្នុងឆ្នាំ២០០៨ ដល់ ២ ០០០នាក់ នៅឆ្នាំ២០០៨ ហើយអ្នកស្ម័គ្រចិត្តភូមិធ្វើការងារគ្រុនចាញ់ បានកើនពី ៣៨០នាក់ ក្នុងឆ្នាំ២០០៤ ដល់ ៨០០នាក់ នៅឆ្នាំ២០០៨ ។ ករណីថ្មីនៃជំងឺគ្រុនចាញ់ បានថយចុះពី ៧.៥ ក្នុងប្រជាជន ១០០០នាក់ ក្នុងឆ្នាំ២០០៤ មក ៤.១ ក្នុងប្រជាជន ១ ០០០នាក់ ក្នុងឆ្នាំ២០០៨ ។ ប្រេវ៉ាឡង់នៃជំងឺគ្រុនចាញ់បានថយចុះពី ៤.២ភាគរយ ក្នុងឆ្នាំ២០០៤ មក ២.៩ភាគរយ ក្នុងឆ្នាំ២០០៧ ។ អត្រាស្លាប់នៃជំងឺគ្រុនចាញ់ ក៏បានថយចុះពី ២.៨ ក្នុងប្រជាជន ១០០ ០០០នាក់ ក្នុងឆ្នាំ២០០៤ មក ១.៤៦ ក្នុងប្រជាជន ១០០ ០០០ នាក់ ក្នុងឆ្នាំ២០០៨ ។

២២៥. ការគ្របដណ្តប់ នៃការប្រយុទ្ធជំងឺគ្រុនឈាមនៅតាមសាលារៀន ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានកើនឡើងពី ១០៧សាលាបឋមសិក្សា ក្នុងឆ្នាំ២០០៤ ដល់ ១៥៩សាលា ក្នុងឆ្នាំ២០០៨ ។ ករណីថ្មីនៃជំងឺគ្រុនឈាមបានថយចុះពី ៩៩៨៣ករណី (៧៨.២/១០០ ០០០នាក់) ក្នុងឆ្នាំ២០០៤ មក ៩៥៤២ករណី (៦៥/១០០ ០០០) ក្នុងឆ្នាំ២០០៨ ។ រីឯ អត្រាស្លាប់ដោយជំងឺគ្រុនឈាម ក៏បានថយចុះពី ៩០ករណី (០.៩០ ភាគរយ) ក្នុង ឆ្នាំ២០០៤ មក ៦៥ករណី (០.៦៨ ភាគរយ) ក្នុងឆ្នាំ២០០៨ ។

២២៦. ក្រុមឆ្លើយតបរហ័ស ត្រូវបានបង្កើតឡើងចាប់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មណ្ឌលសុខភាព ។ មុខងាររបស់ក្រុមការងារនេះគឺ : ការស្រាវជ្រាវទាន់ពេលវេលាចំពោះករណីផ្ទុះជំងឺរាតត្បាត តាមរយៈយន្តការដែលផ្អែកលើប្រព័ន្ធតាមដានជំងឺ និងការឆ្លើយតបទៅនឹងការផ្ទុះជំងឺរាតត្បាត ដោយក្រុមការងារនៅតាមមូលដ្ឋានពេញ ២៤ម៉ោង -- ការផ្គត់ផ្គង់បរិក្ខារមន្ទីរពិសោធន៍សម្រាប់ការវិភាគសំណាកគំរូ និងសំភារៈការពារខ្លួនបុគ្គលិកដើម្បីការពារក្រុមការងារដែលជាផ្នែកមួយនៃការត្រៀមរៀបចំទុកជាមុន -- ការបណ្តុះបណ្តាលបុគ្គលិកស្តីពីការឆ្លើយតបដោយរាប់បញ្ចូលទាំង ការគ្រប់គ្រងករណីសង្ស័យ នៃជំងឺផ្តាសាយលើមនុស្ស ។ បន្ថែមពីលើការស្រាវជ្រាវករណីផ្ទុះជំងឺរាតត្បាត ក្រុមឆ្លើយតបរហ័ស នៅមានភារៈកិច្ចប្រមូលទិន្នន័យព័ត៌មានអំពីជំងឺឆ្លងជាប្រចាំ និងរាយការណ៍ទៅថ្នាក់លើបន្ទាប់ ។ សូចនាករនៃប្រព័ន្ធប្រកាសអាសន្នដំបូងនិងការឆ្លើយតប ដោយផ្អែកលើប្រព័ន្ធរបាយការណ៍សូន្យ កំពុងគ្របដណ្តប់ ១២ ជំងឺ និងរោគសញ្ញា ។ ការផ្តល់ទិន្នន័យព័ត៌មាន ប្រព្រឹត្តទៅតាមប្រព័ន្ធផ្ញើសារ ទៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលនៅទីនោះ ការវិភាគទិន្នន័យ និងរបាយការណ៍ នឹងត្រូវបានធ្វើឡើងជាស្វ័យប្រវត្តិ ដោយប្រព័ន្ធកុំព្យូទ័រ ។

២២៧. មេរោគអេដស៍/ជំងឺអេដស៍ លទ្ធផលនៃការពង្រីកដ៏ទូលំទូលាយនៃសេវាបង្ការ ថែទាំ និងព្យាបាល ធ្វើឱ្យករណីថ្មីនៃការចម្លងមេរោគអេដស៍ បានថយចុះយ៉ាងខ្លាំងចាប់ពី ឆ្នាំ២០០០ មក ហើយ ឥឡូវនេះ មានអត្រាតែ ០,៩ ភាគរយ ប៉ុណ្ណោះ[១] គឺតិចជាងពាក់កណ្ដាលនៃអត្រា ១,៩ ភាគរយ ដែលបានប្រមាណទុកនៅដើមឆ្នាំ២០០៥ ។ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០ ភាគរយ សម្រាប់បង្ការជំងឺអេដស៍គ្របដណ្ដប់រាជធានី និង ២៣ ខេត្ត ហើយ កម្មវិធីចុះតាមមូលដ្ឋាននិងអប់រំក្នុងចំណោមក្រុមជនដែលស្ថានភាពសង្គមដូចគ្នា បានសម្រេចរហូតជាង ៩០ ភាគរយ នៃអ្នកបម្រើការនៅតាមកន្លែងកម្សាន្តនានា ក្នុងឆ្នាំ២០០៨ ។ ការគ្រប់គ្រងករណីជំងឺកាមរោគ បាន និងកំពុងផ្ដល់នៅតាមគ្លីនិកឯកទេសចំនួន ៣២ ក្នុង ២៣ ខេត្ត សម្រាប់ប្រជាជនដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ ហើយវិធីសាស្ត្រព្យាបាលតាមរោគសញ្ញានៃជំងឺកាមរោគ ត្រូវបានដាក់បញ្ចូល នៅមណ្ឌលសុខភាពចំនួន ២២២ សម្រាប់ ប្រជាជនទូទៅ ។ សេវាផ្ដល់ការប្រឹក្សានិងធ្វើតេស្តឈាមដោយសម្ងាត់និងស្ម័គ្រចិត្ត ត្រូវបានពង្រីករហូតដល់ ២១២ កន្លែង នៅទូទាំងប្រទេស ។ នៅឆ្នាំ២០០៨ មានប្រជាជន ៣៩២ ៣១៥ នាក់ ត្រូវបានធ្វើតេស្តឈាមដើម្បីរកមើលមេរោគអេដស៍ ។

២២៨. ការថែទាំអ្នកផ្ទុកមេរោគអេដស៍តាមផ្ទះនិងតាមសហគមន៍ ត្រូវបានពង្រីកដល់ ៦៥៧ មណ្ឌលសុខភាពក្នុង ២០ ខេត្ត ។ សេវាព្យាបាលជំងឺឱកាសនិយម/ការព្យាបាលដោយប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ ត្រូវបានពង្រីក ដល់ ៥១ កន្លែង នៅតាមមន្ទីរពេទ្យបង្អែក/ស្រុកប្រតិបត្តិ ៣៩ ក្នុង ២០ខេត្ត ។ អ្នកជំងឺដែលស្ថិតក្នុងដំណាក់កាលខ្ពស់នៃជំងឺអេដស៍ សរុប ៣១ ៩៩៩ នាក់ (លើសពី ៩០ភាគរយ នៃអ្នកទាំងនេះត្រូវការឱសថប្រឆាំងមេរោគអេដស៍) បច្ចុប្បន្នកំពុងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ ក្នុងនោះមានកុមារ ៣ ០៦៧ នាក់។ លើសពីនេះទៀត អ្នកជំងឺ ១២ ៨០៥ នាក់ កំពុងទទួលការព្យាបាលបង្ការជំងឺឱកាសនិយម ។ អត្រារស់រានមានជីវិតនៃអ្នកជំងឺអេដស៍ ក្រោយរយៈពេល ១២ខែ នៃការព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍ មានកម្រិតខ្ពស់ លើសពី ៨៥ ភាគរយ ក្នុងឆ្នាំ២០០៨ ។

២២៩. *អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍* គឺជាស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវលើការងារសម្របសម្រួល និង ត្រួតពិនិត្យតាមដានការឆ្លើយតបយ៉ាងទូលំទូលាយទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ កម្រិតជាតិ និងកម្រិតពហុវិស័យ ។ ផែនការយុទ្ធសាស្ត្រជាតិដ៏ទូលំទូលាយនិងមានលក្ខណៈពហុវិស័យ លើកទី២ ឆ្នាំ ២០០៦-២០១០ ដែលបានរៀបចំឡើងដោយមានការចូលរួម ពីស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ កំពុងតែអនុវត្តប្រកបដោយជោគជ័យ ក្នុងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា ។ សមិទ្ធផលចម្បងៗ ដែលសម្រេចបាននៅក្នុងផែនការនេះគឺ :

---

[១] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ បានកំណត់តួលេខនេះស្មើនឹង ០,៦ ភាគរយ ប៉ុន្តែការឯកភាពគ្នាក្នុងពេលក្រោយមកទៀត ក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ បានកែសម្រួលតួលេខនេះទៅជា ០,៩ ភាគរយ វិញ ។

- ពិនិត្យជារួម អត្រាផ្ទុក អត្រាឆ្លង និងអត្រាស្លាប់ដោយសារជំងឺអេដស៍ ត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ដោយជោគជ័យ ។
- តាមរយៈការប្រើប្រាស់ទិន្នន័យអង្កេតអត្រាផ្ទុក(ប្រេវ៉ាឡង់)មេរោគអេដស៍ឆ្នាំ ២០០៦ និងយោងតាមការទស្សទាយ ដោយប្រើប្រាស់ម៉ូដែលអេពីដេមីសាស្ត្រនៅអាស៊ី គេបានរកឃើញថា អត្រាផ្ទុក (ប្រេវ៉ាឡង់) មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ មានស្ថានភាពថេរក្នុងអត្រាត្រឹមតែ ០,៧ ភាគរយ ក្នុងឆ្នាំ២០០៩ គឺដូចគ្នានឹង ឆ្នាំ២០០៨ ដែរ ។ ប្រការសំខាន់ដែលយើងត្រូវកត់សម្គាល់នោះ គឺថា អត្រានេះបានថយចុះជាបន្តបន្ទាប់ ពីចំណុចកំពូល ២ ភាគរយ ក្នុង ឆ្នាំ១៩៩៨ មកនៅត្រឹម ០,៧ ភាគរយ នៅឆ្នាំ២០០៩ ។ ប្រសិនបើលទ្ធផលនៃការឆ្លើយតបកម្រិត បច្ចុប្បន្ន មានចិរភាព នោះគេរំពឹងថា អត្រាផ្ទុកមេរោគអេដស៍នឹងបន្តថយចុះរហូតដល់ ០,៦ភាគរយ ក្នុងឆ្នាំ ២០១២ ។
- មនុស្សពេញវ័យ ក្នុងអាយុ ពី១៥-៤៩ឆ្នាំ ដែលកំពុងតែផ្ទុកមេរោគអេដស៍ នៅក្នុងឆ្នាំ២០០៩ មានចំនួនសរុបប្រមាណ ៥៧ ៩០០ នាក់ ក្នុងនោះ ស្ត្រីមានចំនួន ៣០ ៣០០ នាក់ និង បុរសមានចំនួន ២៧ ៦០០ នាក់ គឺមានចំនួនទាបជាង ឆ្នាំ២០០៨ បន្តិច (៥៨ ៧០០ នាក់) ។
- ករណីឆ្លងថ្មីនៃមេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុពី១៥-៤៩ឆ្នាំ បានបន្តធ្លាក់ចុះហើយមានចំនួនសរុបប្រមាណ ៧៤០ នាក់ ក្នុងនោះ បុរសមានចំនួនប្រមាណ ៤១០ នាក់ និង ស្ត្រីមានចំនួនប្រមាណ ៣៣០នាក់ នៅក្នុងឆ្នាំ២០០៩ គឺមានកម្រិតទាបជាង ឆ្នាំ២០០៨ ។
- ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍ បានបន្តធ្លាក់ចុះពី ៣ ៥៩០ នាក់ នៅក្នុងឆ្នាំ២០០៨ ទៅ ១ ២១០ នាក់ នៅក្នុងឆ្នាំ២០០៩ អាស្រ័យដោយហេតុថា លទ្ធភាពក្នុងការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ មានកម្រិតខ្ពស់ជាងមុន ។
- អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទតាមផ្ទះបន បានថយចុះមកនៅត្រឹម ១៤ ភាគរយ ក្នុងឆ្នាំ២០០៦ ដោយបានធ្លាក់ចុះយ៉ាងលឿនពី កម្រិតខ្ពស់បំផុត ៤៥,៨ ភាគរយ នៅក្នុងឆ្នាំ ១៩៩៨ ។
- នៅដំណាច់ឆ្នាំ២០០៩ ៩៧ ភាគរយ នៃមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ ដែលកំពុងស្វែងរកសេវាផ្តល់ឱសថប្រឆាំងមេរោគអេដស៍ បានទទួលឱសថប្រឆាំងមេរោគអេដស៍ ទៅតាមសេចក្តីត្រូវការ ។
- *ការអង្កេតការប្រព្រឹត្តផ្លូវភេទជាប្រចាំ* ឆ្នាំ២០០៧ បានបង្ហាញថា ៩៤ ភាគរយ ស្ត្រីរកស៊ីផ្លូវភេទតាមផ្ទះបន បានប្រើប្រាស់ស្រោមអនាម័យ ជាប់ជានិច្ចជាមួយអតិថិជនរបស់ខ្លួន ដែលជាការរួមចំណែកដ៏សំខាន់ក្នុងការធានាបាននូវជោគជ័យ ក្នុងការកាត់បន្ថយ ការរីករាលដាលមេរោគអេដស៍ ។ អត្រានៃការប្រើប្រាស់ស្រោមអនាម័យ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទដោយប្រយោល បានកើនដល់ ៨៣ ភាគរយ ។ ដោយឡែក អត្រាប្រើប្រាស់ស្រោមអនាម័យដោយប្រយោល នៅក្នុងចំណោមបុរសរួមភេទជាមួយបុរសដូចគ្នា មានកម្រិតត្រឹមតែ ៧៩ ភាគរយ ប៉ុណ្ណោះ ។

- *ការអង្កេតការប្រព្រឹត្តផ្លូវភេទជាប្រចាំ* ឆ្នាំ២០០៧ បានបង្ហាញថា ៩៤ ភាគរយ នៃស្ត្រីរកស៊ីផ្លូវភេទតាមផ្ទះបន ៩១ ភាគរយ នៃស្ត្រីរកស៊ីផ្លូវភេទដោយប្រយោល និង ៩៦ ភាគរយ នៃបុរសរួមភេទជាមួយបុរសដូចគ្នា ត្រូវបានទទួលការអប់រំ ស្តីពីមេរោគអេដស៍និងជំងឺអេដស៍ ។
- ក្នុងឆ្នាំសិក្សា ២០០៨-២០០៩ ប្រមាណ ៣៤,០៧ ភាគរយ នៃសាលារៀនទូទាំងប្រទេស បានចូលរួមក្នុងសកម្មភាព ដែលមាន គោលបំណងផ្តល់ការអប់រំបំណិនជីវិតស្តីអំពី មេរោគអេដស៍និងជំងឺអេដស៍ ។

២៣០. សមិទ្ធផលចម្បងដទៃទៀត រួមមាន ៖

- ការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការឆ្លើយតបដ៏ទូលំទូលាយ និងមានលក្ខណៈពហុវិស័យទៅនឹងការរាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈ ការវិភាគអំពីស្ថានភាព និងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ និងការកំណត់តម្លៃនៃចំណាយលម្អិត ក្នុងឆ្នាំ២០០៧ សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដើម្បីឱ្យបានសមស្របទៅនឹងស្ថានភាពថ្មី នៃការរាលដាលមេរោគអេដស៍ និងការផ្លាស់ប្តូរនូវបទដ្ឋាននៃការប្រឈមមុខនឹងការចម្លងមេរោគអេដស៍ ។
- ផែនការសកម្មភាពនិងផែនការចំណាយជាយុទ្ធសាស្ត្រ ត្រូវបានរៀបចំឡើងនិងពិនិត្យមើលឡើងវិញ សម្រាប់សាមីក្រសួងមួយចំនួន ដោយរាប់បញ្ចូលទាំង *ក្រសួងសុខាភិបាល (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) ក្រសួងកិច្ចការនារី ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* និង សម្រាប់ក្រុមប្រជាជនប្រឈមមុខគ្រោះថ្នាក់ខ្ពស់ ដូចជាអ្នកប្រើប្រាស់គ្រឿងញៀន អ្នកចាក់គ្រឿងញៀន ក្រុមបុរសរួមភេទជាមួយបុរស បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ (តាមផ្ទះបន និង ចល័ត) ។
- ប្រការសំខាន់បំផុតដែលត្រូវយកចិត្តទុកដាក់នោះ គឺការធ្វើសមាហរណកម្មនៃ ជំងឺអេដស៍ សុខភាពបន្តពូជ ជំងឺរបេង និងការពិនិត្យផ្ទៃពោះមុនពេលសម្រាល ទៅក្នុង "ការឆ្លើយតបជាប្រព័ន្ធ" ត្រូវបានជំរុញអនុវត្តយ៉ាងសកម្ម ។
- ការឆ្លើយតបកម្រិតជាតិ បានផ្តោតការយកចិត្តទុកដាក់ច្រើនជាងមុន ទៅលើអាទិភាពគន្លឹះនានា ដែលត្រូវបានណែនាំ ដោយបែបបទនៃការកំណត់គោលដៅ សម្រាប់លទ្ធភាពទទួលបានសេវាជាសកល ដោយមានការចូលរួមពីវិស័យពាក់ព័ន្ធនិងភាគីដទៃទៀត ។
- ទោះបីជា ភាគច្រើននៃចំណុចដៅសម្រាប់លទ្ធភាពទទួលបានសេវាជាសកល ដែលបានកំណត់សម្រាប់ ឆ្នាំ ២០០៨ ត្រូវបានធ្វើឱ្យសម្រេច តាមការកំណត់ ឬលើសពីការកំណត់ ក៏ដោយ ក៏ស្ថានភាពនៃសូចនាករមួយចំនួន បានឆ្លុះបញ្ចាំងឱ្យឃើញថា *រាជរដ្ឋាភិបាល* ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការពង្រីកសេវានានា ជាពិសេស សេវាបង្ការការចម្លងមេរោគអេដស៍ សម្រាប់ក្រុមជនដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (ដែលរួមមាន បុរសស្រឡាញ់បុរសដូចគ្នា អ្នកចាក់គ្រឿងញៀន និងបង្ការការចម្លងមេរោគអេដស៍ ពីម្តាយទៅកូន) និង ក្នុងការកាត់បន្ថយឱ្យនៅម្រិតទាបបំផុត នៃផលប៉ះពាល់នៃជំងឺអេដស៍ទៅលើកុមារកំព្រា និងកុមារងាយរងគ្រោះ ។

- កិច្ចសហប្រតិបត្តិការរវាង ស្ថាប័នរបស់*រាជរដ្ឋាភិបាល* អង្គការក្រៅរដ្ឋាភិបាល អង្គការតាមសហគមន៍ អង្គការសាសនា បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និង ដៃគូអភិវឌ្ឍន៍ ត្រូវបានពង្រឹងជាលំដាប់ ហើយមានសារៈសំខាន់ណាស់ ក្នុងការបង្កើតនិងការអនុវត្តនូវ សេវា បង្ការ ព្យាបាល និង ថែទាំ ប្រកបដោយចីរភាព និងប្រសិទ្ធភាព ។
- ការដឹកនាំ និងការសម្របសម្រួល ដោយ *អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍* ដែលឈរលើ *គោលការណ៍ ៣-១* មានការរីកចម្រើន ហើយ បានផ្តល់នូវបរិយាកាសអំណោយផលដ៏ប្រសើរមួយ ដែលសម្រួលដល់ការរៀបចំគោលនយោបាយ និងការធ្វើផែនការ សម្រាប់ការឆ្លើយតបជាលក្ខណៈពហុវិស័យ ទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ។
- អង្គការសង្គមស៊ីវិល បានបន្តចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការឆ្លើយតបកម្រិតជាតិ នៅក្នុងការងារជាច្រើន ក្នុងនោះរួមមាន ការបង្ការ ការកាត់បន្ថយផលប៉ះពាល់ ការថែទាំ ការគាំទ្រ និង ការព្យាបាល ជាពិសេស ដល់ក្រុមជនដែលប្រឈមនឹងហានិភ័យខ្ពស់ និងក្រុមជនងាយរងគ្រោះ នៅថ្នាក់មូលដ្ឋាន ។
- ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ មេរោគអេដស៍និងជំងឺអេដស៍ ត្រូវបានពង្រឹង តាមរយៈ ការណែនាំស្តីពី*ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃពហុវិស័យនៃមេរោគអេដស៍និងជំងឺអេដស៍ថ្នាក់ជាតិ* ។ សមត្ថភាពនៃប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានលើកកម្ពស់ នៅក្នុង*អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍* នៅតាមក្រសួង-ស្ថាប័ន និង អង្គការសង្គមស៊ីវិល នានា ។
- *ការវាយតម្លៃពីការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍* ត្រូវបានរៀបចំធ្វើឡើង សម្រាប់ឆ្នាំសារពើពន្ធ ២០០៦ ២០០៧ និង ២០០៨ ។

២៣១. បញ្ហាប្រឈមចម្បង ក្នុងការអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺរបេង រួមមាន :

- ការបន្តគំរាមកំហែងដោយជំងឺដែលបានកើតមានរួចមកហើយ រាប់ទាំងជំងឺដែលបានលុបបំបាត់រួចហើយនៅកម្ពុជា ក៏ដូចជាការគំរាមកំហែងដែលកំពុងកើតមាននៃបរិវុបទី ( ការផ្លាស់ប្តូរបម្លែងរូប) នៃវីរុស ។
- ការចម្លងជំងឺឆ្លងកាត់ព្រំដែន ការគំរាមកំហែងនៃជំងឺឆ្លងក្នុងតំបន់ និងពិភពលោក ដូចជា លទ្ធភាពនៃការចម្លងជំងឺគ្រុនផ្តាសាយបក្សី ។
- បន្តការទប់ទល់ដោយប្រុងប្រយ័ត្នមិនធ្វេសប្រហែស មិនឱ្យការីករាលដាលនៃជំងឺឆ្លង ដែលបច្ចុប្បន្ននេះកំពុងថយចុះ មានការកើនឡើងជាថ្មីម្តងទៀត ជាពិសេស ការចម្លងមេរោគអេដស៍ជាថ្មីឡើងវិញ ដែលមានភស្តុតាងបង្ហាញជាអន្តរជាតិ ។
- ថ្លៃចំណាយដ៏ខ្ពស់លើការព្យាបាលផលវិបាកនៃជំងឺឆ្លងរ៉ាំរ៉ៃ ។

២៣២. *អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍* បានកំណត់នូវបញ្ហាប្រឈមមួយចំនួន ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដូចខាងក្រោម :

- ហានិភ័យចម្បងនៃការរីករាលដាលមេរោគអេដស៍ អាចលេចចេញពី ការផ្លាស់ប្តូរឥរិយាបថ ក្នុងទំនាក់ទំនងផ្លូវភេទ ក្នុងចំណោមក្រុមស្ត្រីរកស៊ីផ្លូវភេទ អតិថិជន និងគូសង្សាររបស់ពួកគេ ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកប្រើថ្នាំញៀន ។ អាត្រាផ្ទុកមេរោគអេដស៍ នៅក្នុងចំណោមក្រុមមនុស្ស ដែលមានហានិភ័យខ្ពស់ទាំងនេះ នៅតែមានកម្រិតខ្ពស់នៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនានាក្នុងតំបន់។ ទន្ទឹមនឹងនេះ ការរួមភេទក្រៅពីដៃគូមួយទៅដៃគូមួយផ្សេងទៀត កើតមានកាន់តែច្រើនឡើងនៅក្រៅផ្ទះបន ជាពិសេស ការស្វែង រកការរួមភេទជាមួយគូសង្សារ។ នៅក្នុងទំនាក់ទំនងរបៀបនេះ ការប្រើប្រាស់ស្រោម អនាម័យយ៉ាងទៀងទាត់ មានកម្រិតទាប គួរឱ្យព្រួយបារម្ភ។
- ការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធនៃ ឧស្សាហកម្មអាជីវកម្មផ្លូវភេទ និង ការលំបាកក្នុងការធ្វើឱ្យ*កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ* មានចីរភាព ដោយយោងតាម ការបិទផ្ទះបនទាំងឡាយ ទៅតាមច្បាប់ជាធរមាន បានជំរុញឱ្យមានការខិតខំប្រឹងប្រែងថែមទៀត ដើម្បីស្វែងរកមធ្យោបាយ សម្រាប់លើកកម្ពស់ការប្រើប្រាស់ស្រោមអនាម័យជាប្រចាំ ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកម្សាន្តនានា ដូចជា រង្គសាល ក្លឹបការ៉ាអូខេ ក្លឹបម៉ាស្សា និងភោជនីយដ្ឋានបៀហ្គាដិន ដែលជាកន្លែងរកប្រាក់ចំណូលខ្ពស់របស់អ្នកប្រកបរបរផ្លូវភេទ ។ ដើម្បីដោះស្រាយបញ្ហានេះ *វិធានការប្រតិបត្តិការស្តង់ដារ* ថ្មីមួយ ត្រូវបានរៀបចំបង្កើតឡើង ដោយកំណត់មុខសញ្ញានៃការការពារមេរោគអេដស៍ ជាពិសេស នៅក្នុងក្រុមដែលមានហានិភ័យខ្ពស់ ។
- ហានិភ័យនៃការឆ្លងមេរោគអេដស៍ដែលកំពុងកើនឡើង នៅតែមានកម្រិតខ្ពស់ នៅក្នុងចំណោម បុរសរួមភេទជាមួយបុរសដូចគ្នា ជាពិសេស នៅក្នុងចំណោម អ្នកចាក់គ្រឿងញៀន ដែលអាចមានអត្រាផ្ទុកមេរោគអេដស៍ ២៤ ភាគរយ ។ នៅក្នុងឆ្នាំ២០០៥ ប្រេវ៉ាឡង់មេរោគអេដស៍ នៅក្នុងចំណោមបុរសរួមភេទជាមួយបុរស មានប្រមាណ ៩ ភាគរយ សម្រាប់ប្រជាជនដែលរស់នៅតំបន់ជនបទ និងមានប្រមាណ ១៧ ភាគរយ សម្រាប់ប្រជាជនដែលរស់នៅរាជធានីភ្នំពេញ ។
- ប្រជាជនដែលប្រឈមនឹងហានិភ័យដោយឡែកក្នុងការឆ្លងមេរោគអេដស៍ រួមបញ្ចូលផងដែរនូវ ក្រុមស្ត្រីដែលមានដៃគូបុរសមានហានិភ័យខ្ពស់ក្នុងការផ្ទុកមេរោគអេដស៍ ជនអន្តោប្រវេសន៍ និងយុវជនដែលបោះបង់ចោលការសិក្សានៅសាលា ។ អន្តរាគមន៍នានាដែលមានលក្ខណៈយុទ្ធសាស្ត្រ និងមានប្រសិទ្ធភាពក្នុងការចំណាយជាងមុន ចាំបាច់ត្រូវតែរៀបចំដាក់ឱ្យដំណើរការ ឱ្យបានដល់ក្រុមជនទាំងនោះ ។
- *កម្មវិធីបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន* ត្រូវបានពង្រឹង ជាពិសេស តាមរយៈ*ការឆ្លើយតបរួមគ្នា* ប៉ុន្តែ ការធ្វើឱ្យសម្រេចបាននូវ *គោលដៅលទ្ធភាពទទួលបានសេវាជាសាកល ឆ្នាំ២០១០* គឺជាអាទិភាពមួយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដែលត្រូវបន្តដោះស្រាយ ។

- នៅក្នុងឆ្នាំ២០០៩ *គោលដៅសូចនាករលទ្ធភាពទទួលបានសេវាជាសាកល* ទាក់ទងនឹងអត្រាស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យផ្ទៃពោះ នៅកន្លែងដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន មិនទាន់អាចសម្រេចបាន នៅឡើយ (៨០ ភាគរយ) ។
- កិច្ចប្រតិបត្តិការរបស់*អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍* មិនទាន់ត្រូវបានធ្វើវិមជ្ឈការ ឱ្យបានសមស្របនៅឡើយ ដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការច្រើនវិស័យ ក្នុងការធ្វើអន្តរាគមន៍ទប់ទល់នឹងមេរោគអេដស៍នៅកម្រិតថ្នាក់ក្រោមជាតិ ជាពិសេស ក្រុមប្រឹក្សាឃុំ-សង្កាត់ និង ថ្នាក់ខេត្ត ។
- ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ជាតិ ត្រូវការជាចាំបាច់ នូវការបន្តពង្រឹងបន្ថែមទៀត ដើម្បីធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាព និងលទ្ធផលប្រសើរជាងមុន តាមរយៈ ការឆ្លើយតបរបស់ជាតិ ។ ការយកចិត្តទុកដាក់ ត្រូវតែបានផ្តោតជាពិសេសទៅលើ ការធ្វើសុខដុមនីយកម្មនិយមន័យនៃសូចនាករលទ្ធផល និងឧបករណ៍តាមដានត្រួតពិនិត្យនានា ក៏ដូចជា ការធ្វើឱ្យប្រសើរឡើងនូវ ការប្រមូល ការវិភាគ ការបកស្រាយ និងការប្រើប្រាស់ទិន្នន័យ ។
- ប្រមាណ ៩០ ភាគរយ នៃមូលនិធិ ដែលត្រូវបានចំណាយលើ អន្តរាគមន៍នានា ដែលពាក់ព័ន្ធនឹងជំងឺអេដស៍ក្នុងឆ្នាំ២០០៦ ២០០៧ និង ២០០៨ បានមកពីប្រភពធនធានក្រៅប្រទេស ដែលធ្វើឱ្យការឆ្លើយតបរបស់ជាតិ មានភាពពឹងផ្អែកយ៉ាងខ្លាំង ទៅលើជំនួយក្រៅប្រទេស ។ ការចំណាយលើជំងឺអេដស៍ បានកើនឡើងពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៧ ហើយបានធ្លាក់ចុះនៅឆ្នាំ២០០៨ ។ កិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាជាងមុនចាំបាច់ត្រូវធ្វើឡើង ក្នុងការកៀរគរធនធាន ដើម្បីឆ្លើយតបទៅនឹងជំងឺអេដស៍ ជាពិសេស ធនធានពីថវិកាជាតិជាមួយគ្នានឹង ការកែលម្អវិភាជន៍ថវិកា ទៅតាម អាទិភាពជាយុទ្ធសាស្ត្រ និង អន្តរាគមន៍សំខាន់ៗ ។
- កិច្ចខិតខំប្រឹងប្រែង ក្នុងការកាត់បន្ថយឥទ្ធិពល មេរោគអេដស៍/ជំងឺអេដស៍ នៅមិនទាន់ត្រូវបានធ្វើឡើងឱ្យបានសមស្របនៅឡើយ ។ ការងារជាច្រើនថែមទៀត ចាំបាច់ត្រូវធ្វើឡើង ដើម្បីគាំទ្រកុមារកំព្រា និងកុមារងាយរងគ្រោះ ព្រមទាំង គ្រួសារនិងសហគមន៍ ដែលបានឆ្លងមេរោគអេដស៍និងជំងឺអេដស៍ ។

**តារាងទី៩ : សូចនាករសំខាន់ៗ នៃកម្មវិធីជំងឺឆ្លង**

| សូចនាករសួល | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|
| ប្រេវ៉ាឡង់មេរោគអេដស៍លើមនុស្សអាយុ១៥-៤៩ឆ្នាំ (%) | - | ០,៦/<០,៩* | ០,៧ |
| អ្នកផ្ទុកមេរោគអេដស៍ប្រើប្រាស់ឱសថពន្យារជីវិត (នាក់) | ២០ ១៣១ | ២៦ ៦៦៤ | ៣១ ៩៩៩ |
| អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង (%) | >៨៥ | >៨៥ | >៨៥ |
| អត្រាស្រាវជ្រាវករណីរបេង បេកា វិជ្ជមាន (%) | ៦០ | ៦៥,៤ | ៦៩ |
| ករណីស្លាប់ដោយគ្រុនឈាមនៅមូលដ្ឋានសុខាភិបាលសាធារណៈ(%) | <០,៩% | ១% | ០,៦៨% |
| អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ | - | - | ២.១០ |

*ប្រភព: របាយការណ៍ស្ថិតិសុខាភិបាលប្រចាំឆ្នាំ ២០០៨- ក្រសួងសុខាភិបាល*

* ០,៦ ភាគរយ *អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥* / ការឯកភាពក្នុងកិច្ចប្រជុំជំនាញការ ឆ្នាំ២០០៧ NCHAD

### គម្រោងទីបី : ជំងឺមិនឆ្លងនិងបញ្ហាសុខភាពសាធារណៈដទៃទៀត

២៣៣. សេវាសុខភាពផ្លូវចិត្ត ត្រូវបានពង្រីកជាបន្តបន្ទាប់។ បច្ចុប្បន្នសេវាឯកទេសជំងឺសុខភាពផ្លូវចិត្តមាននៅមន្ទីរពេទ្យចំនួន ១០ ។ រីឯសេវាឯកទេសសម្រាប់ការសម្រាកព្យាបាល មាននៅមន្ទីរពេទ្យថ្នាក់ជាតិចំនួន២ ដោយឡែកសេវាសុខភាពផ្លូវចិត្តបឋម មាននៅ ៤០ មន្ទីរពេទ្យបង្អែក និង ១៨ មណ្ឌលសុខភាព។

២៣៤. កម្មវិធីបង្ការជំងឺមហារីកបាននឹងកំពុងផ្តួចផ្តើម តាមរយៈផ្តល់ការបណ្តុះបណ្តាលឆ្មបនៅតាមមណ្ឌលសុខភាព និងគ្រូពេទ្យព្យាបាលនៅតាម មន្ទីរពេទ្យបង្អែកស្តីអំពីការពិនិត្យដោះដោយខ្លួនឯង និងវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់គ្រូពេទ្យបម្រើការនៅមន្ទីរពេទ្យថ្នាក់ជាតិនៅភ្នំពេញស្តីពី ការស្រាវជ្រាវជំងឺមហារីកមាត់ស្បូន ។ គ្លីនិកជំងឺទឹកនោមផ្អែមចំនួន ១១ ត្រូវបានបង្កើតឡើង ។

២៣៥. ការអភិវឌ្ឍ និងការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រយ៉ាងឆាប់រហ័ស ត្រូវបានរំពឹងទុកថា នឹងនាំមកនូវការវិវឌ្ឍនៅក្នុងស្ថានភាពនៃជំងឺចេញពីជំងឺឆ្លង ឆ្ពោះទៅកាន់ការកើនឡើងនៃប្រេវ៉ាឡង់នៃជំងឺមិនឆ្លង ។ មានសេចក្តីបារម្ភយ៉ាងខ្លាំងពីបន្ទុកនៃជំងឺដែលទាក់ទងទៅនឹង ជំងឺលើសឈាម ជំងឺទឹកនោមផ្អែម របួសដោយសារគ្រោះថ្នាក់ចរាចរ ភាពបំពុលបរិស្ថាន អនាម័យខ្សត់ខ្សោយ និងកង្វះទឹកស្អាតប្រើប្រាស់ ។ ការលេចឡើងនូវការរាតត្បាតនៃការប្រើប្រាស់គ្រឿង ញៀនបានក្លាយទៅជាបញ្ហាប្រឈមមុខចម្បងមួយទៀត ដោយសារផលប៉ះពាល់របស់វាទៅលើសុខភាពផ្លូវចិត្ត ការឆ្លងមេរោគអេដស៍ និងបញ្ហាសង្គមដទៃទៀត ។ ដូច្នេះ ផលវិបាកចំពោះមុខ គឺការលេចឡើងបញ្ហាសុខភាព ទាំងក្នុងផ្នែកបង្ការ ការព្យាបាលបន្ទាន់ និងការស្តារនិតិសម្បទា ដែលនឹងទាមទារឱ្យមានការវិភាជធនធានបន្ថែម សម្រាប់ការធ្វើអន្តរាគមន៍ប្រកបប្រសិទ្ធភាព ។

២៣៦. បញ្ហាប្រឈមចម្បងចំពោះមុខ ក្នុងការអនុវត្តកម្មវិធីជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតរួមមាន :

- កត្តានៃការផ្លាស់ប្តូររបៀបរស់នៅដូចជា ការជក់បារី ការផ្លាស់ប្តូរទម្លាប់នៃការហូបចុក ការផឹកគ្រឿងស្រវឹង ការប្រើថ្នាំញៀន បន្តិចម្តងៗ នឹងនាំឱ្យកើនជាលំដាប់នូវអត្រាអាំងស៊ីដង់និងប្រេវ៉ាឡង់នៃជំងឺបេះដូងសរសៃឈាម រួមមានជំងឺលើសឈាម ជំងឺមហារីក ជំងឺទឹកនោមផ្អែម និងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល។
- គ្រោះថ្នាក់ចរាចរនឹងកើនឡើង ព្រមគ្នាជាមួយនឹងនគរូបនីយកម្ម និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ក៏ដូចជាការកើនឡើងនៃជំងឺដែលបណ្តាលមកពីបំពុលបរិស្ថាន ។ កំណើនសេដ្ឋកិច្ចឆាប់រហ័ស និងឧស្សាហភាវូបណីយកម្ម ធ្វើឱ្យមានការកើនឡើងនៃការគំរាមកំហែងដល់សុខភាព បរិស្ថាន។

- នៅពេលដែលប្រជាជនវ័យចំណាស់កាន់តែច្រើន មានការរំពឹងទុកថា ជំងឺទាក់ទងនឹងសរសៃប្រសាទនឹងកាន់តែកើនឡើងខ្ពស់ ។ ពិការភាពដែលបណ្តាលមកពីជំងឺភ្នែក និងការរលាកសន្លាក់ ក៏នឹងកើនឡើងដែរ ហើយនឹងក្លាយជាបន្ទុកចម្បងមួយដល់បុគ្គល និងដល់សេវាសុខភាព ។
- ជំងឺមិនឆ្លងជាច្រើនចាំបាច់អាចទប់ស្កាត់បានដោយប្រើវិធានការការពារ និងទាមទារកិច្ចសហការកម្រិតខ្ពស់មួយ និងត្រួតពិនិត្យតាមដានវិធានការបង្ការនោះ ពីគ្រប់វិស័យទាំងអស់ ។
- ផលប៉ះពាល់នៃកំណើនបន្ទុកនៃជំងឺមិនឆ្លង នឹងតម្រូវឱ្យមានការវិនិយោគក្នុងផ្នែកបច្ចេកវិទ្យាវេជ្ជ សាស្ត្រ ការរៀបចំមគ្គុទេសក៍គ្លីនិក និងការបណ្តុះបណ្តាលឡើងវិញ ។

## *បន្តពង្រឹងប្រព័ន្ធសុខាភិបាល*

### លើកកម្ពស់ការផ្តល់សេវាសុខាភិបាល

២៣៧. ការពង្រីកមូលដ្ឋានសុខាភិបាលសាធារណៈ សេវាសុខភាពដែលត្រូវផ្តល់ និងរចនាសម្ព័ន្ធទ្រទ្រង់ដទៃទៀត នឹងត្រូវតម្រង់គោលដៅឱ្យកាន់តែជិតថែមទៀត ទៅរកតម្រូវការផ្នែកសុខភាពរបស់ប្រជាជន ដោយផ្អែកលើមូលដ្ឋាននៃ *ផែនការគ្របដណ្តប់សុខាភិបាល* របស់ *អភិក្រមប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិ* ។ *ផែនការគ្របដណ្តប់សុខាភិបាល* គឺជាឧបករណ៍ផែនការ សម្រាប់តម្រង់ទិសដល់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យនៃ ចំនួនប្រជាជន និងភូមិសាស្ត្រ ។

២៣៨. មណ្ឌលសុខភាពនិងប៉ុស្តិ៍សុខភាព គឺជាមូលដ្ឋានសុខាភិបាលជួរមុខ ដែលផ្តល់*សំណុំសកម្មភាពអប្បបរមា* ហើយមន្ទីរពេទ្យបង្អែក គឺជាមូលដ្ឋានសុខាភិបាលថ្នាក់ទីពីរ ដែលផ្តល់សំណុំសកម្មភាពបង្គ្រប់ ។ ក្នុងឆ្នាំ២០០៨ ចំនួនមណ្ឌលសុខភាព បានកើនដល់ ៩៦៧ ហើយ ប៉ុស្តិ៍សុខភាព បានកើនដល់ ១០៨ ដោយមានទីតាំងក្នុងតំបន់ជនបទដាច់ស្រយាល ។ ចំនួនមន្ទីរពេទ្យបង្អែកសរុបមាន ៨៤ ក្នុងនោះរួមមាន មន្ទីរពេទ្យថ្នាក់ជាតិ ៨ នៅរាជធានីភ្នំពេញ *មន្ទីរពេទ្យបង្អែកសំណុំសកម្មភាពបង្គ្រប់កម្រិត៣* ចំនួន ១៨ *មន្ទីរពេទ្យបង្អែកសំណុំសកម្មភាពបង្គ្រប់កម្រិត២* ចំនួន ២៨ និង *មន្ទីរពេទ្យបង្អែកសំណុំសកម្មភាពបង្គ្រប់កម្រិត១* ចំនួន ៣០ ។

២៣៩. ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ត្រូវបានពង្រីកយ៉ាងច្រើន នៅទូទាំងប្រទេស ដោយមានទាំងការវិនិយោគសមស្របនូវឧបករណ៍ពេទ្យទំនើប ដូចជា Scanner Multibarette 64, MRI Angiographie, Radiocobalt, Mamography, MRI 3 Tesla ដល់មន្ទីរពេទ្យឯកទេសមួយចំនួន និងឧបករណ៍ពេទ្យជាមូលដ្ឋានសម្រាប់មូលដ្ឋានសុខាភិបាលដទៃទៀត ដើម្បីលើកកម្ពស់សមត្ថភាពគ្លីនិក និងគុណភាពនៃការថែទាំ ។ ទិន្នន័យក្នុង *តារាងទី៦* បង្ហាញពីការសាងសង់/ជួសជុល ហេដ្ឋារចនាសម្ព័ន្ធ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ចាប់តាំងពីឆ្នាំ១៩៩៥ មក ។

### តារាងទី៦ : ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាល

| | ១៩៩៥_២០០៣ | ២០០៣_២០០៧ | ២០០៨ |
|---|---|---|---|
| ចំនួនមណ្ឌលសុខភាពសង់ថ្មី | ៦៩៤ | ១៣៤ | ៣៧ |
| ចំនួនមន្ទីរពេទ្យបង្អែកសង់ថ្មី | - | ៣ | ៣ |
| ចំនួនអគារមន្ទីរពេទ្យបង្អែកដែលបានសង់ថ្មី | ៣៤ | ៣ | ៣៩ |

២៤០. កិច្ចសន្យាផ្តល់សេវាត្រូវបានពង្រីក និងធ្វើស្ថាបនីយកម្ម ទៅតាមបរិការណ៍ស្ថាប័ននៃវិសយ័សាធារណៈនៅកម្ពុជា ដោយមានការផ្តោតកាន់តែខ្លាំងទៅលើកិច្ចសន្យាផ្ទៃក្នុង និងស្វយ័តភាពលើការងារគ្រប់គ្រង តាមរយៈ *ទីភ្នាក់ងារប្រតិបត្តិការពិសេស* ដោយអនុលោមទៅតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។ ស្រុកប្រតិបត្តិចំនួន ៣០ ដោយរាប់បញ្ចូលទាំង មន្ទីរពេទ្យបង្អែកខេត្ត ត្រូវបានបង្កើតទៅជា *ទីភ្នាក់ងារប្រតិបត្តិការពិសេស* នៅឆ្នាំ២០០៩ ។

២៤១. ការផ្តល់សេវាសុខភាព រួមមាន វិធានការសុខភាពសាធារណៈដើម្បីប្រយុទ្ធនឹងជំងឺ ព្រមទាំង ការពង្រឹងជាទូទៅនូវការផ្តល់សេវាថែទាំសុខភាព តាមរយៈ គោលនយោបាយនិងផែនការដែលមានលក្ខណៈទូទៅនិងដែលផ្តោតលើជំងឺពិសេសណាមួយ ។ ការបង្កើនតម្រូវការផ្នែកសុខភាពនិងការលើកស្ទួយសិទ្ធិរបស់អ្នកជំងឺ គឺជាមធ្យោបាយចំពោះមុខដ៏សំខាន់ សម្រាប់ការបង្កើនគុណភាពនិងការទទួលខុសត្រូវ ក្នុងការផ្តល់សេវាសុខភាព ។

### លើកតម្កល់ហិរញ្ញប្បទានវិស័យសុខាភិបាល

២៤២. ការវិភាជថវិកាចរន្តរបស់ *ក្រសួងសុខាភិបាល* ដោយ *រាជរដ្ឋាភិបាលកម្ពុជា* បានកើនឡើងច្រើនជាងការគ្រោងទុក នៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* ។ ក្នុងអំឡុងពេល ២០ឆ្នាំកន្លងមកនេះ ការវិភាជថវិកាសម្រាប់វិស័យសុខាភិបាល ពីរាជរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍន៍ មានការកើនឡើងយ៉ាងខ្លាំង ។ ក្នុងឆ្នាំ២០០៨ ការរួមចំណែកពីរាជរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍន៍ សម្រាប់វិសយ័សុខាភិបាល គឺប្រហាក់ប្រហែលគ្នា គឺប្រមាណ ៨ ដុល្លារអាមេរិក ក្នុងប្រជាជនម្នាក់ ក្នុងមួយឆ្នាំ ។ ការទូទាត់សាច់ប្រាក់ជាទូទៅ និងការទូទាត់សាច់ប្រាក់ដល់ថ្នាក់ក្រោមៗ មានការរីកចម្រើន ដោយបាន រួមចំណែកធ្វើឱ្យការគ្រប់គ្រងការចំណាយសាធារណៈកាន់តែមានប្រសិទ្ធភាពជាងមុន ។

### តារាងទី៧ : សូចនាករស្នូលសម្រាប់ហិរញ្ញប្បទានវិស័យសុខាភិបាល (គិតត្រឹម ខែធ្នូ ឆ្នាំ២០០៨)

| | |
|---|---|
| ចំណាយថវិកាជាតិសម្រាប់សុខាភិបាល សម្រាប់ប្រជាជនម្នាក់ ក្នុងមួយឆ្នាំ (ដុល្លារ) | ៧,៩៥ |
| ថវិកាជាតិសម្រាប់វិស័យសុខាភិបាល គិតជា % នៃផលិតផលក្នុងស្រុកសរុប (%) | ១,០៥ |
| ថវិកាជាតិសម្រាប់វិស័យសុខាភិបាលគិតជា % នៃចំណាយចរន្តនៃថវិកាជាតិ (%) | ១២,៥៤ |
| ថវិកាជំនួយសម្រាប់ប្រជាជនម្នាក់ ក្នុងមួយឆ្នាំ (ដុល្លារ) | ៨,២៧ |

២៤៣. ប្រព័ន្ធហិរញ្ញប្បទានល្អ គឺជាមធ្យោបាយដ៏សំខាន់តែមួយគត់ ដើម្បីធានាគុណភាពសេវា សម្រាប់ប្រជារាស្ត្រកម្ពុជាទាំងអស់ ។ រាជរដ្ឋាភិបាលកម្ពុជាចាប់អារម្មណ៍លើការចំណាយប្រាក់ហោប៉ៅ ដើម្បីទទួលយកសេវាសុខភាព ដែលនេះជាបញ្ហាចម្បងមួយសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប និងប្រជារាស្ត្រក្រីក្រ ។ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងបន្តពង្រីកវិធានការគាំពារសង្គម និងប្រព័ន្ធសុវត្ថិភាពសង្គមដើម្បីដោះស្រាយបញ្ហានេះ ។ បច្ចុប្បន្ន ការគាំពារនេះ បាននឹងកំពុងផ្តល់តាមរយៈប្រពន្ធ័នានា សំខាន់នោះគឺ ការលើកលែងការបង់ថ្លៃសេវា មូលនិធិសមធម៌ និងការបង់ថ្លៃជំនួស ។ បច្ចុប្បន្ននេះ មូលនិធិសមធម៌ និងគម្រោងបង់ថ្លៃជួស កំពុងត្រូវបានអនុវត្ត នៅក្នុង ៥០ ស្រុកប្រតិបត្តិ (គ្របដណ្តប់ ៥១ មន្ទីរពេទ្យបង្អែក និង ១២០ មណ្ឌលសុខភាព) ។ មន្ទីរពេទ្យជាតិ ៦ និងមន្ទីរពេទ្យបង្អែក ៩ ត្រូវបានទ្រទ្រង់ដោយថវិកាជាតិ តាម*ប្រកាសលេខ ៨០៩ ឆ្នាំ២០០៨* ក្រៅពីនេះ គាំទ្រដោយថវិការបស់ដៃគូអភិវឌ្ឍន៍ ។ ៦៨ភាគរយ នៃប្រជាជនក្រីក្រ ត្រូវបានការពារដោយមូលនិធិសមធម៌ និងគម្រោងបង់ថ្លៃជួស គឺមានចំនួន ២ ៨៣២ ៨៤៤នាក់ នៃចំនួនប្រជាជនក្រីក្រដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ។ លទ្ធផលជំហានដំបូងនៃ*ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជាឆ្នាំ២០០៧* បានបង្ហាញលទ្ធផលគួរឱ្យកត់សម្គាល់ គឺការថយចុះនៃបំណុលលើការថែទាំសុខភាព ក្នុងគ្រួសារដែលទទួលបានផលប្រយោជន៍ពីមូលនិធិសមធម៌ ។ ក្នុងឆ្នាំ២០០៤ ប្រមាណ ៥,១៧ភាគរយ នៃគ្រួសារដែលត្រូវធ្វើបានអង្កេត បានរាយការណ៍ពីការជាប់បំណុលដោយសារការថែទាំសុខភាព រីឯ ក្នុងឆ្នាំ២០០៧ បានថយចុះយ៉ាងច្រើនមកនៅត្រឹម ៣,៤៣ភាគរយ ។

២៤៤. គម្រោងធានារ៉ាប់រងសុខភាពសហគមន៍មួយចំនួន ត្រូវបានដាក់ឱ្យដំណើរការនៅតាមតំបន់ខ្លះនៃប្រទេសកម្ពុជា ដោយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនិងក្នុងស្រុក ។ គម្រោងធានារ៉ាប់រងសុខភាពសហគមន៍ គឺឈរលើមូលដ្ឋាននៃគោលការណ៍ប្រមូលផ្តុំហានិភ័យ និងបង់ថ្លៃមុនសម្រាប់ការថែទាំសុខភាព ។ គម្រោងទាំងអស់នោះជាយន្តការស្ម័គ្រចិត្ត និងមិនស្វែងរកផលកម្រៃ ដែលផ្តល់ឱ្យអ្នកទិញធានារ៉ាប់រងសុខភាព និង គ្រួសាររបស់គេទទួលនូវការគ្របដណ្តប់នៃសេវាសុខភាព ទៅតាមបញ្ជីនៃតាវកាលិកវេជ្ជសាស្ត្រ ដែលបានកំណត់តាមកិច្ចសន្យាជាមួយមូលដ្ឋានសុខាភិបាលសាធារណៈ (ជាទូទៅជាមួយមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក) ។ បច្ចុប្បន្នមានគម្រោងធានារ៉ាប់រងសុខភាព សហគមន៍ចំនួន ១២ ដែលបាននិងកំពុងអនុវត្តក្នុងស្រុកប្រតិបត្តិចំនួន ១១ ក្នុងខេត្ត ៧ និងរាជធានីភ្នំពេញ ដោយគ្របដណ្តប់លើមណ្ឌលសុខភាព ៨១ និង មន្ទីរពេទ្យបង្អែក ១១ និងមានអ្នកទទួលផលប្រយោជន៍ចំនួន ៧៣ ៨២៨ នាក់ ។

## ធនធានមនុស្សសម្រាប់សុខាភិបាល

២៤៥. គិតត្រឹមខែធ្នូ ឆ្នាំ២០០៨ វិស័យសុខាភិបាលសាធារណៈទូទាំងប្រទេស មានបុគ្គលិក សរុប ១៨ ០៩៦ នាក់ ក្នុងនេះមាន វេជ្ជបណ្ឌិត ២ ១៧៣នាក់ គ្រូពេទ្យមធ្យម ១ ២២០នាក់ ទន្តបណ្ឌិត ១៧២នាក់ ឱសថការី ៤២៧នាក់ គិលានុប្បដ្ឋាកយិកាមធ្យម ៥ ០៨៤នាក់ គិលានុប្បដ្ឋាកយិកាបឋម ៣ ៤០៧នាក់ ឆ្មបមធ្យម ១ ៨០៦ នាក់ ឆ្មបបឋម ១ ៤៣៩នាក់ និងឯកទេសមន្ទីរពិសោធន៍មធ្យម ៤២៨នាក់ ។ ការជ្រើសរើសបញ្ចូលក្របខ័ណ្ឌ

និងការបែងចែកបុគ្គលិកត្រូវបានកែលម្អ ។ គិតត្រឹមខែមករាឆ្នាំ២០០៩ ៧៣,៧៨ភាគរយ នៃបុគ្គលិកសរុបបានដាក់ឱ្យបម្រើការងារនៅថ្នាក់ខេត្ត (ដោយរាប់បញ្ចូលទាំងមណ្ឌលសុខភាពនិងប៉ុស្តិ៍សុខភាព) ហើយ ២៦,២២ភាគរយទៀត នៅថ្នាក់កណ្តាលនិងរាជធានីភ្នំពេញ ។ ចំនួនមណ្ឌលសុខភាពដែលមិនទាន់មានឆ្មប បានថយពី ២២៩ មណ្ឌលសុខភាព ក្នុង ឆ្នាំ២០០៤ មកនៅត្រឹម ៧៩ មណ្ឌលសុខភាពនៅចុងឆ្នាំ២០០៨ ។ ហើយនៅខែកក្កដា ឆ្នាំ២០០៩ មណ្ឌលសុខភាព ទាំងអស់ទូទាំងប្រទេស (៩៦៧) មានយ៉ាងហោចណាស់បុគ្គលិកឆ្មបមួយនាក់ ។

២៤៦. ការអនុវត្តកម្មវិធីកន្សោមអាទិភាពរបស់រាជរដ្ឋាភិបាល បានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៦ ហើយបានដំណើរការនៅក្នុងខេត្ត ៧ (*កំពត តាកែវ ឧត្តរមានជ័យ សៀមរាប បន្ទាយមានជ័យ ប៉ៃលិន និង បាត់ដំបង*) ដែលគ្របដណ្តប់លើ មណ្ឌលសុខភាពចំនួន ៦៥ ដោយមានបុគ្គលិកសរុប ៣៨០នាក់ ។ ប្រព័ន្ធប្រាក់លាភការបន្ថែម បានអនុវត្តក្នុងឆ្នាំ២០០៩ នៅក្នុងខេត្តចំនួន ៧ ( មន្ទីរសុខាភិបាលខេត្ត *កោះកុង តាកែវ ព្រៃវែង កំពង់ចាម ព្រះវិហារ មណ្ឌលគិរី និងរតនគិរី*) និងអង្គភាពថ្នាក់កណ្តាលចំនួន ២ ( *មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក* និងទីស្តី ការក្រសួងសុខាភិបាល) សរុប ១៩០ តំណែង ។ ការផ្តល់ប្រាក់ឧបត្ថម្ភលើកចិត្តឆ្មប សម្រាប់ការសម្រាលកូនមាន សុវត្ថិភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈ បានធ្វើឱ្យការសម្រាលកូន នៅមណ្ឌលសុខភាព និងមន្ទីរពេទ្យ កើនឡើង ពី ៣៩ភាគរយ ក្នុងឆ្នាំ២០០៦ ដល់ ៥៨ភាគរយ នៅដំណាច់ឆ្នាំ២០០៨ ។

២៤៧. បើទុកណាជាសកម្មភាពមួយចំនួនត្រូវបានប្រកាន់យក ដើម្បីដោះស្រាយបញ្ហានានាជុំវិញការជ្រើសរើសបញ្ចូលក្របខ័ណ្ឌ និង ការរក្សាទុកឆ្មប ការពង្រាយបុគ្គលិករវាងទីប្រជុំជន និងតំបន់ជនបទនៅតែចោទជាបញ្ហា ។ អាទិភាពរបស់ក្រសួងសុខាភិបាលគឺបង្កើនការជ្រើសរើស និងសមត្ថភាពនៃការបណ្តុះបណ្តាលក្នុងរយៈប្រាំឆ្នាំខាងមុខនេះ ក៏ដូចជា ការកែលម្អគុណភាពនៃការបណ្តុះបណ្តាល ។

២៤៨. ទំនាក់ទំនងរវាងការផ្តល់សេវាក្នុងវិស័យសាធារណៈនិងឯកជន ចាំបាច់ត្រូវតែបន្តដោះស្រាយ ជាពិសេសបញ្ហាអតុល្យភាពនៃប្រព័ន្ធលាភការរវាងវិស័យសាធារណៈនិងឯកជន ។ ក្រសួងសុខាភិបាលកំពុងពិនិត្យមើលជម្រើសនានាដើម្បីអនុវត្តប្រព័ន្ធលាភការផ្អែកលើស្នាដៃការងារ ដើម្បីលើកកម្ពស់ការងារគ្រប់គ្រង និងការផ្តល់សេវាថែទាំសុខភាព ក៏ដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត សម្រាប់បុគ្គលិកសុខាភិបាលដែលបម្រើការងារនៅតំបន់ដែលចូលទៅដល់ ទន្ទឹមគ្នានឹង ការកែលម្អការធ្វើផែនការធនធានមនុស្សថ្នាក់ជាតិ និងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារមានប្រសិទ្ធភាព ។ ជាជំហានដំបូង អន្តរាគមន៍បន្ទាន់ដើម្បីលើកម្ពស់លទ្ធភាព និងគុណភាពនៃសេវាសុខភាពបន្តពូជ មាតា ទារក និងកុមារ បាននិងកំពុងអនុវត្ត ។

## ប្រព័ន្ធព័ត៌មានសុខាភិបាល

២៤៩. ប្រព័ន្ធព័តិមានសុខាភិបាលត្រូវបានអភិវឌ្ឍក្នុងឆ្នាំ១៩៩៣ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រទេស ហើយបានអនុវត្តជាជំហានៗ ។ ការគ្របដណ្តប់ទូទាំងប្រទេសនៃប្រព័ន្ធព័តិមានត្រូវបានសម្រេច នៅខែកុម្ភៈ ឆ្នាំ១៩៩៥ ។

ការប្រមូលទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាលស្ដីអំពីសកម្មភាពសេវាសុខភាពជាប្រចាំ និងអំពីបញ្ហាសុខភាព ត្រូវបានរាយការណ៍ពីគ្រប់ថ្នាក់ទាំងអស់នៃមូលដ្ឋានសុខាភិបាល នៅក្នុងប្រព័ន្ធសុខាភិបាល ។ ទិន្នន័យព័ត៌មានត្រូវបានបំបែកទៅតាម អាយុ ក្រុមប្រជាជន ទីតាំងភូមិសាស្ត្រ និងភេទ ។ គោលដៅអភិវឌ្ឍន៍នៃប្រព័ន្ធព័ត៌មានសុខាភិបាល គឺផ្ដល់ឱ្យក្រសួងសុខាភិបាល និងគ្រប់ថ្នាក់ទាំងអស់នៃប្រព័ន្ធ នូវព័ត៌មានត្រឹមត្រូវ ទាន់ពេលវេលាស្ដីពីបញ្ហាសុខភាព និងសកម្មភាពសេវាសម្រាប់ ការធ្វើផែនការនិងការងារគ្រប់គ្រងសេវា និង ការធ្វើការសម្រេចចិត្តបានល្អប្រសើរ ។

២៥០. ចាប់តាំងពីពេលបង្កើតរួចមក ប្រព័ន្ធព័ត៌មានសុខាភិបាល ត្រូវបានឆ្លងកាត់ការពិនិត្យកែសម្រួល ជាបន្តបន្ទាប់ (នៅឆ្នាំ១៩៩៦ ឆ្នាំ១៩៩៩ និង ចុងឆ្នាំ២០០៣) ហើយ ការពិនិត្យវាយតម្លៃគ្រប់ជ្រុងជ្រោយមួយ នៃប្រព័ន្ធព័ត៌មានសុខាភិបាល បានប្រព្រឹត្តទៅក្នុងឆ្នាំ២០០៦ ដើម្បីកំណត់នូវ ចំណុចខ្លាំងនិងចំណុចខ្សោយ ។ ចំណុចខ្លាំងនៃប្រព័ន្ធព័ត៌មានសុខាភិបាល គឺ ការធ្វើសមាហរណកម្ម ប្រពន្ធ័រាយការណ៍និងកត់ត្រាជាង ២០ ដោយឡែកពីគ្នា ទៅក្នុងប្រព័ន្ធតែមួយ ដើម្បីចៀសវាងការត្រួតជាន់គ្នា និងបន្ថយបន្ទុកការងាររបស់បុគ្គលិក កំណត់ស្ដង់ដារគំរូកត់ត្រា និងរបាយការណ៍ និងប្រើប្រាស់ប្រព័ន្ធទិន្នន័យមូលដ្ឋានព័ត៌មានសុខាភិបាល ដែលបច្ចុប្បន្ននេះ គ្របដណ្ដប់នៅគ្រប់ខេត្ត និង ស្រុកប្រតិបត្តិ ទាំងអស់ ។

២៥១. ខណៈពេលដែល*ក្រសួងសុខាភិបាល* មានប្រព័ន្ធពត៌មានសុខាភិបាល ដែលកំពុងដំណើរកាជាប្រចាំ ដោយគ្របដណ្ដប់ពី មូលដ្ឋានសុខាភិបាលថ្នាក់ក្រោមបំផុត ទៅដល់ស្រុកប្រតិបត្តិ និង ពីថ្នាក់រាជធានី-ខេត្ត ទៅដល់ថ្នាក់កណ្ដាល នោះព័ត៌មានពីវិស័យឯកជន មិនត្រូវបានរាប់បញ្ចូល ។ កង្វះព័ត៌មានពី ផ្នែកឯកជននិងអង្គការក្រៅរដ្ឋាភិបាល គឺជាបញ្ហាសំខាន់មួយដែលត្រូវដោះស្រាយ ដើម្បីធានាថា ការពង្រីកប្រព័ន្ធការផ្ដល់សេវាសុខភាព ក្នុងពេលអនាគត ក្នុងទូទាំងប្រទេស អាចប្រព្រឹត្តទៅបាន ដោយមិនមានការត្រួតជាន់គ្នានៃសេវា ដែលផ្ដល់ដោយផ្នែកសាធារណៈ ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល ។ ដូច្នេះ ប្រព័ន្ធទិន្នន័យមូលដ្ឋានពត៌មានសុខាភិបាល មិនអាចត្រួតពិនិត្យតាមដានស្ថានភាពសុខភាព នៅទូទាំងប្រទេសបានទេ ទោះបីជាមានការកើនឡើងនៃការប្រើប្រាស់ទិន្នន័យ នៅក្នុងការងារផែនការនិងការតាមដានត្រួតពិនិត្យ ក៏ដោយ ។ ខណៈពេលដែលប្រព័ន្ធតាមដានជំងឺកំពុងដំណើរការដោយមានប្រសិទ្ធភាព នោះ ករណីរាយការណ៍ និង ការពិនិត្យតាមដានជំងឺមិនឆ្លងសំខាន់ៗ នៅទន់ខ្សោយនៅឡើយ ។ ការបន្តលើកកម្ពស់ ក្នុងការសម្របសម្រួលនិងកិច្ចសហការក្នុងចំណោម ដៃគូប្រព័ន្ធព័ត៌មានសុខាភិបាល ទាំងនៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសុខាភិបាល គឺជា តម្រូវការបន្ទាន់ចំពោះមុខ ។

២៥២. ផ្នែកសំខាន់សម្រាប់ពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាល គឺការផ្ដល់ ទិន្នន័យព័ត៌មាន មានគុណភាពខ្ពស់ និងទាន់ពេលវេលា ដើម្បីជាមូលដ្ឋានដល់ការតាក់តែងគោលនយោបាយផ្អែកលើភស្តុតាង ការអនុវត្តន៍កម្មវិធី ការ

តាមដានត្រួតពិនិត្យ ស្មាដៃការងារ និងការវាយតម្លៃ ដោយប្រើប្រាស់បច្ចេកវិទ្យា និងការប្រាស្រយ័ទាក់ទងសមស្រប ។ ប្រការនេះ នឹងធ្វើឱ្យព័ត៌មានមានគុណភាពស្តីពី ប្រជាសាស្ត្រ-សង្គម សេដ្ឋកិច្ច ឈឺ មរណៈភាព និងកត្តាគ្រោះថ្នាក់ ទិន្នន័យតាមដានជំងឺ នឹងកាន់តែពេញលេញនិងទាន់ពេលវេលា ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាព ទៅនឹងការផ្ទុះឡើងនៃជំងឺ និងត្រួតត្រាជំងឺ ។ ការគ្របដណ្តប់គ្រប់ជ្រុងជ្រោយនឹងអាចសម្រេចបានជាមួយនឹង ការកែលម្អការគ្រប់គ្រងតាម ពត៌មានវិទ្យាលើហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សនិងភស្តុភារ ។

## អភិបាលកិច្ចប្រព័ន្ធសុខាភិបាល ទីផ្សារ និងទីសហផ្សារ

២៥៣. ដើម្បីលើកកម្ពស់អភិបាលកិច្ចនៃប្រព័ន្ធសុខាភិបាល អនុក្រឹត្យមួយចំនួនដែលគ្របដណ្តប់លើទិដ្ឋភាពនានានៃវិស័យសុខាភិបាល បាននឹងកំពុងអនុវត្តដោយក្រសួងសុខាភិបាល ក្នុងនោះរួមមាន :

- *អនុក្រឹត្យស្តីពីការគ្រប់គ្រងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ* ដែលត្រូវបានអនុវត្តដោយ *ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ* ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ ។
- *អនុក្រឹត្យស្តីពី ក្រមសីលធម៌គ្រូពេទ្យ* ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ។
- *ព្រះរាជក្រឹត្យស្តីពី រូបសញ្ញាបច្ចេកទេស សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម* ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៥ ។
- *ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តនូវកម្មវិធីសិក្សាគិលានុបដ្ឋាក ឆ្មបបឋម* ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ។
- *ប្រកាសអន្តរក្រសួងស្តីពី ការអនុញ្ញាតឱ្យសេវាសុខាភិបាលអនុវត្តការពិនិត្យនិងព្យាបាលជំងឺ ដោយយកកម្រៃពីអ្នកជំងឺ* ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៥ ។
- *ប្រកាសស្តីពី ការកំណត់តំបន់ជួបការលំបាករបស់ក្រសួងសុខាភិបាល* ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០០៥ ។
- *ប្រកាសរួមក្រសួងសុខាភិបាលនិងក្រសួងពត៌មានស្តីពី លក្ខណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ គ្រឿងសម្អាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងវេជ្ជសាស្ត្រជំនួយ* ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០០៦ ។
- អនុក្រឹត្យស្តីពី *ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសុខាភិបាល* ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៦ ។
- *អនុក្រឹត្យស្តីពី ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសុខាភិបាល* ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៦ ។
- *អនុក្រឹត្យស្តីពី ទិវាឆ្មបជាតិ* ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ។
- *អនុក្រឹត្យស្តីពី ការប្រែក្លាយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ជាវិទ្យាស្ថានសាធារណៈរដ្ឋបាល* ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦ ។

- *អនុក្រឹត្យស្តីពី ការប្រែក្លាយមន្ទីរពេទ្យព្រះកុសុមជាគ្រឹះស្ថានសាធារណៈ* ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩។
- *អនុក្រឹត្យស្តីពី ការប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈ* ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ។
- *អនុក្រឹត្យស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ជាគ្រឹះស្ថានសាធារណៈ* ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ។

២៥៤. *ក្រសួងសុខាភិបាល* ទទួលស្គាល់ នូវសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូទាំងអស់ ដែលឆ្លុះបញ្ចាំង ពីភាពជោគជ័យនៃក្រុមការងារបច្ចេកទេសសុខាភិបាល ដែលជាអង្គពិគ្រោះយោបល់សម្រាប វិស័យសុខាភិបាល និងការពង្រឹងនិងពង្រីកអភិក្រមគ្រប់គ្រងទូទាំងវិស័យ តាមរយៈ កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល ជំហានទី២ និងការចុះកិច្ចព្រមព្រៀងក្នុងភាពជាដៃគូរួមគ្នា ដើម្បីតំរៀបតម្រង់ការវិនិយោគរបស់ដៃគូ ទៅតាមផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ។

២៥៥. ការអនុវត្តកម្មវិធីកំណែទម្រង់ទូលំទូលាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ជាកាលានុវត្តភាពដ៏ចម្បង សម្រាប់ លើកកម្ពស់ អភិបាលកិច្ចប្រព័ន្ធសុខាភិបាល និងការផ្តល់សេវាថែទាំសុខភាព ។ ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកខេត្ត ត្រូវបានបង្កើតឱ្យទៅជាទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលធ្វើសមាហរណកម្មស្រុកកិច្ចសន្យាសេវាកម្មកាលពីពេលមុន ទៅក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ និងការទទួលខុសត្រូវនៃប្រព័ន្ធទាំងមូល។ កម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការដែល កំពុងប្រព្រឹត្តទៅនឹងជួយពង្រឹងថែមទៀតនូវការទទួលខុសត្រូវខាងលើនេះ ។ ទោះជាដូច្នេះក្តី ប្រការដ៏សំខាន់គឺ ត្រូវធានាថា ការផ្លាស់ប្តូរដែលនឹងកើតមាន ត្រូវតែមានសង្គតិភាពជាមួយ *ផែនការគ្របដណ្តប់សុខាភិបាល* ដោយឈរលើមូលដ្ឋានភស្តុតាងជាក់ស្តែងនៃសុខភាពសាធារណៈ ។

២៥៦. *ក្រសួងសុខាភិបាល* ទទួលស្គាល់ពីតម្រូវការនៃការផ្តល់សេវាសុខភាពមានគុណភាពខ្ពស់ នៅចំពោះមុខឧបស័គ្គផ្នែក ថវិកា ការគ្រប់គ្រង និងសមត្ថភាពគ្លីនិក ដូចនេះ ចាំបាច់ត្រូវមានការកែលម្អច្រើនបន្ថែមទៀត នៅក្នុងប្រព័ន្ធគ្រប់គ្រង ថវិកានិងបុគ្គលិក ។ មានការយល់ស្របគ្នាថា បើគ្មានការរៀបចំចាត់ចែងការឧបត្ថម្ភ លើកទឹកចិត្តត្រឹមត្រូវទេ ការអនុវត្តការផ្លាស់ប្តូរស្ថាប័ន ដែលតម្រូវដោយកំណែទម្រង់វិមជ្ឈមការនិងវិសហមជ្ឈការ នឹងជួបការលំបាក ។

## ៦.៣ ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ

២៥៧. នៅក្នុងរយៈពេលកន្លងមក កម្ពុជាទទួលបានជោគជ័យ និងសម្រេចបានសមិទ្ធផល គួរឱ្យកត់សម្គាល់ជាច្រើន ក្នុងការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈ ការអនុវត្ត *ផែនការនារីរតនៈទី២ (២០០៤-២០០៨)* របស់ *ក្រសួងកិច្ចការនារី* ។ លទ្ធផលនេះ អាចទទួលបាន ដោយមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ពី *រាជរដ្ឋាភិបាល*

*កម្ពុជា* និងមានកិច្ចសហការយ៉ាងជិតស្និតជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ជាតិនិងអន្តរជាតិ ក្នុងការអនុវត្ត *ផែនការនារីរតនៈទី២* នេះ ។ *ផែនការនារីរតនៈទី២* ផ្តោតជាសំខាន់ទៅលើវិស័យអាទិភាព ចំនួន ៥ គឺៈ

១. ការអភិវឌ្ឍសេដ្ឋកិច្ចស្ត្រី ។
២. ការបង្កើនការអប់រំដល់ស្ត្រី និងក្មេងស្រី
៣. ការការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី
៤. ការលើកកម្ពស់សុខភាពស្ត្រី និងក្មេងស្រី
៥. ការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច
៦. ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីជាតិ ។

## ការអភិវឌ្ឍសេដ្ឋកិច្ចដល់ស្ត្រី

២៥៨. ជាមួយនឹងការកើនឡើងនូវកំណើនសេដ្ឋកិច្ចក្នុងវិស័យឧស្សាហកម្ម និងកាលានុវត្តភាពថ្មីៗ ក្នុងវិស័យទេសចរណ៍ ការងារដែលមានប្រាក់ឈ្នួលសម្រាប់ស្ត្រី មានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ។ ទោះជាដូចនេះក្តី ការទទួលបានការអប់រំតិចតួចក្នុងចំណោមស្ត្រី និងផ្នត់គំនិតយេនឌ័រក្នុងសង្គម (ចំពោះការងារដែលសមស្របចំពោះស្ត្រី) ជាពិសេស ក្នុងវ័យកំលាំងពលកម្ម ក៏ជាមូលហេតុមួយដែលនាំឱ្យស្ត្រីមានជម្រើសតិចតួចក្នុងការប្រកបរបរចិញ្ចឹមជីវិត និងចាប់យកឱកាសការងារថ្មីៗ ដែលមានចំណូលច្រើន ។

២៥៩. បច្ចុប្បន្ននេះ វិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក កំពុងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំង ទៅលើវិស័យសំលៀកបំពាក់និងវាយនភណ្ឌ និងវិស័យទេសចរណ៍ នៅកម្ពុជា ។ វិស័យទាំងពីរនេះគឺជាប្រភពការងារ ដែលមានប្រាក់ចំណូលចម្បងសម្រាប់ស្ត្រី ។ ការបាត់បង់ការងារដែលទទួលប្រាក់ឈ្នួល របស់ស្ត្រី និងសក្តានុពលនៃផលប៉ះពាល់ជាអវិជ្ជមានទៅលើសហគមន៍ជនបទ ហើយនិង ហានិភ័យដែលពាក់ព័ន្ធនឹងបញ្ហាថា ស្ត្រីទាំងនោះនឹងត្រូវបានអូសទាញឱ្យចូលទៅក្នុងមុខរបរមួយ ដែលកាន់តែមានហានិភ័យខ្ពស់ជាងមុន គឺជាកង្វល់ដ៏ធំមួយនៅកម្ពុជា ។ ដើម្បីដោះស្រាយបញ្ហានេះ *រាជរដ្ឋាភិបាលកម្ពុជា* បានដាក់ចេញនូវវិធានការជាច្រើន ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីខាងក្រៅនេះ ទៅលើប្រជាជនដែលងាយរងគ្រោះ ។

## ការបង្កើនការអប់រំដល់ស្ត្រីនិងក្មេងស្រី

២៦០. ការស្រាវជ្រាវនាពេលថ្មីៗនេះ បានបង្ហាញពីភាពរីកចម្រើនគួរឱ្យកត់សម្គាល់ លើការកាត់បន្ថយគម្លាតយេនឌ័រក្នុងការទទួលបានការអប់រំ ជាពិសេស នៅកម្រិតបឋមសិក្សា និងមានភាពប្រសើរឡើងមួយចំនួន នៅកម្រិតឧត្តមសិក្សា ។ ទន្ទឹមនឹងនោះ អត្រាអក្ខរកម្មរបស់ប្រជាជនដែលមានអាយុក្រោម ២០ឆ្នាំ បានទទួលជោគជ័យទៅតាមគោលដៅដែលបានកំណត់ ដែលឆ្លុះបញ្ចាំងពីភាពរីកចម្រើនក្នុងការទទួលបានការអប់រំនៅកម្រិតបឋមសិក្សា ។

ស្ថាប័នដែលទទួលបន្ទុកក្នុងការផ្តល់ការអប់រំ បានបន្តពិចារណា និងបញ្ចូលបញ្ហាយេនឌ័រក្នុង គោលនយោបាយជាតិវិស័យអប់រំ ។ ទោះជាដូចនេះក្តី ក្មេងស្រីនៅមានចំនួនតិចជាងក្មេងប្រុសនៅគ្រប់កម្រិតសិក្សាទាំងអស់ ជាពិសេសនៅកម្រិតឧត្តមសិក្សា ។ លើសពីនេះទៀត ចំនួនដ៏ច្រើននៃស្ត្រីដែលមានអាយុពី ២៥-៤៤ឆ្នាំ និងស្ត្រី ដែលមានអាយុពី ១៥-២៤ឆ្នាំ មានការសិក្សាអប់រំទាបជាងកម្រិតបឋមសិក្សា ។ បន្ថែមលើនេះទៀត ការដោះស្រាយកម្រិតអក្ខរកម្មទាប និងការសិក្សាអប់រំក្នុងចំណោមស្ត្រី ដែលស្ថិតក្នុងកម្លាំងពលកម្មនិងក្នុងវ័យបន្តពូជ និងអត្រាបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់របស់ក្មេងស្រី នៅតែជាបញ្ហាអាទិភាពមួយនៅកម្ពុជា ។

## កិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី

២៦១. ការជំរុញកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី ត្រូវបានបង្ហាញឱ្យឃើញពីភាពរីកចម្រើនគួរឱ្យកត់សម្គាល់ជាច្រើន តាមរយៈ លើកយកបញ្ហាយេនឌ័រ និងសិទ្ធិស្ត្រី មកពិចារណានៅក្នុងការរៀបចំ និងការអនុវត្ត ច្បាប់នានា ព្រមទាំងនៅក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ជូនដល់សាធារណៈជន និងសម្រាប់ស្ថាប័នពាក់ពន្ធ័ ផងដែរ ។ នៅឆ្នាំ២០០៥ *ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* បានទទួល ការអនុម័តដោយរដ្ឋសភាជាតិ ហើយក្នុងពេលបច្ចុប្បន្ននេះ *ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី* ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីរួចហើយ និងកំពុងតែត្រូវបានអនុវត្ត ។ ចំណែកឯ*ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ* ក៏ត្រូវបានទទួលការអនុម័តពីសភាជាតិ កាលពីដើមឆ្នាំ២០០៨ និង កំពុងរៀបចំ*ផែនការសកម្មភាពស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ* ។ ដើម្បីសម្រួលដល់កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ការជួញដូរមនុស្ស គណៈកម្មាធិការជាតិអន្តរក្រសួង ដែលដឹកនាំដោយក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើង ។ ប៉ុន្តែ អំពើហិង្សាលើស្ត្រីនៅតែកើតមានច្រើនក្នុងប្រទេសកម្ពុជា ជាពិសេស ការកើនឡើងនូវ ករណីអំពើហិង្សា ដែលទាក់ទងនឹងយេនឌ័រ ហើយពុំទាន់មានការដោះស្រាយឱ្យមានប្រសិទ្ធភាពលើការផ្លាស់ប្តូរ និងអាកប្បកិរិយា ដែលនាំឱ្យមានការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំង ការរើសអើងលើ ជនរងគ្រោះដោយអំពើហិង្សានៅឡើយ ។

## ការលើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រី

២៦២. ចំពោះវិស័យសុខាភិបាល មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឱ្យកើតមានឡើង ក្នុងការលើកកម្ពស់ស្ថានភាពសុខភាពរបស់ស្ត្រី និងក្មេងស្រី ដោយ ស្ត្រីនិងក្មេងស្រី ភាគច្រើនបានយល់ដឹង និងបានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការទទួលបានពត៌មានស្តីពី ការថែទាំសុខភាពបឋម និងការប្រើប្រាស់សេវា បង្ការ និងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ ជំងឺកាមរោគ និងជំងឺគ្រុនចាញ់ ។ ជាងនេះទៅទៀត អត្រាប្រេវ៉ាឡង់ក្នុងចំណោមស្ត្រីផ្ទុកមេរោគអេដស៍ដែលបានពិនិត្យផ្ទៃពោះ បានថយចុះ ហើយការផ្ទុកមេរោគអេដស៍ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ

ទាំងក្នុងចំណោមស្ត្រីប្រកបរបរ ផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល ក៏មានការថយចុះផងដែរ ។ ប៉ុន្តែ ការឆ្លងមេរោគអេដស៍រវាង ប្តី-ប្រពន្ធ/ដៃគូរួមភេទ និង ពីម្តាយទៅទារក កំពុងតែរីករាលដាល និងក្លាយជារូបភាពចម្បងនៃការចម្លងមេរោគអេដស៍ នាពេលបច្ចុប្បន្ននេះ ។ លើសពីនេះទៀត អត្រាមរណៈភាពមាតា នៅតែមានកម្រិតខ្ពស់នៅឡើយ ដែលជាកង្វល់ដ៏ធំមួយ ។

## ការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច

២៦៣. កន្លងមក ភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឱ្យកើតមានឡើងច្រើន ក្នុងការបង្កើនការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតនៃអភិបាលកិច្ច ។ ជាក់ស្តែង សមាមាត្រស្ត្រីជាសមាជិកព្រឹទ្ធសភា បានកើនឡើងពី ១៣ភាគរយ ក្នុងឆ្នាំ២០០៣ ដល់ ១៤,៨ភាគរយ ក្នុងឆ្នាំ២០០៧ ។ ហើយសមាមាត្រស្ត្រី ដែលបានជាប់ឆ្នោតជាសមាជិការដ្ឋសភា បានកើនឡើងពី ៥ភាគរយ ក្នុងឆ្នាំ១៩៩៣ ដល់ ១១ភាគរយ ក្នុងឆ្នាំ១៩៩៨ និង១៩ភាគរយ ក្នុងឆ្នាំ២០០៣ និងបានកើនឡើងដល់ ២២ភាគរយ ក្នុងឆ្នាំ២០០៨ ។ ចំណែក ឯសមាមាត្រ ស្ត្រីជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បានកើនឡើងពី ៧ភាគរយ និង ៩,៦ភាគរយ ក្នុងឆ្នាំ២០០៣ ដល់ ៧,៧ភាគរយ និង ១៤,៦ភាគរយ ក្នុងឆ្នាំ២០០៨ ។ សមាមាត្រស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ បានកើនឡើងពី ៨ភាគរយ ក្នុងឆ្នាំ២០០២ ដល់ ១៤,៦ភាគរយ ក្នុងឆ្នាំ២០០៧ ដែល ក្នុងនោះស្ត្រីមានចំនួន ៣០ភាគរយ ក្នុងចំណោមអ្នកដឹកនាំភូមិ ។ ទន្ទឹមនឹងនោះ តាមរយៈការបោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ ស្ត្រីជាក្រុមប្រឹក្សារាជធានី ខេត្តមានចំនួន ១០,១ភាគរយ និងស្ត្រីជាក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានចំនួន ១២,៦៥ភាគរយ ។

២៦៤. បន្ថែមលើនេះទៀត ចំនួនស្ត្រីជាមន្ត្រីរាជការ និងថ្នាក់ដឹកនាំនៅរដ្ឋបាលមូលដ្ឋាន ក៏មានការកើនឡើងដែរ ។ *ក្រសួងមហាផ្ទៃ* បានរៀបចំតែងតាំងស្ត្រីជាអភិបាលរង រាជធានី ខេត្ត បាន ចំនួន ២៤នាក់ និង អភិបាលរង ក្រុង ស្រុក ខណ្ឌ បានចំនួន ១៩៧នាក់ នៅទូទាំងប្រទេស ។ ទន្ទឹមនឹងនេះដែរ *រដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ* បានចេញសេចក្តីណែនាំស្តីពី ការកំណត់កម្រិតពី ២០ ទៅ ៥០ភាគរយ សម្រាប់ស្ត្រី ក្នុងការជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ នៅក្នុងស្ថាប័នសាធារណៈ នានា ។ ជាក់ស្តែង យើងសង្កេតឃើញថាចំនួនមន្ត្រី រាជការជាស្ត្រីបានកើនឡើងពី ៣២ភាគរយ ក្នុងឆ្នាំ២០០៧ ដល់ ៣៤ភាគរយ ក្នុងពាក់កណ្តាលឆ្នាំ២០០៩ ។ ទោះជាដូចនេះក្តីក៏តំណាងស្ត្រីក្នុងអង្គនីតិប្រតិបត្តិនៅគ្រប់កម្រិត នៃរាជរដ្ឋាភិបាល នៅតែមានកម្រិតទាបនៅឡើយ ជាពិសេសក្នុងតួនាទីធ្វើសេចក្តីសម្រេចជាន់ខ្ពស់ ទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងរដ្ឋបាលថ្នាក់ស្រុក ។ លើសពីនេះទៀត ចំនួនស្ត្រីនៅក្នុងអង្គតុលាការ ដូចជាចៅក្រម និងព្រះរាជអាជ្ញា ក៏មានកម្រិតតិចតួចបំផុត បើប្រៀបធៀបនឹងបុរស ។

## ការបញ្រ្ជាបយេនឌ័រ ក្នុងគោលនយោបាយនិងកម្មវិធីជាតិ

២៦៥. ដោយមានកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ជាតិ និងអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យគួរជាទីមោទនៈ ក្នុងការបញ្ជ្រាបយេនឌ័រ និងបញ្ចូលសិទ្ធិស្ត្រីទៅក្នុងគោលនយោបាយជាតិសំខាន់ៗ ដែលរួមមានដូចជា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក) ផយអជ ២០០៦-២០១០ ផែនការសកម្មភាពអភិបាលកិច្ចលើកទីពីរ* និង*សូចនាករតាមដានរួមគ្នា របស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ។ ទន្ទឹមនឹងនេះ បញ្ហានិងយុទ្ធសាស្ត្រយេនឌ័រ ក៏ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដែរ ដូចជា *កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទីពីរ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ* និង *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* ព្រមទាំង *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* រយៈពេល ១០ឆ្នាំ ជាដើម ។ល ។

២៦៦. សមិទ្ធផលមួយដែលគួរឱ្យកត់សម្គាល់ ផងដែរ គឺ ការបង្កើតនិងការពង្រឹងយន្តការជាតិ សម្រាប់គាំទ្រការបញ្ជ្រាបយេនឌ័រនៅ*កម្ពុជា* ដែលក្នុងនោះរួមមាន ការបង្កើត*ក្រុមការងារបច្ចេកទេសយេនឌ័រ* ដែលជាផ្នែកមួយរបស់*គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* និងការបង្កើត*ក្រុមការងារបញ្ជ្រាបយេនឌ័រ*នៅស្ទើរគ្រប់ក្រសួង-ស្ថាប័នពាក់ពន្ធ័ទាំងអស់របស់ *រាជរដ្ឋាភិបាលកម្ពុជា* ហើយក្នុងចំណោមនោះ ក្រសួង-ស្ថាប័នចំនួន ១៥ បានរៀបចំបង្កើតផែនការ *យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ* សម្រាប់វិស័យខ្លួនរួចហើយដែរ (រួមមាន *ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងព័ត៌មាន ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*)។ ចំណែកឯក្រសួង-ស្ថាប័នចំនួន បួនទៀត ដូចជា *ក្រសួងបរិស្ថាន ក្រសួងសាធារណៈការនិងដឹកជញ្ជូន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* កំពុងដំណើរការរៀបចំផែនការនេះ ។ ទន្ទឹមនឹងនេះ ក្រសួងចំនួន ១៦ បានទទួលកញ្ចប់ថវិកាជាតិ ឬទទួលជំនួយពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តផែនការបញ្ជ្រាបយេនឌ័រតាមវិស័យ ។ ក្រសួងទាំងនោះ រួមមាន *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងយុត្តិធម៌ ក្រសួងការបរទេស ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* និង *ក្រសួងពាណិជ្ជកម្ម* ។

២៦៧. ទោះជាដូចនេះក្តី ក៏ការជំរុញឱ្យមានការកែប្រែ ផ្នត់គំនិតនិងឥរិយាបថរបស់សង្គម ចំពោះទស្សនៈសមភាពយេនឌ័រ និងសិទ្ធិស្ត្រី ត្រូវចំណាយពេលវេលាយូរ និងតម្រូវឱ្យមានការប្តេជ្ញាចិត្តខ្ពស់ ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ លើសពីនេះទៀត សមត្ថភាពជាតិក្នុងការវិភាគ ការស្រាវជ្រាវ និងការស្វែងរកការគាំទ្រមតិ ផ្នែកយេនឌ័រ ដែលផ្អែកលើព័ត៌មាននិងទិន្នន័យជាក់លាក់ ទាមទារឱ្យមានការពង្រឹងបន្ថែមទៀត ។ ការធ្វើឱ្យមានសុខដុមនីយកម្ម រវាងផែនការបញ្ជ្រាបយេនឌ័រ ផែនការយុទ្ធសាស្ត្រតាមវិស័យ និងយន្តការតាមដានត្រួតពិនិត្យ ព្រមទាំង ការកៀរគរធនធានសមស្រប ដើម្បីអនុវត្តផែនការបញ្ជ្រាបយេនឌ័រតាមវិស័យប្រកបដោយប្រសិទ្ធភាព នៅតែជាបញ្ហាប្រឈមដ៏ចម្បងសម្រាប់*កម្ពុជា* ដែលទាមទារការយកចិត្តទុកដាក់ពីគ្រប់ក្រសួង-ស្ថាបន័ទាំងអស់របស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការបញ្ចូលបញ្ហានេះ ទៅក្នុងផែនការនិងក្របខណ្ឌតាមដាននានាតាមវិស័យ ។

## ៦.៤ ការអនុវត្តគោលនយោបាយជាតិប្រជាជន

២៦៨. *គោលនយោបាយជាតិប្រជាជន* ដែលមានលក្ខណៈគ្របដណ្តប់ទូលំទូលាយគ្រប់ជ្រុងជ្រោយ ពាក់ព័ន្ធនឹងសកម្មភាព នានា នៅក្នុងវិស័យជាច្រើន ដូចជា សុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច យេនឌ័រ បម្លាស់ទីលំនៅ យុវជន ជនចាស់ជរា និង ផ្នែកផ្សេងៗទៀត ។ *គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ* និង ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត បាននិងកំពុងបន្ត ពង្រឹងសមត្ថភាពធនធានមនុស្ស សម្រាប់ការដាក់បញ្ចូលនូវបញ្ហាប្រជាជនទាំងឡាយ ទៅក្នុងដំណើរការ នៃការធ្វើផែនការអភិវឌ្ឍន៍នៅគ្រប់កម្រិត សម្រាប់អ្នករៀបចំផែនការ និងអ្នករៀបចំគោលនយោបាយ ។ គណៈកម្មាធិការជាតិនេះ បានរៀបចំឯកសារយោងផ្នែកប្រជាសាស្ត្រជាច្រើន ស្តីពី *គោលនយោបាយជាតិប្រជាជន* តារាងទិន្នន័យប្រជាជន នគរូបនីយកម្ម បម្លាស់ទីលំនៅ យុវជន ចាស់ជរា និង សូចនាករសម្រាប់គោលនយោបាយជាតិប្រជាជន ។ ឯកសារយោងទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយពី *គោលនយោបាយជាតិប្រជាជន* និង ពីទំនាក់ទំនងរវាងប្រជាជននិងការអភិវឌ្ឍ ទៅដល់ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរដ្ឋបាលមូលដ្ឋាន នៅគ្រប់ ២៣ខេត្ត និង រាជធានីភ្នំពេញ ។ ការផ្សព្វផ្សាយ*គោលនយោបាយជាតិប្រជាជន* ក៏បានធ្វើផងដែរ នៅ*សាលាភូមិន្ទរដ្ឋបាល និង រដ្ឋសភា* ។

២៦៩. ទោះបីជាសម្រេចបានសមិទ្ធផលជាច្រើនដូចនេះ ក៏ដោយ ក៏*គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ* និងដៃគូផ្សេងទៀត នៅមានបញ្ហាប្រឈមជាច្រើនទៀត ដែលត្រូវបន្តដោះស្រាយ ដូចជា :

- សមត្ថភាព និងចំណេះដឹង របស់អ្នកចូលរួម ស្តីពី បញ្ហាប្រជាជន នៅមានកម្រិត ។
- ខ្វះខាតទិន្នន័យថ្មីៗ សម្រាប់ធ្វើបច្ចុប្បន្នភាពសូចនាករប្រជាជន និងឯកសារយោងទាក់ទងនឹងប្រជាជន ។
- ខ្វះខាតការវិភាគស៊ីជម្រៅនូវបញ្ហានានាដែលទាក់ទងនឹងប្រជាជន ដែលចាំបាច់សម្រាប់ការស្វែងយល់ពីឫសគល់នៃបញ្ហា និងការដោះស្រាយ ។ ការយល់ដឹងផ្អែកលើភស្តុតាងនេះ មានសារៈសំខាន់ណាស់ដល់ប្រសិទ្ធភាពនៃផែនការសកម្មភាព ។

- ខ្វះខាតការត្រួតពិនិត្យនិងវាយតម្លៃ និងសកម្មភាពតាមដាន ។
- បញ្ហាប្រជាជន ត្រូវយកចិត្តទុកដាក់គិតគូរឱ្យបានសមស្រប នៅក្នុងការរៀបចំផែនការតាមវិស័យ និងថ្នាក់ក្រោមជាតិ ក៏ដូចជា នៅក្នុងការតាមដានត្រួតពិនិត្យការអនុវត្តផែនការទាំងនោះ ។
- សមត្ថភាពសម្រាប់ ប្រមូលនិងវិភាគ ទិន្នន័យស្តីពីបញ្ហាប្រជាជន នៅមានកម្រិតនៅឡើយ ។
- បញ្ហាប្រជាជននានាដែលបាននិងកំពុងលេចឡើង ត្រូវធ្វើការដោះស្រាយឱ្យបានល្អប្រសើរជាងមុន ។
- សមត្ថភាព និងឧបករណ៍នានា សម្រាប់ការប្រមូលទិន្នន័យ ការវិភាគគោលនយោបាយ និងការរៀបចំផែនការ ទាក់ទងនឹងប្រជាជន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមានកម្រិតនៅឡើយ ។
- សមត្ថភាពសម្រាប់ការវិភាគ និងការបកស្រាយ ទិន្នន័យប្រជាជន ចាំបាច់ត្រូវតែធ្វើការពង្រឹង នៅគ្រប់កម្រិតទាំងអស់ ដើម្បីជំរុញឱ្យមានការប្រើប្រាស់បានកាន់តែល្អប្រសើរជាងមុន នូវទិន្នន័យដែលមាន និង ទិន្នន័យដែលប្រមូលបាន ។

២៧០. *ការធ្វើជំរឿនប្រជាជន* ដប់ឆ្នាំម្តង ត្រូវបានធ្វើឡើងនៅខែមីនា ឆ្នាំ២០០៨ បន្ទាប់ពីការរៀបចំ ដោយប្រុងប្រយ័ត្ននិងដោយល្អិតល្អន់ ។ ការងារនេះត្រូវបានធ្វើឡើងដោយបុគ្គលិកកម្ពុជាទាំងស្រុង ដែលចង្អុលបង្ហាញពីសមត្ថភាពដែលត្រូវបានកសាងឡើង សម្រាប់ការរាប់និងការងារវិភាគដ៏ធំបែបនេះ ។ ដោយបានប្រើប្រាស់នូវអ្នកសម្ភាសន៍ ប្រមាណ ៣៥ ០០០នាក់ និងបានគ្របដណ្តប់លើគ្រួសារទាំងអស់ (២,៨លាន) និងលើប្រជាជនបណ្តោះអាសន្ន ការធ្វើជំរឿននេះ គឺជាការងារមួយដ៏ធំ ដែលត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាពនិងដោយជោគជ័យ ។ លទ្ធផលចុងក្រោយនៃជំរឿនឆ្នាំ២០០៨ បង្ហាញថា :

- នៅ ឆ្នាំ២០០៨ ប្រជាជនសរុបមានចំនួន ១៣,៤លាននាក់ តិចជាងការប៉ាន់ស្មានពីមុន ដែលមាន ប្រមាណ ១៣,៨លាននាក់ ដោយមានសមាមាត្រប្រមាណ ២,៣ភាគរយ នៃប្រជាជននៅអាស៊ីអគ្នេយ៍ ទាំងមូល នៅក្នុងឆ្នាំ២០០៨ ។
- អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ ត្រូវបានរកឃើញថា បានថយចុះជាប្រចាំ ពី ២,៥ភាគរយ ក្នុងមួយឆ្នាំ ក្នុងឆ្នាំ១៩៩៨ (ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨) មកត្រឹម ១,៥ ភាគរយ ក្នុងមួយឆ្នាំ សម្រាប់ ពីឆ្នាំ១៩៩៨ ដល់ ២០០៨ ។ កំណើនមធ្យមនេះ មានកម្រិតតិចជាងការប៉ាន់ស្មាន ពីមុន ដែលមាន ១,៨ភាគរយ ប៉ុន្តែនៅតែខ្ពស់ជាងកម្រិតមធ្យមសម្រាប់កម្រិតតំបន់បន្តិចនៅឡើយ (១,៣ភាគរយ) ។
- អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ នៅតំបន់ទីប្រជុំជនក្នុងឆ្នាំ២០០៨ មានកម្រិត ២,៦ភាគរយ ខ្ពស់ជាងនៅតំបន់ជនបទ ដែលមានកម្រិត ១,៣ភាគរយ ។
- សមាមាត្រភេទ គឺ បុរសមាន ៩៤,២ភាគរយ ធៀបនឹងស្ត្រី ១០០នាក់ ដោយកើនឡើងពី ៩៣ភាគរយ នៅក្នុងឆ្នាំ១៩៩៨ ។

- ទំហំមធ្យមរបស់គ្រួសារ បានថយចុះប្រហែល ០,៥ នៅក្នុងគ្រប់តំបន់ទាំងអស់ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨ (នៅទូទាំងប្រទេស បានថយចុះពី ៥,២ ក្នុងឆ្នាំ១៩៩៨ មកត្រឹម ៤,៧ ឆ្នាំ២០០៨ នៅតំបន់ទីប្រជុំជន បានថយចុះពី ៥,៥ នៅក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ៥,០ នៅក្នុងឆ្នាំ២០០៨ និង នៅតំបន់ជនបទ បានថយចុះពី ៥,១ ក្នុងឆ្នាំ១៩៩៨ មកត្រឹម ៤,៦ ក្នុងឆ្នាំ២០០៨ ។ ទោះជាដូចនេះក្តី ក៏ការប្រែប្រួលនៃទំហំគ្រួសារមធ្យមនេះ គឺបណ្តាលមកពីការកើនឡើងនៃគ្រួសារថ្មី (ចំនួនគ្រួសារធម្មតា បានកើនឡើងពី ២,២លាន ក្នុងឆ្នាំ១៩៩៨ ដល់ ២,៨លាន ក្នុងឆ្នាំ២០០៨) ។
- ទោះបីជារចនាសម្ព័ន្ធអាយុ បង្ហាញថាប្រជាជនកម្ពុជាជាប្រជាជនក្មេង ក៏សមមាត្រប្រជាជនអាយុ ក្រោម ១៥ឆ្នាំ បានថយចុះពី ៤២,៨ភាគរយ ក្នុងឆ្នាំ១៩៩៨ មកត្រឹម ៣៩ភាគរយ ក្នុងឆ្នាំ២០០៤ និង មកត្រឹម ៣៣,៧ភាគរយ ក្នុងឆ្នាំ២០០៨ ។
- ជាមួយគ្នានេះដែរ សមាមាត្រប្រជាជនវ័យចាស់ មានការកើនឡើង ហើយអាយុកាលសង្ឃឹមរស់ពីកំណើត បានកើនឡើងពី ៥៤ឆ្នាំ ក្នុងឆ្នាំ២០០០ ដល់ ៦០ឆ្នាំ ក្នុងឆ្នាំ២០០៨ សម្រាប់បុរស និងពី ៥៨ឆ្នាំ ក្នុងឆ្នាំ ២០០០ ដល់ ៦៤,៣ឆ្នាំ ក្នុងឆ្នាំ២០០៨ សម្រាប់ស្ត្រី ។ ក្នុងឆ្នាំ១៩៩៨ អត្រាប្រជាជន អាយុពី ៦៥ឆ្នាំ ឡើងទៅ មាន ៣,៥ភាគរយ (៣ភាគរយ សម្រាប់បុរស និង ៣,៩ភាគរយ សម្រាប់ស្ត្រី) ។ នៅក្នុងឆ្នាំ២០០៨ តួលេខនេះបានកើនឡើងដល់ ៤,៣ភាគរយ (៣,៥ភាគរយ ក្នុងចំណោមបុរស និង ៥ភាគរយ ក្នុងចំណោមស្ត្រី) ។
- ការថយចុះនៃចំនួនកុមារអាយុក្រោម ១៥ឆ្នាំ មានកម្រិតខ្ពស់ជាង ការកើនឡើងនៃចំនួន ប្រជាជនវ័យចាស់ ដែលនាំឱ្យមានការថយចុះអត្រាប្រជាជនស្ថិតនៅក្រោមបន្ទុក ពី ៨៦,១ភាគរយ (៦០ភាគរយ ក្នុងតំបន់ទីប្រជុំជន និង ៨៩,៧ភាគរយ ក្នុងតំបន់ជនបទ) ក្នុងឆ្នាំ១៩៩៨ មកត្រឹម ៧៤ ភាគរយ (៥៩,៧ ភាគរយ នៅតំបន់ទីប្រជុំជន និង ៧៦,៨ភាគរយ ក្នុងតំបន់ជនបទ) ក្នុងឆ្នាំ២០០៤ និង មកត្រឹម ៦១,២ភាគរយ (៤០,៨ភាគរយ ក្នុងតំបន់ទីប្រជុំជន និង ៦៧,១ភាគរយ នៅក្នុងតំបន់ជនបទ) ក្នុងឆ្នាំ២០០៨ ។
- ប្រជាជននៅតំបន់ទីប្រជុំជន មាន ១៩,៥ភាគរយ កើនឡើងពី ១៧,៤ភាគរយ ក្នុងឆ្នាំ១៩៩៨ ចំណែកឯប្រជាជននៅតំបន់ជនបទ មាន ៨០,៥ភាគរយ ថយចុះពី ៨២,៤ភាគរយ ក្នុងឆ្នាំ១៩៩៨ ។
- *តួលេខជំរឿនប្រជាជន*ឆ្នាំ២០០៨ បានរំលេចយ៉ាងច្បាស់ ពីភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយជាតិប្រជាជន របស់*រាជរដ្ឋាភិបាលកម្ពុជា* ។

# ជំពូកទី៣

# គ្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣

## ១. ស្ថានភាពសេដ្ឋកិច្ច នាពេលចាប់ផ្តើម ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣

២៧១. កិច្ចខិតខំប្រឹងប្រែងរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការថែរក្សា ស្ថិរភាពនយោបាយនិងសង្គម សន្តិភាពនិងសន្តិសុខផ្ទៃក្នុង និងការគ្រប់គ្រងសេដ្ឋកិច្ចដោយភាពម៉ឺងម៉ាត់ បានធ្វើឱ្យកម្ពុជាសម្រេចបាននូវ អត្រាកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ កម្រិតខ្ពស់ ក្នុងទស្សវត្សរ៍ចុងក្រោយនេះ ។ ទោះជាយ៉ាងនេះក៏ដោយ ការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* នឹងចាប់ផ្តើម ខណៈពេលដែលស្ថានភាពសកលលោក កំពុងស្ថិតក្នុងភាពមិនច្បាស់លាស់ ដោយសារតែបណ្តាប្រទេសអភិវឌ្ឍនិងកំពុងអភិវឌ្ឍ កំពុងតែមមាញឹក ក្នុងការកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលលោក ដែលបានកើតឡើង នាចុងឆ្នាំ២០០៧ ដោយបណ្តាលឱ្យមានការធ្លាក់ចុះយ៉ាងខ្លាំង នៅបណ្តាសេដ្ឋកិច្ចជឿនលឿននានា ។ សេដ្ឋកិច្ចកម្ពុជា បានចាប់ផ្តើមរងឥទ្ធិពលអវិជ្ជមានពីវិបត្តិនេះ នៅឆ្នាំ២០០៨ ដោយកំណើន*ផសស* សម្រេចបានតែ ៦,៧ភាគរយ ប៉ុណ្ណោះ បើធៀបនឹង ១០,២ភាគរយ ក្នុងឆ្នាំ២០០៧ ។ ការបន្តធ្លាក់ចុះនៃសេដ្ឋកិច្ច នៅបណ្តាប្រទេសអភិវឌ្ឍ (គិតមកដល់ពាក់កណ្តាលឆ្នាំ២០០៩) នឹងមានផលប៉ះពាល់យ៉ាងខ្លាំងមកលើសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលខ្លី គឺ ឆ្នាំ២០០៩ និង ២០១០ ។

២៧២. *រាជរដ្ឋាភិបាល* ត្រូវប្រឈមនឹងការងារដ៏ធំមួយ ដើម្បីឆ្លើយតបទៅនឹងការវិវត្តខាងក្រៅប្រទេស និងដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលសម្រេចបានក្នុងទស្សវត្សរ៍ចុងក្រោយនេះ ។ ទោះបីជាមានការធ្លាក់ចុះសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៩ និង ២០១០ ក៏ដោយ ក៏*រាជរដ្ឋាភិបាល* បានប្តេជ្ញាថែរក្សាសមិទ្ធផលដែលសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងទស្សវត្សរ៍ចុងក្រោយនេះ ។ *រាជរដ្ឋាភិបាល* នឹងប្រើប្រាស់គ្រប់វិធានការចាំបាច់ទាំងអស់ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការវិវត្តខាងក្រៅប្រទេស មកលើជនងាយរងគ្រោះ និងប្រជាជនជនក្រីក្រ ជាពិសេស ប្រជាជននៅតាមតំបន់ជនបទ ។ ចាប់តាំងពីការបោះឆ្នោតជាសាកលលើកទី១ ក្នុងឆ្នាំ១៩៩៣ មក *រាជរដ្ឋាភិបាលកម្ពុជា* បានប្រឈមនឹង ព្រមទាំង បានជំនះលើ ឧបសគ្គធំៗជាច្រើន ហើយក៏មានទំនុកចិត្តថា នឹងអាចដោះស្រាយបញ្ហាលំបាកទាំងឡាយដែលមាននាបច្ចុប្បន្ននេះ ដោយមានកិច្ចសហការ ពីប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ និង ពីដៃគូអភិវឌ្ឍន៍ថ្មីនិងចាស់ ។ បើពិនិត្យមើលជាលក្ខណៈប្រវត្តិសាស្ត្រ ចាប់តាំងពីការបង្កើត*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី១ នៃរដ្ឋសភា* ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា អាចបែងចែកជា ៣ ដំណាក់កាលសំខាន់ៗ គឺ :

- *ដំណាក់កាលស្តារ ១៩៩៣ - ១៩៩៨*
- *ដំណាក់កាលកសាងឡើងវិញ ១៩៩៩ - ២០០៣*
- *ដំណាក់កាលងើបឡើង ២០០៤ - ២០០៨*

២៧៣. ***ដំណាក់កាលស្តារ ឆ្នាំ១៩៩៣-១៩៩៨ :*** នៅពាក់កណ្តាលទសវត្សរ៍ ឆ្នាំ១៩៨០ ប្រទេសកម្ពុជា បានអនុវត្តកម្មវិធីកំណែទម្រង់ជាច្រើន ដើម្បីប្តូរពីប្រព័ន្ធសេដ្ឋកិច្ចផែនការ ទៅជា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ សមាសធាតុដំបូងចាំបាច់នានា នៃសេដ្ឋកិច្ចទីផ្សារ ត្រូវបានបង្កើតឡើង ដូចជា ការអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជន ដំណើរការឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ និង វិសមូហភាវូបនីយកម្មក្នុងវិស័យកសិកម្ម ដែលកត្តាទាំងនេះ បានបើកផ្លូវឱ្យមាន ការបង្រួបបង្រួមជាតិ និង *ការបោះឆ្នោតជាសកល* លើកទីមួយ ក្នុងឆ្នាំ១៩៩៣ ។ ទោះជាដូចនេះក្តី ក៏កិច្ចខិតខំប្រឹងប្រែងរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី១* ក្នុងការកែទម្រង់ទីផ្សារ បានរងសម្ពាធ ពីអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ដែលបណ្តាលមកពីកត្តាជាច្រើន ដូចជា :

- សេរីភាវូបនីយកម្មសេដ្ឋកិច្ច ដែលបានចាប់ផ្តើមនាចុងទសវត្សរ៍ ឆ្នាំ១៩៨០ បានបង្កជាឧបសគ្គ ដល់ការកៀរគរចំណូលរដ្ឋ ។ *ឯកជនភាវូបនីយកម្មនៃសហគ្រាសរដ្ឋ* និង កំណែទម្រង់សហគ្រាស រួមផ្សំជាមួយសេរីភាវូបនីយកម្មនៃការកំណត់ថ្លៃ និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម បានកាត់បន្ថយឧបត្ថម្ភធន ដែលសហគ្រាសសាធារណៈធ្លាប់បានទទួលពីពេលមុន ។ ការបាត់បង់ចំណូលនេះ មិនអាចត្រូវជំនួសបានភ្លាមៗ ដោយចំណូលពីវិស័យឯកជន ដែលកំពុងតែងើបឡើងនោះទេ ។
- ក្នុងផ្នែកចំណាយវិញ ការបញ្ចប់ការគ្រប់គ្រងថ្លៃ បានបណ្តាលឱ្យ ថ្លៃដើមឯកតានៃទំនិញនិងសេវាកម្មដែលត្រូវផ្គត់ផ្គង់ សម្រាប់ប្រតិបត្តិការនិងការវិនិយោគ កើនឡើងយ៉ាងខ្លាំង ។ គោលនយោបាយរបស់ *រាជ-រដ្ឋាភិបាលកម្ពុជា* ក្នុងការរក្សា ចំណាយលើប្រាក់បៀវត្សរ៍របស់បុគ្គលិករដ្ឋ និងចំណាយលើការការពារជាតិ បានកាត់បន្ថយវិនិយោគសាធារណៈ និង ចំណាយលើប្រតិបត្តិការនិងការថែទាំ។
- កម្ចីក្រោមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មនិងការទូទាត់ ឆ្នាំ១៩៨៦-១៩៩០ ជាមួយ *សហភាពសូវៀត* ត្រូវបានបញ្ឈប់ ។ ជំនួយជាទំនិញដែលទទួលបានក្រោមកិច្ចព្រមព្រៀងនេះ បានរួមចំណែក ១៥ ភាគរយ នៃចំណាយថវិកាសរុប ក្នុងឆ្នាំ១៩៨៩ ។ ជំនួយមនុស្សធម៌ ដែលទទួលបាន មានប្រមាណតែពី ២០-៣០ លានដុល្លារអាមេរិក ប៉ុណ្ណោះ ក្នុងឆ្នាំ ១៩៩១-១៩៩២ ។
- នៅក្នុងស្ថានភាពទាំងនេះ *រាជរដ្ឋាភិបាលកម្ពុជា* ត្រូវដោះស្រាយបញ្ហាឱនភាពថវិកា ដោយការបោះពុម្ពក្រដាសប្រាក់បន្ថែម ។ ការធ្វើហិរញ្ញប្បទាន ដោយការបោះពុម្ពក្រដាសប្រាក់បន្ថែម បានគ្របដណ្តប់ជាងពាក់កណ្តាលនៃកង្វះថវិការដ្ឋ ក្នុងឆ្នាំ១៩៩១ ហើយ ចំណាយ ២០ភាគរយ ត្រូវបានជំពាក់ ។ ការបើកប្រាក់បៀវត្សរ៍មិនសូវទៀងទាត់ ។ ការធ្វើហិរញ្ញប្បទានដល់ឱនភាពថវិកា ដោយការបោះពុម្ពក្រដាសប្រាក់បន្ថែម បានធ្វើឱ្យកម្រិតអតិផរណាឡើងខ្ពស់ ។ កត្តានេះ បានបណ្តាលឱ្យ សាធារណជនគ្មានជំនឿទុកចិត្តលើរូបិយវត្ថុជាតិ ហើយ បានធ្វើឱ្យដុល្លារូបនីយកម្ម មានកម្រិតខ្ពស់ ។

២៧៤. ការបង្កើតឡើងនូវ *រាជរដ្ឋាភិបាលកម្ពុជា* នាឆ្នាំ១៩៩៣ បាននាំដល់ការបញ្ចប់ហ៊ុំព័ទ្ធសេដ្ឋកិច្ចលើកម្ពុជា ដែលអនុវត្តតាំងពីឆ្នាំ១៩៧៩ មក ហើយនាំមកនូវលំហូរនៃ ការវិនិយោគផ្ទាល់ពីបរទេស និង ជំនួយអភិវឌ្ឍន៍ផ្លូវការ សម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ ។ ក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៨ ប្រទេសកម្ពុជា មានទាំង សន្តិភាពនិងសង្គ្រាម ។

*រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី១* មិនអាចផ្តល់អាទិភាពពេញលេញលើការអភិវឌ្ឍសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្របានឡើយ ដោយត្រូវប្រយុទ្ធជាមួយ *ខ្មែរក្រហម* នៅតំបន់ជាច្រើននៃផ្ទៃប្រទេស ។ ចំណាយលើវិស័យការពារជាតិនិងសន្តិសុខ មានប្រមាណ ៦,៣ភាគរយ នៅពេលដែល ចំណាយសង្គមកិច្ចមានប្រមាណតែ ២,១ភាគរយ ប៉ុណ្ណោះ នៃ*ផសស* ក្នុងឆ្នាំ១៩៩៤ ។ ទោះជាដូចនេះក្តី ក៏*រាជរដ្ឋាភិបាលកម្ពុជា* បានចាប់ផ្តើមធ្វើកំណែទម្រង់ដំណាក់កាលទីមួយ ។ អត្រាអតិផរណាធ្លាក់ពី ១២១ភាគរយ ក្នុងឆ្នាំ១៩៩១ មក -០,៧ភាគរយ ក្នុងឆ្នាំ១៩៩៣ ។ ប្រព័ន្ធគ្រប់គ្រងថវិកា បែបប្រទេសបារាំង ត្រូវបានយកមកអនុវត្ត ហើយក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត ត្រូវបានបង្កើតឡើងសម្រាប់សហគ្រាសសាធារណៈ ។ ជាមួយនឹងការអនុវត្តនូវ ***យុទ្ធសាស្ត្រ ឈ្នះ-ឈ្នះ*** របស់*រាជរដ្ឋាភិបាលកម្ពុជា* រចនាសម្ព័ន្ធយោធានិងនយោបាយរបស់ខ្មែរក្រហម ត្រូវបានបញ្ចប់ ក្នុងឆ្នាំ១៩៩៨ ហើយមូលដ្ឋានគ្រឹះសម្រាប់សន្តិភាព សន្តិសុខ និងកំណើនសេដ្ឋកិច្ច ក៏ត្រូវបានធានាឱ្យមាន ។ ទោះជាមានឧបសគ្គជាច្រើនក៏ដោយ ក៏កំណើនសេដ្ឋកិច្ចមធ្យម ក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៧ មាន ៦,៦ភាគរយ ។ កំណើនសេដ្ឋកិច្ចនាពេលនោះ គឺ សម្រេចបានដោយសារ ការប្រើប្រាស់យ៉ាងច្រើនលើសលប់នូវធនធានធម្មជាតិ ជំនួយអភិវឌ្ឍន៍ផ្លូវការ និងលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេស មកក្នុងវិស័យហិរញ្ញវត្ថុ ។ ពីឆ្នាំ១៩៩៤-១៩៩៨ ជំនួយអភិវឌ្ឍន៍ផ្លូវការមួយភាគធំ ត្រូវបានប្រើប្រាស់ដើម្បីស្តារ សមត្ថភាពផលិតថាមពលនិងការផ្គត់ផ្គង់ទឹកស្អាតឡើងវិញ ។ អនុវិស័យ អគ្គិសនី ឧស្ម័ន និងទឹក នៃវិស័យឧស្សាហកម្ម បានកើនជាមធ្យមប្រមាណ ១៤,៩ភាគរយ ក្នុងមួយឆ្នាំ ។ រដ្ឋបាលសាធារណៈ បានកើន ២០,៨ភាគរយ ហើយ វិស័យហិរញ្ញវត្ថុ បានកើនឡើងជាមធ្យម ៣៨,៩ភាគរយ ក្នុងមួយឆ្នាំ ។

២៧៥. ***ដំណាក់កាលកសាងឡើងវិញ ១៩៩៩-២០០៣*** : ក្នុង*នីតិកាលទី២* (១៩៩៨-២០០៣) *រាជរដ្ឋាភិបាលកម្ពុជា* បានអនុវត្ត *យុទ្ធសាស្ត្រត្រីកោណ* របស់ខ្លួនយ៉ាងខ្លាំងក្លា ដោយផ្តោតសំខាន់លើ *(១) រក្សាសន្តិភាពនិងសន្តិសុខ (២) ធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងក្នុងពិភពលោក* និង *(៣) ជំរុញការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច* ។ ការអនុវត្តដោយជោគជ័យនៃយុទ្ធសាស្ត្រនេះ អនុញ្ញាតឱ្យ*រាជរដ្ឋាភិបាលកម្ពុជា* រក្សាបាននូវ សន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ និងចាប់ផ្តើមកសាងស្ថាប័នប្រជាធិបតេយ្យឡើងវិញ ។ *កម្ពុជា* ត្រូវបានទទួលស្គាល់ជាអន្តរជាតិឡើងវិញ បន្ទាប់ពីការផ្ទុះអាវុធ ក្នុងឆ្នាំ១៩៩៧ ។ *កម្ពុជា* ត្រូវបានផ្តល់អាសនៈនៅ*អង្គការសហប្រជាជាតិ* ក្នុងខែធ្នូ ឆ្នាំ១៩៩៨ និងក្លាយជាសមាជិកនៃ*សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍* ក្នុងឆ្នាំ១៩៩៩ ។ លក្ខខណ្ឌទាំងនេះបានអនុញ្ញាតឱ្យ*រដ្ឋាភិបាលកម្ពុជា* ធ្វើឱ្យកាន់តែស៊ីជម្រៅនិងពង្រីកបន្ថែមទៀតនូវ កម្មវិធីកំណែទម្រង់ផ្សេងៗរបស់ខ្លួន ។ របៀបវារៈនៃកំណែទម្រង់បានផ្តោតទៅលើ *ការរក្សានិរន្តរភាពកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ការជំរុញដំណើរការស្តារនាសេដ្ឋកិច្ចឡើងវិញ ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការអនុវត្តនូវវិធានការបន្ថែមក្នុងកំណែទម្រង់សារពើពន្ធ ការធានាឱ្យមាននូវការគ្រប់គ្រងល្អលើទ្រព្យសម្បត្តិសាធារណៈ* និង *ការបង្កើនវិនិយោគសាធារណៈ លើហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម និងការអភិវឌ្ឍធនធានមនុស្ស* ។

២៧៦. ក្នុងអំឡុងឆ្នាំ១៩៩៩-២០០៣ កំណើនសេដ្ឋកិច្ចជាមធ្យម សម្រេចបានប្រមាណ ៨,៨ភាគរយ ក្នុងមួយឆ្នាំ ។ ទោះបីជាជំនួយអភិវឌ្ឍន៍ផ្លូវការ បានបន្តធ្វើហិរញ្ញប្បទានដល់កំណើនសេដ្ឋកិច្ចក៏ដោយ ក៏ការវិនិយោគផ្ទាល់ពីបរទេស ជាពិសេស លើរោងចក្រកាត់ដេរនិងទេសចរណ៍ គឺនៅតែជាកត្តាគន្លឹះសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ក្នុងអំឡុងពេលនោះដែរ ។ អនុវិស័យសម្លៀកបំពាក់ បានកើនឡើងដល់ ៣៥,១ភាគរយ ក្នុងមួយឆ្នាំ ។ អនុវិស័យសំណង់ បានក្លាយជាសសរទ្រូងមួយនៃកំណើន ដោយមានកំណើនជាមធ្យម ២០,១ភាគរយ ក្នុងមួយឆ្នាំ ។ សន្តិភាពដែលទើបទទួលថ្មីៗ បានធ្វើឱ្យវិស័យទេសចរណ៍ មានការរីកចម្រើនយ៉ាងលឿន ដោយមានអត្រាកំណើនជាមធ្យម ១៣,៦ ភាគរយ ក្នុងមួយឆ្នាំ ។ ការបន្តស្តារឡើងវិញលើបញ្ហាថាមពលនិងទឹក បានធ្វើឱ្យមានការរីកចម្រើនក្នុង អនុវិស័យអគ្គិសនី ឧស្ម័ន និងទឹក ដោយមានអត្រាកំណើនជាមធ្យម ១០,២ភាគរយ ។ ទោះបីជាការរួមចំណែករបស់វិស័យកសិកម្មក្នុង *ផសស សរុប* បានថយចុះបន្តិច ខណៈពេលដែលវិស័យផ្សេងៗ បានកើនឡើងក៏ដោយ ក៏វិស័យនេះបានរួមចំណែក ៣២,០ភាគរយ នៃ *ផសស សរុប* នៅក្នុងឆ្នាំ២០០៣ ដែរ ។

**តារាងទី៨ : សូចនាករម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ១៩៩៨ ឆ្នាំ១៩៩៩ ឆ្នាំ២០០១-២០០៨**

| | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាកំណើន *ផសស ពិត* (%) | ៩,១ | ១១,៩ | ៨,៨ | ៨,១ | ៦,៦ | ៨,៥ | ១០,៣ | ១៣,៣ | ១០,៨ | ១០,២ | ៦,៧ |
| -កសិកម្ម (%) | ៩,៧ | ២,២ | -០,៤ | ៣,៦ | -២,៥ | ១០,៥ | -០,៩ | ១៥,៧ | ៥,៥ | ៥,០ | ៥,៧ |
| -ឧស្សាហកម្ម (%) | ១៤,២ | ២១,២ | ៣១,២ | ១១,២ | ១៧,១ | ១២,០ | ១៦,៦ | ១២,៧ | ១៨,៣ | ៨,៤ | ៤,០ |
| -សេវាកម្ម (%) | ០,៦ | ១៤,៦ | ៨,៩ | ១១,១ | ៧,៧ | ៥,៩ | ១៣,២ | ១៣,១ | ១០,១ | ១០,១ | ៩,០ |
| *ផសស* សម្រាប់ម្នាក់ៗ (ដុល្លារ) | ២៤៨ | ២៨១ | ២៨៨ | ៣១២ | ៣៣១ | ៣៥៦ | ៤០២ | ៤៦៨ | ៥៣៤ | ៦២៣ | ៧៣៨ |
| សញ្ជ័យជាតិ (% នៃ*ផសស*) | ១៩,៤ | ១៦,៥ | ១៧,៦ | ២០,២ | ២១,៥ | ១៦,៣ | ១៦,៤ | ១៧,៣ | ២១,១ | ២៣,៨ | ១៦,៩ |
| សញ្ជ័យរបស់រដ្ឋបាលថ្នាក់កណ្តាល (% នៃ*ផសស*) | -១,០ | ១,៦ | ១,៣ | ០,៩ | ០,៩ | ០,៨ | ១,៦ | ១,៧ | ១,០ | ៣,១ | ៣,០ |
| សញ្ជ័យឯកជន (% នៃ*ផសស*) | ២០,៤ | ១៤,៩ | ១៦,២ | ១៩,៣ | ២០,៦ | ១៥,៦ | ១៤,៨ | ១៥,៦ | ២២,១ | ២០,៧ | ១៣,៩ |
| វិនិយោគក្នុងស្រុក (% នៃ*ផសស*) | ១២,១ | ១១,៨ | ១២,១ | ១២,១ | ១១,៩ | ១២,២ | ១១,៨ | ១១,១ | ១១,២ | ១១,១ | ១១,៣ |
| វិនិយោគសាធារណៈ (% នៃ*ផសស*) | ៤,៧ | ៥,៤ | ៥,៩ | ៧,១ | ៨,៤ | ៦,៥ | ៥,៨ | ៥,៣ | ៥,៩ | ៦,២ | ៦,៥ |
| វិនិយោគឯកជន (% នៃ*ផសស*) | ១៨,៧ | ១៦,៥ | ១៤,៧ | ១៤,២ | ១៤,២ | ១២,៨ | ១២,៩ | ១៦,៣ | ១៦,៩ | ២០,៤ | ១៨,០ |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ*

២៧៧. **ដំណាក់កាលសេដ្ឋកិច្ចងើបឡើង ឆ្នាំ២០០៤-២០០៨ :** ក្នុងដំណាក់កាលនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានពន្លឿនការអនុវត្តកំណែទម្រង់ជំហានទី២ ជាពិសេស ការអនុវត្ត*កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ។ ទន្ទឹមនឹងនេះ ការវិនិយោគលើវិស័យសង្គមកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីកាត់បន្ថយភាពក្រីក្រ ក៏ត្រូវបានបង្កើនផងដែរ ជាពិសេស នៅតាមទីជនបទ ។ កិច្ចខិតខំប្រឹងប្រែង ត្រូវបានផ្តោតលើ ការស្តារនិងកសាងប្រព័ន្ធធារាសាស្ត្រជនបទឡើងវិញ និងបណ្តាញផ្លូវថ្នល់ តាមខេត្តនិងជនបទ ។ កំណើនសេដ្ឋកិច្ចក្នុងអំឡុងពេលនេះ

សម្រេចបានជាមធ្យម ១០,៣ភាគរយ ក្នុងមួយឆ្នាំ ដែលក្នុងនោះ កំណើនខ្ពស់បំផុត គឺ ១៣,៣ភាគរយ នៅក្នុងឆ្នាំ ២០០៥ ។ ក្នុងឆ្នាំ២០០៨ សេដ្ឋកិច្ចកម្ពុជានៅតែមានកំណើនគួរឱ្យកត់សម្គាល់ ក្នុងអត្រាប្រចាំឆ្នាំ ៦,៧ភាគរយ ទោះបីជាបានថយចុះ ធៀបនឹងឆ្នាំ២០០៤-២០០៧ ដោយបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចសកលលោក ដែលបានចាប់ផ្តើម ពីចុងឆ្នាំ២០០៧មក ក៏ដោយ ។

**រូបទី១ : អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ១៩៩៤-២០០៨**




២៧៨. ចាប់តាំងពីឆ្នាំ១៩៩៣មក សមាសភាពតាមវិស័យនៃសេដ្ឋកិច្ច បានផ្លាស់ប្តូរយ៉ាងខ្លាំង ។ ពីឆ្នាំ១៩៩៣-២០០៨ ការរួមចំណែករបស់វិស័យនីមួយៗ (គិតតាមថ្ងៃបច្ចុប្បន្ន) មានការប្រែប្រួល ដូចខាងក្រោម :

- វិស័យកសិកម្មថយចុះពី ៤៥,៣ភាគរយ ក្នុងឆ្នាំ១៩៩៣ មក ៣២,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។
- វិស័យឧស្សាហកម្មកើនពី ១២,៦ភាគរយ ក្នុងឆ្នាំ១៩៩៣ ទៅ ២២,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។ ក្នុងវិស័យឧស្សាហកម្ម :
    - ➢ អនុវិស័យសម្លៀកបំពាក់ និងកម្មន្តសាលកាត់ដេរ បានកើនពី ១,០ភាគរយ ក្នុងឆ្នាំ១៩៩៣ ទៅ ១០,៣ភាគរយ ក្នុងឆ្នាំ២០០៨ ។
    - ➢ អនុវិស័យរ៉ែ បានកើនឡើងពី ០,២ភាគរយ ក្នុងឆ្នាំ ១៩៩៣ ទៅ ០,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។
    - ➢ អនុវិស័យសំណង់ឡើងពី ៣,៥ភាគរយ ក្នុងឆ្នាំ ១៩៩៣ ទៅ ៦,១ភាគរយ ក្នុងឆ្នាំ២០០៨ ។
- វិស័យសេវាកម្មមានការធ្លាក់ចុះបន្តិចពី ៣៩,៤ភាគរយ ក្នុងឆ្នាំ១៩៩៣ មក ៣៨,៨ភាគរយ ក្នុងឆ្នាំ២០០៨ ដោយសារ វិស័យឧស្សាហកម្មមានកំណើនខ្ពស់ ។ ក្នុងវិស័យសេវាកម្ម :
    - ➢ អនុវិស័យទេសចរណ៍និងសណ្ឋាគារ បានកើនពី ២,៣ភាគរយ ក្នុងឆ្នាំ១៩៩៣ ទៅ ៤,៥ភាគរយ ក្នុងឆ្នាំ២០០៨ ។
    - ➢ អនុវិស័យដឹកជញ្ជូននិងទូរគមនាគមន៍ បានកើនពី ៥,៥ភាគរយ ក្នុងឆ្នាំ១៩៩៣ ទៅ ៧,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។

- អនុវិស័យហិរញ្ញវត្ថុ បានកើនពី ០,៣ភាគរយ ក្នុងឆ្នាំ១៩៩៣ ដល់ ១,៣ភាគរយ ក្នុងឆ្នាំ ២០០៨ ។
- អនុវិស័យអចលនទ្រព្យ បានធ្លាក់ចុះពី ៩,១ភាគរយ ក្នុងឆ្នាំ១៩៩៣ មក ៦,៤ភាគរយ ក្នុងឆ្នាំ២០០៨ ។

២៧៩. ចាប់តាំងពីការបោះឆ្នោតជាសកលលើកទី១ ក្នុងឆ្នាំ១៩៩៣មក *ផសស សរុប* បានកើនពី ២,៤៨ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ១៩៩៤ ទៅ ១០,៣៤ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៨ ហើយ *ផសស* សម្រាប់មនុស្សម្នាក់ បានកើនពី ២៤៨ដុល្លារអាមេរិក ក្នុងឆ្នាំ១៩៩៤ ទៅ ៧៣៩ដុល្លារអាមេរិក ក្នុងឆ្នាំ២០០៨ ។ ក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយ ២០០៣-២០០៨ កំណើនសេដ្ឋកិច្ចដែលមានសន្ទុះខ្លាំង បានធ្វើឱ្យ*ផសស*សម្រាប់មនុស្សម្នាក់ បានកើនឡើងទ្វេដង ។ ទោះជាយ៉ាងណាក៏ដោយ ក៏ទំហំនៃ*ផសស សរុប* នៅតែស្ថិតក្នុងកម្រិតមធ្យមនៅឡើយ ពោលគឺ ១០,៣ពាន់លានដុល្លារអាមេរិក ។ *ផសស* នៃមនុស្សម្នាក់ៗ នឹងអាចកើនឡើងដល់ ១ 000 ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៥ ឬ អាចឆាប់ជាងនេះទៀត នៅពេលដែលមានចង្វាក់ផលិតកម្មប្រេងនិងឧស្ម័នចាប់ដំណើរការ ។

២៨០. យោងលើការសិក្សាមួយរបស់*ធនាគារពិភពលោក* កម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួន១៥ ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ នៅក្នុងចន្លោះឆ្នាំ១៩៩៨-២០០៧ ដែល ខ្ពស់ជាងប្រទេសចិនបន្តិច និង ខ្ពស់ជាងកំណើនមធ្យម ៨,៤ភាគរយ ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកទាំងមូល ។

**រូបទី២ : បណ្ដាប្រទេសដែលសន្ទុះសេដ្ឋកិច្ចខ្លាំងគ្នា ចន្លោះឆ្នាំ ១៩៩៨-២០០៧**




*ប្រភព : ធនាគារពិភពលោក*

២៨១. ដូចបានគូសបញ្ជាក់ពីខាងដើម ការកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតាមតំបន់ជនបទ នឹងនៅតែជាអាទិភាពចម្បងមួយ ក្នុងចំណោមអាទិភាពនានារបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងទសវត្សរ៍ក្រោយនេះ ដែលសម្រេចបានជាមធ្យម ប្រមាណ ១០ភាគរយ ក្នុងមួយឆ្នាំ បានលើកតម្កើងជីវភាពរស់នៅ និងកាត់បន្ថយចំនួនអ្នកក្រីក្រ នៅទូទាំងប្រទេស ។ លទ្ធផលនៃ*ការអង្កេតសង្គមនិងសេដ្ឋកិច្ចឆ្នាំ២០០៧* បានបង្ហាញថា ចំនួនប្រជាជនស្ថិតក្រោមបន្ទាត់ភាពក្រីក្រនៅទូទាំងប្រទេស បានថយចុះពី ៣៤,៨ភាគរយ ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ៣០,១ភាគរយ នៅឆ្នាំ២០០៧ គឺធ្លាក់ចុះ ៤,៧ភាគរយ ដែលជាមធ្យមបានធ្លាក់ចុះជាង ១ភាគរយ ក្នុងមួយឆ្នាំ ។ ទិន្នន័យនេះបង្ហាញថា *"រូបភាពនៃការធ្វើឱ្យប្រសើរឡើងនៃសុខុមាលភាព ក្នុងក្រុមបញ្ចភាគដែលក្រីក្របំផុត និង ក្រុមបញ្ចភាគដែលក្រីក្របំផុតបន្ទាប់ ត្រូវបានពង្រឹង តាមរយៈ ការធ្វើឱ្យប្រសើរឡើងនៃកត្តាជាច្រើន ដែលពាក់ព័ន្ធជាមួយនឹង ការផ្តល់សេវាកម្ម និង លទ្ធផលនានានៃការអភិវឌ្ឍមនុស្ស ។ សមិទ្ធផលជាច្រើន ត្រូវបានគេសង្កេតឃើញមាន នៅក្នុងវិស័យ អប់រំ សុខាភិបាល ផលិតកម្មកសិកម្ម និងអាហារូបត្ថម្ភ ។ លទ្ធភាពទទួលបានជារូបវន្ត នូវសេវាកម្មសាធារណៈផ្សេងៗ ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយគិតជា ចម្ងាយមធ្យមទៅកាន់មណ្ឌលសុខភាពឬសាលារៀន ដែលនៅជិតបំផុត ។ ប្រការទាំងនេះ ដោយរួមផ្សំជាមួយនឹង ការលើកកម្ពស់ទាំងបរិមាណនិងគុណភាពនៃបណ្តាញផ្លូវថ្នល់ និង ការកើនឡើងនៃប្រាក់ចំណូលពិត បង្ហាញឱ្យឃើញពីមូលហេតុនៃការធ្វើឱ្យប្រសើរឡើងនូវ អត្រានៃការសិក្សា ឬ ឥរិយាបថ នៃការគិតគូរដល់សុខភាព ។ ជាមួយគ្នានេះ លទ្ធផលការងារជាច្រើន ត្រូវបានបន្តធ្វើឱ្យប្រសើរឡើង ដូចជា កម្រិតមធ្យមនៃការទទួលបានការអប់រំ និងស្ថានភាពសុខភាពដែលត្រូវបានរាយការណ៍ ដោយសាមីខ្លួនផ្ទាល់"*[១] ។

២៨២. ការធានាឱ្យបាននូវជោគជ័យ ក្នុងការកាត់បន្ថយភាពក្រីក្រនាពេលអនាគត បានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនថែមទៀត ដែលបណ្តាលមកពីភាពចាំបាច់ក្នុងការការពារ សមិទ្ធផលដែលយើងសម្រេចបានដោយលំបាក ដែលបច្ចុប្បន្ននេះ កំពុងត្រូវបានយាយី ដោយវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ជាការពិតណាស់ ប្រសិនបើស្ថានភាពបច្ចុប្បន្ន នៅតែបន្តអូសបន្លាយសម្រាប់រយៈពេលមួយវែង នោះប្រជាជនទាំងឡាយដែលទើបនឹងបានរស់នៅក្នុងជីវភាពមួយ ស្ថិតនៅលើខ្សែបន្ទាត់ភាពក្រីក្រ នាពេលបច្ចុប្បន្ន អាចនឹងធ្លាក់មកនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រវិញ ។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងចាត់វិធានការបន្ទាន់ ដើម្បីពង្រីកប្រព័ន្ធសុវត្ថិភាពសង្គម តាមរយៈការឧបត្ថម្ភធនផ្សេងៗនិងការបង្កើតការងារអតិពលកម្ម ដូចជា កម្មវិធីស្បៀងនិងប្រាក់ពលកម្ម ជាដើម ដើម្បីការពារក្រុមជនងាយរងគ្រោះបំផុត និងប្រជាជនក្រីក្រ មិនឱ្យរងផលប៉ះពាល់អវិជ្ជមាន នៃការវិវត្តខាងក្រៅប្រទេស ។

---

[១] *ធនាគារពិភពលោក "ស្ថានភាពភាពក្រីក្រនិងនិន្នាការនៅកម្ពុជា : ការរកឃើញពី អង្កេតសេដ្ឋកិច្ច-សង្គមនៅកម្ពុជា ឆ្នាំ២០០៧" របាយការណ៍លេខ. ៤៨៦១៨-KH ទំព័រ viii ខែមិថុនា ឆ្នាំ២០០៩ ។*

## ២. ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០០៩-២០១៣

២៨៣. ទោះប្រឈមជាមួយនឹងភាពមិនច្បាស់លាស់ ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសាកលលោកក៏ដោយ ក៏*រាជរដ្ឋាភិបាលកម្ពុជា* បន្តប្តេជ្ញារក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយអនុវត្តវិធានការនានា ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះមកលើជនងាយរងគ្រោះនិងអ្នកក្រ ជាពិសេស ប្រជាជននៅតាមតំបន់ជនបទ ដើម្បីការពារលទ្ធផលដែលសម្រេចបាន ក្នុងការងារកាត់បន្ថយភាពក្រីក្រប៉ុន្មានឆ្នាំកន្លងមកនេះ ។ គោលដៅរយៈមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់*រាជរដ្ឋាភិបាល* គឺបន្តខិតខំដើម្បី *(១)* សម្រេចបាននូវអត្រាកំណើនជាមធ្យមប្រចាំឆ្នាំពី ៦-៧ ភាគរយ ក្នុងរយៈមធ្យមខាងមុខ *(២)* រក្សាអត្រាអតិផរណាឱ្យនៅក្រោម ៥ ភាគរយ *(៣)* កំណត់បំណុលបរទេសឱ្យមានកម្រិតប្រហាក់ប្រហែលនឹង លំហូរនៃហិរញ្ញប្បទានសម្បទាននិងការវិនិយោគផ្ទាល់ពីបរទេស និង *(៤)* រក្សាទុនបម្រុងបរទេស ស្មើនឹងការនាំចូលបីខែ ។ *រាជរដ្ឋាភិបាល* នឹងបន្តអនុវត្តគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ ដោយប្រយ័ត្នប្រយែង ដោយមានការផ្តោតទៅលើការពង្រីកមូលដ្ឋានសារពើពន្ធ សម្រាប់បង្កើនចំណូល ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២៨៤. ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក *រាជរដ្ឋាភិបាល* បានដាក់ចេញនូវវិធានការបន្ទាន់ជាច្រើន រួមមាន កញ្ចប់សារពើពន្ធជំរុញកំណើន និង ពង្រឹងការយកចិត្តទុកដាក់លើការគាំទ្រដល់កម្មវិធីសំណាញ់សុវត្ថិភាពសង្គម ដែលអនុវត្តដោយស្ថាប័នរដ្ឋនិងភ្នាក់ងារផ្សេងៗ ដើម្បីជួយក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ ។ នៅក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ *ធនាគារជាតិកម្ពុជា* បានឆ្លើយតបយ៉ាងឆាប់រហ័ស ដែលរួមមាន ការសម្រួលដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុមួយដែលជំរុញកំណើនសេដ្ឋកិច្ច និងការដាក់ចេញនូវវិធានការជាច្រើនទៀត ដើម្បីគាំទ្រនិងពង្រឹង ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ។ *រាជរដ្ឋាភិបាល* មានជំនឿថា តាមរយៈការអនុវត្តយ៉ាងស្វាហាប់នូវរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច ក្នុងនីតិកាលទី៤នៃ*រដ្ឋសភា* ដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ជាពិសេស គឺការអនុវត្តគោលនយោបាយដើម្បីធ្វើពិពិធកម្មនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ច និង ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងក្នុងទីផ្សារតំបន់និងពិភពលោក នឹងធ្វើឱ្យសេដ្ឋកិច្ចមានកំណើនឡើងវិញ ក្នុងរយៈមធ្យមខាងមុខ ដូចដែលធ្លាប់សម្រេចបានជាប្រវត្តិសាស្ត្រ នាពេលកន្លងមក ។

២៨៥. ក្នុងរយៈពេលខ្លីទៅមធ្យម *រាជរដ្ឋាភិបាល* នឹងបន្តអនុវត្តវិធានការ ដើម្បី :

- ពង្រឹងវិស័យហិរញ្ញវត្ថុដើម្បី កសាងទំនុកចិត្តក្នុងទីផ្សារឡើងវិញ និងទាក់ទាញមូលធនឯកជនបន្ថែមទៀត ។ ដើម្បីបង្កើតមូលដ្ឋានគ្រឹះ សម្រាប់កំណើនឥណទានធនាគារឡើងវិញ គោលនយោបាយក្នុងរយៈពេលខ្លីខាងមុខនឹងផ្តោតលើ ការកែប្រែរចនាសម្ព័ន្ធនៃស្ថាប័នហិរញ្ញវត្ថុទន់ខ្សោយ ដោយធ្វើការលាងសម្អាតទ្រព្យសកម្មដែលខូចឬបាត់បង់តម្លៃពីតារាងតុល្យការ ការវាយតម្លៃពីភាពជោគជ័យរបស់ធនាគារ និងការធានាឱ្យមានការបំពេញទុនបន្ថែមដល់ធនាគារ ប្រសិនបើចាំបាច់ ។

- បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនានា ដើម្បីជំរុញតម្រូវការ ។
- រក្សាតុល្យភាពរវាង ការប្រឹងប្រែងជំរុញតម្រូវការ និងហានិភ័យនៃការធ្វើឱ្យមានលំហូរចេញនូវមូលធន កាន់តែច្រើនឡើង ឬ ការធ្វើឱ្យធ្លាក់ចុះនូវគុណភាពនៃឥណទាន តាមរយៈ គោលនយោបាយរូបិយវត្ថុ។
- ក្នុងផ្នែកសារពើពន្ធ កាត់បន្ថយបន្តិចម្តងៗនូវឱនភាពថវិកា ក្នុងរយៈពេលមធ្យម ដើម្បីធ្វើឱ្យហិរញ្ញវត្ថុសាធារណៈមាននិរន្តរភាពឡើងវិញ ។ ទោះជាដូចនេះក្តី សម្រាប់រយៈខ្លី ក៏គោលនយោបាយសារពើពន្ធ នឹងនៅតែបន្តផ្តោតលើចំណាយដើម្បីគាំទ្រកំណើន យ៉ាងហោចណាស់ក៏សម្រាប់ឆ្នាំ២០១០ ទាំងមូលផងដែរ ។ ឱនភាពថវិកា ត្រូវបានរំពឹងថា នឹងកើនឡើងខ្ពស់ ក្នុងឆ្នាំ២០០៩ (ប្រហែល ៦,៧៥ភាគរយ នៃ*ផសស*) និងឆ្នាំ២០១០ ដើម្បីផ្តល់ការគាំទ្រផ្នែកសារពើពន្ធចាំបាច់នានា ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ។ យុទ្ធ-សាស្ត្រដកថយពី សកម្មភាពដើម្បីអនុវត្តកញ្ចប់គោលនយោបាយសម្រាប់ការជំរុញកំណើនសេដ្ឋកិច្ច អាស្រ័យទៅនឹងពេលវេលានៃការងើបឡើងវិញនៃសេដ្ឋកិច្ច ។ ពេលដែលកំណើនសេដ្ឋកិច្ចចាប់ផ្តើមងើបឡើងវិញដល់កម្រិតសមស្រប នោះសកម្មភាពសារពើពន្ធដើម្បីជំរុញកំណើន នឹងត្រូវបញ្ចប់ នាពេលនោះដែរ ។ យើងរំពឹងថា នៅចន្លោះឆ្នាំ២០១១-២០១៣ កម្រិតឱនភាពសារពើពន្ធ នឹងធ្លាក់ចុះមកត្រឹម កម្រិតមុនវិបត្តិសេដ្ឋកិច្ចកើតឡើង គឺប្រហែល ២ភាគរយ - ២,៨ភាគរយ នៃ*ផសស* ។

## គោលនយោបាយសារពើពន្ធ

២៨៦. *រាជរដ្ឋាភិបាល នីតិកាលទី ៤* នៃ *រដ្ឋសភា* នឹងបន្តផ្តោតយកចិត្តទុកដាក់លើ :

- *ការប្រមូលចំណូលក្នុងស្រុក ការធានាបែងចែកប្រភពធនធានទៅលើទិសដៅអាទិភាពប្រកបដោយប្រសិទ្ធភាព និងការកែលម្អប្រតិបត្តិការនៃហិរញ្ញវត្ថុសាធារណៈទូទៅ* : ការធ្វើហិរញ្ញប្បទានលើចំណាយសាធារណៈដែលកើនឡើង ទាមទារឱ្យមានកិច្ចប្រឹងប្រែងបន្តទៀត ដើម្បីបង្កើនចំណូល ដែលបច្ចុប្បន្នប្រមូលបានប្រហែល ១២ ភាគរយ នៃ*ផសស* ។ គោលនយោបាយប្រមូលចំណូល នឹងអនុវត្តក្នុងក្របខ័ណ្ឌ *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ។
- *ការកាត់បន្ថយអស្ថិរភាពអត្រាប្តូរប្រាក់ឱ្យបានអតិបរមា :* ក្នុងសេដ្ឋកិច្ចតូចនិងបើកចំហដូចកម្ពុជា បម្រែបម្រួលអត្រាប្តូរប្រាក់ អាចកាត់បន្ថយបាន តាមរយៈ ការធានាបាននូវការបញ្ចេញថវិកាដោយរៀបរយដោយមិនបង្កើនបរិមាណប្រាក់រៀលច្រើនជ្រុលក្នុងសេដ្ឋកិច្ចនៅពេលណាមួយ ។ ឧបករណ៍គោលនយោបាយសារពើពន្ធនេះ ត្រូវបានអនុវត្តស្របជាមួយនឹងឧបករណ៍គោលនយោបាយរូបិយវត្ថុ ដូចជា ប្រតិបត្តិការទិញលក់រូបិយវត្ថុបរទេស ដើម្បីរក្សាលំនឹងអត្រាប្តូរប្រាក់ ។
- *ការទប់ទល់នឹងសម្ពាធអតិផរណា :* បន្ថែមលើការរក្សាលំនឹងអត្រាប្តូរប្រាក់ *រាជរដ្ឋាភិបាល* នឹងបន្តតាមដានកត្តាទីផ្សារក្នុងស្រុក ដែលអាចបណ្តាលឱ្យមានសម្ពាធអតិផរណា ជាពិសេស ផលិតផលកសិកម្ម ។ វិធានការ

សារពើពន្ធនេះ បូករួមជាមួយនឹងការអនុវត្តឧបករណ៍គោលនយោបាយផ្សេងៗទៀត ដូចជា ការបង្កើនវិនិយោគលើខ្សែចង្វាក់តៃម្លៃ និងធានាការប្រកួតប្រជែងក្នុងចំណោមឈ្មួញនិងឈ្មួញកណ្ដាល ដោយយុត្តិធម៌ ដោយការកែលម្អស្ថានភាពផ្លូវដឹកជញ្ជូន និងការសម្រួលពាណិជ្ជកម្ម នឹងជួយធ្វើឱ្យមានស្ថិរភាពថ្លៃផលិតផលកសិកម្ម ។

- *ការគ្រប់គ្រងបំណុលដោយសមស្រប* : ផ្នែកខាងដើមនៃឯកសារនេះ បានរៀបរាប់រួចហើយ ពីឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសកលលោក ដែលមានមកលើ សេដ្ឋកិច្ច ក្រុមជនងាយរងគ្រោះ និងប្រជាជនក្រីក្រ ។ ការធ្វើហិរញ្ញប្បទានលើវិធានការនានាដើម្បីកាត់បន្ថយឥទ្ធិពលពីខាងក្រៅ តម្រូវឱ្យ *រាជរដ្ឋាភិបាល* ចំណាយលើសកម្មភាពជាច្រើន ដែលនាំឱ្យជាការកើនឡើងខ្លាំងនៃឱនភាពថវិកា ក្នុងរយៈពេលខ្លី ។ *រាជរដ្ឋាភិបាល* បាននិងកំពុងអនុវត្ត គោលនយោបាយប្រកប ដោយភាពប្រយ័ត្នប្រយែង ដើម្បីធានាភាពរឹងមាំផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធ ។
- *ការគាំទ្រក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ* : *រាជរដ្ឋាភិបាល* នឹងអនុវត្តវិធានការ ដើម្បីគាំទ្រការអនុវត្តគំនិតផ្ដួចផ្ដើមក្នុងការធ្វើវិមជ្ឈការ ដើម្បីផ្ទេរការទទួលខុសត្រូវមួយចំនួន នៅលើចំណូលនិងចំណាយ ទៅថ្នាក់ រាជធានី-ខេត្ត ក្រុង-ស្រុក-ខ័ណ្ឌ និង ឃុំ-សង្កាត់ ។

២៨៧. *រាជរដ្ឋាភិបាល* នឹងអនុវត្តគោលនយោបាយសារពើពន្ធដោយប្រយ័ត្នប្រយែង ហើយធានាថាឱនភាពថវិកានឹងថយចុះ នៅពេលសេដ្ឋកិច្ចងើបឡើងវិញ ដោយក្នុងពេលជាមួយគ្នានោះ ដាក់ចេញនូវវិធានការជាច្រើន ដើម្បីពង្រឹងដំណើរការនៃការធ្វើឱ្យសេដ្ឋកិច្ចងើបឡើងវិញ ។ ដូចនេះ *រាជរដ្ឋាភិបាល* នឹងដាក់ចេញវិធានការផ្នែកសារពើពន្ធ និងវិធានការកែតម្រូវ មួយចំនួន ដើម្បីរក្សានូវ វិន័យនិងស្ថិរភាពផ្នែកសារពើពន្ធ ដែលរួមមាន :

- ការធ្វើសនិទានកម្មលើចំណាយដែលមានផលិតភាពទាប និងការពារការបែងចែកថវិកាទៅឱ្យវិស័យអាទិភាព ។ *រាជរដ្ឋាភិបាល* នឹងត្រួតពិនិត្យមើលការបើកប្រាក់បៀវត្សរ៍ ដើម្បីអាចដំឡើងប្រាក់បៀវត្សរ៍គោលបន្តិចម្ដងៗ (យោលទៅលើគោលនយោបាយកំណែទម្រង់ស្ដីពីការដំឡើងប្រាក់ខែជូនមន្ត្រីរាជការ) ហើយផ្អាកការបង្កើនប្រាក់ឧបត្ថម្ភមុខងារជាបណ្ដោះអាសន្ន ។ *រាជរដ្ឋាភិបាល* មានទិសដៅបន្ថយកំណើនចំណាយ ក្នុងថវិកាឆ្នាំ២០១០-២០១១ ខណៈពេលដែលសេដ្ឋកិច្ច កំពុងស្ថិតលើផ្លូវនៃការងើបឡើងវិញ ។ *រាជរដ្ឋាភិបាល* នឹងតាមដានត្រួតពិនិត្យទំហំនិងសមាសធាតុនៃចំណាយចរន្ត ដែលបានកើនឡើងយ៉ាងខ្លាំង ក្នុងឆ្នាំ២០០៩ ហើយប្រកាន់ភ្ជាប់នូវការប្រយ័ត្នប្រយែង ដោយបង្ការមិនឱ្យមានការកើនឡើងខ្ពស់នៃចំណាយចរន្តណាមួយ ដែលមិនអាចបន្ថយវិញបាន ដូចជា ប្រាក់បៀវត្សរ៍ជាដើម ដោយសារវាអាចបណ្ដាលឱ្យមានហានិភ័យ ក្នុងការធ្វើឱ្យចំណាយទៅលើវិស័យអាទិភាពថយចុះ ដូចជា សុខាភិបាល អប់រំ និងប្រតិបត្តិការនិងការថែទាំ និងក្នុងការធ្វើកើនឡើងនៃតម្រូវការហិរញ្ញប្បទានក្នុងស្រុក បើសិនជាកំណើននៃចំណូលមិនអាចទប់ទល់បាននោះ ។

- ការបង្កើនចំណូល តាមរយៈការ ពង្រីកមូលដ្ឋានយកពន្ធ និងពង្រឹងការគោរពបែបបទរដ្ឋបាល ។ វិធានការប្រមូលចំណូល រួមមាន ដូចជា (១) ពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនអត្រាពន្ធ (២) ពង្រឹងការយកពន្ធលើអចលនទ្រព្យ និងពន្ធលើដីមិនប្រើប្រាស់ ដោយរួមទាំង ការយកពន្ធលើចំណេញមូលធន (៣) យកពន្ធលើតម្លៃបន្ថែមសម្រាប់ការប្រើប្រាស់ ទឹកនិងអគ្គិសនី និង (៤) ជំនួសការលើកទឹកចិត្តផ្នែកពន្ធដែលកំពុងត្រូវបានអនុវត្តសព្វថ្ងៃ ដោយ ការឧបត្ថម្ភធនលើវិនិយោគ ឥណទានពន្ធ និងការពន្លឿនការកាត់រំលោះ ។
- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* នឹងពិនិត្យមើលឡើងវិញលើ ថវិកាចរន្ត ដោយធ្វើសនិទានកម្មលើ ចំណាយចរន្ត (ចំណាយកាតព្វកិច្ច ធៀបនឹង ចំណាយមិនមែនកាតព្វកិច្ច) និង ការបែងចែកចំណាយទាំងនោះឡើងវិញសម្រាប់ ការគាំទ្រដោយផ្ទាល់ដល់ការជំរុញកំណើន ឬ ចំណាយលើប្រព័ន្ធសុវត្ថិភាពសង្គម ក៏ដូចជាចំណាយចាំបាច់សម្រាប់ទប់ទល់នឹងឥទ្ធិពលដែលមិនអាចដឹងមុនបាន ដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចនិងវិបត្តិហិរញ្ញវត្ថុសកលលោក ។
- ដាក់ចេញនូវគោលនយោបាយ ដើម្បីបង្កើនវិនិយោគលើ វិស័យប្រេងនិងធនធានថាមពល និងដើម្បីធានាថា ការវិនិយោគអាចមានលំនឹង និងអាចទាយទុកជាមុនបាន ក៏ដូចជា បង្កើនកិច្ចសហប្រតិបត្តិការ និងភាពបំពេញឱ្យគ្នាទៅវិញទៅមក រវាងស្ថាប័នជាតិនិងស្ថាប័នអន្តរជាតិដែលជាប់ពាក់ព័ន្ធ តាមរយៈភាពជាដៃគូល្អប្រសើរ ។
- គោលនយោបាយត្រៀមជាមុន ដើម្បីកៀរគរ និងបង្កើនការបញ្ចេញសាច់ប្រាក់ពី ជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់ចំណាយមូលធន ឬចំណាយលើការអភិវឌ្ឍ ។ *រាជរដ្ឋាភិបាល* នឹងប្រឹងឱ្យអស់លទ្ធភាពដើម្បីកៀរគរ និងប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ប្រកបដោយភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាព និងចំទិសដៅ ។ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* នឹងដឹកនាំនិងសម្របសម្រួល ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដើម្បីពន្លឿនការអនុវត្តវិធានការកែទម្រង់ចាំបាច់នានា ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ផ្តល់ការគាំទ្រជាថវិកា ដើម្បីកៀរគរនិងបែកចែកធនធាន បានលឿននិងប្រកបដោយប្រសិទ្ធភាព សំដៅឆ្លើយតបទៅនឹងតម្រូវការក្នុងការអភិវឌ្ឍ ។

២៨៨. *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* កំពុងអនុវត្ត ជំហានទី២នៃ*កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ* ដែលផ្តោតលើ "*ការឈានទៅរកគណនេយ្យភាពហិរញ្ញវត្ថុ ដោយផ្អែកលើភាពជឿទុកចិត្តបាននៃថវិកា*" ។ របៀបវារៈក្នុងជំហានទី២នេះ គឺ បង្កើនភាពជឿទុកចិត្តបានក្នុងចំណោមមន្ត្រីទទួលខុសត្រូវ ដើម្បីសម្រេចបានការចាត់ចែងធនធានសាធារណៈប្រកបដោយ សុវត្ថិភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។ ជំហានទី១ ត្រូវបានអនុវត្ត ដើម្បីកែលម្អក្របខ័ណ្ឌនៃការគ្រប់គ្រងធនធាន និង ដោះស្រាយបញ្ហានានា ក្នុងប្រព័ន្ធទាំងមូល ។ ជំហានទី២ ទាមទារឱ្យស្ថាប័នដែលទទួលថវិកា និងអ្នកគ្រប់គ្រងថវិកាទាំងអស់ ធ្វើការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់ខ្លួន ។

ផែនការសកម្មភាពដែលបង្កើតឡើង មានគោលបំណងសម្រេចឱ្យបានជំហានទី២នេះ តាមរយៈ ការរួមបញ្ចូលគ្នានូវដំណើរការផែ្នកច្បាប់ និងគំនិតផ្តួចផ្តើមកសាងសមត្ថភាព ដោយធ្វើឱ្យមានតុល្យភាពនិងការលើកទឹកចិត្តសម្រាប់ការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈបានល្អ ឬការដាក់ទណ្ឌកម្ម សម្រាប់ការអនុវត្តមិនបានល្អ ។

២៨៩. ការងារក្នុងជំហានទី២ មានទិសដៅផ្តល់អំណាចច្រើនជាងមុន ទៅឱ្យស្ថាប័នដែលទទួលថវិកា និងអ្នកគ្រប់គ្រងថវិកាក្នុងស្ថាប័នទាំងនោះ ។ ទោះជាដូចនេះក្តី ក៏ដំណើរការនេះនឹងត្រូវតាមដានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ហើយត្រូវដាក់ឱ្យអនុវត្ត នៅពេលដែលយើងមានបទពិសោធន៍ និងការទុកចិត្តត្រូវបានពង្រឹង ដោយសារប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដែលកម្មវិធីកំណែទម្រង់ចាប់កំណើតឡើង នៅមានទន់ខ្សោយនៅឡើយ ។

២៩០. ការបង្កើនគណនេយ្យភាពនិងការផ្តល់អំណាច នឹងត្រូវគាំទ្រដោយវិធានការជាច្រើន ដើម្បីកែលម្អប្រព័ន្ធព័ត៌មានវិទ្យានិងតម្លាភាព ស្តីពីអនុវត្តកាតព្វកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ស្ថាប័នទទួលថវិកានិងមន្ត្រីគ្រប់គ្រងថវិកា ។ ការអនុវត្តជំហានទី២ ក្នុងឆ្នាំ ២០០៩ បានផ្តោតលើ :

- ការបង្កើតសំណើ សម្រាប់ការអនុវត្តលម្អិតនូវការងារកែសម្រួលបច្ចេកទេសមួយចំនួនដែលបានដាក់ចេញក្នុងជំហានទី២ ដូចជា របៀបដែលថវិកាធ្លាក់ដល់ដៃអ្នកផ្តល់សេវាកម្មនិងរបៀបប្រើប្រាស់ថវិកា ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាដែលប្រសើរជាងមុន និងវិធីសាស្ត្រ ដើម្បីឱ្យភ្នាក់ងារអនុវត្តមានការទទួលខុសត្រូវជាងមុន (សម្រាប់ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*) ។
- ការបញ្ចូលក្រសួង-ស្ថាប័ន និងភ្នាក់ងារអនុវត្តថវិកាដទៃទៀត ទៅក្នុងការងារជំហានទី២ ។
- ការបង្កើតកម្មវិធីកសាងសមត្ថភាពដែលចាំបាច់ សម្រាប់ជោគជ័យនៃជំហានទី ២ ។

២៩១. យើងសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការងារខាងលើ ក្នុងឆ្នាំ២០០៩ ប៉ុន្តែយើងនឹងបន្តការងារទាំងនេះ ក៏ដូចជា ការងារលម្អិតដទៃទៀត ក្នុងឆ្នាំ២០១០ បន្តទៀត ។ ជាពិសេស ការងាររៀបចំប្រព័ន្ធកុំព្យូទ័រដែលនឹងក្លាយជាស្នូលនៃប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ កំពុងតែដំណើរការយ៉ាងល្អ ។ ការរៀបចំអភិក្រមក្នុងការគ្រប់គ្រងធនធានដែលមានលក្ខណៈជាយុទ្ធសាស្ត្រជាងមុន កំពុងតែដំណើរការយ៉ាងល្អ ។ ក្របខ័ណ្ឌសម្រាប់សវនកម្មផ្ទៃក្នុង កំពុងត្រូវបានរៀបចំឡើង ហើយក្រសួងពាក់ព័ន្ធ បានចូលរួមក្នុង សិក្ខាសាលាផ្សព្វផ្សាយ និង ការរៀបចំកម្មវិធីកសាងសមត្ថភាព ។ ក្រសួងទាំងនោះ បានបង្កើតកម្មវិធីកំណែទម្រង់សម្រាប់ស្ថាប័នរៀងខ្លួន ហើយ ក្រសួងពាក់ព័ន្ធមួយភាគធំ បានរៀបចំផែនការ ដើម្បីចូលរួមក្នុងកម្មវិធីកំណែទម្រង់ទាំងមូល ។

២៩២. ការអនុវត្តជំហានទី២ តាមផែនការនឹងជួយបង្កើតឱ្យមានបរិស្ថានទទួលខុសត្រូវ ក្នុងការងារចាត់ចែងធនធានសាធារណៈនៅគ្រប់កម្រិតទាំងអស់នៃរដ្ឋបាល ។ យើងនឹងទទួលស្គាល់ និងញែកឱ្យដាច់ចេញពីគ្នានូវ ចំណុចខ្លាំង និងចំណុចខ្សោយ ក្នុងការគ្រប់គ្រងធនធានសាធារណៈ ។ បើយើងអនុវត្តការផ្លាស់ប្តូរនេះបានសម្រេច នោះយើងនឹងបង្កើតបានមូលដ្ឋានគ្រឹះដ៏រឹងមាំមួយ សម្រាប់ការអនុវត្តជំហានក្រោយទៀត ពោលគឺ :

- ប្រើប្រាស់អ្វីដែលសម្រេចបានក្នុងជំហានដំបូងៗ ដើម្បីឈានទៅផ្តល់អំណាចច្រើនជាងមុន ទៅឱ្យថ្នាក់ដឹកនាំនៃស្ថាប័នចំណាយ ដើម្បីសម្រេចបានលទ្ធផលប្រសើរជាងមុន ដោយសារ ក្របខ័ណ្ឌនៃការត្រួតពិនិត្យក្នុងការផ្តល់អំណាចនឹងត្រូវបានកែលម្អ ហើយយើងនឹងមានបទពិសោធន៍ជាបណ្តើរៗ ។
- បង្កើនប្រសិទ្ធភាពនៃចំណាយ និងភាពសមស្របនៃចំណាយដែលកំពុងអនុវត្ត ដោយសារការចូលរួមពីសំណាក់ស្ថាប័នចំណាយ និងអ្នកចាត់ចែងក្នុងដំណើរតាមដានត្រួតពិនិត្យគោលបំណងខាងលើ នឹងកាន់តែសកម្មជាងមុន ដោយសារមាន ព័ត៌មានកាន់តែច្រើន និងការយល់ដឹងច្រើនជាងមុន អំពីអ្វីដែលកំពុងកើតមានឡើងក្នុងការចាត់ចែងធនធាន ។
- ចាប់ផ្តើមកំណត់ការងារកាត់តម្រឹម រវាងការអនុវត្តគោលនយោបាយ និងការកែលម្អសេវាកម្មដោយប្រើប្រាស់ធនធានចាំបាច់ ដើម្បីសម្រេចការងារកែលម្អនេះ ដោយសារយើងមានមូលដ្ឋានព័ត៌មាន និងការវិភាគគ្រប់គ្រាន់អំពីការប្រើប្រាស់ធនធាន ។
- ឈានទៅរកគណនេយ្យភាព ក្នុងការចាត់ចែងផលដែលសម្រេចបាន ដោយពឹងផ្អែកលើការបង្កើនគណនេយ្យភាព ក្នុងការចាត់ចែងធនធាន ។

២៩៣. ការអនុវត្តជំហានទី២ ជាការងារលំបាកមួយ ដែលទាមទារឱ្យមាន ការផ្តួចផ្តើមសកម្មភាពចាំបាច់នានា និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធក្នុងសកម្មភាពទាំងនោះ ឧទាហរណ៍ ដូចជា :

- ការអនុវត្តកម្មវិធីដំណាក់កាលនេះ ទាមទារឱ្យស្ថាប័នផ្តល់សេវាសាធារណៈកាន់តែច្រើន ចូលរួមអនុវត្ត ហើយមានការសម្របសម្រួល និងតាមដានត្រួតពិនិត្យយ៉ាងប្រយ័ត្នប្រយែង ។ យើងបានបង្កើតយន្តការដឹកនាំថ្មីដែលស្ថិតក្រោមការគ្រប់គ្រងរបស់**សម្តេចនាយករដ្ឋមន្ត្រី** ហើយការអនុវត្តនូវយន្តការទាំងនោះ ត្រូវដឹកនាំដោយឧបនាយករដ្ឋមន្ត្រី ។
- នៅពេលដែលដំណើរការអនុវត្តការងារកំពុងឈានទៅមុខ ទំនាក់ទំនងរវាងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់សេវាកម្មសាធារណៈ កាន់តែមានភាពខ្លាំងនិងសារៈសំខាន់ ជាងមុន សម្រាប់ការគ្រប់គ្រង ។ ជាក់ស្តែង យើងចាំបាច់ត្រូវបន្សុីកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងកម្មវិធីកំណែទម្រង់ផ្សេងៗទៀត ការគ្រប់គ្រងសេវាកម្មស៊ីវិល និង កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ។ កិច្ចពិភាក្សាជាមួយមន្ត្រីគន្លឹះ ដែលទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ដទៃទៀត បានចាប់ផ្តើមក្នុងឆ្នាំ២០០៩ ។
- ការចូលរួមយ៉ាងសកម្មពីក្រសួងពាក់ព័ន្ធ និងភ្នាក់ងារអនុវត្តថវិកាដទៃទៀត ជាការចាំបាច់ សម្រាប់ជោគជ័យនៃកម្មវិធីនេះ ។ ដូចគ្នានឹងការកែលម្អយន្តការដឹកនាំ ផងដែរ ការបង្កើតកម្មវិធីកំណែទម្រង់ផ្ទាល់ខ្លួន និង ការចូលរួមក្នុងការបង្កើតគម្រោងសកម្មភាព នៃក្រសួងពាក់ព័ន្ធនីមួយៗ គឺជាកត្តាគន្លឹះ ។

- ភាពចាំបាច់ក្នុងការពិនិត្យមើលឡើងវិញនូវ រចនាសម្ព័ន្ធស្ថាប័នដែលទទួលខុសត្រូវ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ (ទាំង *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* និងក្រសួង-ស្ថាប័នដទៃទៀត) ដើម្បីធានាថា យន្តការគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងត្រូវបានអនុវត្តនៅតាមក្រសួង-ស្ថាប័ននានាសព្វថ្ងៃ មានសង្គតិភាព ។ យើងនឹងធ្វើការពិនិត្យមុខងារ និងកែសម្រួលលរចនាសម្ព័ន្ធឡើងវិញ បើសិនជាចាំបាច់ ។ ឧទាហរណ៍ ការដាក់ឱ្យអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ តាមប្រព័ន្ធព័ត៌មានវិទ្យា នឹងមានផលប៉ះពាល់ទៅលើ ការចាត់ចែងរៀបចំនិងដំណើរការនៃអនុវត្តការងារដែលយើងត្រូវទទួលយក បើសិនប្រព័ន្ធទាំងនេះ នឹងត្រូវរក្សាឱ្យមានចីរភាព ។

## គោលនយោបាយរូបិយវត្ថុ

២៩៤. *ធនាគារជាតិនៃកម្ពុជា* នឹងបន្តអនុវត្តយ៉ាងសកម្ម នូវ*យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥* ដើម្បី : (១) រក្សាស្ថិរភាពថ្លៃ ដោយកំណត់គោលដៅអតិផរណា ឱ្យនៅក្រោម ៥ភាគរយ (២) ធានាឱ្យមានភាពរឹងមាំ នៅក្នុងវិស័យហិរញ្ញវត្ថុ ដោយធ្វើការឆ្លើយតប តាមរបៀបមួយត្រៀមលក្ខណៈទប់ស្កាត់ជាមុន ចំពោះការវិវឌ្ឍប្រែប្រួលនៃកត្តាខាងក្រៅប្រទេស ដែលកំពុងកើតមាន (៣) បន្តគ្រប់គ្រងអត្រាប្តូរប្រាក់ទីផ្សារ ដោយរក្សាឱ្យស្ថិតនៅក្នុងរង្វង់ ប្រមាណ ៤ ១០០រៀល ក្នុង១ដុល្លារអាមេរិក និង (៤) រក្សាទុនបម្រុងអន្តរជាតិឱ្យស្ថិតនៅក្នុងកម្រិតដែលអាចធ្វើការនាំចូលបានយ៉ាងតិចរយៈពេល ៣ខែ ។ *ធនាគារជាតិនៃកម្ពុជា* នឹងបន្តអនុវត្តយ៉ាងខ្លាំងក្លានូវគោលនយោបាយចាំបាច់ទាំងឡាយ ដើម្បីសម្រាលឥទ្ធិពលអវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចសកលលោកដែលអាចមានមកលើ សេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុកម្ពុជា និងក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ ។

២៩៥. *ធនាគារជាតិនៃកម្ពុជា* នឹងបន្តពង្រឹងឧបករណ៍រូបិយវត្ថុ និង បន្តអនុវត្តក្របខ័ណ្ឌទីផ្សាររូបិយវត្ថុ :

- បន្តចូលរួមកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់ទំនុកចិត្តសាធារណៈ លើការប្រើប្រាស់ ប្រាក់រៀល ។
- បង្កើតឱ្យមានការទូទាត់ក្នុងស្រុក ប្រព័ន្ធទូទាត់រូបិយវត្ថុនិងទីផ្សារអន្តរធនាគារ ដែលរួមមានសញ្ញាបណ្ណរយៈពេលខ្លីរបស់រាជរដ្ឋាភិបាលផងដែរ ។
- អនុវត្តក្របខ័ណ្ឌប្រាក់លើកទឹកចិត្តសារពើពន្ធដែលរួមមានបញ្ជីបើកប្រាក់បៀវត្សរ៍*រដ្ឋាភិបាល* និងចំណាយប្រាក់រៀលផ្សេងៗ តាមរយៈគណនីធនាគារនិងប្រព័ន្ធទូទាត់ ។ ត្រួតពិនិត្យផងដែរ ជម្រើសផ្សេងៗក្នុងការបញ្ជូនព័ត៌មានបំណុលរបស់អន្តរធនាគារទៅដល់វិស័យឯកជន ។
- ពង្រីកការទូទាត់និងប្រព័ន្ធព័ត៌មានបំណុលដែលរួមទាំងគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយ ដែលមានអាជ្ញាបណ្ណ ។
- ផ្តល់ការដាក់ទ្រព្យបញ្ចាំ ដើម្បីទប់ទល់ហានិភ័យក្នុងប្រព័ន្ធទូទាត់ ដោយការប្រើប្រាស់សញ្ញាបណ្ណ ដែលមានរយៈពេលខ្លីរបស់*រាជរដ្ឋាភិបាល* ។

- លើកទឹកចិត្តចំពោះការផ្គត់ផ្គង់សាច់ប្រាក់និងយន្តការត្រួតពិនិត្យសាច់ប្រាក់ រឹតបន្តឹងប្រព័ន្ធទុនបម្រុងតម្រូវការរៀបចំឱ្យមានការចេញ(សញ្ញាបណ្ណ) ធនាគារកណ្តាល និងដំឡើងយន្តការកៀរគរធនធានចុងក្រោយរបស់ឥណទាយក ។

២៩៦. នៅក្នុងវិស័យធនាគារ *ធនាគារជាតិនៃកម្ពុជា* នឹងបន្តយកចិត្តទុកដាក់លើកត្តាបួនយ៉ាងសំខាន់ៗ :

- ពង្រឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ ។
- កែលម្អវិស័យធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ។
- លើកទឹកចិត្តដល់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារនានា ។
- ស្វែងរកវិធីនានា ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលទាក់ទិនដល់វិស័យផ្សេងៗទៀត ។

២៩៧. ចំពោះសកម្មភាពជាក់លាក់មួយចំនួន *ធនាគារជាតិនៃកម្ពុជា* នឹងអនុវត្តវិធានការនានា ដើម្បី :

- *ពង្រឹងរចនាសម្ព័ន្ធច្បាប់* : បន្តកែលម្អក្របខ័ណ្ឌច្បាប់បទប្បញ្ញត្តិ និង ការត្រួតពិនិត្យវិស័យធនាគារ ជាពិសេស គឺការរៀបចំពង្រឹង ដើម្បីធ្វើវិសោធនកម្មលើច្បាប់ ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងឱ្យមានស្ថិរភាពនៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- *អភិវឌ្ឍធនធានមនុស្ស* : បន្តកែលម្អការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា និងពង្រឹងសមត្ថភាពត្រួតពិនិត្យវិស័យធនាគារ និងត្រួតពិនិត្យផ្ទៃក្នុង *ធនាគារជាតិនៃកម្ពុជា* ។
- *លើកកម្ពស់ការប្រកួតប្រជែងដោយសេរី* : តាមរយៈ ការពង្រឹងបទប្បញ្ញត្តិនៃការផ្តល់អាជ្ញាបណ្ណ និងការដាក់ឱ្យដំណើរការនូវហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់សម្រាប់ ការគាំទ្ររបកគំហើញនិងផលិតផលថ្មីៗនៅក្នុងវិស័យហិរញ្ញវត្ថុ និង ពិពិធភាវូបនីយកម្មវិស័យហិរញ្ញវត្ថុ ។
- *កែលម្អនូវគុណភាពតម្លៃនិងភាពជំនឿទុកចិត្ត* : លើប្រព័ន្ធទូទាត់និងមិនអាចទូទាត់សងបាន នៃធនាគារទាំងឡាយ ដើម្បីបង្កើតនិងអនុវត្តយុទ្ធសាស្ត្រចាកចេញ ឱ្យមានលក្ខណៈជាប្រព័ន្ធ ក្នុងការដកចេញ នូវវិធានការពិសេសនានាដែលបានដាក់ចេញ ដើម្បីដោះស្រាយនូវផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ។

២៩៨. *ធនាគារជាតិនៃកម្ពុជា* នឹងចាត់វិធានការចាំបាច់ ដើម្បីពង្រីកវិសាលភាពនៃសេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលជាតម្រូវការចាំបាច់ របស់អាជីវកម្មធុនតូច និងសហគមន៍នៅតាមជនបទ ជាពិសេស ចំពោះកសិករទាំងឡាយដែលមានដីស្រែតិចតួច ។ គោលបំណងសំខាន់ គឺដាក់ចេញ ប្រព័ន្ធមីក្រូហិរញ្ញវត្ថុទូលំទូលាយ និងមានប្រសិទ្ធភាពដែលគ្រប ដណ្តប់លើផ្ទៃប្រទេសទាំងមូល ។ *ធនាគារជាតិនៃកម្ពុជា* នឹងដាក់ចេញវិធានការ ដើម្បី :

- *ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ* : តាមរយៈ ការបន្តលើកកម្ពស់សមត្ថភាពរបស់ *ធនាគារជាតិនៃកម្ពុជា* ដើម្បីពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុ ដែលរួមមាន ការរឹតបន្តឹងវិធានការប្រុងប្រយ័ត្ន ដើម្បីកសាងទំនុកចិត្តសាធារណៈ លើការប្រើប្រាស់សេវាកម្មមីក្រូហិរញ្ញវត្ថុនិងធនាគារពាណិជ្ជនានា ។
- *ពង្រឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ* : តាមរយៈ ការលើកទឹកចិត្ត អង្គការក្រៅរដ្ឋាភិបាលដែលមិនទាន់បានចុះបញ្ជីឱ្យក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ដើម្បីមានសិទ្ធិស្របច្បាប់ក្នុងការប្រមូលប្រាក់បញ្ញើ ។
- *ពង្រីកបណ្តាញមីក្រូហិរញ្ញវត្ថុ* : តាមរយៈ ការជំរុញកំណើន ដោយផ្តល់អាជ្ញាបណ្ណទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់ បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង ពង្រីកបណ្តាញប្រតិបត្តិការ បង្កើនសមត្ថភាព និង ប្រសិទ្ធភាព និងបង្កើតប្រាក់ចំណេញឱ្យបានច្រើន ដើម្បីផ្តល់ជូនតាមតម្រូវការខ្ចីរបស់ប្រជាជន នៅក្នុង តំបន់ទាំងនោះ ។
- *កសាងសមត្ថភាព* : តាមរយៈ ការផ្តល់ការបណ្តុះបណ្តាលជាមូលដ្ឋានដល់ប្រជាជន ជាពិសេស ជនក្រីក្រ ដើម្បីឱ្យបានយល់ពីសេវាកម្មមីក្រូហិរញ្ញវត្ថុ ដូចជា សេវាសន្សំប្រាក់ និង ការប្រើប្រាស់ប្រាក់កម្ចី សម្រាប់បង្កើតចំណូល និង កម្រិតជីវភាពរបស់ពួកគេប្រសើរឡើង ។
- *ពង្រឹងហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន* : តាមរយៈ ការពង្រឹងនិងការពង្រីកប្រព័ន្ធព័ត៌មានឥណទាន សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការបង្កើនទំនាក់ទំនងហិរញ្ញវត្ថុ រវាង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារពាណិជ្ជ ។

២៩៩. *ធនាគារជាតិនៃកម្ពុជា* នឹងបន្តអភិវឌ្ឍ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធ្វើឱ្យកាន់តែស៊ីជម្រៅលើវិស័យហិរញ្ញវត្ថុ តាមរយៈ :

- *ការពិនិត្យឡើងវិញនូវច្បាប់និងបទប្បញ្ញត្តិដែលគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ* : *ធនាគារជាតិនៃកម្ពុជា* នឹងត្រួតពិនិត្យជម្រើសទាំងឡាយ ដើម្បីធ្វើប្រតិភូកម្មការទទួលខុសត្រូវចំពោះអាជ្ញាធរផ្សេងៗទៀត ដើម្បី ត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ មិនមែនធនាគារ ។
- *ការជំរុញការអភិវឌ្ឍអាជីវកម្មភតិសន្យាផ្សេងៗ* : តាមរយៈ ការលើកទឹកចិត្តដល់ សកម្មភាពផ្តល់ឥណទានដល់អាជីវកម្មភតិសន្យា ដែលជាប្រភពធនធានមួយទៀត សម្រាប់អាជីវកម្មធុនតូចនិងមធ្យម តាមរយៈការបង្កើត *ច្បាប់ភតិសន្យាហិរញ្ញវត្ថុ* ដែលផ្តោតជាសំខាន់លើសិទ្ធិនិងកាតព្វកិច្ច នៃភាគីជាប់កិច្ចសន្យា ។
- *ការអភិវឌ្ឍប្រព័ន្ធចែករំលែកព័ត៌មានឥណទាន* : ដើម្បីកែលម្អប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងដើម្បីបង្កើតឱ្យមានក្របខណ្ឌសម្រាប់ប្រព័ន្ធព័ត៌មានឥណទានដែលមានទ្រង់ទ្រាយធំ ។
- *ពង្រឹងការតាមដានទីផ្សារប្តូរប្រាក់* : តាមរយៈ ការកែលម្អនិងការធ្វើបញ្ញត្តិកម្មទីផ្សារអាជីវកម្មប្តូរប្រាក់បរទេស ។
- *បង្កើតប្រព័ន្ធទូទាត់ជាតិ* : តាមរយៈ ការបន្តលើកកម្ពស់ សុវត្ថិភាព ប្រសិទ្ធភាព និងសមត្ថភាព របស់ប្រព័ន្ធនេះ ដោយ ការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធទូទាត់មូលប្បទានបត្រធនាគារ និងការអភិវឌ្ឍប្រព័ន្ធទូទាត់អេឡិចត្រូនិច នៅថ្នាក់ជាតិ ដើម្បីគាំទ្រទីផ្សារអន្តរធនាគារ ។

៣០០. *ធនាគារជាតិនៃកម្ពុជា* នឹងបង្កើតនិងអនុវត្ត ប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន ដែលជាតម្រូវការចាំបាច់ សម្រាប់ធានានូវមុខងារសំខាន់ៗ និងបង្កើនប្រសិទ្ធភាពនិងផលិតភាព របស់បុគ្គលិក ។

៣០១. នៅក្នុងវិស័យមិនមែនធនាគារ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* នឹងបន្តអនុវត្តយ៉ាងសកម្ម និង ដាក់ចេញនូវផែនការដូចខាងក្រោម ដើម្បីអភិវឌ្ឍវិស័យនេះ :

- **វិស័យមូលបត្រ** : *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ក៏ដូចជា *គណៈកម្មការមូលបត្រកម្ពុជា* នឹងបន្តអនុវត្តការងារ ឆ្ពោះទៅបង្កើតនិងដាក់ឱ្យដំណើរការទីផ្សារមូលបត្រ ប្រកបដោយជោគជ័យ សំដៅធានាបាន នូវទីផ្សារមួយ ដែលមាន ប្រតិបត្តិការប្រកបដោយ យុត្តិធម៌ សមភាព តម្លាភាព និងរឹងមាំ ដែលអាចទាក់ទាញបាននូវទំនុកចិត្តខ្ពស់របស់សាធារណជន ។ ដើម្បីសម្រេចបានតាមទិសដៅនេះ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* និង *គណៈកម្មការមូលបត្រកម្ពុជា* នឹងផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម :

*ក. ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ* :

- រៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ សម្រាប់អនុវត្ត *ច្បាប់ស្តីពីមូលបត្ររដ្ឋ* ។
- បន្តអភិវឌ្ឍ និង ពង្រឹងសមត្ថភាពធនធានមនុស្សនិងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រងការបោះផ្សាយមូលបត្ររដ្ឋ ប្រកបដោយ ប្រសិទ្ធភាពនិងនិរន្តរភាព ។

*ខ. ការអភិវឌ្ឍទីផ្សារមូលបត្រមហាជន* :

- *គណៈកម្មការមូលបត្រកម្ពុជា* នឹងបន្តរៀបចំបទដ្ឋានគតិយុត្តចាំបាច់ សម្រាប់ផ្តល់ការអនុញ្ញាត ឬអាជ្ញាបណ្ណ ចំពោះអាជីវកម្ម ឬសកម្មភាពប្រតិបត្តិការនានា នៅក្នុងទីផ្សារមូលបត្រ ដើម្បីធានាឱ្យការចេញដំណើរ នៃទីផ្សារមូលបត្រ អាចប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និង សណ្តាប់ធ្នាប់ ។
- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* និង *គណៈកម្មការមូលបត្រកម្ពុជា* នឹងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ នឹងគោលនយោបាយនៃការលើកទឹកចិត្តចំពោះវិស័យមូលបត្រ ដើម្បីគាំទ្រនិងជំរុញ ការអភិវឌ្ឍទីផ្សារមូលបត្រ ពេលចាប់ផ្តើមដំបូង ។
- បន្តពង្រឹងសមត្ថភាពមន្ត្រីជំនាញ នៃ *គណៈកម្មការមូលបត្រកម្ពុជា* និង *ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា* ដើម្បីឱ្យការគ្រប់គ្រងនិងការត្រួតពិនិត្យទីផ្សារ អាចប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព ។
- បន្តលើកកម្ពស់ចំណេះដឹងសាធារណៈ ពីវិស័យមូលបត្រ ដើម្បីឱ្យមានការចូលរួមទូលំទូលាយ នៅក្នុងទីផ្សារមូលបត្រកម្ពុជា ដែលទើបនឹងបង្កើតជាលើកដំបូង ។

*គ. ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ :*

- រៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ សម្រាប់បង្កើតនិងដាក់ឱ្យដំណើរការ យន្តការ គ្រប់គ្រងនិងត្រួតពិនិត្យការអភិវឌ្ឍមជ្ឈមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ និងការអនុវត្តគោលនយោបាយលើកទឹកចិត្ត នៅក្នុងមជ្ឈមណ្ឌល អភិវឌ្ឍន៍ហិរញ្ញវត្ថុ នេះ ។
- បង្កើតនិងដាក់ឱ្យដំណើរការ *ក្រុមហ៊ុនគ្រប់គ្រងនិងអភិវឌ្ឍមជ្ឈមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ* ។

- **វិស័យធានារ៉ាប់រង :**
  - *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* នឹងបន្តពង្រឹង ការអភិវឌ្ឍបទប្បញ្ញត្តិធានារ៉ាប់រង ដើម្បីធានាឱ្យអាជីវកម្មធានារ៉ាប់រង ដំណើរការប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និង ភាពត្រឹមត្រូវ ។
  - គោលបំណងនានាពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង គឺត្រូវបង្កើតឱ្យមាន ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងជីវិត ធានារ៉ាប់រងខ្នាតតូច និង ប្រព័ន្ធសោធននិវត្តន៍ ក្រសួងនឹងផ្តល់នូវមូលធន សម្រាប់ការវិនិយោគរយៈពេលវែង ។ ក្នុងកិច្ចដំណើរការគាំទ្រគោលបំណង នេះ កម្ពុជានឹងអនុវត្តតាមស្តង់ដារ និងបទពិសោធន៍ពីប្រទេសនានា ជាពិសេស ប្រទេសនៅក្នុងតំបន់ រួមទាំង គោលការណ៍គ្រឹះធានារ៉ាប់រងរបស់*សមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ* ។

- **វិស័យមីក្រូហិរញ្ញវត្ថុ :** ដើម្បីសម្រេចបាននូវ ការផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ គ្រួសារដែលមានប្រាក់ចំណូលទាប និង មីក្រូសហគ្រាស ទទួលបានកាន់តែប្រសើរឡើង *រាជរដ្ឋាភិបាលកម្ពុជា* នឹងដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ដែលរួមមាន ដូចខាងក្រោម :
  - រៀបចំយន្តការ សម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុ ដែលបាននិងកំពុង ប្រើប្រាស់ដោយប្រតិបត្តិករឥណទាន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឬធនាគារនានា ដែលបានទទួលមូលនិធិហិរញ្ញប្បទាន តាមរយៈដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញឱ្យមានតម្លាភាពនិងមានអភិបាលកិច្ចល្អ ដើម្បីធ្វើឱ្យមានសមភាពក្នុងចំណោមអ្នកផ្គត់ផ្គង់សេវាមីក្រូហិរញ្ញវត្ថុ នៅលើទីផ្សារ ។
  - រៀបចំបទប្បញ្ញត្តិ ដើម្បីផ្តល់អាជ្ញាបណ្ណដល់ ប្រតិបត្តិករផ្តល់សេវាធានារ៉ាប់រងខ្នាតតូច ។
  - លើកទឹកចិត្តឱ្យមានការទាក់ទាញវិនិយោគទុន ក្នុងនិងក្រៅប្រទេស ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏អាច មានសិទ្ធិខ្ចីប្រាក់ដោយផ្ទាល់ ពីស្ថាប័នហិរញ្ញវត្ថុក្រៅប្រទេស ផងដែរ ។
  - ជំរុញការពង្រឹងសមត្ថភាពរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ឱ្យកាន់តែមានជំនាញនិងវិជ្ជាជីវៈត្រឹមត្រូវ ។
  - ជំរុញឱ្យរដ្ឋអំណាចមូលដ្ឋាន ដើរតួនាទីជាអ្នកជួយសម្របសម្រួល នូវរាល់កិច្ចការទាំងឡាយណា ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការសកម្មភាពមីក្រូហិរញ្ញវត្ថុ ដើម្បីចូលរួមចំណែកអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពខ្ពស់ ។
  - បន្តនិងជំរុញ ការគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍នៅតាមសហគមន៍/សហករណ៍ ឬ សមាគមផ្សេងៗ នៅតាមមូលដ្ឋាន តាមរយៈ ការធ្វើអន្តរាគមន៍ជាអាទិភាពនូវមូលនិធិរបស់*រាជរដ្ឋាភិបាល* ឬ ពីដៃគូអភិវឌ្ឍន៍នានា ។

- **ការគ្រប់គ្រងការជួញដូរអចលនវត្ថុ :**
  - ➢ បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសមស្រប ដើម្បីទ្រទ្រង់ដល់សេវាកម្មវាយតម្លៃ និង សេវាប្រតិបត្តិការអចលនវត្ថុ ។
  - ➢ ពង្រឹងការកសាងសមត្ថភាព ដល់អ្នកវាយតម្លៃនិងបញ្ញត្តិករអចលនវត្ថុ ។

## ៣. ទស្សនៈវិស័យសេដ្ឋកិច្ច ឆ្នាំ ២០០៩-២០១៣

៣០២. នាពាក់កណ្តាលឆ្នាំ២០០៩ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា បានប្រឈមមុខនឹងហានិភ័យចម្បងពីរ ដែលអាចធ្វើឱ្យកំណើនមានការធ្លាក់ចុះ ។ ***ទី១*** : ភាពមិនច្បាស់លាស់អំពី កម្រិតនិងរយៈពេល នៃវិបត្តិហិរញ្ញវត្ថុ និងឱនភាពសេដ្ឋកិច្ចសកលលោក ដែលកំពុងបន្តកើតមាន នៅប្រទេសអភិវឌ្ឍ ក៏ដូចជា ផលប៉ះពាល់ពីជំងឺផ្តាសាយថ្មី ទៅ លើ វិស័យទេសចរណ៍ ។ ***ទី២*** : សេដ្ឋកិច្ចនៅបណ្តាប្រទេសអភិវឌ្ឍ បានងើបឡើងវិញយឺតៗ ។ *រាជរដ្ឋាភិបាល កម្ពុជា* បានធ្វើការឆ្លើយតបយ៉ាងទាន់ពេលវេលា ក្នុងការកាត់បន្ថយឱ្យបានច្រើនបំផុត នូវហានិភ័យនានា ដែលអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចមានការធ្លាក់ចុះ ក៏ដូចជា ផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោក និងឱនភាពសេដ្ឋកិច្ចក្នុងសកលលោកនិងក្នុងតំបន់ មកលើ កំណើនសេដ្ឋកិច្ចរបស់កម្ពុជា និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ជាពិសេស ប្រជាជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ។ ពិនិត្យជារួម ជំងឺផ្តាសាយថ្មី ពុំបានរីករាលដាលនៅក្នុងកម្រិតមួយ ដូចដែលយើងបានគិតស្មានទុកជាមុននោះទេ ។ កម្រិតនៃការព្រួយបារម្ភអំពីល្បឿននៃការស្ទុះងើបឡើងវិញរបស់សេដ្ឋកិច្ច ហាក់ដូចជាមានការធ្លាក់ចុះចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៩ មក ដោយសារតែសេដ្ឋកិច្ចសកលលោកបានចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗ ។ បច្ចុប្បន្ននេះ កម្ពុជាកំពុងជួបប្រទះនឹងបញ្ហាប្រឈម ក្នុងការរកទីផ្សារថ្មីៗទៀត ក្រៅពីទីផ្សារសហរដ្ឋអាមេរិកនិងទីផ្សារអឺរ៉ុប ដើម្បីជំរុញឱ្យកំណើនសេដ្ឋកិច្ចមានអត្រាខ្ពស់ឡើងវិញ ដោយមានការកាត់បន្ថយភាពក្រីក្រក្នុងល្បឿនមួយ ដែលយើងធ្លាប់បានសម្រេចនៅក្នុងទសវត្សរ៍កន្លងទៅ ។

៣០៣. ទិន្នន័យដំបូង ស្តីពីស្ថានភាពសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ បានបង្ហាញពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលលោក មកលើវិស័យសេដ្ឋកិច្ចសំខាន់ៗ របស់កម្ពុជា ។ ដោយផ្អែកលើការប៉ាន់ស្មានដំបូង កំណើនផលិតផលក្នុងស្រុកសរុប បានកើនឡើង ០,១ភាគរយ ក្នុងឆ្នាំ២០០៩ ធៀបនឹង ៦,៧ភាគរយ ក្នុងឆ្នាំ២០០៨ ។ កំណើនជាទូទៅដែលមានលក្ខណៈវិជ្ជមាននេះ ត្រូវបានធ្វើឱ្យកើតមានឡើង តាមរយៈ ការសម្រេចបានលទ្ធផលល្អនៅក្នុងវិស័យកសិកម្ម ដែលមានកំណើន ៥,៤ភាគរយ និងក្នុងវិស័យសេវាកម្ម ដែលមានកំណើន ២,៣ភាគរយ ដោយបានជួយបំពេញ ឱ្យវិស័យឧស្សាហកម្ម ដែលបានធ្លាក់ចុះ ៩,៥ភាគរយ ជាពិសេស អនុវិស័យកាត់ដេរ ដែលមានការធ្លាក់ចុះ ៩,០ភាគរយ ។ អនុវិស័យទាំងអស់ នៃវិស័យសេវាកម្ម បានកើនឡើង លើកលែងតែ អនុវិស័យអចលនទ្រព្យ ដែលមានការធ្លាក់ចុះ ២,៥ភាគរយ ។ វិស័យទេសចរណ៍ បានទទួលរងផលប៉ះពាល់ខ្លាំង ពីវិបត្តិសកលលោកនេះ បានថយចុះ ១,៨ភាគរយ ក្នុងឆ្នាំ២០០៩ ធៀបនឹង កំណើនពីរខ្ទង់ នៅក្នុងបណ្តាឆ្នាំមុនៗ ។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ក៏បានធ្លាក់ចុះយ៉ាងច្រើន នៅក្នុងទំហំប្រមាណ ៥០០លានដុល្លារអាមេរិក ផងដែរ ។

៣០៤. ដូចដែលបានគូសបញ្ជាក់ពីខាងលើ សេដ្ឋកិច្ចសកលលោកនាពេលបច្ចុប្បន្ននេះ បានងើបឡើងវិញ - ជំនឿរបស់វិនិយោគិនអន្តរជាតិក៏មានឡើងវិញបន្តិចម្តងៗ - សូចនាករនៃផលិតកម្មនិងតម្រូវការនាពេលខាងមុខ ក៏មានលក្ខណៈរឹងមាំ - ជំនឿរបស់អ្នកប្រើប្រាស់កំពុងតែកើនឡើង - កម្មន្តសាល និងការងារធ្វើដែលបានធ្លាក់ចុះ បានចាប់ផ្តើមងើបឡើងវិញ - ហើយ ការផ្តល់ឥណទានដល់វិស័យឯកជន កំពុងស្ថិតក្នុងសន្ទុះវិជ្ជមាន ផងដែរ ។ ទោះជាដូចនេះក្តី ក៏មូលដ្ឋានតូចចង្អៀតនៃផលិតកម្ម ការពឹងផ្អែកនៃវិស័យកាត់ដេរទៅលើសហរដ្ឋអាមេរិក និងភាពពឹងផ្អែកនៃសេដ្ឋកិច្ចទៅលើលំហូរទុនបរទេស នឹងបន្តធ្វើឱ្យកម្ពុជានៅតែទទួលរងនូវភាពងាយរងគ្រោះ ចំពោះការប្រែប្រួលនៃទីផ្សារសកលលោក ។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសចិនថ្មីៗនេះ និងស្ថានភាពរឹងមាំនៃអត្រាកំណើននៃសេដ្ឋកិច្ចនេះ នាពេលអនាគត អាចនឹងមានផលប៉ះពាល់ជាវិជ្ជមាន មកលើសេដ្ឋកិច្ចកម្ពុជា ។

៣០៥. ទោះបីជា *រាជរដ្ឋាភិបាលកម្ពុជា* បានត្រៀមខ្លួនយ៉ាងល្អទប់ទល់នឹងវិបត្តិសេដ្ឋកិច្ចនេះ តាមរយៈ ក្របខ័ណ្ឌគោលនយោបាយដ៏រឹងមាំ ដែលមានតាំងពីទសវត្សរ៍មុនមក និងការអនុវត្តវិធានការគោលនយោបាយយ៉ាងឆាប់រហ័សទាន់ពេល យ៉ាងណាក្តី ក៏ការមិនសម្រេចបាននូវលទ្ធផលនានា និងអត្រានៃភាពមានការងារធ្វើ ទំនងជានឹងកើនឡើង នៅក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។ បើផ្អែកលើស្ថានភាពប្រែប្រួលទាំងនេះ កម្រិតនៃសកម្មភាពសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានទុកជាមុនថា នឹងកើនឡើងយឺតៗ នៅក្នុងឆ្នាំ២០១០ ហើយអត្រាកំណើនសេដ្ឋកិច្ច នឹងកើនឡើងជាមធ្យម ប្រមាណ ៥ ភាគរយ បើធៀបនឹងអត្រាកំណើន ដែលមាននៅក្នុងទសវត្សរ៍មុន។

៣០៦. *រាជរដ្ឋាភិបាល* យល់ថា កំណើនចំណាយរបស់អ្នកប្រើប្រាស់ នៅក្នុងប្រទេសសេដ្ឋកិច្ចធំៗ ជាពិសេសសេដ្ឋកិច្ចនៃសហរដ្ឋអាមេរិកនិងអឺរ៉ុប នឹងមិនជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ដូចកាលពីអតីតកាលទេ ។ *រាជរដ្ឋាភិបាល* មានជំនឿថា តាមរយៈ ការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយក្នុងការធ្វើពិពិធកម្មនិងការពង្រីកមូលដ្ឋានសេដ្ឋកិច្ច ការបង្កើនភាពប្រកួតប្រជែងនៅក្នុងទីផ្សារអន្តរជាតិនិងតំបន់ កំណើនសេដ្ឋកិច្ច នឹងមានទំនោរទៅរកនិន្នាការកំណើនដូចធ្លាប់មានពីមុន សម្រាប់ដំណាក់ឆ្នាំ ២០១១-២០១៣ ។

៣០៧. ការប៉ាន់ស្មានដំបូងអំពី *ផសស ពិតសរុប* តាមសកម្មភាពសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០០៩ និងការព្យាករណ៍សម្រាប់ដំណាក់កាលឆ្នាំ ២០០៩-២០១៣ ត្រូវបានបង្ហាញនៅក្នុង *តារាងទី៩* ។

**តារាងទី៩ : ការព្យាករណ៍សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០០៨-២០១៣**

| សូចនាករសេដ្ឋកិច្ច | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| *ផសស* (ថ្លៃថេរឆ្នាំ២០០០-គិតជា ពាន់លានរៀល) | ២៨ ៦៦៨ | ២៨ ៦៩២ | ៣០ ១២៦ | ៣១ ៩៤១ | ៣៤ ០២៩ | ៣៦ ២៣៥ |
| *ផសស* (ថ្លៃថេរឆ្នាំ២០០០-គិតជា លានដុល្លារ) | ៧ ០៦១ | ៦ ៩១៧ | ៧ ២៦៨ | ៧ ៧២៥ | ៨ ១៨៤ | ៨ ៧០៤ |
| *ផសស* សម្រាប់ប្រជាជនម្នាក់ៗ (ដុល្លារ) | ៧៣៨ | ៧៣១ | ៧៩២ | ៨៥៣ | ៩១៥ | ៩៨១ |
| *ផសស* សម្រាប់ប្រជាជនម្នាក់ៗ (ពាន់រៀល) | ២ ៩៩៨ | ៣ ០៣០ | ៣ ២៣៤ | ៣ ៥២៨ | ៣ ៧៩៩ | ៤ ០៨៤ |

| សូចនាករសេដ្ឋកិច្ច | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| **អត្រាកំណើន *ផសស ពិត* (%)** | **៦,៧** | **០,១** | **៥,០** | **៦,០** | **៦,៥** | **៦,៥** |
| សន្ទស្សន៍*ផសស - ផសស ឌីផ្លេតទ័រ* (ការប្រែប្រួលប្រចាំឆ្នាំ - %) | ១២,៣ | ២,៦ | ៤,៨ | ២,៩ | ២,៦ | ២,៥ |
| | | | | | | |
| អតិផរណា (ការប្រែប្រួលមធ្យមប្រចាំឆ្នាំ - %) | ១៩,៧ | -០,៦ | ៦,០ | ៤,៥ | ៣,៥ | ៣,០ |
| អតិផរណា (ការប្រែប្រួលក្នុងត្រីមាសទី៤ - %) | ១៥,៨ | ៦,០ | ៦,០ | ៣,៥ | ៣,៥ | ៣,០ |
| **អតិផរណា (ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ-%)** | **១២,៥** | **៥,៣** | **៦,២** | **៥,០** | **៣,៥** | **៣,០** |
| ប្រាក់រៀល ធៀបនឹង ដុល្លារ (មធ្យមប្រចាំឆ្នាំ) | ៤ ០៦០ | ៤ ១៤៨ | ៤ ១៤៥ | ៤ ១៣៥ | ៤ ១៥៣ | ៤ ១៦៣ |
| ប្រាក់រៀល ធៀបនឹង ដុល្លារ (ចុងឆ្នាំ) | ៤ ០៨០ | ៤ ១៨០ | ៤ ១១០ | ៤ ១៤០ | ៤ ១៦០ | ៤ ១៧០ |
| | | | | | | |
| **ការវិនិយោគសរុប (% *ផសស*)** | **២៤,៥** | **២៣,៣** | **២៤,១** | **២៤,២** | **២៤,៣** | **២៤,៤** |
| ការវិនិយោគសាធារណៈ (% *ផសស*) | ៦,៥ | ៦,៩ | ៧,០ | ៦,៧ | ៦,៨ | ៦,៨ |
| ការវិនិយោគឯកជន (% *ផសស*) | ១៨,០ | ១៦,៤ | ១៧,១ | ១៧,៤ | ១៧,៥ | ១៧,៦ |
| សញ្ជ័យជាតិ (% *ផសស*) | ១៦,៩ | ១៨,៦ | ១៩,២ | ១៩,៤ | ២០,២ | ២១,២ |
| សញ្ជ័យក្រៅប្រទេស (% *ផសស*) | ៧,៦ | ៤,៧ | ៤,៩ | ៤,៨ | ៤,១ | ៣,៣ |
| | | | | | | |
| **ចំណូលថវិកាសរុប (% *ផសស*)** | **១៣,៣** | **១១,៨** | **១២,៦** | **១៣,២** | **១៣,៧** | **១៤,២** |
| **ចំណាយថវិកាសរុប (% *ផសស*)** | **១៥,៩** | **១៧,៥** | **១៧,៩** | **១៧,៨%** | **១៧,៨** | **១៧,៧** |
| ឱនភាព/អតិរេក ថវិកាចរន្ត (% *ផសស*) | ៣,០ | ០,១ | ១,៣ | ១,៧ | ២,២ | ២,៨ |
| ឱនភាព/អតិរេក ថវិកាទូទៅ (% *ផសស*) | -២,៩ | -៦,៣ | -៥,៣ | -៤,៦ | -៤,០ | -៣,៥ |
| | | | | | | |
| **ការនាំចេញនៃទំនិញ (% *ផសស*)** | **៤៥,៥** | **៣៧,៦** | **៣៧,៤** | **៣៨,៨** | **៤១,០** | **៤៣,៤** |
| **ការនាំចូលនៃទំនិញ (% *ផសស*)** | **៦៣,០** | **៥២,៥** | **៥២,៥** | **៥៣,៧** | **៥៥,១** | **៥៦,៦** |
| តុល្យភាពពាណិជ្ជកម្ម (% *ផសស*) | -១៧,៤ | -១៤,៨ | -១៥,១ | -១៤,៩ | -១៤,១ | -១៣,១ |
| តុល្យភាពគណនីចរន្ត (% *ផសស*) | -១២,២ | -១០,១ | -១០,១ | -៩,៧ | -៨,៩ | -៧,៨ |
| | | | | | | |
| សាច់ប្រាក់ងាយស្រួលសរុប (ពាន់លានរៀល) | ១១ ៨៥៨ | ១៦ ២២៨ | ១៩ ១៣៧ | ២៣ ០៦៩ | ២៨ ០០១ | ៣៤ ០៣០ |
| សាច់ប្រាក់ងាយស្រួលសរុប (ការប្រែប្រួលជា %) | ៤,៨ | ៣៦,៩ | ១៧,៩ | ២០,៥ | ២១,៤ | ២១,៥ |
| សាច់ប្រាក់ងាយស្រួលសរុប (% *ផសស*) | ២៨,៣ | ៣៧,៧ | ៤០,៤ | ៤៤,៦ | ៤៩,៥ | ៥៥,១ |
| **ទុនបម្រុងបរទេសដុល (លានដុល្លារ)** | **២ ១៦៤** | **២ ៣៦៧** | **១ ៩៣៥** | **២ ១៤២** | **២ ៣៦១** | **២ ៦០០** |
| ទុនបម្រុងបរទេសដុល (ខែនៃការនាំចូល ទំនិញ និងសេវាកម្ម) | ៣,៥ | ៤,៦ | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ |
| | | | | | | |
| **ចំនួនប្រជាជន (តួលេខកែសម្រួល-លាននាក់)** | **១៤,០** | **១៤,២** | **១៤,៤** | **១៤,៧** | **១៤,៩** | **១៥,១** |

***ប្រភព** : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ*

៣០៨. ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ កិច្ចខិតខំរបស់ *រាជរដ្ឋាភិបាល* ក្នុងការពង្រឹងវិន័យសារពើពន្ធ ការដាក់ឱ្យមានក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ ដែលកាន់តែទទួលបានជំនឿទុកចិត្ត និងការអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធបានជួយឱ្យកម្ពុជា សម្រេចបាននូវការអនុវត្តសេដ្ឋកិច្ចមួយដ៏ល្អបំផុត នៅក្នុងប្រវត្តិសាស្ត្រថ្មីចាប់តាំងពីឆ្នាំ ១៩៩៣ ។ កំណែទម្រង់រចនាសម្ព័ន្ធបានជួយឱ្យដំណើរការសេដ្ឋកិច្ចប្រព្រឹត្តទៅបានយ៉ាងល្អ នៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជាចាប់តាំងពីឆ្នាំ ២០០៣ មក ។ ក្នុងអំឡុងពេលនៃវិបត្តិហិរញ្ញវត្ថុ សេដ្ឋកិច្ចកម្ពុជានៅតែបង្ហាញនូវ ភាពមិនទ្រុឌទ្រោម និងបត់បែនបាន ។ *រាជរដ្ឋាភិបាលកម្ពុជា* មានជំនឿជឿជាក់ថា ការបន្តអនុវត្តដ៏ខ្លាំងក្លានូវនយោបាយរបស់ខ្លួន នឹងអាចទាញយកប្រយោជន៍ពីសក្តានុពលសេដ្ឋកិច្ចនេះ ។

## តារាងទី១០ : ផលិតផលក្នុងស្រុកពិតសរុប – *ផសស ពិតសរុប* (ថ្លៃថេរឆ្នាំ២០០០)
## អត្រាកំណើននៃសកម្មភាពសេដ្ឋកិច្ចឆ្នាំ : ២០០៩-២០១៣
(គិតជា%)

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | **៥,៤** | **៤,០** | **៣,២** | **៣,៤** | **៣,២** |
| ដំណាំ | ៥,៨ | ៤,៤ | ៣,៥ | ៣,៧ | ៣,៤ |
| បសុសត្វ និង បសុបក្សី | ៥,០ | ៥,៦ | ៤,៤ | ៤,៦ | ៤,៩ |
| ជលផល | ៦,០% | ២,៩ | ២,៥ | ២,៥ | ២,៥ |
| ផលព្រៃឈើ | ១,១% | ១,១ | ១,១ | ១,១ | ១,១ |
| **ឧស្សាហកម្ម** | **-៩,៥** | **១០,៥** | **៧,៩** | **៨,៤** | **៨,២** |
| រ៉ែ | ២០,០ | ៥,៦ | ៧,៣ | ៧,៧ | ៦,២ |
| កម្មន្តសាល | -១៥,៥ | ១៤,២ | ៩,០ | ៩,២ | ៩,២ |
| អាហារ ភេសជ្ជៈ និង ថ្នាំជក់ | ៦,០ | ២,៦ | ៦,៧ | ៧,៨ | ៧,៨ |
| វាយនភ័ណ្ឌ សម្លៀកបំពាក់ និង គ្រឿងសម្រាប់ពាក់នៅជើង | -៩,០ | ១,៥ | ១០,០ | ១០,០ | ១០,០ |
| ឈើ ក្រដាស និង បោះពុម្ព | ៥,០ | ២,៥ | ៥,៧ | ៦,២ | ៦,១ |
| កម្មន្តសាលកៅស៊ូ | ៩,៥ | ៣,១ | ៥,៧ | ៦,០ | ៦,០ |
| កម្មន្តសាលផ្សេងៗទៀត | ៧,៨ | ៣,១ | ៥,៦ | ៦,៨ | ៦,៨ |
| អគ្គិសនី ឧស្ម័ន និងទឹក | ៨,៥ | ៤,៦ | ៨,២ | ៨,៦ | ៨,៦ |
| សំណង់ | ៥,០ | ២,៦ | ៤,៩ | ៦,០ | ៥,១ |
| **សេវា** | **២,៣** | **៣,៣** | **៧,៣** | **៧,៤** | **៧,៤** |

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| ពាណិជ្ជកម្ម | ៤.២ | ៣.៣ | ៥.៦ | ៥.៦ | ៥.៦ |
| សណ្ឋាគារ និង ភោជនីយដ្ឋាន | ១.៨ | ៤.២ | ៩.៤ | ៩.៥ | ៩.៥ |
| ដឹកជញ្ជូន និង ទូរគមនាគមន៍ | ៣.៩ | ៣.៤ | ៧.៣ | ៧.៥ | ៧.៥ |
| ហិរញ្ញវត្ថុ | ៨.០ | ៣.៣ | ៨.០ | ៧.៧ | ៧.៧ |
| រដ្ឋបាលសាធារណៈ | ១.០ | ៣.២ | ៨.៧ | ៨.២ | ៨.២ |
| អចលនវត្ថុ និង ធុរកិច្ច | -២.៥ | ៣.៤ | ៧.៦ | ៧.៧ | ៧.៧ |
| សេវាផ្សេងៗ | ២.៩ | ២.៧ | ៧.៥ | ៧.៥ | ៧.៥ |
| | | | | | |
| ពន្ធលើផលិតផល ដក ឧបត្ថម្ភធន | ៦.១ | ០.១ | ៣.៨ | ៧.០ | ៧.០ |
| ដក ឧបត្ថម្ភធន | ១.៩ | ៣៥.៥ | ៣.៨ | ៧.០ | ៧.០ |
| ដក បន្ទុកលើសេវាហិរញ្ញវត្ថុ | ១២.០ | ៥.៨ | ៨.០ | ៧.៧ | ៧.៧ |
| **ផលិតផលក្នុងស្រុកសរុប ( *ផសស សរុប*** | **០.១** | **៥.០** | **៦.០** | **៦.៥** | **៦.៥** |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ*

## ៤. ការវិនិយោគដែលចាំបាច់ ដើម្បីសម្រេចបាននូវកំណើន *ផសស* ដែលបានគ្រោងទុក

៣០៩. គំរូនៃសេដ្ឋកិច្ចវិទ្យាធ្លាប់ប្រើ ដើម្បីធ្វើការព្យាករណ៍សេដ្ឋកិច្ច សម្រាប់រយៈពេល ៥ឆ្នាំ ពី ឆ្នាំ២០០៩ ដល់ ២០១៣ ក៏អាចត្រូវបានប្រើប្រាស់ ដើម្បីធ្វើការព្យាករណ៍ការវិនិយោគសរុប ដែលចាំបាច់ក្នុងការធ្វើសម្រេចបាននូវកំណើន *ផសស សរុប* ដូចដែលបានគ្រោង និង ការបែងចែកនៃការវិនិយោគសរុប ទៅតាមវិស័យសេដ្ឋកិច្ច ។ ថ្វីបើភាពមានកម្រិតខ្លះពីគំរូនៃសេដ្ឋកិច្ចវិទ្យាក៏ដោយ ក៏លទ្ធផលនៃការវិភាគបង្ហាញថា ទឹកប្រាក់នៃការវិនិយោគសរុបចំនួន ៦២ ០២០,៧ពាន់លានរៀល (១៥,១២៧ពាន់លានដុល្លារអាមេរិក) គឺជាតម្រូវការ ដើម្បីសម្រេចបាននូវកំណើន *ផសស សរុប* ដែលបានគ្រោងទុក សម្រាប់ដំណាក់កាលនៃ *ផយអជ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣* ។ ចំពោះប្រភពនៃវិនិយោគមូលធនសរុប ការវិនិយោគរបស់វិស័យឯកជនបានចូលរួមចំណែកចំនួន ៤៤ ៤៨០,១ពាន់លានរៀល (១០,៨ពាន់លានដុល្លារអាមេរិក) ដែលស្មើនឹងប្រមាណ ៧១,៧ភាគរយ នៃការវិនិយោគសរុប ។ ការវិនិយោគសាធារណៈមានចំនួន ១៧ ៥៤០,៦ពាន់លានរៀល (៤,២ពាន់លានដុល្លារអាមេរិក) ។ ចំពោះធនធានក្នុងស្រុកនិងពីបរទេសសម្រាប់ការធ្វើហិរញ្ញប្បទានដល់ការវិនិយោគមូលធនសរុប ៥៦,២ភាគរយ នៃវិនិយោគសរុប ត្រូវបានគ្រោងទុកថា ទទួលបានការធ្វើហិរញ្ញប្បទានពីធនធានក្នុងស្រុក ដែលស្មើនឹងប្រមាណ ៣៤ ៨៤៩,០ពាន់លានរៀល (៨,៤ពាន់លានដុល្លារអាមេរិក) ។ ហិរញ្ញប្បទានពីប្រភពក្រៅប្រទេស អាចមានចំនួនប្រមាណ ២៧ ១៧១,៧ពាន់លានរៀល (៦,៦ពាន់លានដុល្លារអាមេរិក) ដែលស្មើនឹងប្រមាណ ៤៣,៨ភាគរយ នៃវិនិយោគមូលធនសរុប ។

## តារាងទី១១ : ការវិនិយោគមូលធនចាំបាច់ ដើម្បីសម្រេចបានកំណើនផលិតផលសរុបក្នុងស្រុកដែលបានគ្រោងទុក និង ធនធានដែលអាចមាន សម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ឆ្នាំ ២០០៩-២០១៣

(គិតជា ពាន់លានរៀល)*

| ប្រភពហិរញ្ញប្បទាន | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប ២០០៩-២០១៣ |
|---|---|---|---|---|---|---|
| **វិនិយោគមូលធនសរុប** | **៩ ៩១៤,៦** | **១១ ៣០៧,៥** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦២ ០២០,៧** |
| • **វិនិយោគមូលធនរបស់វិស័យសាធារណៈ** | **២ ៩១៧,១** | **៣ ២៩០,៨** | **៣ ៤៤៨,២** | **៣ ៧៧០,៦** | **៣ ១១៣,៩** | **១៧ ៥៤០,៦** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧៣៧,៧ | ៧៦២,៦ | ៧៩៩,១ | ៨៧៣,៨ | ៩៥៣,៤ | ៤ ១២៦,៧ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ២ ១៧៩,៤ | ២ ៥២៨,១ | ២ ៦៤៩,១ | ២ ៨៩៦,៧ | ៣ ១៦០,៥ | ១៣ ៤១៣,៩ |
| • **វិនិយោគមូលធនរបស់វិស័យឯកជន** | **៦ ៩៩៧,៥** | **៨ ០១៦,៨** | **៨ ៩៤៦,៧** | **៩ ៧៩៣,៩** | **១០ ៧២៥,៣** | **៤៤ ៤៨០,១** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៤ ៨៨៧,២ | ៥ ៥៥៩,៦ | ៦ ១៧៣,៦ | ៦ ៧៤១,១ | ៧ ៣៦០,៧ | ៣០ ៧២២,៣ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ២ ១១០,៣ | ២ ៤៥៧,១ | ២ ៧៧៣,១ | ៣ ០៥២,៧ | ៣ ៣៦៤,៦ | ១៣ ៧៥៧,៨ |
| **វិនិយោគមូលធនសរុប** | **៩ ៩១៤,៨** | **១១ ៣០៧,៥** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦០ ២០០,៧** |
| • វិនិយោគមូលធនរបស់វិស័យសាធារណៈ | ២ ៩១៧,១ | ៣ ២៩០,៨ | ៣ ៤៤៨,២ | ៣ ៧៧០,៦ | ៤ ១១៣,៩ | ១៧ ៥៤០,៦ |
| • វិនិយោគមូលធនរបស់វិស័យឯកជន | ៦ ៩៩៧,៥ | ៨ ០១៦,៨ | ៨ ៩៤៦,៧ | ៩ ៧៩៣,៨ | ១០ ៧២៥,៣ | ៤៤ ៤៨០,១ |
| **វិនិយោគមូលធនសរុប** | **៩ ៩១៤,៦** | **១១ ៣០៧,៥** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦២ ០២០,៧** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៥ ៦២៥,០ | ៦ ៣២២,៣ | ៦ ៩៧២,៧ | ៧ ៦១៤,៩ | ៨ ៣១៤,១ | ៣៤ ៨៤៩,០ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ៤ ២៨៩,៦ | ៤ ៩៨៥,២ | ៥ ៤២២,២ | ៥ ៩៤៩,៥ | ៦ ៥២៥,១ | ២៧ ១៧១,៧ |
| **វិនិយោគមូលធនរបស់វិស័យសាធារណៈ** | **២ ៩១៧,១** | **៣ ២៩០,៨** | **៣ ៤៤៨,២** | **៣ ៧៧០,៦** | **៤ ១១៣,៩** | **១៧ ៥៤០,៦** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧៣៧,៧ | ៧៦២,៦ | ៧៩៩,១ | ៨៧៣,៨ | ៩៥៣,៤ | ៤ ១២៦,៧ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ២ ១៧៩,៤ | ២ ៥២៨,១ | ២ ៦៤៩,១ | ២ ៨៩៦,៧ | ៣ ១៦០,៥ | ១៣ ៤១៣,៩ |

*__ប្រភព__ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

* តួលេខជាប្រាក់រៀលនៅក្នុងតារាងនេះ ត្រូវបានគណនាចេញពីការព្យាករជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យម ៤ ១០០រៀល/១ដុល្លារអាមេរិក

** គិតតែវិនិយោគមូលធនប៉ុណ្ណោះ ដោយមិនគិតបញ្ចូលនូវ ជំនួយបច្ចេកទេស

៣១០. ការបែងចែកលម្អិតនៃការវិនិយោគចាំបាច់ ដើម្បីសម្រេចបានកំណើន *ផសស សរុប* ដែលបានគ្រោងទុកតាមរយៈ វិស័យសេដ្ឋកិច្ច ត្រូវបានបង្ហាញក្នុង *តារាងទី១២* ។ ដើម្បីសម្រេចបានអត្រាកំណើន*ផសស សរុប* ដែលបានគ្រោងទុកតាមវិស័យ ការវិនិយោគក្នុងក្រុមវិស័យសំខាន់ៗ រួមមាន ដូចខាងក្រោម :

- *វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* នឹងត្រូវការ ទុនវិនិយោគចំនួន ១១ ៨២៥,១ ពាន់លានរៀល (២,៨៨៤ ពាន់លានដុល្លារអាមេរិក) សម្រាប់រយៈពេល ៥ឆ្នាំ (២០០៩-២០១៣) ។
- *វិស័យឧស្សាហកម្មទូទៅ* រួមមាន (*រុករករ៉ែ - កម្មន្តសាល - អគ្គិសនី ឧស្ម័ន និងទឹក* - និង*សំណង់*) នឹងត្រូវការទុនវិនិយោគចំនួន ២៨ ៦០១,៨ ពាន់លានរៀល (៦,៩៧៦ ពាន់លានដុល្លារអាមេរិក) សម្រាប់

រយៈពេល៥ឆ្នាំ (២០០៩-២០១៣) ។ នៅក្នុងក្រុមនេះ *អនុវិស័យកម្មន្តសាល ( វាយនភ័ណ្ឌ សម្លៀកបំពាក់ និងគ្រឿងពាក់នៅជើង)* នឹងត្រូវការចំណែកធំជាងគេនៃការវិនិយោគ គឺមានចំនួនប្រមាណ ១៣ ០០៤.០ ពាន់លានរៀល (៣.១៧១ពាន់លានដុល្លារអាមេរិក) ។ បន្ទាប់ពី*អនុវិស័យកម្មន្តសាល អនុវិស័យសំណង់* ត្រូវការចំណែកធំបន្ទាប់នៃការវិនិយោគ គឺមានចំនួន ៩ ៨២៤.៧ពាន់លានរៀល (២.៣៩៦ពាន់លានដុល្លារអាមេរិក) ហើយ *អនុវិស័យអគ្គិសនី ឧស្ម័ន និងទឹក* ត្រូវការទុនវិនិយោគចំនួនប្រមាណ ៤ ១៩៣.៣ ពាន់លានរៀល (១.០០២ពាន់លានដុល្លារអាមេរិក) ។

- *វិស័យសេវាកម្ម* (ដែលរួមមាន *ពាណិជ្ជកម្ម សណ្ឋាគារ និង ភោជនីយដ្ឋាន (ទេសចរណ៍) ដឹកជញ្ជូន និងទូរគមនាគមន៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យ)* ត្រូវការនូវទុនវិនិយោគ ២១ ៥៩៣.៨ ពាន់លានរៀល (៥.២៦៦ពាន់លានដុល្លារអាមេរិក) ។

**តារាងទី១២ : វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន ផសស**

(គិតជា ពាន់លានរៀល)

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
|---|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់និង នេសាទ** | **១ ៩៦០.២** | **២ ៣១៤.៧** | **២ ៤៨៣.៧** | **២ ៦៩០១** | **២ ៨១៦.៤** | **១១ ៨២៥.១** |
| ដំណាំ | ១ ២៨១.១ | ១ ៨៩២.៩ | ២ ០៣៣.៨ | ២ ១៧៣.៨ | ២ ៣១២.១ | ៩.៦៩៣.៧ |
| ចិញ្ចឹមសត្វ | ៨១.៩ | ១៥១.៣ | ១៦៣.៨ | ១៧៦.២ | ១៨៩.៩ | ៧៦៣.០ |
| នេសាទ | ១០៤.៥ | ១៧៧.៩ | ១៨៨.៩ | ១៩៩.១ | ២០៩.៦ | ៨៨០.០ |
| ព្រៃឈើ | ៩២.៦ | ៩២.៧ | ៩៧.១ | ១០១.០ | ១០៤.៨ | ៤៨៨.៣ |
| **ឧស្សាហកម្ម** | **៤ ៦១៤.១** | **៥ ០៧០.២** | **៥ ៧១៧.៥** | **៦ ២៨៨.៣** | **៦ ៩១១.៦** | **២៨ ៦០១.៨** |
| រ៉ែ | ២៥៣.៣ | ២៨២.៤ | ៣១៣.៩ | ៣៤៦.៧ | ៣៨៣៥ | ១.៥៧៩.៧ |
| ផលិតកម្ម | ១ ៩២០.២ | ២ ២៧៥.៩ | ២ ៦៤៧.៦ | ២ ៩២៣.៣ | ៣ ២៣៦.៩ | ១៣ ០០៤.០ |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ១៩៩.៧ | ២៥៣.៤ | ២៨០.១ | ៣០៩.៦ | ៣៤២.៨ | ១.៣៨១.៦ |
| វាយនភ័ណ្ឌ | ៨២៨.៤ | ៨២៦.១ | ១ ០៥៨.៩ | ១ ១៨១.៣ | ១ ៣២៣.២ | ៥ ២១៧.៨ |
| ឈើ ក្រដាស និងផ្នែកបោះពុម្ព | ៥៨.៤ | ៥៥.១ | ៦០.៤ | ៦៥.៧ | ៧១.៧ | ៣១១.៣ |
| ផលិតកម្មកៅស៊ូ | ៦៧.៨ | ៦៣.១ | ៦៩.១ | ៧៥.១ | ៨១.៨ | ៣៥៦.៩ |
| ផលិតកម្មដទៃ | ៧៧០.០ | ១ ០៧៨.២ | ១ ១៧៩.២ | ១ ២៩១.៧ | ១ ៤១៧.៤ | ៥ ៧៣៦.៥ |
| អគ្គិសនី ឧស្ម័ន និង ទឹកស្អាត | ៦៧២.០ | ៧៣៩.៧ | ៨២៩.១ | ៩២៣.០ | ១ ០២៩.៥ | ៤ ១៩៣.៣ |
| សំណង់ | ១ ៧៦៨.៦ | ១ ៧៧២.៣ | ១ ៩២៦.៩ | ២ ០៩៥.៣ | ២ ២៦១.៧ | ៩ ៨២៤.៧ |
| **សេវាកម្ម** | **៣ ៧៤០.៣** | **៣ ៩២២.៦** | **៤ ១៩៣.៧** | **៤ ៦២៥.៩** | **៥ ១១១.២** | **២១ ៥៩៣.៨** |
| ពាណិជ្ជកម្ម | ៦៩១.២ | ៦៩៧.៨ | ៧៦២.៩ | ៨២៦.៥ | ៨៩៦.៩ | ៣ ៨៧៥.២ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៤៩៦.០ | ៥៤៤.២ | ៦០៩.២ | ៦៨១.៤ | ៧៦២.១ | ៣ ០៩៣.០ |

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
|---|---|---|---|---|---|---|
| ដឹកជញ្ជូន និងទូរគមនាគមន៍ | ៦៣៩,៨ | ៦៧៦,៨ | ៧៥២,១ | ៨២៨,៩ | ៩១៥,១ | ៣ ៨១២,៧ |
| ហិរញ្ញវត្ថុ | ១១០,៨ | ១០៥,១ | ១១៧,៦ | ១២៩,៩ | ១៤៣,៨ | ៦០៧,១ |
| រដ្ឋបាលសាធារណៈ | ៨១៦,៨ | ៨៩៩,៥ | ៨៣៨,៥ | ៩៣០,៦ | ១ ០៣៤,៨ | ៤ ៥២០,២ |
| អចលនទ្រព្យ និងធុរកិច្ច | ៦០៥,៤ | ៦២២,៥ | ៦៩៣,៩ | ៧៦៦,៥ | ៨៤៨,៣ | ៣ ៥៣៦,៧ |
| សេវាកម្មដ៏ទៃទៀត | ៣៨០,៤ | ៣៧៦,៧ | ៤១៩,៤ | ៤៦២,២ | ៥១០,៣ | ២ ១៤៨,៩ |
| **សរុប** | **៩ ៩១៤,៦** | **១១ ៣០៧,៦** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦២ ០២០,៧** |

***ប្រភព** : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ៥. ចំណូលនិងចំណាយថវិកា : ២០០៩-២០១៣

៣១១. ដោយសារវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសកលលោក ដែលបាននិងកំពុងកើតឡើងក្នុងប្រទេសអភិវឌ្ឍ បានជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ចំណូលថវិកាបានធ្លាក់ចុះពី ១៣,៣ភាគរយនៃ *ផសស សរុប* ក្នុងឆ្នាំ២០០៨ មក ១១,៨ភាគរយនៃ *ផសស សរុប* ក្នុងឆ្នាំ២០០៩ *(សូមមើលតារាងទី៩)* ។ ចំណូលថវិកា ត្រូវបានព្យាករណ៍ថា នឹងកើនឡើងវិញជាបន្តបន្ទាប់ ហើយនឹងកើនលើសកម្រិតក្នុងឆ្នាំ២០០៨ នៅឆ្នាំ២០១២ ហើយត្រូវបានព្យាករណ៍ថា នឹងកើនដល់ ១៤,២ភាគរយ នៃ *ផសស សរុប* ក្នុងឆ្នាំ២០១៣ ។ ការអនុវត្តនូវវិធានការនានារបស់ *រាជរដ្ឋាភិបាល* ដែលផ្តោតលើការការពារ ក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ ពីផលប៉ះពាល់អវិជ្ជមាននៃឱនភាពសេដ្ឋកិច្ច ក៏ដូចជា ការអនុវត្តវិធានការសម្រាប់ជំរុញតម្រូវការ តាមរយៈ កញ្ចប់គោលនយោបាយសម្រាប់ជំរុញកំណើន បានធ្វើឱ្យចំណាយថវិកាជាសមាមាត្រនៃ*ផសស សរុប* បានកើនឡើងពី ១៥,៩ភាគរយ ក្នុងឆ្នាំ២០០៨ ដល់ ១៧,៥ភាគរយ ក្នុងឆ្នាំ២០០៩ ។

៣១២. ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បានអនុវត្តដំណើរការចំនួនពីរ ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ។ ***ទីមួយ*** គឺ ក្របខ័ណ្ឌចំណាយសម្រាប់រយៈមធ្យម ដែលព្យាករណ៍តួលេខចំណាយចរន្តសម្រាប់រយៈពេលបីឆ្នាំខាងមុខ ។ ការព្យាករណ៍នេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ ។ ការព្យាករណ៍ផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ច គោលនយោបាយអាទិភាព ក៏ដូចជាព័ត៌មានបានពីស្ថាប័ននានារបស់ *រាជរដ្ឋាភិបាល* ។ នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃ*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ទទួលបន្ទុកធ្វើការវិភាគនេះ ។ ***ទីពីរ*** គឺក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកាសម្រាប់រយៈពេលបីឆ្នាំ ដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើ និងរៀបចំដោយនាយកដ្ឋានថវិកានៃ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ។ ធាតុចូលដែលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះ គឺផ្អែកទៅលើព័ត៌មានដែលប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាង *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ជាមួយស្ថាប័ននានារបស់ *រាជរដ្ឋាភិបាល* និងព័ត៌មានស្តីពី ចំណាយនិងតម្រូវការរយៈពេលពីរឆ្នាំទៅមុខ នៃស្ថាប័នទាំងនោះ ។ ក្នុងការអនុវត្ត *កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* នឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការ ទាំងពីរ ដើម្បីកែលម្អការរៀបចំថវិកាប្រចាំឆ្នាំ ។

៣១៣. ក្នុងដំណាក់កាលនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅកម្ពុជាសព្វថ្ងៃ យើងនៅមានការងារយ៉ាងធំចំពោះមុខ ក្នុងការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលចាំបាច់ ដើម្បីសម្រេចបានគោលដៅម៉ាក្រូសេដ្ឋកិច្ចគឺ កំណើនសេដ្ឋកិច្ចខ្ពស់ ដើម្បីឈានទៅកាត់បន្ថយភាពក្រីក្រ ។ ទោះបីជាប្រហែល ៤០ភាគរយនៃចំណាយសាធារណៈសរុប ត្រូវបានប្រើប្រាស់ទៅលើចំណាយមូលធនក៏ដោយ ក៏ចំនួននេះនៅតិចតួចនៅឡើយសម្រាប់ការស្តារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលយើងកំពុងត្រូវការចាំបាច់ ដើម្បីកាត់បន្ថយភាពក្រីក្របន្ថែមទៀត ។ ការពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅ ប៉ះពាល់ដល់ជម្រើសរបស់ *រាជរដ្ឋាភិបាល* ក្នុងការបំពេញតម្រូវការជាក់ស្តែងរបស់ខ្លួន ។ *រាជរដ្ឋាភិបាល* បានប្រើប្រាស់ចំណាយមូលធន ដែលជាផ្នែកនៃថវិកាជាតិ ដើម្បីទាក់ទាញហិរញ្ញប្បទានពីខាងក្រៅប្រទេស សម្រាប់បំពេញតម្រូវការនៃចំណាយមូលធនជាអាទិភាពរបស់ខ្លួន ។

### តារាងទី១៣ : ចំណាយមូលធន និងចំណាយចរន្តសម្រាប់ឆ្នាំ ២០០៩ - ២០១៣

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **ចំណាយសរុប** (គិតជាពាន់លានរៀល) | **៧ ៥៤៨,៦** | **៨ ៤៥៥,៨** | **៩ ១៩៦,៨** | **១០ ០៣៩,៣** | **១០ ៩៣១,៦** |
| ចំណាយមូលធន (គិតជាពាន់លានរៀល) | ២ ៩៥១,៦ | ៣ ៣២៦៩ | ៣ ៥៣៤,៣ | ៣ ៨៧៦,៣ | ៤ ២៣៤,៩ |
| ចំណាយចរន្ត (គិតជាពាន់លានរៀល) | ៤ ៥៩៧,១ | ៥ ១៧២,៩ | ៥ ៦៦២,៥ | ៦ ១៦៣,០ | ៦ ៦៩៦,៨ |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

៣១៤. ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ *រាជរដ្ឋាភិបាល* កំពុងពង្រឹងភាពផ្សារភ្ជាប់គ្នា រវាងកម្មវិធីនានាដែល ***ទីមួយ*** - កំណត់ការវិនិយោគសាធារណៈអាទិភាព ដែលរួមមាន *ផយអជ* សម្រាប់រយៈពេល៥ឆ្នាំ និង*កម្មវិធីវិនិយោគសាធារណៈ* សម្រាប់រយៈពេល៣ឆ្នាំ ***ទីពីរ*** - កៀរគរធនធានពីខាងក្រៅ ទាំងពីដៃគូអភិវឌ្ឍន៍ចាស់និងថ្មី និង ***ទីបី*** - រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកា ។ *រាជរដ្ឋាភិបាល* ដឹងច្បាស់ពីតម្រូវនៃការកែលម្អ *កម្មវិធីវិនិយោគសាធារណៈ*សម្រាប់រយៈ៣ឆ្នាំ ដើម្បីធានាថា (១) តម្រូវការចំណាយចរន្តដែលពាក់ព័ន្ធដល់ការរៀបចំថវិកាប្រចាំឆ្នាំ គឺជា ផ្នែកមួយដែលមិនអាចខ្វះបាននៃព័ត៌មានដែលប្រមូលបាន នៅក្នុងការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ* (២) គម្រោងនានានៃ*កម្មវិធីវិនិយោគសាធារណៈ* ត្រូវបានចាត់ថ្នាក់តាមលំដាប់អាទិភាព ។ ការងារនេះទាមទារឱ្យស្ថាប័នរបស់ *រាជរដ្ឋាភិបាល* ធ្វើចំណាត់ថ្នាក់គម្រោងដែលស្នើសុំ ទៅតាមលំដាប់អាទិភាព សម្រាប់ការអនុវត្តក្នុងរយៈបីឆ្នាំទៅមុខ ដោយផ្អែកលើ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចទូទៅ និង ការយល់ដឹងពីលទ្ធភាពនៃការកៀរគរធនធានពីប្រភពក្រៅប្រទេស ។

៣១៥. ការពង្រឹងដំណើរការនៃការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ* គឺជាអាទិភាពមួយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ នៅពេលដែលគុណភាពនៃព័ត៌មានរបស់ *កម្មវិធីវិនិយោគសាធារណៈ* ល្អជាងមុននោះ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* នឹងធានាថា មានតែកម្មវិធីឬគម្រោងដែលស្ថិតនៅក្នុង*កម្មវិធីវិនិយោគសាធារណៈ* ប៉ុណ្ណោះ ដែលនឹងត្រូវដាក់បញ្ចូលសម្រាប់ការពិចារណាក្នុងការផ្តល់ហិរញ្ញប្បទាន នៅក្នុងអំឡុងពេលនៃការរៀបចំ*ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកា* ។ *គណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* នឹងធានាថា នឹងជំរុញការធ្វើហិរញ្ញប្បទានដល់គម្រោងនានា ដែលជាផ្នែកនៃ*កម្មវិធីវិនិយោគសាធារណៈ* នៅក្នុងការងារកៀរគរធនធានរបស់ខ្លួន និងរៀបចំដោយទៀងទាត់នូវរបាយការណ៍អំពី គម្រោងក្នុង*កម្មវិធីវិនិយោគសាធារណៈ* ក៏ដូចជា គម្រោងក្រៅ*កម្មវិធីវិនិយោគសាធារណៈ* ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ខាងក្រៅ ។

៣១៦. ជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីជំរុញតម្លាភាពនៃដំណើរការរៀបចំថវិកា *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* បានរៀបចំនូវការព្យាករណ៍ដំបូងមួយអំពីការវិភាជចំណាយចរន្ត សម្រាប់ក្រសួង-ស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់ដំណាក់កាលរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។ ការព្យាករណ៍នោះ មាននៅក្នុង *តារាងទី១៤* ។

### តារាងទី១៤ : ចំណាយថវិកាចរន្តដែលបានស្នើឡើងសម្រាប់ ក្រសួង-ស្ថាប័ននីមួយៗ ២០០៩-២០១៣

(គិតជា ពាន់លានរៀល)

| ក្រសួង/ស្ថាប័ន | ២០០៩ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ | ២០១១ ព្យាករណ៍ | ២០១២ ព្យាករណ៍ | ២០១៣ ព្យាករណ៍ |
|---|---|---|---|---|---|
| **I. រដ្ឋបាលទូទៅ** | **១ ៣៣២,៩៨៩** | **៧៩៣,០៩៨** | **៨០៦,៩៥៤** | **៨៩៥,០០៥** | **៩០២,៩៨០** |
| ០៥.១ ទីស្តីការគណៈរដ្ឋមន្ត្រី | ៣៣១,០៣៧ | ១៩០,៥៧១ | ២០៣,៦១៦ | ២១៤,៩២៣ | ២២៥,៩២៩ |
| ០៥.២ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ២,៧៣៧ | ២,៧៥១ | ២,៩៣៩ | ៣,១០២ | ៣,២៦១ |
| ០៥.៤ ក.អ.ក | ៤,៧៤៣ | ៥,៣៥៤ | ៥,៧២០ | ៦,០៣៨ | ៦,៣៤៧ |
| ០៧.២ មហាផ្ទៃ-រដ្ឋបាល | ៤៧,០៤៤ | ៥១,៤៣០ | ៥៤,៩៥០ | ៥៨,០០២ | ៦០,៩៧២ |
| ០៨. ទំនាក់ទំនងការប្រជុំនិងត្រួតពិនិត្យ | ១០,៣៣៦ | ១៤,៩៩៧ | ១៦,០២៣ | ១៦,៩១៣ | ១៧,៧៧៩ |
| ០៩. ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ៧១,៩៣១ | ៦៩,៧៧៤ | ៧៤,៥៥០ | ៧៨,៦៩០ | ៨២,៧១៩ |
| ១០. សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥៥៦,៦៦៥ | ៨៣,៦៥៣ | ៨៩,៣៧៩ | ៩៤,៣៤៣ | ៩៩,១៧៤ |
| ១៤. ផែនការ | ១៤,៨២៩ | ២២,៧៩៤ | ២៤,៣៥៤ | ២៥,៧០៧ | ២៧,០២៣ |
| ២៦. យុត្តិធម៌ | ២២,៨២៦ | ៣៤,៩៧៨ | ៣៩,៦៧៩ | ៤៥,១១៩ | ៥១,២២៣ |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ១០,៥៧២ | ៨,៧០៧ | ៩,៣០៣ | ៩,៨២០ | ១០,៣២៣ |
| ៣១. អជ្ញាធរ សវនកម្មជាតិ | ៥,៥០៣ | ៦,៣៩២ | ៦,៨២៩ | ៧,២០៩ | ៧,៥៧៨ |
| ៣២. បណ្ឌុះបណ្ដាលវិជ្ជាជីវៈ | ៧៣,៣១២ | ៥៨,៧៤៦ | ៦២,៧៦៧ | ៦៦,២៥៣ | ៦៩,៦៤៥ |
| **II. ការពារ និងសន្តិសុខ** | **១ ២៥៤,០៤១** | **១ ១៥០,៥២២** | **១ ២២៩,២៧៦** | **១ ២៩៧,៥៤៣** | **១ ៣៦៣,៩៨៤** |

| ក្រសួង/ស្ថាប័ន | ២០០៩ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ | ២០១១ ព្យាករណ៍ | ២០១២ ព្យាករណ៍ | ២០១៣ ព្យាករណ៍ |
|---|---|---|---|---|---|
| ០៦. ការពារជាតិ | ៨៣៧,០៤៥ | ៧០២,៤៧២ | ៧៥០,៥៥៧ | ៧៩២,២៣៨ | ៨៣២,៨០៥ |
| ០៧.១ មហាផ្ទៃ-សន្តិសុខ | ៤១៦,៩៩៦ | ៤៤៨,០៥០ | ៤៧៨,៧១៩ | ៥០៥,៣០៤ | ៥៣១,១៧៩ |
| **III. រដ្ឋបាលសង្គម** | **១ ៥០៥,៨៤៥** | **១ ៧៧០,៦១៩** | **១ ៩៨៧,៦២៣** | **២ ២៣២,៤៥៤** | **២ ៥០៤,៣៤២** |
| ១១. ពតិមាន | ៣៩,៣២៦ | ៤០,៩១២ | ៤៣,៧១២ | ៤៦,១៤០ | ៤៨,៥០៣ |
| ១២. សុខភាពសាធារណៈ | ៥០៥,២០៥ | ៦០០,០៥៦ | ៦៨០,៦៩៩ | ៧៧៤,០៣២ | ៨៧៨,៧៤៩ |
| ១៦. អប់រំ យុវជន និងកីឡា | ៦៨៩,៧២៣ | ៨២៤,៨៧៩ | ៩៣៥,៧៣៧ | ១ ០៦៤,០៣៩ | ១ ២០៧,៩៨៩ |
| ១៨. វប្បធម៌ និងសិល្បៈ | ២៣,៦២២ | ២៦,៤៣៦ | ២៨,២៤៦ | ២៩,៨១៥ | ៣១,៣៤១ |
| ១៩. បរិស្ថាន | ១៧,០៥៤ | ១៩,៥៦២ | ២០,៩០១ | ២២,០៦២ | ២៣,១៩១ |
| ២១. សង្គមកិច្ច ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៩៥,៨៨២ | ២១៥,៦៧១ | ២៣០,៤៣៤ | ២៤៣,២៣១ | ២៥៥,៦៨៥ |
| ២៣. កិច្ចការ សាធារណៈ និងសាសនា | ១១,៦៨៦ | ១៥,១៩៤ | ១៦,២៣៤ | ១៧,១៣៦ | ១៨,០១៣ |
| ២៤. កិច្ចការនារី និងអតីតយុទ្ធជន | ២៣,៣៤៧ | ២៧,៩០៨ | ៣១,៦៥៩ | ៣៦,០០០ | ៤០,៨៧០ |
| **IV. រដ្ឋបាលសេដ្ឋកិច្ច** | **៣៣២,៦៦៣** | **៤១៩,១១២** | **៤៦០,៨២៥** | **៥០៤,៦៩៦** | **៥៥១,៩៦១** |
| ០៥.៣ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ១១,១០៩ | ១២,២២៩ | ១៣,០៦៦ | ១៣,៧៩២ | ១៤,៤៩៨ |
| ១៣. ឧស្សាហកម្ម រ៉ែ និងថាមពល | ១៤,១៧១ | ១៧,៤១៣ | ១៨,៦០៥ | ១៩,៦៣៩ | ២០,៦៤៤ |
| ១៥. ពាណិជ្ជកម្ម | ៣៣,៩៨៩ | ៥២,៨៦៧ | ៥៦,៤៨៦ | ៥៩,៦២៣ | ៦២,៦៧៦ |
| ១៧. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧៨,១៩២ | ៨៧,៤៨៥ | ៩៩,២៤២ | ១១២,៨៥០ | ១២៨,១១៧ |
| ២០. អភិវឌ្ឍន៍ជនបទ | ៥៤,៩៩៦ | ៨៣,១៥៦ | ៩៤,៣៣២ | ១០៧,២៦៦ | ១២១,៧៧៧ |
| ២២. ប្រៃសណីយ៍-ទូរគមនាគមន៍ | ៣៦,៥៦៩ | ៣៩,៨២១ | ៤២,៥៤៧ | ៤៤,៩១០ | ៤៧,២១០ |
| ២៥. សាធារណៈការ និងដឹកជញ្ជូន | ២៩,២២៧ | ៣២,១៣៩ | ៣៤,៣៣៩ | ៣៦,២៤៦ | ៣៨,១០២ |
| ២៧. ទេសចរណ៍ | ២៧,២២៦ | ៣០,៣៣០ | ៣២,៤០៦ | ៣៤,២០៦ | ៣៥,៩៥៧ |
| ២៨. នគរូបនីយកម្ម និងសំណង់ | ២១,៥៥៥ | ២៦,៨៧៦ | ៣០,៤៨៨ | ៣៤,៦៦៨ | ៣៩,៣៥៨ |
| ២៩. ធនធានទឹក និងឧតុនិយម | ២៦,០២៩ | ៣៦,៧៩៥ | ៣៩,៣១៤ | ៤១,៤៩៧ | ៤៣,៦២២ |
| **V. ចំណាយសម្រាប់រាជធានី ខេត្ត ក្រុង និងផ្សេងៗ** | **១៧១,៩២៧** | **១ ០៧៩,៥២៣** | **១ ១៧៧,៨០៣** | **១ ២៧៣,២៦៦** | **១ ៣៧៣,៨៩៧** |
| **សរុប** | **៤ ៩៩៧,០៦៥** | **៥ ១៧២,៩០៤** | **៥ ៦៦២,៤៨៣** | **៦ ១៦២,៩៦៤** | **៦ ៦៩៦,៧៦៤** |

***ប្រភព*** : *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

# ជំពូកទី៤

## គោលនយោបាយ និងសកម្មភាព អាទិភាព : ២០០៩-២០១៣

៣១៧. ទិសដៅរួមរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺកសាងជាជំហានៗ នូវសង្គមកម្ពុជាមួយ ដែលរឹងមាំ មានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារភ្ជាប់គ្នា នឹងត្រូវបានពង្រឹងដើម្បីធានាថា ប្រជាជនកម្ពុជា មានចំណេះដឹងខ្ពស់ និងមានវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និង មានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងក្នុងសង្គមជាតិ ។

៣១៨. *រាជរដ្ឋាភិបាលកម្ពុជា* បានប្តេជ្ញាចិត្ត ដើម្បីសម្រេចឱ្យបាន នូវបណ្តាគោលដៅអាទិភាពរបស់ខ្លួន នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា ដោយធានានូវ :

- ចីរភាព សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដើម្បីលើកកម្ពស់វិធានការណ៍ច្បាប់ ការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។
- ចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង ក្នុងអត្រា ៧ ភាគរយ ក្នុងមួយឆ្នាំ ដោយផ្អែកលើមូលដ្ឋានទូលំទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាទាប ក្នុងកម្រិតតួលេខមួយខ្ទង់ ។
- ការកាត់បន្ថយភាពក្រីក្រឱ្យបានលើសពី ១ភាគរយ ក្នុងមួយឆ្នាំ និងការធ្វើឱ្យប្រសើរឡើងនូវ សូចនាករសង្គមកិច្ចសំខាន់ៗ ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ ។
- បង្កើន ប្រសិទ្ធភាព គុណភាព ភាពជឿជាក់ចំពោះ ការផ្តល់សេវាកម្មសាធារណៈនានា ។

៣១៩. បញ្ហាប្រឈមដ៏ចម្បងរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺ ការកាត់បន្ថយភាពក្រីក្រ និង ការលើកកម្ពស់កម្រិតជីវភាពរស់នៅនិងគុណភាពជីវិត របស់ប្រជាជន ដែលមានកំណើនយ៉ាងឆាប់រហ័ស ។ *រាជរដ្ឋាភិបាលកម្ពុជា* ចាត់ទុកថា ភាពក្រីក្រគឺជាការខ្វះខាតនៃតម្លៃធនធានសេដ្ឋកិច្ច ដែលមិនត្រឹមតែមិនអាចទទួលយកបានខាងផ្នែកផ្លូវចិត្តប៉ុណ្ណោះទេ ប៉ុន្តែ អាចបណ្តាលឱ្យមានការបែកខ្ញែក និងអស្ថិរភាព នៅក្នុងសង្គម ។ កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ សម្រេចបានលទ្ធផល គួរឱ្យកត់សម្គាល់ ចាប់តាំងពីខែមីនា ឆ្នាំ២០០៣ មក នៅពេលដែល*រាជរដ្ឋាភិបាលកម្ពុជា* បានផ្សព្វផ្សាយ *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* ។ ដូចបានពណ៌នារួចមកហើយ នៅក្នុងជំពូកទី២ លទ្ធផលថ្មីៗនៃ*អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៧* បង្ហាញថា អត្រានៃភាពក្រីក្រនៅទូទាំង

ប្រទេសបានថយចុះពី ៣៤,៧ភាគរយ ក្នុងឆ្នាំ២០០៤ មកត្រឹម ៣០,១ភាគរយ នៅក្នុងឆ្នាំ២០០៧ (គួរកត់សម្គាល់ថា ការថយចុះ ៤,៧ភាគរយនេះ បង្ហាញពីការកាត់បន្ថយភាពក្រីក្រ បានជាង ១ភាគរយ ក្នុងមួយឆ្នាំ) ។ លទ្ធផលនៃការអង្កេត ក៏បានបង្ហាញ ផងដែរថា កម្រិតនៃភាពក្រីក្របានធ្លាក់ចុះនៅគ្រប់កម្រិតនៃថ្នាក់ក្រោមជាតិទាំងអស់ : នៅភ្នំពេញ បានធ្លាក់ចុះពី ៤,៦ភាគរយ ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ០,៨ភាគរយ នៅឆ្នាំ២០០៧ នៅតំបន់ទីប្រជុំជន កម្រិតភាពក្រីក្រ បាន ធ្លាក់ចុះពី ២៥,៨ភាគរយ នៅឆ្នាំ២០០៤ មកត្រឹម ២១,៩ភាគរយ នៅឆ្នាំ២០០៧ ហើយ នៅតំបន់ជនបទ កម្រិតនៃភាពក្រីក្របានធ្លាក់ចុះពី ៣៩,១ភាគរយ នៅឆ្នាំ២០០៤ មកត្រឹម ៣៤,៧ភាគរយ នៅឆ្នាំ២០០៧ ។ ការធ្លាក់ចុះនៃ ភាពក្រីក្រ ក្នុងអំឡុងពេលពី ឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៧ បានឆ្លុះបញ្ចាំងឱ្យឃើញ ពីកំណើនគួរឱ្យកត់សម្គាល់ផ្នែកស្ថិតិ នៃការប្រើប្រាស់របស់គ្រួសារនីមួយៗ (ការវាស់វែងពីកម្រិតជីវភាពរស់នៅដែលគេនិយមប្រើប្រាស់) ។ ការកើនឡើងនៃការប្រើប្រាស់នេះ ត្រូវបានរកឃើញថា បានកើតមានឡើងគួរឱ្យកត់សម្គាល់ ទាំងក្នុងភាពជាក់ស្តែង ទាំងតាមតួលេខស្ថិតិ នៅក្នុងចំណោមប្រជាជន ក្នុងបញ្ចភាគពីរដែលក្រីក្រជាងគេ ។ តាមភាពជាក់ស្តែង ក្នុងចំណោមប្រជាជនដែលស្ថិតនៅក្នុងបញ្ចភាគក្រីក្រជាងគេ ការប្រើប្រាស់បានកើនឡើង ១០,៧ភាគរយ ហើយ ការប្រើប្រាស់នៅក្នុងបញ្ចភាគ បន្ទាប់ពីបញ្ចភាគក្រីក្រជាងគេ បានកើនឡើង ១១,៥ភាគរយ ។

៣២០. បច្ចុប្បន្ននេះ ការថែរក្សានូវសមិទ្ធផលដែលសម្រេចបានដោយលំបាកកន្លងមក និងការធ្វើឱ្យស្ថិតនៅក្នុងគន្លងផ្លូវ ដើម្បីធានាឱ្យទទួលបាននូវលទ្ធផលពីការកាត់បន្ថយភាពក្រីក្រនៅពេលអនាគត កំពុងជួបប្រទះនូវបញ្ហាបន្ថែមទៀត ដោយសារវិបត្តិហិរញ្ញវត្ថុសាកលលោក និងវិបត្តិសេដ្ឋកិច្ចនានា ដែលកំពុងកើតមាននៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជឿនលឿន ។ ទោះបីជា មិនបានដឹងជាមុន នូវវិបត្តិដែលកើតឡើងភ្លាមៗ តាមរយៈ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្រៅប្រទេសក៏ដោយ ក៏*រាជរដ្ឋាភិបាលកម្ពុជា* បានឆ្លើយតបយ៉ាងឆាប់រហ័ស នូវយន្តការឆ្លើយតបមួយ ។ យន្តការឆ្លើយតបនេះ បានអនុម័តនូវវិធីសាស្ត្រមុខពីរ ដែលផ្តោតលើ សកម្មភាពរយៈពេលវែង និងខ្លី ។ សកម្មភាពរយៈពេលខ្លី ផ្តោតលើការអនុវត្តវិធានការសារពើពន្ធ សម្រាប់លើកទឹកចិត្តដល់ផលិតករនិងអ្នកប្រើប្រាស់នានា ដើម្បីធ្វើឱ្យសេដ្ឋកិច្ចដែលមិនសូវមានសកម្មភាព រស់រានឡើងវិញ និងដើម្បីអនុវត្តទៅតាមគោលនយោបាយហិរញ្ញវត្ថុដែលបានឆ្លើយតបជាបន្ទាន់ទៅនឹងលក្ខខណ្ឌនានាដែលផ្លាស់ប្តូរ ។ ចំពោះវិធានការរយៈពេលវែង អាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺការបន្តដោះស្រាយបញ្ហារយៈពេលវែង តាមរយៈ ការប្រកួតប្រជែងដែលបានធ្វើឱ្យប្រសើរឡើង ។ ដើម្បីកសាងនូវមូលដ្ឋានមួយ សម្រាប់ទប់ទល់នឹងវិបត្តិនានា ដែលកំពុងកើតមាននៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជឿនលឿន និងធ្វើឱ្យមានស្ថិរភាពកំណើនសេដ្ឋកិច្ច *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងរិះរកវិធីសាស្ត្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែង ក្នុងវេទិកាតំបន់និងអន្តរជាតិ និងសកម្មភាពសម្រាប់ស្វែងរកឱកាស ដើម្បីពង្រីកនិងធ្វើឱ្យមានភាពឆ្លាស់គ្នានៃមូលដ្ឋានសេដ្ឋកិច្ច ។

## ប្រអប់ទី៧

## គោលនយោបាយអាទិភាពខ្ពស់បំផុត របស់*រាជរដ្ឋាភិបាលកម្ពុជា* គឺការបន្តកាត់បន្ថយភាពក្រីក្រ អាទិភាពសម្រាប់ ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃ វិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក មកលើកម្ពុជា

១. ដើម្បីកាត់បន្ថយផលប៉ះពាល់ នៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក *រាជរដ្ឋាភិបាលកម្ពុជា* កំពុងអនុវត្តកញ្ចប់បង្កើនសារពើពន្ធ ឱ្យបានទូលំទូលាយ និងការផ្តោតដោយប្រុងប្រយ័ត្នជាងមុន លើការគាំទ្រកម្ម វិធីប្រព័ន្ធសុវត្ថិភាពសង្គម ដែលត្រូវបានផ្តល់ដោយក្រសួង-ស្ថាប័ន សំដៅជួយបន្ថយនូវផលប៉ះពាល់អវិជ្ជមានណាមួយនៃវិបត្តិនេះ មកលើក្រុមជនងាយរងគ្រោះ និងប្រជាជនក្រីក្រ ។ ចំពោះគោលនយោបាយ រូបិយវត្ថុវិញ ធនាគារជាតិនៃកម្ពុជា បានឆ្លើយតបនឹងវិបត្តិយ៉ាងឆាប់រហ័ស តាមរយៈ ការអនុម័តនូវការបន្ធូរបន្ថយ និងសម្របសម្រួលគោលនយោបាយរូបិយវត្ថុ និងតាមរយៈ ការអនុវត្តវិធានការ ដែលគ្របដណ្តប់លើការគាំទ្រ និងពង្រឹងប្រព័ន្ធស្ថាប័ន ធនាគារ និង ប្រព័ន្ធហិរញ្ញវត្ថុ ។

២. *រាជរដ្ឋាភិបាល* នឹងបន្តពង្រឹងកិច្ចសម្របសម្រួល និងពង្រីកវិសាលភាពនៃកម្មវិធីប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុវត្ថិភាពសង្គម រួមមាន ការការពារឱ្យបាននូវសមិទ្ធផល ដែលរាជរដ្ឋាភិបាលពុះពារសម្រេចបានក្នុងរយៈពេលកន្លងមក ការឈរលើមាគ៌ាមួយ ដើម្បីធានាបានសមិទ្ធផល សម្រាប់ពេលអនាគតក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនទាំងមូល និងការលើកកម្ពស់សមធម៌ និងកំណើនសេដ្ឋកិច្ចដោយចីរភាព ដែលជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវបានផ្តល់ភារកិច្ច ដើម្បីរៀបចំបង្កើតយុទ្ធសាស្ត្រ ប្រព័ន្ធគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ឱ្យកាន់តែមានលក្ខណៈចម្រុះនិងស៊ីជម្រៅ ដោយសង្កត់ធ្ងន់លើប្រព័ន្ធសុវត្ថិភាពសង្គម និងដើម្បីធានាឱ្យមានប្រសិទ្ធភាព ក្នុងយន្តការសម្របសម្រួលអន្តរក្រសួង ដោយមានការចូលរួមពី ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ ដែលមានភារកិច្ចអនុវត្ត កម្មវិធីប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់ជួយដល់ជនក្រីក្រ និងងាយរងគ្រោះ ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក៏មានភារកិច្ចដើម្បីរៀបចំយុទ្ធសាស្ត្រនានា ដែលឈរលើលក្ខណៈទូលំទូលាយ ដោយមានការគ្របដណ្តប់លើវិស័យទាំងអស់ ប្រជាជននៅតំបន់ជនបទ គឺជាប្រពៃណីមួយដ៏យូរលង់ នៅកម្ពុជា ។ ពេលនេះ កិច្ចខិតខំប្រឹងប្រែងជាលក្ខណៈឯកជនបែបនេះ គួរតែត្រូវបានពង្រីកបន្ថែមទៀត ឱ្យដល់តំបន់ដាច់ស្រយាលដែលមិនទាន់មានការជួយឧបត្ថម្ភគាំទ្រ ហើយ មានភាពក្រីក្រខ្ពស់ ។

៤. ដើម្បីធ្វើឱ្យមានការងើបឡើងវិញ ទប់ទល់នឹងវិបត្តិសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសជឿនលឿន និង ដើម្បីធ្វើឱ្យមានស្ថិរភាពកំណើនសេដ្ឋកិច្ច *រាជរដ្ឋាភិបាលកម្ពុជា* នឹងស្វែងរកវិធីសាស្ត្រនានា ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង នៅក្នុងសេដ្ឋកិច្ចតំបន់និងអន្តរជាតិ ក៏ដូចជា ស្វែងរកកាលានុវត្តភាព ក្នុងការធ្វើពិពិធភាវូបនីយកម្ម និងការពង្រីកមូលដ្ឋានសេដ្ឋកិច្ច ។

៥. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងទីផ្សារក្នុងតំបន់ ដែលមានការប្រែប្រួលជាប់ជានិច្ច ។

៦. ដើម្បីពង្រឹងការងារ សម្រាប់ការអភិវឌ្ឍដំណាក់កាលបន្ទាប់ *រាជរដ្ឋាភិបាលកម្ពុជា* នឹងអនុវត្តគោលនយោបាយធនធានមនុស្សមួយ ដែលលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការពង្រីកសេវាកម្មអប់រំដែលត្រូវការចាំបាច់ ហើយនឹងធានាថា សិស្ស-និស្សិតទាំងឡាយ ដែលសិក្សានៅសាលាមធ្យមសិក្សា និងសាកលវិទ្យាល័យ នឹងត្រូវបានបណ្តុះបណ្តាល ដើម្បីបំពេញតម្រូវការរបស់សេដ្ឋកិច្ច ដែលមានការប្រែប្រួល ។

៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងអនុវត្តយ៉ាងខ្លាំងក្លានូវ យុទ្ធសាស្ត្រមួយដើម្បីធានានូវ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដែលមានមូលដ្ឋានទូលំទូលាយ សំដៅ បង្កើតការងារថ្មីៗ និងបង្កើនចំណូល ដើម្បីលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍ជនបទ និង ដើម្បីឱ្យពួកគាត់អាចរួម ចំណែកច្រើនថែមទៀត នៅក្នុងសេដ្ឋកិច្ចជាតិ ។

៨. *រាជរដ្ឋាភិបាលកម្ពុជា* នឹងធ្វើការងារជាមួយដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីធានាថា ធនធានជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ ត្រូវបានផ្ទេរច្រើនជាងមុន

នៃការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចជនបទ និងដើម្បីសម្របសម្រួល តាមដាននិងវាយតម្លៃការអនុវត្តនូវយុទ្ធសាស្ត្រខាងលើនេះ ក្នុងន័យកិច្ចការសម្របសម្រួល និងពេលវេលាច្បាស់លាស់ លើការអនុវត្តនៃស្ថាប័នរបស់រាជរដ្ឋាភិបាល សំដៅសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចជនបទប្រកបដោយ ចីរភាព ។

៣. ក្នុងរយៈពេលខ្លី *រាជរដ្ឋាភិបាលកម្ពុជា* លើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមាន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋទូទៅ ដែលអាចជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់សហគមន៍នានា ដែលរងផលប៉ះពាល់អវិជ្ជមានពីវិបត្តិនាពេលបច្ចុប្បន្ន ។ ការចូលរួមចំណែករបស់ឥស្សរជនក្នុងផ្នែកសាធារណៈនិងឯកជន ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ទៅដល់ ប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះ នៅសហគមន៍ជនបទ ជាពិសេស សហគមន៍ជនបទដាច់ស្រយាល ។ ពិសេសជាងនេះទៀត ការកើនឡើងគួរឱ្យកត់សម្គាល់នៃសមាមាត្រជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលត្រូវបាន ធ្វើវិភាជន៍ និងផ្តល់ដល់ប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះ តាមរយៈ វិធីសាស្ត្រនៃការកម្មវិធីផ្តល់នានា ដែលផ្តោតលើ ការចូលរួមយ៉ាងសកម្មរបស់ប្រជាជនក្រីក្រ ក្នុងការប្រើប្រាស់ធនធានទាំងនោះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅ និងការចូលរួមរបស់ពួកគាត់នៅក្នុងសេដ្ឋកិច្ចជាតិ ។

៣២១. ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ លក្ខខណ្ឌសំខាន់ៗមួយចំនួន សម្រាប់រក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ត្រូវបានធ្វើឱ្យសម្រេច ។ ផលប្រយោជន៍ ដែលទទួលបានពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានបង្ហាញឱ្យឃើញ ។ កំណើនក្នុងវិស័យកាត់ដេរ បង្ហាញថា ការលើកកម្ពស់ការរៀបចំអភិបាលកិច្ច អាចបណ្តាលឱ្យមានកំណើនសេដ្ឋកិច្ច ។ សារសំខាន់នៃភាគីទី៣ ដែលដើរតួជាអ្នកតាមដានត្រួតពិនិត្យឯករាជ្យ ក្នុងករណីនៃវិស័យកាត់នេះ ក៏ត្រូវបានបង្ហាញ ផងដែរ ។ ប្រសិទ្ធភាពនៃភាពជាដៃគូ រវាង *រាជរដ្ឋាភិបាលកម្ពុជា* និងវិស័យឯកជន *(វេទិការាជរដ្ឋាភិបាលកម្ពុជានិងវិស័យឯកជន)* ត្រូវបានសិក្សាពិនិត្យមើល ហើយផលប្រយោជន៍នៃការអនុវត្ត *គោលនយោបាយឧស្សាហកម្ម* ក៏ត្រូវបានបង្ហាញ ផងដែរ ។

៣២២. ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ *ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ* បានធ្វើការសិក្សាស្រាវជ្រាវ មួយចំនួន ដើម្បីពិនិត្យមើលលើ (១) ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក មកលើសេដ្ឋកិច្ចកម្ពុជា (២) ការរិះរកវិធីសាស្ត្រដើម្បីជំរុញការប្រកួតប្រជែង នៃការនាំចេញផលិតផលកម្ពុជា ទៅក្នុងទីផ្សារក្នុងតំបន់ និងទីផ្សារអន្តរជាតិ (៣) ការពិនិត្យមើលពីមធ្យោបាយនានា ដើម្បីពង្រីកឱ្យបានទូលំទូលាយ និងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ដើម្បីធ្វើឱ្យសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចខ្ពស់ និងវឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្រ ក្នុងទសវត្សរ៍ចុងក្រោយនេះ ។ លទ្ធផលនៃការសិក្សានេះ គូសបញ្ជាក់ពី ជម្រើសមួយចំនួន ដែលតម្រូវឱ្យមានសកម្មភាពសម្របសម្រួលច្បាស់លាស់ ហើយដែលត្រូវអនុវត្តដោយស្ថាប័ននានារបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ជាមួយនឹងក្របខ័ណ្ឌអាទិភាពនានារបស់*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ដែលបានបង្ហាញក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ស្ថាប័នរាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ ដល់ការរៀបចំ និងការអនុវត្ត កម្មវិធី និងសកម្មភាពនានា ដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ ។

៣២៣. ការរក្សាឱ្យបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងការធានានូវការទទួលបានកាត់បន្ថយភាពក្រីក្រ នៅពេលអនាគត គឺជាអាទិភាពខ្ពស់ សម្រាប់គ្រប់ស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ដើម្បីបន្តធ្វើឱ្យមានវឌ្ឍនភាព នៅក្នុងស្ថានភាពសេដ្ឋកិច្ចរបស់ពិភពលោកនាពេលបច្ចុប្បន្ននេះ ទាមទារឱ្យមានសកម្មភាពសម្របសម្រួលនានា ដែលធ្វើឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់*រាជរដ្ឋាភិបាលកម្ពុជា* ដូចបានបញ្ជាក់*ដោយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា* នៅក្នុងពិធីបើកសន្និសីទស្តីពី ទស្សនវិស័យសម្រាប់កម្ពុជា លើប្រធានបទស្តីពី *"កម្ពុជា និងវិបត្តិសេដ្ឋកិច្ចពិភពលោក : ផលប៉ះពាល់ គោលនយោបាយ ឆ្លើយតប និងវិធានការ"* ។ **សម្តេចនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់ថា *"បញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមាន មិនត្រឹមតែកិច្ចសហប្រតិបត្តិការ និងជវភាពថែមទៀត រវាងរាជរដ្ឋាបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ប៉ុណ្ណោះទេ លើសពីនេះទៀត ថែមទាំង តម្រូវឱ្យមានការសម្របសម្រួលសហការនៅក្នុងចង្កោមស្ថាប័ន ក្រសួង មន្ទីរ របស់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អភិវឌ្ឍន៍ ។ នៅក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម និងអភិវឌ្ឍន៍ជនបទ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងធារាសាស្ត្រ និង ការគ្រប់គ្រងធនធានទឹក ព្រមទាំង ការសម្រួលពាណិជ្ជកម្ម ។ ខ្ញុំសូមឱ្យក្រសួងមន្ទីរ ពាក់ព័ន្ធទាំងអស់ ជាពិសេស ថ្នាក់ដឹកនាំក្រសួង ត្រូវធ្វើការជាមួយគ្នា និងសហការគ្នាឱ្យកាន់តែជិតស្និទ្ធថែមទៀត ដើម្បីធានាថា កម្មវិធីអភិវឌ្ឍន៍ ត្រូវបានរៀបចំឡើងនិងអនុវត្ត ដោយឆាប់រហ័ស និងមានប្រសិទ្ធភាព ។ ការធ្វើបែបនេះ ធនធានហិរញ្ញប្បទានដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍របស់យើង នឹងត្រូវបានផ្តល់ឱ្យកាន់តែលឿន សម្រាប់ការអភិវឌ្ឍគម្រោងការរបស់ខ្លួន ។ ការងារទាំងនេះ មិនមែនងាយស្រួលអនុវត្តទេ ប៉ុន្តែដោយសារវិបត្តិនេះ តម្រូវឱ្យយើងទាំងអស់គ្នាត្រូវធ្វើការរួមគ្នាកាន់តែច្រើនថែមទៀត ដើម្បីដោះស្រាយបញ្ហាប្រឈម ។*

៣២៤. ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រមួយ ដើម្បីធានាថា ការអភិវឌ្ឍសេដ្ឋកិច្ចនៅជនបទមានមូលដ្ឋានទូលំទូលាយសម្រាប់ បង្កើតការងារថ្មីនិងបង្កើនប្រាក់ចំណូល សំដៅលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍ជនបទ និងធ្វើឱ្យពួកគេអាចចូលរួមចំណែកកាន់តែច្រើនថែមទៀតក្នុងសេដ្ឋកិច្ចជាតិ ទាមទារឱ្យមានការសម្របសម្រួលនៅក្នុងការរៀបចំផែនការ និងការអនុវត្តកម្មវិធីដោយស្ថាប័នមួយចំនួនរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ការអភិវឌ្ឍដែលមានមូលដ្ឋានទូលំទូលាយនេះ នឹងផ្តោតលើ ការបង្កើនផលិតភាពនិងពិពិធកម្មវិស័យកសិកម្ម ការអភិវឌ្ឍកសិ-ឧស្សាហកម្ម ការស្តារឡើងវិញនិងការកសាងបណ្តាញផ្លូវជនបទ ដើម្បីធានាថា ផលិតផលរបស់សហគមន៍ជនបទ មានលទ្ធភាពចូលដល់ទៅដល់ទីផ្សារក្នុងស្រុកនិងក្នុងតំបន់ ព្រមទាំង ផ្តោតលើការពង្រីកការអប់រំ ការបណ្តុះបណ្តាលបច្ចេកទេសនិងមុខវិជ្ជាជីវៈ និងសេវាសុខភាពនៅក្នុងតំបន់ជនបទ ។ *ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ* បានទទួលភារកិច្ច ពី*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៅជនបទ ហើយដើម្បី សម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រ

និងគោលនយោបាយនានា ដោយក្រសួង-ស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ អាទិភាពខ្ពស់របស់ *ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ* គឺ ការដាក់ឱ្យអនុវត្តនូវ យន្តការសម្របសម្រួលអន្តរក្រសួងនានាដែលមានប្រសិទ្ធភាព ដោយធានាថា កម្មវិធីនិងគម្រោងអភិវឌ្ឍន៍នានា ត្រូវបានអនុវត្តដោយក្រសួង-ស្ថាប័នទាំងឡាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងក្របខ័ណ្ឌនៃការងារសម្របសម្រួល និងតាមបែបផែនមួយដែលមានលក្ខណៈលំដាប់លំដោយជាយុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចជនបទប្រកបដោយចីរភាព ។ ដើម្បីកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋក្រីក្រ នៅក្នុងបរិការណ៍នៃវិបត្តិបច្ចុប្បន្ន *រាជរដ្ឋាភិបាលកម្ពុជា* នឹងប្រឹងប្រែងឱ្យខ្លាំងក្លាបន្ថែមទៀត ដើម្បីធ្វើឱ្យប្រជាពលរដ្ឋក្រីក្រ មានលទ្ធភាពកាន់តែប្រសើរឡើងទាំងផ្នែករូបវន្ត និងសេដ្ឋកិច្ច ក្នុងការទទួលបានស្បៀងអាហារ ដែលមានសុវត្ថិភាពនិងមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ តាមរយៈការធ្វើវិនិយោគចម្រុះវិស័យនិងចំគោលដៅ ដូចមានចែងនៅក្នុង *ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភឆ្នាំ២០០៨-២០១២* ដែលរៀបចំដោយ *ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ* ។

៣២៥. ការបន្តពង្រឹងនូវការសម្រួលពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងទីផ្សារតំបន់ជាពិសេស នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ *អាស៊ាន មហាអនុតំបន់ទន្លេមេគង្គ* និង *តំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម* តម្រូវឱ្យស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* សម្របសម្រួលឱ្យកាន់តែជិតស្និទ្ធថែមទៀតនូវយុទ្ធសាស្ត្រនិងកម្មវិធីអភិវឌ្ឍន៍នានារបស់ខ្លួន សម្រាប់វិស័យមួយចំនួន ដូចជា ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវថ្នល់ ផ្លូវ រថភ្លើង កំពង់ផែ និងព្រលានយន្តហោះ) ការអភិវឌ្ឍវិស័យឯកជន (ជាពិសេស ការរៀបចំផែនការនិងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស) ការសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យឧស្សាហកម្ម (ជាពិសេស ការបង្កើតលក្ខខណ្ឌចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យមិនរៀបរយ ទៅក្នុង សេដ្ឋកិច្ចរៀបរយ) ។

៣២៦. ការពង្រឹងសមត្ថភាពរបស់ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់សេវាកម្មរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងដើម្បីជំរុញ វប្បធម៌មិតម្ករភាព និងគណនេយ្យភាព គឺជា ការងារបន្ទាន់ចំពោះមុខ ។ អាទិភាពខ្ពស់របស់ *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ* គឺ ការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពយ៉ាងទូលំទូលាយមួយ ដែលគ្របដណ្តប់លើគ្រប់ស្ថាប័នសាធារណៈទាំងអស់ ដោយមានកិច្ចសហការជាមួយស្ថាប័នសាធារណៈទាំងនោះ ។ ដើម្បីដោះស្រាយនឹងសំនួរដែលសួរថា *"តើយើងកសាងសមត្ថភាពដើម្បីអ្វី?"* នោះ *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ* នឹងត្រួតពិនិត្យបញ្ហានានាដែលទាក់ទងនឹង : (១) មុខងាររបស់ស្ថាប័ននីមួយៗ និងការកំណត់អំពីការត្រួតស៊ីគ្នាដែលអាចមានរវាងមុខងាររបស់ស្ថាប័នទាំងឡាយ និង (២) ការរៀបចំមុខងាររបស់ស្ថាប័ននីមួយៗក្នុងការអនុវត្តតួនាទីភារកិច្ច និង ការកម្រិតចំនួនបុគ្គលិកនិងជំនាញអប្បបរមា ដែលត្រូវចាំបាច់ក្នុងការអនុវត្តតួនាទីភារកិច្ច ។

៣២៧. ការពង្រឹងសមត្ថភាព*រាជរដ្ឋាភិបាល* ដើម្បីកំណត់ពីទំនាក់ទំនងនៃបម្រែបម្រួលអាកាសធាតុ ការបង្កើតយុទ្ធសាស្ត្រ ដើម្បីដោះស្រាយជាមួយនឹងឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុដែលបានស្មានទុក និងការពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ ។

៣២៨. ទន្ទឹមនឹងនេះ ការងារដែលត្រូវយកចិត្តទុកដាក់ដោះស្រាយចំពោះមុខ ផងដែរនោះ រួមមាន :

- ការធានាឱ្យមានការផ្ទេរសុទ្ធសាធកាន់តែច្រើនឡើង នូវធានធានសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលផ្តោតលើក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រនៅសហគមន៍ជនបទ ជាពិសេស សហគមន៍ជនបទដាច់ស្រយាល ។
- ការបង្កើនឱ្យបានច្រើន នូវសមាមាត្រនៃធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលបានធ្វើវិភាជ និងផ្តល់ដល់ក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ តាមរយៈ វិធីសាស្ត្រនៃការផ្តល់កម្មវិធី ដែលផ្អែកលើ ការចូលរួមយ៉ាងសកម្មនៃប្រជាជនក្រីក្រក្នុងការប្រើប្រាស់នូវធនធានទាំងនេះ ដើម្បី លើកកម្ពស់ជីវភាពរស់នៅ និងបង្កើនប្រាក់ចំណូល របស់ប្រជាជន និង ការរួមចំណែករបស់ពួកគាត់ទៅក្នុងសេដ្ឋកិច្ចជាតិ ។
- ការពង្រឹងការសម្របសម្រួល រវាង ស្ថាប័នកណ្តាល ៤ គឺ *ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* និង *ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ* ក្នុង ការរៀបចំផែនការ ការរៀបចំផែនការថវិកា និង ការវិភាជធនធាន ដែលមានពីគ្រប់ប្រភពទាំងអស់សម្រាប់ការអភិវឌ្ឍ ។

៣២៩. *"យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២"* គឺជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍របស់*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ដែល រក្សានូវរចនាសម្ព័ន្ធនៃ*"យុទ្ធសាស្ត្រចតុកោណ"* ផ្តល់នូវការកែលម្អបន្តិចបន្តួច និងផ្តល់នូវគោលនយោបាយអាទិភាពដែលមានភាពច្បាស់លាស់ ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌនាពេលបច្ចុប្បន្ន ។ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចនានារបស់*រាជរដ្ឋាភិបាលកម្ពុជា "យុទ្ធសាស្ត្រចតុកោណ"* បានដាក់ចេញនូវគោលដៅ ៤យ៉ាង ដែលស្តែងចេញតាមរយៈបាវចនា *កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* ។ *យុទ្ធសាស្ត្រចតុកោណ* នេះ គឺជាយុទ្ធសាស្ត្ររយៈពេលវែងរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដែលផ្អែកលើគោលនយោបាយជាមូលដ្ឋានគ្រឹះ ដូចខាងក្រោម :

ទី១. ការធានានូវចីរភាពនៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម តាមរយៈវិធានការជាក់លាក់នានា សំដៅលើកស្ទួយនីតិរដ្ឋ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីបង្កើតឡើងនូវបរិស្ថាននយោបាយ និងសន្តិសុខ ដែលអនុគ្រោះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរយៈពេលវែង ។

ទី២. ការធានាឱ្យបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង ក្នុងអត្រាប្រមាណ ៧ភាគរយក្នុងមួយឆ្នាំ លើមូលដ្ឋានទូលំទូលាយជាងមុន និងមានមូលដ្ឋានសេដ្ឋកិច្ចប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងបរទេសជាប្រចាំ ។

ទី៣. ការធានាបែងចែកប្រកបដោយសមធម៌ នូវកាលានុវត្តភាព និងផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ។

ទី៤. ការធានាចីរភាពនៃបរិស្ថាន ជាពិសេស តាមរយៈការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយចីរភាព នូវធនធានធម្មជាតិ ។

៣៣០. បន្ថែមពីលើនេះ នៅមានកត្តាជាក់ស្តែងមួយចំនួនទៀត ដែលកំណត់ពីភាពចាំបាច់ក្នុងការបន្តអនុវត្ត *"យុទ្ធសាស្ត្រចតុកោណ"* ដូចជា :

ទី១. ភាពចាំបាច់ក្នុងការបន្តពង្រីក និងពង្រឹងសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន តាមរយៈការអនុវត្ត *"យុទ្ធសាស្ត្រចតុកោណ"* ក្នុងនីតិកាលទី៣ នៃរដ្ឋសភា កន្លងមក ។

ទី២. ដូចបានរំលេចខាងលើការអនុវត្ត *"យុទ្ធសាស្ត្រចតុកោណ"* ក្នុងនីតិកាលទី៣ នៃរដ្ឋសភាកន្លងមក បានបង្ហាញឱ្យឃើញនូវបញ្ហាប្រឈមចម្បងៗមួយចំនួន ដែលទាមទារឱ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំងកែលម្អ និងពង្រឹងអាទិភាពគោលនយោបាយរបស់ខ្លួន ហើយជំរុញការអនុវត្តនូវរបៀបវារៈគោល-នយោបាយនេះ នៅក្នុងដំណាក់កាលបន្ទាប់ទៀត ។

ទី៣. ការបន្តអនុវត្ត *"យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២"* គឺជាជំហាននាំឆ្ពោះទៅសម្រេចឱ្យបាន *"គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា"* ។

ទី៤. ឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជា រួមផ្សំនឹងការប្រែប្រួលសភាពការណ៍ពិភពលោក និងក្នុងប្រទេស គឺជាកត្តាកំណត់ថ្មីបន្ថែមទៀត ដែលទាមទារឱ្យមានការកែលម្អ សម្រិតសម្រាំងបន្ថែម នូវ *"យុទ្ធសាស្ត្រចតុកោណ"* និងជំរុញអនុវត្តនៅក្នុងដំណាក់កាលទី២ ។

៣៣១. *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣* បង្ហាញដោយសង្ខេប ពី បណ្តាសកម្ម-ភាព កម្មវិធី និងគម្រោងនានា ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធនានាត្រូវទទួលយក ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពសំខាន់ៗ របស់ *រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា (២០០៨-២០១៣)* ដែលបានគូសបញ្ជាក់នៅក្នុង *"យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២"* ។ ព័ត៌មានដែលបានបង្ហាញខាងក្រោមនេះ គឺរៀបចំទៅតាមទម្រង់របស់ *យុទ្ធសាស្ត្រចតុកោណ* ។ ចំពោះ សមាសភាគ និងសមាសភាគរងនីមួយៗរបស់ *យុទ្ធសាស្ត្រ-ចតុកោណ* នេះ ត្រូវបានរៀបចំ តាមរយៈ ការដាក់ចេញនូវ : ទី១ គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់វិស័យជាក់លាក់នីមួយៗ និង ទី២ សកម្មភាព កម្មវិធី និងគម្រោង នានា ដែលបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលយក ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងអស់នេះ ។

## ១. អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

៣៣២. សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ការបន្តធ្វើកំណែទម្រង់អភិបាលកិច្ច *របស់រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្ដោតជាសំខាន់ លើការបង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយ និង ក្នុងការផ្ដល់និងការគ្រប់គ្រងទំនិញសាធារណៈ ជាពិសេស ការផ្ដល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ។ កំណែទម្រង់ ឬសមាសភាគរង ៤ យ៉ាង នៃសមាសភាគរបស់ *យុទ្ធសាស្ត្រចតុកោណ* ផ្សារភ្ជាប់ជាមួយ (១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២) កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (៣) កំណែទម្រង់រដ្ឋបាលសាធារណៈ (៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ។

### ១.១ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៣៣. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅតែជារបៀបវារៈអាទិភាពខ្ពស់ នៃបញ្ជីរបៀបវារៈរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ។ ក្នុងស្មារតីនេះ *រាជរដ្ឋាភិបាលកម្ពុជា* នៅតែប្ដេជ្ញាចិត្តយ៉ាងមោះមុតឥតរាថយ ដើម្បីរៀបចំនិងជំរុញអនុម័តច្បាប់នេះ ដែលមានសង្គតិភាពជាមួយនឹងច្បាប់គោលដទៃទៀតជាមូលដ្ឋានសំដៅធានាបាន នូវភាពរលូន និងសង្គតិភាព ក្នុងចំណោមច្បាប់ផ្សេងៗ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពដោយបន្តកិច្ចសហការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ ។ ការរៀបចំ និងជំរុញអនុម័តច្បាប់គោលដទៃទៀតជាមូលដ្ឋាន នឹងនៅតែជាអាទិភាពខ្ពស់របស់ *រាជរដ្ឋាភិបាលកម្ពុជា* ។

៣៣៤. នៅពេលដែលការរៀបចំច្បាប់ទាំងនេះកំពុងដំណើរការ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តវិធានការម៉ឺងម៉ាត់ជាយុទ្ធសាស្ត្រនានា ដើម្បីលុបបំបាត់ឫសគល់នៃអំពើពុករលួយ តាមរយៈ សកម្មភាពដែលមានទំនាក់ទំនងទៅវិញទៅមក ដូចខាងក្រោម :

- *ការបង្ការទប់ស្កាត់ជាមុន* : *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញសកម្មភាពលើកកម្ពស់ការយល់ដឹង រាល់ទិដ្ឋភាពនៃអំពើពុករលួយ ដែលរួមមាន មូលហេតុ ឥទ្ធិពល និងផលវិបាក ដ៏គ្រោះថ្នាក់នៃអំពើពុករលួយ ដើម្បី បន្តលើកទឹកចិត្តសាធារណជន ឱ្យចូលរួមក្នុងការទប់ស្កាត់ និង ប្រយុទ្ធប្រឆាំង នឹងអំពើពុករលួយ ។ បន្តចាត់វិធានការជាក់ស្ដែង ដើម្បីលើកទឹកចិត្តមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ឱ្យប្រកាន់ខ្ជាប់នូវសេចក្ដីថ្លៃថ្នូរសីលធម៌ស្អាតស្អំ និងអនុវត្តការងារប្រកបដោយមនសិការមុខវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ។
- *ការពង្រឹងគណនេយ្យភាពនិងសមត្ថភាពស្ថាប័ន* : *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្ដោតការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើង នូវប្រសិទ្ធភាពក្នុងការបញ្ចៀសជម្លោះ រវាងផលប្រយោជន៍ឯកជន និងសាធារណៈ

ដោយប្រកាន់ខ្ជាប់នូវគោលការណ៍សម្របសម្រួលរវាងតួនាទីនានា ជាពិសេស ការសម្របសម្រួល រវាងតួនាទីនយោបាយនិងមុខងារសាធារណៈ និងរវាង តួនាទីនយោបាយឬមុខងារសាធារណៈនិងសកម្មភាពឯកជន ។ ជាមួយគ្នានេះដែរ *រាជរដ្ឋាភិបាលកម្ពុជា* នឹងកាត់បន្ថយនិងលុបបំបាត់ ការប្រើប្រាស់តួនាទីសាធារណៈ ការធ្វើអន្តរាគមន៍ និងអំណាច ដើម្បីបិទបាំងអំពើអាក្រក់នានា និងធ្វើឱ្យដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត មានភាពលម្អៀង ។

- *ការគាំទ្រនិងការចូលរួមពីសាធារណៈជន* ៖ ការគាំទ្រ និងការចូលរួមពីសាធារណៈជន គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ ការការពារ ការកាត់បន្ថយ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ប្រកបដោយប្រសិទ្ធភាព ។ ដើម្បីសម្រេចបានគោលបំណងនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញ និងការពារសិទ្ធិសេរីភាពក្នុងការស្វែងរក ការទទួលបាន និង ការផ្សព្វផ្សាយព័ត៌មាន ស្តីពី ករណីអំពើពុករលួយក្នុង ប្រព័ន្ធផ្សព្វផ្សាយ ។ ទោះជាដូចនេះក្តី ការងារនេះត្រូវបានធ្វើឡើងក្នុងរបៀបមួយ ដែលមានការទទួលខុសត្រូវ និងមានទំនុកចិត្ត ដោយគោរពនូវ សិទ្ធិសេរីភាព ភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរបស់ ប្រជាជន ទាក់ទងនឹង ការការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ។
- *ការចូលរួមពីវិស័យឯកជន* ៖ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តរៀបចំនិងជំរុញ អនុវត្តគោលនយោបាយបទដ្ឋានគតិយុត្ត និងនីតិវិធី សម្រាប់ការពារភាពសុចរិតនៃវិស័យឯកជន ដើម្បីបញ្ចៀសការឃុបឃិត និងធានាឱ្យបាននូវការប្រកួតប្រជែងដោយស្មោះត្រង់ រវាងក្រុមហ៊ុន និងសហគ្រាសឯកជន ដោយធានាឱ្យបាននូវ ការប្រព្រឹត្តល្អត្រឹមត្រូវ ប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ក្នុងសកម្មភាពធុរកិច្ច ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធានាតុល្យភាពរវាងសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យារវាង ភាគីរដ្ឋនិងវិស័យឯកជន ។
- *ការពង្រឹងការអនុវត្តច្បាប់* ៖ *រាជរដ្ឋាភិបាលកម្ពុជា* នឹងចាត់វិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ ចំពោះជនល្មើសប្រព្រឹត្តអំពើពុករលួយ កាត់បន្ថយភាពក្រីក្រ បំបាត់អំពើពុករលួយ និងបង្កើនជំនឿទុកចិត្ត ពីសំណាក់សាធារណជន ។

## ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៣៣៩. ដើម្បីអនុវត្តបណ្តាគោលនយោបាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ទិសដៅរបស់ *អង្គភាពប្រឆាំងអំពើពុករលួយ* ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមមាន ៖

- ពង្រឹងនិងបង្កើនល្បឿន ការងារអប់រំ និង ការងារផ្សព្វផ្សាយ ពីលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងអំពើពុករលួយ ។
- ជំរុញលើកទឹកចិត្តមហាជនឱ្យចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។
- ជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងជនប្រព្រឹត្តអំពើពុករលួយ ។

៣៣៦. ដើម្បីសម្រេចបានទិសដៅខាងលើ នៅក្នុង នីតិកាលទី៤ នៃរដ្ឋសភា *អង្គភាពប្រឆាំងអំពើពុករលួយ* នឹងអនុវត្តនូវបណ្តាយុទ្ធសាស្ត្ររួមគ្នា ដូចខាងក្រោម :

- *ការបង្ការទប់ស្កាត់ជាមុន :*
  - បន្តជំរុញសកម្មភាពលើកកម្ពស់ការយល់ដឹងអំពី វាល់ទិដ្ឋភាពនៃអំពើពុករលួយ រួមមាន មូលហេតុ ឥទ្ធិពល និង ផលវិបាកដ៏គ្រោះថ្នាក់ នៃអំពើពុករលួយ ដើម្បីបន្តលើកទឹកចិត្តសាធារណជន ឱ្យចូលរួមក្នុងការទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ ។
  - បន្តចាត់វិធានការជាក់ស្តែង ដើម្បីលើកទឹកចិត្ត ដល់មន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ឱ្យប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ សីលធមិស្អាតស្អំ និង អនុវត្តការងារ ប្រកបដោយមនសិការមុខវិជ្ជាជីវៈ និង មានស្មារតីទទួលខុសត្រូវខ្ពស់ ។
- *ការពង្រឹង គណនេយ្យភាព និង សមត្ថភាពស្ថាប័ន :*
  - ពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាព នូវគោលការណ៍បញ្ចៀសទំនាស់ផលប្រយោជន៍ រវាង ឯកជន និង សាធារណៈ ។
  - បន្តកសាងនិងពង្រឹងសមត្ថភាពស្ថាប័ន រួមទាំង ការងារអធិការកិច្ច ដើម្បី គ្រប់គ្រងនិងជំរុញការអនុវត្ត *ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ* ប្រកបដោយប្រសិទ្ធភាព។
- *ការគាំទ្រ និង ការចូលរួម ពីសាធារណជន :*
  - បន្តជំរុញលើកកម្ពស់ថែមទៀត និងការការពារសិទ្ធិសេរីភាពនៃការស្វែងរក ការទទួលបាន និង ការផ្សព្វផ្សាយ ក្នុងបណ្តាញព័ត៌មាន នូវករណីពាក់ព័ន្ធនឹងអំពើពុករលួយ ។
  - បន្ត និងពង្រីកការរៀបចំសិក្ខាសាលា ថ្នាក់ជាតិនិងអន្តរជាតិ ស្តីពី ការងារប្រឆាំងអំពើពុករលួយ ។
  - បន្តកិច្ចសហប្រតិបត្តិការ ជាលក្ខណៈអន្តរជាតិ ក្នុងភាពជាដៃគូ សំដៅទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។
- *ការចូលរួមពីវិស័យឯកជន :*
  - បន្តរៀបចំនិងជំរុញ ការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ការពារភាពសុចរិតនៃវិស័យឯកជន ដើម្បី បញ្ចៀសការឃុបឃិត និង ធានាឱ្យបាននូវការប្រកួតប្រជែងដោយស្មើភាព រវាងក្រុមហ៊ុនសហគ្រាសឯកជននានា ដោយធានាឱ្យបាននូវការប្រព្រឹត្តល្អត្រឹមត្រូវប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ក្នុងសកម្មភាពធុរកិច្ច ។
  - ធានាតុល្យភាពរវាងសិទ្ធិ និង ផលប្រយោជន៍ទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យា រវាងភាគីរដ្ឋ និង វិស័យឯកជន ។
- *ការពង្រឹងការអនុវត្តច្បាប់ :*
  - បន្តចាត់វិធានការច្បាប់យ៉ាងម៉ឺងម៉ាត់និងតឹងរ៉ឹង ចំពោះជនល្មើសប្រព្រឹត្តអំពើពុករលួយ ដើម្បីកាត់បន្ថយអំពើពុករលួយ និង បង្កើនជំនឿទុកចិត្ត ពីសំណាក់សាធារណជន ។

៣៣៧. *ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* នឹងផ្តោតការយកចិត្តទុកដាក់លើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈ កម្មវិធីអាទិភាពគន្លឹះចំនួន៥ គឺ *(១) ការងារផ្សព្វផ្សាយច្បាប់ (២) ការងារអធិការកិច្ច (៣) ការងារតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ (៤) ការងារទទួលនិងដោះស្រាយពាក្យបណ្តឹង និង (៥) ការអភិវឌ្ឍស្ថាប័ន ការកសាងសមត្ថភាពមន្ត្រីរាជការ រួមទាំង ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអាទិភាពគន្លឹះសំខាន់ៗ ទាំង ៥* ។

៣៣៨. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* នឹងផ្តោតលើសកម្មភាព ដូចខាងក្រោម ៖

- *ការពង្រឹងការងារផ្សព្វផ្សាយច្បាប់* ដើម្បីបង្កើនការយល់ដឹងពី ច្បាប់ សិទ្ធិ និង កាតព្វកិច្ចនានា ដែលមានចែងនៅក្នុងច្បាប់ ក្នុងគោលបំណងរក្សាឱ្យបាននូវ ស្ថិរភាព សណ្តាប់ធ្នាប់សង្គម និងនីតិរដ្ឋ ឆ្ពោះទៅរកគោលដៅកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ និងបទល្មើសក្នុងសង្គម ។ *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* បានជ្រើសរើសច្បាប់អាទិភាពចំនួន៩ គឺ *ច្បាប់ភូមិបាល ច្បាប់ព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបមុខរបរវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង ច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍* សម្រាប់ធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុង រាជធានី និង ខេត្តទាំង២៣ ។
- *ការពង្រឹង ការងារអធិការកិច្ចនិងទទួលនិងដោះស្រាយបណ្តឹង ដើម្បីប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ ការរំលោភបំពានដោយអំណាច និង សកម្មភាពអសកម្មនានា* សំដៅធានាឱ្យមាន ការអនុវត្តច្បាប់ និង ការកាត់បន្ថយអំពើពុករលួយ ការរំលោភបំពានដោយអំណាច និង បាតុភាពអសកម្មនានា ។ ការងារនេះបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើ កម្មវិធីអាទិភាពជាគន្លឹះចំនួន៣ របស់ *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* ក្នុងនោះរួមមាន *ការងារអធិការកិច្ច ការតាមដានត្រួតពិនិត្យការអនុវត្តច្បាប់* និង *ការងារទទួលនិងដោះស្រាយបណ្តឹង* ។ ការងារនេះ ពុំត្រឹមតែជាយន្តការមួយ ដើម្បីបង្ការទប់ស្កាត់និងបង្ក្រាប អំពើពុករលួយ ការរំលោភបំពានដោយអំណាច និង បាតុភាពអសកម្មនានា ប៉ុណ្ណោះទេ ប៉ុន្តែ វាក៏ជាយន្តការមួយ ដែលបានចូលរួមពង្រឹងអភិបាលកិច្ចល្អ ដែលជាស្នូលនៃ*យុទ្ធសាស្ត្រចតុកោណ* របស់*រាជរដ្ឋាភិបាលកម្ពុជា* ឱ្យមានប្រសិទ្ធភាព ទៀតផង ។ *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* បានកំណត់យកសកម្មភាពអាទិភាពចំនួន៣ សម្រាប់កម្មវិធីអធិការកិច្ច គឺ (១) *ការធ្វើអធិការកិច្ចលើ ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ចំណូល-ចំណាយថវិការដ្ឋនិង*

*ជំនួយអន្តរជាតិ និង ការងារដឹកនាំគ្រប់គ្រង នៅតាមក្រសួង-ស្ថាប័ន និង គ្រឹះស្ថានសាធារណៈនានា* (២) *ការតាមដានត្រួតពិនិត្យការអនុវត្ត ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម សាធារណការ អប់រំ ថែទាំសុខភាព រៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ពាណិជ្ជកម្ម ឧស្សាហកម្ម និង សង្គមកិច្ច និង* (៣) *ការងារទទួលនិងដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ។*

- *ការពង្រឹងស្ថាប័ន និង ការអភិវឌ្ឍធនធានមនុស្ស* ដើម្បីបង្កើនសមត្ថភាពស្ថាប័ននៅ ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ តាមរយៈ : (១) ការបន្តរៀបចំ សេចក្តីព្រាងច្បាប់ នីតិវិធី និង គោលនយោបាយ ស្តីពីអធិការកិច្ច (២) ការរៀបចំវគ្គបណ្តុះបណ្តាលលើមុខជំនាញជាច្រើន ដូចជា ជំនាញគ្រូបង្គោលសម្រាប់ការផ្សព្វផ្សាយច្បាប់ ជំនាញស៊ើបអង្កេតស្រាវជ្រាវ ជំនាញធ្វើកោសល្យវិច័យគណនេយ្យ ជំនាញគ្រប់គ្រងធនធានមនុស្ស ជំនាញរដ្ឋបាលទូទៅ និង ជំនាញរៀបចំផែនការ (៣) បង្កើតគម្រោងកន្សោមអាទិភាព និង (៤) សាងសង់ *មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច* នៅថ្នាក់ក្រោមជាតិ ។

## ១.២ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៣៩. *រាជរដ្ឋាភិបាលកម្ពុជា* បានកែលម្អច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយផ្តោតជាសំខាន់លើការរៀបចំក្របខ័ណ្ឌច្បាប់ឱ្យបានរឹងមាំ និងការធ្វើទំនើបនីយកម្មច្បាប់ ព្រមទាំងដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការចាំបាច់នានា ក្នុងគោលដៅពង្រឹងសមត្ថភាព ឯករាជភាព និងអព្យាក្រឹតភាព នៃស្ថាប័នតុលាការ ដែលជាកត្តាសំខាន់ ក្នុងដំណើរការពង្រឹងនីតិរដ្ឋ ។ ក្នុងនីតិកាលទី៣ នៃរដ្ឋសភា កន្លងទៅនេះ ច្បាប់ចំនួន ១៤០ ត្រូវបានអនុម័ត ក្នុងនោះមានក្រមធំៗចំនួន ៣ គឺ *ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមរដ្ឋប្បវេណី* ។ *ក្រមព្រហ្មទណ្ឌ* ត្រូវបានប្រកាសឱ្យប្រើកាលពី ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្ត*យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* ដើម្បី ឈានទៅសម្រេចឱ្យបាននូវ ទិសដៅជាយុទ្ធសាស្ត្រទាំង ៧ របស់ខ្លួន ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់ថែមទៀត ក្នុងការបន្ត និងជំរុញការអនុម័តច្បាប់គោលសំខាន់ៗ ដូចជា *ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអង្គការតុលាការ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម* ។ ជាមួយគ្នានេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តរៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ ដល់ប្រជាពលរដ្ឋ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ ក្នុងគោលដៅ បង្កើនការយល់ដឹង និង ការអនុវត្តឱ្យបានត្រឹមត្រូវ ។

៣៤០. ក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តផ្តល់នូវអាទិភាពបន្ថែមទៀត លើ *(១) ការពង្រឹងសមត្ថភាពរបស់ចៅក្រមនិងព្រះរាជអាជ្ញា* តាមរយៈ ការបណ្តុះបណ្តាលបន្ត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

ដំបូង ប្រកបដោយគុណភាពខ្ពស់ និងការពង្រឹងការទទួលខុសត្រូវរបស់*ចៅក្រម និងព្រះរាជអាជ្ញា* តាមរយៈការបង្កើតឱ្យមានលក្ខន្តិកៈសម្រាប់*ចៅក្រមនិងព្រះរាជអាជ្ញា* និងតាមរយៈ ការពង្រឹងវិន័យ ដោយសហការជាមួយ*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (២) ការកសាងនូវយន្តការផ្សេងៗ ដែលចូលរួមបម្រើឱ្យវិស័យយុត្តិធម៌* រួមមានការបង្កើតឱ្យមាន*លក្ខន្តិកៈក្រឡាបញ្ជី លក្ខន្តិកៈសារការី* និង *លក្ខន្តិកៈអាជ្ញាសាលា* ព្រមទាំង ការបង្កើតឱ្យមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីជំនួយឱ្យវិស័យយុត្តិធម៌ទាំងនេះ ដើម្បីធានាឱ្យបាន នូវគុណភាព និងសមត្ថ-ភាពវិជ្ជាជីវៈខ្ពស់ *(៣) ការផ្តល់ជំនួយផ្នែកច្បាប់* ជាពិសេស តាមរយៈការផ្តល់ជំនួយមេធាវីដល់ជនក្រីក្រ ដើម្បីការពារសិទ្ធិ និងប្រយោជន៍តាមផ្លូវតុលាការ *(៤) ការបន្តជំរុញលើកកម្ពស់យន្តការ នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ* ជូនប្រជាពលរដ្ឋ ដើម្បីលើកស្ទួយ និងពង្រឹងវប្បធម៌នៃការរួមរស់ជាមួយគ្នាដោយ សន្តិភាព សាមគ្គីភាព និង សុខដុមរមនា ក្នុងសង្គម ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៣៤១. *ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* បានរៀបចំផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ដែលមានសកម្មភាព ដូចខាងក្រោម :

*១. កំណែទម្រង់ច្បាប់ :*

- បន្តជំរុញការអនុម័តច្បាប់គោលសំខាន់ៗ រួមមាន *ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម* ។
- ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយច្បាប់
  - ➢ *ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី បណ្ឌិតសភានគរបាលជាតិ វិទ្យាស្ថានឯកទេស និង ក្រសួងស្ថាប័នជំនាញផ្សេងៗ* ទៀត នឹងចូលរួមយ៉ាងសកម្ម ក្នុងការបណ្តុះបណ្តាល ជូនប្រជាពលរដ្ឋ និងអ្នកអនុវត្តច្បាប់ អំពីប្រធានបទពាក់ព័ន្ធនឹងច្បាប់និងការអនុវត្តច្បាប់ និង ផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយ អំពីប្រធានបទ ទាំងនេះ ។
  - ➢ បង្កើតសេវាព័ត៌មានច្បាប់និងតុលាការ សម្រាប់ប្រជាជន នៅសាលាដំបូង រាជធានី និង ខេត្ត ។

*២. កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ :*

- ពង្រឹងសមត្ថភាពចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីអនុវត្តច្បាប់ តាមរយៈ :
  - ➢ ការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលបន្ត ។
  - ➢ ការពង្រឹងក្រុមប្រឹក្សាវិន័យរបស់ *ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម* ។

➢ ការអនុវត្តតុលាការគំរូ តាមរយៈ ការពង្រឹងរដ្ឋបាលតុលាការនិងការគ្រប់គ្រងតុលាការ ការពង្រីកតុលាការគំរូទៅតុលាការផ្សេងទៀត និង ការបង្កើនហិរញ្ញប្បទានគាំទ្រសម្រាប់កំណែទម្រង់តុលាការ ។

➢ ការប្រមូល ចងក្រង វិភាគ និង បោះពុម្ពផ្សាយ សេចក្តីសម្រេចរបស់តុលាការ ។

- បង្កើតយន្តការ សម្រាប់ជាជំនួយដល់វិស័យតុលាការ :

➢ អនុម័ត និងអនុវត្តលក្ខន្តិកៈសម្រាប់ ក្រឡាបញ្ជី សារការី អាជ្ញាសាលា នគរបាល និង មន្ត្រីពន្ធនាគារ ។

➢ ពង្រឹងសាលាបណ្តុះបណ្តាលសម្រាប់ ក្រឡាបញ្ជី សារការី និងអាជ្ញាសាលា ។

- ការផ្តល់ជំនួយផ្នែកច្បាប់ :

➢ រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តអនុសាសន៍សំខាន់ៗ នៃ *"ការស្ទង់មតិថ្នាក់ជាតិស្តីពីជំនួយផ្នែកច្បាប់នៅកម្ពុជា"* ខែធ្នូ ឆ្នាំ២០០៦ ។

➢ អនុវត្តផែនការសកម្មភាព សម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់ ។

- បន្តជំរុញយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ :

➢ ពង្រឹងគម្រោង *មណ្ឌលសេវាកម្មយុត្តិធម៌* ។

➢ ពង្រីកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈ ការពង្រឹងមជ្ឈមណ្ឌលសេវាយុត្តិធម៌ដែលមានស្រាប់នៅក្នុងស្រុកចំនួន ២០ និងការពង្រីកសេវាកម្មនេះ ទៅដល់ស្រុក-ក្រុងផ្សេងៗទៀតទូទាំងប្រទេស ដើម្បីសម្រួលឱ្យបានឆាប់រហ័សនូវការដោះស្រាយវិវាទ ដោយចំណាយថវិកាតិច ជូនប្រជាពលរដ្ឋ ជាពិសេស ប្រជាជនក្រីក្រ ព្រមទាំង ដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿង នៅសាលាដំបូង រាជធានី-ខេត្ត ។

➢ សិក្សានិងរៀបចំក្របខ័ណ្ឌច្បាប់ សម្រាប់ធ្វើស្ថាបនូបនីយកម្ម ការដោះស្រាយវិវាទក្រៅប្រព័ន្ធ តុលាការ ។

- ពង្រីកសេវាកម្មយុត្តិធម៌ ដោយបង្កើត :

➢ សភា តុលាការពិសេស តាមតម្រូវការ ទាក់ទងនឹងផ្នែក *ពាណិជ្ជកម្ម ការងារ អនីតិជន* និង *រដ្ឋបាល* ។

➢ សាលាឧទ្ធរណ៍តាមតំបន់ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋ ឱ្យទទួលបានសេវាប្រព័ន្ធតុលាការ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅខេត្តឆ្ងាយៗ ព្រមទាំង ដើម្បីកាត់បន្ថយនូវការកកស្ទះសំណុំរឿងនៅសាលាឧទ្ធរណ៍ រាជធានីភ្នំពេញ ។

➢ សាលាដំបូងនៅខេត្តប៉ៃលិន ឧត្តរមានជ័យ និងកែប ។

➢ កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់ និងយុត្តិធម៌ ជាពិសេស ការជួយគ្នាទៅវិញទៅមកតាមផ្លូវតុលាការ ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ។

*៣. ការជំរុញកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តាមរយៈ :*

- ការបន្តបណ្តុះបណ្តាលជំនាញពាក់ព័ន្ធ ដល់មន្ត្រីដែលចូលរួមក្នុងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

- ការបន្តបណ្តុះបណ្តាល ពី មគ្គុទ្ទេសក៍ នៃការធ្វើផែនការសម្រាប់ស្ថាប័នវិស័យយុត្តិធម៌ និងរៀបចំយន្តការចាំបាច់ សម្រាប់ពង្រឹង និងអនុវត្តវិធានការនានា របស់កំណែទម្រង់ ។
- ការរៀបចំសូចនាករ និង ការតាមដានត្រួតពិនិត្យ ការអនុវត្តកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។
- ការបន្តផ្សព្វផ្សាយដល់តុលាការ និងអាជ្ញាធរមូលដ្ឋាន ពីកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។

## ១.៣ កំណែទម្រង់រដ្ឋបាលសាធារណៈ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៤២. ដោយផ្អែកទៅលើសមិទ្ធផលនានា ដែលសម្រេចបានរហូតមកដល់បច្ចុប្បន្ននេះ *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល* បាននិងកំពុងអនុវត្តឱ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយថែមទៀតលើការងារកំណែទម្រង់ ដោយយកចិត្តទុកដាក់ជាសំខាន់ទៅលើ ការកែលម្អគុណភាព និងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសមត្ថភាពមនុស្សនិងស្ថាប័ន សំដៅអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា* និងទទួលបានលទ្ធផលប្រកបដោយចីរភាព ។ *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ* សម្រាប់នីតិកាលទី ៤ នេះ *រាជរដ្ឋាភិបាល* បានផ្តោតលើ ការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពដែលជាកត្តាគន្លឹះពីរក្នុងការប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យក្លាយទៅជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ ។ កិច្ចការទាំងនេះ ទាមទារឱ្យមានការផ្លាស់ប្តូរឱ្យបានទូលំទូលាយនូវអាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រីរាជការ តាមរយៈ ការពង្រឹងការជ្រើសរើសក្របខ័ណ្ឌថ្មី ការពង្រាយមន្ត្រីរាជការ និងការដាក់មន្ត្រីឱ្យចូលនិវត្តន៍ ។ រាល់គំនិតផ្តួចផ្តើមនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល បានចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលសាធារណៈ ដើម្បីអនុវត្តគោលនយោបាយ និងអាទិភាពនានារបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។

៣៤៣. នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល ២០០៩-២០១៣* នឹងត្រូវអនុវត្តក្នុងក្របខ័ណ្ឌដូចខាងក្រោម :

- ***គោលបំណង*** : បម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ និង វិបុលភាពប្រទេសជាតិ ។
- ***គោលដៅ*** : ប្រែក្លាយរដ្ឋបាលសាធារណៈ ទៅជាអ្នកផ្តល់សេវាដ៏ស័ក្តិសិទ្ធិ តាមរយៈ ការធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមាន តម្លាភាព ភាពឆ្លើយតប ប្រសិទ្ធភាព និងការលើកកម្ពស់ ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ។

### ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៣៤៤. *រាជរដ្ឋាភិបាលកម្ពុជា* បានប្តេជ្ញាចិត្តបន្តអនុវត្តឱ្យបានខ្លាំងក្លានូវ *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល* សំដៅប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ ។ ការងារអាទិភាពនានា ដើម្បីសម្រេចបានគោលនយោបាយអាទិភាពខាងលើ រួមមាន :

## ១. ការធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមាន តម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព :

- បន្តផ្សព្វផ្សាយគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ។
- ត្រួតពិនិត្យឡើងវិញ ចងក្រងបញ្ចប់ និងផ្សព្វផ្សាយ កម្រងព័ត៌មានសេវាសាធារណៈ ។
- សម្រួលការទទួលយកព័ត៌មាន នីតិវិធីសាមញ្ញ កាត់បន្ថយការិយាធិបតេយ្យ ។
- ចងក្រងបញ្ចប់ និងផ្សព្វផ្សាយ *ផែនការអភិបាលកិច្ចទី៣* ។
- បន្តដាក់ឱ្យអនុវត្ត ទីភ្នាក់ងារប្រតិបត្តិការពិសេស ។
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា (E-Government) ។
- រៀបចំ និងបង្កើតឱ្យមានយន្តការផ្តល់ព័ត៌មានត្រឡប់របស់អ្នកប្រើប្រាស់សេវា និងយន្តការបណ្តឹង ។
- កំណត់តួនាទី និងភារកិច្ចឱ្យបានច្បាស់លាស់ និងសម្រួលនីតិវិធីផ្ទៃក្នុង (សេវាទ្រទ្រង់) ដែលគាំទ្រដល់ការផ្តល់សេវា ។
- បញ្ចប់ការចងក្រង និងដាក់ឱ្យអនុវត្ត គោលនយោបាយពង្រាយមន្ត្រីរាជការ និង ឯកសារណែនាំសម្រាប់អនុវត្ត ។
- ដាក់ឱ្យអនុវត្តគម្រោង *ចំណាយប្រតិបត្តិការអាទិភាព* (POC) ។
- បង្កើតឱ្យមាន មូលដ្ឋានទិន្នន័យច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ ។

## ២. លើកកម្ពស់ ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ

- ប្រតិបត្តិការជំរឿន និងរាប់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងដាក់ឱ្យអនុវត្តប្រព័ន្ធ *ស្មាតខាត* (Smart Card) និង គ្រប់គ្រងវត្តមានតាម *អេឡិចត្រូនិក* ។
- បញ្ចប់ការចងក្រងនិងផ្សព្វផ្សាយសៀវភៅស្តីពី គុណសម្បត្តិ៤យ៉ាងនៃឥរិយាបថមន្ត្រីរាជការកាតព្វកិច្ចមន្ត្រីរាជការស៊ីវិល និងការគ្រប់គ្រងមន្ត្រីរាជការ (Handbook on Civil Service) ។
- រៀបចំនិងអនុវត្តបទដ្ឋាននៃការផ្តល់សេវាសាធារណៈ (Code of Service) (ស្តង់ដារនៃគុណភាពសេវាសាធារណៈ) ។
- ជំរុញការទទួលស្គាល់ និងផ្តល់តម្លៃដល់បែបបទការងារដែលល្អជាងគេ (Best Practices) ឧទាហរណ៍ រង្វាន់ ឬ វិញ្ញាបនបត្រសរសើរ ។
- ដាក់ឱ្យអនុវត្តឧបករណ៍គ្រប់គ្រងប្រសិទ្ធភាពការងារ និងពង្រឹងគណនេយ្យភាព (លក្ខខណ្ឌយោង ការពិពណ៌នាមុខដំណែង កិច្ចសន្យាការងារ ការវាយតម្លៃការងារជាលក្ខណៈបុគ្គល និងដំណើរការ) ។
- ពង្រឹងអភិក្រមនៃការគ្រប់គ្រងធនធានមនុស្ស ដូចជា ការធ្វើផែនការ ការជ្រើសរើស ការវិវឌ្ឍអាជីព ការចូលនិវត្តន៍ ជាដើម ។
- ពង្រឹងការអភិវឌ្ឍធនធានមនុស្ស (ការវាយតម្លៃលើតម្រូវការប្រតិបត្តិ ការបង្កើនការប្រើប្រាស់ជំនាញដែលមានស្រាប់កម្មវិធីបណ្តុះបណ្តាល ការជំរុញឱ្យមានការបណ្តុះបណ្តាលបន្ត (Continuous training) និងការ បង្កើតមូលដ្ឋានទិន្នន័យជំនាញ (Skill database) ។

- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាល និងការផ្ទេរចំណេះដឹងដែលផ្អែកលើតម្រូវការជាក់ស្តែង និងកម្ពុជានីយកម្ម ព្រមទាំង កម្មវិធីដឹកនាំបង្ហាត់ (Mentoring Programmes) ដល់អ្នកគ្រប់គ្រង គ្រូឧទ្ទេស និងអ្នកជំនាញ ។
- អភិវឌ្ឍសមត្ថភាពអង្គភាពគ្រប់គ្រងធនធានមនុស្ស នៅក្នុងក្រសួង-ស្ថាប័ននានាអំពីការរៀបចំការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យ ការងារបណ្តុះបណ្តាល ។
- រៀបចំនិងអនុវត្តកម្មវិធីកំណែទម្រង់បៀវត្សរ៍ ដោយគោរពនូវគោលការណ៍ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រសិទ្ធភាព នៃសេវាសាធារណៈ និងសមធម៌ ។
- រៀបចំនិងអនុវត្តយន្តការដែលទាក់ទាញ និងថែរក្សាបុគ្គលិកដែលមានជំនាញខ្ពស់ ។

៣៤៥. ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយក្រសួង ស្ថាប័ននានា *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល* បានធ្វើបច្ចុប្បន្នភាព*ផែនការសកម្មភាពអភិបាលកិច្ច* ។ *ផែនការសកម្មភាពអភិបាលកិច្ច* នាពេលកន្លងមក បានផ្តោតជាសំខាន់ទៅលើការបង្កើនល្បឿនកំណែទម្រង់រដ្ឋ តាមរយៈ ការពង្រឹងអភិបាលកិច្ច និងកែលម្អការផ្តល់សេវាសាធារណៈ ។ ដោយឡែក *ផែនការសកម្មភាពអភិបាលកិច្ចទី៣* នឹងសំដៅទៅដល់ការកែលម្អគុណភាព និងការផ្តល់សេវាសាធារណៈ និងផ្តោតលើការសម្របសម្រួលជាមួយកំណែទម្រង់នានា ។ សេវាសាធារណៈ ដែលបានជ្រើសរើសជាអាទិភាព នឹងត្រូវយកចិត្តទុកដាក់ក្នុងការកែលម្អឱ្យមានតម្លាភាព មានការឆ្លើយតប មានគណនេយ្យភាព និងប្រសិទ្ធភាព ។ យន្តការផ្សេងៗ ដូចជា ក្រុមការងារអន្តរក្រសួងនឹងត្រូវដាក់ឱ្យដំណើរការ ដើម្បីសម្រួលដល់ការអនុវត្ត និងការតាមដានត្រួតពិនិត្យអំពីវឌ្ឍនភាព ។

៣៤៦. *ផែនការសកម្មភាពអភិបាលកិច្ចទី៣* នឹងបង្ហាញដល់ក្រសួង-ស្ថាប័ន អំពីវិធីសាស្ត្រក្នុងការអនុវត្តការងារកំណែទម្រង់របស់ខ្លួន ដើម្បីកែលម្អគុណភាព និងការផ្តល់សេវាសាធារណៈ ។ កម្មវិធីជាតិផ្សេងៗ ដូចជា *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ* រួមទាំងកម្មវិធី និងយុទ្ធសាស្ត្រតាមវិស័យ ក៏នឹងផ្តល់នូវវិធីសាស្ត្រ និងការណែនាំអនុវត្តលើការងារកំណែទម្រង់ផងដែរ ។ *ផែនការសកម្មភាពអភិបាលកិច្ច* នឹងផ្តោតលើវិធីសាស្ត្រ ដែលក្រសួងស្ថាប័ន ត្រូវធ្វើការកែលម្អអភិបាលកិច្ចរបស់ខ្លួនចំពោះកិច្ចការដែលទាក់ទងទៅនឹងសេវាសាធាណៈ ។ ទន្ទឹមនឹងនេះ *ផែនការសកម្មភាពអភិបាលកិច្ចទី៣* ក៏នឹងចង្អុលបង្ហាញអំពីវិធីសាស្ត្រដែលក្រសួង-ស្ថាប័ន ត្រូវដំណើរការអនុវត្តការងារកំណែទម្រង់ (ដូចជា ការរៀបចំផែនការ ការចាត់ចែងអនុវត្ត ការគ្រប់គ្រង និង ការតាមដានត្រួតពិនិត្យវាយតម្លៃ) ដើម្បីឆ្លើយតបទៅនឹងប្រសិទ្ធភាពនៃការផ្តល់សេវាដែលបានរំពឹងទុក ។

## កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

៣៤៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញការអនុវត្ត គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការដាក់ចេញនូវវិធានការថ្មីៗថែមទៀត ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវ

*"ច្បាប់ស្តីពី ការគ្រប់គ្រង រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ"* ជាពិសេស ការរៀបចំនិងអនុវត្ត លិខិតបទដ្ឋាន ដែលពាក់ព័ន្ធ នឹងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិមករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យបានច្បាស់លាស់នូវ តួនាទី សិទ្ធិ អំណាច និងការធានាគណនេយ្យភាពក្នុងការបំពេញការងារ ព្រមទាំង ការកសាងសមត្ថភាពគ្រប់គ្រង និងការបែងចែកធនធានហិរញ្ញវត្ថុសមស្រប ដល់ថ្នាក់មូលដ្ឋាន ។ ច្បាប់នេះ នឹងត្រូវបានអនុវត្តជា ជំហានៗ ដោយប្រុងប្រយ័ត្ន ដោយក្រសួង-ស្ថាប័ននីមួយៗ ដោយត្រូវរៀបចំផែនការជាក់ស្តែងស្តីពី ការផ្ទេរប្រតិភូកម្មអំណាច និងមុខងារ ដល់ថ្នាក់ក្រោមជាតិ ។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ នឹងត្រូវបានអនុវត្តដោយភាពទន់ភ្លន់ និងតាមដំណាក់ៗ ក្នុងរយៈពេលមធ្យម ដើម្បីមានពេលគ្រប់គ្រាន់ក្នុងការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ *គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* នឹងរៀបចំកម្មវិធីជាតិ សម្រាប់អនុវត្ត ក្នុងរយៈពេល ១០ឆ្នាំ ។

៣៤៨. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និង ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ បច្ចុប្បន្ននេះ *គណៈកម្មាធិការជាតិសម្រាប់កាអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)* កំពុងរៀបចំកម្មវិធី សម្រាប់ការអនុវត្ត រយៈពេល១០ឆ្នាំ មានឈ្មោះថា*កម្មវិធីសម្រាប់អភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* ។ កម្មវិធីនេះ រួមមាន ៣ ដំណាក់កាល :

- *ដំណាក់កាលទី១ ដែលមានរយៈពេល៣ឆ្នាំ (២០១០-២០១២)* នឹងផ្តោតការយកចិត្តទុកដាក់លើ ការបង្កើត និង ការរៀបចំ រចនាសម្ព័ន្ធនិងក្របខ័ណ្ឌ អភិបាលកិច្ចល្អ នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។
- *ដំណាក់កាលទី២ ដែលមានរយៈពេល៣ឆ្នាំ (២០០១៣-ឆ្នាំ២០១៥)* នឹងផ្តោតការយកចិត្តទុកដាក់លើ ការរួមបញ្ចូលគ្នានិងការកែលម្អ រចនាសម្ព័ន្ធនិងក្របខ័ណ្ឌរដ្ឋបាល ដើម្បីធានាថា រដ្ឋបាលនៅថ្នាក់ក្រោមជាតិមានលទ្ធភាព បង្កើតនិងអនុវត្តគោលនយោបាយ សម្រាប់មូលដ្ឋានផ្ទាល់របស់ខ្លួន សំដៅធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាកម្មសាធារណៈ ។
- *ដំណាក់កាលទី៣ ដែលមានរយៈពេល ៤ឆ្នាំ (២០១៦-២០១៩)* នឹងផ្តោតការយកចិត្តទុកដាក់លើ ការផ្លាស់ប្តូរ សមាសធាតុនិងសកម្មភាពរបស់កម្មវិធី ដើម្បីធានាឱ្យសម្រេចបានសមិទ្ធផលធំជាងមុន និងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យបានល្អប្រសើរជាងមុន តាមរយៈ មេរៀន និង បទពិសោធន៍ ដែលដកស្រង់បាននៅក្នុងការអនុវត្ត នៅក្នុង ដំណាក់កាលទី១ និង ទី២ ។

## ១.៤ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

៣៤៩. *រាជរដ្ឋាភិបាលកម្ពុជា* បានអនុវត្តតាមផែនការនៃកម្មវិធីកំណែទម្រង់ និងបានពង្រីកសមត្ថភាពនៃកងកម្លាំងប្រដាប់អាវុធកម្ពុជា ។ នៅក្នុង *នីតិកាលទី៤ នៃរដ្ឋសភា* នេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តនូវកម្មវិធី

កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវអធិបតេយ្យ និងបូរណភាពទឹកដីនៃ *ព្រះរាជាណាចក្រកម្ពុជា* ព្រមទាំង សន្តិសុខនិងសណ្តាប់ធ្នាប់សង្គមនៅក្នុង *ព្រះរាជាណាចក្រកម្ពុជា* ។ ដោយផ្អែកលើធនធាន ការវិវត្តនៃសភាពការណ៍សន្តិសុខអន្តរជាតិ និង ស្ថានការណ៍ជាក់ស្តែងរបស់ *កម្ពុជា* កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ក្នុង *នីតិកាលទី ៤ នៃរដ្ឋសភា* នេះ នឹងផ្តោតលើ :

- ការបន្តពង្រឹងកងកម្លាំងប្រដាប់អាវុធ ឱ្យក្លាយទៅជាកងកម្លាំងមានវិជ្ជាជីវៈជំនាញ មានសមត្ថភាពក្នុងការបន្តវេន មានបច្ចេកវិទ្យា និង សម្ភារៈសមស្រប គោរពប្រតិបត្តិច្បាប់មុឺងម៉ាត់ គោរពសិទ្ធិមនុស្ស មានទឹកចិត្តស្មោះត្រង់ចំពោះ *ជាតិ សាសនា ព្រះមហាក្សត្រ* ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបូរណភាពទឹកដី និង ឧត្តមប្រយោជន៍ជាតិនិងប្រជាជន ព្រមទាំង ខិតខំពង្រឹងសីលធម៌សង្គម និង សីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើនជំនឿថែមទៀត មកលើកងកម្លាំងប្រដាប់អាវុធ ។
- *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញឱ្យបានកាន់តែប្រសើរថែមទៀត នូវកិច្ចសហប្រតិបត្តិការក្នុងចំណោមកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង រវាងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីបុព្វហេតុ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងឯកភាពជាតិ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញលើកកម្ពស់ប្រពៃណី នៃការផ្សារភ្ជាប់គ្នារវាងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាមួយប្រជាជន តាមរយៈ ការពង្រឹងសមត្ថភាពចូលរួមប្រតិបត្តិការសង្គ្រោះពេលមានគ្រោះមហន្តរាយ និង កិច្ចប្រតិបត្តិការមនុស្សធម៌ផ្សេងៗ រួមទាំង ការជួយប្រជាជនក្នុងការងារបង្កបង្កើនផលផងដែរ ។ ព្រមជាមួយគ្នានេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញកិច្ចសហប្រតិបត្តិការ ជាមួយសហគមន៍អន្តរជាតិ ដើម្បីរួមចំណែកការពារនិងថែរក្សា សន្តិភាពនិងសន្តិសុខជាអន្តរជាតិ ជាពិសេស ដើម្បីបង្ការទប់ស្កាត់និងបង្ក្រាបអំពើភេរវកម្ម និង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ មានជាអាទិ៍ ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និង បទល្មើសផ្សេងទៀត ។
- ការជំរុញការកសាងផែនការយុទ្ធសាស្ត្រ សម្រាប់កងកម្លាំងនគរបាលជាតិ សំដៅពង្រឹងប្រសិទ្ធភាពដឹកនាំបញ្ជាមានទិសដៅច្បាស់លាស់ ដោយធានាភាពសកម្មគ្រប់គ្រង ក្នុងការបំពេញមុខងារ ព្រមទាំង ពង្រឹងប្រសិទ្ធភាព ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និង ធនធានផ្សេងទៀត ។ ទន្ទឹមនឹងនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញការកសាង *ច្បាប់ស្តីពីនគរបាលជាតិ* ដែលជាច្បាប់គោលមួយកំណត់ពី សិទ្ធិ កាតព្វកិច្ច ករណីយកិច្ច និង ការទទួលខុសត្រូវ របស់នគរបាលជាតិទាំងមូល ។

## ២. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល

៣៥០. បរិស្ថានគ្របដណ្តប់ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល រួមមាន ៤ផ្នែក គឺ : *(១) សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម (២) សមាហរណកម្មប្រទេសកម្ពុជាក្នុងតំបន់និងពិភពលោក (៣) ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ* និង *(៤) បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ*។

## ២.១ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៥១. នៅក្នុង*នីតិកាលទី៣ នៃរដ្ឋសភា* កន្លងទៅនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានពង្រឹងនូវ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ដើម្បីសម្រេចបាននូវ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ ។ ជាលទ្ធផល *ប្រទេសកម្ពុជា* បានបង្កើនជំនឿទុកចិត្តពី សំណាក់វិនិយោគិន និង ទេសចរ ដែលត្រូវបានឆ្លុះបញ្ចាំងឡើង តាមរយៈ ការកើនឡើងនៃការដាក់ទុនវិនិយោគ និង ការកើនឡើងនៃចំនួនភ្ញៀវទេសចរ ដែលចូលមកទស្សនាប្រទេសកម្ពុជា ។ ទន្ទឹមនឹងនេះ *ប្រជាជនកម្ពុជា* អាចរស់នៅប្រកបរបរអាជីវកម្មតាមធម្មតា និង ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងសកម្ម តាមសមត្ថភាពរៀងៗខ្លួន ។ ការអភិវឌ្ឍនេះបានក្លាយទៅជាមូលដ្ឋានគ្រឹះនៃការពង្រឹង សុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម សម្រាប់រយៈពេលដ៏យូរអង្វែង ។

៣៥២. នៅក្នុង *នីតិកាលទី៤ នៃរដ្ឋសភា* នេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងគោលដៅបន្តពង្រឹងថែមទៀតនូវ សុខសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ជូនដល់ប្រជាពលរដ្ឋ ដើម្បីធានាពង្រឹងលក្ខខណ្ឌគ្រឹះនៃការកសាង និងកែទម្រង់រដ្ឋ សម្រាប់ការបោះជំហានរបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍ និងភាពកាន់តែចម្រើនរុងរឿងខាងមុខ ។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដើម្បីពង្រឹងសន្តិសុខ និង កាត់បន្ថយឱ្យបានច្រើននូវ ឧក្រិដ្ឋកម្ម និងបទល្មើសផ្សេងៗ ពង្រឹង *"នីតិរដ្ឋ"* ពង្រឹងការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដែលផ្តល់នូវកាលានុវត្តភាព ប្រកបដោយសមធម៌ ជូនប្រជាជនគ្រប់រូប ។

### ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៣៥៣. នៅក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន លើការងារ ស៊ីវិល និង ការងារនគរបាល *ក្រសួងមហាផ្ទៃ* បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានាឱ្យមាននូវស្ថានភាពមួយ ដែលមាន សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។ ដើម្បីអនុវត្តគោលនយោបាយអាទិភាព ទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ* នឹងផ្តោតការយកចិត្តទុកដាក់លើ ការពង្រីកសមត្ថភាពស្ថាប័ន នៅ ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយ ប្រកបដោយប្រសិទ្ធភាព នូវបញ្ហាដែលកំពុងលេចឡើង និង ដើម្បីធ្វើឱ្យប្រសើរឡើង នូវ ការទទួលបានសេវាកម្ម សាធារណៈ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន លើការងារស៊ីវិល និង ការងារនគរបាល ។ *ក្រសួងមហាផ្ទៃ* នឹងរៀបចំ*អនុក្រឹត្យថ្មីមួយ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ* និង កែសម្រួលបទបញ្ជាផ្ទៃក្នុង ដើម្បីធានាថា មន្ត្រី ស៊ីវិលនិងប៉ូលីស របស់ខ្លួន បំពេញតួនាទីភារកិច្ច ដោយប្រកាន់ខ្ជាប់នូវ វិន័យ អព្យាក្រឹត្យភាព ក្រមសីលធម៌ និង ការគោរពតាមបទបញ្ជា ។

៣៩៤. ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ *ក្រសួងមហាផ្ទៃ* បាននឹងកំពុងអនុវត្ត កម្មវិធីសាកល្បង *"សេវាកម្មច្រកចេញចូលតែមួយ"* នៅថ្នាក់ស្រុក នៅក្នុង ខេត្ត ២ សៀមរាប និង បាត់ដំបង ។ នៅក្នុងកម្មវិធីនេះ *ក្រសួងមហាផ្ទៃ* បានកំណត់ *"តំណាងស្រុក"* ដែលមានភារកិច្ច ទទួលលិខិតទិទៀនពី ប្រជាជន សហគមន៍ អង្គការសង្គមស៊ីវិល និង មន្ត្រីស្រុក ។ *ក្រសួងមហាផ្ទៃ* នឹងពង្រីកជាបន្តបន្ទាប់ នូវការគ្របដណ្តប់របស់កម្មវិធីនេះ ឱ្យបានគ្រប់ខេត្តទាំង ២៣ និង រាជធានី ។

៣៩៥. *ក្រសួងមហាផ្ទៃ*នឹងបន្តអនុវត្ត*គម្រោងសិទ្ធិទទួលបានយុត្តិធម៌*រវាង *ក្រសួងមហាផ្ទៃ* និង *ក្រសួងយុត្តិធម៌* ។ នៅក្នុងគម្រោងនេះ *មជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌* ចំនួន ២០ នៅថ្នាក់ស្រុក ត្រូវបានបង្កើតឡើង នៅក្នុងស្រុក *គងពិសី ភ្នំស្រួច បាសិទ្ធ៍ និង ឧត្តុង្គ នៃខេត្តកំពង់ស្ពឺ - ស្រុកទឹកផុស កំពុងលែង បរិបូរ និង កំពង់ត្រឡាច នៃខេត្តកំពង់ឆ្នាំង - ស្រុក សៀមរាប សូត្រនិគម បន្ទាយស្រី ពួក ប្រាសាទបាគង្គ និង ស្វាយលើ នៃខេត្តសៀមរាប ស្រុក សែនមនោរម្យ និង កោះញែក នៃខេត្តមណ្ឌលគិរី* និង *ស្រុក បានលុង និង អូរយ៉ាដាវ នៃខេត្តរតនគិរី* ។

៣៩៦. *ក្រសួងមហាផ្ទៃ* នឹងបន្ត កែលម្អពន្ធនាគារឱ្យបានសមស្របទៅតាមស្តង់ដារអន្តរជាតិ ដោយធ្វើការជួសជុលអគារទ្រុឌទ្រោម និងធ្វើការបំពាក់សំភារៈបរិក្ខា ឱ្យមានសមាមាត្រទៅនឹង ការកើនឡើងនៃចំនួនអ្នកទោស និង ដំណើរការសាងសង់ពន្ធធាគារថ្មី នៅខេត្ត ក្រចេះ កំពង់ចាម បាត់ដំបង ពោធិសាត់ មណ្ឌលគិរី ស្ទឹងត្រែង កំពង់ធំ ព្រៃវែង និង រតនគិរី ព្រមទាំង សាងសង់*មជ្ឈមណ្ឌលអប់រំកែប្រែទី៤* ដែលជាប្រភេទ*ពន្ធនាគារកសិកម្ម* នៅក្នុងខេត្តពោធិ៍សាត់ ។ *ក្រសួងមហាផ្ទៃ* នឹងផ្តោត ការយកចិត្តទុកដាក់លើ ការអប់រំកែប្រែ និង ការស្តារនីតិសម្បទាពិរុទ្ធជន-ទណ្ឌិត តាមរយៈ ការលើកកម្ពស់ សុខភាព ជីវភាព ដោយអនុវត្តតាម ក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ របស់*រាជរដ្ឋាភិបាលកម្ពុជា* និង នីតិវិធីនៃការគ្រប់គ្រងពន្ធនាគារ ឧស្សាហកម្មនិងកសិកម្ម រួមទាំងការយកចិត្តទុកដាក់លើ ការអប់រំផ្នែក ស្មារតី គុណធម៌ សមធម៌ ដើម្បីប្រែក្លាយពួកគេ ឱ្យទៅជាពលរដ្ឋល្អ ដែលមានជំនាញអាជីព នៅពេលត្រឡប់ទៅរស់នៅក្នុងសហគមន៍វិញ បន្ទាប់ពីពេលផុតទោស ។ *ក្រសួងមហាផ្ទៃ* នឹងរៀបចំ*ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃមន្ត្រីអនុរក្សពន្ធនាគារ* និង បន្តសហការល្អជាមួយអាជ្ញាធរ រាជធានី-ខេត្តដែលពាក់ព័ន្ធ រួមទាំង អង្គការក្រៅរដ្ឋាភិបាល សំដៅពង្រឹង ការអនុវត្តច្បាប់ និង ការគោរពសិទ្ធិមនុស្ស នៅពន្ធនាគារ ។

៣៩៧. *ក្រសួងមហាផ្ទៃ* នឹងបន្តពង្រឹងកងកម្លាំងនគរបាលជាតិ ឱ្យទៅជា កងកម្លាំងមួយដែល មានវិជ្ជាជីវៈជំនាញពិតប្រាកដបំពាក់ដោយបច្ចេកវិទ្យាទំនើប មានអត្តចរិកសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវ គោរពប្រតិបត្តិច្បាប់ និង មានគោលជំហរ គោរពសិទ្ធិមនុស្ស រក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិតទ្រព្យសម្បត្តិរបស់ប្រជាជន និង បម្រើសេវាជូនប្រជាពលរដ្ឋដោយស្មោះត្រង់ ។ *ក្រសួងមហាផ្ទៃ* នឹងបន្តពង្រឹង នគរបាលនៅតាមប៉ុស្តិ៍រដ្ឋបាល ក្រោមប្រធានបទ *"នគរបាលនិងសហមន៍"* ។ ទន្ទឹមនឹងនេះ *ក្រសួងមហាផ្ទៃ* អនុញ្ញាតឱ្យ សិស្ស-និស្សិត ចូលមកសិក្សានៅ *បណ្ឌិតសភានគរបាលកម្ពុជា* ដើម្បីធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញនគរបាល ហើយ អនុញ្ញាតឱ្យពួកគេ ប្រឡងចូលក្របខ័ណ្ឌមន្ត្រីនគរបាល ទៅតាមតម្រូវការ

ប្រចាំឆ្នាំនីមួយៗរបស់ក្រសួង ។ *ក្រសួងមហាផ្ទៃ* ក៏បានប្រគល់ភារកិច្ចជូន *បណ្ឌិតសភានគរបាលជាតិកម្ពុជា* ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ អនុរក្សពន្ធនាគារ និង ឆ្មាំក្រឹតការ សុក្រឹតការ ដល់ មន្ត្រីនិងថ្នាក់ដឹកនាំពន្ធនាគារគ្រប់លំដាប់ថ្នាក់ ។

## ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន

៣៥៨. *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* នឹងបន្តដឹកនាំការអនុវត្តឱ្យមានប្រសិទ្ធភាពនូវ យុទ្ធសាស្ត្រទាំង៥ របស់ *ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន* ដែលរួមមាន : (១) ការកាត់បន្ថយតម្រូវការ (២) ការកាត់បន្ថយការផ្គត់ផ្គង់ (៣) ការព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម (៤) ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ និង (៥) កិច្ចសហប្រតិបត្តិការអន្តរជាតិ ។ ការអនុវត្ត យុទ្ធសាស្ត្រទាំង៥ នេះ នឹងផ្តោតលើ :

- ការបង្កើនការយល់ដឹងជាសារធារណៈ អំពីគ្រោះថ្នាក់នៃគ្រឿងញៀន ជាពិសេស នៅតាម ចំណុចគោលដៅដែលមានការប្រឈមខ្ពស់ និងមុខសញ្ញាងាយរងគ្រោះ ដោយប្រើប្រាស់វិធានការផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាពជាប្រចាំនិងចំគោលដៅ និងដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ ក្នុងនោះដូចជា បណ្តាអង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា សប្បុរសជននានា សំដៅកាត់បន្ថយតម្រូវការគ្រឿងញៀន ។
- ការលើកកម្ពស់សមត្ថភាពរបស់អង្គភាពអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំងពួកឧក្រិដ្ឋជនជួញដូរគ្រឿងញៀនឆ្លងដែន ដោយសហការយ៉ាងជិតស្និទជាមួយ ដៃគូពាក់ព័ន្ធ ព្រមទាំងចាត់វិធានការគ្រប់បែបយ៉ាង តាមផ្លូវច្បាប់ ដើម្បីប្រឆាំង ការដាំដុះ ការផលិត ការកែច្នៃ ការចរាចរ ការជួញដូរ ការចែកចាយ ការស្តុកទុក និងការប្រើប្រាស់គ្រឿងញៀន តាមគ្រប់រូបភាព ព្រមទាំង ពង្រឹងការយល់ដឹង សមត្ថភាព ឆន្ទៈ គុណធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវនៃស្ថាប័នអនុវត្តច្បាប់ ឱ្យកាន់តែមានគុណភាព ដើម្បីកាត់បន្ថយនូវភាពអសកម្មនានា ក្នុងការអនុវត្ត *ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន* ។
- ការជំរុញការរៀបចំបង្កើត *មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន* ដែលមានតួនាទីភារកិច្ចក្នុង ការព្យាបាល ស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំង ការធ្វើសមាហរណកម្មអ្នកជាសះស្បើយពីគ្រឿងញៀន ទៅក្នុងគ្រួសារនិងសហគមន៍វិញ ដោយរៀបចំឱ្យមានឯកសារគោល-នយោបាយជាតិស្តីពី *ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន តម្រូវការអប្បបរមាសម្រាប់ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន* និង *បទដ្ឋានវេជ្ជសាស្ត្រសម្រាប់ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន* ដើម្បីធានានិរន្តរភាពរបស់មជ្ឈមណ្ឌលជាតិ ។

- ការពង្រឹងសេវាសុខភាពនៅតាមមណ្ឌលបណ្ដោះអាសន្ន ដែលមាននាពេលបច្ចុប្បន្ន ដោយរដ្ឋនឹងផ្ដល់ការគាំទ្រសម្រាប់ចំណាយចរន្តនៅក្នុងមណ្ឌល ។
- ការកំណត់គោលដៅអាទិភាពមួយចំនួន សម្រាប់ធ្វើសកម្មភាពឱ្យបានខ្លាំងក្លា ដើម្បីធ្វើឱ្យមានសាលារៀនគំរូ សហគមន៍គំរូ នៅតាម បណ្ដា ក្រុង ស្រុក ខណ្ឌ នីមួយៗ និង ភូមិគំរូនៅតាមព្រំដែន ដែលគ្មានគ្រឿងញៀន ។
- ការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធ នានា ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងធ្វើការណែនាំដល់ស្ថាប័នត្រួតពិនិត្យគ្រឿងញៀនថ្នាក់ក្រោមជាតិ ឱ្យរៀបចំបង្កើតក្រុមពិគ្រោះយោបល់ នៅតាមឃុំ/សង្កាត់ សម្រាប់ប្រឹក្សាផ្ដល់យោបល់ និងធ្វើទំនាក់ទំនាក់ទំនងសហការជាមួយស្ថាប័នរដ្ឋ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក វត្តអារាម អង្គការសង្គមស៊ីវិល និង សប្បុរសជននានា ដើម្បីជួយសម្រួលនិងដោះស្រាយបញ្ហាគ្រឿងញៀន នៅក្នុងសហគមន៍មូលដ្ឋាន នៅតាមបណ្ដាឃុំ-សង្កាត់គោលដៅនានា ។
- ការជំរុញការរៀបចំសេចក្ដីព្រាងច្បាប់ថ្មីស្ដីពី ការត្រួតពិនិត្យគ្រឿងញៀន ដើម្បី ទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៅក្នុងឆ្នាំ២០១០ ។

៣៥៩. ដើម្បីពង្រឹងតម្លៃរបស់គ្រួសារនិងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំសង្គមកម្ពុជា *ក្រសួងធម្មការនិងសាសនា* នឹងបន្តជំរុញលើកកម្ពស់យ៉ាងសកម្មនូវ តួនាទីរបស់គ្រួសារ និងការផ្សារភ្ជាប់ទៅនឹងតម្លៃជាប្រពៃណីនៃសាសនា របស់ *ព្រះរាជាណាចក្រកម្ពុជា* ។ ដើម្បីអនុវត្តតាមគំនិតផ្ដួចផ្ដើម របស់ **សម្ដេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** *ក្រសួងធម្មការនិងសាសនា* បានបង្កើតកម្មវិធី *"នាទីព្រះពុទ្ធ-សាសនា ផ្សារភ្ជាប់នឹងសង្គម"* សំដៅបញ្ជ្រាបការអប់រំផ្នែកព្រះពុទ្ធសាសនា ទៅក្នុងស្រទាប់មហាជនទូទៅ ដើម្បីបង្កើនការយល់ដឹងពីតម្លៃសីលធមិរស់នៅល្អក្នុងសង្គម និង ដើម្បីចៀសផុតពី ការប្រើប្រាស់គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ អំពើអនាចារ ការកេងប្រវ័ញ្ចផ្លូវភេទ និង ក្មេងទំនើងក្នុងស្រទាប់យុវវ័យ ។ ក្រសួង បានរៀបចំកម្មវិធីនេះចំនួន ៤លើក ដែលត្រូវបានផលិតជា វីស៊ីឌី និង ឌីវីឌី ហើយត្រូវបានចាក់ផ្សាយតាមវិទ្យុនិងទូរទស្សន៍ ជារៀងរាល់ថ្ងៃផងដែរ ។ ទន្ទឹមនឹងនេះ *ក្រសួងធម្មការនិងសាសនា* ក៏បានជំរុញលើកទឹកចិត្តឱ្យសាសនាដ៏ទៃទៀត បានចូលរួមចំណែកយ៉ាងសកម្ម នៅក្នុងការពង្រឹងនិងលើកកម្ពស់សីលធមិរស់នៅល្អ ក្នុងសង្គម ផងដែរ ។

៣៦០. ជាមួយគ្នានេះដែរ នៅក្នុងនីតិកាលទី៤ នៃ *រដ្ឋសភា* នេះ *ក្រសួងធម្មការនិងសាសនា* នឹងពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សា តាំងពីកម្រិតបឋមសិក្សា រហូតដល់ឧត្ដមសិក្សា តាមរយៈ ការបណ្ដុះបណ្ដាលសមណសិស្សនិងនិស្សិតនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សានានា ដែលមាន ក្នុងពេលបច្ចុប្បន្ននេះ តាំងពី កម្រិតបឋមសិក្សា រហូតដល់ ឧត្ដមសិក្សា មានចំនួនសរុប ៥១៥ ក្នុងនោះរួមមាន (១) សាលាពុទ្ធិកបឋមសិក្សា មានចំនួន ៤៧០ (២) ពុទ្ធិកអនុវិទ្យាល័យ

មានចំនួន ២៩ និង ពុទ្ធិកវិទ្យាល័យ មានចំនួន ១៤ និង (៣) ពុទ្ធិកសាកលវិទ្យាល័យ ចំនួន ២ ដែលមានពុទ្ធិកមហាវិទ្យាល័យសរុបចំនួន ១២ នៅភ្នំពេញ និងនៅខេត្តចំនួនបី ។ សមណសិស្សនិងនិស្សិត ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានពុទ្ធិកសិក្សាទាំងនេះ មានចំនួនសរុប ១៨ ៧៧១ អង្គ ។ ពុទ្ធិកមហាវិទ្យាល័យ នៅខេត្តបាត់ដំបងនិង ខេត្តកំពង់ចាម នឹងត្រូវបង្កើតទៅជាពុទ្ធិកសកលវិទ្យាល័យ នៅឆ្នាំ២០១០ ហើយពុទ្ធិកមហាវិទ្យាល័យនៅខេត្តកំពង់ឆ្នាំង នឹងត្រូវបង្កើតទៅជាពុទ្ធិកសកលវិទ្យាល័យ នៅឆ្នាំ២០១១ ឬ ២០១២ ។

## ២.២ សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៦១. នៅក្នុង*នីតិកាលទី៣ នៃរដ្ឋសភា* កន្លងមក *កម្ពុជា* បានចូលរួមដោយស្មើភាព និង ស្មើសិទ្ធិ ជាសមាជិកនៅក្នុង*អាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក* ព្រមទាំង បានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមនានា ក្នុងកម្រិតអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ជាពិសេស *កិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចាវប្រាយ៉ា-មេគង្គ (អ៊ិកម៉ិក) កិច្ចសហប្រតិបត្តិការត្រីកោណ ក្នុងកម្រិតអនុតំបន់ដទៃទៀត និង កិច្ចប្រជុំ អាស៊ី-អឺរ៉ុប (អាសិម)* ជាដើម ។ ដំណើរការសមាហរណកម្មសេដ្ឋកិច្ច*កម្ពុជា* នៅក្នុងតំបន់ និងពិភពលោក និង ការអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ បានបង្កើតបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍវិស័យ កសិកម្ម ទេសចរណ៍ និងឧស្សាហកម្ម ជាពិសេស ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និង បានបង្កលក្ខណៈសម្បត្តិឱ្យកសិករកម្ពុជា អាចនាំចេញផលិតផលរបស់ខ្លួន ទៅលក់នៅលើទីផ្សារ តំបន់ និងអន្តរជាតិ ។ ទន្ទឹមនេះ សមាជិកភាពរបស់កម្ពុជានៅក្នុង *អង្គការពាណិជ្ជកម្មពិភពលោក* បាននាំមកនូវឱកាសសមស្រប ឱ្យកម្ពុជារៀបចំកំណែទម្រង់ផ្ទៃក្នុង ហើយបានទាក់ទាញការវិនិយោគទុន ក្នុងស្រុក និងពីបរទេស និង បានពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅ*កម្ពុជា* ។

៣៦២. ដោយពាណិជ្ជកម្ម គឺជាប្រភពសំខាន់ នៃកំណើនសេដ្ឋកិច្ច និងសម្រាប់ការកាត់បន្ថយភាពក្រីក្រ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តដំណើរទៅមុខយ៉ាងស្វាហាប់ នៅលើមាគ៌ានៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាឱ្យទំនិញនិងសេវាគ្រប់ប្រភេទ អាចចរាចរបានដោយសេរីនៅក្នុងទូទាំងប្រទេស និង រវាងប្រទេសកម្ពុជា និងប្រទេសជាដៃគូសំខាន់ៗ នៅក្នុងតំបន់ និងសកលលោក ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តបើកច្រកឱ្យផលិតផលកម្ពុជា ឱ្យអាចឈានចូលដោយគ្មានរបាំង និងឧបសគ្គនានា ទៅកាន់ទីផ្សារធំៗ នៅក្នុងតំបន់ និងក្នុងពិភពលោក ដែលនឹងផ្តល់ឱ្យកម្ពុជា នូវកាលានុវត្តភាពនៃ *"វិមាត្រសេដ្ឋកិច្ច"* ដ៏ធំធេង និងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជា

កំណើននៃការវិនិយោគ កំណើននៃការងារ កំណើននៃប្រាក់ចំណូល និង កំណើននៃសេដ្ឋកិច្ចជាតិទាំងមូល ដែលសុទ្ធតែជាកត្តាដ៏សំខាន់ សម្រាប់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៣៦៣. ក្នុងស្មារតីនេះ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងផ្តល់អាទិភាពលើការបន្តធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ តាមរយៈ ការជំរុញការងារចូលជាសមាជិក នៃ *អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (អេប៉ិក)* និងការចូលរួមកសាង*សហគមន៍អាស៊ាន* ។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ឱ្យយកចិត្តទុកដាក់ ក្នុងការបំពេញកាតព្វកិច្ចនៃសមាជិកភាពរបស់កម្ពុជា ក្នុង*អង្គការពាណិជ្ជកម្មពិភពលោក* តាមរយៈ ការរៀបចំអនុម័ត និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ទាំងឡាយ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៣៦៤. ដើម្បីអនុវត្តគោលនយោបាយអាទិភាពសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា *រាជរដ្ឋាភិបាលកម្ពុជា* នឹង បន្តពង្រឹងការសម្របសម្រួលអន្តរក្រសួង អនុម័តច្បាប់និងលិខិតបទដ្ឋានចាំបាច់នានា ដើម្បីបំពេញនូវកាតព្វកិច្ចជាសមាជិកនៃអង្គការអន្តរជាតិនិងក្នុងតំបន់ ថែមទាំង ការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនានា របស់*រាជរដ្ឋាភិបាលកម្ពុជា* ដើម្បីគ្រប់គ្រង និងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋាននានា ឱ្យមានប្រសិទ្ធភាព ។

៣៦៥. ដើម្បីជំរុញការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់ឱ្យទទួលបានទីផ្សារក្នុងតំបន់ និងជំរុញការធ្វើពាណិជ្ជកម្ម *រាជរដ្ឋាភិបាលកម្ពុជា* នឹង :

- ចូលរួមក្នុងកិច្ចពិភាក្សា/ចរចារ ដើម្បីបានក្លាយជាសមាជិក *វេទិកាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក* និងបន្តចូលរួមក្នុងការកសាងសមាគម *អាស៊ាន* និង *បណ្តាញអាស៊ីអាគ្នេយ៍* ។
- ជំរុញយ៉ាងសកម្មក្នុងការបង្កើត *អាស៊ានបូកចិន អាស៊ានបូកកូរ៉េ អាស៊ានបូកអូស្ត្រាលី ញូស្ហេឡង់* ព្រមទាំងការបង្កើត *មជ្ឈមណ្ឌល អាស៊ានបូកចិន និង បូកកូរ៉េ* ។
- ចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត *យុទ្ធសាស្ត្រមហាអនុតំបន់ទន្លេមេគង្គ យុទ្ធសាស្ត្រសហប្រតិបត្តិការ អាយ៉េយ៉ាវ៉ាដាវ៉-ចាវប្រ៉ាយ៉ា* ដែលផ្តោតលើ ការអភិវឌ្ឍការវិនិយោគឆ្លងកាត់ព្រំដែន ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងការវិនិយោគនៅតាមបណ្តោយព្រំដែន ។
- ចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍគន្លងសេដ្ឋកិច្ច តាមរយៈ *វេទិកាគន្លងសេដ្ឋកិច្ចរបស់មហាអនុតំបន់ទន្លេមេគង្គ* ជានឹងការចូលរួមយ៉ាងសកម្មនៃវេទិកាអភិបាលខេត្ត និងធានាការស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលត្រូវការសម្រាប់គាំទ្រដល់ ការអភិវឌ្ឍគន្លងសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គ ដើម្បីជំរុញការអភិវឌ្ឍតំបន់ដាច់ស្រយាល ។

## ២.៣ បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៦៦. *រាជរដ្ឋាភិបាលកម្ពុជា* បានទទួលជោគជ័យក្នុងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ១១,១ភាគរយ ពីអំឡុងឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៧ ខ្ពស់ជាងចំណុចដៅដែលបានគ្រោងទុក ៦ ទៅ ៧ភាគរយ ក្នុងមួយឆ្នាំ ។ ប្រការនេះ បានធ្វើឱ្យចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ បានកើនឡើងពី ៤០២ ដុល្លារ ក្នុងឆ្នាំ២០០៤ ដល់ ៦២៣ដុល្លារ ក្នុងឆ្នាំ២០០៧ ។ ទុនបម្រុងបរទេស ក៏មានការកើនឡើងជិតទ្វេដង ដល់ ២,១៦៤ពាន់លានដុល្លារ នៅពាក់កណ្តាលឆ្នាំ២០០៨ ។ ព្រមជាមួយគ្នានេះ អតិផរណាត្រូវបានរក្សាឱ្យនៅក្នុងកម្រិតអាចគ្រប់គ្រងបាននៅក្រោមកម្រិត ៦ភាគរយ ក្នុងមួយឆ្នាំ ហើយអត្រាប្តូរប្រាក់ ជាទូទៅ មានស្ថិរភាពល្អ ។ ការហូរចូលការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងជាង ៦ ដង ពោលគឺ ពី ១៣១លានដុល្លារ ក្នុងឆ្នាំ២០០៤ ដល់ ៨៦៧លានដុល្លារ ក្នុងឆ្នាំ២០០៧ ។ បន្ទាប់ពីការដាក់ឱ្យអនុវត្ត*កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ចំណូលថវិកាបានកើនឡើងជាមធ្យម ២៦ភាគរយ ក្នុងមួយឆ្នាំ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានកែប្រែស្ថានភាពនៃការអនុវត្តថវិកា ពី*ភាពរ៉ាំរ៉ៃនៃឱនភាពសាច់ប្រាក់* មកជាមាន *អតិរេកសាច់ប្រាក់* ដោយធ្វើឱ្យថវិកាកាន់តែអាចជឿទុកចិត្តបាន ។ ទន្ទឹមនេះ *រាជរដ្ឋាភិបាលកម្ពុជា* បានអនុវត្តដោយជោគជ័យនូវផែនការសកម្មភាព ដែលបានដាក់ចេញនៅក្នុង "*ទស្សនវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០១-២០១០*" ដែលក្រោយមក ត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា "*យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥*" ។

៣៦៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តព្យាយាម ដើម្បីសម្រេចឱ្យបាន នូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរង្វង់ ៧ភាគរយ ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបក្នុងកម្រិតតួលេខតែមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ ។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តនូវគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈ ដោយប្រុងប្រយ័ត្ន ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស លើ វិធានការរួមជាកញ្ចប់ ដើម្បីពិនិត្យមើលអតិផរណា និងផលប៉ះពាល់របស់វាលើថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋានសំខាន់ៗ ដូចជា ម្ហូបអាហារ និង ប្រេងឥន្ធនៈ ជាដើម ដោយការអនុវត្តវិធានការសន្សំសំចៃនិងសនិទានកម្មនៃការប្រើប្រាស់ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងបណ្តាញចែកចាយថាមពល ដែលអាចកាត់បន្ថយថ្លៃដើម និងលើកកម្ពស់ ផលិតភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងបង្កើនការវិនិយោគដើម្បីជំរុញផលិតភាពកសិកម្ម ក្នុងគោលដៅឆ្លើយតប ប្រកបដោយប្រសិទ្ធភាព ទៅនឹងការកើនឡើងនៃថ្លៃម្ហូបអាហារ និងក្នុងគោលដៅឆក់យកឱកាសនៃការកើនឡើង នូវសេចក្តីត្រូវការស្បៀងនៅក្នុងពិភពលោក ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ។

៣៦៨. ដើម្បីធានាស្ថិរភាពកំណើនសេដ្ឋកិច្ចខ្ពស់ ដែលជាបុរេលក្ខខណ្ឌនៃការបង្កើតការងារ និងបង្កើនចំណូលរបស់ប្រជាជន *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញអនុវត្តវិធានការធ្វើពិពិធភាវូបនីយកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា តាមរយៈ ការបង្កើតបរិស្ថានអនុគ្រោះដល់ការវិនិយោគ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន (ទាំងក្នុងស្រុក និងទាំងបរទេស) សម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ ដូចជា (១) កសិកម្ម (២) ទឹកនិងប្រព័ន្ធស្រោចស្រព (៣) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (៤) អគ្គិសនី (៥) ការអភិវឌ្ឍធនធានមនុស្ស (៦) ឧស្សាហកម្ម អតិពលកម្ម និងឧស្សាហកម្មផលិតទំនិញនាំចេញ (៧) ទេសចរណ៍ (៨) អាជីវកម្មប្រេងកាតឧស្ម័នធម្មជាតិ និងរ៉ែ ដទៃទៀត (៩) បច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ (១០) ពាណិជ្ជកម្ម ។

៣៦៩. *រាជរដ្ឋាភិបាលកម្ពុជា* នឹងពង្រឹងវិស័យហិរញ្ញវត្ថុបន្ថែមទៀត តាមរយៈ ការជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវ *"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥"* ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស លើ វិស័យធនាគារ ឥណទានជនបទ និងមីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រង និងទីផ្សារមូលបត្រ រួមទាំងការជំរុញការបង្កើតមជ្ឈមណ្ឌលហិរញ្ញវត្ថុពិសេស ដើម្បីកៀរគរធនធានប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ ។

៣៧០. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវ *"កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"* ជាពិសេស ដំណាក់កាលទី២ នៃកម្មវិធីនេះ ដើម្បីពង្រឹងប្រសិទ្ធភាពថវិកាជាតិ ដែលជាឧបករណ៍គន្លឹះ ក្នុងការអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍របស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ការអនុវត្តដំណាក់កាលទី២ ដែលបានគ្រោងឡើង នឹងជួយបង្កើតនូវបរិយាកាសទទួលខុសត្រូវ លើការគ្រប់គ្រងធនធានសាធារណៈគ្រប់កម្រិតក្នុងផ្នែករដ្ឋបាល ។ ចំណុចខ្លាំងនិងខ្សោយ នៃការគ្រប់គ្រងធនធានទាំងនោះ នឹងត្រូវបានទទួលស្គាល់ និងធ្វើឱ្យឃើញពីភាពខុសគ្នា ។ លទ្ធផលនៃការផ្លាស់ប្តូរក្នុងដំណាក់កាលនេះ គឺ ជាមូលដ្ឋានមួយដែលត្រូវបានរៀបចំឡើងសម្រាប់ការអភិវឌ្ឍនៅជំហានបន្ទាប់ តាមរយៈ (ក) ប្រើប្រាស់អ្វីដែលសម្រេចបានក្នុងជំហានដំបូងៗ ដើម្បីឈានទៅផ្តល់អំណាចច្រើនជាងមុន ទៅឱ្យថ្នាក់ ដឹកនាំនៃស្ថាប័នចំណាយ ដើម្បីសម្រេចបានលទ្ធផលប្រសើរជាងមុន ដោយសារ ក្របខ័ណ្ឌនៃការត្រួតពិនិត្យ ក្នុងការផ្តល់អំណាចនឹងត្រូវបានកែលម្អ ហើយយើងនឹងមានបទពិសោធន៍ជាបណ្តើរៗ (ខ) ចាប់ផ្តើមកំណត់ការងារកាត់តម្រឹម រវាងការអនុវត្តគោលនយោបាយ និងការកែលម្អសេវាកម្មដោយប្រើប្រាស់ធនធានចាំបាច់ ដើម្បីសម្រេចការងារកែលម្អនេះ ដោយសារយើងមានមូលដ្ឋានព័ត៌មាន និងការវិភាគគ្រប់គ្រាន់អំពីការប្រើប្រាស់ធនធាន និង (គ) ឈានទៅរកគណនេយ្យភាព ក្នុងការចាត់ចែងផលដែលសម្រេចបាន ដោយពឹងផ្អែកលើការបង្កើនគណនេយ្យភាព ក្នុងការចាត់ចែងធនធាន ។ ដំណាក់កាលទី២ នេះ ផ្តោតជាពិសេស លើ :

- ការកែលម្អ និង ការធ្វើឱ្យមានភាពជឿជាក់កាន់តែខ្លាំងឡើងនៃថវិកា តាមរយៈ ការកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល ការគ្រប់គ្រងបំណុល ការគ្រប់គ្រងគណនីធនាគារនិងសាច់ប្រាក់ និងការគ្រប់គ្រងលទ្ធកម្មសាធារណៈ ។
- ការកែលម្អភាពជឿជាក់នៃថវិកា ឱ្យឈានទៅដល់ ការសម្រេចបាននូវគណនេយ្យភាពហិរញ្ញវត្ថុ ដែលអាចធ្វើឱ្យប្រសើរឡើង តាមរយៈ ការកែលម្អបន្ទាត់គណនេយ្យភាព ដែលជាឧបករណ៍សម្រាប់ជំរុញឱ្យមានការទទួលខុសត្រូវចំពោះ ការគ្រប់គ្រងហិរញ្ញវត្ថុ ការពង្រឹងគណនេយ្យភាព ការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ដំណើរការនិងប្រតិបត្តិការអនុវត្ត ថវិកា ប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាឱ្យមាន តម្លាភាពនៃសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ និង ការកសាងសមត្ថភាពដល់ស្ថាប័ននិងវិធានការលើកទឹកចិត្ត ។
- ការត្រៀមរៀបចំការងារជាមូលដ្ឋាន សម្រាប់ជំហានបន្តទៀត តាមរយៈ ការពង្រឹងនិងពង្រីកនូវការអនុវត្តថវិកាកម្មវិធី និង ការធ្វើឱ្យប្រសើរឡើងនូវភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មនៃថវិកា ។

៣៧១. *រាជរដ្ឋាភិបាលកម្ពុជា* ប្តេជ្ញាគ្រប់គ្រងប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និងមានគណនេយ្យភាព នូវចំណូលដែលទទួលបាន មកពីការធ្វើអាជីវកម្មលើធនធានរ៉ែ និង ប្រេងកាតនិងឧស្ម័ន ។

### ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៣៧២. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* (មានបង្ហាញជូនក្នុងជំពូកទី៣) គូសបញ្ជាក់ពីសកម្មភាព ដែល *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* នឹងអនុវត្តនូវគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ។

## ២.៤ ភាពជាដៃគូក្នុងការអភិវឌ្ឍ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៧៣. *រាជរដ្ឋាភិបាលកម្ពុជា* បានសម្រេចលទ្ធផលជាច្រើន ក្នុងការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ដែលក្នុងនោះ រួមមាន សហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិលដោយឈរលើគោលការណ៍ជាមូលដ្ឋាន និងការប្តេជ្ញា ដែលមានចរិតសាកលនានា ដែលធានាឱ្យមានភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការដឹកនាំកិច្ចអភិវឌ្ឍប្រទេសជាតិ ។

៣៧៤. *កម្ពុជា* បានទទួលជោគជ័យដ៏ត្រចះត្រចង់ ក្នុងការរៀបចំ និងដំណើរការជាបន្តបន្ទាប់ នូវកិច្ចប្រជុំពិគ្រោះយោបល់ និងការផ្ទេរកិច្ចដំណើរការនៃកិច្ចប្រជុំពិគ្រោះយោបល់ឱ្យមកជា *"វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍*

*កម្ពុជា"* ។ *វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ទី១* បានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ ហើយ *វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាទី២* បានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ នាថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០០៨ នៅក្រោមភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ។ ជាមួយគ្នានេះ វឌ្ឍនភាពនៃការអនុវត្តការដ្ឋានកំណែទម្រង់ ជាពិសេស លទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនៃការអនុវត្ត *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ក្នុងដំណាក់កាលទី១ក៏បានឆ្លុះបញ្ចាំងផងដែរ នូវការអនុវត្តដោយជោគជ័យនូវភាពជាដៃគូក្នុងការអភិវឌ្ឍរវាង *រាជរដ្ឋាភិបាល* និងសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំង វិស័យឯកជន និង សង្គមស៊ីវិល ។

៣៧៥. *រាជរដ្ឋាភិបាល* នឹងបន្តពង្រឹងនូវយន្តការ *"វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា"* និង *"វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន"* ដោយពិចារណាអំពីលទ្ធភាពក្នុងការប្រែក្លាយវេទិកានេះ ឱ្យទៅជា *"វេទិកាអភិវឌ្ឍន៍កម្ពុជា"* ដែលនេះជាយន្តការសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជា បណ្តាភាគីពាក់ព័ន្ធទាំងឡាយចូលរួមពិភាក្សារាល់បញ្ហានានា ដែលពាក់ព័ន្ធនឹងការ អភិវឌ្ឍ ទាំងវិស័យសាធារណៈ និងទាំងវិស័យឯកជន ។ ទន្ទឹមនឹងនេះ យន្តការសម្របសម្រួលនៃគណៈកម្មាធិការសម្របសម្រួល រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេស នឹងត្រូវបានពិនិត្យ និងពង្រឹងបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់យន្តការ ជាពិសេស កិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់ការអភិវឌ្ឍធនធានមនុស្ស និង ស្ថាប័ន និងសម្រាប់ពង្រឹងភាពជាដៃគូរវាងភាគីពាក់ព័ន្ធទាំងអស់ ។ រាជរដ្ឋាភិបាលបន្តលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយប្រតិបត្តិការដោយឈរលើគោលការណ៍ អភិបាលកិច្ចល្អឱ្យចូលរួមក្នុងកិច្ចដំណើរការស្តារនិងអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និង ការលើកស្ទួយការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងចូលរួមជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ នានា ផងដែរ ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញការបង្កើតនិងអនុវត្តច្បាប់ស្តីពីអង្គការមិនមែន រដ្ឋាភិបាល និងសមាគម ដោយមានការពិគ្រោះយោបល់ជាមួយនឹងស្ថាប័ន និងអង្គការពាក់ព័ន្ធ ។

៣៧៦. រាជរដ្ឋាភិបាល ប្តេជ្ញាអនុវត្ត *"ផែនការសកម្មភាពទីក្រុងអាក្រា"* ដែលជាលទ្ធផលនៃការសម្រេចចិត្តរបស់វេទិកាកម្រិតខ្ពស់លើកទី៣ ស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍដើម្បីពង្រឹងភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ ភាពជាដៃគូ និងតម្លាភាព ជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ព្រមទាំងពង្រឹងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។

## ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

### *ដំណើរឆ្ពោះទៅកាន់វេទិកាអភិវឌ្ឍន៍កម្ពុជាដ៏ទូលំទូលាយ*

៣៧៧. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយទៅនឹងការបង្កើនសមត្ថភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដើម្បីពង្រឹងភាពជាម្ចាស់និងភាពជាអ្នកដឹកនាំ ក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ដែលមានការចូលរួមពីគ្រប់ភាគីដែលមានចំណែកពាក់ព័ន្ធ ទាំងក្នុងនិងក្រៅប្រទេស ហើយដែលនៅក្នុងពេលនោះ បញ្ហាជាតិសំខាន់ៗ ត្រូវបានលើកមកពិភាក្សា ។ មិនតែប៉ុណ្ណោះ សកម្មភាពទាំងអស់ ក៏ត្រូវមានការព្រមព្រៀងគ្នាក្នុងលក្ខណៈជាប្រព័ន្ធ តាមរយៈ ការធ្វើសមាហរណកម្មយ៉ាងទូលំទូលាយ ជាមួយនឹង ភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់ ។ *រាជរដ្ឋាភិបាលកម្ពុជា* រំពឹងថា *វេទិកាអភិវឌ្ឍន៍កម្ពុជា* យ៉ាងទូលំទូលាយមួយ ដែលមិនត្រឹមតែធានាឱ្យមាន ការចូលរួមពីដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមាន សហគមន៍ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការសង្គមស៊ីវិល និងភាគីដែលមានចំណែកពាក់ព័ន្ធដទៃទៀត ដែលត្រូវបានអញ្ជើញមកចូលរួមពិគ្រោះយោបល់លើបញ្ហាដែលជាប់ពាក់ព័ន្ធជាមួយការវិនិយោគក្នុងវិស័យសាធារណៈនិងផ្នែកឯកជន ប៉ុណ្ណោះទេ ប៉ុន្តែ វេទិកានេះថែមទាំង ធ្វើឱ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធថែមទៀត រវាង ការវិនិយោគក្នុងវិស័យសាធារណៈ និងវិស័យឯកជន ។ សំខាន់ជាងនេះទៀត ការវិនិយោគក្នុងវិស័យសាធារណៈនិងវិស័យឯកជន គឺជាកត្តាដ៏យ៉ាងសំខាន់ សម្រាប់ជំរុញនិងរួមចំណែកធ្វើឱ្យសម្រេចបានគោលដៅរយៈពេលវែង នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម កម្ពុជា ។

### *យន្តការពិគ្រោះយោបល់ដែលមានលក្ខណៈទូលំទូលាយ និងមានការចូលរួមពីភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងៗគ្នា*

៣៧៨. ទម្រង់នៃកិច្ចពិគ្រោះយោបល់ដ៏មានប្រសិទ្ធភាពមួយ ដែលរំពឹងទុកដោយ *វេទិកាអភិវឌ្ឍន៍កម្ពុជា* នឹងតម្រូវឱ្យមានការសម្របសម្រួលយ៉ាងសមស្រប ពីការពាក់ព័ន្ធនៃការចូលរួម របស់ភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់ តាមរបៀបមួយ ដែលមានការធ្វើសមាហរណកម្ម និងរួមគ្នាគាំទ្រ ។ កន្លងមក *វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា* តំណាងឱ្យភាពជាដៃគូក្នុងការចូលរួមពិគ្រោះយោបល់កម្រិតខ្ពស់ រវាង *រាជរដ្ឋាភិបាលកម្ពុជា* និងសហគមន៍ដៃគូអភិវឌ្ឍន៍ រួមទាំងអង្គការក្រៅរដ្ឋាភិបាល ដែលកិច្ចពិភាក្សាស្តីពី គោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម (បានគូសបញ្ជាក់ដោយ *យុទ្ធសាស្ត្រចតុកោណ*) ត្រូវបានរៀបចំនិងអនុវត្ត ដោយឈរលើទស្សនទាននៃការត្រួតពិនិត្យរួមគ្នា ព្រមទាំង មានទំនាក់ទំនងជាមួយ គម្រោងហិរញ្ញប្បទាន ដែលធានាពីលទ្ធផលការអភិវឌ្ឍ និងគណនេយ្យភាព ទៅវិញទៅមក ។ *វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន* នឹងកំណត់ នូវកិច្ចប្រជុំជាប្រចាំមួយ សម្រាប់ឱ្យ *រាជរដ្ឋាភិបាលកម្ពុជា* ដោះស្រាយបញ្ហាស្តីពី ការជំរុញការវិនិយោគបរទេស និងការធ្វើឱ្យប្រសើរឡើង បរិយាកាសធុរកិច្ច និងពាណិជ្ជកម្ម ។ អ្នកចូលរួមចម្រុះ គួបផ្សំនឹងក្របខ័ណ្ឌនៃទំនាក់ទំនង

ខុសៗគ្នា នៃការពិគ្រោះយោបល់និងការចូលរួមដែលត្រូវបានបង្កើតឡើង នឹងត្រូវបានពិនិត្យមើល និងពិចារណាឡើងវិញយ៉ាងល្អិតល្អន់ ដោយ *រាជរដ្ឋាភិបាលកម្ពុជា* ដោយរៀបចំស្ថាបនាឆ្ពោះទៅរក *វេទិកាអភិវឌ្ឍន៍កម្ពុជា* និងដើម្បីធានាថា រចនាសម្ព័ន្ធនិងទម្រង់នៃ *វេទិកាអភិវឌ្ឍន៍កម្ពុជា* នឹងឆ្លុះបញ្ចាំងឱ្យឃើញពី ភាពសុច្ឆ័រិតភាពរបស់អ្នកចូលរួមចម្រុះ ការសម្របសម្រួល និង ប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ នៃវេទិកានោះ ។

### *ទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាង ផែនការ ការវិនិយោគសាធារណៈ និងហិរញ្ញប្បទានជំនួយអភិវឌ្ឍន៍*

៣៧៩. ដើម្បីធានាប្រសិទ្ធភាព និងការទទួលបានផលប្រយោជន៍ ពីការប្រើប្រាស់ធនធានសាធារណៈ និងធនធានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអនុវត្តអាទិភាពនៃការអភិវឌ្ឍជាតិ ចាំបាច់ត្រូវតែភ្ជាប់ទំនាក់ទំនងឱ្យបានជិតស្និទ្ធ រវាងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ថវិកាវិនិយោគសាធារណៈរបស់ *រាជរដ្ឋាភិបាលកម្ពុជា* និងអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលបានកំណត់នៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* ។ ការភ្ជាប់ទំនាក់ទំនងនេះ នឹងធានាថា ការអនុវត្តនូវអាទិភាពជាតិ នឹងត្រូវបានគ្រប់គ្រងឱ្យស្របទៅតាមធនធានដែលមាន ទាំងពី ថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ក្នុងគោលបំណងឈានទៅសម្រេចបាននូវ ចំណុចដៅនានាដែលចង់បាន ប្រកបដោយប្រសិទ្ធភាព និងផ្តល់ផលប្រយោជន៍ជាអតិបរមា ដែលនេះ គឺជាការប្រើប្រាស់ធនធានដោយមានគណនេយ្យភាព និងសម្រេចបានលទ្ធផល តាមការរំពឹងទុក ។

### *ការលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន ក្នុងដំណើរការអភិវឌ្ឍន៍ជាតិ*

៣៨០. ផ្នែកឯកជន គឺជាក្បាលម៉ាស៊ីនសម្រាប់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ ។ ការព្យាករណ៍សម្រាប់រយៈពេល ៥ឆ្នាំ ២០០៩-២០១៣ ខាងមុខ បង្ហាញថា ផ្នែកឯកជននឹងក្លាយជាប្រភពដ៏សំខាន់មួយ នៃការវិនិយោគសរុបសម្រាប់ប្រទេស ។ កំណែទម្រង់ ដែល *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងអនុវត្ត (ផ្នែក រចនាសម្ព័ន្ធ អភិបាលកិច្ច និងសម្ភារបរិក្ខារពាណិជ្ជកម្ម ក្នុងចំណោមកំណែទម្រង់ផ្សេងទៀត) បានផ្តល់នូវមូលដ្ឋានស្ថិរភាពមួយ សម្រាប់ឱ្យវិស័យឯកជនដំណើរការល្អប្រសើរ និងមានការកើនឡើង ។ ដើម្បីធានានូវភាពចាំបាច់នៃយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍវិស័យឯកជន ក្នុងការសម្រេចឱ្យបានការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច *រាជរដ្ឋាភិបាលកម្ពុជា* បានទទួលស្គាល់ពីសារៈសំខាន់នៃការបន្តផ្តល់ ការដឹកនាំដល់វិស័យឯកជន ដែលពាក់ព័ន្ធនឹងដំណើរការនៃការអភិវឌ្ឍជាតិ ។ ផ្អែកលើសមិទ្ធផល កន្លងមក យន្តការពិគ្រោះយោបល់រវាង *រាជរដ្ឋាភិបាលកម្ពុជា* និងវិស័យឯកជន នៅក្នុង *វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន* *រាជរដ្ឋាភិបាលកម្ពុជា* នឹងខិតខំប្រឹងប្រែងបន្តទៀត ដើម្បីពង្រឹងការចូលរួមរបស់វិស័យឯកជននៅក្នុងការពិភាក្សា ដើម្បីធានាថា យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឯកជន មិនមែនអនុវត្តតែក្នុងវិស័យរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង មានសារៈសំខាន់ និងរួមចំណែកយ៉ាងទូលំទូលាយផងដែរ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច នៅទូទាំងប្រទេស ។

### ឆ្ពោះទៅរកការពង្រឹងយន្តការ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍-ក្រុមការងារបច្ចេកទេស

៣៨១. យន្តការ *គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ និង ក្រុមការងារបច្ចេកទេស* នឹងបន្តផ្តល់នូវ គោលការណ៍មូលដ្ឋាននៃការពិគ្រោះយោបល់ រវាង *រាជរដ្ឋាភិបាលកម្ពុជា* និងដៃគូអភិវឌ្ឍន៍ ។ រចនាសម្ព័ន្ធ និងការអនុវត្តនៃយន្តការនេះ នឹងត្រូវបានតាមដានត្រួតពិនិត្យ និងពិនិត្យមើលឡើងវិញ ដើម្បីធានានូវថា ភាពជាដៃគូរវាង *រាជរដ្ឋាភិបាលកម្ពុជា* និងដៃគូអភិវឌ្ឍន៍ គឺផ្អែកលើ ភាពជាម្ចាស់របស់*រាជរដ្ឋាភិបាលកម្ពុជា* ដែលបានពង្រឹង និងមានគណនេយ្យភាព សម្រាប់លទ្ធផលនៃការអភិវឌ្ឍ ។

៣៨២. *រាជរដ្ឋាភិបាលកម្ពុជា* ជឿជាក់ថា ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ នៃយន្តការភាពជាដៃគូ ត្រូវបានគូសបញ្ជាក់ដោយ និងមានសង្គតិភាពជាមួយ ការប្តេជ្ញាចិត្តបន្ទរបស់*រាជរដ្ឋាភិបាលកម្ពុជា* ទៅនឹង *សេចក្តីប្រកាសនាទីក្រុងប៉ារីសស្តីពី ប្រសិទ្ធភាពជំនួយ (ឆ្នាំ២០០៥)* និងការអនុវត្តការប្តេជ្ញាចិត្ត ដែលបានដាក់បញ្ចូលក្នុង *ផែនការសកម្មភាពទីក្រុងអាក្រា (ឆ្នាំ២០០៨)* ។

### ភាពជាអ្នកដឹកនាំគឺជាមូលដ្ឋានសម្រាប់ភាពជាដៃគូ

៣៨៣. *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ពីភាពចាំបាច់នៃការពង្រឹងភាពជាអ្នកដឹកនាំ ដែលជាមូលដ្ឋានសម្រាប់អនុវត្តតួនាទីដ៏មានប្រសិទ្ធភាព នៅក្នុងយន្តការភាពជាដៃគូ ។ ក្រុមការងារបច្ចេកទេស អាចនឹងគាំទ្រដល់លទ្ធភាពធ្វើជាអ្នកដឹកនាំ ក្នុងការពិគ្រោះយោបល់ ជាមួយដៃគូអភិវឌ្ឍន៍ លើគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់នៅក្នុងវិស័យ និងផ្នែកកំណែទម្រង់របស់ខ្លួន ។

### ភាពជាដៃគូគឺជាគណនេយ្យភាពសម្រាប់លទ្ធផលនៃការអភិវឌ្ឍ

៣៨៤. *ភាពជាដៃគូ* មានសារប្រយោជន៍ណាស់ ដែលយន្តការក្រុមការងារបច្ចេកទេស មិនមែនត្រឹមតែជាវេទិកាសម្រាប់ពិភាក្សាពីបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែ ជាវិធានការនានាសម្រាប់ដោះស្រាយបញ្ហាទាំងនោះ ដែលត្រូវបានឯកភាព និងអនុវត្តការតាមដានត្រួតពិនិត្យរួមគ្នា ដោយ *រាជរដ្ឋាភិបាលកម្ពុជា* និងដៃគូអភិវឌ្ឍន៍ ។ យន្តការក្រុមការងារបច្ចេកទេស នឹងត្រូវបានពង្រឹង ដើម្បីគាំទ្រដល់ ការតាមដានត្រួតពិនិត្យ ការអនុវត្តសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ នៅក្នុងវិស័យ ឬតំបន់ដែលគេគាំទ្រ ។

### ព័ត៌មានគឺជាឧបករណ៍សម្រាប់ណែនាំភាពជាដៃគូ

៣៨៥. *រាជរដ្ឋាភិបាលកម្ពុជា* កំពុងពិចារណាលើព័ត៌មានស្តីពី សកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលត្រូវបានថែរក្សាទុក ហើយដែលជាឧបករណ៍យ៉ាងសំខាន់សម្រាប់បង្ហាញផ្លូវដល់ការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ។ *មូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កម្ពុជា* ដែលជាព័ត៌មានកម្មវិធីគោលនយោបាយរបស់*រាជរដ្ឋាភិបាល*

*កម្ពុជា* ស្តីពី សកម្មភាពសហប្រតិបត្តការអភិវឌ្ឍន៍ នឹងត្រូវបានកំណត់ដើម្បីគាំទ្រដល់ការងាររៀបចំផែនការ និង ផែនការថវិកា ។ ដើម្បីឱ្យមានសង្គតិភាពទៅនឹង ការប្តេជ្ញាចិត្តសេចក្តី *ប្រកាសទីក្រុងប៉ារីស* និង *ផែនការសកម្មភាពទីក្រុងអាក្រា* *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តធ្វើការងារជាមួយ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាការផ្តល់ព័ត៌មានស្តីពី *ជំនួយអភិវឌ្ឍន៍ផ្លូវការ* ដោយពេញលេញ មានភាពត្រឹមត្រូវ និងទាន់ពេល និងដើម្បីគាំទ្រដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេស ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រើប្រាស់ព័ត៌មានទាំងនេះ ក្នុងការពង្រឹងដំណើរការរៀបចំផែនការ និងការសម្របសម្រួលរបស់ខ្លួន ក៏ដូចជា បំពេញភារកិច្ចក្នុងការរៀបចំរបាយការណ៍ទៅដល់ថ្នាក់ជាតិ ។

៣៨៦. *ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (២០០៦-២០១០)* បានរៀបចំការគ្រប់គ្រងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទាក់ទងនឹង ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ រួមទាំងការកៀរគរ និងការបែងចែកធនធាន ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តការងារជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ ដើម្បីធានាថា ព័ត៌មានពេញលេញនិងជាក់លាក់ ស្តីពីជំនួយបរទេស នឹងអាចរកបាន និងត្រូវបានបញ្ចូលទៅក្នុងដំណើរការរៀបចំ ផែនការជាតិ និងថវិកា ។

## ផ្តោះទៅរក ការលើកកម្ពស់បន្ថែមទៀតនិងការចូលរួមដោយមានការទទួលខុសត្រូវ របស់សង្គមស៊ីវិលក្នុងដំណើរការអភិវឌ្ឍជាតិ

៣៨៧. *រាជរដ្ឋាភិបាលកម្ពុជា* យល់ថា អង្គការសង្គមស៊ីវិល គឺជាដៃគូអភិវឌ្ឍយ៉ាងសំខាន់ ក្នុងដំណើរការអភិវឌ្ឍន៍ជាតិ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញលើកទឹកចិត្ត ដល់អង្គការសង្គមស៊ីវិល ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ និងដំណើរការដោយផ្អែកលើមូលដ្ឋានអភិបាលកិច្ចល្អ ក្នុងការធ្វើឱ្យមានចំណែកពាក់ព័ន្ធ ទៅក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រទេសជាតិ និង ក្នុងការធ្វើឱ្យប្រសើរឡើងប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងលើកទឹកចិត្តដល់ ការចូលរួមទទួលខុសត្រូវ ក្នុងការ តាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយនិងយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ ។

## ការពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់អង្គការសង្គមស៊ីវិល

៣៨៨. *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ពីភាពចាំបាច់នៃ *ច្បាប់ស្តីពី អង្គការក្រៅរដ្ឋាភិបាល និងសមាគម* ដែលជាក្របខ័ណ្ឌច្បាប់ សម្រាប់អនុវត្តតួនាទីរបស់ អង្គការក្រៅរដ្ឋាភិបាល និងសមាគម ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តស្វែងរកការអនុម័តនិងអនុវត្តច្បាប់ ដោយការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ជាមួយនឹងក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធ ។

### *ការពង្រឹងយន្តការសម្រាប់ ការចូលរួមដោយមានការទទួលខុសត្រូវរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការពិគ្រោះពិភាក្សា*

៣៨៩. *រាជរដ្ឋាភិបាលកម្ពុជា* កោតសរសើរ ចំពោះការចូលរួមយ៉ាងសកម្ម របស់អង្គការសង្គមស៊ីវិល ក្នុងដំណើរការអភិវឌ្ឍន៍ជាតិ តាមរយៈ ការរួមចំណែកដោយស្ម័គ្រស្មោះ និងដោយសុទ្ធចិត្ត ទាំងធនធានហិរញ្ញវត្ថុ និងប្រតិបត្តិការ ។ *រាជរដ្ឋាភិបាលកម្ពុជា* យល់ថា ធនធាន និងជំនាញការ ដែលបានផ្តល់ដោយអង្គការសង្គមស៊ីវិល គឺជាធាតុចូលយ៉ាងសំខាន់នៅក្នុងដំណើរការគោលនយោបាយ ដើម្បីឈានទៅសម្រេចលទ្ធផលអភិវឌ្ឍន៍ ដែលចង់បាន ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តធានា នូវការចូលរួមយ៉ាងសកម្ម របស់អង្គការសង្គមស៊ីវិល នៅក្នុងយន្តការពិគ្រោះយោបល់ ។

### *ឆ្ពោះទៅរកការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពជាងមុន នូវធនធានសម្រាប់អភិវឌ្ឍ*

៣៩០. កិច្ចព្រមព្រៀងសកលលោកស្តីពី *ការប្រើប្រាស់ធនធានអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាពជាងមុន* ដែលបានបង្ហាញនៅក្នុង *ផែនការសកម្មភាពទីក្រុងអាក្រា* នឹងនៅបន្តជាឯកសារយោង សម្រាប់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បី កំណត់និងអនុវត្ត សកម្មភាពពាក់ព័ន្ធនានា ដែលនឹងពង្រឹងនូវប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិ ។ ការប្តេជ្ញាចិត្តរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការអនុម័ត និងការអនុវត្តការប្តេជ្ញាចិត្ត *ផែនការសកម្មភាពទីក្រុងអាក្រា* និងការប្តេជ្ញាចិត្តជាសកល ដែលនឹងត្រូវបានបង្ហាញឱ្យឃើញ នៅក្នុង *វេទិកាកម្រិតខ្ពស់ បន្ទាប់* នៅទីក្រុងសេអ៊ូល ក្នុងឆ្នាំ២០១១ នឹងមានគោលដៅដើម្បីធានា ការពង្រឹងភាពជាម្ចាស់និងភាពជាអ្នកដឹកនាំរបស់ជាតិ ការពង្រឹងគណនេយ្យភាពនៃភាពជាដៃគូថែមទៀតជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ និង ការលើកកម្ពស់លទ្ធផលនៃការអភិវឌ្ឍ ។

### *ការកំណត់និងការអនុវត្ត សកម្មភាពដែលពាក់ព័ន្ធនិងអាទិភាព នៅកម្រិតវិស័យ*

៣៩១. បទពិសោធន៍នៃការអនុវត្ត *ផែនការសកម្មភាពសុខដុមនីយកម្ម បន្សុី និងលទ្ធផល* បានផ្តោតការយកចិត្តទុកដាក់លើ តម្រូវការសម្រាប់ភាពជាអ្នកដឹកនាំ នៅក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃធនធានអភិវឌ្ឍន៍ នៅតាមកម្រិតវិស័យ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងដំណើរការរួមគ្នា ក្នុងការកំណត់ការឯកភាព និងការតាមដានត្រួតពិនិត្យរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ នូវការអនុវត្តអាទិភាពនៃប្រសិទ្ធភាពជំនួយ ដែលពាក់ព័ន្ធនឹងបញ្ហាប្រឈមតាមវិស័យ និងផ្តោតលើលទ្ធផលដែលសម្រេចបាន ។ វិធីសាស្ត្រជាអាទិភាពនិងនៃបរិការណ៍ នេះ នឹងបន្តធ្វើការណែនាំដល់បណ្តាគោលនយោបាយប្រសិទ្ធភាពនៃជំនួយ ។

### បង្កើនការផ្ទេរសុទ្ធសាធនៃធនធានសម្រាប់អភិវឌ្ឍ

៣៩២. លទ្ធផលដ៏សំខាន់ (ដែលជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល) គឺ សម្រេចឱ្យបានការកើនឡើងគួរឱ្យកត់សម្គាល់ នូវការផ្ទេរធនសុទ្ធសាធ ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ក្នុងរយៈពេល ៥ឆ្នាំខាងមុខ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធ្វើការងារ ដើម្បី សម្រេចឱ្យបាននូវការផ្ទេរទុនសុទ្ធសាធនេះ នៅក្នុងបរិការណ៍នៃបរិស្ថានផ្តល់ជំនួយមានចំណែកតិចតួច និង បង្កើនការប្រើប្រាស់ប្រព័ន្ធរបស់*រាជរដ្ឋាភិបាល* ក្នុងការអនុវត្តសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ ។

### ផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាព ប្រកបដោយប្រសិទ្ធភាព

៣៩៣. *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ពីសារសំខាន់ នៃការពង្រឹងសមត្ថភាពមនុស្សនិងស្ថាប័ន ដើម្បីអនុវត្តភាពជាម្ចាស់និងភាពជាអ្នកដឹកនាំ នៅក្នុងដំណើរការអភិវឌ្ឍន៍ ។ ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ត្រូវតែមានការគ្រប់គ្រងគោលដៅដែលត្រូវទៅដល់ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធានាថា គ្រប់ការគាំទ្រដល់កិច្ចសហប្រតិ-បត្តិការបច្ចេកទេសពីបរទេស នឹងត្រូវបានតម្រង់ទិសជាមុន ទៅដល់ការអភិវឌ្ឍ ប្រព័ន្ធជាតិ និង សមត្ថភាពមនុស្សនិងស្ថាប័នជាតិ តាមរបៀបមួយដែល ស៊ីសង្វាក់គ្នាជាមួយ គោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស របស់*រាជរដ្ឋាភិបាលកម្ពុជា* និងជាមួយ *កំណែទម្រង់រដ្ឋបាលសាធារណៈជាតិ (២០០៩-២០១៣)* ។ *សេចក្តីណែនាំស្តីពី សហប្រតិបត្តិការបច្ចេកទេស* នឹងត្រូវបានអនុវត្ត និងប្រើប្រាស់ ដើម្បីគ្រប់គ្រងធនធានទាំងនេះ នៅតាមវិស័យ និងដើម្បីណែនាំការគាំទ្រ ដល់ការអនុវត្តកម្មវិធីកំណែទម្រង់ស្នូល របស់*រាជរដ្ឋាភិបាលកម្ពុជា* ។

### ការបង្កើនការប្រើប្រាស់ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី

៣៩៤. *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ពីភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមានឡើង ដោយសារបរិយាកាសនៃជំនួយជាផ្នែក ផ្តល់មកកម្ពុជា និងការប្រើប្រាស់នៅមានកម្រិត នូវប្រព័ន្ធនិងនីតិវិធីរបស់*រាជរដ្ឋាភិបាលកម្ពុជា* នៅក្នុងការអនុវត្តសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ ។ *រាជរដ្ឋាភិបាលកម្ពុជា* លើកទឹកចិត្តឱ្យប្រើប្រាស់ *វិធីសាស្ត្រផ្អែកលើកម្មវិធី* ដើម្បីដំណើរការ ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំ ឱ្យមានប្រសិទ្ធភាព ក្នុងការអនុវត្ត គោលនយោបាយអាទិភាពជាតិ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ជំរុញភាពជាដៃគូឱ្យកាន់តែមានភាពរឹងមាំជាងមុន និងធានាលទ្ធផលនៃការអភិវឌ្ឍ និងគណនេយ្យភាព ។ នៅក្នុងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើកម្មវិធីនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធានាថា នឹងគាំទ្រដល់ការរៀបចំផែនការនិងថវិកាដែលមានលក្ខណៈទូលំទូលាយ ផ្សារភ្ជាប់ជាមួយនឹងអាទិភាពជាតិ ការអភិវឌ្ឍសមត្ថភាពសម្របសម្រួល ដើម្បីពង្រឹងប្រព័ន្ធជាតិនិងធនធានមនុស្ស កាត់បន្ថយឱ្យនៅកម្រិតទាបបំផុត នូវផលប៉ះពាល់មិនល្អ ពីប្រភពហិរញ្ញប្បទានដោយឡែកៗនិងមិនល្អ ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ និង ផ្តល់យន្តការសម្រាប់លើកម្ពស់គណនេយ្យភាពរួមគ្នា នៃភាគីដែលមានចំណែកពាក់ព័ន្ធ ក្នុងការអភិវឌ្ឍន៍ ក្នុងនិងក្រៅប្រទេស ។

*ការវិនិយោគលើភាពជាដៃគូ*

៣៩៥. *រាជរដ្ឋាភិបាលកម្ពុជា* ចាត់ទុកថា ភាពជាដៃគូជាមួយគ្រប់ភាគីអភិវឌ្ឍន៍ទាំងអស់ គឺជាគោលនយោបាយអាទិភាពដ៏សំខាន់ សម្រាប់ភាពជោគជ័យនៃការអនុវត្ត*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* របស់*រាជរដ្ឋាភិបាលកម្ពុជា* ហើយត្រូវបានប្តេជ្ញាបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងយោបល់មួយ ដែលមានភាពហ្មត់ចត់ និងផ្តោតលើលទ្ធផល ។ នៅក្នុងការអនុវត្តនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធានាថា ភាពជាដៃគូជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ត្រូវបានពិនិត្យឃើញនៅក្នុងផ្នែកនៃ ភាពជាម្ចាស់និងភាពជាអ្នកដឹកនាំ ការគោរពគ្នាទៅវិញទៅមក និងគណនេយ្យភាព ដែលមានគោលបំណងគាំទ្រដល់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការសម្រេចគោលដៅជាតិរបស់ខ្លួន ។ ការវិនិយោគជាបន្តទៀត នឹងត្រូវបានធ្វើឡើង ដើម្បីពង្រឹងយន្តការភាពជាដៃគូ រួមមាន ការធ្វើការងារជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីធានាថា ធនធានសមស្របនិងគ្រប់គ្រាន់ ត្រូវបានផ្តល់ឱ្យ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់កាលានុវត្តភាព ដើម្បី ពិនិត្យមើលពីវឌ្ឍនភាព កំណត់ពីភាពប្រែប្រួល និងឆ្លើយតបក្នុងរបៀបមួយ ផ្អែកលើភាពជាដៃគូ និងផ្តោតលើលទ្ធផល ។

## ៣. ការលើកស្ទួយវិស័យកសិកម្ម

៣៩៦. កំណើនសេដ្ឋកិច្ចកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ដែលក្នុងនោះ វិស័យកសិកម្មដើរតួយ៉ាងសំខាន់ក្នុងកំណើននេះ ។ កសិកម្ម គឺជាវិស័យមួយ ដែលផ្តល់ប្រភពការងារ និងជាស្នូលនៃសេដ្ឋកិច្ចជនបទ ។ ការលើកកម្ពស់វិស័យកសិកម្ម គឺជាការចាំបាច់ណាស់ ដើម្បី (១) ពង្រីកមូលដ្ឋាន និងជួយរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច និង (២) ជំរុញការកាត់បន្ថយភាពក្រីក្រ ។ ក្នុងន័យនេះ គោលដៅចម្បងនៃគោលនយោបាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្ម វិស័យកសិកម្ម ព្រមទាំង លើកកម្ពស់កំណែទម្រង់ ដីធ្លី ជលផល និងព្រៃឈើ ដោយធ្វើការដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងអគ្គិសនី ព្រមទាំង ឥណទាន ទីផ្សារ និងការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ។ ការងារនេះ តម្រូវឱ្យមានយន្តការស្ថាប័ន និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បី ឱ្យមានវឌ្ឍនភាព និងការប្រែប្រួលគុណភាព ក្នុងវិស័យទាំងមូល ។

៣៩៧. *ចតុកោណ* នៃ*ការលើកកម្ពស់វិស័យកសិកម្ម* មានសមាសធាតុ ៤ ដែលរួមមាន : *(១) ការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម (២) កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន (៣) កំណែទម្រង់ជលផល និង (៤) កំណែទម្រង់ព្រៃឈើ* ។

## ៣.១ ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មវូបនីយកម្មកសិកម្ម

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៣៩៨. តម្លៃបន្ថែមក្នុងវិស័យកសិកម្ម បានកើនឡើងជាមធ្យមប្រមាណ ៧,២ភាគរយក្នុងមួយឆ្នាំ ក្នុងអំឡុងពេលឆ្នាំ២០០៣-២០០៧ ធៀបទៅនឹងប្រមាណ ១,៦ភាគរយ ក្នុងអំឡុងឆ្នាំ១៩៩៨-២០០២ និងប្រមាណ ៤,៩ភាគរយក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៧ ។ កម្ពុជាសម្រេចបាននូវទិន្នផលស្រូវក្នុងរង្វង់ ២,៥តោន ក្នុងមួយហិកតា ក្នុងអំឡុងឆ្នាំ២០០៤-២០០៨ ដែលជាទិន្នផលខ្ពស់បំផុតនៅក្នុងប្រវត្តិសាស្រ្តរបស់កម្ពុជា ដោយសារ ការបង្កើនការយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដែលបានលើកកម្ពស់ចំណេះដឹងនិងចំណេះធ្វើរបស់កសិករក្នុងការងារដាំដុះ ការកើនឡើងនៃការវិនិយោគលើបណ្តាញធារាសាស្រ្ត ការកែលម្អការគ្រប់គ្រងទឹក ការកើនឡើងនៃឥណទានពីធនាគារពាណិជ្ជ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ ការផ្លាស់ប្តូរទៅរកប្រពលវប្បកម្មកសិកម្ម ដែលកំពុងចាក់ឫសបន្តិចម្តងៗ និងការកើនឡើងនៃតម្លៃ ស្រូវ អង្ករ ពោត សណ្តែក ដំឡូង និងកៅស៊ូ នឹងផ្តល់នូវការលើកទឹកចិត្តបន្ថែមទៀត ដល់ការអនុវត្តគោលនយោបាយពិពិធភាវូបនីយកម្មកសិកម្មនេះ ។

៣៩៩. *រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ នីតិកាលទី៤ នៃរដ្ឋសភា* នឹងបន្តផ្តល់អាទិភាពខ្ពស់ ទៅលើការលើកកម្ពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធភាវូបនីយកម្មវិស័យកសិកម្ម ព្រមទាំង ការបន្តជំរុញកសិ-ឧស្សាហកម្ម ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តការយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែរទិសពីការអភិវឌ្ឍតាមបែប *"បើកទូលាយ"* ឬ តាមបែប *"វិបុលកម្ម"* ទៅកាន់ការអភិវឌ្ឍតាមបែប *"ស៊ីជម្រៅ"* ឬ តាមបែប *"ប្រពលវប្បកម្ម"* ក្នុងគោលដៅ បង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទនិងធានានូវសន្តិសុខស្បៀង និង បង្កើនការនាំចេញកសិផល ជាពិសេស កសិផលសម្រេច ដូចជាអង្ករ ជាដើម ។ ដើម្បីសម្រេចបានគោលដៅទាំងអស់នេះ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើអន្តរាគមន៍ប្រទាក់ក្រឡាគ្នា ក្នុងវិស័យពាក់ព័ន្ធ ដូចជា ការប្រើប្រាស់ផលិតកម្មកសិកម្មតាមបច្ចេកទេស ការស្រាវជ្រាវពីការអភិវឌ្ឍនិងផ្សព្វផ្សាយកសិកម្ម ការសាងសង់និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ជាពិសេស ប្រព័ន្ធធារាសាស្រ្ត ការពង្រីកការផ្តល់ឥណទានជនបទនិងមីក្រូហិរញ្ញវត្ថុ ការពង្រីកទីផ្សារកសិកម្ម ការរៀបចំសហគមន៍កសិករ និងការគ្រប់គ្រងដីធ្លីកសិកម្ម ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តកិច្ចខិតខំប្រឹងប្រែង ពង្រឹងនិងពង្រីកប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានកសិកម្ម ដោយជំរុញការផ្តល់សេវានេះ ឱ្យទៅដល់ថ្នាក់ស្រុក ដោយផ្សារភ្ជាប់ជាមួយនឹង បណ្តាញអ្នកស្ម័គ្រចិត្តថ្នាក់ឃុំ ព្រមទាំងកិច្ចខិតខំធានាស្ថិរភាពនៃប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម ដែលបាននឹងកំពុងអនុវត្តក្នុងក្របខ័ណ្ឌនៃគម្រោងអភិវឌ្ឍន៍នានា ។ ជាមួយគ្នានោះដែរ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញឱ្យមានភាពជាដៃគូ រវាងកសិករម្ចាស់ដីតូចតាចនិងកសិដ្ឋានខ្នាតធំឬសាជីវកម្មកសិកម្ម និង រវាង សម្បទានិកដីសេដ្ឋកិច្ចជាមួយនិងសម្បទានិក

ដីសង្គមកិច្ច ជាពិសេស សម្រាប់ដំណាំកសិ-ឧស្សាហកម្ម ដូចជា ដំណាំកៅស៊ូ ជាដើម ឱ្យស្របតាម *ផែនការយុទ្ធ-សាស្ត្រសម្រាប់អភិវឌ្ឍន៍ដំណាំ កៅស៊ូ ស្វាយចន្ទី និង អំពៅ* ។ *រាជរដ្ឋាភិបាលកម្ពុជា* និងលើកទឹកចិត្តចំពោះការអភិវឌ្ឍកសិដ្ឋានពហុបំណង ក្នុងគោលដៅ លើកកម្ពស់ផលិតភាពនៃការចិញ្ចឹមសត្វ ការដាំដំណាំចម្រុះគួបផ្សំជាមួយការចិញ្ចឹមសត្វ ។

៤០០. ជាងនេះទៀត *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញបង្កើតបរិយាកាសអនុគ្រោះកាន់តែប្រសើរឡើងថែមទៀត សម្រាប់ទាក់ទាញវិនិយោគទុនឯកជន ទាំងក្នុងនិងក្រៅប្រទេស និងស្វាគមន៍ផងដែរ ចំពោះការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដល់កសិករ ក្នុងការដាំដុះ និងចិញ្ចឹមសត្វ និងផ្សារភ្ជាប់កសិករទៅនឹងសង្វាក់ផ្គត់ផ្គង់កសិផល ក្នុងតំបន់និងពិភពលោក តាមរយៈ ការបង្កើតយន្តការស្ថាប័ន ចាំបាច់ និងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ គុណភាពកសិផល ឱ្យស្របតាមស្តង់ដារអន្តរជាតិ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព

៤០១. ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* នឹងបន្តការងាររបស់ខ្លួនដើម្បីធ្វើបច្ចុប្បន្នកម្ម*យុទ្ធសាស្ត្រវិស័យកសិកម្ម* និងខិតខំស្វែងរកការគាំទ្រសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួន តាមរយៈ *កម្មវិធីទូទាំងវិស័យ* ។ សកម្មភាពសំខាន់ៗ រួមមាន :

- កែលម្អដីជាតិដី ធ្វើចំណាត់ថ្នាក់ដីសម្រាប់កំណត់តំបន់ដាំដុះ និង រៀបចំផែនការប្រើប្រាស់ដីធ្លី ។
- អនុវត្ត*កម្មវិធីសកម្មភាពជាតិ* ដើម្បីទប់ទល់នឹង ការថយចុះគុណភាពដីធ្លី និងភាពរហោស្ថាន នៅកម្ពុជា ។
- ពង្រឹងការស្រាវជ្រាវនិងការអភិវឌ្ឍ ពូជដំណាំ និង បច្ចេកទេសផលិតកម្មដំណាំ ។
- បញ្ជ្រាបការប្រើប្រាស់ពូជដំណាំ ដែលមានគុណភាពនិងទិន្នផលខ្ពស់ ។
- ជំរុញការធ្វើ ប្រពលវប្បកម្ម និង ពិពិធកម្មកសិកម្ម ។
- ពង្រឹងការយល់ដឹង ពីការការពារដំណាំ ។
- កែលម្អគុណភាពផលិតផលកសិកម្ម ។
- ពង្រឹងសមត្ថភាព និងសេវាកម្មត្រួតពិនិត្យ គុណភាព និងសុវត្ថិភាព ផលិតផលកសិកម្ម ។
- ពង្រឹងនិងពង្រីក រចនាសម្ព័ន្ធនិងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម តាមរយៈ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ប្រសិទ្ធភាពនៃការងារផ្សព្វផ្សាយកសិកម្ម ។
- បង្កើនសមត្ថភាពរបស់ មន្ត្រីផ្សព្វផ្សាយកសិកម្ម និង ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ តាមរយៈ ការអប់រំ ការបណ្តុះបណ្តាល អំពីវិធីសាស្ត្រផ្សព្វផ្សាយ ។

- ជំរុញការពង្រឹងនិងការអភិវឌ្ឍ អង្គការកសិករ ជាពិសេស សហគមន៍កសិកម្ម ។
- អភិវឌ្ឍនិងពង្រឹងនូវ ប្រព័ន្ធគ្រប់គ្រងកសិកម្ម និង បទដ្ឋានសម្រាប់ការអនុវត្តបច្ចេកវិទ្យា ដើម្បីចូលរួមចំណែកក្នុងការកសាង ផែនការអភិវឌ្ឍន៍មូលដ្ឋាន ។
- ពង្រឹង សមត្ថភាពជំនាញនិងទេពកោសល្យ របស់មន្ត្រីកសិកម្មពាក់ព័ន្ធ នៅគ្រប់កម្រិត ។
- កែលម្អរចនាសម្ព័ន្ធ តួនាទីភារៈកិច្ច របស់ក្រសួង ដើម្បីឱ្យមានចីរភាពក្នុងការងារផ្សព្វផ្សាយកសិកម្ម ។
- ពង្រឹងប្រសិទ្ធភាពនៃការផ្សព្វផ្សាយព័ត៌មាននិងបច្ចេកវិទ្យាកសិកម្ម តាមរយៈ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសាធារណៈ ។
- បង្កើនផលិតកម្មស្បៀងនិងប្រាក់ចំណូលរបស់គ្រួសារកសិករ តាមរយៈ ការអនុវត្តបច្ចេកទេសផ្សព្វផ្សាយកសិកម្ម នៅជនបទ ។
- ជំរុញការផ្សព្វផ្សាយព័ត៌មានអំពី តម្រូវការនិងលក្ខខណ្ឌរបស់ ទីផ្សារក្នុងស្រុកនិងក្រៅស្រុក នៅក្រោមរបបពាណិជ្ជកម្មពិភពលោក ដល់អ្នកពាក់ព័ន្ធទាំងអស់។
- ពង្រឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍ បច្ចេកទេសគ្រឿងយន្តកសិកម្ម និង ឧបករណ៍កសិកម្ម ។
- ពង្រីកការអភិវឌ្ឍនិងការប្រើប្រាស់ គ្រឿងយន្តកសិកម្ម និង ឧបករណ៍កសិកម្ម ។
- កែលម្អបច្ចេកទេសថែរក្សាផលដំណាំ ក្រោយពេលប្រមូលផល ។
- ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលចាំបាច់សម្រាប់ ការស្រាវជ្រាវ ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា កសិកម្ម។
- បន្តជំរុញការអនុវត្ត *កម្មវិធីសកម្មភាពជាតិ* នៅលើ ការងារបញ្ជ្រាប និង ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាយេនឌ័រ នៅក្នុងវិស័យកសិកម្ម ។
- ជំរុញការឱ្យមានការអនុវត្ត ប្រកបដោយប្រសិទ្ធភាពនូវ ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ ។
- ធ្វើឱ្យប្រសើរឡើងនូវ លក្ខណៈសម្បត្តិរបស់ពូជស្រូវទាំងឡាយ ដែលបានបញ្ចេញរួចហើយ និងដែលកំពុងពេញនិយម ដើម្បីឱ្យប្រភេទស្រូវទាំងនេះ អាចធន់ទ្រាំទៅនឹង ទឹកជំនន់ ភាពរាំងស្ងួត និងសត្វល្អិត ។
- ធ្វើឱ្យប្រសើរឡើងនូវ ទិន្នផលនិងគុណភាព ដំណាំស្រូវ ដំណាំធញ្ញជាតិ ដំណាំផ្តល់ផ្លែ ផ្តល់មើម ដំណាំវាយនភ័ណ្ឌ ដំណាំបន្លែ រុក្ខជាតិលម្អ ។ល។
- ពង្រឹងសមត្ថភាពរបស់មន្ទីរពិសោធន៍ សម្រាប់ការវិភាគ ដី ទឹក សត្វល្អិតចង្រៃ និងជំងឺ ព្រមទាំង ជាលិកាវប្បកម្ម ។
- ធ្វើការប្រមែប្រមូល អភិរក្ស និង ប្រើប្រាស់ ពូជដំណាំ ផ្សេងៗ។
- អភិវឌ្ឍវិធីសាស្ត្ររៀបចំដី ប្រកបដោយចីរភាព សម្រាប់ផលិតកម្មដំណាំស្រូវប្រដេញទឹក ។

- អភិវឌ្ឍឧបករណ៍កសិកម្ម ដែលរួមមាន ម៉ាស៊ីនដាំគ្រាប់ធញ្ញជាតិ ឧបករណ៍ជម្រះស្មៅ និងឧបករណ៍ប្រឡោះសណ្តែកដី ។
- អភិវឌ្ឍ បរិក្ខារសម្រាប់រក្សាទុក ឬ សម្រាប់វេចខ្ចប់ផលិតផលកសិកម្ម ។
- អភិវឌ្ឍបង្កំបច្ចេកវិទ្យាសម្រាប់ប្រព័ន្ធដាំដុះដំណាំកសិកម្ម ដើម្បីបង្កើនទិន្នផលស្រូវ តាមរយៈ ការប្រើប្រាស់បច្ចេកវិទ្យារបស់ *វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា* ដោយកសិករ ដែលរស់នៅតំបន់ក្រីក្រ និងតំបន់ងាយរងគ្រោះ ព្រមទាំង ជំរុញនិងធ្វើឱ្យប្រសើរឡើងនូវ ប្រព័ន្ធកសិកម្មគំរូ ។
- សិក្សាអំពីនិន្នាការរយៈពេលវែងនៃជីជាតិដី សម្រាប់ផលិកម្មដំណាំស្រូវ ដោយប្រើជីខនិជ ឬជីសរីរាង្គ ក្នុងលក្ខខណ្ឌដីខ្សាច់នៃតំបន់ទំនាប ។
- គ្រប់គ្រង ថែទាំ និង អភិវឌ្ឍ មន្ទីរពិសោធន៍ សម្រាប់ការវិភាគ ដី រុក្ខជាតិ និងទឹក ។
- សិក្សាអំពីបម្រែបម្រួលតាមរដូវនៃគុណភាពទឹក ដែលអាចប៉ះពាល់ដល់ផលិតកម្មដំណាំកសិកម្ម ។
- បង្កើនផលិតភាពដីនៃតំបន់ទំនាប សម្រាប់ផលិតកម្មដំណាំស្រូវ ប្រកបដោយចីរភាពសេដ្ឋកិច្ចនិងបរិស្ថាន ។
- ធ្វើពិពិធកម្មដំណាំនៅតំបន់ទំនាប ដោយដំណាំសណ្តែក ក្រោយពេលប្រមូលផលដំណាំស្រូវវស្សា ។
- បង្កើនផលិតភាពដីនៃតំបន់ខ្ពង់រាប សម្រាប់ផលិតកម្មដំណាំចម្ការនិងបន្លែ ប្រកបដោយចីរភាពសេដ្ឋកិច្ចនិងបរិស្ថាន ។
- ប្រមែប្រមូលរក្សាទុក នៅក្នុងមន្ទីរពិសោធន៍តាមវិទ្យាស្ថាននិងតាមបណ្តាខេត្ត នូវសត្វល្អិតចង្រៃនិងជំងឺដែល បំផ្លាញដល់ដំណាំបន្លែនិងធញ្ញជាតិ ។
- ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍបច្ចេកវិទ្យា សម្រាប់បង្កើនវប្បកម្មនិងផលិតកម្មដំណាំផ្សិត ។
- ធានាថា ថ្នាំកសិកម្មសរីរាង្គនិងអសរីរាង្គ ដែលកំពុងត្រូវបានប្រើប្រាស់ មានបទដ្ឋានត្រឹមត្រូវ និង មានប្រសិទ្ធភាព ក្នុងផលិតកម្មដំណាំស្រូវ និង បន្លែមួយចំនួន ។
- ជំរុញការងារបណ្តុះបណ្តាល និងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម តាមរយៈ វគ្គបណ្តុះបណ្តាលសិក្ខាសាលា សន្និបាត ការបោះពុម្ពផ្សាយ និង គេហទំព័រ របស់វិទ្យាស្ថាន ។
- កសាងក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និង ការអភិវឌ្ឍធនធានមនុស្ស ។
- ការកាត់បន្ថយអត្រាសត្វឈឺ និង ស្លាប់ ។
- ការធ្វើឱ្យប្រសើរឡើងនូវសុខភាពសាធារណៈ ជាពិសេស បញ្ហាសុខភាពដែលពាក់ព័ន្ធនឹងជំងឺ មានប្រភពមកពីសត្វនិងបញ្ហាសុវត្ថិភាពម្ហូបអាហារ ។
- ជំរុញ ផលិតកម្មចំណីសត្វ និង ធ្វើឱ្យប្រសើរឡើងនូវគុណភាពពូជសត្វ ។
- ជំរុញការប្រើប្រាស់លាមកសត្វ ដើម្បីផលិតជីវឧស្ម័ន ។
- បង្កើននិងពង្រីង ការស្រាវជ្រាវនិងការផ្សព្វផ្សាយ អំពីការងារផលិតកម្មសត្វនិងបសុព្យាបាល ។
- ធ្វើឱ្យប្រសើរឡើងនូវការផ្តល់ឥណទាន ដល់ផលិតកម្មសត្វ ។

- លើកទឹកចិត្តដល់ការវិនិយោគលើការចិញ្ចឹមសត្វនិងបសុព្យាបាល និង ជំរុញលើកទឹកចិត្តដល់ទីផ្សារសត្វនិងទីផ្សារផលិតផលដែលមានប្រភពពីសត្វ ។
- ជំរុញ ការអភិវឌ្ឍនិងការវិនិយោគលើ ដំណាំកៅស៊ូ (គ្រួសារ/ឯកជន) និងរៀបចំបង្កើតប្រព័ន្ធព័ត៌មានអំពីកៅស៊ូ ។
- លើកកម្ពស់និងពង្រឹង ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និង អភិបាលកិច្ចល្អ ក្នុងវិស័យកៅស៊ូ ។

៤០២. ដើម្បីជំរុញកំណើនផលិតកម្មកសិកម្ម សម្រាប់អំឡុងឆ្នាំ២០០៩-២០១៣ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានរៀបចំសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិ នានា រួមមាន :

- *ច្បាប់ស្តីពី ថ្នាំកសិកម្មនិងសម្ភារកសិកម្ម* ។
- *ច្បាប់ស្តីពី សហគមន៍កសិកម្ម* ។
- *ច្បាប់ស្តីពី ការគ្រប់គ្រងនិងការផ្ទេរបច្ចេកវិទ្យាកសិកម្ម* ។
- *ច្បាប់ស្តីពី ផលិតកម្មសត្វ និង បសុព្យាបាល* ។
- *ច្បាប់ស្តីពី កៅស៊ូ* ។
- *ច្បាប់ស្តីពី ការការពារដំណាំ* ។
- *ច្បាប់ស្តីពី គុណភាព សុវត្ថិភាព ផលិតផលកសិកម្ម* ។
- *ច្បាប់ស្តីពី ការគ្រប់គ្រងដីកសិកម្ម* ។
- *អនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា* ។
- *អនុក្រឹត្យស្តីពី ការគ្រប់គ្រងគ្រឿងយន្តនិងឧបករណ៍កសិកម្ម* ។
- *អនុក្រឹត្យស្តីពី ការបង្កើតមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និង ការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ* ។
- *អនុក្រឹត្យស្តីពី វិញ្ញាបនបត្រ បញ្ជាក់ គុណភាពនិងសុវត្ថិភាព នៃផលិតផលកសិកម្ម* ។
- *អនុក្រឹត្យស្តីពី នីតិវិធីនៃការបង្កើតឬរំសាយ តំបន់គ្រប់គ្រងជលផល* ។
- *អនុក្រឹត្យស្តីពី ព្រំប្រទល់ដែននេសាទ* ។
- *អនុក្រឹត្យស្តីពី នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ* ។
- *អនុក្រឹត្យស្តីពី សម្លៀកបំពាក់ ឯកសណ្ឋាន សញ្ញាសម្គាល់ និង ឋានន្តរសក្តិ របស់មន្ត្រីរដ្ឋបាលព្រៃឈើ* ។
- *គោលនយោបាយជាតិ ស្តីពីវិស័យកៅស៊ូ* ។

៤០៣. សូចនាករសំខាន់ៗ ដែលបង្ហាញពីវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធី របស់ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* មានបង្ហាញនៅក្នុងតារាងទី១៥ ខាងក្រោម ។

### តារាងទី១៩ : សូចនាករសំខាន់ៗ របស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| សូចនាករសំខាន់ៗ | ឯកតា | ២០០៨ ជាក់ស្តែង | ២០០៩ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ | ២០១១ ព្យាករណ៍ | ២០១២ ព្យាករណ៍ | ២០១៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះដំណាំ (ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម) | ពាន់ហ.ត | ៥៩៦ | ៦៤៥ | ៧៧៤ | ៩៣០ | ១ ០០០ | ១ ០០០ |
| ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត | ២,៦១ | ២,៦៣ | ២,៦៥ | ២,៦៥ | ២,៦៥ | ២,៦៥ |
| ទិន្នផលស្រូវ ក្នុងមួយហិកតា | តោន | ២,៧៤ | ២,៧៧ | ២,៨០ | ២,៨៣ | ២,៨៧ | ៣,០០ |
| ផលិតកម្មដំណាំស្រូវ | លានតោន | ៧,១៧ | ៧,២៨ | ៧,៤២ | ៧,៥០ | ៧,៦០ | ៧,៩៥ |
| ផ្ទៃដីស្រោចស្រព | ពាន់ហត | ១ ១២០ | ១ ១៤៥ | ១ ១៧០ | ១ ១៩៥ | ១ ២២០ | ១ ២៤៥ |
| កាត់បន្ថយអាត្រាសត្វស្លាប់ | ភាគរយ | ៦,០ | ៥,៥ | ៥,០ | ៤,៥ | ៤,០ | ៣,៥ |
| ការចិញ្ចឹមសត្វគោ-ក្របី | លានក្បាល | ៤,២០ | ៤,២៩ | ៤,៣២ | ៤,៣៨ | ៤,៤៤ | ៤,៥០ |
| ផ្ទៃដីដាំដុះដំណាំកៅស៊ូ | ពាន់ហ.ត | ១១១,៤ | ១២៨,៤ | ១៤៣,៤ | ១៥៨,៤ | ១៧៣,៤ | ១៨៨,៤ |
| ទិន្នផលជ័រ/ហិកតា | តោន | ០,៩៥ | ១,១០ | ១,១០ | ១,១៥ | ១,២០ | ១,៣០ |
| ផលិតកម្មជ័រស្ងួត | ពាន់តោន | ២៦,៦ | ៣៨,៥ | ៤៩,៥ | ៦៣,៣ | ៧៨,០ | ៩៧,៥ |
| ឡូត៍នេសាទ | គម$^2$ | ៤១៩ | ៤១៩ | ៤១៩ | ៤១៩ | ៤១៩ | ៤១៩ |
| ឡូត៍នេសាទ ដែលបានផ្តល់ជូនសហគមន៍នេសាទ | % | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ |
| ផលិតកម្មនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | ៤៧១ | ៥១៥ | ៦១៧ | ៦៦៨ | ៧២៦ | ៧៨៨ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | %នៃផ្ទៃដី | ៥៩,០០ | ៥៧,៥៩ | ៥៧,៩៩ | ៥៨,៣៩ | ៥៨,៧៩ | ៥៩,១៩ |
| ការដាំដុះឈើឡើងវិញ | ពាន់ហ.ត | ១០,៨១ | ១៨,៩២ | ៧៣ | ៧៣ | ៧៣ | ៧៣ |
| គ្រួសារប្រើប្រាស់អុស-ធ្យូង សម្រាប់ដុត | %គ្រួសារសរុប | ៧៣ | ៦៧ | ៦១ | ៥៩ | ៥៦ | ៥៤ |
| ការបោះបង្គោលព្រំព្រៃឈើ | គម | ៣២១ | ២២៨ | ៤១៣ | ៥០០ | ៥០០ | ៥០០ |
| សហគមន៍ព្រៃឈើ | សហគមន៍ | ១២៤ | ២១០ | ៣០០ | ៣៥០ | ៤០០ | ៤៥០ |

## ៣.២ កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤០៤. កំណែទម្រង់ដីធ្លីរបស់*រាជរដ្ឋាភិបាល* បានផ្តោតជាសំខាន់លើ វិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុក ដោយមិនបានប្រើប្រាស់និងមិនផលិត ។ ការងារកែទម្រង់ដីធ្លី ក៏មានសារៈសំខាន់ផងដែរ ក្នុងការពង្រីកនិងបែងចែកដីធ្លីកសិកម្មក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ជាមូលដ្ឋានសម្រាប់កសិករ សំដៅលើកកម្ពស់បង្កើនផលិតភាព និង ពិពិធភាវូបនីយកម្មកសិកម្ម ។ ការចុះបញ្ជីដីធ្លី សម្រេចបាន លទ្ធផលសមស្រប ដោយបញ្ចប់ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ បានចំនួន ១៧៥ ឃុំ-សង្កាត់ ក្នុងទូទាំង ១១ ខេត្ត-រាជធានី ។ ដីជាង ១ លានក្បាលដី ត្រូវបានផ្តល់បណ្ណកម្មសិទ្ធិ រួចហើយ ។

៤០៥. ក្នុងនីតិកាលទី៤ នេះ *រាជរដ្ឋាភិបាល* នឹងបន្តធ្វើកំណែទម្រង់ដីធ្លី ក្នុងក្របខ័ណ្ឌ*ច្បាប់ភូមិបាល* និង គោល-នយោបាយដីធ្លីដែលមានស្រាប់ និង តាមរយៈការរៀបចំក្របខ័ណ្ឌគតិយុត្តិបន្ថែមទៀត ដូចជា ***ច្បាប់អស្សាមិករណ៍ ច្បាប់ស្តីពីសិទ្ធិបុព្វកែ្រ ក្រមសំណង់និងនគរូបនីយកម្ម*** និង ***ស្តង់ដារជាតិខាងសំណង់*** ។

៤០៦. *រាជរដ្ឋាភិបាល* នឹងបន្ត ពិនិត្យឡើងវិញ និង ដាក់ចេញវិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីទំនេររបស់រដ្ឋ និង ក្នុងការដោះស្រាយតាមបទប្បញ្ញត្តិច្បាប់នូវករណីឯកជនកាន់កាប់ដីរដ្ឋដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្តិ ។ *រាជរដ្ឋាភិបាល* នឹងបន្តជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌអចលនទ្រព្យរបស់រដ្ឋ ព្រមទាំង ការចុះបញ្ជីជាប្រព័ន្ធ ឱ្យបានទូលំទូលាយនិងកាន់តែលឿនថែមទៀត ដោយអនុវត្ត "*ច្រកចេញ-ចូលតែមួយ*" លើការផ្តល់សេវាចុះបញ្ជីឱ្យមានតម្លាភាព និង ដោយផ្តល់អាទិភាពចំពោះ តំបន់ដែលគ្មានទំនាស់និងតំបន់នៃសហគមន៍ជនជាតិដើមភាគតិច ដើម្បី កាត់បន្ថយទំនាស់ដីធ្លី ធានាសុវត្ថិភាពកម្មសិទ្ធិ និង លុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដី ។ *រាជរដ្ឋាភិបាល* បន្តដោះស្រាយជម្លោះដីធ្លី ដោយប្រើប្រាស់យន្តការច្បាប់ដើម្បីធានាយុត្តិធម៌ ដោយគួបផ្សំ ជាមួយនឹងយន្តការដោះស្រាយ វិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ដែលក្នុងនោះ *រាជរដ្ឋាភិបាល* ផ្តល់អាទិភាពសមស្រប ចំពោះសិទ្ធិកាន់កាប់ដីធ្លី សម្រាប់សង់លំនៅឋាន សម្រាប់កសិកម្ម និងសម្រាប់អាជីវកម្មខ្នាតតូច របស់គ្រួសារក្រីក្រនិងក្រុមជនងាយរងគ្រោះ ។

៤០៧. ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ដី *រាជរដ្ឋាភិបាល* ជំរុញការរៀបចំផែនការប្រើប្រាស់ដី ដើម្បីបែងចែកដីសម្រាប់ការអភិវឌ្ឍ កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ តំបន់ទីក្រុង តំបន់ជនបទ តំបន់លំនៅឋាន តំបន់បម្រុងទុក និង តំបន់អភិរក្ស ចៀសវាង ការប្រើប្រាស់ដី និង ការបំប្លែងការប្រើប្រាស់ដី មិនចំសក្តានុពល ។ *រាជរដ្ឋាភិបាល* នឹងពិនិត្យឡើងវិញ និង តាមដានជាប្រចាំនូវ ការអនុវត្តក្នុងក្របខ័ណ្ឌដីសម្បទានសេដ្ឋកិច្ច ដើម្បីឱ្យស្របតាមអាទិភាពរបស់*រាជរដ្ឋាភិបាល* ដែលបានកំណត់និងធានាថា ដីសម្បទានសេដ្ឋកិច្ចមានសកម្មភាព ចៀសវាងការទុកចោលមិនមានការផលិត ។ *រាជរដ្ឋាភិបាល* បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ ។

៤០៨. *រាជរដ្ឋាភិបាលកម្ពុជា* បានដាក់ចេញនូវគោលនយោបាយជាតិ ពីរ គឺ ទី១ ស្តីពី **ការអភិវឌ្ឍជនជាតិដើមភាគតិច** និងទី២ ស្តីពី **ការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា** ក្នុងគោលបំណង : (១) ធានាការគ្រប់គ្រងដីរដ្ឋ និងពង្រីកការអភិរក្សសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថានទីតាំងនៃតំបន់មានធនធានរ៉ែធម្មជាតិ ដែលកំពុងគ្រប់គ្រងដោយអាជ្ញាធរមានអាណត្តិកាន់កាប់ដីរដ្ឋ (២) ពង្រីក និងពង្រឹងឿនសេដ្ឋកិច្ចជាតិ តាមរយៈ ការជំរុញការវិនិយោគជាមួយផ្នែកឯកជន លើវិស័យកសិ-ឧស្សាហកម្ម (ដូចជា ដំណាំកៅស៊ូ) លើវិស័យធនធានរ៉ែធម្មជាតិ និងលើវិស័យផ្សេងៗទៀត និង (៣)

បញ្ចៀសបាននូវទំនាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច ជាមួយការធ្វើសម្បទានដីសេដ្ឋកិច្ច ក្នុងគោលដៅការពារ ឧត្តមប្រយោជន៍ជាតិ និងជំរុញការអភិវឌ្ឍខឿនសេដ្ឋកិច្ច ដោយមានការចូលរួមពីសហគមន៍ ។ ដើម្បីរួមចំណែក ក្នុងការអនុវត្តគោលនយោបាយនេះ *ក្រសួងមហាផ្ទៃ* នឹងបន្តខិតខំរៀបចំលិខិតបទដ្ឋាន ដោយមានកិច្ចសហការ ជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងដោយមានការស្នើសុំពីរដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់ ដើម្បីមាន មូលដ្ឋានគតិយុត្តគ្រប់គ្រាន់ សម្រាប់ជំរុញការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច ជានីតិបុគ្គលស្របច្បាប់ ។ បច្ចុប្បន្ននេះ *រាជរដ្ឋាភិបាល* កំពុងធ្វើការស្រាវជ្រាវកំណត់តំបន់ជនជាតិដើមភាគតិច និងកំពុងធ្វើការចងក្រងបង្កើតជាសហគមន៍ ជនជាតិដើមភាគតិច តាមរយៈដំណើរការមួយដែលមានការចូលរួម ។ មកដល់ពេលនេះ *រាជរដ្ឋាភិបាល* ចុះបញ្ជី សហគមន៍ជនជាតិដើមភាគតិច បានចំនួន ៤ សហគមន៍ ហើយ កំពុងបន្តអនុវត្តការរៀបចំចុះបញ្ជីបន្ថែមទៀត នូវ សហគមន៍ទាំងឡាយណា ដែលត្រូវបានកំណត់រួចហើយ ។

៤០៩. វឌ្ឍនភាពក្នុងការបោសសម្អាតមីន ត្រូវបានឆ្លុះបញ្ចាំង តាមរយៈ ការថយចុះយ៉ាងខ្លាំងនៃអត្រាគ្រោះថ្នាក់ ដោយសារ មីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលនៅឆ្នាំ ២០០៣ មាន ៨០០ករណី មកត្រឹម ២៤៣ករណី នៅឆ្នាំ២០០៩ ការបង្កើនបណ្តាញផ្លូវថ្នល់ ការពង្រីកផ្ទៃដីកសិកម្ម និង លទ្ធភាពធ្វើដំណើរទូទាំងប្រទេសសឹងតែគ្រប់ ច្រកល្ហក ។ ក្នុង*នីតិកាលទី៤* នេះ ការបោសសម្អាតមីននិង កាកសំណល់ជាតិផ្ទុះពីសង្គ្រាម នៅតែជាអាទិភាពរបស់ *រាជរដ្ឋាភិបាល* ពិសេស នៅតំបន់ដាច់ស្រយាល តំបន់ដែលកសិករខ្វះដី និង តំបន់មានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍ កសិកម្មនិងហេដ្ឋារចនាសម្ព័ន្ធ ។ ទន្ទឹមនឹងនេះ សកម្មភាពដោះមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវផ្សារភ្ជាប់ នឹងគោលការណ៍បែងចែកដី សម្អាតរួចហើយនេះ ឱ្យប្រជាកសិករដែលខ្វះដីពិតប្រាកដ ប្រកបដោយសមធម៌ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤១០. ដើម្បីអនុវត្ត គោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* មានផែនការសកម្មភាព ដូចខាងក្រោម :

- រៀបចំការអនុវត្តកម្មវិធីកំណែទម្រង់ដីធ្លី តាមរូបភាពនៃអភិក្រមគ្រប់គ្រងទូទាំងវិស័យដីធ្លី (រដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី) ដោយមានយន្តការច្បាស់លាស់សម្រាប់ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការកៀរគរការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញនិងតម្រង់ទិស ការអនុវត្តក្របខ័ណ្ឌ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលមានស្រាប់ ឱ្យចំគោលដៅនៃការកែទម្រង់ដីធ្លី ដូចដែល បានកំណត់ ក្នុងសេចក្តីថ្លែងការណ៍របស់ *រាជរដ្ឋាភិបាលកម្ពុជា* ស្តីពីគោលនយោបាយដីធ្លី ។
- បន្តជំរុញការចុះបញ្ជីដីធ្លីឱ្យបានច្បាស់លាស់ ដើម្បីផ្តល់កម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់ (រដ្ឋនិងឯកជន) ដើម្បីធ្វើការផ្ទេរសិទ្ធិកាន់កាប់លើទ្រព្យទាំងនោះជាផ្លូវការ ព្រមទាំង ដើម្បីទប់ស្កាត់និង

ដោះស្រាយវិវាទដីធ្លី សំដៅ ពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងធានាឱ្យបាននូវ ប្រសិទ្ធភាពនិង ទំនុកចិត្តលើ ទីផ្សារដី ព្រមគ្នានឹង បន្តជំរុញការរៀបចំក្របខ័ណ្ឌ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន គតិយុត្ត សម្រាប់គាំទ្រដល់ ការអនុវត្តរបស់ស្ថាប័នពាក់ព័ន្ធទាំងអស់ ។

- បង្កើនល្បឿននៃ ការរៀបចំផែនការរៀបចំដែនដី នៅគ្រប់កម្រិត និង ការធ្វើផែនទីដីរដ្ឋ សម្រាប់គ្រប់ក្រុង ស្រុក ខណ្ឌ ឱ្យបានស្របតាមគោលការណ៍ដែល មានតម្លាភាព មានការចូលរួម មានការព្រមព្រៀង និង ដោយមានការគោរពតាម ឋានានុក្រម បទបញ្ញា និងនីតិវិធីពាក់ព័ន្ធដែលមាន តម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព ក្នុងដំណើរការនៃការរៀបចំផែនការ ទាំងនៅ តំបន់ទីប្រជុំជន និង តំបន់ជនបទ ព្រមទាំង ទប់ស្កាត់វិវាទលើការប្រើប្រាស់ដី ដោយដាក់បញ្ញត្តិលើ ការអភិវឌ្ឍដី ការប្តូររូបភាពនៃការប្រើប្រាស់ដី ការកែសម្រួលក្បាលដី និង ការសាងសង់ ។
- ផ្តល់ការគាំទ្របច្ចេកទេស ក្នុងក្របខណ្ឌនៃ *គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ* ដើម្បីជំរុញការអនុវត្តនូវ ការបែងចែកនិងប្រើប្រាស់ដីរដ្ឋ ប្រកបដោយតម្លាភាពនិងសមធម៌ និង ដោយផ្អែកលើប្រភេទនិងគុណភាពអំណោយផលពីធម្មជាតិនៃដី សំដៅ (១) បម្រើ គោលបំណងឯកជននិងសាធារណៈ (២) ធានាឱ្យមាន ស្ថិរភាពសង្គម សន្តិសុខស្បៀង និងការសម្រួល ដល់ការវិនិយោគ (៣) ឆ្លើយតបទៅនឹងផលប្រយោជន៍សាធារណៈ ការការពារបូរភាពទឹកដី និងតម្រូវការជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេស ប្រជា-ពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះ អតីតកងកម្លាំងប្រដាប់អាវុធនិងក្រុមគ្រួសារ គ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ គ្រួសារគ្មានដី គ្មានលំនៅឋាន និងសហគមន៍ជនជាតិដើមភាគតិច តាមរយៈ (១) ការអនុវត្ត *កម្មវិធីសម្បទានដីសង្គមកិច្ច អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ* និង *សារាចរលេខ ០២ សណន ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់* និង (២) ការជំរុញការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព របស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងខេត្ត ដែលមានសហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានបង្កើតឡើងជាផ្លូវការ រួចហើយ ។
- សហការជាមួយអាជ្ញាធរផ្តល់សម្បទានដីសេដ្ឋកិច្ច ក្នុងការជំរុញភាពជាដៃគូ រវាងម្ចាស់ចម្ការខ្នាតតូច និងកសិដ្ឋានដាំដុះនិងសាជីវកម្មនៅក្នុងផលិតកម្មកសិកម្ម ក៏ដូចជា រវាង សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច សំដៅជំរុញនិងលើកទឹកចិត្តដល់គ្រួសារក្រីក្រ នៅក្នុងផលិតកម្មកសិកម្ម និងដល់ការបង្កើតការងារធ្វើនិងទីផ្សារ សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋាន ទាំងនោះ ។

៤១១. ផែនការសកម្មភាពជាក់ស្តែងរបស់ *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* មានដូចខាងក្រោម ៖

- បន្តជំរុញបង្កើត ក្របខ័ណ្ឌគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងទៅនឹងការពង្រឹងការអនុវត្ត *ច្បាប់ភូមិបាល* និង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ដោយមានតម្លាភាព និងមានការចូលរួមពីគ្រប់

ភាគីពាក់ព័ន្ធទាំងក្នុងនិងក្រៅ*រាជរដ្ឋាភិបាល* និង ដោយធានាថា សិទ្ធិនិងផលប្រយោជន៍ របស់ស្ត្រីនិងជនពិការ ត្រូវបានគាំពារ ប្រកបដោយសមធម៌និងយុត្តិធម៌ ដើម្បីគាំទ្រដល់ ការពង្រឹងរដ្ឋបាលដីធ្លី ការងាររៀបចំដែនដីនិងសំណង់ និងការងារបែងចែកដីធ្លី ដែលជាអនុវិស័យគន្លឹះ ទាំង៣ នៃកម្មវិធីកំណែទម្រង់ដីធ្លីរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ សកម្មភាពអាទិភាព ចំពោះមុខ ដែលត្រូវយកចិត្តទុកដាក់ រួមមាន :

- រៀបចំ*ឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី* ទៅជា *គោលនយោបាយដីធ្លីទូលំទូលាយ* ( *សៀវភៅស* ) ។
- បន្តរៀបចំ និង ដាក់ឱ្យអនុវត្តនូវ ក្របខ័ណ្ឌគោលនយោបាយនិងច្បាប់ ដែលចាំបាច់សម្រាប់កំណែទម្រង់ដីធ្លី ក្នុងនោះរួមមាន : *គោលនយោបាយរៀបចំដែនដី គោលនយោបាយជាតិលំនៅឋាន ក្របខ័ណ្ឌគោលនយោបាយនិងច្បាប់សម្រាប់ការវាយតម្លៃថ្លៃដី ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីការវាស់វែងនិងផែនទី ច្បាប់ស្តីពីសិទ្ធិបុព្វកៃ ច្បាប់វិសោធនកម្មច្បាប់ភូមិបាលដើម្បីបន្ស៊ីជាមួយក្រមនីតិវិធីរដ្ឋប្បវេណីនិងក្រមរដ្ឋប្បវេណី ក្រមសំណង់ ស្តង់ដារជាតិខាងសំណង់ សារាចរណែនាំស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីដែលកាន់កាប់ខុសច្បាប់ ក្នុងទីក្រុងនិងទីប្រជុំជន* គោលការណ៍ណែនាំដែលទាក់ទងនឹងការរៀបចំច្រកចេញចូលតែមួយ សម្រាប់ការងារផ្តល់សេវាសុរិយោដី ការបង្រួមក្បាលដី ការបំបែកក្បាលដី ការវាយតម្លៃថ្លៃដីនិងទីផ្សារដី និង ការគ្រប់គ្រងការអភិវឌ្ឍដីនៅតំបន់ជនបទនិងតំបន់ទីប្រជុំជន សម្រាប់បម្រើឱ្យផលិតកម្មកសិកម្ម ការសាងសង់ និងការកំណត់ឱ្យបានត្រឹមត្រូវនូវកម្ពស់អគារ ក្នុងទីក្រុងនិងប្រជុំជន ជាពិសេស នៅ*រាជធានីភ្នំពេញ* ។ល។
- ផ្តល់ការគាំទ្របច្ចេកទេស នៅក្នុងការរៀបចំក្របខ័ណ្ឌច្បាប់និងនីតិវិធី សម្រាប់អនុវត្តការយកពន្ធប្រចាំឆ្នាំលើ អចលនវត្ថុ ផ្ទះសំបែង និង ដីដែលមិនមែនជាដីកសិកម្មសម្រាប់ការបង្កបង្កើនផលជាលក្ខណៈគ្រួសារ ។

• បង្កើនល្បឿននៃ ការកសាងបទប្បញ្ញត្តិនិងបទដ្ឋានបច្ចេកទេស សម្រាប់វិស័យសំណង់ដែលកំពុងមានការរីកចម្រើន ជាពិសេស សម្រាប់ការសាងសង់អគារខ្ពស់ៗ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ក៏ដូចជាដើម្បីឆ្លើយតបទៅនឹង លក្ខខណ្ឌតម្រូវរបស់សហគមន៍អន្តរជាតិនិងតំបន់ និង លក្ខខណ្ឌនៃការបង្កឱ្យមានភាពងាយស្រួលដល់ជនពិការ ដោយធ្វើការបំពាក់មធ្យោបាយសមរម្យដល់ មន្ត្រីជំនាញរបស់ក្រសួងសម្រាប់ការងារស្រាវជ្រាវ អំពីការរីកចម្រើននៃបច្ចេកវិទ្យា និងសម្រាប់ការគ្រប់គ្រងត្រួតពិនិត្យផ្នែកបច្ចេកទេស ប្រកបដោយប្រសិទ្ធភាព ។

- លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត*អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋនៅរាជធានីខេត្ត* និង បង្កើតឡើងជាជំហានៗនូវ បញ្ជីសារពើភ័ណ្ឌអចលនវត្ថុរបស់រដ្ឋ (ដីនិងអគារ) នៅក្នុងប្រព័ន្ធទិន្នន័យឯកភាពមួយ ដើម្បីពង្រឹង ការគ្រប់គ្រង ការប្រើប្រាស់ និងការបែងចែក ដីរដ្ឋ របស់រដ្ឋបាលគ្រប់ថ្នាក់ ជាពិសេស រដ្ឋបាលវិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ឱ្យប្រព្រឹត្តទៅ បានចំសក្តានុពលនៃដី និងប្រកបដោយ តម្លាភាព គណនេយ្យភាព សមធមិ ចីរភាព និងប្រសិទ្ធភាព ។
- បង្កើនល្បឿនចុះបញ្ជី ដីរដ្ឋ (ដីសាធារណៈ និង ដីឯកជនរបស់រដ្ឋ) និង ដីឯកជន (ដីឯកជនរបស់បុគ្គលឯកជនរបស់សម្ហូហភាព និង អគារសហកម្មសិទ្ធិ) តាមនីតិវិធីទាំងពីរដែលមានជាធរមាន *(ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ)* ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព និង ដោយមានការចូលរួម ពីគ្រប់ភាគីពាក់ព័ន្ធទាំងក្នុងនិងក្រៅ*រាជរដ្ឋាភិបាល* ជាពិសេស ពីស្ត្រីជាមេគ្រួសារ ។ ការចុះបញ្ជីដីធ្លីនេះ នឹងផ្តល់អាទិភាពទៅដល់ តំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច និង តំបន់ដីកម្មសិទ្ធិសម្ហូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលមានការទទួលស្គាល់ជាផ្លូវការ ។ ចំណុចដៅនៃការចុះបញ្ជីដីធ្លី នូវក្បាលដីឯកជនសរុប ៦-៧លានក្បាលដី ដែលត្រូវចុះបញ្ជី គឺស្មើនឹង ៣២ភាគរយ នៅឆ្នាំ២០១០ និង ៣៨ភាគរយ នៅឆ្នាំ ២០១៣ ហើយ ចំណុចដៅនៃការចុះបញ្ជីដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច គឺស្មើនឹង ២/៥ នៃក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចសរុប ដែលត្រូវបានបង្កើតនិងទទួលស្គាល់រួច ជាផ្លូវការ សម្រាប់ខេត្តនីមួយៗ ក្នុងមួយឆ្នាំ ។
- សហការជាមួយ *ក្រសួងមហាផ្ទៃ* និង *ក្រសួងអភិវឌ្ឍន៍ជនបទ* ដើម្បីសិក្សាអំពីវិធានការការពារជាបណ្តោះអាសន្ន ចំពោះដីសហគមន៍ជនជាតិដើមភាគតិចទាំងឡាយ ដែល*ក្រសួងមហាផ្ទៃ* បានទទួលស្គាល់ជាផ្លូវការរួចហើយ ក្នុងពេលកំពុងរង់ចាំការចុះបញ្ជីដីធ្លីទាំងនោះ ជាកម្មសិទ្ធិសម្ហូហភាពរបស់សហគមន៍ ជាផ្លូវការ ។
- សិក្សារៀបចំបង្កើតឡើងនូវប្រព័ន្ធព័ត៌មានដីធ្លីមួយ ដែលសាធារណៈជន អាចមើលឃើញនិងដឹងឮបានដោយងាយស្រួល និងដើម្បីជាមូលដ្ឋាន សម្រាប់ការបង្កើតឡើងនូវប្រព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ និងសម្រាប់ការប្រើប្រាស់ ក្នុងគោលបំណងជាប្រយោជន៍ស្របច្បាប់ ផ្សេងទៀត ។
- សហការជាមួយ*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីរៀបចំសេចក្តីព្រាង*ច្បាប់ស្តីពីដីកសិកម្ម* បង្កើតប្រព័ន្ធព័ត៌មានធរណីសាស្ត្រ ព្រមទាំង ធ្វើចំណាត់ថ្នាក់ប្រភេទដី ដោយផ្អែកលើលក្ខណៈធម្មជាតិរបស់ដី ឱ្យមានលក្ខណៈឯកភាពគ្នា នៅទូទាំងប្រទេស ។
- បន្តរៀបចំ បណ្តាញប្រថពីវិភាគ និង បណ្តាញរយៈកម្ពស់ នៅទូទាំងប្រទេស និង បង្កើតស្ថានីយអចិន្ត្រៃយ៍ សម្រាប់ *ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ* ។

- បង្កើនល្បឿនដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ តាមរយៈ *គណៈកម្មការសុរិយោដី* នៅគ្រប់ថ្នាក់ (ថ្នាក់ជាតិ រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ) ដោយ (១) ធ្វើប្រតិភូកម្មនូវមុខងារធ្វើសេចក្តីសម្រេចដល់រដ្ឋបាលថ្នាក់រាជធានី-ខេត្ត (២) បង្កើត*ក្រុមដោះស្រាយវិវាទដីធ្លីចល័ត* នៅតាមស្រុកទាំងឡាយដែលនៅមានវិវាទ សេសសល់ច្រើន (៣) ពង្រឹងសមត្ថភាពសម្រុះសម្រួលវិវាទដល់អ្នកជំនួយការរបស់ភាគីវិវាទ នីមួយៗ និង (៤) ធ្វើកិច្ចសហការជិតស្និទ្ធជាមួយ *អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី* ចំពោះករណីវិវាទពហុភាគី ។
- បង្កើតប្រព័ន្ធផែនការរៀបចំដែនដី ដែលរួមមាន ប្លង់គោល ឬ ផែនការរៀបចំដែនដី ថ្នាក់ជាតិ ថ្នាក់ភូមិភាគ ថ្នាក់ខេត្ត និង ផែនការប្រើប្រាស់ដីនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ដោយមានការចូលរួមពីវិស័យជំនាញពាក់ព័ន្ធ និង ពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះរួមមាន អង្គការសង្គមស៊ីវិល និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗទៀត ជាពិសេស ស្ត្រីជាមេគ្រួសារ ជនពិការ (ប្រសិនបើមាន) ដើម្បីធានាចីរភាពបរិស្ថាន និងដើម្បីគាំទ្រដល់វិមជ្ឈការនិងវិសហមជ្ឈការនៃ ការរៀបចំដែនដី ការរៀបចំផែនការអភិវឌ្ឍន៍ដីការកំណត់ច្បាស់លាស់នូវតំបន់ប្រើប្រាស់ដី ជាពិសេស នៅតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច ដូចជា *រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តបាត់ដំបង* និង បណ្តាខេត្តតាមតំបន់ឆ្នេរទាំងអស់ ព្រមទាំង ការជំរុញការកសាង *ផែនការយុទ្ធសាស្ត្រជាតិស្តីពីសមាហរណកម្មតំបន់ឆ្នេរ* ផងដែរ ។
- ដោយផ្អែកលើមូលដ្ឋាននៃលទ្ធភាពថវិកាជាតិ *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* នឹងជំរុញការបែងចែកដីធ្លីសម្រាប់គោលដៅសង្គមកិច្ច ដល់គ្រួសារប្រជាពលរដ្ឋក្រីក្រដែលគ្មានដី ឱ្យបាន ១០ ០០០គ្រួសារ ត្រឹមឆ្នាំ២០១៣ តាមស្មារតីនៃ*សារាចរណែនាំ លេខ ០៦ របស់រាជរដ្ឋាភិបាល ស្តីពីផែនការបែងចែកដីសម្បទានសង្គមកិច្ច* ។ ក្នុងករណីមានប្រភពទុនពីដៃគូអភិវឌ្ឍន៍ ចំណុចដៅនេះ នឹងត្រូវបានបង្កើនថែមទៀត ទៅតាមផែនការនិងលទ្ធភាពទុនដែលមាន និងកិច្ចព្រមព្រៀងជាក់ស្តែង ជាមួយដៃគូដែលផ្តល់ជំនួយទាំងនោះ ។ ក្នុងក្របខ័ណ្ឌនៃ*គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ* ក្រសួងក៏បានជំរុញការអនុវត្តគោលនយោបាយរបស់*រាជរដ្ឋាភិបាល* ក្នុងការផ្តល់សម្បទានដីសង្គមកិច្ច ដល់អតីតកងយោធពលខេមរភូមិន្ទដែលចូលនិវត្តន៍និងក្រុមគ្រួសារ ទៅតាមបរិមាណ និងផែនការជាក់ស្តែងប្រចាំឆ្នាំនីមួយៗដែល*រាជរដ្ឋាភិបាល* បានដាក់ចេញ ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់*រាជរដ្ឋាភិបាល* ក្នុងការដោះស្រាយបញ្ហាសង្គម និងកិច្ចការពារជាតិ ។
- សហការជាមួយ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ក្នុងការរៀបចំសេចក្តីព្រាង *ច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ* ប្រកបដោយ តម្លាភាព និង គណនេយ្យភាព ។
- ពង្រឹងការងារសវនកម្មផ្ទៃក្នុង និងក្រុមការងារអធិការកិច្ចរបស់ក្រសួង ដោយមានផែនការ កាលវិភាគអនុវត្តន៍ច្បាស់លាស់ សម្រាប់ការតាមដានត្រួតពិនិត្យ ការអនុវត្តរាល់ផែនការ និងការណែនាំនានាដែល*រាជរដ្ឋាភិបាល* បានដាក់ចេញ ។

៤១២. **ការបោសសម្អាតមីន** : ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានគួរឱ្យកត់សម្គាល់ ក្នុងការបោសសម្អាតមីន និងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ក៏នៅមាន ផ្ទៃដីជាច្រើនហិកតាដែលត្រូវបានសង្ស័យថាមានមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលនឹងបន្តជា ឧបសគ្គដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងគ្រោះថ្នាក់ដល់ប្រជាជន ជារៀងរាល់ថ្ងៃ ។ *ប្រទេសកម្ពុជា* ដែលបានក្លាយជារដ្ឋហត្ថលេខីមួយនៃ *អនុសញ្ញាស្តីពី ការហាមការប្រើប្រាស់ ការរក្សាទុក ការផលិតនិងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន* នៅក្នុងឆ្នាំ១៩៩៩ បានអនុវត្តយ៉ាងពេញលេញនូវអនុសញ្ញានេះ អស់រយៈពេល១០ឆ្នាំ ដោយគិតមកដល់ចុងឆ្នាំ២០០៩ កន្លងទៅនេះ ។ ទោះជាដូចនេះក្តី ក៏*ប្រទេសកម្ពុជា* នៅតែមិនទាន់អាចសម្រេចបាននូវចំណុចដៅដែលបានគ្រោងទុក ដោយទំហំនៃការងារបោសសម្អាតមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម មានកម្រិតធំហួសពីសមត្ថភាពរបស់*កម្ពុជា* ។ យោងតាម*មាត្រាទី៥* នៃ*អនុសញ្ញា* នេះ *កម្ពុជា* បានស្នើសុំពន្យារការបោសសម្អាតមីន សម្រាប់រយៈពេល១០ឆ្នាំបន្តទៀត ដោយគិតចាប់ពីឆ្នាំ២០១០ រហូតដល់ចុងឆ្នាំ២០១៩ ដើម្បីធ្វើការបោសសម្អាតផ្ទៃដីមានមីន ដែលនៅសល់ប្រហែល ៤៧០គីឡូម៉ែត្រក្រឡា ដោយត្រូវការថវិកាប្រមាណ ៣៣០លានដុល្លារអាមេរិក ។ ដោយមានកិច្ចសហការជាមួយនឹង ស្ថាប័នពាក់ព័ន្ធនានា *អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន* បាននិងកំពុងរៀបចំ *យុទ្ធសាស្ត្រជាតិសកម្មភាពកម្ចាត់មីន* ដើម្បីគាំទ្រដល់ ការងារបោសសម្អាតមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ។

៤១៣. ចីរភាពនៃការគាំទ្រផ្នែកថវិកា ពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា នឹងនៅបន្តជាតម្រូវការចាំបាច់ដើម្បីធ្វើឱ្យសម្រេចបាននូវគោលដៅនៃសកម្មភាពកម្ចាត់មីន ដែលបានចែងនៅក្នុង *ផយអជ* ហើយការបង្កើនការគាំទ្រ គឺជាប្រការចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវកាតព្វកិច្ច ក្នុងការអនុវត្ត *អនុសញ្ញា* ខាងលើ នៅក្នុងរយៈពេល ១០ឆ្នាំ ខាងមុខ ។

## ៣.៣ **កំណែទម្រង់វិស័យផល**

## ក. **គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤**

៤១៤. ត្រី ដែលជាធនធានធម្មជាតិមួយអាចកកើតឡើងវិញ មានតួនាទីដ៏សំខាន់ ជាម្ហូបអាហារ ចំណូល និងសន្តិសុខស្បៀង ក្នុងជីវិតរស់នៅរបស់ប្រជាជនកម្ពុជា ។ *រាជរដ្ឋាភិបាលកម្ពុជា* បានធ្វើការបែងចែកឡូត៍នេសាទដល់ប្រជាជន និងបង្កើតសហគមន៍នេសាទចំនួន ៤៦៩ ទាំងសហគមន៍នេសាទសមុទ្រ និងនេសាទទឹកសាប ។ គោលដៅរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺដើម្បីធានា និងអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គម ក៏ដូចជាសហគមន៍នេសាទ ។

៤១៥. *រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ នីតិកាលទី៤ នៃរដ្ឋសភា* នឹងបន្តអាទិភាព ក្នុងការជួយ និងការលើកទឹកចិត្ត ដល់សហគមន៍នេសាទ ក្នុងការចូលរួមរៀបចំផែនការ និងការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្តល់នូវការណែនាំ និងបណ្តុះបណ្តាលបច្ចេកទេស ដើម្បីធានាស្ថិរភាពគ្រប់គ្រងធនធានជលផល ដោយផ្អែកលើស្តង់ដារបច្ចេកទេស ។ ដើម្បីសម្រេចបានដូចគោលបំណងខាងលើ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធ្វើការកំណត់ព្រំដែនឡូត៍នេសាទច្បាស់លាស់ ។

៤១៦. ដើម្បីធានាថា តម្លៃត្រី បញ្ជាក់ពីតម្លៃពិតនៃសេដ្ឋកិច្ច *រាជរដ្ឋាភិបាលកម្ពុជា* នឹងបង្កើតយន្តការទីផ្សារត្រី មួយប្រកបដោយប្រសិទ្ធភាព ដែលត្រីជាប្រភពចំណូល ឬជាការចំណាយរបស់អ្នកក្រ សម្រាប់ការរស់នៅ ។ យន្តការទីផ្សារត្រីនេះ នឹងរួមបញ្ចូលនូវ ការរៀបចំដំណើរការដេញថ្លៃឡូត៍នេសាទឱ្យមានតម្លាភាពជាងមុន ហើយ នឹងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងឡូត៍នេសាទ ក៏ដូចជា បង្កើតចំណូលរបស់រដ្ឋ ។

៤១៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងពង្រឹងបន្ថែមទៀត នូវការអភិរក្សធនធានរបស់ជាតិ ជាពិសេស បង្កើនទំនាក់ទំនង រវាងការអភិរក្សទៅនឹងទេសចរណ៍ធម្មជាតិ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តនូវសកម្មភាពយ៉ាងម៉ឺងម៉ាត់ ប្រឆាំងនឹងទប់ស្កាត់ បទល្មើសកាប់បំផ្លាញព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ និងទប់ស្កាត់រាល់ សកម្មភាពអនាធិបតេយ្យគ្រប់ប្រភេទ ដែលប៉ះពាល់ដល់កិច្ចខិតខំអភិរក្ស តាមរយៈ ការលើកទឹកចិត្តឱ្យមានការ ចូលរួម ពីសមត្ថកិច្ចដែលមានការពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

៤១៨. ការបង្កើនវារីវប្បកម្ម គឺជាភាពចាំបាច់ ដើម្បីការពារធនធានមច្ឆជាតិ ដែល *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្តល់ នូវការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី រួមទាំង បច្ចេកទេស ពូជត្រី ឥណទាន និងទីផ្សារ ។ ការធ្វើឱ្យប្រសើរឡើង ការអនុវត្តច្បាប់ តាមរយៈ ការប្រើប្រាស់បន្តនូវយន្តការដែលមានស្រាប់ គឺជាអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការការពារធនធានជលផល ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤១៩. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* *វិស័យជលផល* នឹងផ្តោតការខិតខំយកចិត្តទុកដាក់លើ ការពង្រឹង ការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍ ធនធានជលផលប្រកបដោយចីរភាព ដែលរួមចំណែក ដល់ ការធានាសន្តិសុខស្បៀង និង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដើម្បី បង្កើនជីវភាពរបស់ប្រជាជន និង ភាពថ្កុំថ្កើងរបស់ជាតិ ។ ជាមួយគ្នានេះដែរ ដើម្បីរួមចំណែក ធានាចីរភាពវិស័យជលផល និង រក្សាការប្រើប្រាស់ត្រីរបស់ប្រជាជន ចំណុចដៅចំនួន ៣ សំខាន់ៗ ត្រូវបានដាក់ ឱ្យអនុវត្ត ក្នុងនោះរួមមាន (១) សម្រេចឱ្យបានតាមទិសដៅ ក្នុងក្របខណ្ឌ *ផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០០៩-២០១៣)* ដើម្បីឆ្លើយតបទៅនឹងគោលដៅវឌ្ឍនភាព នៃក្របខណ្ឌ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យជលផល*

*រយៈពេល ១០ឆ្នាំ* (២) យុទ្ធសាស្ត្រលម្អិតមួយសម្រាប់ កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ ក្នុងការកំណត់នូវបញ្ហាប្រឈមជាលក្ខណៈអន្តរជាតិ ចំពោះវិស័យជលផលកម្ពុជា រួមមាន បម្រែបម្រួលអាកាសធាតុ ការសាងសង់ទំនប់ និងភាពរេចរឹលនៃបរិស្ថាន ត្រូវបានបង្កើតឡើង និង អនុវត្តនៅដំណាច់ឆ្នាំ២០១៣ និង (៣) ទិន្នផលត្រីសរុបប្រចាំឆ្នាំ (រួមមានត្រីធម្មជាតិ ត្រីតាមវាលស្រែ និងវារីវប្បកម្ម) មានចំនួន ៧៨៨ ០០០តោន នៅដំណាច់ឆ្នាំ ២០១៣ ។ ដើម្បីសម្រេចបានតាមទស្សនវិស័យខាងលើ *រដ្ឋបាលជលផល* មានគោលដៅសំខាន់ៗ ចំនួន៧ សម្រាប់ណែនាំ ដូចខាងក្រោម ៖

- ការរួមចំណែករបស់វិស័យជលផលទៅដល់ការរីកចម្រើនជាតិ មានកម្រិតខ្ពស់ និងមានស្ថិរភាព ។
- ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងវិស័យនេះ កំពុងត្រូវបានធ្វើឱ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យមដែលបានកំណត់នៅថ្នាក់ជាតិ ។
- ដែននេសាទ និងប្រភពធនធានជលផលពាក់ព័ន្ធផ្សេងៗមានលក្ខខណ្ឌល្អ និងមានភាពរឹងមាំ ហើយត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព ។
- ត្រី គឺជាប្រភពអាហារដែលសម្បូរបែប មានសុខភាពល្អ និងមានតម្លៃ ។
- មុខជំនួញក្នុងរបរនេសាទ គឺមានភាពចំណេញ ស្ថិរភាព និងមានភាពទទួលខុសត្រូវ ។
- ដែននេសាទត្រូវបាន គ្រប់គ្រង អភិវឌ្ឍ និងអភិរក្ស ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយប្រទេសជិតខាង ។
- បរិយាកាស គោលនយោបាយ ច្បាប់ និងការជួយគាំទ្រ ដល់វិស័យនេះ មានលក្ខណៈគ្រប់គ្រាន់ សមស្រប និងមានសមត្ថភាព អាចអនុវត្តបាន ។

៤២០. ដើម្បីសម្រេចបានតាមគោលដៅទាំង ៧ ខាងលើ *រដ្ឋបាលជល* បានរៀបចំផែនការសកម្មភាព សំខាន់ៗ ដូចខាងក្រោម ៖

- ធានាការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកធានាសុវត្ថិភាពសន្តិសុខស្បៀង ជូនប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ។
- លើកទឹកចិត្តដល់ការរៀបចំពង្រឹងសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី នៅដែននេសាទទឹកសាប និងនៅតំបន់ឆ្នេរ ឱ្យមានប្រសិទ្ធភាព ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលឱ្យមានចីរភាព ដោយប្រគល់សិទ្ធិអំណាចទៅឱ្យសហគមន៍នេសាទមូលដ្ឋាន ។
- លើកទឹកចិត្តដល់ការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទ តាមគ្រប់រូបភាព ទាំងទឹកសាប និងសមុទ្រ ឱ្យក្លាយជាចលនាជាតិ ទូលំទូលាយ ដោយអនុវត្តតាម *ក្រមប្រតិបត្តិវារីវប្បកម្ម ដោយទទួលខុសត្រូវ ក្នុងតំបន់* ។

- លើកទឹកចិត្តដល់ ការវិនិយោគកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធជលផល ដើម្បីអភិវឌ្ឍការកែច្នៃ និងវេចខ្ចប់ផលិតផលជលផល ពង្រីកទីផ្សារ និងការប្រកួតប្រជែង ។
- រៀបចំកសាង និងផ្សព្វផ្សាយ លិខិតបទដ្ឋាននានា ពង្រឹងការអនុវត្តច្បាប់ ទប់ស្កាត់បទល្មើសជលផល និងការពារព្រៃលិចទឹក ឱ្យបានគង់វង្ស ។
- បង្កើនការយល់ដឹងដល់សហគមន៍នេសាទ និងអ្នកនេសាទ ពីសារៈសំខាន់នៃធនធានជលផល និងការអភិរក្សធនធានទាំងនោះ ដើម្បីធានាឱ្យមានស្ថិរភាព និងធានាការចូលរួមជាអតិបរមាពីសហគមន៍នេសាទមូលដ្ឋាន ក្នុងបែបផែននៃការអភិរក្ស និងការគ្រប់គ្រង ជលផល ។
- ខិតខំស្តារឡើងវិញ នូវជម្រកត្រីសំខាន់ៗ និងអេកូឡូស៊ីដែលវិចវិល តាមរយៈ ការរៀបចំស្រះជម្រកត្រីសហគមន៍ នៅគ្រប់ឃុំ និងលែងពូជមច្ឆជាតិនៅគ្រប់ឡូត៍នេសាទ និងតាមតំបន់មេទឹកសំខាន់ៗ នៅទូទាំងប្រទេស ។
- បង្កើនការកសាងធនធានមនុស្សក្នុងវិស័យជលផល សំដៅធានាគុណភាព ក្នុងការបម្រើសេវាកម្មដល់អតិថិជន ទៅតាមមុខជំនាញនីមួយៗ សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។
- លើកទឹកចិត្ត និងជំរុញ ដល់កម្មវិធីស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល លើគ្រប់ផ្នែក ។
- ផ្តល់អាទិភាព ដើម្បីប្រើប្រាស់ចំណូលថវិកាដែលទទួលបានមកពីវិស័យជលផល តាមនីតិវិធីហិរញ្ញវត្ថុពិសេស ដើម្បីសម្រេចនូវកំណែទម្រង់វិស័យជលផល ការអភិរក្សការស្រាវជ្រាវ ការអភិវឌ្ឍ និងថែរក្សាប្រភពធនធានជលផលឱ្យមានលំនឹង ។
- ធានានូវការទទួលទានផលត្រីតាម កម្រិត ៥២.៤ គក្រ ក្នុងម្នាក់ ក្នុងមួយឆ្នាំ ។

## ៣.៤ កំណែទម្រង់ព្រៃឈើ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤២១. គោលនយោបាយព្រៃឈើរបស់*រាជរដ្ឋាភិបាលកម្ពុជា* គឺ ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានព្រៃឈើ សម្រាប់លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ និងរួមចំណែក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ កន្លងមក *រាជរដ្ឋាភិបាលកម្ពុជា* បានផ្អាកការធ្វើអាជីវកម្មព្រៃឈើ បង្កើតតំបន់ព្រៃការពារនិងអភិរក្សធនធានជីវៈចម្រុះ ការដាំព្រៃឈើឡើងវិញ ការរៀបចំសហគមន៍ព្រៃឈើ ការកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ និង ការចាត់វិធានការទប់ស្កាត់បង្ក្រាបនិងលុបបំបាត់ ការដុតរានឈូសឆាយនិងហ៊ុំព័ទ្ធដីព្រៃ ធ្វើជាកម្មសិទ្ធិឯកជន ល្មើសច្បាប់ ។

៤២២. *រាជរដ្ឋាភិបាលកម្ពុជា* បានយកចិត្តទុកដាក់ចំពោះសហគមន៍ព្រៃឈើ ដែលជាយន្តការដ៏មានសារៈសំខាន់ ក្នុងការគ្រប់គ្រងព្រៃឈើ ។ ដោយផ្អែកលើសមិទ្ធផលដែលសម្រេចបានកន្លងមក *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្ត ការតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រកបដោយប្រសិទ្ធភាព លើកម្មវិធីនេះ ក្នុងការលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាជនតំបន់ជនបទ រក្សាស្ថិរភាពធនធានព្រៃឈើ និងបង្កើនចំនួនសហគមន៍ព្រៃឈើ ។ លើសពីនេះ *រាជរដ្ឋាភិបាលកម្ពុជា* លើកទឹកឱ្យមានការចូលរួមរបស់វិស័យឯកជន ក្នុងការដាំដុះព្រៃឈើ ដែលមានលក្ខណៈ សេដ្ឋកិច្ច ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ ជាពិសេស ក្នុងតំបន់ព្រៃឈើរេចរឹល ។

៤២៣. *រាជរដ្ឋាភិបាលកម្ពុជា* នឹងអនុវត្តគោលនយោបាយនិងកម្មវិធីព្រៃឈើជាតិ ដើម្បីធានាការគ្រប់គ្រងនិងការ អភិវឌ្ឍ ព្រៃឈើប្រកបដោយចីរភាព ស្របតាមបទដ្ឋានអន្តរជាតិ តាមរយៈ ការស្វែងរកជំនួយពីក្រៅប្រទេស ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និង តាមរយៈ ការអនុញ្ញាតឱ្យសង្គមស៊ីវិល បានចូលរួមក្នុងការតាមដានត្រួតពិនិត្យ នេះ ដោយសកម្មនិងសមស្រប ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញការអនុវត្ត *ច្បាប់ព្រៃឈើ* និងចាត់វិធានការ ម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ ព្រមទាំង នឹងបន្តអប់រំប្រជាពលរដ្ឋ ឱ្យយល់ដឹងពី កាតព្វកិច្ចការពារព្រៃឈើ និងបញ្ឈប់ការកាប់រានព្រៃ ដោយខុសច្បាប់ ។

៤២៤. ដោយសារព្រៃឈើ មានសំខាន់សម្រាប់លើកកម្ពស់ជីវភាពរបស់ប្រជាជន *រាជរដ្ឋាភិបាលកម្ពុជា* នឹង បង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុងទុក និង ធានានូវការទទួលបានការការពារនិងធ្វើការអភិវឌ្ឍសមស្រប រួម ទាំងទេសចរណ៍ធម្មជាតិ និងឥណទានកាបូនព្រៃឈើ ដើម្បី បង្កើតការងារ និងប្រភពចំណូលបន្ថែមជូនប្រជាជន ។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក៏ត្រូវបានបន្តការយកចិត្តទុកដាក់ខ្ពស់ ផងដែរ ។ *រាជរដ្ឋាភិបាល កម្ពុជា* នឹងកៀរគរ ធនធាន ការគាំទ្រ និងហិរញ្ញប្បទាន នានា ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភព លោក ក្នុងការដោះស្រាយបញ្ហា បម្រែបម្រួលអាកាសធាតុ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤២៥. ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ នីតិកាលទី៤ នៃរដ្ឋសភា រដ្ឋបាលព្រៃឈើ* បានរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តកម្មវិធីព្រៃឈើជាតិ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយ រួមបញ្ចូលផងដែរនូវការងារ ដូចខាងក្រោម :

- បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃ ប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃកម្មវិធី ក្នុងនោះ រួមមាន ការផ្តោត ការយកចិត្តទុកដាក់លើ ការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើ ឱ្យបានកាន់តែទូលំទូលាយ ។

- ផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការដាំដុះព្រៃឯកជនដែលមានលក្ខណៈសេដ្ឋកិច្ច ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ នៅក្នុងតំបន់ព្រៃឈើរេចរឹល ។
- បន្តយកចិត្តទុកដាក់តាមដានត្រួតពិនិត្យ ការធ្វើអាជីវកម្មព្រៃឈើសម្បទាន ឱ្យសមស្របតាមបទដ្ឋានអន្តរជាតិ តាមរយៈ ការស្វែងរកជំនួយពីក្រៅប្រទេស ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងតាមរយៈ ការអនុញ្ញាតឱ្យសង្គមស៊ីវិល បានចូលរួមក្នុងការតាមដានត្រួតពិនិត្យនេះ ដោយសកម្មនិងសមស្រប ។
- បន្តយកចិត្តទុកដាក់ក្នុងការពង្រឹងការអនុវត្ត*ច្បាប់ព្រៃឈើ* និង ចាត់វិធានការម៉ឺងម៉ាត់ ចំពោះបទល្មើសព្រៃឈើ ព្រមទាំង បន្តអប់រំប្រជាជនឱ្យយល់ពីកាតព្វកិច្ចការពារព្រៃឈើ និងបញ្ឈប់ការកាប់រានព្រៃដោយខុសច្បាប់ ។
- បង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុងទុក និងធានាថាព្រៃបម្រុងនោះ ត្រូវបានទទួលការការពារ និងការអភិវឌ្ឍសមស្រប រួមទាំងទេសចរណ៍ធម្មជាតិ ដើម្បី បង្កើតការងារ និងប្រភពចំណូលបន្ថែម ជូនប្រជាជន ។ ទន្ទឹមនឹងនេះ ការគ្រប់គ្រង តំបន់ការពារធម្មជាតិ ក៏ត្រូវបានបន្តការយកចិត្តទុកដាក់ខ្ពស់ផងដែរ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងកៀរគរ ធនធាន ការគាំទ្រ និងហិរញ្ញប្បទាន នានា ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោក ក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ ជាពិសេសតាមរយៈ យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ ។
- បន្តពង្រឹង ការកសាងសមត្ថភាព ការស្រាវជ្រាវ និងការអភិវឌ្ឍ វិស័យព្រៃឈើ ប្រកបដោយចីរភាព ។

## កិច្ចការពារ ការអភិរក្ស បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

៤២៦. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងបរិស្ថាន* នឹងអនុវត្តសកម្មភាព ដូចខាងក្រោម :

- ធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ហើយ អនុវត្តនូវវិធានការនានា ដែលតម្រូវឱ្យមាន*ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន* លើគម្រោងអភិវឌ្ឍន៍នានាដែលបានស្នើឡើង មុននឹងមានការអនុញ្ញាតឱ្យអនុវត្តនូវគម្រោងទាំងនោះ ។
- ធានាមិនឱ្យមានការបំពុល ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានទឹក ។
- ទប់ស្កាត់ និងកាត់បន្ថយ ការបំពុលបរិស្ថាន ។
- ពង្រឹង ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បី លុបបំបាត់ភាពអនាធិបតេយ្យក្នុងតំបន់ទាំងនោះ លុបបំបាត់ការធ្វើអាជីវកម្មធនធានធម្មជាតិខុសច្បាប់ និង ត្រួតពិនិត្យ ការទន្ទ្រានដីដើម្បីប្រើប្រាស់ និង ការកាប់ព្រៃឈើខុសច្បាប់ ។
- ធានាឱ្យមាន ការគោរព និង ការអនុវត្ត *ច្បាប់បរិស្ថាន* ។

- ស្វែងរក ប្រភពធនធាន និងការគាំទ្រ ផ្នែកហិរញ្ញវត្ថុ សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ទាំងវិធានការបន្សាំ ទាំងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

៤២៧. *ក្រសួងបរិស្ថាន* នឹងរៀបចំលិខិតបទដ្ឋាន និងឯកសារច្បាប់ មួយចំនួន ដូចខាងក្រោម ៖

- រៀបចំ*សេចក្តីព្រាងច្បាប់ស្តីពី ការទទួល និងការបែងចែក ផលប្រយោជន៍ពីធនធានសេនេទិច និង ចំណេះដឹងជាប្រពៃណី* ។
- រៀបចំ*ច្បាប់ស្តីពី ការត្រួតពិនិត្យការបំពុលទឹក* ។
- រៀបចំ*ច្បាប់ស្តីពី ការគ្រប់គ្រង សំណល់រឹង និង សំណល់គ្រោះថ្នាក់* ។
- រៀបចំ*ច្បាប់ស្តីពី ការគ្រប់គ្រង ការបំពុលខ្យល់ និង ការរំខានដោយសម្លេងនិងរំញ័រ* ។
- រៀបចំ*សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងសារធាតុគីមី* ។
- ពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម*ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព* ។
- រៀបចំ*អនុក្រឹត្យស្តីពី មូលនិធិការពារតំបន់ធម្មជាតិ* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការកំណត់តំបន់ការពារធម្មជាតិ* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការផ្តល់ដីសម្រាប់បង្កើនផលិតភាពជូនដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការរៀបចំកំណត់តំបន់រុក្ខឧទ្យានជាតិភ្នំគូលែន* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការរៀបចំកំណត់តំបន់ឧទ្យានជាតិសមុទ្រ* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការរៀបចំកែប្រែតំបន់ការពារធម្មជាតិ* ។
- រៀបចំ*អនុក្រឹត្យស្តីពី ការបង្កើតតំបន់ការពារធម្មជាតិថ្នាក់រាជធានី-ខេត្ត* ។
- បន្តរៀបចំ*គោលការណ៍ណែនាំស្តីពី ការរៀបចំរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន តាមវិស័យនីមួយៗ* ។
- ត្រៀមរៀបចំ *គោលនយោបាយជាតិស្តីពី ការគ្រប់គ្រងសំណល់រឹងនិងសំរាម* សម្រាប់ធ្វើជាផែនទីចង្អុលផ្លូវក្នុងការអនុវត្តឱ្យបានព្រមគ្នា នៅទូទាំងប្រទេស ។
- រៀបចំ*គោលការណ៍ណែនាំស្តីពី ការគ្រប់គ្រង សំណល់រាវ ប្រកបដោយចីរភាពបរិស្ថាន* ។
- រៀបចំ*គោលការណ៍ណែនាំ ដើម្បីជំរុញការអនុវត្ត ការប្រើប្រាស់កាកសំណល់ឡើងវិញ ការកែច្នៃកាកសំណល់សម្រាប់ប្រើប្រាស់ជាវត្ថុធាតុដើម និង ការកាត់បន្ថយការបង្កើតកាកសំណល់ (3R)* តាមរយៈ ការអនុវត្ត នៅតាមតំបន់គំរូមួយចំនួន ។

- រៀបចំ *គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងការបំពុលខ្យល់ និង ការរំខានដោយសម្លេង* ។
- រៀបចំសកម្មភាពសម្រាប់ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។
- រៀបចំបញ្ជាប *ផែនការសកម្មភាព សម្រាប់ការគ្រប់គ្រងសារធាតុគីមី ប្រកបដោយចីរភាព ទៅក្នុងការអភិវឌ្ឍជាតិ* ។
- រៀបចំ *គោលការណ៍ណែនាំស្តីពី ការកសាងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ* ។
- រៀបចំ *គោលការណ៍ណែនាំស្តីពី ការបែងចែកតំបន់គ្រប់គ្រងនីមួយៗ ក្នុងតំបន់ការពារធម្មជាតិ* ។

៤២៨. នៅក្នុងផ្នែក *ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថាន* នឹងសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឱ្យមាន ការប្រើប្រាស់ប្រកបដោយចីរភាព នូវធនធានធម្មជាតិ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព ដោយធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹង អនុវត្តគម្រោងអភិវឌ្ឍន៍នានា តាមរយៈ :

- ការពង្រឹងសមត្ថភាពបច្ចេកទេសរបស់មន្ត្រីជំនាញ នៅគ្រប់កម្រិត ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។
- ការរៀបចំ និង ការធ្វើវិសោធនកម្ម ក្របខណ្ឌច្បាប់និងគោលនយោបាយ ដែលពាក់ព័ន្ធនឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។
- ការពង្រឹងការតាមដានត្រួតពិនិត្យ លើការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង លើការអនុវត្តកិច្ចព្រមព្រៀងការការពារបរិស្ថានរបស់ម្ចាស់គម្រោង នៅក្នុងសកម្មភាពអភិវឌ្ឍន៍របស់ខ្លួន ។

៤២៩. នៅក្នុងផ្នែក *ការត្រួតពិនិត្យការបំពុលបរិស្ថាន ក្រសួងបរិស្ថាន* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- ធានាទប់ស្កាត់ ការបំពុល បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និង ទឹក ។
- ត្រួតពិនិត្យ និងកាត់បន្ថយ ការបំពុលបរិស្ថាន និងវាយតម្លៃគុណភាពបរិស្ថាន ។
- ត្រួតពិនិត្យ និងកាត់បន្ថយ ការបំពុលទឹក ។
- អនុវត្តការគ្រប់គ្រង សំណល់រឹង និងសារធាតុប្រកបដោយគ្រោះថ្នាក់ដទៃទៀត ប្រកបដោយសុវត្ថិភាពបរិស្ថាន ។
- ត្រួតពិនិត្យនិងកាត់បន្ថយ ការបំពុលខ្យល់ និង ការរំខានដោយសំលេងនិងរំញ័រ ។
- ជំរុញការអនុវត្ត *ការប្រើប្រាស់កាកសំណល់ឡើងវិញ ការកែច្នៃកាកសំណល់សម្រាប់ប្រើប្រាស់ជាវត្ថុធាតុដើម និងការកាត់បន្ថយការបង្កើតកាកសំណល់* (3R) ដើម្បីកាត់បន្ថយសំណល់ និងកែច្នៃ សម្រាប់ប្រើប្រាស់ឡើងវិញ ឬនាំចេញ ។

- ពិនិត្យពិចារណា ដាក់បញ្ចូលបន្ថែម នូវសារធាតុក្នុងខ្យល់ ដែលអាចបង្កគ្រោះថ្នាក់ ដល់សុខភាពនិងបរិស្ថាន នៅក្នុងការងារតាមដានត្រួតពិនិត្យ គុណភាពខ្យល់ ។
- ពង្រឹង គុណភាព និង សមត្ថភាព មន្ទីរពិសោធន៍ ។
- ពង្រឹងសមត្ថភាពមន្ត្រីជំនាញស្តីពី ការបំពុលបរិស្ថាន ព្រមទាំង លើកកម្ពស់ការយល់ដឹងរបស់សាធារណជន ស្តីពី ការការពារបរិស្ថាន ។

៤៣០. នៅក្នុងផ្នែក *ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន* នឹងអនុវត្ត សកម្មភាពមួយចំនួន ដូចខាង ក្រោម :

- ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ។
- រៀបចំ ផែនទី ការបោះបង្គោលព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និង ការគ្រប់គ្រងទិន្នន័យ នៅ តំបន់ការពារធម្មជាតិ ។
- រៀបចំ បង្កើតរុក្ខឧទ្យានជាតិ និងឧទ្យានជាតិសមុទ្រ ។
- កំណត់តំបន់សក្តានុពល សម្រាប់ការចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ នៅតំបន់ការពារ ធម្មជាតិ ។
- ពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ។
- ពង្រឹង ការគ្រប់គ្រង និងការអភិរក្ស តំបន់ដីសើម ទីជម្រាល ឋបនីយជីវមណ្ឌល និងតំបន់ឆ្នេរ ។
- បន្តរៀបចំទិវា ដីសើម ។
- ផ្តោតការយកចិត្តទុកដាក់លើ ការងារជាយុទ្ធសាស្ត្រមួយចំនួន ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ :
  - ➢ ពង្រឹងសមត្ថភាពរបស់ *លេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ* ។
  - ➢ ជំរុញ និងសម្របសម្រួលការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ ទៅក្នុងវិស័យពាក់ព័ន្ធ ។
  - ➢ បន្តរៀបចំ *របាយការណ៍ជាតិលើកទី២* ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួល អាកាសធាតុ ។
  - ➢ រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។
  - ➢ ជំរុញនូវការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិ ។
  - ➢ ជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម *កម្មវិធីសកម្មភាពជាតិ* ស្តីពីការ *បន្សាំនឹងការប្រែប្រួលអាកាសធាតុ* ។
  - ➢ បន្តកំណត់រកនិងជំរុញការអនុវត្ត យន្តការអភិវឌ្ឍន៍ស្អាត និងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នានា ។
  - ➢ អប់រំ និងផ្សព្វផ្សាយ ដល់សាធារណជន ស្តីពី ការប្រែប្រួលអាកាសធាតុ ។
  - ➢ កៀរគរធនធាន និងការគាំទ្រ សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ។

- ធ្វើវិមជ្ឈការ ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន ។

៤៣១. ដើម្បីផ្តល់ *ការអប់រំពីបរិស្ថាន និងព័ត៌មានស្តីពីបរិស្ថាន ក្រសួងបរិស្ថាន* នឹង :

- សម្របសម្រួល និង សហការ ជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធ លើការងារអប់រំបរិស្ថាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ។
- ពង្រឹងការអភិវឌ្ឍធនធានមនុស្ស សម្រាប់ការងារអប់រំបរិស្ថាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ។
- អនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹងពីបរិស្ថាន និងការផ្លាស់ប្តូរព័ត៌មានទាន់ហេតុការណ៍ ដើម្បីបន្សុំានឹងការប្រែប្រួលអាកាសធាតុ ។
- លើកកម្ពស់ការអប់រំនិងការផ្សព្វផ្សាយ ពី គ្រោះថ្នាក់នៃការប្រើប្រាស់សារធាតុ ប្រកបដោយគ្រោះថ្នាក់ និងសំណល់របស់វា នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃសកម្មភាពសេដ្ឋកិច្ច រួមមាន ការផលិត ការនាំចូល-ការនាំចេញ ការស្តុកទុក ការដឹកជញ្ជូន ការចែកចាយ ការប្រើប្រាស់ និង ការបោះបង់ចោល ។

## ការគ្រប់គ្រងគ្រោះមហន្តរាយ

៤៣២. នៅក្នុង នីតិកាលទី៤ នៃរដ្ឋសភា *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្តោតការយកចិត្តទុកដាក់ លើការអនុវត្ត *"ផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣"* តាមរយៈ ការពង្រឹងយន្តការមួយ ដែលមានការចូលរួម និងការសម្របសម្រួលដ៏មានប្រសិទ្ធភាព ពីគ្រប់អ្នកមានចំណែកពាក់ព័ន្ធ ទាំងក្នុង *រាជរដ្ឋាភិបាល* ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិល ។ ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ *គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* នឹងអនុវត្តកម្មវិធីអាទិភាព ដូចតទៅ :

- ធ្វើការកែទម្រង់ប្រព័ន្ធនិងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីឆ្លើយតបនឹងតម្រូវការ នៅគ្រប់កម្រិត ។
- ជំរុញការបង្កើតក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ (នៅក្នុងក្រសួង-ស្ថាប័នដែលមិនទាន់មានក្រុម-ការងារនេះ) និងការកែសម្រួលរចនាសម្ព័ន្ធក្រុមការងារ (នៅក្នុងក្រសួង-ស្ថាប័នដែលបានបង្កើតក្រុម-ការងារនេះរួចហើយ) ដោយផ្អែកលើស្មារតី *អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* ។
- រៀបចំ ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំជាគោលនយោបាយ សម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

- រៀបចំ និងអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ និង ផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីលើកកម្ពស់ការបញ្ជ្រាប និងការធ្វើសមាហរណកម្ម *ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ* និង*ការត្រៀមបង្ការសម្រាប់ឆ្លើយតបគ្រោះអាសន្ន* ទៅក្នុងការអភិវឌ្ឍវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច-សង្គមកិច្ច និងការស្តារឡើងវិញ ក្រោយគ្រោះមហន្តរាយ ។

៤៣៣. *រាជរដ្ឋាភិបាល* នឹងពង្រឹង តួនាទី របស់ *គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* ក្នុងការសម្របសម្រួលការអនុវត្ត *ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣* ដែលមានសមាសភាពសំខាន់ចំនួន៦ គឺ :

- ធានាឱ្យបាននូវការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និង ការត្រៀមបង្ការ សម្រាប់ឆ្លើយតបគ្រោះអាសន្ន ទាំងនៅ ថ្នាក់ជាតិ និង មូលដ្ឋាន ។
- ពង្រឹងការគ្រប់គ្រងហានិភ័យ គ្រោះមហន្តរាយ និង ការត្រៀមបង្ការ សម្រាប់ឆ្លើយតប គ្រោះអាសន្ន ថ្នាក់ក្រោមជាតិ និង ថ្នាក់មូលដ្ឋានសហគមន៍ ។
- កំណត់ ប៉ាន់ប្រមាណ និង តាមដានត្រួតពិនិត្យ មុខសញ្ញាគ្រោះថ្នាក់ និង លើកកម្ពស់ការផ្តល់ដំណឹងជាមុន ។
- ប្រើប្រាស់ ចំណេះដឹង ការរកឃើញថ្មីៗ និង ការអប់រំ ដើម្បី កសាងវប្បធម៌សុវត្ថិភាព និង សមត្ថភាពទប់ទល់ហានិភ័យ គ្រោះមហន្តរាយ ឱ្យបាននៅគ្រប់កម្រិត ។
- បញ្ជ្រាប ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ទៅក្នុង គោលនយោបាយ និង កម្មវិធី នានា របស់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ។
- ពង្រឹងការត្រៀមបង្ការ សម្រាប់ឆ្លើយតបគ្រោះមហន្តរាយ ឱ្យមានប្រសិទ្ធភាព នៅគ្រប់កម្រិត ។

៤៣៤. នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តការតំបន់ *គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* នឹងចាប់ផ្តើមអនុវត្ត កិច្ចប្រតិបត្តិការនៃ*មូលនិធិអាស៊ានសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ*ពី ខែមករា ឆ្នាំ២០១០ ។

## ការអភិវឌ្ឍជនបទ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៣៥. *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នៅតែចាត់ទុកថា *ការកាត់បន្ថយភាពក្រីក្រ* តាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពដ៏ចម្បងមួយ ។ ការអភិវឌ្ឍជនបទ គឺមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយហេតុថា ៨៥ភាគរយនៃប្រជាជនក្រីក្រ រស់នៅតំបន់ជនបទ ។ *រាជរដ្ឋា-*

*ភិបាល* នឹងបន្តជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ទៅលើកត្តាដែលមានផលប៉ះពាល់ជាវិជ្ជមានទៅលើប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទ ដូចជា *ការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការអនុវត្តការធ្វើផែនការមូលដ្ឋានចម្រុះ ការកសាងផ្លូវជនបទ ការផ្គត់ផ្គង់ទឹកនៅជនបទ ការថែទាំសុខភាពបឋមនិងការងារអនាម័យជនបទ ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ* ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជា ឱ្យមានភាពប្រសើរជាងមុន ជាពិសេស ប្រជាជននៅជនបទ ។

៤៣៦. ដើម្បីសម្រេចបាននូវគោលដៅនានានៃការអភិវឌ្ឍជនបទ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា* នឹងបន្តការផ្តោតការយកចិត្តទុកដាក់លើ :

- ការពង្រឹងសមត្ថភាពស្ថាប័ន ដោយ បន្តការពង្រឹងនិងការអភិវឌ្ឍស្ថាប័នថ្នាក់ជាតិ តាមរយៈ ការអភិវឌ្ឍផ្នែករូបវន្ត និងការកសាងក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ឱ្យបានគ្រប់គ្រាន់ ព្រមទាំង បន្តការពង្រឹងនិងការអភិវឌ្ឍស្ថាប័នថ្នាក់ក្រោមជាតិ តាមរយៈ ការពង្រឹង *មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត* និង *ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក-ខណ្ឌ* ។
- ការអភិវឌ្ឍធនធានមនុស្ស ដោយបន្តការអប់រំ បណ្តុះបណ្តាលនូវចំណេះដឹងជំនាញផ្សេងៗ និងបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រក្នុងការអភិវឌ្ឍ ដល់មន្ត្រីរបស់ *ក្រសួងអភិវឌ្ឍន៍ជនបទ* និងប្រជាពលរដ្ឋទូទៅ ដោយរួមទាំង ប្រជាជនជាជនជាតិដើមភាគតិច ផងដែរ ។
- ការបន្តអនុវត្ត *ការធ្វើផែនការមូលដ្ឋានចម្រុះ* ដែលជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយដ៏សំខាន់ សម្រាប់ធ្វើការកំណត់ឱ្យបានប្រសើរជាងមុន នូវអាទិភាពទាំងឡាយ និង សម្រាប់ការរៀបចំកសាងកម្មវិធីវិនិយោគសាធារណៈ លើការផ្តល់សេវាកម្មគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធ នៅជនបទ ។
- ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាកម្មរបស់ប្រជាជននៅជនបទ និង ធ្វើឱ្យមានភាពងាយស្រួលដល់ ការដឹកជញ្ជូនផលិតផលនៅជនបទ ទៅកាន់ទីផ្សារ ជាពិសេស ការសាងសង់ជាជំហានៗ នូវផ្លូវមានគុណភាពខ្ពស់ ដែលធានាដល់ការប្រើប្រាស់បានរយៈពេលវែង ។
- ការបន្តការគាំទ្រដល់ *ក្រុមប្រឹក្សាឃុំ-សង្កាត់* ដើម្បីអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទខ្នាតតូច នៅក្នុងមូលដ្ឋានឃុំ-សង្កាត់ ។
- ការធ្វើឱ្យប្រសើរឡើងនូវ ការទទួលបានទឹកស្អាតសម្រាប់បរិភោគ និងសេវាអនាម័យ ជាពិសេស នៅសហគមន៍ជនបទដែលរស់នៅក្នុងតំបន់ខ្វះខាតទឹក ក៏ដូចជា ទឹកប្រើប្រាស់ក្នុងគ្រួសារ និងទឹកសម្រាប់ការស្រោចស្រព ។

- ការជំរុញដំណើរការនៃ "*ភូមិមួយ-ផលិតផលមួយ*" សំដៅលើកទឹកចិត្តដល់ការបង្កើតផលិតផល ដែលមានតម្លៃខ្ពស់ ដើម្បីទាក់ទាញឱ្យមានការចូលរួម ពីផ្នែកឯកជន ។
- ការពង្រឹងនិងគាំទ្រយន្តការដែលមានស្រាប់របស់ *ក្រុមប្រឹក្សាឃុំ សង្កាត់* ដើម្បី ដឹកនាំការអភិវឌ្ឍភូមិ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន និង ជំរុញការអភិវឌ្ឍភូមិរបស់ប្រជាពលរដ្ឋ ជាពិសេស របស់គ្រួសារយោធិននិងនគរបាល រស់នៅតាមបណ្តោយព្រំដែនទិសខាងលិចនិងខាងជើង *នៃព្រះរាជាណាចក្រកម្ពុជា* ដើម្បីប្រែក្លាយអតីតតំបន់ប្រយុទ្ធ ឱ្យក្លាយទៅជាតំបន់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ដោយផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រសម្រាប់ការការពារបូរណភាពទឹកដី ។
- ការបង្កើនថវិកាប្រចាំឆ្នាំ ១ភាគរយ នៃថវិកាចំណាយរបស់ក្រសួង-ស្ថាប័ន នីមួយៗ ដើម្បីយកទៅធ្វើការអភិវឌ្ឍតំបន់ទល់ដែន*កម្ពុជា-វៀតណាម-ឡាវ* និង *កម្ពុជា-ឡាវ-ថៃ* ។
- ការបន្តជំរុញ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈ ការបង្កើនទំហំមីក្រូហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ឥណទានជនបទប្រកបដោយប្រសិទ្ធភាព ក្នុងអត្រាការប្រាក់ទាប ។

## ខ. សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្ត គោលនយោបាយអាទិភាព

៤៣៧. ដើម្បីអនុវត្តគោលនយោបាយអាទិភាព *សម្រាប់និតិកាលទី៤ នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទ* នឹងត្រូវបន្តអនុវត្តសកម្មភាព ដូចតទៅ ៖

- ផ្តល់អាទិភាពដល់ ការពង្រឹងនិងការអភិវឌ្ឍស្ថាប័ន សម្រាប់ *ក្រសួងអភិវឌ្ឍន៍ជនបទ* ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជា ការជំរុញការអភិវឌ្ឍធនធានមនុស្ស សម្រាប់ មន្ត្រីរាជការរបស់*ក្រសួងអភិវឌ្ឍន៍ជនបទ* និង ប្រជាពលរដ្ឋជនបទទូទៅ រួមទាំង ជនជាតិដើមភាគតិច ផងដែរ ។
- អនុវត្ត *ការធ្វើផែនការមូលដ្ឋានចម្រុះ* ដោយធ្វើការបញ្ចប់ការងារនេះ នៅតាមបណ្តាខេត្តដែលកំពុងអនុវត្ត និងពង្រីកទំហំការងារទៅបណ្តាខេត្តផ្សេងៗទៀតដែលពុំទាន់បានអនុវត្ត ។
- ធ្វើបញ្ជីសារពើភណ្ឌផ្លូវជនបទគ្រប់ប្រភេទ ហើយបញ្ចូលផ្លូវទាំងនោះទៅក្នុងផែនទីផ្លូវរបស់ក្រសួង ព្រមទាំងដាក់ស្លាកឈ្មោះផ្លូវនិងសញ្ញាចរាចរណ៍ ។
- លើកកម្ពស់គុណភាពផ្លូវជាបណ្តើរៗ ពីក្រាលគ្រួសក្រហម ឱ្យទៅជាផ្លូវបេតុង ឬ ក្រាលកៅស៊ូ លើគ្រឹះដីដែលធ្វើស្ថេរកម្ម ដោយលាយជាមួយផ្ទាំកំបោរនិងស៊ីម៉ង់ត៍ ។
- សាងសង់ថ្មី ជួសជុល និង ថែទាំ អណ្តូងទឹកគ្រប់ប្រភេទដែលមានស្រាប់ ផ្តល់ស្រះទឹក និងផលិតពាងយក្ស ដើម្បីផ្គត់ផ្គង់ ទឹកស្អាតសម្រាប់បរិភោគ និងទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ព្រមទាំង កសាងប្រព័ន្ធស្រោចស្រពខ្នាតតូច ។
- ផ្តល់ការអប់រំអំពីសុខភាពនិងអនាម័យ ព្រមទាំង សាងសង់បង្គន់អនាម័យ ។

- បង្កើត *គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ* នៅក្នុងរចនាសម្ព័ន្ធនិងប្រព័ន្ធដែលមានស្រាប់របស់ *ក្រុមប្រឹក្សាឃុំសង្កាត់* ។ ក្រសួងមហាផ្ទៃនិងក្រសួងអភិវឌ្ឍន៍ជនបទ សហការរៀបចំ បែបបទ នីតិវិធីនៃ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ *គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ* ។
- បន្តធ្វើសកម្មភាពណែនាំឱ្យប្រជាជន បានយល់ដឹង ពីអត្ថប្រយោជន៍ *"ភូមិមួយ-ផលិតផលមួយ"* ។
- ជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ភូមិរបស់ប្រជាជន ជាពិសេស របស់គ្រួសារយោធិននិងនគរបាល ដែលរស់នៅតាមតំបន់ទល់ដែន ទិសខាងលិចនិងខាងជើង នៃ*ព្រះរាជាណាចក្រកម្ពុជា* ដោយកសាងប្រព័ន្ធផ្លូវ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អណ្តូងទឹក ផ្ទះ សាលារៀន មណ្ឌលសុខភាព ទីផ្សារជាដើម ព្រមទាំងផ្តល់ជីបង្កបង្កើនផលកសិកម្ម ជូនប្រជាជនទាំងនោះ ។
- កសាងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ នៅតាមទីកន្លែងដែលចាំបាច់នៃរាជធានី-ខេត្ត ដើម្បីធ្វើជាកន្លែងពិសោធន៍បច្ចេកវិទ្យាដាំដុះ ដំណាំកសិកម្មផ្សេងៗ សម្រាប់បង្ហាញដល់គ្រួសារកសិករនៅក្នុងសហគមន៍ ប្រយោជន៍ឱ្យពួកគាត់យកបទពិសោធន៍ដែលទទួលបានជោគជ័យ ទៅអនុវត្ត ដើម្បីបង្កើនចំណូលគ្រួសារ ។
- ជំរុញការអនុវត្តកម្មវិធីសន្តិសុខស្បៀង តាមគ្រួសារកសិករ នៅក្នុងភូមិ ។
- ចងក្រងគ្រួសារកសិករជាសមាគមន៍ សម្រាប់ការផ្តល់ឥណទានជនបទ ក្នុងអត្រាការប្រាក់ទាប ដើម្បីយកទៅប្រើប្រាស់ ក្នុងការទិញជីនិងពូជ ការបង្កបង្កើនផល ការចិញ្ចឹមសត្វ ឬការបង្កើតមុខជំនួញខ្នាតតូច ដើម្បី បង្កើនប្រាក់ចំណូលប្រចាំគ្រួសារ ព្រមទាំង ណែនាំឱ្យប្រជាជនបង្កើតធនាគារគោ/ក្របី និងធនាគារស្រូវ ដើម្បីឱ្យប្រជាជនមានលទ្ធភាពជួយគ្នាទៅវិញទៅមក ក្នុងរូបភាពជាការប្រើប្រាស់ទុនបង្វិលម្តងម្នាក់ ។

## តារាងទី១៦ : សូចនាករសំខាន់ៗ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

| សូចនាករ | ២០០៨ ជាក់ស្តែង | ២០០៩ ប៉ាន់ស្មាន | ២០១០ ប៉ាន់ស្មាន | ២០១១ ប៉ាន់ស្មាន | ២០១២ ប៉ាន់ស្មាន | ២០១៣ ប៉ាន់ស្មាន | ២០១៥ គោលដៅ |
|---|---|---|---|---|---|---|---|
| ការស្តារផ្លូវថ្នល់ជនបទ ២៨ ០០០ គ.ម | ២៤ ១៤០ | ២៥ ៦៥៨ | ២៦ ៦៥៨ | ២៧ ៦៥៨ | ២៨ ៦៥៨ | ២៩ ៦៥៨ | ៣២ ០០០ |
| ការទទួលបានទឹកស្អាត (% នៃប្រជាជននៅជនបទ) | ៤០,៤៩ | ៤១,៩៩ | ៤៣,៤៩ | ៤៤,៩៩ | ៤៦,៤៩ | ៤៧,៦៩ | ៥០,០៩ |
| ការទទួលបានអនាម័យនៅជនបទ (%នៃប្រជាជន នៅជនបទ) | ២៣,២៤ | ២៤,២៤ | ២៥,០០ | ២៧,០០ | ២៩,០០ | ៣១,០០ | ៣៣,០០ |

**សម្គាល់:** គោលដៅស្តារនិងអភិវឌ្ឍ ផ្លូវជនបទ ដែលក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់ក្នុង *ផយអជ* ក្នុង *ប្រវែង ២៥ ០០០ គ.ម សម្រាប់ឆ្នាំ២០១០* នោះ បច្ចុប្បន្ន ក្រសួងអភិវឌ្ឍន៍ជនបទ បានអនុវត្តសម្រេច និងលើសផែនការ ចាប់តាំងពី *ឆ្នាំ២០០៩* ពោល គឺអនុវត្តបាន *ប្រវែង ២៥ ៦៥៨ គ.ម* ។ *គោលដៅថ្មីសម្រាប់ឆ្នាំ២០១៥* ដែលជា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ក្រសួងអភិវឌ្ឍន៍ជនបទ នឹងខិតខំអនុវត្តសម្រេចឱ្យបាន *ប្រវែង ៣២ ០០០ គ.ម* គឺជាតួលេខលើសប្រវែងផ្លូវជនបទមានក្នុងអំឡុងមុនបណ្តាឆ្នាំ១៩៧៩ ដែលបានកំណត់យក*ប្រវែង ២៨ ០០០ គ.ម* ។

# ៤. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

៤៣៨. មុំ ឬសមាធាតុរង ទាំង៤ នៃចតុកោណ *ការបន្តការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត* រួមមាន : *(១) ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (២) ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ (៣) ការអភិវឌ្ឍន៍វិស័យថាមពល និង (៤) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍* ។

## ៤.១ ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៣៩. ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បណ្តាញគមនាគមន៍ គឺជា *"ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច"* ។ ការតភ្ជាប់គ្រប់ច្រកល្ហកទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យបណ្តាញគមនាគមន៍ ក្លាយជាសរីរាង្គសេដ្ឋកិច្ចមួយ និងជួយធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ លើមូលដ្ឋាននៃសមិទ្ធផល *រាជរដ្ឋាភិបាលកម្ពុជា* បានបញ្ចប់ស្ទើរតែទាំងស្រុង នូវការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវជាតិសំខាន់ៗ ។ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងបន្តផ្តល់អាទិភាពខ្ពស់ លើការស្តារ និងកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនពហុប្រភេទ ដែលតភ្ជាប់រវាងគ្រប់តំបន់ នៅទូទាំងប្រទេស និងតភ្ជាប់ជាមួយបណ្តាប្រទេសជិតខាង ។ តាមរយៈនេះ ប្រព័ន្ធគមនាគមន៍ នឹងអាចផ្តល់សេវាដឹកជញ្ជូន ងាយស្រួល មានស្ថិរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច មានតម្លៃទាប ក្នុងទិសដៅសម្រួលដល់ការធ្វើ ពាណិជ្ជកម្ម ជំរុញវិស័យទេសចរណ៍ ការអភិវឌ្ឍជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់និងសកលលោក ព្រមទាំង បម្រើដល់កិច្ចការពារជាតិផងទៀតផង ។

៤៤០. *រាជរដ្ឋាភិបាលកម្ពុជា* មានគោលដៅបន្តស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដោយផ្តោតអាទិភាពខ្ពស់ លើការថែទាំផ្លូវជាតិ ការបន្តកសាងឡើងវិញផ្លូវខេត្តនិងជនបទ ការពង្រីកសមត្ថភាពរបស់កំពង់ផែសំខាន់ៗ និង ការស្តារបណ្តាញផ្លូវដែក ដើម្បីតភ្ជាប់បណ្តាញផ្លូវដែកកម្ពុជា ទៅប្រព័ន្ធផ្លូវដែកប្រទេសជិតខាង ក្នុងក្របខ័ណ្ឌមហាអនុ-តំបន់ទន្លេមេគង្គ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងខិតខំប្រឹងប្រែង ដើម្បីធ្វើឯកជនភាវូបនីយកម្មនូវកិច្ចប្រតិបត្តិការអាជីវកម្មនៃរាជាស្វ័យយានកម្ពុជា ព្រមទាំង នឹងបន្តលើកទឹកចិត្តដល់ការចូលរួមពីវិស័យឯកជន ក្នុងការស្តារ-ហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាដឹកជញ្ជូន ។

៤៤១. *រាជរដ្ឋាភិបាលកម្ពុជា* នឹងស្វែងរកការបង្កើនការចូលរួមពីផ្នែកឯកជន តាមរយៈ ដំណើរការដេញថ្លៃ ក្នុងកិច្ចសន្យា ថែទាំផ្លូវខួប និង ថែទាំជាប្រចាំ ។ ដំណើរការនេះ នឹងពង្រឹង ការគ្រប់គ្រងនិងការត្រួតពិនិត្យបច្ចេក-ទេស និង សមត្ថភាពសវនកម្ម របស់ *មន្ទីរសាធារណការនិងដឹកជញ្ជូន* និង *មន្ទីរអភិវឌ្ឍន៍ជនបទ* ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តគោលនយោបាយ បើកចំហជើងមេឃ ពង្រឹងសុវត្ថិភាពហោះហើរ ព្រមទាំង ពង្រឹងសេវាកម្មព្រលានយន្តហោះ ។

៤៤២. *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញអនុម័ត គោលនយោបាយដឹកជញ្ជូន *ច្បាប់ស្តីពីផ្លូវថ្នល់* ព្រមទាំង ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត សម្រាប់ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ឱ្យកាន់តែមានប្រសិទ្ធភាព ។ *រាជរដ្ឋាភិបាលកម្ពុជា* ក៏នឹងផ្តោតការយកចិត្តទុកដាក់ ផងដែរ លើសុវត្ថិភាពចរាចរណ៍ និងមានវិធានការយ៉ាងម៉ឺងម៉ាត់ ចំពោះបទល្មើសដឹកជញ្ជូនលើសទម្ងន់ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៤៣. *ក្រសួងសាធារណការនិងដឹកជញ្ជូន* មានភារកិច្ចដឹកនាំការអនុវត្តគោលនយោបាយជាតិ ទាក់ទងនឹងគ្រប់ការងារសាងសង់សាធារណៈ តាមរយៈ (១) ការបង្កើតក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងការធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននានា ដើម្បីអភិវឌ្ឍប្រទេស (២) ការសាងសង់និងថែរក្សារាល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដូចជា ផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវដែក និងផ្លូវទឹក (៣) ការបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក និងផ្លូវទឹក (៤) ការបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់ការដឹកជញ្ជូនតាម ផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក និង ការត្រួតពិនិត្យ ការដឹកជញ្ជូនតាម ផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក (៥) ការចូលរួមរៀបចំនិងសហការ ក្នុងការបង្កើតច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការងារដឹកជញ្ជូន (៦) ការសម្រេចឱ្យបាននូវការសាងសង់ផ្សេងៗទៀត ដែល *រាជរដ្ឋាភិបាលកម្ពុជា* ប្រគល់ជូន (៧) ការធ្វើកិច្ចសហប្រតិបត្តិការជាមួយ *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* ក្នុងការងារសាងសង់ព្រលានយន្តហោះ និង (៨) ជំរុញឱ្យមានការចូលរួមរបស់ស្ត្រីនិងបុរស នៅក្នុងការអនុវត្តគោលនយោបាយទាំងអស់ខាងលើ ព្រមទាំង បង្កើនតួនាទីនិងភាពអង់អាច ផ្នែកបច្ចេកទេសគ្រប់គ្រង ដឹកនាំ និង ការពារសិទ្ធិទទួលបាននូវផលប្រយោជន៍របស់ស្ត្រី ជាមន្ត្រីរាជការនិងប្រជាពលរដ្ឋ ក្នុងវិស័យសាធារណការ និង ការដឹកជញ្ជូន ។

៤៤៤. *ក្រសួងសាធារណការនិងដឹកជញ្ជូន* បានរៀបចំផ្តល់សេវាកម្ម តាមរយៈ តួនាទី/កម្មវិធី ដូចខាងក្រោម :

- *អគ្គនាយកដ្ឋានការងារសាធារណៈ* ទទួលខុសត្រូវក្នុងការ ពិនិត្យមើលការសាងសង់ ជួសជុល និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ និងស្ពាន ។ អគ្គនាយកដ្ឋាននេះ មាន ៥នាយកដ្ឋាន គឺ *នាយកដ្ឋានរចនាសម្ព័ន្ធផ្លូវថ្នល់ មជ្ឈមណ្ឌលគ្រឿងចក្រធុនធ្ងន់ មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស នាយកដ្ឋានផ្លូវទឹក និងនាយកដ្ឋានសំណង់ផ្លូវអាកាស* ។
- *អគ្គនាយកដ្ឋានផែនការនិងរដ្ឋបាល* ទទួលខុសត្រូវ ជាអ្នកធ្វើទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរបស់ក្រសួង គ្រប់គ្រងការងារផ្សេងៗទាក់ទងនឹង ការងាររដ្ឋបាល ធនធានមនុស្សនិងបុគ្គលិក សំភារៈបរិក្ខា គណនេយ្យហិរញ្ញវត្ថុ ការរៀបចំការបណ្តុះបណ្តាល និង ផែនការ ។ អគ្គនាយកដ្ឋាន នេះ មាន ៥នាយកដ្ឋាន គឺ *នាយកដ្ឋានផែនការនិងវិនិយោគ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិកនិងធនធានមនុស្ស នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ និង នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ* ។

- *អគ្គនាយកដ្ឋានដឹកជញ្ជូន* ទទួលខុសត្រូវក្នុងការ គ្រប់គ្រង និងត្រួតពិនិត្យ ការដឹកជញ្ជូនតាម ផ្លូវថ្នល់ ផ្លូវទឹក និងសមុទ្រ និង រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត នានា ដើម្បីសម្របសម្រួល និងធានាឱ្យការធ្វើដំណើរ ប្រកបដោយសុវត្ថិភាព ។ អគ្គនាយកដ្ឋាននេះ មាន ៣នាយកដ្ឋាន គឺ *នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នាយកដ្ឋានដឹកញ្ជូនផ្លូវទឹក និង នាយកដ្ឋាននាវាជំនួញសមុទ្រ* ។

៤៤៥. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងសាធារណការនិងដឹកជញ្ជូន* នឹងអនុវត្តសកម្មភាព ដូចខាងក្រោម ៖

១. *វិស័យផ្លូវថ្នល់ ៖*

- បន្តពង្រឹងការងារគ្រប់គ្រងបណ្តាញផ្លូវថ្នល់ តាមរយៈ ៖
  - ការថែទាំជាប្រចាំ និងថែទាំខួប ។
  - ការទប់ស្កាត់ការដឹកជញ្ជូនលើសទម្ងន់ ។
  - ការរៀបចំគោលនយោបាយនានាស្តីពី ការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន ជាពិសេស ផ្លូវថ្នល់ ។
  - ការរៀបចំ និងធ្វើបច្ចុប្បន្នភាព និងអនុម័តលើ យុទ្ធសាស្ត្រ និងផែនការមេ សម្រាប់ការអភិវឌ្ឍផ្លូវថ្នល់ ។
  - ការរៀបចំឯកសារច្បាប់ សម្រាប់ពង្រឹងការងារគ្រប់គ្រងផ្លូវថ្នល់ ដូចជា *ច្បាប់ស្តីពីផ្លូវថ្នល់* ។ល។
  - ការរៀបចំដាក់ប្រព័ន្ធលេខផ្លូវ ដែលគ្រប់គ្រងដោយ *ក្រសួងសាធារណការនិងដឹកជញ្ជូន* ។
  - ការថែទាំ និងកសាងបណ្តាញលូតាមទីប្រជុំជន ស្ថិតនៅតាមបណ្តោយផ្លូវជាតិ ។
  - ការថែទាំ និងដាក់ផ្លាកសញ្ញាចរាចរណ៍ គំនូសចរាចរណ៍ បង្គោលគីឡូម៉ែត្រ ។
  - ការពង្រឹងការត្រួតពិនិត្យ គុណភាពនិងរចនាសម្ព័ន្ធ ផ្លូវនិងស្ពាន ។
  - ការរៀបចំផែនការមេ សម្រាប់សាងសង់ផ្លូវវាងនៅ *រាជធានីភ្នំពេញ* និងតាមបណ្តាខេត្ត-ក្រុង មួយចំនួន ។
- បន្តការកសាងផ្លូវជាតិសំខាន់ៗ សម្រាប់បម្រើការងារធ្វើសមាហរណកម្មគ្រប់តំបន់ទាំងអស់ក្នុងប្រទេស និងការងារធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់ ដោយ ៖
  - បន្តស្តារផ្លូវជាតិសេសសល់ ដើម្បីភ្ជាប់ពីទីរួមខេត្ត ទៅរាជធានី និងភ្ជាប់ទៅប្រទេសជិតខាង ។
  - ស្តារនិងសាងសង់ផ្លូវ តភ្ជាប់ពីទីរួមខេត្តសំខាន់ៗ ទៅកាន់ប្រទេសជិតខាង ជាពិសេស ផ្លូវក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ ផ្លូវក្នុងក្របខ័ណ្ឌកម្ពុជា-ឡាវ-មីយ៉ានម៉ា-វៀតណាម និងផ្លូវក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ អាយ៉េយ៉ាវ៉ាឌី-មេគង្គ-ចៅប្រាយ៉ា ។ល។
  - បន្តស្វែងរកប្រភពទុនដើម្បី ពង្រីកផ្លូវជុំវិញរាជធានីភ្នំពេញ សាងសង់ផ្លូវនៅជុំវិញទីក្រុងធំៗ និងដើម្បីពង្រីកផ្លូវជាតិ លេខ១ លេខ៤ លេខ៥ និង លេខ៦ ជាបួនខ្សែគន្លងចរាចរណ៍ ។

- ធ្វើការសិក្សា និងស្វែងរកប្រភពទុន ដើម្បី ស្តារនិងកសាងផ្លូវមួយចំនួន ដូចជា (១) ផ្លូវភ្ជាប់ខេត្តសៀមរាប-ព្រះវិហារ-ស្ទឹងត្រែង-រតនគិរី (២) ផ្លូវភ្ជាប់ពីខេត្តមណ្ឌលគិរី-ស្រុកកោះញែក-ស្រុកបានលុង-ព្រំដែនឡាវ (ផ្លូវជាតិលេខ៧៦ ផ្លូវជាតិលេខ៧៨អា ផ្លូវខេត្ត៣៧៨អា១ ផ្លូវខេត្ត៣០១បេ ផ្លូវខេត្ត៣០១អា) (៣) ផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៧-ជុំក្រឡ-សៀមប៉ាង-ព្រំដែនកម្ពុជា-ឡាវ (៤) ផ្លូវខ្សែក្រវាត់ព្រំដែន ខាងជើង ៣យ័ព្យ និង ឰសាន ។

- សហការជាមួយ *ក្រសួងអភិវឌ្ឍន៍ជនបទ* និង អាជ្ញាធរខេត្ត-ក្រុង ដើម្បីរៀបចំបណ្តាញផ្លូវ ឱ្យមានភាពរលូន និងស៊ីចង្វាក់គ្នា ។

## ២. *វិស័យដឹកជញ្ជូនផ្លូវគោក :*

- បំព្រួញរយៈពេលនៃ ការចុះបញ្ជីយានយន្ត និងការផ្តល់ស្លាកលេខយានយន្តនិងបណ្ណបើកបរ ។ល។
- ពង្រឹងការអនុវត្តនិងរៀបចំផែនការមេថ្មី ស្តីពី សុវត្ថិភាពចរាចរណ៍ផ្លូវគោក ។
- ជំរុញការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដោយ :
  - ជំរុញការដឹកជញ្ជូនទំនិញជាមួយវៀតណាម ។
  - ជំរុញការអនុវត្ត *កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនជាមួយឡាវ* ។
  - ជំរុញការអនុវត្ត *កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនជាមួយថៃ* ។
  - ជំរុញការអនុវត្ត ការត្រួតពិនិត្យរួមគ្នា និង ការត្រួតពិនិត្យតាមបញ្ជរតែមួយ ជាមួយ វៀតណាម ឡាវ និងថៃ ក្នុងក្របខ័ណ្ឌនៃមហាអនុតំបន់ទន្លេមេគង្គ។
  - ជំរុញការសម្រួលដល់ ការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន និង ការដឹកជញ្ជូនទំនិញពហុរូបភាព រវាងរដ្ឋរបស់អាស៊ាន ។
- ពង្រឹងការគ្រប់គ្រងលើការផ្តល់សេវាសាធារណៈ សម្រាប់ ការគ្រប់គ្រងនិងការចុះបញ្ជីយានយន្តផ្លូវគោក និង ការផ្តល់បណ្ណបើកបរយានយន្តផ្លូវគោក ក្នុងក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការ ។

## ៣. *វិស័យដឹកជញ្ជូនផ្លូវទឹក នាវាសមុទ្រ និងកំពង់ផែ :*

- ជំរុញឱ្យមានការអភិវឌ្ឍធនធានមនុស្ស នៅក្នុងវិស័យនាវាចរណ៍ តាមរយៈ ការវិនិយោគលើការបង្កើតគ្រឹះស្ថានអប់រំនិងការបណ្តុះបណ្តាល ក្នុងប្រទេស ផ្នែកនាវាចរណ៍សមុទ្រ និងផ្នែកនាវាចរណ៍ទន្លេ ។
- លើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជនក្នុង ការអភិវឌ្ឍការដឹកជញ្ជូនតាមនាវា ការអភិវឌ្ឍកំពង់ផែ ព្រមទាំង បង្កលក្ខណៈឱ្យមានភាពជាដៃគូ រវាង ផ្នែកឯកជន និង ផ្នែកសាធារណៈ ។
- ពង្រឹងការអនុវត្ត ច្បាប់និងបទប្បញ្ញត្តិ នៃ*ព្រះរាជាណាចក្រកម្ពុជា* និង វិធាននានានៃកិច្ចព្រមព្រៀង ឬ អនុសញ្ញាអន្តរជាតិ ដែល*ព្រះរាជាណាចក្រកម្ពុជា* ជាភាគីហត្ថលេខី ស្តីពី ការដឹកជញ្ជូនតាមផ្លូវសមុទ្រ ផ្លូវទឹកក្នុងប្រទេស និង កំពង់ផែ ។

- រៀបចំសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹង ការដឹកជញ្ជូនតាមផ្លូវសមុទ្រ ផ្លូវទឹកក្នុងប្រទេស និងកំពង់ផែ ។
- រៀបចំនិងពង្រឹង យន្តការគ្រប់គ្រង ការដឹកជញ្ជូនតាមផ្លូវសមុទ្រ ផ្លូវទឹកក្នុងប្រទេស និង កំពង់ផែ ។
- ធានាសុវត្ថិភាពនិងសន្តិសុខ សម្រាប់នាវានិងកំពង់ផែ និង រួមចំណែកការពារបរិស្ថាន រួមមាន វិធានការទប់ស្កាត់និងកាត់បន្ថយ ការបំភាយឧស្ម័នកាបូនិក នៅក្នុងវិស័យនាវាចរណ៍និងកំពង់ផែ ។
- ជំរុញ ការអភិវឌ្ឍនិងការប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាទំនើប ដើម្បីជួយសម្រួលដល់បែបបទត្រួតពិនិត្យឱ្យបានឆាប់រហ័ស និង មានប្រសិទ្ធភាព ។
- បន្តការយកចិត្តទុកដាក់ លើការគ្រប់គ្រងការដឹកជញ្ជូនតាមដងទន្លេមេគង្គ ពីភ្នំពេញ ទៅសមុទ្រ ឆ្លងកាត់តាមប្រទេសវៀតណាម ។
- បញ្ចប់នូវការរៀបចំ *ផែនការមេផ្លូវទឹក* និងត្រៀមអនុវត្ត ។
- បន្តអនុវត្ត *គម្រោងទី២ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ* ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយ *ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន* :
  - ➢ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់កសាងតំបន់*អភិវឌ្ឍន៍សេដ្ឋកិច្ចពិសេស* នៅលើផ្ទៃដី ៧០ហិកតារបស់កំពង់ផែ (នៅក្នុង ជំហានទី១និងទី២) ។
  - ➢ គម្រោងសាងសង់កំពង់ផែពហុបំណង សម្រាប់ការគាំទ្រផ្នែកទ្រភស្តុភារកម្មដល់ការរុករកប្រេង នៅក្នុងលំហសមុទ្រ និង កំពង់ផែសម្រាប់ទំនិញពិសេស ។

*៤. វិស័យផ្លូវដែក :*

- ជំរុញ ការងារស្តារផ្លូវដែកទាំងពីរទិស និង ការតភ្ជាប់ជាមួយប្រព័ន្ធផ្លូវដែករបស់ប្រទេសថៃ ។
- ជំរុញការសិក្សាបញ្ចប់ស្តីពីគម្រោងផ្លូវដែក ពី *បាត់ដឹង* (កម្ពុជា) - *ឡុកនិញ* (វៀតណាម) ក្នុងក្របខ័ណ្ឌផ្លូវដែកអាស៊ាន *(ផ្លូវដែកតភ្ជាប់ សិង្ហបុរី-គុនមិញ)* ។
- លើកកម្ពស់ការគ្រប់គ្រងការអនុវត្ត កិច្ចសន្យាស្តីពីការផ្តល់សម្បទានឱ្យផ្នែកឯកជន ធ្វើការគ្រប់គ្រងនិងធ្វើអាជីវកម្មលើផ្លូវដែកកម្ពុជា ដែលជាគម្រោងមួយ ក្នុងរូបភាពនៃ ភាពជាដៃគូរវាងផ្នែកសាធារណៈនិងផ្នែកឯកជន ។
- ជំរុញ ការរៀបចំនាយកដ្ឋានផ្លូវដែកថ្មី និង ការបណ្តុះបណ្តាលធនធានមនុស្ស ។

*៥. សេវាបញ្ជូនទំនិញ ការដឹកជញ្ជូនពហុរូបភាព ភស្តុភារកម្ម និង សេវាភ្នាក់ងារនាវា :*

- រៀបចំផែនការមេស្តីពី ការផ្គត់ផ្គង់ភស្តុភារ និង ការដឹកជញ្ជូនពហុរូបភាព នៅក្នុងប្រទេសនិងតំបន់ ដើម្បីបង្កឱ្យមានការសម្រួលពាណិជ្ជកម្ម ដោយមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ដទៃទៀត ។

- បង្កើនប្រសិទ្ធភាពនៃ សេវាបញ្ជូនទំនិញ ការដឹកជញ្ជូនពហុរូបភាព ភស្តុភារកម្ម និង *ភ្នាក់ងារកម្ពុជានាវាចរណ៍ "កាំសាប"* ។
- គាំទ្រ និងលើកចិត្តដល់ សកម្មភាពរបស់ *កាំសាប* ដើម្បីបង្កលក្ខណៈឱ្យ ភ្នាក់ងារនេះ បានបំពេញតួនាទីជាអ្នកបញ្ជូនទំនិញ តំណាង និងជាអ្នកផ្តល់សេវា ក្នុងនាមម្ចាស់នាវា ឬ អ្នកជួលនាវា ឬ ម្ចាស់ទំនិញ និងជាអ្នកផ្តល់ភស្តុភារកម្ម ទៅតាមសេចក្តីត្រូវការ ក៏ដូចជា ដើម្បីធានាបាននូវ ប្រសិទ្ធភាព សុវត្ថិភាព គុណភាព ការផ្តល់ដល់គោលដៅទាន់ពេលវេលា តម្លៃសមស្រប ប្រកបដោយឧត្តមភាពប្រកួតប្រជែង ។

*៦. ការដឹកជញ្ជូនក្នុងក្រុង :*

- ពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវ ការគ្រប់គ្រង បរិស្ថាននិងការដឹកជញ្ជូនក្នុងក្រុង ។
- ជំរុញការធ្វើផែនការស្តីពី ការដឹកជញ្ជូនក្នុងក្រុង និងការដឹកជញ្ជូនសាធារណៈ នៅតាមទីក្រុងសំខាន់ៗ ។
- ជំរុញការរៀបចំប្លង់មេថ្មី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការដឹកជញ្ជូនក្នុងក្រុង ក្នុងនោះរួមមានគម្រោងសាងសង់ រថភ្លើងស្រាលដឹកអ្នកដំណើរក្នុងក្រុង ដើម្បីចូលរួមកាត់បន្ថយ ការបញ្ចេញឧស្ម័នកាបូនិកដែលបណ្តាលឱ្យមាន ការបំពុលបរិស្ថាន ការកើនឡើងកម្តៅផែនដី និង ការប្រែប្រួលអាកាសធាតុ ។
- ជំរុញការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងភាពស័ក្តិសិទ្ធិ នូវហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដឹកជញ្ជូនសាធារណៈ និងដឹកជញ្ជូនក្នុងក្រុង ដែលគ្រប់គ្រងនិងកាន់កាប់ដោយឯកជន ។
- ដាក់ចេញនូវវិធានការបន្ថែម សម្រាប់ការគ្រប់គ្រងចរាចរណ៍ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ ។
- ពង្រឹងការអនុវត្ត *ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក* និងកែលម្អសុវត្ថិភាពចរាចរណ៍លើផ្លូវថ្នល់ ។

*៧. ការពង្រឹងនិងការកែលម្អនូវ ការគ្រប់គ្រងមូលដ្ឋានទិន្នន័យស្ថិតិ និង ការរៀបចំផែនការ សម្រាប់វិស័យដឹកជញ្ជូន :*

- ពង្រឹងនិងកែលម្អ ការរៀបចំផែនការ ការងារស្ថិតិ និង ការគ្រប់គ្រងនិងការផ្សព្វផ្សាយទិន្នន័យ ក្នុងវិស័យដឹកជញ្ជូន ។
- ពង្រឹងកសាងសមត្ថភាពមន្ត្រី និងស្ថាប័ន ក្នុងវិស័យដឹកជញ្ជូន ។

*៨. ការកសាង ក្របខ័ណ្ឌ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន និង ការជំរុញការអនុវត្តច្បាប់ :*

- ពង្រឹងការអនុវត្ត *ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក* (ប្រកាសដាក់ឱ្យប្រើប្រាស់ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧) និង *អនុក្រឹត្យស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុល កែច្នៃយានយន្ត* ។
- សេចក្តីព្រាង គោលនយោបាយ និង លិខិតបទដ្ឋានគតិយុត្ត ដែលត្រូវបានបញ្ជូនទៅ ស្នើសុំការអនុម័ត រួមមាន :

- *គោលនយោបាយជាតិវិស័យដឹកជញ្ជូន ។*
- *អនុក្រឹត្យ ស្តីពីការគ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវទឹក* (កំពុងត្រូវបានកែសម្រួល) ។
- *គោលនយោបាយជាតិ យុទ្ធសាស្ត្រជាតិ និង ផែនការសកម្មភាពជាតិ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ។*

• សេចក្តីព្រាង គោលនយោបាយ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលកំពុងត្រូវបានរៀបចំ ហើយនឹងត្រូវបញ្ជូនទៅសុំការអនុម័ត រួមមាន :

- *អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងការធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ។*
- *អនុក្រឹត្យ ស្តីពីការបង្កើត គណៈកម្មាធិការត្រួតពិនិត្យចម្រុះលើបទល្មើសចរាចរណ៍ផ្លូវគោក ។*
- *សេចក្តីព្រាងច្បាប់ ស្តីពីការដឹកជញ្ជូនពហុរូបភាព ។*
- *នីតិវិធីនៃការដកពិន្ទុបណ្ណបើកបរ ។*
- *ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទន្លេ ។*
- *ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក* (កំពុងត្រូវបានធ្វើវិសោធនកម្ម) ។
- *ផែនការមេស្តីពីវិស័យដឹកជញ្ជូនផ្លូវទឹកក្នុងប្រទេស ។*
- *អនុក្រឹត្យស្តីពីនីតិវិធីនៃ ការចុះបញ្ជីយានយន្ត និងការផ្តល់បណ្ណសម្គាល់យានយន្ត និងស្លាកលេខយានយន្ត ។*
- *អនុក្រឹត្យស្តីពីការដឹកជញ្ជូនផ្លូវគោក ។*
- *អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសុវត្ថិភាពចរាចរណ៍ផ្លូវគោក* (កំពុងត្រូវបានកែសម្រួល) ។
- *អនុក្រឹត្យស្តីពីការគ្រប់គ្រងក្រុមហ៊ុនអាជីវកម្ម-សេវាកម្មដឹកជញ្ជូន។*
- *បណ្ណបើកបរអន្តរជាតិ* (កំពុងត្រូវបានរៀបចំបង្កើត) ។
- *អនុក្រឹត្យស្តីពីការគ្រប់គ្រងបណ្ណបើកបរអន្តរជាតិ ។*
- *គោលនយោបាយ និងផែនការសកម្មភាព ស្តីពី សុវត្ថិភាពចរាចរណ៍ ។*
- *ច្បាប់ស្តីពីការដឹកជញ្ជូន* ( កំពុងត្រូវបានរៀបចំ) ។
- *គោលនយោបាយជាតិ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សម្រាប់វិស័យកំពង់ផែ នៅកម្ពុជា ២០០៩-២០១១* (កំពុងត្រូវបានរៀបចំបង្កើតឡើង) ។
- *គោលនយោបាយស្តីពីការដឹកជញ្ជូនតាមផ្លូវសមុទ្រ ។*
- *នីតិវិធីស្តីពីការចុះបញ្ជីនាវាសមុទ្រ ។*
- *ក្រមនាវាចរណ៍សមុទ្រ* (កំពុងត្រូវបានពិនិត្យមើលឡើងវិញ) ។
- *អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការទប់ទល់នឹងប្រេងកំពប់* (កំពុងត្រូវបានរៀបចំ) ។
- *អនុក្រឹត្យស្តីពីការចេញឱ្យប្រើប្រាស់សៀវភៅវិជ្ជាជីវៈនាវិក* (កំពុងត្រូវបានរៀបចំ) ។

- *ច្បាប់ស្តីពីកំពង់ផែ* (កំពុងត្រូវបានរៀបចំ) ។
- *គោលនយោបាយជាតិស្តីពីកំពង់ផែ* (កំពុងត្រូវបានរៀបចំ) ។
- *អនុក្រឹត្យស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក* (កំពុងត្រូវបានរៀបចំ) ។
- *ព្រះរាជក្រមស្តីពី ការដឹកជញ្ជូនតាមផ្លូវសមុទ្រ* (កំពុងត្រូវបានពិនិត្យមើលឡើងវិញ) ។
- *អនុក្រឹត្យស្តីពីការបង្កើតប្រព័ន្ធថ្នាក់ជាតិសម្រាប់ ការត្រៀមទប់ទល់នឹងការកំពប់ប្រេង និងកិច្ចសហ-ប្រតិបត្តិការ ដើម្បីដោះស្រាយការកំពប់ប្រេង* ។
- *ប្រកាសស្តីពីការអនុញ្ញាតឱ្យនាវាចូលចតតាមកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា* ។
- *ប្រកាសស្តីពីសន្តិសុខក្នុងបរិវេណមណ្ឌលផែ នៃព្រះរាជាណាចក្រកម្ពុជា* ។
- *ផែនការជាតិ ដើម្បីបង្ការការពារហានិភ័យ បណ្តាលមកពីប្រេងកំពប់* ។
- *ផែនការមេស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក នៅក្នុងប្រព័ន្ធទន្លេមេគង្គកម្ពុជា* ។
- *ផែនការមេអភិវឌ្ឍបណ្តាញផ្លូវថ្នល់ បច្ចុប្បន្នកម្ម នៃព្រះរាជាណាចក្រកម្ពុជា* ។
- *ផែនការមេស្តីពីការដឹកជញ្ជូនតាមសមុទ្រនិងកំពង់ផែសមុទ្រ* ។

- ជំរុញ ការផ្តល់សច្ចាប័ននិងការអនុវត្ត *កិច្ចព្រមព្រៀងស្តីពី ការដឹកជញ្ជូនតាមផ្លូវទឹក ជាមួយប្រទេសវៀតណាម* ។
- *ជំរុញ ការផ្តល់សច្ចាប័ននិងការអនុវត្ត កិច្ចព្រមព្រៀងអាស៊ានស្តីពីការដឹកជញ្ជូនរវាងរដ្ឋសមាជិក ពិធីសារទី១អាស៊ាន ស្តីពីការកំណត់ ច្រកចូល-ចេញនិងផ្លូវដឹកជញ្ជូនឆ្លងកាត់* ក៏ដូចជា *អនុសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិ ផ្សេងៗទៀត* ។

៤៤៦. *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* មានភារកិច្ច ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍ វិស័យអាកាសចរណ៍ស៊ីវិលរបស់ប្រទេសកម្ពុជា ដើម្បីធានាឱ្យបាន នូវការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ទាំងក្នុងស្រុកនិងអន្តរជាតិ ប្រកបដោយ សុវត្ថិភាព សន្តិសុខ ប្រសិទ្ធភាព គុណភាព ព្រមទាំង ប្រសិទ្ធភាពចំណាយ ក្នុងកម្រិតស្តង់ដារអន្តរជាតិនៃប្រតិបត្តិការ និង ដើម្បីធ្វើអតិបរមាកម្ម ការរួមចំណែកដ៏សំខាន់របស់វិស័យនេះ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច របស់ *ព្រះរាជាណាកម្ពុជា* និង ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ តំបន់ និងអនុតំបន់ ។ ដើម្បីចូលរួមបន្តអនុវត្តគោលនយោបាយបើកចំហជើងមេឃ របស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ព្រមទាំង ដើម្បីពង្រឹងសន្តិសុខនិងសុវត្ថិភាពហោះហើរនិងចីរភាពបរិស្ថាន ក៏ដូចជា ដើម្បីពង្រឹងសេវាកម្មអាកាសយានដ្ឋាន *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* នឹងអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម :

- *ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យអាកាសចរណ៍ស៊ីវិល :*

- ធ្វើសមាហរណកម្ម និង ធ្វើឱ្យមានសុខដុមនីយកម្ម បន្តិចម្តងៗ ជាមួយនឹង គោលនយោបាយបើកចំហជើងមេឃ របស់ *អាស៊ាន មហាអនុតំបន់ទន្លេមេគង្គ ក្រុមប្រទេស កម្ពុជា ឡាវ ភូមា វៀតណាម* និង កិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងៗទៀត ។
- ជំរុញការកសាងនិងការកែលម្អសមត្ថភាពស្ថាប័ន ជាពិសេស កែសម្រួលរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង របស់ *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* ដើម្បីប្រែក្លាយជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងតាមបែប មជ្ឈការ ទៅជា បែបវិមជ្ឈការ និង វិសហមជ្ឈការ ក៏ដូចជា ដើម្បីឱ្យស្របទៅតាមតម្រូវការ របស់ *អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ* ។

- *ការពង្រឹងសន្តិសុខនិងសុវត្ថិភាព :*
  - ធ្វើវិសោធនកម្ម *ច្បាប់អាកាសចរណ៍ស៊ីវិល* ដែលបានអនុម័តកន្លងមក ដើម្បីឆ្លើយតបនឹងភាពចាំបាច់ ក្នុងការពង្រឹង សន្តិសុខ សុវត្ថិភាព ក្នុងការហោះហើរ និង ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ដែលត្រូវបានបង្កឡើងដោយ សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ។
  - ពង្រឹងតួនាទីរបស់ *រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល* ក្នុង ការធ្វើបច្ចុប្បន្នកម្ម និងការរៀបចំ បទ-ប្បញ្ញត្តិនានាសម្រាប់ បទដ្ឋានបច្ចេកទេសនិងសេដ្ឋកិច្ច និងចីរភាពបរិស្ថាន ក្នុងវិស័យអាកាសចរណ៍ស៊ីវិល ។
  - លើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ សន្តិសុខ សុវត្ថិភាព និង ការកាត់បន្ថយផលប៉ះពាល់ លើបរិស្ថាន ក្នុងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ដោយផ្អែកលើគោលការណ៍ច្បាប់និងបទប្បញ្ញត្តិ នានា ។
  - បង្កើតកិច្ចព្រមព្រៀងផ្លូវការនានា ជាមួយប្រទេសជិតខាង សម្រាប់ ការងារសន្តិសុខ សុវត្ថិភាព និង ការផ្លាស់ប្តូរទិន្នន័យប្រតិបត្តិការ ។

- *ការពង្រឹងសេវាកម្មនាំផ្លូវអាកាស និង អាកាសយានដ្ឋាន :*
  - កែលម្អ និងធ្វើទំនើបកម្ម នូវ អាកាសយានដ្ឋានដែលបានកំណត់ និង ហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ រួមមាន ការអនុវត្តនូវប្រព័ន្ធថ្មីមួយ គឺ *ប្រព័ន្ធគមនាគមន៍នាំផ្លូវ ការឃ្លាំមើលការហោះហើរ និងការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស*។
  - ជំរុញការចូលរួមរបស់ វិស័យឯកជននិងសាធារណៈ នៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និង សេវាកម្មអាកាសចរណ៍ ជាពិសេស ជំរុញឱ្យមានការវិនិយោគ ពីវិស័យឯកជនលើសកម្មភាពដែលបម្រើឱ្យវិស័យអាកាសចរណ៍ ដោយផ្ទាល់និងដោយប្រយោល ។ សកម្មភាពទាំងនោះ រួមមាន អគារលក់ដូរ ទីលានវាយកូនហ្គោល ឧទ្យានសម្រាប់កម្សាន្ត កីឡាអាកាសចរណ៍ ជាដើម ដែលមានទីតាំងនៅក្បែរអាកាសយានដ្ឋាន ហើយ ដែលនឹងត្រូវជំរុញ ដើម្បីបង្កើនចំណូល ធានាចីរភាពរបស់អាកាសយានដ្ឋាន និង ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ ។

- លើកកម្ពស់ការចូលរួមក្នុងការ ត្រួតពិនិត្យនិងសម្របសម្រួល ដំណើរនៃការអភិវឌ្ឍធុរកិច្ចទាំងឡាយ ដែលស្ថិតនៅក្រោមកិច្ចសន្យាសម្បទាន ។
- បន្តជំរុញការលើកកម្ពស់សមត្ថភាព និងការយល់ដឹងរបស់និយោជិតស្ត្រី ដើម្បីធ្វើឱ្យប្រសើរឡើង នូវតួនាទី និងស្ថានភាពរបស់ស្ត្រី នៅក្នុងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ។
- អភិវឌ្ឍ ព័ត៌មានវិទ្យា ប្រព័ន្ធព័ត៌មានឧតុនិយម ប្រព័ន្ធទិន្នន័យស្ថិតិ និង ធ្វើការសិក្សាស្រាវជ្រាវ ។

## ៤.២ ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៤៧. *រាជរដ្ឋាភិបាលកម្ពុជា* បានខិតខំស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ បន្ថែមទៀត ហើយបានដាក់ចេញនូវវិធានការនានា ដើម្បីប្រើឱ្យអស់លទ្ធភាពនូវសក្តានុពលពីប្រព័ន្ធធារាសាស្ត្រនេះ សម្រាប់ដោះស្រាយបញ្ហាទឹក ក្នុងវិស័យកសិកម្ម ។ ជាលទ្ធផល សមត្ថភាពអាងស្តុកទឹកត្រូវបានពង្រីក ហើយលទ្ធភាពនៃការដោះស្រាយទឹកសម្រាប់ការដាំដុះ ក៏បានកើនឡើងដែរ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ដែលមានការចូលរួមកាន់តែច្រើនឡើង ពីសំណាក់កសិករ ។ ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន និងតំបន់ជនបទក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ផងដែរ ។

៤៤៨. *រាជរដ្ឋាភិបាលក*ម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា នឹងបន្តផ្តល់អាទិភាពខ្ពស់ដល់ការស្តារការកសាង ការថែទាំ និងការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព នូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព អាងស្តុកទឹក ប្រឡាយទឹក សំណង់ទ្វារទឹក លូទឹក ប្រព័ន្ធដោះទឹក ប្រឡាយនាំដីល្បាប់ ទំនប់ការពារទឹកជំនន់ ទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើនផ្ទៃដី ស្រោចស្រព និង ជំរុញការងារបង្កបង្កើនផល ។

៤៤៩. *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្តោតការយកចិត្តទុកដាក់លើការធានាសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត តាមរយៈ ការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ជូនប្រជាជនគ្រប់រូប ដើម្បី ធានាសន្តិសុខស្បៀង ក្នុងជីវភាពរស់នៅរបស់ប្រជាជន ស្របតាម*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ហើយនឹង ធានាឱ្យបាន នូវ ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានទឹកពុំមានការបំពុល ។ ចក្ខុវិស័យសម្រាប់ពេលអនាគត ក្នុងការគ្រប់គ្រងទឹកក្នុងអាងទន្លេមេគង្គ *រាជរដ្ឋា-ភិបាលកម្ពុជា* នឹងបន្តចាត់វិធានការធ្វើវិចារណកម្មការប្រើប្រាស់ធនធានទឹក នៅគ្រប់ដងស្ទឹង បឹង និង ទន្លេ រួមទាំងបឹងទន្លេសាប ផងដែរ ។

៤៥០. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ តាមរយៈ ការពង្រឹងសមត្ថ-ភាពស្ថាប័នរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ តាមរយៈការបង្កើនប្រសិទ្ធភាពនេះ នឹងធ្វើឱ្យមានការកើនឡើងនូវការចូលរួមរបស់ប្រជាជន ក្នុង ការគ្រប់គ្រងនិងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រតាមបែបវិមជ្ឈការ និង ការប្រើប្រាស់

ប្រព័ន្ធធារាសាស្ត្រ ដើម្បីដោះស្រាយទឹកសម្រាប់បង្កបង្កើនផលផង សម្រួលដល់ការធ្វើដំណើររបស់ប្រជាជនផង និងអនុវត្តវារីវប្បកម្ម ផង ហើយនឹង ពង្រឹងសមត្ថភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក ផងដែរ ។ ទន្ទឹមនឹងការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន ដើម្បីធ្វើការវិនិយោគក្នុងវិស័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញ ឱ្យវិស័យឯកជនបានចូលរួមចំណែកយ៉ាងសកម្មបន្ថែមទៀត ក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹកស្អាត ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៥១. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* សកម្មភាពរបស់ *ក្រសួងធនធានទឹក និងឧតុនិយម* នឹងត្រូវផ្តោតការយកចិត្តទុកដាក់លើ យុទ្ធសាស្ត្រ ៥ ផ្នែក ៖

១. ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹក និង ការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ ។
២. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ។
៣. ការជំរុញការរៀបចំ ច្បាប់ បទប្បញ្ញត្តិ និងចីរភាពទឹក ។
៤. ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម ។
៥. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស ។

៤៥២. នៅក្នុងផ្នែក *ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹក និងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ ក្រសួងធនធានទឹកនិងឧតុនិយម* នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម ៖

- កសាងនិងស្តារ ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកបន្ទាន់ សម្រាប់ការងារកសិកម្ម ។
- ជំរុញការផ្សព្វផ្សាយពីបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្រប នៅតំបន់កសិកម្មដែលពឹងផ្អែកលើទឹកភ្លៀង ។
- ផ្តល់អាទិភាពដល់ការងារស្តារនិងសាងសង់ អាងតម្កល់ទឹក ស្រះទឹក ប្រឡាយនាំទឹក និងប្រព័ន្ធដោះទឹក ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកដល់ ផ្ទៃដីបង្កបង្កើនផល មច្ឆវប្បកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និង សត្វពាហនៈ ។
- ផ្តល់អាទិភាពដល់ ការស្តារឡើងវិញនិងការសាងសង់នូវ ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក នៅតំបន់ដែលមានប្រជាជនក្រីក្ររស់នៅ ។
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងដល់ មន្ត្រីធនធានទឹកនិងឧតុនិយម ដើម្បីអនុវត្តវិធីសាស្ត្រ និងជំនាញបច្ចេកទេសស្រោចស្រព និងដោះទឹក ។
- ប្រមូលផ្តុំឱ្យមានការចូលរួមពី កសិករ អ្នកដែលមានចំណែកពាក់ព័ន្ធ និងផ្នែកឯកជន នៅគ្រប់ដំណាក់កាលនៃការរៀបចំកែលម្អគម្រោង ព្រមទាំង ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងដោះទឹក ។

- ជំរុញការសិក្សា និងរៀបចំ ផែនការអភិវឌ្ឍន៏អាងទន្លេ សម្រាប់រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងគិតគូរដល់ ការប្រែប្រួលធារទឹកទន្លេ និង ការផ្លាស់ប្តូរចរន្តទឹកនិងល្បាងទឹកធម្មជាតិក្រោមដី ដើម្បីធានាដល់ ការប្រើប្រាស់ធនធានទឹក នា ពេលបច្ចុប្បន្ន និង ពេលអនាគត ។
- ផ្តោតការយកចិត្តទុកដាក់លើ អាងស្ទឹងអាទិភាព ព្រមទាំង អភិរក្សល្បាងទឹកក្រោមដី ។
- អនុវត្តវិធីសាស្ត្រចម្រុះ សម្រាប់ គ្រប់គ្រងនិងអភិវឌ្ឍធនធានទឹក ដោយគិតគូរពី បញ្ហាធនធានទឹកដែលផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពផ្សេងៗនៃបរិស្ថាន ការប្រែប្រួលនៃបរិស្ថាន និងការប្រែប្រួលនៃតម្រូវការរបស់មនុស្សលើធនធានទឹក ព្រមទាំង តម្រូវការនូវវិធីសាស្ត្រនានា ក្នុងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព ។
- បង្កើនការយល់ដឹង និងលើកទឹកចិត្តឱ្យមានការរៀបចំនិងការអនុវត្ត ផែនការគ្រប់គ្រងនិងអនុវត្តអាងទន្លេដោយមានការចូលរួមសហការពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអ្នកទទួលផល ។
- ជំរុញឱ្យមានការចូលរួមពី *សហគមន៍កសិករប្រើប្រាស់ទឹក* អ្នកទទួលផល និងផ្នែកឯកជន នៅគ្រប់ដំណាក់កាលនៃ ការអភិវឌ្ឍ និងការគ្រប់គ្រង ប្រព័ន្ធធារាសាស្ត្រ និង ប្រព័ន្ធដោះទឹក ។
- បង្កើនសមត្ថភាពដល់*សហគមន៍កសិករប្រើប្រាស់ទឹក* ស្តីពីរបៀបគ្រប់គ្រង ថែទាំ និងដំណើរការ ប្រព័ន្ធធារាសាស្ត្រ តាមរយៈ ការអភិវឌ្ឍ និងការគ្រប់គ្រង ដោយមានការចូលរួម ។
- ជំរុញឱ្យមានការវិនិយោគពី ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៏អន្តរជាតិ និង ផ្នែកឯកជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ការថែទាំ និង ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ តាមរយៈ ការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួម ។
- បង្កើតប្រាក់ចំណូល តាមរយៈ កសិកម្មដែលផ្អែកលើធារាសាស្ត្រ និងការបន្តការវិនិយោគក្នុងវិស័យធនធានទឹក សម្រាប់ផលិតកម្មដំណាំ ។

៤៥៣. នៅក្នុងផ្នែកនៃ*ការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ក្រសួងធនធានទឹកនិងឧតុនិយម* នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម :

- ជំរុញនិងយកចិត្តទុកដាក់លើ ការសិក្សានិងការសាងសង់ ទំនប់ការពារទឹកជំនន់ ព្រមទាំង ប្រឡាយដោះទឹកក្នុងគោលបំណង កាត់បន្ថយឱ្យបានជាអតិបរមា នូវគ្រោះធម្មជាតិដែលបណ្តាលមកពីទឹក ។
- អនុវត្តគ្រប់សកម្មភាពទាំងអស់ ដើម្បី កាត់បន្ថយទឹកជំនន់នៅគ្រប់តំបន់ ដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ចខ្ពស់ តាមរយៈ ការអប់រំដល់សហគមន៍ និង ការផ្តល់ព័ត៌មានជាសាធារណៈ តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។
- ឆ្លើយតបជាបន្ទាន់ ចំពោះ តម្រូវការរបស់ប្រជាជននៅតំបន់ដែលទទួលរងគ្រោះរាំងស្ងួត គ្រោះទឹកជំនន់និងគ្រោះមហន្តរាយផ្សេងទៀត ដែលបង្កឡើងដោយសារទឹក ។

- បន្តលើកទឹកចិត្តដល់ ប្រជាពលរដ្ឋគ្រប់រូប និង គ្រប់ស្ថាប័ន ឱ្យចូលរួមក្នុងសកម្មភាពកាត់បន្ថយគ្រោះទឹកជំនន់ ដូចជា ការរៀបចំទីទួលសុវត្ថិភាព ការផ្គត់ផ្គង់សម្ភារបរិក្ខារនិងគ្រឿងចក្រ ការផ្តល់ការអប់រំ ការបង្ហាញពីបច្ចេកវិទ្យាថ្មីៗដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែង ជាដើម ។
- ចូលរួមយ៉ាងសកម្ម ក្នុងកម្មវិធីជាតិ និងអន្តរជាតិ ដើម្បីកាត់បន្ថយឥទ្ធិពលនៃគ្រោះមហន្តរាយ ដែលបង្កឡើងដោយសារទឹក ។
- ត្រៀមលក្ខណៈចុះធ្វើអន្តរាគមន៍បូមទឹកសង្គ្រោះដំណាំស្រូវប្រាំង និងស្រូវវស្សា ពេលជួបការខ្វះខាតទឹក និង គ្រោះរាំងស្ងួត ជូនប្រជាកសិករគ្រប់ខេត្ត ជាពិសេស តំបន់នៅជិតប្រភពទឹក ហើយគ្មានប្រព័ន្ធស្រោចស្រពទៅដល់ ។

៤៥៤. នៅក្នុងផ្នែកនៃ*ការជំរុញការរៀបចំ ច្បាប់ បទប្បញ្ញត្តិ និងនិរន្តរភាពទឹក ក្រសួងធនធានទឹកនិងឧតុនិយម* នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម ៖

- រៀបចំអនុក្រឹត្យមួយចំនួន ដើម្បីអនុវត្ត *ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹក* ដែលត្រូវបានអនុម័តកាលពីខែមិថុនា ឆ្នាំ២០០៧ ដូចជា ៖
  - *អនុក្រឹត្យស្តីពី សហគមន៍កសិករប្រើប្រាស់ទឹក* ។
  - *អនុក្រឹត្យស្តីពី អាជ្ញាបណ្ណទឹក និងការចែកចាយទឹក* ។
  - *អនុក្រឹត្យស្តីពី ការគ្រប់គ្រងអាងទន្លេ* ។
  - *អនុក្រឹត្យស្តីពី គុណភាពទឹក* ។
- ពង្រឹងនិងជំរុញការអនុវត្ត*ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹក* និង បទប្បញ្ញត្តិដែលពាក់ព័ន្ធនានា ដើម្បីតាមដានត្រួតពិនិត្យនិងទប់ស្កាត់ នូវរាល់គម្រោងស្តារឡើងវិញនិងសាងសង់ ដែលអាចមានផលប៉ះពាល់ដល់ ធនធានទឹក និងប្រព័ន្ធអេកូឡូស៊ី ។
- រៀបចំនីតិវិធីសម្រាប់ការវាយតម្លៃ និងការកាត់បន្ថយ ផលប៉ះពាល់ដល់ធនធានទឹក និងសង្គម ។
- រក្សាឱ្យបាននូវ ធារទឹកនិងកម្រិតកម្ពស់អប្បបរមា ទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ដើម្បីធានានូវចីរភាពប្រព័ន្ធអេកូឡូស៊ី និងនាវាចរណ៍ ។
- ហាមឃាត់ និងមានវិធានការជាបន្ទាន់ ចំពោះការចាក់បំពេញ ការជីក ឬរំលោភបំពានដោយខុសច្បាប់លើ ផ្លូវទឹក ទន្លេ ស្ទឹង ឬដីទំនាបដែលលិចទឹកជាប្រចាំ និង ឆ្នេរសមុទ្រ ដែលបណ្តាលឱ្យមានផលប៉ះពាល់លើ ធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ។
- ពង្រឹងការងារអភិរក្ស អាងទឹកនិងបឹងធម្មជាតិ ដែលមានលទ្ធភាពស្តុកទឹក ដើម្បីជួយដល់ការកាត់បន្ថយទឹកជំនន់ ព្រមទាំងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ។

- បន្តពង្រឹងនិងពង្រីកបន្ថែម *សហគមន៍កសិករប្រើប្រាស់ទឹក* ដើម្បីរួមចំណែកក្នុងការ គ្រប់គ្រងនិងបែកចែកទឹក ដោយមានការថែរក្សាប្រព័ន្ធធារាសាស្ត្រ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ចីរភាព ។
- រៀបចំ*អនុក្រឹត្យស្តីពី ការកំណត់ទីតាំងភូមិសាស្ត្រ នៃប្រព័ន្ធធារាសាស្ត្រ និងអាងស្តុកទឹក* ដើម្បីចៀសវាងការរំលោភបំពាននានា ដែលអាចកើតមានឡើង មកលើតំបន់គ្របដណ្តប់របស់ប្រព័ន្ធធារាសាស្ត្រ ។

៤៥៥. នៅក្នុងផ្នែកនៃ *ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម ក្រសួងធនធានទឹកនិងឧតុនិយម* នឹងអនុវត្តសកម្មភាព ដូចខាងក្រោម :

- ពង្រឹង និងពង្រីកប្រព័ន្ធឧតុនិយម និងជលសាស្ត្រ រួមទាំងការប្រមូលផ្តុំព័ត៌មាន និងការផ្សព្វផ្សាយ ។
- ធ្វើការព្យាករណ៍ និងប្រកាសភាពអាសន្ន ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រងគ្រោះ ពីភាពរាំងស្ងួត ទឹកជំនន់ និង ព្យុះ សម្រាប់រយៈពេលខ្លី មធ្យម និងវែង ។
- កែលម្អនិងសាងសង់ ស្ថានីយឧតុនិយមនិងជលសាស្ត្រ ព្រមទាំង ប៉ុស្តិ៍តម្រងទឹកភ្លៀង និងក្តារវាស់កម្ពស់ទឹក នៅតាមទីតាំង និងស្ទឹងសំខាន់ៗ រួមទាំង ការប្រមូលព័ត៌មាន និងការផ្សព្វផ្សាយ ។
- តម្លើងប្រព័ន្ធអង្កេតជលសាស្ត្រ ដើម្បីផ្តល់នូវកម្រិតកម្ពស់ទឹកជាក់លាក់ និងទិន្នន័យធារទឹក សម្រាប់ការព្យាករទឹកជំនន់ និងទិន្នន័យជលសាស្ត្រដែលត្រូវយកទៅប្រើប្រាស់ សម្រាប់ការរៀបចំគម្រោង និងការគ្រប់គ្រងធនធានទឹក ។
- តម្លើងប្រព័ន្ធអង្កេតឧតុនិយម ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់ សម្រាប់ព្យាករអាកាសធាតុ ការរៀបចំគម្រោង និង សម្រាប់គោលបំណងផ្សេងៗទៀត ។
- ផ្តល់ព័ត៌មានស្តីពី ការព្យាករអាកាសធាតុ ការណែនាំ និងការអប់រំ ដល់សាធារណជន ដើម្បីលើកកម្ពស់ចំណេះដឹងពួកគាត់ ឱ្យចេះបង្ការទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ ដែលបង្កឡើងដោយការប្រែប្រួលធម្មជាតិ និង អាកាសធាតុ ដូចជា ខ្យល់ព្យុះ រន្ទះ ស៊ូណាមិ ទឹកជំនន់ ជាដើម ។
- រៀបចំសារពើភណ្ឌនិងផែនទីភូមិសាស្ត្រ សម្រាប់ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធការពារទឹកជំនន់ ទំនប់ការពារទឹកប្រៃ អាងទន្លេ-ស្ទឹង ផ្ទៃដីលិចទឹក និងការគ្រប់គ្រងធនធានទឹក ។

៤៥៦. នៅក្នុងផ្នែកនៃ *ការធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស ក្រសួងធនធានទឹក និងឧតុនិយម* នឹងអនុវត្តសកម្មភាព ដូចខាងក្រោម :

- ពង្រឹងដំណើរការរដ្ឋបាល និងផ្តល់ការបណ្តុះបណ្តាលក្នុងការងារ ដល់មន្ត្រី *ក្រសួងធនធានទឹក និងឧតុនិយម* ដើម្បីឆ្លើយតបទៅនឹងកម្រិតស្តង់ដារជាតិ និងអន្តរជាតិ ។
- បន្តពង្រឹង សមត្ថភាពរបស់មន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និង សមត្ថភាពរបស់*សហគមន៍កសិករប្រើប្រាស់ទឹក* ឱ្យយល់ដឹងពីអត្ថប្រយោជន៍របស់ទឹក ចំពោះជីវភាពប្រចាំថ្ងៃនិងការអភិវឌ្ឍសេដ្ឋកិច្ច និង

ណែនាំពួកគាត់ ឱ្យចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំផែនការសម្រាប់ ការគ្រប់គ្រង ការថែទាំ ការអភិរក្ស និង ការប្រើប្រាស់ធនធានទឹក ប្រកបដោយប្រសិទ្ធភាពនិងចីរភាព ដើម្បីរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីល្អ ដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដូចជា ការរៀបចំ កម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និង បញ្ចូលបញ្ហាទាំងនេះទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សា និង ធ្វើការផ្សព្វផ្សាយព័ត៌មាននេះ ឱ្យបានទូលំទូលាយ តាមរយៈ ព្រឹត្តិបត្រ ព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយ ផ្សេងទៀត ។

- បង្កើតប្រព័ន្ធការងារយេនឌ័រ នៅគ្រប់មន្ទីរធនធានទឹក និងឧតុនិយម ខេត្ត-រាជធានី ។
- បង្កើនការយល់ដឹង និងការវិភាគពីយេនឌ័រ នៅគ្រប់ខេត្ត-រាជធានី ។
- ធានាឱ្យមានការចូលរួមរបស់ក្រុមការងារយេនឌ័រ នៅក្នុងគ្រប់ទិដ្ឋភាពការងាររបស់ *ក្រសួងធនធានទឹក និងឧតុនិយម* ។

៤៥៧. នៅក្នុងការអនុវត្តតួនាទី ភារកិច្ច របស់ខ្លួន *ក្រសួងធនធានទឹកនិងឧតុនិយម* នឹងផ្តោតលើ :

- ការប្រើប្រាស់ជាអតិបរមានូវសក្តានុពលនៃប្រព័ន្ធធារាសាស្ត្រ ដើម្បីជាផលប្រយោជន៍ សម្រាប់ការដោះស្រាយបញ្ហាទឹក ដល់វិស័យកសិកម្ម។
- ការធានាឱ្យមានការចូលរួមច្រើនជាងមុនពីកសិករទាំងឡាយ នៅក្នុង *សហគមន៍កសិករប្រើប្រាស់ទឹក* ។
- ការពង្រឹងនូវដំណើរការនៃការផ្តល់អាទិភាពដល់ ការស្តារឡើងវិញ ការសាងសង់ ការថែទាំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដូចជា អាងស្តុកទឹក ប្រព័ន្ធដោះទឹក ប្រឡាយទឹក ប្រព័ន្ធត្រួតពិនិត្យទឹកជំនន់ ទំនប់ការពារទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើន ផ្ទៃដីដាំដុះ និង ផលិតកម្មកសិកម្ម ។
- ការយកចិត្តទុកដាក់លើ មតិយោបល់និងសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត និងការធានានូវសុវត្ថិភាពស្បៀង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដើម្បីធ្វើឱ្យសម្រេចបាននូវ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* និង ដើម្បីធានាឱ្យមាននូវ ប្រព័ន្ធអេកូឡូស៊ីនិងទឹក ដែលគ្មានការបំពុលនៅក្នុង អាងទន្លេមេគង្គ និង បន្តសិក្សាពីការប្រើប្រាស់ធនធានទឹកក្នុងទន្លេ បឹងបួរ ស្ទឹង និងទន្លេសាប ។
- ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធារាសាស្ត្រ តាមរយៈ ការកសាងសមត្ថភាព ។
- ការធានាឱ្យមានចូលរួមរបស់ស្ថាប័ននានា និងភាពជាម្ចាស់របស់ប្រជាជន ក្នុងការប្រើប្រាស់និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។
- ការធានាឱ្យមានទឹកស្អាតគ្រប់គ្រាន់ ហើយគុណភាពទឹក ឆ្លើយតបទៅនឹងតម្រូវការនៅគ្រប់វិស័យពេញទូទាំងឆ្នាំ និងដើម្បីការពារប្រព័ន្ធអេកូឡូស៊ី ។
- ការកាត់បន្ថយនៅនៅកម្រិតតិចបំផុតនូវផលប៉ះពាល់ពីទឹកជំនន់ និងកសាងសមត្ថភាព ដើម្បីការពារពីទឹកជំនន់ ដែលបណ្តាលមកពីទឹកភ្លៀង និងទឹកសមុទ្រ ។
- ការបញ្ចៀសការបំពុលធនធានទឹក ដើម្បីការពារប្រព័ន្ធអេកូឡូស៊ី ជាពិសេស ធនធានត្រី ។

## ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

៤៥៨. ដើម្បីអនុវត្តគោលនយោបាយអាទិភាព របស់ *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា រាល់សកម្មភាពរបស់ *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងត្រូវអនុវត្ត ទៅតាមកម្មវិធី បីខាងក្រោម :

១. ការងារបញ្ញត្តិកម្ម និងការកសាងភាពជាដៃគូជាមួយផ្នែកឯកជន ដើម្បីជំរុញការចូលរួមរបស់វិស័យឯកជន និងផ្តល់ការការពារនិងការឧបត្ថម្ភធនដល់ជនក្រីក្រ ។

២. កំណែទម្រង់ការគ្រប់គ្រងអង្គភាពរដ្ឋាករទឹកសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាពរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ ។

៣. ពង្រឹងការការពារបរិស្ថាននិងអនាម័យ ដើម្បីបង្ការទុកឱ្យមានប្រព័ន្ធអេកូឡូស៊ីនៃទឹកដែលគ្មានការបំពុល និងបរិស្ថានស្អាត ។

៤៥៩. នៅក្នុងផ្នែកនៃកម្មវិធី *ការងារបញ្ញត្តិកម្មនិងការកសាងភាពជាដៃគូ ជាមួយវិស័យឯកជន ដើម្បីជំរុញការចូលរួមរបស់វិស័យឯកជន និងផ្តល់ការការពារនិងការឧបត្ថម្ភធនដល់អ្នកក្រីក្រ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- រៀបចំ *សេចក្តីណែនាំអំពី នីតិវិធី និងគោលការណ៍សម្រាប់ការវិនិយោគ ក្នុងផ្នែកផ្គត់ផ្គង់ទឹកស្អាត* ។
- រៀបចំ *ប្រកាសស្តីពី ប្រតិបត្តិការ និងការផ្គត់ផ្គង់ទឹកស្អាត* ។
- រៀបចំ *ប្រកាសស្តីពី គោលនយោបាយថ្លៃដើមទឹក* ។
- ពិនិត្យនិងសិក្សាលើការកំណត់ថ្លៃដើមទឹក នៅអង្គភាពរដ្ឋាករទឹកឯកជន នៅតាមបណ្តាក្រុងនានា ។
- ពង្រឹងសមត្ថភាពការងារបញ្ញត្តិកម្ម របស់បញ្ញត្តិករ ។
- រៀបចំការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់បែងចែកតួនាទី ភារកិច្ច លើការងារបញ្ញត្តិកម្ម វិស័យផ្គត់ផ្គង់ទឹកស្អាត ។
- ពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារបញ្ញត្តិកម្ម វិស័យផ្គត់ផ្គង់ទឹកស្អាត ។
- រៀបចំលិខិតបទដ្ឋានចាំបាច់សម្រាប់លើកទឹកចិត្តដល់ ការវិនិយោគឯកជន ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត ។
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាព ពីបច្ចេកទេស និងមូលដ្ឋានគ្រប់គ្រង និងការកត់ត្រាបញ្ជីគណនេយ្យ ដល់សេវាករ ផ្គត់ផ្គង់ទឹកស្អាតឯកជន ។
- អនុវត្តគម្រោងអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ក្នុងវិស័យទឹកស្អាត ។
- ពិនិត្យនិងសិក្សា លើការរៀបចំកម្មវិធីអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យតាមទីក្រុង ។
- ជំរុញភាពជាដៃគូ ជាមួយវិស័យឯកជន ក្នុងក្របខ័ណ្ឌនៃ *វេទិកាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជា លើវិស័យទឹកស្អាត និងអនាម័យ* ។

៤៦០. នៅក្នុងផ្នែកនៃកម្មវិធី *កំណែទម្រង់ការគ្រប់គ្រងអង្គភាពរដ្ឋាករទឹកសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាពរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- ពិនិត្យសិក្សាកំណត់សម្រាប់ការពង្រឹង និងកែលម្អ គុណភាព ប្រសិទ្ធភាពអាជីវកម្ម និងអភិបាលកិច្ច របស់អង្គភាពរដ្ឋាករទឹក ។
- ត្រួតពិនិត្យនិងតាមដាន ស្ថានភាពវឌ្ឍនភាព នៃការអនុវត្ត របស់អង្គភាពរដ្ឋាករទឹកសាធារណៈ ។
- ចុះពិនិត្យ និងសិក្សាកំណត់ថ្លៃដើមទឹកនៅអង្គភាពរដ្ឋាករទឹកសាធារណៈ លើកលែងអង្គភាពស្វយ័ត ។
- អនុវត្ត គម្រោងបណ្តុះបណ្តាលនិងកសាងសមត្ថភាព អង្គភាព រដ្ឋាករទឹកសាធារណៈ ក្នុងក្រុងចំនួន ៨ ។
- ជំរុញការបង្កើត *សមាគមអង្គភាពរដ្ឋាករទឹកកម្ពុជា* ។
- អនុវត្តគម្រោងពង្រីកការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដល់សហគមន៍ក្រីក្រក្នុងទីក្រុង ចំនួន ៥ ។
- សិក្សានិងរៀបចំ គម្រោងពង្រីកការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ដល់សហគមន៍ក្រីក្រក្នុងទីក្រុង ចំនួន ៥ ។
- សិក្សានិងរៀបចំ គម្រោងស្តារ អង្គភាពរដ្ឋាករទឹក ខេត្តក្រចេះ និង ខេត្តស្ទឹងត្រែង ។
- អនុវត្តគម្រោងស្តារនិងអភិវឌ្ឍ វិស័យផ្គត់ផ្គង់ទឹកស្អាត នៅតំបន់ត្រីកោណក្នុងខេត្តរតនគិរី និង ខេត្តមណ្ឌលគិរី ។
- សិក្សានិងរៀបចំ គម្រោងពង្រីកការផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងសៀមរាប ។
- សិក្សានិងរៀបចំ គម្រោងអភិវឌ្ឍវិស័យទឹកស្អាត នៅទីប្រជុំជន ប្រាសាទសំបូរ ខេត្តកំពង់ធំ ។
- អនុវត្តគម្រោងស្តារនិងពង្រីក ការផ្គត់ផ្គង់ទឹកស្អាត នៅក្រុងកំពត ខេត្តកំពត ។
- រៀបចំនិងអនុវត្ត គម្រោងស្តារនិងពង្រីក ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងចំនួន ៦ ។
- រៀបចំនិងអនុវត្ត គម្រោងពង្រីកសមត្ថភាពផលិតកម្មទឹកស្អាត នៅក្នុងក្រុងបាត់ដំបង នៃខេត្តបាត់ដំបង ក្រុងកំពង់ចាម នៃខេត្តកំពង់ចាម ។

៤៦១. នៅក្នុងផ្នែកនៃកម្មវិធី *ពង្រឹងការការពារបរិស្ថាននិងអនាម័យ ដើម្បីបង្ការទុកឱ្យមានប្រព័ន្ធអេកូឡូស៊ីនៃទឹកដែលគ្មានការបំពុល និងបរិស្ថានស្អាត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- បង្កើនការយល់ដឹងរបស់សហគមន៍ អំពីសារៈសំខាន់នៃ ទឹកស្អាត និងអនាម័យ តាមរយៈ រូបភាពផ្សេងៗ នៃការផ្សព្វផ្សាយ និងការអប់រំ ។
- សម្របសម្រួលការរៀបចំ ផែនការសមាហរណកម្មការគ្រប់គ្រងបរិស្ថាននិងអនាម័យ នៅក្រុងចំនួន ៥ ។
- រៀបចំនិងអនុវត្ត ការដឹកនាំសម្របសម្រួល ការរៀបចំផែនការ សមាហរណកម្ម នៃការគ្រប់គ្រងបរិស្ថាន និងអនាម័យ នៅក្នុងក្រុង ចំនួន ៥ ។

- អនុវត្តគម្រោងសិក្សា អំពីក្របខ័ណ្ឌស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននិងអនាម័យ ។
- អនុវត្តគម្រោងសិក្សាអំពីយុទ្ធសាស្ត្រហិរញ្ញប្បទានលើវិស័យ បរិស្ថាន អនាម័យ និងទឹកស្អាត ។

## ៤.៣ ការអភិវឌ្ឍវិស័យថាមពល

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៦២. នៅក្នុងនីតិកាលទី៣ នៃរដ្ឋសភាកន្លងទៅ *រាជរដ្ឋាភិបាលកម្ពុជា* សម្រេចបាននូវការស្តារ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដែលមានស្រាប់ឡើងវិញ និងរៀបចំឱ្យមាន ការផ្គត់ផ្គង់អគ្គិសនី នៅតំបន់សំខាន់ៗមួយចំនួនទៀត ។ សមិទ្ធផលសំខាន់ៗ រួមមាន *(១)* ការចាប់ផ្តើមការសាងសង់ វារីអគ្គិសនីកំចាយ និងអាតៃ ព្រមទាំង បណ្តាញបញ្ជូនថាមពលមួយចំនួន *(២)* ការផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ត្រូវបានស្តារឡើងវិញ និងត្រូវបានពង្រីកឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង *(៣)* ការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាក្រុងក្នុងខេត្ត ក៏ត្រូវបានស្តារនិងកសាងថ្មី ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងក្រុងនៃខេត្តទាំងនោះ *(៤)* ទីប្រជុំជននានាជាប់ព្រំដែន ត្រូវបានរៀបចំឱ្យមានការផ្គត់ផ្គង់អគ្គិសនី តាមរយៈ ការនាំចូលអគ្គិសនីពីប្រទេសជិតខាងដែលមានតម្លៃថោក *(៥)* តំបន់ជនបទនានា ក៏ត្រូវបានរៀបចំឱ្យមានការផ្គត់ផ្គង់អគ្គិសនីផងដែរ តាមរូបភាពតូចៗ ដោយសេវាករឯកជន ក្នុងក្របខ័ណ្ឌនៃអាជ្ញាបណ្ណ ស្របតាម *ច្បាប់ស្តីពីអគ្គិសនី* ។

៤៦៣. *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងផ្តល់អាទិភាព ក្នុងការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ និងបញ្ចុះថ្លៃអគ្គិសនីឱ្យបានសមរម្យ ព្រមទាំង យកចិត្តទុកដាក់លើការពង្រឹងយន្តការស្ថាប័ន និងសមត្ថភាពគ្រប់គ្រង ។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញការបង្កើតរោងចក្រផលិតអគ្គិសនី ដែលមានថ្លៃដើមថោក ដោយប្រើប្រភពថាមពលក្នុងស្រុក ដូចជា ថាមពលវារី ឧស្ម័នធម្មជាតិ រ៉ែធ្យូងថ្ម គួបផ្សំនឹងការអភិវឌ្ឍរោងចក្រផលិតអគ្គិសនីដែលប្រើបច្ចេកវិទ្យាទំនើប និងប្រភពថាមពលបែបមិនមែនប្រពៃណី រួមទាំង ការពិនិត្យលទ្ធភាពប្រើប្រាស់ប្រភពថាមពលនុយក្លេអ៊ែរផង ព្រមទាំង ការបន្តភ្ជាប់បណ្តាញថាមពលអគ្គិសនីជាមួយប្រទេសជិតខាង ។ ការធ្វើពិពិធភាវូបនីយកម្មប្រភពថាមពល និងការបង្កើតឱ្យមានប្រភពថាមពលបម្រុងសមស្រប ក្នុងប្រព័ន្ធជាកត្តាគន្លឹះ ក្នុងការធានាសន្តិសុខថាមពល សម្រាប់កម្ពុជា ។ ជាមួយគ្នានេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញការកសាងបណ្តាញអគ្គិសនីឱ្យគ្របដណ្តប់ទូទាំងប្រទេស ដើម្បីបញ្ជូនថាមពលដែលមានគុណភាពនិងថ្លៃសមរម្យពីប្រភពនានា ទៅផ្គត់ផ្គង់សេចក្តីត្រូវការ នៅតាមបណ្តាទីក្រុង តំបន់ទីប្រជុំជន និងតំបន់ជនបទ ទាំងឡាយ ព្រមទាំង រៀបចំជាបណ្តើរៗ ដើម្បីធ្វើសមាហរណកម្មប្រព័ន្ធថាមពលអគ្គិសនីកម្ពុជា ទៅក្នុងបណ្តាញអគ្គិសនី ក្នុងប្រទេស *មហាអនុតំបន់មេគង្គ* និង *អាស៊ាន* ។

៤៦៤. ដើម្បីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ និងធានានូវការរស់នៅប្រកបដោយសុខដុមរមនារបស់ប្រជាជននៅតំបន់ជនបទ *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្តល់អាទិភាពដល់ការជំរុញ ការអនុវត្តអគ្គិសនីភាវូបនីយកម្មជនបទជាបន្តទៀត រួមទាំង ការអភិវឌ្ឍថាមពលកកើតឡើងវិញ ដើម្បីឱ្យប្រជាជននៅតំបន់ជនបទ មានអគ្គិសនីប្រើប្រាស់ ។

៤៦៥. *រាជរដ្ឋាភិបាលកម្ពុជា* នឹងផ្តល់អាទិភាពខ្ពស់លើ ការទាក់ទាញឱ្យមានការចូលរួមរបស់វិស័យឯកជន ក្នុងការវិនិយោគក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពល រួមទាំងការផលិត ការបញ្ជូន និងការចែកចាយ ក្នុងនោះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តការផ្តោតការយកចិត្តទុកដាក់ឱ្យបានជាអតិបរមា លើបរិស្ថានធម្មជាតិ និងសង្គម ក្នុងការអភិវឌ្ឍគម្រោងវិស័យថាមពល ទន្ទឹមនឹង ការសង្កត់ធ្ងន់លើប្រសិទ្ធភាពសេដ្ឋកិច្ចរបស់គម្រោងនីមួយៗ ។ ការយកចិត្តទុកដាក់ ក៏នឹងត្រូវផ្តោតជាសំខាន់ផងដែរ លើការកសាងសមត្ថភាព និងការកែទម្រង់ស្ថាប័ន ក្នុងវិស័យថាមពលអគ្គិសនី រួមមាន *អាជ្ញាធរអគ្គិសនី ក្រុមហ៊ុនអគ្គិសនីកម្ពុជា* ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រង ក៏ដូចជា គុណភាពសេវាផ្គត់ផ្គង់អគ្គិសនី ។

៤៦៦. *រាជរដ្ឋាភិបាលកម្ពុជា* ចាត់ទុកធនធានប្រេងនិងឧស្ម័នកម្ពុជា គឺជាសក្តានុពលថ្មីដ៏សំខាន់ សម្រាប់ធានាសន្តិសុខថាមពល និងជាប្រភពនៃធនធានដ៏មានតម្លៃ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែង ។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយ និង ក្របខ័ណ្ឌគតិយុត្ត សម្រាប់វិស័យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធាននេះ ក្នុងបុព្វហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ច និងការលើកកម្ពស់កម្រិតជីវភាពរស់នៅ របស់ប្រជាជនកម្ពុជា ។

៤៦៧. *រាជរដ្ឋាភិបាលកម្ពុជា* លើកទឹកចិត្តឱ្យប្រើប្រាស់ប្រភេទថាមពល ដែលមានប្រសិទ្ធភាព និងមានផលប៉ះពាល់តិចតួច ដល់បរិស្ថាន ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៦៨. ដើម្បីអនុវត្ត*យុទ្ធសាស្ត្រចតុកោណ* របស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងផ្តោតការយកចិត្តទុកដាក់ លើ :

- ការបង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនី និងកាត់បន្ថយថ្លៃឱ្យនៅក្នុងកម្រិតមួយសមស្រប ជាមួយគ្នានឹង ការពង្រឹងយន្តការស្ថាប័ន និង សមត្ថភាពផ្គត់ផ្គង់ ។
- ធានាការជឿជាក់លើការផ្គត់ផ្គង់អគ្គិសនី ដើម្បីសម្រួលនិងទាក់ទាញការវិនិយោគក្នុងវិស័យនេះ និងដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។

- បង្កើតគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យថាមពល ដើម្បីធានាប្រសិទ្ធភាព នៃការគ្រប់គ្រង និងប្រើប្រាស់ធនធាន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។
- លើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងមានផលប៉ះពាល់ដល់បរិស្ថាន ក្នុងកម្រិតទាបបំផុត ។

៤៦៩. ដើម្បីបំពេញតម្រូវការអគ្គិសនី នៅទូទាំងប្រទេស *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* មានទិសដៅអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- ជំរុញការរុករកប្រភពធនធានថាមពល ដូចជា ថាមពលវារី ឧស្ម័នធម្មជាតិ និងធ្យូងថ្មជាដើម សម្រាប់ការផលិតថាមពលអគ្គិសនី ។
- ធានាឱ្យមានការទុកចិត្តនិងស្ថិរភាព ក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីសម្រួលដល់ការវិនិយោគ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។
- លើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមកពី ការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពល ។
- បន្តជំរុញឱ្យមានការចូលរួមវិនិយោគពីផ្នែកឯកជន ក្នុងវិស័យថាមពល រួមមាន ការផលិត ការបញ្ជូន និងការចែកចាយ ជាដើម ។
- បន្តជំរុញឱ្យមានការអភិវឌ្ឍ លើវិស័យថាមពលកកើតឡើងវិញគ្រប់ប្រភេទ ដូចជា ជីវម៉ាស់ ជីវឧស្ម័ន ជីវឥន្ធនៈ ។ល។ និងបង្កើនប្រសិទ្ធភាពនៃថាមពល តាមរយៈ ការប្រើប្រាស់ចង្ក្រានប្រសិទ្ធភាព ដើម្បីកាត់បន្ថយការប្រើប្រាស់ ប្រេង អុស ធ្យូង ជាដើម ។
- ជំរុញការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងតំបន់ តាមរយៈ សហប្រតិបត្តិការទ្វេនិងពហុភាគី ។

៤៧០. ដើម្បីបង្កើនការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅក្នុងរយៈពេល ៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣) ខាងមុខ *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹង :

- ដាក់ឱ្យដំណើរការ *វារីអគ្គិសនីកំចាយ* ដែលមានអានុភាពសរុប ១៩៣,២ មេហ្គាវ៉ាត់ នៅឆ្នាំ២០១១ ។
- ដាក់ឱ្យដំណើរការ *វារីអគ្គិសនីគីរីរម្យទី៣* ដែលមានអានុភាពសរុប ១៨ មេហ្គាវ៉ាត់ នៅឆ្នាំ២០១២ ។
- ដាក់ឱ្យដំណើរការនូវជំហានទី១ ដោយមានអានុភាព ១០០ មេហ្គាវ៉ាត់ នៃ *រោងចក្រអគ្គិសនីធ្យូងថ្មទី១* ដែលមានអានុភាពសរុប ២០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ នៅឆ្នាំ២០១១ ។
- ដាក់ឱ្យដំណើរការ *វារីអគ្គិសនីស្ទឹងអាតៃ* ដែលមានអានុភាពសរុប ១២០មេហ្គាវ៉ាត់ នៅឆ្នាំ២០១២ ។

- ដាក់ឱ្យដំណើរការជំហានទី២ *រោងចក្រអគ្គិសនីធ្យូងថ្មទី១* ដោយមានអានុភាពសរុប ២០០ មេហ្គាវ៉ាត់ នៅខេត្តព្រះ សីហនុ នៅឆ្នាំ២០១២ ។
- ដាក់ឱ្យដំណើរការមួយផ្នែកនៃ *វារីអគ្គិសនីស្ទឹងតាតៃ* ដែលមានអានុភាពសរុប ២៤៦ មេហ្គាវ៉ាត់ នៅចុងឆ្នាំ២០១៣ ។
- ដាក់ឱ្យដំណើរការមួយផ្នែកនៃ*វារីអគ្គិសនីស្ទឹងឫស្សីជ្រំក្រោម* ដែលមានអានុភាពសរុប ៣៣៨ មេហ្គាវ៉ាត់ នៅចុងឆ្នាំ២០១៣ ។

៤៧១. ដើម្បីពង្រីកបណ្តាញបញ្ជូនថាមពលអគ្គិសនី *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តនូវគម្រោងមួយចំនួន ដូចខាងក្រោម :

- ដាក់ឱ្យដំណើរការ ខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល (៧៣ គីឡូម៉ែត្រ) តភ្ជាប់ តាកែវ-កំពត និង អនុស្ថានីយកំពត នៅឆ្នាំ២០១១ ។
- នាំចូលថាមពលអគ្គិសនី តាមរយៈខ្សែបញ្ជូនថាមពលតង់ស្យុង ១១៥គីឡូវ៉ុល (៥៨គីឡូម៉ែត្រ) ដោយមានអានុភាព ២០ មេហ្គាវ៉ាត់ ពីព្រំដែន *កម្ពុជា-ឡាវ* មកទីរួម ខេត្តស្ទឹងត្រែង និង បង្កើតអនុស្ថានីយស្ទឹងត្រែងមួយកន្លែង នៅឆ្នាំ២០១១ ។
- នាំចូលថាមពលអគ្គិសនី តាមរយៈខ្សែបញ្ជូនថាមពលតង់ស្យុង ១១៥គីឡូវ៉ុល (៦៥ គីឡូម៉ែត្រ) ដោយមានអានុភាព ២០ មេហ្គាវ៉ាត់ ពី ព្រំដែនកម្ពុជា-វៀតណាម មកទីរួមខេត្តកំពង់ចាម និង បង្កើតអនុស្ថានីយចំនួនបី : *ពញាក្រែក សួង កំពង់ចាម* នៅឆ្នាំ២០១១ ។
- ដាក់ឱ្យដំណើរការ ខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល (៨៩ គីឡូម៉ែត្រ) តភ្ជាប់ កំពត-ខេត្តព្រះសីហនុ និង អនុស្ថានីយខេត្តព្រះសីហនុ នៅឆ្នាំ២០១១ ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល (១៧៥ គីឡូម៉ែត្រ) តភ្ជាប់ពី អនុស្ថានីយអូរសោម (ជាអនុស្ថានីយរួមសម្រាប់ភ្ជាប់វារីអគ្គិសនីផ្សេងៗទៀត នៅតំបន់នោះ) មកកាន់អនុស្ថានីយពោធិសាត់ នៅឆ្នាំ២០១២ ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល តភ្ជាប់ ភ្នំពេញ-កំពង់ឆ្នាំង-ពោធិសាត់-បាត់ដំបង (៣០២គីឡូម៉ែត្រ) និងអនុស្ថានីយចំនួន ៣ : កំពង់ឆ្នាំង-ពោធិសាត់ និងបាត់ដំបង នៅឆ្នាំ ២០១២ ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល តភ្ជាប់ ភ្នំពេញ-កំពង់ចាម (១១០គីឡូម៉ែត្រ) នៅឆ្នាំ២០១២ ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០គីឡូវ៉ុល តភ្ជាប់ កំពង់ចាម-ក្រចេះ (១២០គីឡូម៉ែត្រ) នៅឆ្នាំ២០១២ ។

- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល តភ្ជាប់ ក្រចេះ-ស្ទឹងត្រែង (១៣០គីឡូម៉ែត្រ) នៅឆ្នាំ២០១២ ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនកង (Loop Line) ថាមពលតង់ស្យុង ២៣០ គីឡូវ៉ុល (៧១,៥ គីឡូម៉ែត្រ) នៅជុំវិញរាជធានីភ្នំពេញ នៅឆ្នាំ២០១២ ។
- ដាក់ឱ្យដំណើរការខ្សែបញ្ជូនថាមពលតង់ស្យុង ២៣០គីឡូវ៉ុល តភ្ជាប់ ភ្នំពេញ-ខេត្តព្រះសីហនុ (២២៥ គីឡូម៉ែត្រ) តាមផ្លូវជាតិលេខ៤ នៅឆ្នាំ២០១៣ ។

### តារាងទី១៧ : សូចនាករសំខាន់ៗ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

| សូចនាករ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|
| អគ្គិសនីដែលផលិតបាន | លាន គវ៉ម | ១ ៨៥៨,៣៦៤ | ១ ៨៨២,០០៣ | ២ ១៦៤,៣០០ | ២ ៤៨៨,៩៤៥ | ២ ៨៦២,២៨៧ | ៣ ២៩១,៦២៩ |
| ចំនួនគ្រួសារប្រើប្រាស់ថាមពល | គ្រួសារ | ៤៨៧ ៤២៦ | ៥៦០ ៩៣៩ | ៦៤៤ ៦២១ | ៧៤១ ៣១៤ | ៨៥២ ៥១១ | ៩៨០ ៣៨៨ |
| ការប្រើប្រាស់ថាមពលរបស់ប្រជាជនម្នាក់ក្នុង១ឆ្នាំ | គវ៉ម | ១៣៩ | ១៣៥ | ១៥៣ | ១៧៤ | ១៩៧ | ២២៤ |
| ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (២២ KV) | គម | ១ ៤៥០ | ១ ៥៥៥ | ១ ៩១៤ | ២ ២០១ | ២ ៩៣១ | ២ ៩១១ |
| ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (១១៥ KV) | គម | ៣២៣ | ៣៥៣ | ៣៥៣ | ៤៧៦ | ៥៤៧,៥ | ៥៤៧,៥ |
| ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (២៣០ KV) | គម | ០ | ១០០ | ១០០ | ២៦៩ | ១ ១៨២ | ១ ៤០៧ |

*ប្រភព : ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល*

៤៧២. ដើម្បីអនុវត្ត*យុទ្ធសាស្ត្រចតុកោណ* របស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា អាជ្ញាធរប្រេងកាតជាតិកម្ពុជា* នឹងផ្តោតការយកចិត្តទុកដាក់លើ :

- បន្តរកចំណូលឱ្យបានជាអតិបរមាជូន*រាជរដ្ឋាភិបាល* តាមរយៈ ចំណូលជា សួយសារ ការបែងចែកផល ពន្ធលើប្រាក់ចំណេញ និងចំណូលពន្ធផ្សេងៗទៀត ទាក់ទងនឹងអាជីវកម្មប្រេងកាត និងឧស្ម័ន ដើម្បីចូលរួមក្នុងការបង្កើនសមត្ថភាពហិរញ្ញវត្ថុរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។
- បង្កើតគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា សម្រាប់វិស័យប្រេងកាត ដើម្បីធានានូវប្រសិទ្ធភាព ក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ ធនធានប្រេងកាតនិងឧស្ម័ន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។
- យកចិត្តទុកដាក់រៀបចំផែនការ សម្រាប់ការប្រើប្រាស់ឧស្ម័ន ដែលស្ថិតនៅលាយឡំជាមួយប្រេងកាត ដែលនឹងទទួលបានពីផលិតកម្មប្រេងកាត ដើម្បីការពារកុំឱ្យឧស្ម័នទាំងនោះក្លាយជាសំណល់ ដែលឆេះចោលនៅក្នុងខ្យល់ ។
- លើកកម្ពស់សកម្មភាពឱ្យបានសមស្រប សម្រាប់កែច្នៃធនធានប្រេងកាតប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបង្កើតកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម ។

- ជំរុញការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័ន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។
- បង្កើនការគ្រប់គ្រង និងតាមដានត្រួតពិនិត្យ លើកាអនុវត្តកិច្ចព្រមព្រៀងប្រេងកាត ឱ្យមានប្រសិទ្ធភាពជាងមុន ។
- ជំរុញការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ដោយផ្តោតលើបញ្ហាប្រេងកាតនិងឧស្ម័ន ។

## ៤.៤ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៧៣. នៅក្នុងនីតិកាលទី៣ នៃរដ្ឋសភាកន្លងមក វិស័យបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ សម្រេចបាននូវការរីកចម្រើនគួរកត់សម្គាល់ តាមរយៈ ការពង្រីកវិសាលភាពគ្របដណ្តប់នៃសេវាប្រៃសណីយ៍និងទូរគមនាគមន៍ និងសេវាអ៊ីនធឺណេតផង និង ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់សេវានេះ ។

៤៧៤. ដោយវិស័យនេះ ជាវិស័យមួយដែលមានការប្រកួតប្រជែងខ្ពស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងបន្តអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ និង ជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនា-គមន៍ទំនើបទាន់សម័យ ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃថោកសមរម្យ និងមានសេវាគ្របដណ្តប់ទូទាំងប្រទេស ។ អាទិភាពសំខាន់ៗក្នុងវិស័យនេះ រួមមាន *(១)* ជំរុញអនុម័ត*ច្បាប់ស្តីពី ទូរគមនាគមន៍* និងក្របខ័ណ្ឌបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនានា *(២)* កសាងសមត្ថភាពស្ថាប័នក្នុងវិស័យនេះ *(៣)* កែលម្អ និងជំរុញការធ្វើទំនើបកម្មមូលដ្ឋានសម្ភារបច្ចេកទេស ដើម្បីធានាប្រសិទ្ធភាពនិងវិសាលភាពនៃសេវានេះ *(៤)* លើកស្ទួយការប្រកួតប្រជែង នៅក្នុងទីផ្សារសេវាប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីធានាប្រសិទ្ធភាពនៃវិស័យនេះ *(៥)* បន្តពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងរដ្ឋបាលអេឡិចត្រូនិច *(៦)* ជំរុញការកសាង និងបង្កើនប្រសិទ្ធភាព ហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង សម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ។

### ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៧៥. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* នឹងធ្វើការពង្រីកសេវាកម្មប្រៃសណីយ៍ និងកាត់បន្ថយថ្លៃ ដោយ :

- ធ្វើការអភិវឌ្ឍ និងផ្តល់ព័ត៌មានស្តីពី កាលានុវត្តភាពនៃការវិនិយោគ ដល់អ្នកវិនិយោគ ទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ។

- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវការអនុវត្តគម្រោងអភិវឌ្ឍនានា ដែលកំពុងដំណើរការ ដើម្បីធានាការបញ្ចប់គម្រោងទាំងនេះ ទៅតាមកម្មវិធី ដែលបានគ្រោងទុក ។ គម្រោងទាំងនេះ រួមមាន :
  - ➢ បណ្តាញទូរគមនាគមន៍ឆ្អឹងខ្នងមហាអនុតំបន់មេគង្គ GMTBN (របៀងសេដ្ឋកិច្ច) ឬគម្រោង JICA CP-P5 ។
  - ➢ ស្ពានខ្សែកាបអុបទិកនៅក្រោមសមុទ្រ ។
  - ➢ សាងសង់ បណ្តាញទូរគមនាគមន៍ខ្សែអុបទិក ។
  - ➢ គម្រោងក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលភ្ជាប់បណ្តាញខ្សែកាបពី សៀមរាប ទៅ ស្គន់ ពី កំពង់ចាម ទៅ ព្រំប្រទល់ប្រទេសឡាវ (ស្ទឹងត្រែង) និង ការធ្វើឱ្យប្រសើរឡើងនូវ សេវាទូរគមនាគមន៍ក្នុងតំបន់ ទីប្រជុំជន និងតំបន់ជនបទ ។
- បន្តតាមដានត្រួតពិនិត្យ និងអនុវត្តវិធានការច្បាប់នានា ចំពោះអ្នកផ្តល់សេវាទូរគមនាគមន៍នានា ដែលរំលោភលើកិច្ចសន្យា ។
- រៀបចំនិងប្រកាសឱ្យប្រើប្រាស់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យនេះ ដែលត្រូវការចាំបាច់ ដើម្បីតម្រង់ទិសដល់ក្រុមហ៊ុនវិនិយោគនានា ។
- បន្ត និងផ្តល់អាទិភាព ក្នុងការលុបបំបាត់ការបាត់បង់ចំណូល ពីប្រព័ន្ធទូរគមនាគមន៍ចល័ត ។
- បន្តជំរុញការអភិវឌ្ឍបណ្តាញខ្សែកាបអុបទិក ដោយប្រើប្រាស់ខ្សែកាបនៅក្រោមដីនិងក្រោមសមុទ្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវ សេវាកម្មទូរគមនាគមន៍ក្នុងប្រទេស និងសេវាកម្មទូរគមនាគមន៍ទៅក្រៅប្រទេស ។
- លើកកម្ពស់ និងធ្វើឱ្យប្រសើរឡើង ការស្រាវជ្រាវ និងការអភិវឌ្ឍ ផ្តោតលើបញ្ហាយេនឌ័រ ។
- សាងសង់ការិយាល័យទូរគមនាគមន៍ នៅ *រតនគិរី តាកែវ ស្ទឹងត្រែង* និង *កំពង់ធំ* ។

៤៧៦. ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ *ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* នឹងស្នើសុំការអនុម័តជាផ្លូវការ លើ :

- *ច្បាប់ស្តីពី ទូរគមនាគមន៍ (២០០៩)* ។
- *ច្បាប់ស្តីពី វិទ្យុទូរគមនាគមន៍ (២០១០-២០១១)* ។
- *ច្បាប់ស្តីពី អ៊ិនធឺណែត (២០១១-២០១២)* ។
- *ច្បាប់ស្តីពី ប្រព័ន្ធខ្សែកាបអុបទិក (២០១១-២០១២)* ។
- *អនុក្រឹត្យស្តីពី ការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា* ។
- *អនុក្រឹត្យស្តីពី ការបង្កើតសេវាទូរគមនាគមន៍សកល (២០០៩-២០១១)* ។
- ការផ្តល់សច្ចាប័នដល់ *ធម្មនុញ្ញ* និង *អនុសញ្ញា ស្តីពី សហគមន៍ទូរគមនាគមន៍អន្តរជាតិ (២០០៩)* ។
- ការផ្តល់សច្ចាប័នលើ ការឱ្យកម្ពុជាចូលជាហត្ថលេខី លើ *អនុស្សារណៈអង្គការអ៊ិនធឺណែតរបស់សហរដ្ឋ (២០០៩-២០១០)* ។

- ការផ្ដល់សច្ចាប័នលើ ការឱ្យកម្ពុជាចូលជាសមាជិក *អង្គការអន្តរជាតិពហុភាគី ប្រឆាំងភេរវកម្មអ៊ិនធឺណែត (២០១០-២០១១)* ។
- គោលនយោបាយស្ដីពី ការគ្រប់គ្រងសេវាទូរសព្ទតាមរយៈប្រព័ន្ធអ៊ិនធឺណែត សម្លេងតាមអ៊ិនធឺណែត និងអ្នកផ្ដល់សេវាអ៊ិនធឺណែត (២០១០-២០១១) ។
- *សេចក្ដីប្រកាសស្ដីពី តារាងផែនការហ្វ្រេកង់ជាតិ (២០០៩)* ។
- *សេចក្ដីប្រកាសស្ដីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យការប្រើប្រាស់រលកអាកាសវិទ្យុ* (២០១០) ។
- *សារាចរស្ដីពី បទដ្ឋានដំឡើងបង្គោលអង់តែនវិទ្យុគមនាគមន៍គ្រប់ប្រភេទ (២០០៩)* ។
- *ប្រកាសស្ដីពី ប្លង់លេខទូរសព្ទជាតិ (២០០៩-២០១០)* ។
- *ប្រកាសស្ដីពី តម្លៃប្រើប្រាស់ប្លង់លេខទូរសព្ទ (២០០៩-២០១០)* ។
- *ប្រកាសស្ដីពី ការភ្ជាប់បណ្ដាញទូរគមនាគមន៍សាធារណៈ (២០០៩-២០១០* ។
- *ប្រកាសស្ដីពី ការគ្រប់គ្រងសម្ភារបរិក្ខារវិទ្យុទាក់ទង និងថ្លៃនៃការប្រើប្រាស់រលកអាកាសវិទ្យុ (២០១១)* ។
- *ប្រកាសស្ដីពី ការគ្រប់គ្រងបច្ចេកវិទ្យា ការស្ថាបនានិងការប្រើប្រាស់ សេវាទូរសព្ទចល័ត និងអចល័ត (២០០៩)*។

៤៧៧. ចំណុចដៅនៃកំណើន ដែលត្រូវបានកំណត់សម្រាប់ការពង្រីកវិស័យទូរគមនាគមន៍ ត្រូវបានបង្ហាញនៅក្នុងតារាងទី១៨ ខាងក្រោម ៖

**តារាងទី១៨ ៖ ចំណុចដៅនៃការពង្រីកសេវាកម្មទូរគមនាគមន៍**

| ចំណុចដៅ | ២០០៨ ជាក់ស្ដែង | ២០០៩ ជាក់ស្ដែង | ២០១០ ព្យាករណ៍ | ២០១១ ព្យាករណ៍ | ២០១២ ព្យាករណ៍ | ២០១៣ ព្យាករណ៍ |
|---|---|---|---|---|---|---|
| ទូរស័ព្ទចល័តនិងអចល័ត (ពាន់គ្រឿង) | ៤ ១៤៣ | ៦ ៤៤៧ | ៧ ១០០ | ៧ ៧០០ | ៨ ៣០០ | ៨ ៩០០ |
| ចំនួនអ្នកជាវអ៊ិនធឺណែត (នាក់) | ២០ ១០៨ | ២៩១ ៤១៣ | ៣៥០ 000 | ៤០០ 000 | ៤៥០ 000 | ៥០០ 000 |

៤៧៨. ដើម្បីអនុវត្តគោលនយោបាយអាទិភាព របស់*រាជរដ្ឋាភិបាលកម្ពុជា ក្រសួងព័ត៌មាន* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- ពង្រីកវិសាលភាព និងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាព នៃបណ្ដាញផ្សព្វផ្សាយជាតិ ដើម្បីផ្ដល់សេវាកម្មឱ្យបាន ដល់ ៩៥ភាគរយនៃប្រជាជនទូទាំងប្រទេស ដល់ក្នុងតំបន់ និងទ្វីបផ្សេងទៀត រួមទាំង អាមេរិកខាងជើង ។
- បន្តសាងសង់ស្ថានីយវិទ្យុ និងទូរទស្សន៍ នៅតាមខេត្ត និងលើកកម្ពស់សមត្ថភាព ដើម្បីមានលទ្ធភាពអាចបន្តផ្ទាល់នូវព្រឹត្តការណ៍សំខាន់ៗ នៅកម្រិតជាតិ និង មានលទ្ធភាពផលិតនូវកម្មវិធីផ្សព្វផ្សាយទៅដល់តំបន់នានាបន្ថែមទៀត ជាពិសេស បញ្ហាទាក់ទងនឹងស្ត្រីនិងកុមារ ។

- កសាងស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ដោយផ្តោតលើ ការបង្កើនចំនួនមន្ត្រីស្ត្រី ការធ្វើឱ្យប្រសើរឡើងការផ្តល់សេវាកម្ម និង ប្រសិទ្ធភាពនៃការទាក់ទាញនិងសហការ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ ។
- ជំរុញការការអនុវត្តច្បាប់ស្តីពី សារព័ត៌មាន ដើម្បីលើកកម្ពស់ វិធានការច្បាប់ សិទ្ធិសេរីភាពសារព័ត៌មានក្នុងការសរសេរ និងបោះពុម្ពផ្សាយ ។
- សិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងឧបករណ៍ច្បាប់ ដើម្បីតាមដានត្រួតពិនិត្យការធ្វើអាជីវកម្មប្រព័ន្ធផ្សព្វផ្សាយ និង ដើម្បីគាំទ្រដល់ការអភិវឌ្ឍផ្នែកព័ត៌មានសោតទស្សន៍ និង បច្ចេកវិទ្យាព័ត៌មាន ។
- បន្តលើកទឹកចិត្តនិងបើកទូលាយ នូវការចូលរួមរបស់វិស័យសាធារណៈ សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល និង ផ្តល់អាទិភាពដល់ស្ត្រី ក្នុងការដើរតួនាទីរបស់ខ្លួន នៅក្នុងផ្នែកព័ត៌មានសោតទស្សន៍ ។

## តារាងទី១៩ : សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន

| សូចនាករសំខាន់ៗ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|
| ***ក. អង្គភាពភ្នាក់ងារព័ត៌មានរដ្ឋ*** | | | | | | | |
| ១. ទូរទស្សន៍រដ្ឋ | | | | | | | |
| ស្ថានីយកណ្តាល | ចំនួន | ០១ | ០១ | ០២ | ០២ | ០២ | ០២ |
| ស្ថានីយខេត្ត | ចំនួន | ០៥ | ០៥ | ០៧ | ០៧ | ០៨ | ១០ |
| ២. វិទ្យុរដ្ឋ | | | | | | | |
| ស្ថានីយកណ្តាល | ចំនួន | ០២ | ០២ | ០៣ | ០៤ | ០៤ | ០៥ |
| ស្ថានីយខេត្ត | ចំនួន | ១១ | ១៣ | ១៥ | ១៦ | ១៨ | ២០ |
| ៣. ទីភ្នាក់ងារសារព័ត៌មានជាតិ | ផ្នែក | ០១ | ០១ | ០១ | ០១ | ០១ | ០១ |
| ***ខ. អង្គភាពភ្នាក់ងារព័ត៌មានឯកជន*** | | | | | | | |
| ១. ស្ថានីយទូរទស្សន៍ | ចំនួន | ០៦ | ០៧ | ០៩ | ១០ | ១០ | ១១ |
| ២. ទូរទស្សន៍ខ្សែកាប (ក្រុង/ខេត្ត) | កន្លែង | ៩០ | ៩៣ | ៩៣ | ៩៣ | ៩៥ | ៩៦ |
| ៣. ស្ថានីយវិទ្យុ | ចំនួន | ៣៩ | ៤០ | ៤២ | ៤៣ | ៤៣ | ៤៤ |
| ៤. ទីភ្នាក់ងារបោះពុម្ពផ្សាយ (សារព័ត៌មាន ព្រឹត្តិបត្រទស្សនាវដ្តី ជាភាសាខ្មែរ និង បរទេស) | កន្លែង | ៥៤២ | ៥៥០ | ៥៥៥ | ៥៦០ | ៥៦៥ | ៥៧០ |
| ៥. រោងពុម្ព | កន្លែង | ១៣៣ | ១៣៤ | ១៣៥ | ១៣៥ | ១៣៦ | ១៣៦ |

# ៥. ការអភិវឌ្ឍវិស័យឯកជននិងការងារ

៤៧៩. មុំ ឬ សមាសធាតុរងទាំងបួន នៃចតុកោណនេះ រួមមាន : *(១) ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ (២) ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ (៣) ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (៤) ការរៀបចំសុវត្ថិភាពសង្គម* ។

## ៥.១ ការពង្រឹងវិស័យឯកជន និង ការទាក់ទាញការវិនិយោគ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៨០. *រាជរដ្ឋាភិបាលកម្ពុជា* បានធានាធ្វើឲយចុះនូវចំណាយនៃប្រតិបត្តិការធុរកិច្ច និងពង្រីកលទ្ធភាពចូលទីផ្សារ ក៏ដូចជា កាត់បន្ថយចំណាយលើការដឹកជញ្ជូន និងកែលម្អសុវត្ថិភាពធ្វើដំណើរ តាមរយៈ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលធានាបាននូវ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទជាមួយនឹងសេដ្ឋកិច្ចទីប្រជុំជន ។ *រាជរដ្ឋាភិបាលកម្ពុជា* បានរៀបចំក្របខ័ណ្ឌគតិយុត្តចាំបាច់ ជាច្រើន សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន និងបានពង្រឹង *"វេទិការាជរដ្ឋាភិបាល-វិស័យឯកជន"* ឱ្យទៅជាយន្តការដោះស្រាយបញ្ហាដ៏មានប្រសិទ្ធភាព ។ ការកាត់បន្ថយនូវការតម្រូវខាងឯកសារ បានជួយសម្រួលដល់ធុរកិច្ចនានា ជាពិសេស តាមរយៈការដាក់អនុវត្តនូវប្រព័ន្ធ *"ឯកសាររដ្ឋបាលតែមួយ"* និងសេវា *"ច្រកចេញ-ចូលតែមួយ"* ។

៤៨១. *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងបន្តផ្តោតអាទិភាព លើការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈ ការបង្កើនការវិនិយោគសាធារណៈ នៅក្នុងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមមាន ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក (រួមទាំងតាមទន្លេនិងសមុទ្រ) និងផ្លូវអាកាស ការជំរុញការផលិត និងពង្រីកបណ្តាញចែកចាយអគ្គិសនី នៅតំបន់ទីប្រជុំជននិងជនបទ ក្នុងថ្លៃថោកសមរម្យ ការពង្រឹង និងពង្រីកបណ្តាញទូរគមនាគមន៍ដែលមានសេវាទំនើប ក្នុងថ្លៃថោកសមរម្យ ការពង្រឹងនិងពង្រីក បណ្តាញផ្គត់ផ្គង់ទឹកស្អាតព្រមទាំង ការពង្រឹងនិងពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សម្រាប់វិស័យទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិ ។

៤៨២. *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈ ការអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវកាតព្វកិច្ចរបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃ*អង្គការពាណិជ្ជកម្មពិភពលោក* ក្របខ័ណ្ឌ*អាស៊ាន* និងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងអនុតំបន់ដទៃទៀត ។ បន្ថែមលើនេះទៀត *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រវិស័យឯកជន រួមមាន បទប្បញ្ញត្តិច្បាប់និងនីតិវិធីរដ្ឋបាល ការលើកកម្ពស់ផលិតភាព តាមរយៈ ការបណ្តុះបណ្តាលបុគ្គលិក អ្នកបច្ចេកទេស និងកម្មករជំនាញ ការធានាឱ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ ការបន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ការជំរុញការអនុវត្ត*ច្បាប់ស្តីពីការងារ*និងការពង្រឹងយន្តការដោះស្រាយវិវាទឱ្យមានប្រសិទ្ធភាព ។

៤៨៣. ជាចំណែកមួយដ៏សំខាន់នៃគោលនយោបាយពិពិធភាវូបនីយកម្ម មូលដ្ឋានសេដ្ឋកិច្ច *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញការបង្កើតនូវបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃ និងវិស័យឧស្សាហកម្មគ្រឿងបង្គុំអេឡិចត្រូនិក និងគ្រឿងម៉ាស៊ីន ។ ក្នុងស្មារតីនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់ ជាពិសេស ការរៀបចំក្របខ័ណ្ឌច្បាប់និងកិខិតបទដ្ឋានគតិយុត្ត សម្រាប់កិច្ចដំណើរការ ប្រកបដោយប្រសិទ្ធភាព នូវតំបន់សេដ្ឋកិច្ចពិសេស ។

៤៨៤. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តលើកទឹកចិត្តដល់ភាពជាដៃគូ រវាង វិស័យសាធារណៈ និងវិស័យឯកជន នៅក្នុងការវិនិយោគ ជាពិសេស នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៨៥. *ក្រសួងផែនការ* បាននឹងកំពុងដឹកនាំរៀបចំដំណើរការ *ជំរឿនសហគ្រាស* ឆ្នាំ២០១១ ដែលជាជំរឿនសេដ្ឋកិច្ចជាប្រវត្តិសាស្ត្រលើកដំបូងនៅកម្ពុជា ដើម្បីបម្រើឱ្យ ការគ្រប់គ្រង និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពក្នុងវិស័យនេះ ។ *ជំរឿនសហគ្រាស* ជាជំរឿនមួយនៃជំរឿនទាំងបី *(ជំរឿនប្រជារាស្ត្រ ជំរឿនសហគ្រាស និង ជំរឿនកសិកម្ម)* ដែលមានចែងនៅក្នុងច្បាប់ស្ថិតិ និងផែនការមេស្ថិតិ ឆ្នាំ២០០៨-២០១៥ ដែលត្រូវអនុវត្ត ដោយ *វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ* ។ *ជំរឿនសហគ្រាស* ដែលនឹងផ្តល់នូវព័ត៌មានស្ថិតិសំខាន់ៗ សម្រាប់ ការកំណត់សកម្មភាពសេដ្ឋកិច្ច និង ទីតាំងនៃអាជីវកម្ម ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច នឹងរួមចំណែក ក្នុងការអនុវត្តគោលនយោបាយនានារបស់ *រាជរដ្ឋាភិបាល* ដូចជា ការរៀបចំ និង ការតាមដានត្រួតពិនិត្យការអនុវត្ត ផែនការអភិវឌ្ឍជាតិ ការងារកំណែទម្រង់អភិបាលកិច្ចល្អ ការកាត់បន្ថយភាពក្រីក្រ ការពង្រឹងការអភិវឌ្ឍវិស័យឯកជន និង ការទាក់ទាញវិនិយោគិន ទាំងក្នុង និងក្រៅប្រទេស ។

៤៨៦. *សម្រាប់រាជរដ្ឋាភិបាកម្ពុជា* វិស័យឯកជន គឺជាក្បាលម៉ាស៊ីនម្រាប់កំណើន និងការកាត់បន្ថយភាពក្រីក្រ ។ *រាជរដ្ឋាភិបាល* ទទួលស្គាល់ថា ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្ម និងការបង្កើតនូវបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍវិស័យឯកជន គឺជាមូលដ្ឋានគន្លឹះសម្រាប់ជំរុញ ការអភិវឌ្ឍ បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និង សម្រេចបានស្ថិរភាពកំណើនសេដ្ឋកិច្ច ។ ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ គឺជាបញ្ហាអន្តរវិស័យ ដែលមានការពាក់ព័ន្ធជាមួយស្ថាប័នមួយចំនួន របស់ *រាជរដ្ឋាភិបាលកម្ពុជា* ។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* អាទិភាពខ្ពស់បំផុតរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់ *រាជរដ្ឋាភិបាលកម្ពុជា គឺ ការគាំទ្រការបង្កើតនូវបរិយាកាសអំណោយផល ដែលជំរុញឱ្យមានការអភិវឌ្ឍវិស័យឯកជន តាមរយៈ ការអនុវត្តវិធានការនានា ដើម្បីលុបបំបាត់បណ្តាឱបសគ្គទាំងឡាយ ដែលរារាំងដល់ការអភិវឌ្ឍវិស័យឯកជន* ។

៤៨៧. *ក្រុមប្រឹក្សាវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* បានបង្កើត *"សេវាកម្មច្រកចេញចូលតែមួយ "* សម្រាប់ឱ្យវិនិយោគិន ជាច្រើនឆ្នាំមកហើយ ដើម្បីកាត់បន្ថយបន្ទុកផ្នែករដ្ឋបាល នៅក្នុងការសុំការអនុម័ត ពី *រាជរដ្ឋាភិបាលកម្ពុជា* លើគម្រោងវិនិយោគថ្មី។ នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ យន្តការ *"សេវាកម្មច្រកចេញចូលតែមួយ"* នឹងត្រូវបានបន្តពង្រឹងនិងតម្រែតម្រង់ ហើយយន្តការថ្មី *"ការយកចិត្តទុកដាក់ចំពោះវិនិយោគិន"* និង *"ប្រព័ន្ធតាមដាននិងត្រួតពិនិត្យការវិនិយោគ"* នឹងត្រូវបានបង្កើតឡើង និងអនុវត្ត ។ *ក្រុមប្រឹក្សាវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* និង *ក្រសួងពាណិជ្ជកម្ម* នឹងបន្តជំរុញយ៉ាងសកម្មឱ្យមានការវិនិយោគថ្មីៗ ក្នុងវិស័យសេដ្ឋកិច្ចអាទិភាពនានា ដើម្បី ធ្វើពិពិធកម្មនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ច រៀបចំនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយ នូវព័ត៌មានស្តីពីកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យអាទិភាព ដើម្បីផ្តល់សក្តានុពលដល់វិនិយោគិនវិស័យឯកជន និង ពង្រឹងការសម្របសម្រួលក្នុងចំណោមស្ថាប័នពាក់ព័ន្ធនានារបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការជំរុញការទទួលខុសត្រូវរួមគ្នា សម្រាប់លើកកម្ពស់ការប្រកួតប្រជែងរបស់អាជីវកម្ម ក្នុងវិស័យឯកជន ។

៤៨៨. *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* នឹងពង្រឹងបន្តទៀត នូវការអនុវត្ត *តំបន់សេដ្ឋកិច្ចពិសេស* ហើយនឹងធានាថា ទីតាំងនៃ *តំបន់សេដ្ឋកិច្ចពិសេស* នឹងសមស្របសម្រាប់ធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ ឱ្យបានជាអតិបរមា ។

**តារាងទី២០ : សូចនាករសំខាន់ៗរបស់វិស័យពាណិជ្ជកម្ម**

| សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០១០ | ២០១៣ |
|---|---|---|---|---|---|
| តម្លៃនៃការនាំចូល | ពាន់លានរៀល | ១៥ ២៨១ | ១៨ ០៤០ | | |
| តម្លៃនៃការនាំចូល | លានដុល្លារ | ៣ ៧២៧ | ៤ ៤០០ | | |
| តម្លៃនៃការនាំចេញ | ពាន់លានរៀល | ១១ ៨៩០ | ១៧ ៨០២ | | |
| តម្លៃនៃការនាំចេញ | លានដុល្លារ | ២ ៩០០ | ៤ ៣៤២ | | |
| សម្លៀកបំពាក់ | ពាន់លានរៀល | ៨ ៩៧៩ | ២ ២១៨ | ១០ ២៥០ | |
| សម្លៀកបំពាក់ | លានដុល្លារ | ២ ១៩០ | ២ ៩៨០ | ២ ៥០០ | |
| ចំនួនរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ២២៤ | ២៩៣ | ២៩៥ | ៣៥០ |
| ចំនួនកម្មករ (ប្រុសនិងស្រី) បំពេញការងារក្នុងរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ២៦៣ ៩៤១ | ៣៥១ ៣៤០ | ៣៥០ ០០០ | ៤០០ ០០០ |
| ប្រាក់បៀវត្សរ៍សរុប | លានរៀល | ៧៣ ៨០០ | ១១២ ៧៥០ | ១១០ ៧០០ | ១២៣ ០០០ |

៤៨៩. ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៩ មក *វេទិការាជរដ្ឋាភិបាលកម្ពុជា-វិស័យឯកជន* និងគណៈកម្មាធិការ ដែលស្ថិតនៅក្រោមយន្តការនេះ បានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងដំណើរការនៃ កំណែទម្រង់ការរដ្ឋបាល និងកំណែទម្រង់ច្បាប់ ដើម្បីជំរុញការអភិវឌ្ឍវិស័យឯកជន ។ យន្តការសម្របសម្រួលនេះ មិនត្រឹមតែមានប្រសិទ្ធភាពក្នុងការកសាងភាពជាដៃគូជាមួយវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំង ក្នុងការផ្តល់ធាតុចូល នៅក្នុងការធ្វើ

អាទិភាពរូបនីយកម្ម នូវសកម្មភាពនានានៃកម្មវិធីកំណែទម្រង់ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តរិះរកវិធីសាស្ត្រថ្មី ដើម្បីបន្តពង្រឹងយន្តការសម្របសម្រួលរវាង *រាជរដ្ឋាភិបាលកម្ពុជា-វិស័យឯកជន* និង កសាងនូវភាពជាដៃគូរវាង *វិស័យសាធារណៈ-វិស័យឯកជន* ។

៤៩០. ក្នុងនីតិកាលទី៤ នៃរដ្ឋសភា *ក្រសួងពាណិជ្ជកម្ម* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- ពង្រឹងការអនុវត្តកម្មវិធីវិស័យពាណិជ្ជកម្ម ដែលផ្អែកលើ *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* ដែលផ្តោតលើកិច្ចសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យឯកជន ។ សូចនាករសំខាន់ៗសម្រាប់វិស័យពាណិជ្ជកម្ម មានបង្ហាញជូនក្នុង តារាងទី២០ ខាងលើ ។
- បន្តអនុវត្តនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈ ការជំរុញការនាំចេញផលិតផល ជាពិសេស ផលិត-ផលកសិកម្ម សម្លៀកបំពាក់ និងផលិតផលផ្សេងទៀត ។
- បន្តធ្វើសមាហរណកម្ម ដើម្បីសម្រេចគោលដៅបើកច្រកចូលទីផ្សារក្នុងតំបន់ និងអន្តរជាតិ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ។
- រៀបចំពិពណ៌កម្រិតជាតិ នឹងអន្តរជាតិ ឱ្យបានច្រើនថែមទៀត ។
- ពង្រឹងប្រសិទ្ធភាព នៃការត្រួតពិនិត្យទីផ្សារ ដើម្បីការពារសុខភាព និងសុខុមាលភាព អ្នកប្រើប្រាស់ ។
- ពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ។
- ពង្រឹងភាពជាដៃគូ ជាមួយស្ថាប័នអន្តរជាតិ និងជាមួយបរទេស ដើម្បីធ្វើឱ្យកម្ពុជាក្លាយជាដៃគូអភិវឌ្ឍន៍ល្អ និងគួរជាទីទុកចិត្ត ។

៤៩១. នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា *ក្រសួងពាណិជ្ជកម្ម* នឹងបញ្ជូនច្បាប់មួយចំនួន ដូចខាងក្រោម ដើម្បីសុំការពិនិត្យពិភាក្សា និងអនុម័ត :

- នៅចុងឆ្នាំ ២០០៩នេះ *ក្រសួងពាណិជ្ជកម្ម* នឹងបញ្ជូនច្បាប់ចំនួន ៣ ទៅគណរដ្ឋមន្ត្រី ដើម្បីសុំការអនុម័ត គឺ *(១) ច្បាប់កិច្ចសន្យាពាណិជ្ជកម្ម (២) ច្បាប់ស្តីពី ការការពារ ការសម្គាល់ភូមិសាស្ត្រទំនិញ* និង *(៣) ច្បាប់ស្តីពី ការបង្កើតតុលាការពាណិជ្ជកម្ម* ។
- នៅឆ្នាំ២០១០ *ក្រសួងពាណិជ្ជកម្ម* នឹងបញ្ជូនសេចក្តីព្រាងច្បាប់ មួយចំនួន ទៅគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័ត ដែលរួមមាន *(១) ច្បាប់ស្តីពី ការប្រកួតប្រជែង* (កំពុងរៀបចំ) *(២) ច្បាប់ស្តីពី ពាណិជ្ជកម្មអេឡិចត្រូនិក* (កំពុងរៀបចំ) *ច្បាប់ស្តីពី ការការពារអ្នកប្រើប្រាស់* (នឹងត្រូវរៀបចំ) និង *ច្បាប់ស្តីពី ឧបាស្រ័យពាណិជ្ជកម្ម (កំពុងរៀបចំ)* ។
- នៅចុងឆ្នាំ២០១១ *ច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម* នឹងត្រូវបញ្ជូនទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងអនុម័ត ។

៤៩២. នៅក្នុង*នីតិកាលទី៤នៃរដ្ឋសភា ក្រសួងទេសចរណ៍* នឹងផ្តោតលើសកម្មភាព លើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ ដើម្បីទាក់ទាញការទស្សនា ការពន្យារពេលស្នាក់នៅ និងការធ្វើវិនិយោគក្នុងវិស័យទេសចរណ៍ ។ សកម្មភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ ជាសំខាន់ រួមមាន ៖

- បន្តអនុវត្តគោលនយោបាយបើកចំហជើងមេឃ និងបន្តជំរុញយុទ្ធនាការឃោសនាផ្សព្វផ្សាយ*កម្ពុជា ៖ ព្រះរាជាណាចក្រអច្ឆរិយៈ* និងជំរុញចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ ។
- ពិនិត្យលទ្ធភាពក្នុងការជំរុញការលើកលែងទិដ្ឋាការចំពោះប្រទេសសំខាន់ៗ ជាពិសេស ជាមួយប្រទេសជប៉ុន និង សាធារណរដ្ឋកូរ៉េ ។
- ការរៀបចំគេហទំព័រ ដើម្បីធ្វើការផ្សព្វផ្សាយពីវិស័យទេសចរណ៍កម្ពុជា ទៅតាមប្រទេស ដែលជាគោលដៅទីផ្សារសំខាន់ៗ ។
- បន្តផ្សព្វផ្សាយ *ច្បាប់ស្តីពីទេសចរណ៍* ដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេស ផ្នែកឯកជន ដើម្បីពង្រឹងការអនុវត្តច្បាប់នេះ និង ដើម្បីលើកកម្ពស់គុណភាពនៃផលិតផលនិងសេវាកម្មទេសចរណ៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។
- សម្រួលការធ្វើដំណើរនិងការដឹកជញ្ជូន និង ការកាត់បន្ថយរបាំងមិនចាំបាច់នានា ដែលបង្កការលំបាកដល់ភ្ញៀវទេសចរមកទស្សនាកម្ពុជា ។
- បង្កើតផលិតផលទេសចរណ៍ថ្មី ព្រឹត្តិការណ៍ទេសចរណ៍ និងគោលដៅដែលមានការទាក់ទាញ (ដោយផ្អែកលើទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិ) ។
- ជំរុញចលនាទេសចរណ៍ក្នុងស្រុក ឱ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។
- ពង្រឹងនិងពង្រីក កិច្ចសហប្រតិបត្តិការទេសចរណ៍ ជាមួយបណ្តាប្រទេសនានាក្នុងតំបន់ និងបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក ។
- ពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយ ក្រសួង-ស្ថាប័ន ផ្នែកឯកជន អង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធនានា ក្នុងការជំរុញកិច្ចអភិវឌ្ឍទេសចរណ៍កម្ពុជា ឱ្យក្លាយជាគោលដៅទេសចរណ៍ ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ។
- ជំរុញកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ឱ្យស្របតាមគោលនយោបាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* និង ស្របតាមកំណើននិងនិន្នាការទេសចរណ៍បច្ចុប្បន្ន ។
- ជំរុញការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យទេសចរណ៍ ទាំងក្នុង ផ្នែកសាធារណៈ ផ្នែកឯកជន និងសហគមន៍មូលដ្ឋាន ។
- ធ្វើអង្កេតទេសចរណ៍ និងរៀបចំបង្កើតស្ថិតិទេសចរណ៍ ។
- បន្តពង្រឹងសន្តិសុខ និងសុវត្ថិភាពសង្គម ជូនភ្ញៀវទេសចរ ដែលបានមកទស្សនាកម្ពុជា ។

៤៩៣. *ក្រសួងទេសចរណ៍* នឹងបញ្ចប់ការរៀបចំ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត មួយចំនួន សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ដែលក្នុងនោះ រួមមាន :

- *យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ជាតិ ២០១០-២០២០* ។
- *ផែនការអភិវឌ្ឍន៍ទេសចរណ៍ជាតិ ២០១០-២០១៣* ។
- *គោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍ជាតិ* ។
- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដែលតម្រូវដោយ *ច្បាប់ស្តីពីទេសចរណ៍* និង សកម្មភាពទេសចរណ៍ ។

៤៩៤. ការការពារ និងការលើកកម្ពស់មតិកវប្បធម៌ប្រពៃណីខ្មែរដ៏សម្បូរបែប នឹងនៅតែបន្តជាអាទិភាពខ្ពស់របស់*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ។ *ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ* នឹងបន្តការថែរក្សាប្រាសាទបុរាណនានា និងសារមន្ទីរជាតិ និង ជំរុញលើកកម្ពស់យ៉ាងខ្លាំងក្លានូវ សិល្បៈខ្មែរ រួមទាំង របាំប្រពៃណីខ្មែរ ចម្រៀង និងក្បាច់ចម្លាក់ ព្រមទាំង ជំរុញលើកទឹកចិត្តដល់ការធ្វើឱ្យរស់រានឡើងវិញនូវ ផលិតផលនិងទីផ្សារសិប្បកម្មខ្មែរ ដែលរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រដល់កំណើនវិស័យទេសចរណ៍ ។

៤៩៥. នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ *ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ* មានផែនការនឹងអនុវត្តនូវ កម្មវិធីចំនួន ២៣ ដែលទាក់ទងនឹង :

- ជួសជុល និងថែរក្សាប្រាសាទបុរាណ រួមទាំងកែលម្អផ្លូវថ្នល់ និងស្ពាន ដើម្បីងាយស្រួលធ្វើដំណើរទៅប្រាសាទបុរាណ ទាំងនោះ ។
- ជួសជុលនិងថែទាំ សារមន្ទីរជាតិ រួមទាំង ការរក្សា និងសាងសង់ឡើងវិញ នូវសារមន្ទីរតាំងពិព័រណ៍ ។
- សាងសង់ការិយាល័យនៅខេត្ត និងមជ្ឈមណ្ឌលកុលសម្ព័ន្ធ នៅភូមិភាគឦសាន។
- សាងសង់សាលតាំងពិព័រណ៍ផលិតផលវប្បធម៌ និងសាលសម្រាប់ការបង្ហាញពីរបាំប្រពៃណីខ្មែរ ។

## ៥.២ ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៤៩៦. នៅក្នុងនីតិកាលទី៣ នៃរដ្ឋសភា ចំនួនសហគ្រាស និងគ្រឹះស្ថានសេដ្ឋកិច្ច បានកើនឡើងគួរឱ្យកត់សម្គាល់ដល់ចំនួន ២ ៤០០ ហើយស្រូបយកកម្មករ និយោជិតប្រមាណ ៤៤០ ៥០០នាក់ ។ ពលករកម្ពុជាចំនួនជាង ៥០ ០០០នាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ។ ការអនុវត្តគោលនយោបាយបើកចំហជើងមេឃ បាននាំឱ្យមានការកើនឡើងយ៉ាងខ្លាំងនូវចំនួនភ្ញៀវទេសចរ និងបានបង្កើនការងារជាច្រើនជូនប្រជាពលរដ្ឋ ។ សេរីភាពសហជីព ក៏ត្រូវបានលើកកម្ពស់ ផងដែរ ។ យន្តការត្រួតពិនិត្យការងារ និងដោះស្រាយវិវាទការងារ ត្រូវបានពង្រឹង ដើម្បីតាមដានត្រួតពិនិត្យ ការជំរុញការអនុវត្ត*ច្បាប់ស្តីពីការងារ* និងធានានូវបរិស្ថានការងារ ប្រកបដោយសុខដុមរមនា ។

៤៩៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តគោលនយោបាយ ផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ ស្តង់ដារការងារ បទដ្ឋានពលកម្មនិង*ច្បាប់ស្តីពីការងារ* និងអនុសញ្ញាអន្តរជាតិនានា រួមទាំង ការបន្តជំរុញយន្តការ *"រោងចក្រប្រសើរនៅកម្ពុជា"* ការនាំចេញពលករទៅបរទេស ការពង្រឹងសមត្ថភាពជំនាញ តាមរយៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យសមស្របតាមតម្រូវការទីផ្សារ ដោយផ្តោតជាសំខាន់លើមុខសញ្ញាយុវជនដែលពុំមានលទ្ធភាពបន្តការសិក្សានៅសាលាចំណេះទូទៅ ជនពិការ ស្ត្រី ជនបាត់បង់ឱកាស និងជនជាតិភាគតិច ការកសាងប្រព័ន្ធស្ថិតិការងារ និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព័ត៌មានស្តីពីតម្រូវការទីផ្សារការងារ ដើម្បីធានាឱ្យបាននូវចល័តភាពនៃពលកម្ម និងការពង្រឹងយន្តការដោះស្រាយវិវាទការងារដែលមានស្រាប់ ដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាល គណៈកម្មការដោះស្រាយបាតុកម្ម កូដកម្ម គ្រប់ថ្នាក់ ។

៤៩៨. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបណ្តុះបណ្តាលអ្នកផ្សះផ្សាវិវាទស្ម័គ្រចិត្ត ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន សំដៅដោះស្រាយវិវាទប្រកបដោយសន្តិវិធី ។ បន្ថែមលើនេះ កិច្ចខិតខំប្រឹងប្រែង នឹងត្រូវធ្វើឡើង ដើម្បីធានានូវ ស្ថិរភាពនៃការបង្កើតការងារ ការជំរុញការអនុវត្ត*ច្បាប់ស្តីពីការងារ* តាមរយៈ ការអប់រំបណ្តុះបណ្តាល និងការចុះអធិការកិច្ចការងារ តាមរោងចក្រសហគ្រាស ដើម្បី បង្កើនការយល់ដឹងពីលក្ខខណ្ឌការងារ រួមទាំង អនាម័យនិងសុខភាពសុវត្ថិភាពការងារ ការប្រឆាំងនឹងពលកម្មកុមារនិងការប្រើប្រាស់ពលករបរទេស ការអនុវត្តសេរីភាពរបស់សហជីពស្របតាម *ច្បាប់ស្តីពីការងារ* និងកសាង *ច្បាប់សហជីព* ព្រមទាំង ក្របខ័ណ្ឌបទដ្ឋានគតិយុត្តនានា ស្តីពីការបង្កើត*តុលាការការងារ* តាមរយៈ ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយភាគីពាក់ព័ន្ធ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤៩៩. ការធានាឱ្យមានលក្ខខណ្ឌការងារល្អ មានសុវត្ថិភាពត្រឹមត្រូវ មានអនាម័យល្អ និងមានលក្ខខណ្ឌកិច្ចសន្យាត្រឹមត្រូវនិងយុត្តិធម៌ សម្រាប់ពលករ នៅកន្លែងធ្វើការ គឺជាកិច្ចការមួយដ៏សំខាន់ក្នុងការជំរុញការអនុវត្តនូវគោល-នយោបាយនិងយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធវិស័យការងារ ។ *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* បាននិងកំពុងដោះស្រាយជាប្រចាំនូវកិច្ចការទាំងអស់នេះ ដោយបាន ដាក់កម្រិតអប្បបរមានៃ ប្រាក់ឈ្នួលប្រចាំខែ និងថ្ងៃឈប់សម្រាក កាត់បន្ថយវិសមភាពប្រាក់ឈ្នួលរវាងបុរសនិងស្ត្រី ដោះស្រាយជម្លោះនិងការមិនឯកភាពគ្នា ដោយសន្តិវិធីដោយមិនបង្កឡើងនូវការអាក់ខានដល់ចង្វាក់ផលិតកម្ម និង ការបាត់បង់ប្រាក់ឈ្នួលរបស់កម្មករ-និយោជិត ។ ជាមួយគ្នានេះ *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* ក៏បានលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យទាំងពីរ (ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ) សំដៅ បង្កើតឱកាសការងារសមស្រប ទាំងក្នុងនិងក្រៅប្រព័ន្ធ បង្កើតបណ្តាញអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសម្រាប់ពលករទាំងពីរភេទ បង្កើតប្រព័ន្ធទិន្នន័យស្ថិតិពលករដែលមានការបែងចែកតាមភេទ លើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរសម្រាប់កម្មករទាំងពីរភេទ ជាពិសេស កម្មការិនី

ទាំងនៅក្នុងស្រុកនិងនៅក្រៅប្រទេស ដោះស្រាយគម្លាតប្រាក់បៀវត្សរ៍រវាងបុរសនិងស្ត្រី និងពង្រឹងការអនុវត្ត *ច្បាប់ស្តីពីការងារ* និង *ច្បាប់ស្តីពីរបបសន្តិសុខសង្គម* ។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាល-កម្ពុជា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- សិក្សានិងរៀបចំ *គោលនយោបាយជាតិស្តីពីការគ្រប់គ្រងមុខរបរនិងហត្ថពលកម្ម* ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ពលករក្នុងប្រទេស និងកែលម្អការគ្រប់គ្រងការផ្តល់សេវាមុខរបរនៅក្រៅប្រទេស តាមរយៈ ទីភ្នាក់ងារស្របច្បាប់របស់ក្រសួង ការបង្កើតប្រព័ន្ធសាធារណៈនៃសេវាមុខរបរក្រៅប្រទេស និង ការការពារពលករទេសន្តប្រវេសន៍ ក៏ដូចជា ដើម្បីរួមចំណែកក្នុងការបង្កើតការងារគ្រប់ប្រភេទ សំដៅបង្កើនប្រាក់ចំណូលដោយមិនមានការរើសអើង ជាពិសេស សំដៅលើកកម្ពស់តម្លៃស្ត្រី ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ គោលនយោបាយនេះ នឹងផ្តោតលើ :
  - ➢ ការអភិវឌ្ឍមុខរបរក្នុងប្រទេស និង ការងារនៅបរទេស ។
  - ➢ ការអភិវឌ្ឍការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។
  - ➢ ការរៀបចំឯកសណ្ឋានអធិការកិច្ចការងារ ។
  - ➢ ការបង្កើតវិទ្យាស្ថានការងារ ។
  - ➢ ការបង្កើតគណៈកម្មការស្រាវជ្រាវ និងផ្សព្វផ្សាយ ព័ត៌មាន ស្តីពី សហគ្រាសគ្រឹះស្ថាន ។
- ធានាលក្ខខណ្ឌការងារល្អប្រសើរ សំដៅ លើកកម្ពស់សិទ្ធិការងារជាមូលដ្ឋានរបស់កម្មករ-និយោជិត និង រក្សាលក្ខខណ្ឌការងារល្អក្នុងកន្លែងធ្វើការងារ ជាពិសេស សម្រាប់ជនពិការនិងកម្មការិនី ។ សកម្មភាពអាទិភាពនានា ដែលត្រូវអនុវត្តដើម្បីសម្រេចឱ្យបានតាមទិសដៅការងារខាងលើ រួមមាន ដូចខាងក្រោម :
  - ➢ លើកកម្ពស់សិទ្ធិការងារជាមូលដ្ឋានរបស់ កម្មករ-និយោជិត ។
  - ➢ ការរក្សាលក្ខខណ្ឌល្អក្នុងកន្លែងធ្វើការ ។
  - ➢ ការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ ថ្នាក់ជាតិ ។
  - ➢ ការកែលម្អការធ្វើអធិការកិច្ច ផ្នែកសុខភាពនិងសុវត្ថិភាពការងារ និង ការអនុវត្តតាមច្បាប់ ។
  - ➢ ការជំរុញសកម្មភាព ផ្នែកសុខភាពនិងសុវត្ថិភាពការងារ តាមរយៈ អង្គការនិយោជក និង អង្គការកម្មករ-និយោជិត ។
  - ➢ ការអនុវត្តកម្មវិធីពិសេស សម្រាប់ មុខរបរគ្រោះថ្នាក់ ។
  - ➢ ការពង្រីកការការពារ ផ្នែកសុខភាពនិងសុវត្ថិភាពការងារ ដល់ សហគ្រាសខ្នាតតូច និងកន្លែងការងារនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។
  - ➢ ការជំរុញឱ្យមានការបណ្តុះបណ្តាលស្តីពីសុខភាពនិងសុវត្ថិភាពការងារ សម្រាប់កសិករ ។

- ការចូលរួមកាត់បន្ថយករណីឆ្លងថ្មី និង ផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈ ការកាត់បន្ថយភាពងាយរងគ្រោះចំពោះ ការឆ្លងមេរោគអេដស៍ ក្នុងចំណោមកម្មករ-និយោជិត នៅតាមរោងចក្រកាត់ដេរ គ្រឹះស្ថានសហគ្រាស និងសិស្ស និស្សិត នៅតាមបណ្តាគ្រឹះស្ថានអប់រំ ។
- ការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដល់ ប្រជាជនចំណាកស្រុក ដើម្បីឱ្យពួកគាត់មានភាពងាយស្រួល ក្នុងការស្វែងរកការងារធ្វើ ។
- លើកកម្ពស់សុវត្ថិភាពការងារសម្រាប់ កុមារអាយុ១៥ឆ្នាំ ដល់ អាយុក្រោម១៨ឆ្នាំ (អាយុអប្បបរមាអាចបម្រើការងារបាន) ។
- ឆ្ពោះទៅរកការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នាឆ្នាំ២០១៦ ។
- រៀបចំផែនការសកម្មភាពរាជធានី-ខេត្ត ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។
- តាមដានត្រួតពិនិត្យ និងធ្វើអធិការកិច្ចពលកម្មកុមារ ក្នុងតំបន់ដែលមានសហគ្រាសឧស្សាហកម្ម ។
- ទប់ស្កាត់ និងដកហូត កម្មពលករកុមារ ព្រមទាំង ធ្វើសមាហរណកម្មពលករកុមារទៅក្នុងសង្គម ក្នុងគោលដៅលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។
- តាមដានត្រួតពិនិត្យនិងវាយតម្លៃ ការងារលុបបំបាត់ពលកម្មកុមារ ។

• ជំរុញការអនុវត្ត*ច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ* តាមរយៈ សកម្មភាពអាទិភាព ដូចខាងក្រោម ៖

- ពង្រីកនិងពង្រឹង ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ឱ្យបានលើគ្រប់សហគ្រាសគ្រឹះស្ថាននៅទូទាំងប្រទេស ។
- សិក្សានិងរៀបចំបង្កើតរបបថែទាំសុខភាពសម្រាប់កម្មករ-និយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃ*ច្បាប់ស្តីពីការងារ* ។
- សិក្សានិងរៀបចំបង្កើតរបបប្រាក់សោធន សម្រាប់កម្មករ-និយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃ*ច្បាប់ស្តីពីការងារ* ។

• ជំរុញការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ជូនប្រជាពលរដ្ឋ សំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ជាពិសេស ការលើកកម្ពស់សិទ្ធិជនពិការ និងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។ សកម្មភាពអាទិភាព នៅក្នុងការងារនេះ រួមមានដូចខាងក្រោម ៖

- ផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យបានសមស្រប តាមតម្រូវការទីផ្សារពលកម្ម ទាំងក្នុងនិងក្រៅប្រទេស ។
- ការអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារជាតិសមត្ថភាព ការធ្វើតេស្ត និង ការទទួលស្គាល់វគ្គកម្មវិធីសិក្សា និងគ្រឹះស្ថានសិក្សា ។

- ការពង្រាយកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈ ការហ្វឹកហ្វឺនកូនជាង ការបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ និង មូលនិធិជាតិកាត់បន្ថយភាពក្រីក្រ ។
- ការអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ។
- ការជំរុញ ការផ្សព្វផ្សាយអំពីសមភាពយេនឌ័រ និង ការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ៥.៣ ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៥០០. *រាជរដ្ឋាភិបាលកម្ពុជា* បានកាត់បន្ថយការតម្រូវអប្បបរមា សម្រាប់ការចុះបញ្ជីទុននៃសហគ្រាសធុនតូចនិងមធ្យម និងបានកាត់បន្ថយចំណាយក្នុងការចុះបញ្ជីក្រុមហ៊ុន ។ ប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានកែលម្អឱ្យមានលក្ខណៈសាមញ្ញ ។ កម្ចីដែលផ្តល់ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូចនិងមធ្យម បានកើនឡើងគួរឱ្យកត់សម្គាល់ ។

៥០១. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងបរិស្ថានធុរកិច្ច សម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដោយផ្តោតលើ ទិដ្ឋភាពសំខាន់បួន គឺ *(១) ក្របខ័ណ្ឌច្បាប់ និងបញ្ញត្តិកម្ម* ការសម្រួលការចុះបញ្ជី ជាពិសេសតាមប្រព័ន្ធអ៊ិនធឺណែត ការកំណត់នីតិវិធីនិងគោលការណ៍ សម្រាប់ការត្រួតពិនិត្យនិងបញ្ជាក់ពីផលិតផលនាំចេញនិងនាំចូល និង ការអនុម័ត*អនុក្រឹត្យស្តីពី ការសម្រួលពាណិជ្ជកម្ម* តាមរយៈ វិធីសាស្ត្រគ្រប់គ្រងហានិភ័យ *(២) ការផ្តល់ហិរញ្ញប្បទាន* រួមមាន ការបង្កើតក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និង ការពង្រឹងអភិបាលកិច្ច និងរបាយការណ៍ហិរញ្ញវត្ថុ *(៣) សកម្មភាពគាំទ្រសហគ្រាសធុនតូច និងមធ្យម* រួមមាន ការលើកស្ទួយនវានុវត្តន៍ និង បច្ចេកវិទ្យា ព្រមទាំង ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម និងពង្រីកសេវាគាំទ្រផ្សេងៗទៀត *(៤) ការបញ្ចូលសហគ្រាសធុនតូចនិងមធ្យម* ទៅក្នុងខ្សែចង្វាក់តម្លៃជាសកល និង ការទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ ។

៥០២. បន្ថែមលើនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញការអនុវត្តនូវវិធានការថ្មីៗមួយចំនួនទៀត ដូចជា ការបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដើម្បីលើកកម្ពស់ផលិតភាព និងកាត់បន្ថយថ្លៃដើមផលិតកម្ម ការបង្កើតវិទ្យាស្ថានស្តង់ដារជាតិ ដើម្បីធានានូវគុណភាពផលិតផល ដោយអនុលោមតាម ស្តង់ដារជាតិនិងអន្តរជាតិ ការបង្កើតមន្ទីរពិសោធន៍ជាតិ សម្រាប់ធ្វើតេស្តផ្នែករូបសាស្ត្រ គីមីសាស្ត្រ មីក្រូជីវសាស្ត្រ និងមេកានិច ដើម្បីកំណត់គុណភាព និងលក្ខណៈវិនិច្ឆ័យផលិតផល ការពង្រឹងយន្តការការពារកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញតក្កកម្ម ការប្រើប្រាស់បច្ចេកទេសនិងបច្ចេកវិទ្យាថ្មី ព្រមទាំង ការលើកកម្ពស់ការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងការពង្រឹងក្របខ័ណ្ឌគតិយុត្ត ។

៥០៣. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញចលនា *"ភូមិមួយ-ផលិតផលមួយ"* ដោយលើកទឹកចិត្តឱ្យមានគំនិតច្នៃប្រឌិត សហគ្រិនភាព និងភាពជំនឿលើខ្លួនឯង នៅតាមតំបន់ទីជនបទ ។ ចលនានេះ បានផ្តល់នូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយ ដើម្បីផ្សារភ្ជាប់ផលិតកម្មទៅនឹងទីផ្សារ ជួយរក្សាអត្តសញ្ញាណតំបន់ និងលើកទឹកចិត្តឱ្យមានគំនិតផ្តួចផ្តើមថ្មីៗ និងទូលំទូលាយ តាមរយៈ ការធ្វើពិពិធភាវូបនីយកម្មកម្មប្រភេទមុខទំនិញឱ្យបានច្រើន ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញការធ្វើវិក្រឹត្យការបច្ចេកទេស ចំពោះទំនិញដែលមានលក្ខណៈជាពិសេស នៅតាមតំបន់មួយចំនួន ក្នុងន័យពង្រឹងគុណភាព និងពង្រីកទីផ្សារ ដែលជាចំណុចស្នូលសម្រាប់ការលើកកម្ពស់ចលនានេះ ឱ្យមានការគាំទ្រ និងការចូលរួមកាន់តែច្រើនឡើង ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៥០៤. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងផ្តោតការយកចិត្តទុកដាក់ សម្រេចឱ្យបាននូវ ទិសដៅបួន ដូចខាងក្រោម :

១. ការបង្កើតបរិស្ថានធុរកិច្ចសមស្រប សម្រាប់ការរីកលូតលាស់នៃវិស័យឧស្សាហកម្មកម្មន្តសាល ។

២. ការជួយគាំទ្រលើកស្ទួយ សហគ្រាសធុនតូចនិងមធ្យម និង ការអភិវឌ្ឍធុរកិច្ច ។

៣. ការអភិវឌ្ឍវិស័យឯកជន និង ការលើកទឹកចិត្តដល់ការវិនិយោគ ។

៤. ការកសាងធនធានមនុស្ស និង ការផ្ទេរបច្ចេកវិទ្យា ។

៥០៥. ទិសដៅទាំងនេះ នឹងអាចសម្រេចបាន តាមរយៈ ការអនុវត្តកម្មវិធី ប្រាំបី ដូចខាងក្រោម :

*កម្មវិធីទី១* : ពង្រឹងស្ថាប័នកិច្ច និងធ្វើឱ្យប្រសើរឡើង គុណភាពនិងប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ ។

*កម្មវិធីទី២* : ពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអនុវត្ត *ច្បាប់គ្រប់គ្រងរោងចក្រ-សិប្បកម្ម* ។

*កម្មវិធីទី៣* : ពង្រឹងភាពជាដៃគូជាមួយ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ។

*កម្មវិធីទី៤* : រៀបចំគោលនយោបាយនានា សម្រាប់គាំទ្រដល់ឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម ។

*កម្មវិធីទី៥* : ជំរុញរៀបចំឱ្យផលិតផលជាតិ អនុលោមតាមស្តង់ដារជាតិនិងអន្តរជាតិ ។

*កម្មវិធីទី៦* : ជំរុញលើកកម្ពស់ ផលិតភាពនិងសមត្ថភាព របស់ឧស្សាហករនិងសិប្បករកម្ពុជា ។

*កម្មវិធីទី៧* : បង្កើតនិងអនុវត្តគោលនយោបាយពង្រឹងការងារកម្មសិទ្ធិឧស្សាហកម្ម ។

កម្មវិធីទី៨ : បង្កើតនិងអនុវត្តគោលនយោបាយពង្រឹងការងារមាត្រាសាស្ត្រ ។

៥០៦. នៅក្នុង *កម្មវិធីទី១ - ពង្រឹងសមត្ថភាពស្ថាប័ននិងធ្វើឱ្យប្រសើរឡើងនូវ គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពខាងក្រោម ដែលផ្តោតលើ :

- ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងនិងបែងចែកព័ត៌មាន និងការពង្រឹងសមត្ថភាពលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ។
- ពង្រឹងសមត្ថភាពមន្ត្រីរបស់អគ្គនាយកដ្ឋានឧស្សាហកម្ម ដោយរៀបចំការបណ្តុះបណ្តាលផ្សេងៗ ។
- ពិនិត្យមើលឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវ នីតិវិធីនិងបែបបទបញ្ញត្តិកម្មផ្សេងៗ សម្រាប់វិស័យឧស្សាហកម្ម សំដៅពង្រឹង គុណភាពនិងប្រសិទ្ធភាព នៃការអនុវត្ត*ច្បាប់គ្រប់គ្រងរោងចក្រ-សិប្បកម្ម* ។
- ជំរុញឱ្យមានការអនុវត្តល្អប្រសើរ ក្នុងការងារបញ្ញត្តិកម្ម វិស័យឧស្សាហកម្ម និងកម្មន្តសាល ។
- ពង្រឹងស្ថាប័នកិច្ច និងលើកកម្ពស់សមត្ថភាពរបស់មណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ដើម្បីធ្វើការវិភាគ សិក្សា ស្រាវជ្រាវ និង ជំរុញការលើកកម្ពស់គុណភាពផលិតផល ។
- ពង្រឹងវិទ្យាស្ថានស្តង់ដារកម្ពុជា ដើម្បីបង្កើតស្តង់ដារជាតិ សម្រាប់ជាមូលដ្ឋានក្នុងការចេញ វិញ្ញាបនបត្របញ្ជាក់ផលិតផល សំដៅលើកកម្ពស់គុណភាពផលិតផល និងជំរុញការនាំចេញ ។

៥០៧. ក្នុង*កម្មវិធីទី២ - ពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអនុវត្តច្បាប់គ្រប់គ្រងរោងចក្រ-សិប្បកម្ម - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- ពិនិត្យពិតម្រូវការ និងបង្កើត នូវលិខិតបទដ្ឋាន គោលការណ៍ណែនាំ និងនីតិវិធី ចាំបាច់ៗ ដើម្បីពង្រឹងការអនុវត្តច្បាប់ ។
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយ ច្បាប់ និងលិខិតបទដ្ឋាន បញ្ញត្តិកម្ម ផ្សេងៗ ។
- ពង្រឹងការគ្រប់គ្រងកិច្ចសន្យាសម្បទានរោងចក្រ ។
- ពង្រឹងការងារអធិការកិច្ច និងការតាមដានត្រួតពិនិត្យ អនុលោមតាម ច្បាប់សហគ្រាសឧស្សាហកម្មនិងកម្មន្តសាល ។
- ផ្សព្វផ្សាយ អំពីការអនុវត្តបញ្ញត្តិកម្ម លើវិស័យឧស្សាហកម្ម ។

៥០៨. ក្នុង*កម្មវិធីទី៣ -ពង្រឹងភាពជាដៃគូជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍន៍ - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ដែលផ្តោតជាពិសេសលើ៖

- ការពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងអនុវត្តសកម្មភាពដែលមាននៅក្នុងក្របខ័ណ្ឌ*វេទិកាសាធារណៈរវាង រាជរដ្ឋាភិបាលកម្ពុជា និងផ្នែកឯកជន* ។
- ការពង្រឹងការអនុវត្តតួនាទីរបស់ *អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម* ។
- ការសម្របសម្រួល និងតម្រង់ទិសសកម្មភាព ដៃគូអភិវឌ្ឍន៍ផ្សេងៗ ក្នុងវិស័យឧស្សាហកម្មកម្មន្តសាល ។

៥០៩. ក្នុង*កម្មវិធីទី៤ -រៀបចំគោលនយោបាយនានា សម្រាប់គាំទ្រដល់ឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- ការតាមដានត្រួតពិនិត្យ និងលើកវិធានការសមស្រប សម្រាប់ការកែលម្អ វិធានការសារពើពន្ធនិងមិនមែនសារពើពន្ធផ្សេងៗ សម្រាប់ទ្រទ្រង់វិស័យឧស្សាហកម្ម ដែលមានអាទិភាព ។
- រៀបចំលិខិតបទដ្ឋានដែលចាំបាច់ សម្រាប់អនុវត្តការលើកទឹកចិត្តដល់ការវិនិយោគ ក្នុងវិស័យឧស្សាហកម្មអាទិភាព ។

៥១០. ក្នុង*កម្មវិធីទី៥ - ជំរុញរៀបចំ ឱ្យផលិតផលជាតិ អនុលោមតាមស្តង់ដារជាតិ និងអន្តរជាតិ - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូច ខាងក្រោម :

- រៀបចំបង្កើតស្តង់ដារផលិតផលចាំបាច់ ដើម្បីជាបង្អែកក្នុងការលើកកម្ពស់គុណភាពផលិតផលជាតិ ។
- ផ្សព្វផ្សាយអំពីសារៈសំខាន់នៃ ស្តង់ដារជាតិនិងអន្តរជាតិ និងជំរុញឱ្យឧស្សាហករកម្ពុជា ទទួលអនុវត្តតាមដើម្បីធានាគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួន ។
- ពង្រឹងរចនាសម្ព័ន្ធវាយតម្លៃគុណភាព ដោយអនុលោមតាមស្តង់ដារ ដើម្បីជាមូលដ្ឋានបង្អែកសម្រាប់ការនាំចេញផលិតផលជាតិ ។
- ផ្តល់ការពិគ្រោះយោបល់ជាមួយឧស្សាហករពាក់ព័ន្ធ អំពីការអនុលោមតាមស្តង់ដារជាតិ និងអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ។
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គភាពស្តង់ដារជាតិ តំបន់ និងអន្តរជាតិ ។

៥១១. ក្នុង*កម្មវិធីទី៦ - ជំរុញលើកកម្ពស់ផលិតភាព និងសមត្ថភាពរបស់ឧស្សាហករ និងសិប្បករកម្ពុជា - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូច ខាងក្រោម :

- បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដើម្បី ជំរុញលើកកម្ពស់ បច្ចេកទេស និងបច្ចេកវិទ្យា ។
- ផ្សព្វផ្សាយផលិតភាព និងបច្ចេកទេស ។
- ជំរុញការបណ្តុះបណ្តាល ស្តីពី ផលិតភាព និងបច្ចេកទេសផ្សេងៗ ដល់ឧស្សាហករ-សិប្បករ ។
- បង្កើតសេវាទីប្រឹក្សាយោបល់លើការងារផលិតភាព និងបច្ចេកទេស ។
- ពង្រឹងនិងពង្រីកការប្រើប្រាស់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍ ។

៥១២. ក្នុង*កម្មវិធីទី៧ - បង្កើតនិងអនុវត្តគោលនយោបាយពង្រឹងការងារកម្មសិទ្ធិឧស្សាហកម្ម - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- ពង្រឹង និងអនុវត្ត ការផ្តល់សេវាកម្មការពារកម្មសិទ្ធិឧស្សាហកម្ម ។
- ជំរុញនិងផ្សព្វផ្សាយ ការបណ្តុះបណ្តាល ចំណេះដឹងស្តីអំពីកម្មសិទ្ធិឧស្សាហកម្ម ។

- បង្កើតនិងពង្រឹង ការអនុវត្តនិងដំណើរការ នៃមជ្ឈមណ្ឌលច្នៃប្រឌិតនិងបង្កើតថ្មី ។
- ជំរុញសកម្មភាពការច្នៃប្រឌិត និងបង្កើតថ្មី ។
- ជំរុញនិងពង្រឹង ទំនាក់ទំនងជាមួយភ្នាក់ងារកម្មសិទ្ធិបញ្ញា និង អ្នកដាក់ពាក្យស្នើសុំផ្តល់ប្រកាសនីយបត្រ តក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង ការចុះបញ្ជីគំនូរឧស្សាហកម្ម ។
- បង្កើត និងផ្តល់សេវាទីប្រឹក្សាយោបល់លើ កម្មសិទ្ធិឧស្សាហកម្ម ។
- ការជំរុញកិច្ចសហប្រតិបត្តិការជាមួយ អង្គការជាតិនិងអន្តរជាតិ ក្នុងការអនុវត្ត កម្មសិទ្ធិឧស្សាហកម្ម ។

៥១៣. ក្នុង*កម្មវិធីទី៨ - បង្កើត និងអនុវត្តគោលនយោបាយពង្រឹងការងារមាត្រាសាស្ត្រ - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :

- បង្កើតលិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជាបច្ចេកទេស ដើម្បីគ្រប់គ្រងការអនុវត្តដំណើរការងារមាត្រ-សាស្ត្រជាតិ ។
- បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកមាត្រសាស្ត្រ រួមមាន មជ្ឈមណ្ឌលជាតិមាត្រសាស្ត្រជាតិ និងមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទាំង ៥ តំបន់។
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ការងារមាត្រសាស្ត្រ ។
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយ អង្គការមាត្រាសាស្ត្រអន្តរជាតិ និង អង្គការមាត្រាសាស្ត្រប្រចាំតំបន់ ។

## ៥.៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៥១៤. ក្នុង*នីតិកាលទី៣ នៃរដ្ឋសភា* កន្លងទៅនេះ *រាជរដ្ឋាភិបាលកម្ពុជា* សម្រេចបានជោគជ័យគួរកត់សម្គាល់ នៅក្នុងការជួយសង្គ្រោះ និងផ្តល់ការគាំទ្រយ៉ាងច្រើន ដល់ ជនអនាថា ក្រុមជនងាយរងគ្រោះជាស្ត្រីនិងកុមារ ជនអសមត្ថភាពពលកម្ម ជនរងគ្រោះដោយសារការជួញដូរ និង គ្រួសារដែលទទួលរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ ។ ប្រជាជនទាំងនេះ ត្រូវបានផ្តល់ ការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងការងារ ដើម្បីឱ្យមានមុខរបរផ្ទាល់ខ្លួន សម្រាប់ចិញ្ចឹមជីវិត ។

៥១៥. *រាជរដ្ឋាភិបាលកម្ពុជា* បានសហការជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីផ្តល់នូវកាលានុវត្តភាពការងារ និង កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ ។ ទន្ទឹមនឹងនេះ *រាជរដ្ឋាភិបាលកកម្ពុជា* បានធ្វើឱ្យប្រសើរឡើង និងពង្រឹងប្រព័ន្ធសន្តិសុខសង្គម ដល់អតីតមន្ត្រីរាជការស៊ីវិល ក៏ដូចជា អតីតយុទ្ធជន តាមរយៈ ការតម្លើងប្រាក់បៀវត្សរ៍ និងផលប្រយោជន៍ផ្សេងៗទៀត ។

៥១៦. ដើម្បីបន្តអនុវត្តគោលនយោបាយសុវត្ថិភាពសង្គម *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នឹងផ្តល់អាទិភាពលើការធ្វើឱ្យប្រសើរឡើង នូវ លក្ខខណ្ឌការងាររបស់កម្មករនិងនិយោជិត ការជំរុញការ អនុវត្ត *ច្បាប់ស្តីពី របបសន្តិសុខសង្គម* ការអនុវត្តគោលការណ៍របបសោធននិវត្តន៍សម្រាប់អ្នកបាត់បង់សមត្ថភាពពលកម្ម និងអ្នកនៅក្នុងបន្ទុក ធានានូវការការពារដល់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិការងារ និងធានាឱ្យនិយោជិតទាំងអស់ ទទួលបាលនូវការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ក្នុងការងារ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងការជួយឧបត្ថម្ភឱ្យបានដិតដល់ ចំពោះជនពិការជាអតីតយុទ្ធជន និងគ្រួសារ ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។ បន្ថែមលើនេះទៀត *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជួយគាំទ្រដល់ យោធិន និងមន្ត្រីរាជការចូលនិវត្តន៍ តាមរយៈការអនុវត្តប្រព័ន្ធសោធននិវត្តន៍មួយ ដែលស្ថិតនៅក្រោម*បេឡាជាតិសន្តិសុខសង្គម* ។ នៅក្នុងបរិការណ៍នេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងជំរុញការអនុម័ត *ច្បាប់ស្តីពី របបសន្តិសុខសង្គមទូលំទូលាយ សម្រាប់ប្រជាជនទូទៅ* និង *អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គម សម្រាប់អតីតយុទ្ធជន* ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៥១៧. បច្ចុប្បន្ននេះ ពិភពលោកទាំងមូល កំពុងតែប្រឈមមុខទៅនឹង វិបត្តិកលិយុគជាបន្តបន្ទាប់ដែលពុំធ្លាប់មានពីមុនមក ដោយមិនមែនមានតែ វិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ដែលនៅបន្តអូសបន្លាយប៉ុណ្ណោះទេ ថែមទាំងមានបញ្ហាជាច្រើនទៀតពាក់ព័ន្ធទៅនឹង បម្រែបម្រួលអាកាសធាតុ ការឡើងចុះនៃថ្លៃម្ហូបអាហារនិងថ្លៃប្រេងឥន្ធនៈ ជំងឺឆ្លងនានា ។ល។ ការវិវត្តប្រែប្រួលទាំងនេះ បានបង្កើនភាពបន្ទាន់សម្រាប់ស្ថាប័ននានារបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការដោះស្រាយនូវបញ្ហាទាក់ទងនឹងការគាំពារសង្គម តាមរយៈ វិធីសាស្ត្រមួយដែលមានការសម្របសម្រួលគ្នាច្រើនជាងមុន ក្នុងគោលបំណង ថែរក្សានូវសមិទ្ធផលសំខាន់ៗ ដែលទទួលបានពីការកាត់បន្ថយភាពក្រីក្រក្នុងទសវត្សរ៍កន្លងមក ហើយ ដើម្បីធានាថា បណ្តាញសុវត្ថិភាពសង្គម ត្រូវបានដាក់ឱ្យដំណើរការសម្រាប់គាំទ្រដល់ពលករទាំងឡាយ (អ្នកដែលចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិ) ទាំងនៅក្នុងពេលបំពេញការងារ និង នៅពេលដែលចូលនិវត្តន៍ ។

៥១៨. *រាជរដ្ឋាភិបាលកម្ពុជា* នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបង្កើតនិងអនុវត្ត ប្រព័ន្ធសុវត្ថិភាពសង្គមមួយដែលមានលក្ខណៈទូលំទូលាយ មានចីរភាព ក្នុងគោលបំណង គាំពារដល់ជីវភាពរស់នៅរបស់ជនក្រីក្រ និងជនងាយរងគ្រោះ ។ *ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ* បានបោះជំហានយ៉ាងសំខាន់មួយ ក្នុងការបង្កើតបាននូវការឯកភាពលើទស្សនទានសំខាន់ៗ និងទិសដៅទូលំទូលាយ ដើម្បីបង្កើត *គោលនយោបាយស្តីពី បណ្តាញសុវត្ថិភាពសង្គម* សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដោយមានកិច្ចសហការ ជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ។ របកគំហើញនិងអនុសាសន៍ទាំងឡាយ ដែលផ្អែកលើការពិគ្រោះយោបល់ទាំងនេះ ត្រូវបានបង្ហាញនៅក្នុង*វេទិកាជាតិស្តីពី សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ* ក្រោមប្រធានបទ *ប្រព័ន្ធសុវត្ថិភាពសង្គមនៅកម្ពុជា* កាល

ពីថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ២០០៩ ហើយនឹង ត្រូវបានដាក់បញ្ចូលទៅក្នុង *ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី ប្រព័ន្ធគាំពារសង្គម សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ* ។ បច្ចុប្បន្ននេះ *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តល់អាណត្តិការងារដល់ *ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ* ដើម្បី បង្កើតយន្តការសម្របសម្រួលអន្តរក្រសួង តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តកិច្ចអន្តរាគមន៍ប្រព័ន្ធសុវត្ថិភាពសង្គម សំដៅពង្រឹងស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ របស់ជនក្រីក្រ និងជនងាយរងគ្រោះ ។

៥១៩. ដើម្បីសម្រេចបាននូវភារកិច្ចដ៏សំខាន់នេះ *ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ* នឹងធានាឱ្យមានការរៀបចំផែនការសម្រាប់អនុវត្ត *វិធានការគាំពារសង្គម* ដែលមានគោលការណ៍ ដូចខាងក្រោម :

- ជាមួយនឹង ស្ថានភាពមានកម្រិតនៃធនធាន និងតម្រូវការមានទំហំច្រើនលើសពីប្រភពធនធានដែលអាចមានការផ្តល់នូវវិធានការគាំពារសង្គម ដែលផ្តល់នូវជំនួយសង្គ្រោះបន្ទាន់ ហើយថែមទាំងចូលរួមចំណែកដល់ការកសាងសមត្ថភាពរបស់ប្រជាពលរដ្ឋដែលជាអ្នកទទួលផល ដើម្បីចូលរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍របស់ពួកគាត់ - កម្មវិធីស្បៀងពលកម្ម ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលជួយឱ្យប្រជាពលរដ្ឋជាអ្នកទទួលផល អាចមានលទ្ធភាពទទួលបាន សេវាអប់រំនិងសុខាភិបាលច្រើនជាងមុន និងមានភាពងាយស្រួលជាងមុនក្នុងការដឹកជញ្ជូនផលិតផលរបស់ពួកគាត់ទៅដល់ទីផ្សារ - កម្មវិធីមូលនិធិសមធម៌ដើម្បីសុខភាព ដែលផ្តល់ការជួយសង្គ្រោះតាមរយៈការផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃ - កម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំដើម្បីកសាងមូលដ្ឋានជំនាញ - និង ការបែងចែកមធ្យោបាយផលិតកម្មកសិកម្ម (ពូជ ជី សេវាកម្មផ្សព្វផ្សាយ) ដែលតម្រង់ទិសទៅរកប្រជាកសិករដែលមានដីតិចតួច ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងបង្កើតចំណូលបន្ថែម - គឺជាឧទាហរណ៍គំរូ ដែលកំពុងត្រូវបានអនុវត្តដោយក្រសួង-ស្ថាប័នរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ហើយ ការងារទាំងនេះ ចាំបាច់ត្រូវតែពង្រឹងថែមទៀត ជាពិសេស ការគាំទ្រដល់កសិករដែលមានដីតិចតួច ។
- ដើម្បីធានាឱ្យមានតម្លាភាពនិងការកំណត់គោលដៅឱ្យបានប្រសើរជាងមុន ក្នុងការផ្ទេរសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់*រាជរដ្ឋាភិបាល* នឹងត្រូវបានលើកទឹកចិត្ត ឱ្យប្រើប្រាស់ទិន្នន័យ របស់ *ប្រព័ន្ធអត្តសញ្ញាណកម្មជាតិសម្រាប់គ្រួសារក្រីក្រ* ដែលកំពុងត្រូវបានគាំទ្រដោយ *កម្មវិធីអត្តសញ្ញាណគ្រួសារក្រីក្រ* របស់ក្រសួងផែនការ ។ នៅចុងឆ្នាំ២០០៩ ទិន្នន័យសម្រាប់ភូមិជាង ៧ ៣៤៥ភូមិ អាចទទួលបានពីប្រព័ន្ធនេះ ។ *កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ* នឹងពង្រីកការគ្របដណ្តប់របស់ខ្លួនឱ្យបាននៅទូទាំងប្រទេស និងធ្វើបច្ចុប្បន្នកម្មតាមពេល ដើម្បីរក្សានូវប្រភពទិន្នន័យដែលអាចជឿទុកចិត្តបានសម្រាប់ការកំណត់គោលដៅអន្តរាគមន៍ផ្នែកប្រព័ន្ធសុវត្ថិភាពសង្គមដល់គ្រួសារក្រីក្រ ។ នាពេលបច្ចុប្បន្ននេះ *កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ* គ្របដណ្តប់តែនៅតំបន់ជនបទប៉ុណ្ណោះ ហើយ វិធីសាស្ត្រមួយសម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតំបន់ទីប្រជុំជន នឹងត្រូវបង្កើតឡើង ។

- លើកកម្ពស់ការសម្របសម្រួលអន្តរវិស័យ និងច្របាច់បញ្ចូលវិធានការគាំពារសង្គមជាមួយដំណើរការរៀបចំផែនការអភិវឌ្ឍន៍តាមបែបវិមជ្ឈការ នៅថ្នាក់ក្រោមជាតិ ។
- កាត់បន្ថយឱ្យនៅកម្រិតទាបបំផុត នូវចំណាយក្នុងការរៀបចំផែនការ និងការអនុវត្ត (ការចំណាយហួសកំណត់) នៃកម្មវិធីបណ្តាញសុវត្ថិភាពសង្គម ដើម្បីសម្រេចបានជាអតិបរមានូវការផ្ទេរធនធាន ទៅដល់ប្រជាពលរដ្ឋអ្នកទទួលផល ។

៥២០. បច្ចុប្បន្ននេះ ស្ថាប័នរាជរដ្ឋាភិបាលមួយចំនួន កំពុងផ្តល់កម្មវិធីគាំពារសង្គម និងបណ្តាញសុវត្ថិភាពសង្គម ដើម្បីជួយដល់ បុគ្គល គ្រួសារ និងសហគមន៍ នានា ក្នុងការគ្រប់គ្រងឱ្យបានប្រសើរជាងមុននូវហានិភ័យ ការភ័យខ្លាច និងភាពក្រីក្រធ្ងន់ធ្ងរ ។ *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី* សុទ្ធតែបានទទួលភារកិច្ច ដើម្បីផ្តល់នូវសេវាសង្គមដល់ប្រជាពលរដ្ឋ និងការពារដល់ក្រុមជនងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យ ទាំងឡាយ ។ ការធ្វើអន្តរាគមន៍ដោយឡែក នៃបណ្តាញសុវត្ថិភាពសង្គម ត្រូវបានអនុវត្តដោយក្រសួង-ស្ថាប័នផ្សេងទៀតរបស់*រាជរដ្ឋាភិបាលកម្ពុជា* ឧទាហរណ៍ *ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* កំពុងតែផ្តល់កម្មវិធីមួយចំនួន ដើម្បីដោះស្រាយប្រភពសំខាន់ៗនៃភាពងាយរងគ្រោះ តាមរយៈ ការផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃ កម្មវិធីអាហារូបករណ៍ និងការលើកលែងពន្ធអាករ ដែលកម្មវិធីទាំងនេះ បានជួយទៅដល់គ្រួសារនានា ក្នុងការដោះស្រាយ បាននូវការចំណាយផ្នែកសុខភាព និងមានលទ្ធភាពបញ្ជូនកូនចៅរបស់ពួកគាត់ឱ្យទៅរៀន ។ អន្តរាគមន៍បណ្តាញសុវត្ថិភាពសង្គមមួយចំនួនទៀត រួមមាន ការចែកស្បៀងអាហារ ការងារសាធារណៈ ដែលប្រើប្រាស់ស្បៀងពលកម្ម និងការផ្តល់ដល់ក្រុមគោលដៅ ។

៥២១. កម្មវិធីទាំងឡាយរបស់*ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* ផ្តោតការយកចិត្តទុកដាក់ លើការកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកក្រ ការជួយដល់ក្រុមជនដែលគេបោះបង់ ការផ្តល់ការគាំទ្រទាំងសម្ភារៈ និងស្មារតី និង ការពង្រឹងនិងបង្កើតប្រព័ន្ធសន្តិសុខសង្គម ។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងគោលបំណង ពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងការគាំពារសង្គម ការងាររបស់ក្រសួង នឹងត្រូវផ្តោតទៅលើវិស័យ ៦ ដូចខាងក្រោម :

**អាទិភាពទី១ : ពង្រឹងនិងពង្រីកសេវាជំនួយសង្គមកិច្ចសម្រាប់អ្នកក្រីក្រដែលងាយរងគ្រោះ**

- បន្តពង្រីកកម្មវិធីសង្គ្រោះបន្ទាន់ ដើម្បីផ្តល់ជំនួយទៅដល់ជនក្រីក្រ និងជនងាយរងគ្រោះ ។
- ពង្រឹងសកម្មភាពផ្សេងៗ ដើម្បីដោះស្រាយបញ្ហាជនគ្មានផ្ទះសម្បែង ដោយបន្តអនុវត្តយុទ្ធសាស្ត្រ ៩ចំណុច និងយន្តការដែលមានស្រាប់ ឱ្យមានប្រសិទ្ធភាព ។

- បន្តប្រឆាំងការជួញដូរមនុស្ស និងជំរុញឱ្យមានការស្តារលទ្ធភាពពលកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ដោយផ្តល់នូវការគាំទ្រផ្នែកនីតិសម្បទាឱ្យបានប្រសើរជាងមុន និងតាក់តែងច្បាប់ដើម្បីការពារសិទ្ធិរបស់អ្នករងគ្រោះដោយសារការជួញដូរមនុស្ស និងពង្រឹងមជ្ឈមណ្ឌលសង្គមកិច្ច ដើម្បីធានាការផ្តល់សេវាល្អគ្រប់គ្រាន់ដល់ជនរងគ្រោះ ។
- ពង្រឹងនិងពង្រីកចលនាគ្រួសារល្អ លើកកម្ពស់តួនាទីរបស់គ្រួសារ និងប្រជាជន ក្នុងការអភិវឌ្ឍសង្គម និងបន្តរៀបចំទិវាគ្រួសារអន្តរជាតិ ១៥ ឧសភា ជារៀងរាល់ឆ្នាំ ។
- បង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការផ្តល់សេវាសង្គមកិច្ច ដល់គ្រួសារដែលមានស្ត្រី និងកុមារ ទទួលរងគ្រោះដោយមេរោគអេដស៍/ជំងឺអេដស៍ ។

**អាទិភាពទី២ : ពង្រឹងនិងពង្រីកសេវាជំនួយដល់កុមារនិងសេវានីតិសម្បទាសម្រាប់យុវជន**

- ពង្រឹងនិងពង្រីកការអនុវត្តសិទ្ធិជាមូលដ្ឋានទាំង ៤ របស់កុមារ ដោយប្រមូលផ្តុំកម្លាំង ដើម្បីដោះស្រាយបញ្ហាកុមារកំព្រា កុមារពិការ និងកុមារពីគ្រួសារក្រីក្រ ។
- បន្តអនុវត្ត *គោលនយោបាយថែទាំជំនួស* ចំពោះកុមារ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារតាមមណ្ឌល ។ ពង្រឹងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំង បង្កើនប្រសិទ្ធភាពក្នុងការថែទាំកុមារ ។
- ពង្រឹងការងារសុំកូនក្នុងប្រទេស និងអន្តរប្រទេស ។
- ជំរុញឱ្យមានការអនុម័ត *ច្បាប់ស្តីពីសិទ្ធិកុមារ* និង អនុវត្ត *ច្បាប់ស្តីពីសុំកូនអន្តរប្រទេស* ។
- ពង្រឹងនិងពង្រីកសកម្មភាពរបស់ *ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និង* បណ្តាញការពារកុមារនៅតាមសហគមន៍ ។
- បំផុសចលនា ***បីល្អ*** សម្រាប់កុមារ គឺ *កូនល្អ សិស្សល្អ មិត្តល្អ* និងរៀបចំ *ទិវាកុមារអន្តរជាតិ ១ មិថុនា* ជារៀងរាល់ឆ្នាំ ។
- ពង្រឹងនិងពង្រីក *កម្មវិធីអប់រំស្តីពីសីលធម៌ និងភាពស្អាតស្អំ* ដើម្បីបង្ការទប់ស្កាត់ អំពើហិង្សា ឧក្រិដ្ឋកម្ម និងការរំលោភបំពាន ក្នុងចំណោមយុវជននិងកុមារ ។
- ពង្រឹងនិងពង្រីក មជ្ឈមណ្ឌលយុវនីតិសម្បទា ។
- ជំរុញការការពារសិទ្ធិរបស់កុមារ ស្របទៅតាម*អនុសញ្ញាស្តីពីសិទ្ធិកុមារ* នៅក្នុងប្រព័ន្ធយុត្តិធម៌និងតុលាការ ។
- លើកទឹកចិត្តដល់ការធ្វើ សកម្មភាពកីឡា ការបោះជំរំ ដំណើរទស្សនកិច្ចសិក្សា សម្រាប់កុមារនិងយុវជន ។
- ជំរុញការតស៊ូមតិក្នុងការបញ្ចូលនូវ តម្រូវការរបស់កុមារនិងយុវជន ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ នៅគ្រប់កម្រិត ។

- ជំរុញឱ្យមានការអនុម័ត*ច្បាប់ស្តីពីយុត្តិធម៌អនីតិជន* ។
- សម្របសម្រួលការរៀបចំនិងការអនុវត្ត*យុទ្ធសាស្ត្រពហុវិស័យសម្រាប់ កុមារកំព្រានិងកុមារងាយរងគ្រោះ* ។

**អាទិភាពទី៣ : ពង្រឹងនិងពង្រីកសេវាជំនួយនិងសេវានីតិសម្បទាសម្រាប់ជនពិការ**

- អនុវត្តគោលនយោបាយសម្រាប់ជនពិការ ជំរុញការអនុវត្ត*ច្បាប់ស្តីពី កិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ* និង ជំរុញការអនុវត្ត*អនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិជនពិការ* ។
- បន្តធ្វើឱ្យមានស្ថិរភាព សេវានីតិសម្បទា សម្រាប់ជនពិការ ។
- បន្តពង្រឹងសេវាបណ្តុះបណ្តាលភាសាសញ្ញាសម្រាប់មនុស្សគរ និងអក្សរស្ទាបសម្រាប់មនុស្សខ្វាក់ និង ជំរុញការផ្តល់សេវាទាំងនេះ តាមរយៈ ប្រព័ន្ធបច្ចេកវិទ្យា ។
- ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតការងារ និងការផ្តល់សេវាសហគមន៍ ក៏ដូចជា ការលើកទឹកចិត្តឱ្យមានការជួយខ្លួនឯងសម្រាប់ជនពិការ ។
- ពង្រឹងនិងពង្រីក ចលនាកីឡា ការរៀបចំទិវាកីឡា និងទិវាអន្តរជាតិនានា សម្រាប់ជនពិការ និង បញ្ចូលតម្រូវការរបស់ជនពិការ ទៅក្នុងផែនការអភិវឌ្ឍន៍ នៅគ្រប់កម្រិត ។
- បន្តលើកកម្ពស់ការយល់ដឹងពីពិការភាព ក្នុងចំណោមគ្រួសារជនពិការ សហគមន៍ និយោជិត និងភ្នាក់ងារមានសមត្ថភាព ដើម្បីកាត់បន្ថយការរើសអើងចំពោះជនពិការ និង បន្តបង្កើតបរិស្ថានសមស្របមួយសម្រាប់ជនពិការនៅគ្រប់ថ្នាក់ សំដៅធានាឱ្យមាននូវសេវាម្ដែលមានគុណភាព និង កាត់បន្ថយផលវិបាកផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ ដែលអាចកើតមាន ។

**អាទិភាពទី៤ : ពង្រឹងនិងពង្រីកប្រព័ន្ធសន្តិសុខសង្គមនិងសេវាជំនួយ សម្រាប់ជនចាស់ជរា មន្ត្រីរាជការ និងប្រជាពលរដ្ឋទូទៅ**

- ពង្រឹងការបើកផ្តល់របបសោធនសម្រាប់អតីតមន្ត្រីរាជការ និង ពង្រីកផែនការសោធន ឱ្យសមស្របទៅនឹងលទ្ធភាពថវិកាជាតិ ។
- ពង្រឹងការអនុវត្ត*មូលនិធិជាតិសម្រាប់សន្តិសុខសង្គម*ដល់មន្ត្រីរាជការ ។
- ធ្វើការស្រាវជ្រាវ និងបង្កើត *ប្រព័ន្ធសន្តិសុខសង្គម សម្រាប់ប្រជាពលរដ្ឋទូទៅ* ។
- រៀបចំ*ច្បាប់ស្តីពី របបសន្តិសុខសង្គមទូលំទូលាយ សម្រាប់ប្រជាពលរដ្ឋទូទៅ* ។
- ជំរុញការបង្កើត*សមាគមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងសមាគមចាស់ជរានៅក្នុងសហគមន៍* ។ លើកទឹកចិត្តដល់គ្រួសារនិងសហគមន៍ ឱ្យជួយគាំទ្រដល់ជនចាស់ជរា ដែលគ្មានទីពឹងពាក់ ។ ផ្តល់សេវាគាំទ្រដល់ជនចាស់ជរា និង រៀបចំ*ទិវាមនុស្សចាស់អន្តរជាតិ ១ តុលា* ជារៀងរាល់ឆ្នាំ ។

**អាទិភាពទី៥ : ពង្រឹងនិងពង្រីកប្រព័ន្ធសន្តិសុខសង្គមនិងសេវាជំនួយសម្រាប់អតីតយុទ្ធជន**

- បន្តអនុវត្តគោលនយោបាយជាតិសម្រាប់អតីតយុទ្ធជន ដោយទទួលស្គាល់ស្នាដៃល្អរបស់ពួកគាត់ដែលបានពលីសម្រាប់ប្រទេសជាតិ ។
- បន្តជំរុញការធ្វើកំណែទម្រង់ក្នុងការគ្រប់គ្រង ការបើកផ្តល់ប្រាក់បៀវត្សរ៍ជូនដល់អតីតយុទ្ធជន ឱ្យកាន់តែមានប្រសិទ្ធភាព ជាងមុន ។
- រៀបចំ *ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន* និង *អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន* ។
- រៀបចំបង្កើតភូមិអតីតយុទ្ធជន ដោយប្រើរូបភាពភូមិគំរូសម្រាប់យុទ្ធជនពិការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។
- ពង្រឹងដំណើរការរបស់សមាគមអតីតយុទ្ធជនកម្ពុជា ។
- ជំរុញចលនា ***បីល្អ*** របស់អតីតយុទ្ធជន គឺ *ការប្រើប្រាស់របបគោលនយោបាយល្អ កសាងជីវភាពគ្រួសារល្អ* និង *ការចូលរួមអភិវឌ្ឍមូលដ្ឋានល្អ* ។

**អាទិភាពទី៦ : ពង្រឹងនិងពង្រីក សមត្ថភាពស្ថាប័ន ភាពជាដៃគូ និងសមត្ថភាពកៀរគរមូលនិធិ ដើម្បីបង្កើនប្រសិទ្ធភាពនៃសេវាសង្គម**

- ពង្រឹងរដ្ឋបាលសង្គមកិច្ច ឱ្យមានប្រសិទ្ធភាព និង គុណភាពក្នុងការផ្តល់សេវាសង្គមកិច្ច ។
- ពង្រឹងអភិបាលកិច្ចល្អ និងបង្កើនប្រសិទ្ធភាពបទបញ្ជាផ្ទៃក្នុងនៃការងារ និង ជំរុញការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ស្របទៅតាម *ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល* និងគោលការណ៍របស់កំណែទម្រង់រដ្ឋបាលសាធារណៈ ។
- បន្តការលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ តាមរយៈ ការបណ្តុះបណ្តាល ការបង្កើតវិទ្យាស្ថានជាតិ-សង្គមកិច្ច និងលើកកម្ពស់សមត្ថភាពស្ត្រីនៅក្នុងការងារ និង គាំទ្រការសម្រេចចិត្តរបស់ពួកគាត់ ។
- បង្កើតប្រព័ន្ធស្ថិតិសម្រាប់វិស័យសង្គមកិច្ច ដោយផ្អែកលើអាទិភាពទាំង ៦ ដែលកំណត់ដោយក្រសួង ។
- ជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងផ្សព្វផ្សាយព័ត៌មានពីសមិទ្ធផលនៃសកម្មភាពការងារ ។
- បន្តអនុវត្តកំណែទម្រង់គោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈ ការផ្ទេរសិទ្ធិអំណាចជាជំហានៗ ពីក្រសួងទៅថ្នាក់ក្រោមជាតិ និងការដាក់បញ្ចូលការងារសង្គមកិច្ច ទៅក្នុងផែនការអភិវឌ្ឍន៍នៅគ្រប់កម្រិត ។
- ពង្រឹងការអនុវត្ត *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ។
- ពង្រឹងភាពជាដៃគូជាមួយ អង្គការក្រៅរដ្ឋាភិបាល អង្គការមនុស្សធម៌ជាតិនិងអន្តរជាតិ ព្រមទាំង សប្បុរសជនផ្សេងៗទៀត ដើម្បីរិះរកការគាំទ្រផ្នែក បច្ចេកទេស សំភារៈ និងហិរញ្ញវត្ថុ សម្រាប់ការផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះ និង ក្រុមងាយរងគ្រោះក្នុងសង្គម ។ ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ អន្តរជាតិទ្វេនិងពហុភាគី និង អំពាវនាវរកការគាំទ្រ និងការចូលរួមពីដៃគូអភិវឌ្ឍន៍ក្នុងវិស័យសង្គមកិច្ច ។

៥២២. *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* អនុវត្ត *បេឡាជាតិសន្តិសុខសង្គម* សម្រាប់កម្មករ/និយោជិត ដែលត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ២០០៨ ។ មូលនិធិនេះ ផ្តល់ដល់និយោជិតក្នុងវិស័យឯកជននូវ *កិច្ចការពារការរងគ្រោះរបស់និយោជិត* (ការផ្តល់ប្រាក់សំណងដល់កម្មករ-អ្នកធ្វើការ) *ការធានារ៉ាប់រងផ្នែកសុខភាព* និង *ការបង់ថ្លៃសម្រាប់ការចូលនិវត្តន៍* ។ *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* នឹងបន្តពង្រឹងនិងពង្រីកបន្ថែមទៀតនូវវិសាលភាពនៃការអនុវត្តរបស់ផ្នែកទាំងបីនេះ ។ *គម្រោងកិច្ចការពារការរងគ្រោះរបស់និយោជិត* ត្រូវបានចាប់ផ្តើម នៅខែធ្នូ ឆ្នាំ២០០៨ ក៏ប៉ុន្តែ *គម្រោងការធានារ៉ាប់រងផ្នែកសុខភាព* គ្រោងនឹងចាប់ផ្តើម នៅឆ្នាំ២០១០ ហើយ *គម្រោងការបង់ថ្លៃសម្រាប់ការចូលនិវត្តន៍* គ្រោងនឹងចាប់ផ្តើម នៅឆ្នាំ២០១២ ។ រាល់ក្រុមហ៊ុនទាំងអស់ដែលមាននិយោជិតចាប់ពី ៨នាក់ ឡើងទៅ ត្រូវបានតម្រូវឱ្យចូលរួម ក្នុងផែនការនេះ ។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០០៩ *បេឡាជាតិសន្តិសុខសង្គម* បានចុះឈ្មោះក្រុមហ៊ុន ប្រមាណ ៤០០ នៅក្នុង *គម្រោងកិច្ចការពារការរងគ្រោះរបស់និយោជិត* ដែលក្នុងនោះ រោងចក្រប្រមាណ ២៥០ ជារោងចក្រកាត់ដេរ ដែលមាននិយោជិតសរុបប្រមាណ ៣០០ ០០០នាក់ ។ និយោជកដែលចូលរួមក្នុងមូលនិធិនេះ ត្រូវបានតម្រូវឱ្យបង់ប្រាក់វិភាគទានប្រចាំខែ ដែលស្មើនឹង ០,៨ភាគរយ នៃប្រាក់បៀវត្សរ៍របស់និយោជិត ។ ផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះ គឺ មួយផ្នែកជាប្រាក់សុទ្ធ និង មួយផ្នែកទៀតជាសម្ភារ ។ និយោជិតដែលត្រូវបានបញ្ចូលទៅក្នុងគម្រោងនេះ នឹងទទួលបានជំនួយពេញលេញសម្រាប់តម្លៃនៃការព្យាបាលរបស់ពេទ្យ ដោយបូកបញ្ចូលថែម ៧០ភាគរយ នៃប្រាក់បៀវត្សរ៍ដើម្បីបំពេញឱ្យទៅប្រាក់ចំណូល ដែលបានបាត់បង់ ក្នុងពេលដែលសម្រាកព្យាបាល ។

## ៦. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

៥២៣. មុំទាំងបួនរបស់ សមាសភាគមួយនេះនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* បង្ហាញពីការកិច្ចការសំខាន់ៗ ដែលត្រូវដោះស្រាយ រួមមាន : (១) *ការពង្រឹងគុណភាពវិស័យអប់រំ* (២) *ការលើកកម្ពស់សេវាសុខាភិបាល* (៣) *ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ* (៤) *ការអនុវត្តគោលនយោបាយជាតិប្រជាជន* ។

### ៦.១ ការពង្រឹងគុណភាពវិស័យអប់រំ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៥២៤. *រាជរដ្ឋាភិបាលកម្ពុជា* សម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្តយុទ្ធសាស្ត្រ *"អប់រំសម្រាប់ទាំងអស់គ្នា"* តាមរយៈ ការធានាសមធម៌ ក្នុងការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ សម្រាប់កុមារគ្រប់រូប ។ សមិទ្ធផលសំខាន់ៗ រួមមាន ចំនួនសាលារៀន និងគ្រូបង្រៀន ព្រមទាំងអត្រាចុះឈ្មោះចូលរៀននៅគ្រប់កម្រិត សិក្សានៃចំណេះទូទៅ បានកើនឡើងជាលំដាប់ ពិសេស នៅតាមតំបន់ជនបទ ។ ដោយឡែក អនុវិទ្យាល័យ ត្រូវបានបង្កើត

ឡើងនៅ ស្ទើរគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស ។ ចំនួនគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស និងគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំង ចំនួនបុគ្គលិកបង្រៀន ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ដែរ ។ ទន្ទឹមនឹងនេះ *រាជរដ្ឋាភិបាលកម្ពុជា* បាន បង្កើនថវិកាយ៉ាងច្រើន សម្រាប់វិស័យអប់រំ ។ ក្នុងនីតិកាលទី៣ កន្លងទៅនេះ ថវិកាចំណាយចរន្តសម្រាប់វិស័យអប់រំ បានកើនឡើងទ្វេដង ក្នុងឆ្នាំ២០០៧ ធៀបទៅនឹង ឆ្នាំ២០០៣ បើគិតជាភាគរយនៃថវិកាចរន្តសរុប ថវិកាចរន្ត សម្រាប់វិស័យអប់រំមានប្រមាណ ១៩,២ភាគរយ ។ រាជរដ្ឋាភិបាលសម្រេចបានជោគជ័យគួរជាទីមោទនៈ ក្នុងការ លើកកម្ពស់ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យអប់រំនេះ រួមទាំង ដៃគូផ្លូវការ វិស័យឯកជន និង អង្គការក្រៅរដ្ឋាភិបាល ។

៥២៥. ក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្ត *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ* ដោយ ផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារនិងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើម កំណើត និងឋានៈ នៅក្នុងសង្គមឡើយ ។ម្យ៉ាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់ នឹង ការអប់រំ វប្បធម៌ សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ កុមារនិងស្ត្រី និងការរើសអើងគ្រប់ប្រភេទ ក្នុងសង្គម ។

៥២៦. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តយកចិត្តទុកដាក់លើ ការកែលម្អគុណភាពអប់រំ តាមរយៈ ការលើកទឹកចិត្តគ្រូ បង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែ ការបណ្តុះបណ្តាលគ្រូបង្រៀន និងបំប៉នវិធីសាស្ត្របង្រៀន ព្រមទាំងការកែលម្អលក្ខខណ្ឌនៃការសិក្សា និងការផ្គត់ផ្គង់សម្ភារសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ ជាដើម។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកបដោយសមធម៌ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តបង្កើតអន្តេវាសិកដ្ឋាន សម្រាប់ សិស្ស-និស្សិត ជាពិសេស សម្រាប់សិស្ស-និស្សិតជានារីភេទ និងបន្តសាងសង់សាលារៀនគ្រប់កម្រិតសិក្សា ជា ពិសេស នៅតាមតំបន់ជនបទនិងតំបន់ដាច់ស្រយាល និងការបង្កើនអាហារូបករណ៍ សម្រាប់សិស្ស-និស្សិតក្រីក្រ ។ ទន្ទឹមនឹងនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាព ឱ្យបានគ្រប់គ្រាន់ និង អនុវត្តគោលនយោបាយពង្រាយគ្រូឱ្យមានប្រសិទ្ធភាព ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងលើកទឹកចិត្តឱ្យគ្រូបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងគ្រូដែលបានបន្តរៀនចប់បរិញ្ញាបត្រ បានប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដោយគ្មានកម្រិតអាយុ និងបង្កលក្ខណៈសម្បត្តិឱ្យគ្រូបឋមសិក្សា ដែលមិនទាន់មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានលទ្ធភាពប្រឡងយកសញ្ញាបត្រសមមូលមធ្យមសិក្សាទុតិយភូមិ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់មានលទ្ធភាពរៀន នៅថ្នាក់ឧត្តមសិក្សា ឬក្រោយឧត្តមសិក្សា និងផ្លាស់ប្តូរវេនវេកាំប្រាក់បៀវត្សរ៍បាន។

៥២៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងជាមួយសហគមន៍ជាតិនិងអន្តរជាតិ ដើម្បីបង្កើននិងលើកកម្ពស់ គុណភាពសេវាអប់រំ ក្នុងនោះ មានការយកចិត្តទុកដាក់បន្ថែម លើការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យានិងភាសាបរទេស នៅក្នុងគ្រប់កម្រិតមធ្យមសិក្សាចំណេះទូទៅ នៅក្នុងការបណ្តុះបណ្តាលមុខវិជ្ជាជីវៈនិងបច្ចេកទេស និង នៅក្នុងកម្រិតឧត្តមសិក្សាឱ្យស្របទៅនឹងស្តង់ដារអន្តរជាតិ និង តម្រូវការអភិវឌ្ឍន៍របស់ប្រទេស ។ ពិសេសជាងនេះទៀត ក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស និងឧត្តមសិក្សា *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលវិស្វករនិងអ្នកបច្ចេកទេស ឱ្យបានសមស្រប ។ ទន្ទឹមនេះ ដើម្បីកាត់បន្ថយគម្លាតរវាងការផ្គត់ផ្គង់និងតម្រូវការការងារ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តគោលនយោបាយបណ្តុះបណ្តាលមុខវិជ្ជាជីវៈផ្សារភ្ជាប់នឹងទីផ្សារពលកម្ម ដោយសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធ តាមរយៈវិធានការ ដូចតទៅ *(ទី១)* ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ដល់ប្រជាពលករនៅជនបទ ដើម្បីបង្កើនប្រាក់ចំណូល *(ទី២)* ផ្តល់ការបណ្តុះបណ្តាល ឬវិក្រឹតការដល់ពលករតាមរោងចក្រ ដោយសហការជាមួយនិយោជក *(ទី៣)* បន្តជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ ដោយពង្រីកសេវានេះឱ្យទៅដល់រាជធានី-ខេត្ត ក្នុងនោះ រួមទាំងការបញ្ចូលការបណ្តុះបណ្តាលសហគ្រិនទៅក្នុងកម្មវិធីផងដែរ *(ទី៤)* ការរៀបចំបង្កើតទីភ្នាក់ងារជាតិមុខរបរនិងការងារ និងមជ្ឈមណ្ឌលការងារតាមរាជធានី-ខេត្ត សម្រាប់ជាយន្តការសម្រួលដល់ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ។

៥២៨. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រីកការអប់រំក្រៅប្រព័ន្ធ តាមរយៈ កម្មវិធីអក្ខរកម្ម និងអក្ខរកម្មវិជ្ជាជីវៈ បង្កើនការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងអនុវត្តកម្មវិធីសមធម៌ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តបង្កើនចំណាយថវិកា និងកៀរគរហិរញ្ញប្បទានឱ្យបានច្រើនថែមទៀត សម្រាប់គាំទ្រការអប់រំ ដើម្បីធានាគុណភាពអប់រំ ឱ្យកាន់តែមានកម្រិតខ្ពស់ និងប្រកបដោយប្រសិទ្ធភាព ។ នៅកម្រិតឧត្តមសិក្សា បានបង្ហាញអំពីតម្រូវការនិស្សិតដែលបញ្ចប់ការសិក្សានៅឧត្តមសិក្សានឹងក្លាយជា អ្នកវិទ្យាសាស្ត្រ និយោជិត និង ជាប្រជាពលរដ្ឋដែលអាចគិតត្រិះរិះបានល្អិតល្អន់ និងធ្វើសេចក្តីសម្រេចចិត្តដោយមានអំណះអំណាងត្រឹមត្រូវ នាពេលអនាគត រយៈពេលខ្លី និងរយៈពេលវែង របស់កម្ពុជា ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៥២៩. ដើម្បីអនុវត្តគោលនយោបាយជាអាទិភាព ក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ *ក្រសួងអប់រំ យុវជន និងកីឡា* នឹងបន្តអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍សម្រាប់វិស័យអប់រំ ដូចដែលមានកំណត់ក្នុង *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-២០១០* ដោយផ្តោតលើការសម្រេចឱ្យបាននូវគោលដៅទាំងឡាយ នៃគោលនយោបាយជាអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។ ជាអាទិភាពបន្ទាន់ ក្រសួងអប់រំ យុវជន និងកីឡា នឹងចាប់ផ្តើមដំណើរការកែលម្អ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣* ដើម្បីធានាឱ្យមានសុខដុមនីយកម្មរវាងផែនការវិស័យអប់រំ ជាមួយនឹងនីតិកាលរបស់រដ្ឋសភាជាតិ និងគោលនយោបាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* លើវិស័យអប់រំ ។

៥៣០. ដើម្បីសម្រេចគោលដៅនៃគោលនយោបាយជាអាទិភាពខាងលើនេះ *ក្រសួងអប់រំ យុវជន និងកីឡា* នឹងបន្តអនុវត្តនូវវិធានការណ៍សមស្រប នៅក្នុងគោលនយោបាយទាំងបី នៃ*ផែនការយុទ្ធសាស្ត្រវិស័យអប់រំ*ដែលផ្តោតលើ :

- *ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌* តាមរយៈ កិច្ចខិតខំកសាងសាលារៀន ឱ្យបានកាន់តែជិតផ្ទះប្រជាពលរដ្ឋ កាត់បន្ថយចំនួនសាលាបឋមសិក្សាមិនគ្រប់កម្រិត ជាមួយនឹងការផ្តត់ផ្គង់ថវិកាដំណើរការគ្រឹះស្ថានសិក្សា ផ្តល់គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់គ្រប់ទីកន្លែង និង សាងសង់ផ្ទះស្នាក់នៅរបស់គ្រូបង្រៀន អន្តេវាសិកដ្ឋានសម្រាប់សិស្ស-និស្សិតនៅតាមតំបន់ជួបការលំបាក ជាពិសេស សម្រាប់សិស្ស-និស្សិតជានារីភេទ ។ ការទទួលបានសេវាអប់រំ នឹងត្រូវពង្រីកដល់កុមារក្នុងវ័យសិក្សានៅមត្តេយ្យសិក្សា ក៏ដូចជាកុមារពិការ និងជនជាតិភាគតិច។ ការធានាឱ្យមានការចូលរួមពីសំណាក់សហគមន៍ និងផ្នែកឯកជននៅក្នុងដំណើរការនេះ មានសារៈសំខាន់ណាស់ សម្រាប់ភាពជោគជ័យរយៈពេលវែង ។
- *បង្កើនគុណភាពនិងប្រសិទ្ធភាពសេវាអប់រំ* តាមរយៈ ការបង្កើនការផ្គត់ផ្គង់សម្ភារសិក្សាបណ្ណាល័យនិងបន្ទប់ពិសោធន៍ បន្តជំរុញការអនុវត្តកំណែទម្រង់កម្មវិធីសិក្សា និងការបង្កើនម៉ោងសិក្សា ព្រមទាំងផ្តល់អាហា-រូបករណ៍ ដល់សិស្ស-និស្សិតក្រីក្រឱ្យបានច្រើនថែមទៀត ។ លើកកម្ពស់សមត្ថភាពលើការបង្រៀន និងការគ្រប់គ្រង ។ ពង្រឹងការគោរពក្រមសីលធម៌គ្រូបង្រៀន ។ កែលម្អបរិស្ថានសាលារៀន (ការផ្គត់ផ្គង់ទឹកស្អាត និងបង្គន់អនាម័យ) ពង្រីកសកម្មភាពការអប់រំតម្រង់ទិសវិជ្ជាជីវៈ ។ បង្កើនសកម្មភាពអធិការកិច្ច លើការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និងការធានាគុណភាពអប់រំ ។ ការធានាគុណភាពអប់រំ នឹងត្រូវបង្កើតឡើង ។ ការពង្រឹងប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន ការគ្រប់គ្រងវគ្គបំប៉ន និងការផ្សារភ្ជាប់ការងារទាំងនោះទៅនឹង ឱកាសការងារនិងការតម្លើងឋានៈ នឹងជួយជំរុញលើកទឹកចិត្តគ្រូបង្រៀន និងមន្ត្រីគ្រប់គ្រង។
- *អភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពមន្ត្រីអប់រំ* តាមរយៈ ការជំរុញការកែលម្អរចនាសម្ព័ន្ធការងារកសាងច្បាប់ និងលិខិតបទដ្ឋានឱ្យបានគ្រប់គ្រាន់ ជាមួយនោះធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដល់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ។ ការបន្តផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធសវនកម្មផ្ទៃក្នុង ការកសាងផែនការ ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ នឹងជំរុញដល់ការអភិវឌ្ឍស្ថាប័ន និងបង្កើនសមត្ថភាព ដើម្បីគ្រប់គ្រងប្រព័ន្ធទាំងនេះ។

៥៣១. ដើម្បីបន្តសម្រេចបានតាមគោលនយោបាយទាំងបីខាងលើ *ក្រសួងអប់រំ យុវជន និងកីឡា* នឹងបន្តអនុវត្តកម្មវិធីជាអាទិភាពមួយចំនួន តាមរយៈ ការប្រើប្រាស់ថវិកាតាមកម្មវិធី ដែលបានកំណត់នៅក្នុង *ផែនការយុទ្ធ-សាស្ត្រថវិកាឆ្នាំ២០១០-២០១២* ដែលក្នុងនោះមានកម្មវិធីធំៗចំនួន ៥ និងអនុកម្មវិធីចំនួន ២១ ដូចខាងក្រោម :

- *កម្មវិធីទី១ : ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ :* កម្មវិធីនេះ ផ្តោតលើ :

- ➢ ការពង្រីកការអប់រំកុមារតូច ។
- ➢ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា ។
- ➢ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា ។
- ➢ ការចូលរៀនប្រកបដោយសមធម៌ និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក ។
- ➢ ការពង្រីកការអប់រំក្រៅប្រព័ន្ធ ។

- *កម្មវិធីទី២ : ការអភិវឌ្ឍអប់រំ បណ្តុះបណ្តាល បច្ចេកទេស ឧត្តមសិក្សា និងស្រាវជ្រាវវិទ្យាសាស្ត្រ :* កម្មវិធីនេះ ផ្តោតជាសំខាន់លើ :
  - ➢ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅឧត្តមសិក្សា ។
- *កម្មវិធីទី៣ : ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា* កម្មវិធីនេះ ផ្តោតជាសំខាន់លើ :
  - ➢ ការអភិវឌ្ឍសមាគមកីឡាមហាជន ។
  - ➢ ការអភិវឌ្ឍសមាគមកីឡាសិស្ស-និស្សិត ។
  - ➢ ការបណ្តុះបណ្តាល និងស្រាវជ្រាវអប់រំកាយ និងកីឡា ។
  - ➢ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ ។
- *កម្មវិធីទី ៤ : ការអភិវឌ្ឍយុវជន* ផ្តោតសំខាន់លើ
  - ➢ ការយល់ដឹងរបស់យុវជនអំពីជំងឺអេដស៍ និងការពង្រឹងសកម្មភាពយុវជន ។
  - ➢ ការពង្រឹងសមត្ថភាព និងអភិវឌ្ឍមជ្ឈមណ្ឌលយុវជន ។
- *កម្មវិធីទី ៥ : ការគាំទ្រ ការគ្រប់គ្រងសេវាអប់រំ និងអភិបាលកិច្ចល្អ* កម្មវិធីនេះ ផ្តោតលើ :
  - ➢ ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងប្រព័ន្ធផែនការអប់រំ ។
  - ➢ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ។
  - ➢ ការអភិវឌ្ឍសម្ភារ និងសៀវភៅសិក្សា ។
  - ➢ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស ។
  - ➢ ការអភិវឌ្ឍសមត្ថភាព ការងារគ្រប់គ្រង ផែនការ ហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារ ។
  - ➢ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង ។
  - ➢ ការពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងារវិស័យអប់រំទាំងមូល។
  - ➢ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ។
  - ➢ ការអភិវឌ្ឍការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ។

៥៣២. ដើម្បីគាំទ្រស្មារតីអនុវត្តនូវគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល *ក្រសួងអប់រំ យុវជន និងកីឡា* នឹងបន្តរៀបចំ និងសុំការអនុម័ត នូវព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដូចខាងក្រោម :

- គោលនយោបាយទី១ : ធានាការទទួលបានសមធម៌ នូវសេវាកម្មអប់រំ
  - ប្រកាសស្តីពី ការបង្កើត ការបិទ ការរំលាយបញ្ចូលគ្នា ការបង្កើតជំនាញថ្មី ការបំបែក និងការប្រែក្លាយសាលារៀន ឬគ្រឹះស្ថានសិក្សា ។
  - សារាចរស្តីពី ការផ្សព្វផ្សាយ ឃោសនាព័ត៌មានអប់រំ ។
  - អនុក្រឹត្យស្តីពី លក្ខណៈវិនិច្ឆ័យ ប្រភេទគ្រឹះស្ថានឧត្តមសិក្សា និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរៀន ។
  - គោលនយោបាយស្តីពី ការផ្តល់អាហារូបករណ៍ឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា ។
- គោលនយោបាយទី២ : ធ្វើឱ្យប្រសើរឡើង គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ
  - ប្រកាសស្តីពីកម្មវិធីអប់រំពិសេស ។
  - អនុក្រឹត្យស្តីពីស្តង់ដារជាតិអប់រំ ជាតិបណ្តុះបណ្តាល និងស្តង់ដារជាតិសមត្ថភាព ។
  - សារាចរណែនាំស្តីពីនីតិវិធី សម្រាប់ដំណើរការ យន្តការតាមដានត្រួតពិនិត្យ និង យន្តការវាយតម្លៃគុណភាពអប់រំ ។
  - ប្រកាសស្តីពីការកំណត់កម្មវិធីសិក្សាគោលសម្រាប់ការអប់រំចំណេះទូទៅ ។
  - គោលនយោបាយស្តីពីការកំណត់ក្របខ័ណ្ឌលម្អិតនៃកម្មវិធីសិក្សា សម្រាប់អនុវត្តនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធ អប់រំកម្ពុជា ។
  - ប្រកាសស្តីពី ការកំណត់ក្របខ័ណ្ឌ និងលក្ខណៈនៃកម្រិត សញ្ញាបត្រ និងវិញ្ញាបនបត្រ ។
  - សេចក្តីណែនាំស្តីពី កម្មវិធីគោលសម្រាប់ការបណ្តុះបណ្តាល បុគ្គលិកអប់រំ ។
  - អនុក្រឹត្យស្តីពី នីតិវិធីនៃការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល ។
  - សេចក្តីណែនាំស្តីពី ការណែនាំដំណើរការប្រឡង ។
  - គោលនយោបាយស្តីពី វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ ។
  - ប្រកាសស្តីពី ការត្រួតពិនិត្យសុខភាពសម្រាប់អ្នកសិក្សា និងបុគ្គលិកអប់រំ ។
  - ប្រកាសស្តីពី ការកំណត់ភាសាសម្រាប់អ្នកសិក្សាសញ្ជាតិខ្មែរ មានដើមកំណើតជាជនជាតិភាគតិច ។
  - សារាចរណែនាំស្តីពី បែបបទ និងនីតិវិធីនៃការអនុវត្តអនុក្រឹត្យក្រមសីលធម៌គ្រូបង្រៀន ។
- គោលនយោបាយទី៣ : ពង្រឹងការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពដល់បុគ្គលិកអប់រំ
  - ប្រកាសស្តីពី រចនាសម្ព័ន្ធនៃឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងអប់រំ ។
  - គោលនយោបាយស្តីពី ការកំណត់កាយសម្បទា និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈ សម្រាប់ការជ្រើសរើសបុគ្គលិកអប់រំ ។
  - ប្រកាសស្តីពី ការគ្រប់គ្រងសាលារៀន ឬគ្រឹះស្ថានសិក្សា ។

- *ព្រះរាជក្រឹត្យស្តីពី ប្រព័ន្ធអប់រំ ។*
- *សារាចរណែនាំស្តីពី ការផ្តល់វិញ្ញាបនបត្រ ឬសញ្ញាបត្រដល់អ្នកសិក្សា ។*
- *ប្រកាសស្តីពី នីតិវិធីនៃការស្នើ ប្តឹង និងនីតិវិធីនៃដំណោះស្រាយ ។*
- *សារាចរណែនាំស្តីពី នីតិវិធីនៃការចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀង ។*
- *សារាចរស្តីពី ការផ្តល់ព័ត៌មានអប់រំ ។*
- *ប្រកាសស្តីពី ការរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន ។*
- *ប្រកាសស្តីពី ការគ្រប់គ្រងប្រភពធនធាននៃការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់ការអប់រំ ។*
- *អនុក្រឹត្យស្តីពី ការប្រើប្រាស់ប្រភេទសាលារៀន និងគ្រឹះស្ថានសិក្សា ។*
- *សារាចរណែនាំស្តីពី ការផ្តល់សិទ្ធិជាអង្គភាពមានស្វ័យភាពក្នុងការគ្រប់គ្រង ។*
- *ព្រះរាជក្រមស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។*

៥៣៣. ដើម្បីដំណោះស្រាយ នូវបញ្ហាប្រឈមនានា ក្នុងអំឡុងពេលអនុវត្ត*ផយអជ* ឆ្នាំ២០០៦-២០១០ និងផ្អែកលើបទពិសោធន៍កន្លងមក *ក្រសួងអប់រំ យុវជន និងកីឡា* នឹងជំរុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងអាណត្តិនៃ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដោយ :

- *គោលនយោបាយទី១ : ធានាការទទួលបានសេវាកម្មអប់រំ ប្រកបដោយសមធម៌*
  - ផ្តល់ឱកាសដល់កុមារក្នុងវ័យសិក្សាទាំងអស់ឱ្យបានចូលរៀនទាំងអស់គ្នា តាមរយៈការរៀបចំ *ផែនការអភិវឌ្ឍសម្ភារូបវន្ត* ដោយសហការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ។
  - បង្កើនតួលេខជ្រើសរើសគ្រូតាមមូលដ្ឋាន ជាពិសេសតំបន់ដែលជួបការលំបាក ដើម្បីដោះស្រាយបញ្ហាគម្លាតក្នុងការពង្រាយគ្រូ រវាងតំបន់ប្រជុំជននិងតំបន់ជនបទ និង អនុវត្តគោលការណ៍ពង្រាយគ្រូ ឱ្យមានប្រសិទ្ធភាព ជាពិសេស គ្រូទើបចេញថ្មី និងការគ្រប់គ្រងបុគ្គលិកធម្មតា ។
  - កែលម្អការរក្សាសិស្សឱ្យនៅក្នុងសាលារៀន តាមរយៈ ការលុបបំបាត់ឧបសគ្គចំណាយរបស់មាតាបិតាសិស្ស ដូចជា ចំណាយក្រៅផ្លូវការ និងបង្កើនចំនួនអាហារូបករណ៍សម្រាប់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេសសិស្សស្រី ។
- *គោលនយោបាយទី២ : បង្កើនគុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*
  - បង្កើនគុណភាពអប់រំ តាមរយៈការពង្រឹងការអប់រំកុមារតូច ការពង្រឹងនិងពង្រីកសាលាកុមារមេត្រី ការបង្កើនថវិកាដំណើរការសាលារៀនស្របទៅតាមផែនការអភិវឌ្ឍន៍សាលារៀន ការកែលម្អកម្មវិធីសិក្សាឱ្យកាន់តែឆ្លើយតបសទៅនឹងតម្រូវការសង្គម-សេដ្ឋកិច្ច ការកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅគ្រប់កម្រិតនិងគ្រប់មុខវិជ្ជា ការពង្រីកបណ្ណាល័យនៅតាមសាលារៀន ការបង្កើនសកម្មភាពអធិការកិច្ច លើការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុនិងការធានាគុណភាពអប់រំ និងការកែលម្អ ស្តង់ដារនិងគុណភាពនៃការប្រឡងនៅថ្នាក់ទី១២ ដោយស្វែងរកបច្ចេកវិទ្យាថ្មីៗសម្រាប់ត្រួតពិនិត្យការប្រឡង ។

- បង្កើតទីប្រឹក្សាកុមារីតាមសាលារៀន ដើម្បីជួយដោះស្រាយបញ្ហាជួបការលំបាក និងលើកទឹកចិត្តដល់កុមារី ។
- ផ្តល់ឱកាសសិក្សាដល់កុមារនិងយុវជននៅក្រៅសាលា តាមរយៈ ការពង្រីកកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ការកែលម្អនិងពង្រីកកម្មវិធីអក្ខរកម្មនិងបំណិនវិជ្ជាជីវៈ រួមទាំង ការពង្រឹងរចនាសម្ព័ន្ធនិងសមត្ថភាពរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធ ។
- កែលម្អក្របខ័ណ្ឌកម្មវិធីអប់រំនៅឧត្តមសិក្សា ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ និងតម្រូវការជាតិ ឱ្យស្របនឹងចក្ខុវិស័យ និងយុទ្ធសាស្ត្រការអប់រំនៅឧត្តមសិក្សាឆ្នាំ២០២០ ។ បង្កើនថវិកាជាតិ សម្រាប់ផ្តល់អាហារូបករណ៍លើផ្នែកសំខាន់ៗ ជាពិសេស សម្រាប់និស្សិតស្រី កែលម្អការស្រាវជ្រាវនិងការអប់រំ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និង ពង្រឹងការអភិវឌ្ឍមន្ត្រីនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។
- បន្តលើកកម្ពស់សកម្មភាពយុវជន តាមរយៈ ការបញ្ចប់ការរៀបចំ *គោលនយោបាយជាតិស្តីពីការងារយុវជនកម្ពុជា* សំដៅលើកទឹកចិត្ត ដល់ ក្រសួងនិងស្ថាប័នរដ្ឋ ផ្នែកឯកជន និង អង្គការសង្គមស៊ីវិល ឱ្យយកចិត្តទុកដាក់ បង្កឱកាស ដល់យុវជនគ្រប់រូប ជាពិសេស យុវជនក្រីក្រ យុវជនពិការ យុវជនជនជាតិភាគតិច យុវជនងាយរងគ្រោះ ។ល។ ទទួលនូវការអប់រំ ការបណ្តុះបណ្តាលសមត្ថភាព ដើម្បីពួកគេអាចរួមចំណែកអភិវឌ្ឍប្រទេសជាតិ ។ ទន្ទឹមនឹងនេះ ត្រូវពង្រឹងនិងពង្រីក ក្រុមប្រឹក្សាកុមារ-យុវជន នៅតាម គ្រឹះស្ថានសិក្សា សមាគមនិស្សិត និង មហាវិទ្យាល័យ និងជំរុញចលនាប្រឡងប្រណាំង ***បីល្អ*** *"កូនល្អ សិស្សល្អ មិត្តល្អ"* ឱ្យកាន់តែប្រសើរឡើង ។ ម៉្យាងវិញទៀត ត្រូវជំរុញការរៀបចំ ក្រុមយុវជនស្ម័គ្រចិត្ត ទាំងនៅថ្នាក់ជាតិ រាជធានី-ខេត្ត ឱ្យបានល្អ និងរៀបចំមជ្ឈមណ្ឌលយុវជន នៅថ្នាក់ជាតិ និង រាជធានី-ខេត្ត ឱ្យបានដំណើរការល្អប្រសើរ ព្រមទាំង បង្កើនការអប់រំដល់សិស្សឱ្យយល់ដឹងអំពីមេរោគអេដស៍ អំពើហិង្សា គ្រឿងញៀន សុខភាពផ្លូវភេទ ។ល។
- លើកកម្ពស់ការអភិវឌ្ឍវិស័យកីឡា តាមរយៈការរៀបចំ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍការងារអប់រំកាយនិងកីឡា ។

- *គោលនយោបាយទី៣ : អភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពដល់បុគ្គលិកអប់រំ*

  - ពង្រឹងអភិបាលកិច្ចល្អនៅគ្រប់កម្រិត រួមទាំង ការធ្វើសនិទានកម្មការគ្រប់គ្រងបុគ្គលិក ដូចជា ប្រាក់បៀវត្សរ៍ ការជ្រើសរើស ការតែងតាំង និងការផ្លាស់ប្តូរ ការរៀបចំលិខិតបទដ្ឋានស្តីពីការប្រើប្រាស់ថវិកាឱ្យស្របទៅនឹងកម្មវិធីបែងចែកថវិកា ការពង្រឹងសវនកម្មផ្ទៃក្នុង អធិការកិច្ចរដ្ឋបាលនិងហិរញ្ញវត្ថុ និងយន្តការតាមដានត្រួតពិនិត្យ ដោយរួមបញ្ចូលទាំង ការកែលម្អសុក្រឹតភាពនិងភាពទៀងទាត់របស់ស្ថិតិ ។
  - បន្តកែលម្អប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈ ការពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល និងពង្រឹងប្រព័ន្ធរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។

- ពង្រឹងការគ្រប់គ្រងកម្មវិធីអភិវឌ្ឍសមត្ថភាព តាមរយៈ ការកែលម្អកិច្ចសម្របសម្រួលសកម្មភាព និងបង្កើនការយកចិត្តទុកដាក់នៅថ្នាក់ក្រោមជាតិ ។
- ពន្លឿនការបញ្ជ្រាបយេនឌ័រ ដោយមានគោលនយោបាយយេនឌ័រច្បាស់លាស់ នៅក្នុងវិស័យអប់រំ យុវជន និងកីឡា និង ផែនការយុទ្ធសាស្ត្រ ។

៥៣៤. សូចនាករ និងចំណុចដៅសំខាន់ៗ ដែលនឹងត្រូវ ធ្វើការតាមដានពិនិត្យ និងរាយការណ៍ជាប្រចាំ ដោយ *ក្រសួងអប់រំ យុវជន និង កីឡា* មានបង្ហាញជូន នៅក្នុងតារាងទី២១ ខាងក្រោម :

**តារាងទី២១ : សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា**

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៨-០៩ ជាក់ស្តែង | ២០០៩-១០ ប៉ាន់ស្មាន | ២០១០-១១ ព្យាករណ៍ | ២០១១-១២ ព្យាករណ៍ | ២០១២-១៣ ព្យាករណ៍ | ២០១៣-១៤ ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|
| ១ | សាលាបឋមសិក្សា (១-៦) | ចំនួន | ៦ ៥៦៥ | ៦ ៦៣៥ | ៦ ៦៨៥ | ៦ ៧៨៥ | ៦ ៨៦៥ | ៦ ៩៤៥ |
| ២ | អត្រាពិតនៃការសិក្សា : សរុប | % | ៩៤,៤ | ៩៥,០ | ៩៦,០ | ៩៧,០ | ៩៧,៥ | ៩៨,០ |
| | ប្រុស | % | ៩៤,៨ | ៩៥,០ | ៩៥,៥ | ៩៦,០ | ៩៦,៥ | ៩៧,០ |
| | ស្រី | % | ៩៤,០ | ៩៥,០ | ៩៦,០ | ៩៧,០ | ៩៨,០ | ៩៩,០ |
| ៣ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន | % | ៩៤,០ | ៩៦,០ | ៩៦,៥ | ៩៧,០ | ៩៧,៥ | ៩៨,០ |
| | ជនបទ | % | ៩៤,៧ | ៩៥,០ | ៩៦,០ | ៩៦,៥ | ៩៧,៥ | ៩៨,០ |
| | តំបន់ដាច់ស្រយាល | % | ៩០,៣ | ៩២,០ | ៩៤,០ | ៩៦,០ | ៩៧,៥ | ៩៨,០ |
| ៤ | អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៦ : សរុប | % | ៨៥,៦ | ៨៦,០ | ៨៨,០ | ៩០,០ | ៩២,០ | ៩៤,០ |
| | ប្រុស | % | ៨៥,៤ | ៨៦,០ | ៨៨,០ | ៩០,០ | ៩២,០ | ៩៤,០ |
| | ស្រី | % | ៨៥,៧ | ៨៦,០ | ៨៩,០ | ៩២,០ | ៩៥,០ | ៩៨,០ |
| ៥ | ចំនួនសាលាមធ្យមសិក្សាបឋមភូមិ (៧-៩) | ចំនួន | ១ ៤៥១ | ១ ៥២១ | ១ ៦០០ | ឃុំ ១មាន សាលា ១ | ឃុំ ១មាន សាលា ១ | ឃុំ ១ មាន សាលា ១ |
| ៦ | អត្រាពិតនៃការសិក្សា : សរុប | % | ៣៣,៩ | ៤០,០ | ៤៣,០ | ៤៦,០ | ៤៨,០ | ៥១,០ |
| | ប្រុស | % | ៣២,០ | ៣៨,០ | ៤១,០ | ៤៣,០ | ៤៦,០ | ៤៩,០ |
| | ស្រី | % | ៣៥,០ | ៤២,០ | ៤៥,០ | ៤៨,០ | ៥១,០ | ៥៤,០ |
| ៧ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន | % | ៥៤,០ | ៥៦,០ | ៥៨,០ | ៦០,០ | ៦២,០ | ៦៤,០ |
| | ជនបទ | % | ៣០,៩ | ៣៤,០ | ៣៦,០ | ៣៨,០ | ៤០,០ | ៤២,០ |
| | តំបន់ដាច់ស្រយាល | % | ១១,៣ | ១៤,០ | ១៦,០ | ១៨,០ | ២០,០ | ២២,០ |
| ៨ | អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៩ : សរុប | % | ៤៩,១ | ៥១,០ | ៥៣,០ | ៥៥,០ | ៥៧,០ | ៥៩,០ |
| | ប្រុស | % | ៥២,២ | ៥៤,០ | ៥៦,០ | ៥៨,០ | ៦០,០ | ៦២,០ |
| | ស្រី | % | ៤៥,៩ | ៤៨,០ | ៥០,០ | ៥២,០ | ៥៤,០ | ៥៦,០ |
| ៩ | អត្រាអក្ខរជនអាយុ ១៥-២៤ ឆ្នាំ | % | ៨៧,៥ | ៨៨,០ | ៨៩,០ | ៩០,០ | ៩១,០ | ៩២,០ |

**ប្រភព** : EMIS ក្រសួងអប់រំ យុវជន និងកីឡា

## ៦.២ ការលើកកម្ពស់សេវាសុខាភិបាល

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៥៣៥. *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ថា ប្រជារាស្ត្រមានសុខភាពល្អ គឺជាមូលដ្ឋានគន្លឹះ សម្រាប់ ការអភិវឌ្ឍធនធានមនុស្ស និងការវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាព ។ *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តោតការយកចិត្តទុកដាក់លើ ការលើកកម្ពស់សុខុមាលភាពរបស់ពលរដ្ឋជាទូទៅ ជាពិសេស ប្រជារាស្ត្រក្រីក្រ ស្ត្រី និង កុមារ ។ ដើម្បីធានាឱ្យការអភិវឌ្ឍដែលមានលក្ខណៈជាប្រព័ន្ធក្នុងការផ្តល់សេវាសុខាភិបាលចំពោះប្រជាជន *រាជរដ្ឋាភិបាលកម្ពុជា* បានប្រកាន់យកវិធីសាស្ត្រ*អភិក្រមគ្រប់គ្រងទូទាំងវិស័យ* និងបានរៀបចំ *ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី១ (២០០៣-២០០៧)* ។ ផែនការនេះ ត្រូវបានអនុវត្តដោយសហការយ៉ាងជិតស្និទ្ធ ជាមួយដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ ។ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥* ត្រូវបានរៀបចំឡើង ហើយបច្ចុប្បន្ននេះ កំពុងត្រូវបានអនុវត្ត ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ។ ជាមួយគ្នានេះ ការអនុវត្ត*សំណុំសកម្មភាពអប្បបរមា* កំពុងមានវឌ្ឍនភាពល្អ ។ វិស័យសុខាភិបាល គឺជាវិស័យអាទិភាពមួយ សម្រាប់ *"កម្មវិធីជា អាទិភាព"* ដែលធានាការវិភាជថវិកាគ្រប់គ្រាន់ និងការផ្តល់មូលនិធិទាន់ពេលវេលា ទាំងថវិកាចំណាយចរន្ត និងចំណាយជាមូលធន ។ ក្នុងនីតិកាលទី៣ នៃរដ្ឋសភា ថវិកាចរន្តសម្រាប់វិស័យសុខាភិបាល បានកើនឡើងទ្វេដង គឺប្រមាណ ១០ភាគរយនៃថវិកាចរន្ត សម្រាប់ឆ្នាំ២០០៧ ។

៥៣៦. ក្នុងនីតិកាលទី៤ នៃរដ្ឋសភា នេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញការអនុវត្ត *ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល* ក្នុងគោលដៅកាត់បន្ថយអត្រាស្លាប់របស់មាតានិងទារក និងកែលម្អសូចនាករសុខាភិបាលសំខាន់ៗផ្សេងទៀត តាមរយៈ ការពង្រឹងគុណភាព និងពង្រីកសេវាសុខាភិបាល ជាពិសេស សេវាសុខភាពបន្តពូជ សេវាសុខភាពមាតា និង សេវាសុខភាពទារកនិងកុមារ ។

៥៣៧. *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តោតការយកចិត្តទុកដាក់ លើការអនុវត្តកម្មវិធីបង្ការ និងព្យាបាលជំងឺឆ្លងនានា ការសាងសង់មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព ទូទាំងប្រទេស ដែលអាចផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយ ប្រសិទ្ធភាព ចីរភាព សមធម៌ និងបង្កើនគុណភាពវិជ្ជាជីវៈ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញកែលម្អការបែងចែកចំនួន វេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ពេទ្យឆ្មប ក្នុងប្រព័ន្ធសុខាភិបាល បង្កើនប្រាក់កម្រៃលើកទឹកចិត្តសម្រាប់បុគ្គលិកសុខាភិបាលនៅតំបន់ជនបទ និង បង្កើនចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យ និងពេទ្យឆ្មប ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអប់រំ និងផ្សព្វផ្សាយ ពត៌មានសុខាភិបាល អនាម័យ ឱ្យបានទូលំទូលាយ ជាពិសេស ដល់តំបន់ជនបទ ព្រមទាំង ផ្តល់សេវាដល់ជនក្រីក្រ តាមរយៈ មូលនិធិសមធម៌ និងប្រព័ន្ធធានារ៉ាប់រងសុខភាព ។

៥៣៨. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញអនុវត្តវិធានការចាំបាច់នានា ដើម្បីធ្វើឱ្យសេវាសុខាភិបាលកាន់តែឆ្លើយតប និង ខិតកាន់តែជិតសាធារណៈជន តាមរយៈ ការអនុវត្តវិមជ្ឈការលើមុខងារផ្តល់សេវា និង ការធ្វើវិមជ្ឈការការគ្រប់គ្រង ទៅឱ្យថ្នាក់ក្រោមជាតិ ដូចជាមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។ ជាមួយគ្នានេះ នឹងបង្កើនការវិនិយោគ លើ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បរិក្ខាពេទ្យ និងបច្ចេកវិទ្យា ជាមួយនឹង ការលើកកម្ពស់សេវាគាំទ្រផ្សេងៗទៀត ។ បន្ថែមពីលើនេះទៀត *រាជរដ្ឋាភិបាលកម្ពុជា* នឹងលើក កម្ពស់ ការស្រាវជ្រាវសុខភាព សម្រាប់ការកសាង គោលនយោបាយ ផែនការ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ពីសមិទ្ធផល និងការពង្រឹងអភិបាលកិច្ចទូទាំងវិស័យសុខាភិបាល តាមរយៈ ការអនុវត្តកម្មវិធី *អភិក្រមទូទាំងវិស័យ* ដោយត្រូវបង្កើនភាពជាម្ចាស់ និងពង្រឹងភាពជាដៃគូ ជាមួយ សហគមន៍អន្តរជាតិ ។ ទន្ទឹមនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តលើកកម្ពស់ ការចូលរួមរបស់វិស័យឯកជន ដើម្បីបង្កើនការវិនិយោគបន្ថែមទៀត ក្នុងវិស័យសុខាភិបាល និង ការពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៥៣៩. ការអនុវត្តនគោលនយោបាយជាអាទិភាព សម្រាប់វិស័យសុខាភិបាល ក្នុងរយៈពេល ៥ឆ្នាំខាងមុខ នឹងត្រូវបានត្រួសត្រាយដោយ ក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលបានលើកឡើងនៅក្នុង*ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥* គោលនយោបាយស្តីអំពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្របខ័ណ្ឌគោលនយោបាយសម្រាប់វិមជ្ឈមការនិងវិសហមជ្ឈការ និង ក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកាជាតិ ។ អាទិភាពជាយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាល រួមមានពីរផ្នែកធំៗ មានទំនាក់ទំនងគ្នាអន្តរវិស័យ ហើយដែលក្រសួងសុខាភិបាល និងដៃគូទាំងអស់ត្រូវផ្តោតយកចិត្តទុកដាក់ជាពិសេស ។ អាទិភាពទាំងពីរផ្នែកនេះ រួមមាន អាទិភាពសុខភាពរបស់ប្រជាជន និងសេវាសុខភាពជាសារវន្ត និង បញ្ហាប្រឈមដែលមានទាក់ទងនឹងដំណើរការមុខងារ របស់ប្រព័ន្ធសុខាភិបាល *"ទាំងផ្នែកផ្តល់សេវា"* និង *"ទាំងផ្នែកតម្រូវការសេវា"* ។ ការកសាងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃ *ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥* រួមមាន កម្មវិធីសុខភាព ចម្បងចំនួន ៣ របស់ *ក្រសួងសុខាភិបាល* :

១. កម្មវិធីសុខភាពបន្តពូជ មាតា ទារកនិងកុមារ ។

២. កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង ។

៣. កម្មវិធីប្រយុទ្ធនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃ ។

៥៤០. នៅក្នុងកម្មវិធីនីមួយៗ នៃកម្មវិធីទាំង ៣ ខាងលើ *ក្រសួងសុខាភិបាល* នឹងផ្តោតលើការអនុវត្តយុទ្ធសាស្ត្រសុខាភិបាលប្រទាក់ក្រឡា ចំនួន ៥ ដែលរួមបញ្ចូលវិធានការទាំងផ្នែកផ្តល់សេវា និងផ្នែកតម្រូវការសេវា :

- ក្នុងផ្នែកនៃ*ការផ្តល់សេវាសុខាភិបាល* សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :

- ពង្រីកការគ្របដណ្តប់ការផ្តល់ *សេវាសំណុំសកម្មភាពអប្បបរមា* និង *សំណុំសកម្មភាពបង្គ្រប់* យោងតាម ផែនការគ្របដណ្តប់វិស័យសុខាភិបាល និងតម្រូវការរបស់អតិថិជន ។
- ពង្រឹងប្រព័ន្ធគាំទ្រការផ្តល់សេវាសុខាភិបាលក្នុងលក្ខណៈសមាហរណកម្ម ។
- តម្រែតម្រង់ការផ្តល់សេវា និងការធ្វើអន្តរាគមន៍សុខភាពសាធារណៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាព ។
- បង្កើតនិងអនុវត្ត បទដ្ឋានគុណភាព នៅទូទាំងវិស័យសុខាភិបាល (សេវារដ្ឋ សេវាឯកជន និងសេវាឯកជនមិនស្វែងរកកម្រៃ) ។
- បង្កើតគំរូកិច្ចសន្យា ដែលជាចំណែកមួយនៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ សម្រាប់ការផ្តល់សេវា ។

• ក្នុងផ្នែក *ហិរញ្ញប្បទានការថែទាំសុខភាព* សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :

- បង្កើនថវិការដ្ឋ និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានរដ្ឋ ដែលបានវិភាជសម្រាប់វិស័យសុខាភិបាល ។
- តម្រែតម្រង់ការផ្តល់មូលនិធិសម្រាប់កិច្ចសហការអភិវឌ្ឍ ជាមួយនឹង យុទ្ធសាស្ត្រ ផែនការ និងអាទិភាពទាំងឡាយរបស់ *ក្រសួងសុខាភិបាល* និងពង្រឹងការសម្របសម្រួលការផ្តល់មូលនិធិ ទាំងនោះក្នុងវិស័យសុខាភិបាល ។
- បន្ថយឧបសគ្គហិរញ្ញវត្ថុ ក្នុងពេលទទួលយក សេវាថែទាំសុខភាព និងអភិវឌ្ឍយន្តការគាំពារសុខភាពសង្គម ។
- គិតគូរពីប្រភពចម្បងៗ និងការប្រើប្រាស់ធនធានជាតិ នៅថ្នាក់ផ្តល់សេវា សម្រាប់ធ្វើអន្តរាគមន៍ជាយុទ្ធសាស្ត្រ ។
- ប្រមូលទិន្នន័យព័ត៌មានដែលត្រូវការសម្រាប់អភិវឌ្ឍ និង តាមដានត្រួតពិនិត្យគោលនយោបាយហិរញ្ញប្បទានសុខាភិបាល ។

• ក្នុងផ្នែក *ធនធានមនុស្សសម្រាប់វិស័យសុខាភិបាល* សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :

- បង្កើនជំនាញបច្ចេកទេស និងសមត្ថភាពធនធានមនុស្សសម្រាប់វិស័យសុខាភិបាល ។
- ពង្រឹងក្របខណ្ឌមុខវិជ្ជាជីវៈ ក្រមសីលធម៌ និងគុណភាពការងារ ។
- លើកកម្ពស់ការបែងចែកនិងការរក្សាទុកបុគ្គលិក ដោយផ្តល់អាទិភាពដល់បុគ្គលិក ដែលចាំបាច់សម្រាប់ផ្នែកអាទិភាព ។
- កែលម្អប្រពន្ធ័លាភការ បៀវត្សរ៍ និងការលើកទឹកចិត្ត តាមស្នាដៃការងារ ។

• ក្នុងផ្នែក *ប្រព័ន្ធព័ត៌មានសុខាភិបាល* សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :

- ➢ បង្កើនភាពត្រឹមត្រូវ ទាន់ពេលវេលា និងពេញលេញ នៃទិន្នន័យដែលមានគុណភាពខ្ពស់ ពីផ្នែករដ្ឋនិងឯកជន ជាមួយនឹងការលើកកម្ពស់ការសម្របសម្រួល និងបង្កើនធនធាន សម្រាប់ប្រព័ន្ធពត៌មានសុខាភិបាល ។
- ➢ លើកកម្ពស់ការចែករំលែក ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យនៅ គ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល រួមទាំងទិន្នន័យប្រជាជន និងទិន្នន័យប្រជាសាស្ត្រសង្គម ។
- ➢ លើកកម្ពស់ប្រព័ន្ធតាមដានជំងឺថ្នាក់ជាតិ ប្រព័ន្ធកត់ត្រាប្រវត្តិវេជ្ជសាស្ត្ររបស់អ្នកជំងឺនៅមូលដ្ឋានសុខាភិបាលរដ្ឋ និងពង្រឹងករណីរាយការណ៍ជំងឺ ការតាមដានត្រួតពិនិត្យ និងការឆ្លើយតបទៅនឹងជំងឺមិនឆ្លង ។
- ➢ ពង្រីកការចូលរួមរបស់វិស័យឯកជន នៅក្នុងប្រព័ន្ធពត៌មានសុខាភិបាលជាតិ និងសម្រួលការប្រើប្រាស់ទិន្នន័យ សម្រាប់ ការរៀបចំផែនការ ការបែងចែកធនធាន ការគ្រប់គ្រងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់ ។

- ក្នុងផ្នែក *អភិបាលកិច្ចប្រព័ន្ធសុខាភិបាល* សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :
  - ➢ ធ្វើសុខដុមនីយកម្ម និងការតម្រែតម្រង់សកម្មភាព នៅក្រសួងសុខាភិបាល និងទូទាំងវិស័យ ដើម្បីឱ្យសម្រេចបានគោលដៅនៃ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥* ។
  - ➢ កសាងភាពជាដៃគូរវាងរដ្ឋនិងឯកជន ។
  - ➢ លើកកម្ពស់សមត្ថភាពនៃការស្រាវជ្រាវ ការវិភាគគោលនយោបាយ និងធ្វើរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត នានា ។
  - ➢ ពង្រឹងសមត្ថភាពស្ថាប័ន ដែលជាចំណែកមួយនៃកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍស្ថាប័នក្រសួងសុខាភិបាល ។
  - ➢ ពង្រឹងមត្តទេសភាពរបស់ *ក្រសួងសុខាភិបាល* តាមរយៈ វិមជ្ឈការនិងវិសហមជ្ឈការ ។
  - ➢ កៀរគរការឆ្លើយតបពហុវិស័យ ដើម្បីលើកស្ទួយគណនេយ្យភាពប្រព័ន្ធសុខាភិបាល ដើម្បីទទួលបានគុណភាពនៃសេវាសុខភាពសម្រាប់ប្រជាជនទាំងអស់ ។

៥៤១. គោលដៅនិងទិសដៅ នៃសកម្មភាព ដែល *ក្រសួងសុខាភិបាល* នឹងអនុវត្ត រួមមាន :

**គោលដៅទី១ : បន្ថយការឈឺនិងស្លាប់របស់មាតាទារកនិងកុមារ និងការលើកកម្ពស់សេវាសុខភាពបន្តពូជ**

- *ទិសដៅទី១* : លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតា និងកុមារ ។
- *ទិសដៅទី២* : ធ្វើឱ្យប្រសើរឡើងលទ្ធភាពទទួលបានពត៌មាននិងសេវាសុខភាពបន្តពូជមានគុណភាព ។
- *ទិសដៅទី៣* : ធ្វើឱ្យប្រសើរឡើង លទ្ធភាពទទួលបានសេវាសុខភាពចាំបាច់ សម្រាប់មាតានិងទារក និងការប្រព្រឹត្ត ការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ ។

- *ទិសដៅទី៤* : ធានានូវលទ្ធភាពទទួលបាន សេវាសុខភាពចាំបាច់សម្រាប់កុមារ និងការថែទាំសុខភាពគ្រួសារបានល្អជាងមុន ។

**គោលដៅទី២ : បន្ថយការឈឺនិងស្លាប់ដោយជំងឺ អេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងផ្សេងទៀត**

- *ទិសដៅទី១* : កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍ ។
- *ទិសដៅទី២* : បង្កើនការរស់រានមានជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។
- *ទិសដៅទី៣* : សម្រេចបានអត្រាការពារជំងឺរបេងខ្ពស់ និងរក្សាអត្រាជាសះស្បើយកម្រិតខ្ពស់នៃ ករណីជំងឺរបេងស្ងួតបេកាវិជ្ជមាន ។
- *ទិសដៅទី៤* : កាត់បន្ថយការស្លាប់ដោយជំងឺគ្រុនចាញ់ និងអត្រាឈឺ ក្នុងចំណោមប្រជាជនទូទៅ ។
- *ទិសដៅទី៥* : កាត់បន្ថយបន្ទុកនៃជំងឺឆ្លងដទៃទៀត ។

**គោលដៅទី៣ : បន្ថយបន្ទុកជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត**

- *ទិសដៅទី១* : កាត់បន្ថយឥរិយាបទគ្រោះថ្នាក់នាំទៅរកជំងឺមិនឆ្លង ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺសរសៃឈាម ជំងឺមហារីក ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល ។
- *ទិសដៅទី២* : លើកកម្ពស់លទ្ធភាពមកទទួលយកសេវាព្យាបាល និងការស្តារនិតិសម្បទា បង្កឡើងដោយជំងឺមិនឆ្លង ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺសរសៃឈាម ជំងឺមហារីក ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ ។ល ។
- *ទិសដៅទី៣* : ធានាដំណើរការមុខងារសារវន្តនៃសុខភាពសាធារណៈ សុខភាពបរិស្ថាន សុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការត្រៀមលក្ខណៈ (សម្រាប់គ្រាអាសន្ន) ។

៥៤២. ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់វិស័យសុខាភិបាល សកម្មភាពសំខាន់ៗរបស់ អ្នកគ្រប់គ្រងនិងមន្ត្រី សុខាភិបាល នៅគ្រប់ផ្នែកទាំងអស់ នឹងត្រូវបានណែនាំដោយគោលការណ៍អនុវត្តការងារ ៥ យ៉ាង ដូចខាងក្រោម :

១. ការគាំពារសុខភាពសង្គម ជាពិសេស ប្រជាជនក្រីក្រ និងក្រុមប្រជាជនងាយរងគ្រោះ ។
២. វិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់លើអតិថិជន ក្នុងការ ផ្តល់សេវាសុខភាព ។
៣. វិធីសាស្ត្រសមាហរណកម្ម នៅក្នុងការផ្នែកផ្តល់សេវាសុខភាព និងការធ្វើអន្តរាគមន៍សុខភាពសាធារណៈមានគុណភាពខ្ពស់ ។
៤. ការគ្រប់គ្រងធនធានមនុស្ស គឺជាសសរទ្រូងនៃប្រព័ន្ធសុខាភិបាល ទាំងមូល ។
៥. អភិបាលកិច្ចល្អ និងការទទួលខុសត្រូវ ។

៥៤៣. ឈរលើមូលដ្ឋាននៃគោលការណ៍ ៥យ៉ាង ខាងលើនេះ ការខិតខំប្រឹងប្រែងនៃការងារគ្រប់គ្រង និងមន្ត្រីរាជការសុខាភិបាល នៅគ្រប់ជាន់ថ្នាក់ នឹងផ្តោតលើ ៖

- អនុវត្តវិមជ្ឈការ លើមុខងារផ្តល់សេវា និងមុខងារគ្រប់គ្រង ។
- ពង្រឹងអភិបាលកិច្ច ទូទាំងវិស័យសុខាភិបាល ។
- ពង្រីកលទ្ធភាពមកទទួលយកសេវានិងការគ្របដណ្តប់សេវាសុខភាព ។
- អនុវត្តប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល គាំទ្រដល់ជនក្រីក្រ ។
- ពង្រឹងការអនុវត្ត នីតិក្រមសុខាភិបាល ក្រមសីលធម៌វិជ្ជាជីវៈនិងលក្ខន្តិកៈ និងពង្រឹងយន្តការនិយ័តកម្ម ។
- លើកកម្ពស់គុណភាព ក្នុងការផ្តល់សេវាសុខភាព និងការគ្រប់គ្រង ។
- បង្កើនសមត្ថភាព និងជំនាញ រួមទាំង បច្ចេកទេសជំនាញពាក់ព័ន្ធ របស់បុគ្គលិកសុខាភិបាល ។
- ពង្រឹង និងវិនិយោគ លើប្រព័ន្ធពត៌មានសុខាភិបាលនិងលើកកម្ពស់ការស្រាវជ្រាវសុខភាព ។
- បង្កើនការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍បរិក្ខាពេទ្យ និងបច្ចេកវិទ្យាទំនើបនិងលើកកម្ពស់សេវាគាំទ្រមិនមែនវេជ្ជសាស្ត្រ ។
- លើកកម្ពស់ គុណភាព និងរបៀបរបបរស់នៅ ប្រកបដោយសុខភាពល្អរបស់ប្រជាជន ។
- បង្ការ និងទប់ស្កាត់ ជំងឺឆ្លង ជំងឺរ៉ាំរ៉ៃ និងជំងឺមិនឆ្លង ព្រមទាំងពង្រឹងប្រព័ន្ធតាមដានជំងឺ ។
- ពង្រឹងអន្តរាគមន៍សុខភាពសាធារណៈដើម្បីដោះស្រាយបញ្ហាប្រឈមមុខប្រទាក់ក្រឡាគ្នា ។
- លើកកម្ពស់ភាពជាដៃគូដ៏មានប្រសិទ្ធភាព រវាង វិសយ័សាធារណៈនិងវិស័យឯកជន ក្នុងការផ្តល់សេវា ។
- លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍ ក្នុងសកម្មភាពផ្តល់សេវា និងលើកកម្ពស់គុណភាព ។
- ពង្រឹងស្ថាប័នសុខាភិបាលជាប្រព័ន្ធ នៅគ្រប់ថ្នាក់ ក្នុងប្រព័ន្ធសុខាភិបាល ។

៥៤៤. ក្របខ័ណ្ឌប្រតិបត្តិការ និងមុខងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ របស់ *ក្រសួងសុខាភិបាល* គឺជាឧបករណ៍ដ៏សំខាន់ សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ ការអនុវត្តក្នុងវិស័យសុខាភិបាល លើមូលដ្ឋានទៀងទាត់មួយ ដើម្បីរៀបចំព័ត៌មានដែលត្រូវការចាំបាច់សម្រាប់ ការធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ និងដើម្បីតម្រែតម្រង់កម្មវិធីនៃការផ្តល់សេវាសារជាថ្មី ប្រសិនបើចាំបាច់ ដើម្បីសម្រេចនូវចំណុចដៅដែលបានកំណត់របស់កម្មវិធី ក៏ដូចជា ដើម្បីផ្តល់ធាតុចូលសម្រាប់ ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី ការអនុវត្ត *ផយអជ បច្ចុប្បន្នភាព ២០០៩-២០១៣* ។ ឧបករណ៍គន្លឹះនៃការរៀបចំផែនការ ដើម្បីអនុវត្តមុខងារ ទាំងអស់នោះ គឺ *ផែនការវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល* ដែលផ្សារភ្ជាប់នឹងក្របខ័ណ្ឌថវិកាយុទ្ធសាស្ត្រ និងកម្មវិធីវិនិយោគសាធារណៈ និងផែនការប្រតិបត្តិប្រចាំឆ្នាំ របស់ក្រសួងសុខាភិបាល និងការកសាងថវិកាតាមកម្មវិធី ។ មានការរំពឹងទុក គ្រប់ដៃគូសុខាភិបាលទាំងអស់ នឹងប្រើប្រាស់ក្របខណ្ឌ័នេះ (ដោយរាប់បញ្ចូលទាំង សំណុំសូចនាករដែលបានឯកភាពគ្នា) ដើម្បី

ពិនិត្យវឌ្ឍនភាពនៃកម្មវិធី-គម្រោងរបស់ខ្លួន ក្នុងវិស័យសុខាភិបាល ។ *ក្រសួងសុខាភិបាល* នឹងត្រួតពិនិត្យវឌ្ឍន-ភាពប្រចាំឆ្នាំ ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការ ដែលបន្តដោយការវាយតម្លៃ នៅពេលបញ្ចប់វដ្តផែនការយុទ្ធសាស្ត្រ ដើម្បីធ្វើរបាយការណ៍ស្តីពីផលប៉ះពាល់នៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រសុខាភិបាល លើកទី២* ក្នុងការលើកស្ទួយ ស្ថានភាពសុខភាពរបស់ប្រជារាស្ត្រ ដែលជាមុខសញ្ញា។

៥៨៥. សូចនាករសំខាន់ៗដែលបានជ្រើសរើស សម្រាប់កម្មវិធីនីមួយៗ នៃកម្មវិធីទាំងបី (កម្មវិធីសុខភាពបន្តពូជ មាតា ទារក និងកុមារ កម្មវិធីជំងឺឆ្លង និងកម្មវិធីជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត) *ដែលក្រសួងសុខាភិបាល* នឹងរាយការណ៍តាមពេលវេលា មានបង្ហាញនៅ ក្នុងតារាងទី២២ ខាងក្រោម ។

៥៨៦. *មេរោគអេដស៍/ជំងឺអេដស៍ : អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍* នឹងរួមចំណែកក្នុង (១) ការអនុវត្តយុទ្ធ-សាស្ត្រ កម្មវិធី និងគម្រោង ដើម្បីបន្តកាត់បន្ថយថែមទៀត នូវចំនួនករណីថ្មីនៃមេរោគអេដស៍ ដោយផ្តោតលើការពង្រីកអន្តរាគមន៍បង្ការដែលបានកំណត់ (២) ការបង្កើនការគ្របដណ្តប់និងគុណភាពនៃ ការថែទាំ ការព្យាបាល និងការគាំទ្រ ដល់ប្រជាជនដែលមានផ្ទុកមេរោគអេដស៍ និង (៣) ការកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ច និងធនធានមនុស្ស បណ្តាលមកពីជំងឺអេដស៍ទៅលើបុគ្គល គ្រួសារ សហគមន៍ និងសង្គម។ គម្រោងនិងកម្មវិធីទាំងនោះ នឹងតម្រង់ទិសដៅទៅលើ :

- ការបង្កើនការគ្របដណ្តប់នៃអន្តរាគមន៍បង្ការ ដែលមានប្រសិទ្ធភាព និងការរៀបចំឱ្យមាននូវអន្តរាគមន៍ថ្មីៗ បន្ថែមទៀត ។
- ការបង្កើនការគ្របដណ្តប់នៃអន្តរាគមន៍ ដែលមានប្រសិទ្ធភាព សម្រាប់ការថែទាំព្យាបាលនិងការគាំទ្រ និង ការរៀបចំឱ្យមាននូវអន្តរាគមន៍ថ្មីៗ បន្ថែមទៀត ។
- ការបង្កើនការគ្របដណ្តប់នៃអន្តរាគមន៍ ដែលមានប្រសិទ្ធភាព សម្រាប់ការកាត់បន្ថយផលប៉ះពាល់ និង ការរៀបចំឱ្យមាននូវអន្តរាគមន៍ថ្មីៗ បន្ថែមទៀត។
- ការពង្រឹងភាពដឹកនាំរបស់ស្ថាប័នរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការអនុវត្តនូវការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ការធានាឱ្យមានបរិស្ថានគតិយុត្តនិងគោលនយោបាយសាធារណៈមួយ ដែលគាំទ្រដល់ ការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងកម្រិតជាតិ ។
- ការបង្កើនប្រភពព័ត៌មានសម្រាប់អ្នករៀបចំគោលនយោបាយ និងអ្នកធ្វើផែនការសម្រាប់កម្មវិធី តាមរយៈការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សាស្រាវជ្រាវ ។
- ការបង្កើន និងការធ្វើឱ្យមាន ចីរភាពនិងប្រសិទ្ធភាព ក្នុងការកៀរគរ និងការវិភាជធនធាន សម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ នៅកម្រិតជាតិនិងក្រោមជាតិ ។

## តារាងទី២២ : សូចនាករសំខាន់ៗ (ធាតុចេញ និងលទ្ធផល[1]) និងចំណុចដៅរបស់វិស័យសុខាភិបាល

| សូចនាករស្នូល | ២០០៨[2] | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ***កម្មវិធីសុខភាពបន្តពូជ មាតា ទារក និងកុមារ*** | | | | | | |
| ពិនិត្យផ្ទៃពោះមុនសម្រាល ២ដង ឬច្រើនដង ដោយបុគ្គលិកសុខាភិបាល (%) | ៨១ | ៨៥ | ៨៨ | ៩០ | ៩២ | ៩៤ |
| %នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល | ៥៨ | ៦៥ | ៧០ | ៧៥ | ៨០ | ៨៥ |
| %នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលនៅមូលដ្ឋានសុខាភិបាល | ៣៩ | ៤៥ | ៥០ | ៥៥ | ៦០ | ៦៥ |
| % នៃការសម្រាលកូនដោយវះកាត់ | ២ | ២.២ | ២.៥ | ៣ | ៣ | ៣.២ |
| ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប % | ២៦ | ៣៧ | ៤០ | ៤៥ | ៤៦ | ៤៩ |
| % សមាមាត្រនៃកុមារអាយុក្រោមមួយឆ្នាំដែលបានទទួលថ្នាំបង្ការពេញលេញ | ៨៧ | ៨៥ | ៨៦ | ៨៧ | ៨៨ | ៨៩ |
| %នៃកុមារអាយុក្រោមមួយឆ្នាំបានទទួលថ្នាំបង្ការជំងឺកញ្ជ្រឹល | ៩១ | ៩០ | ៩១ | ៩៣ | ៩៥ | ៩៥ |
| ការពិគ្រោះជំងឺ (ករណីថ្មី) លើប្រជាជនម្នាក់ក្នុងមួយឆ្នាំ | | | | | | |
| *ប្រជាជនទូទៅ* | ០.៥៤ | ០.៥ | ០.៦ | ០.៦ | ០.៧ | ០.៨ |
| *កុមារក្រោម៥ឆ្នាំ* | ១.១ | ១.៣ | ១.៥ | ១.៧ | ១.៧ | ១.៨ |
| ***កម្មវិធីជំងឺឆ្លង*** | | | | | | |
| % នៃអ្នកផ្ទុកមេរោគអេដស៍ដែលប្រើឱសថពន្យារជីវិតនៅរស់ក្រោយការព្យាបាលរយៈពេល ១២ខែ | គ្មានតួលេខ | >៨៥ | >៨៥ | >៨៥ | >៨៥ | >៨៥ |
| អត្រាស្រាវជ្រាវករណីជំងឺរបេងសួតបេកាវិជ្ជមាន (%) | ៦៩ | >៧០ | >៧០ | >៧០ | >៧០ | >៧០ |
| អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង (%) | ៩០ | >៨៥ | >៨៥ | >៨៥ | >៨៥ | >៨៥ |
| អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ | ២.១០ | ១.៥០ | ១.២០ | ១.១០ | ០.៩៩ | ០.៩០ |
| អត្រាស្លាប់ដោយជំងឺគ្រុនឈាម បានរាយការណ៍មក មណ្ឌលសុខាភិបាលសាធារណៈ | ០.៦៨ | ០.៧ | ០.៦ | ០.៦ | ០.៦ | <០.៦ |
| ***ជំងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត*** | | | | | | |
| ប្រេវ៉ាឡង់ជំងឺទឹកនោមផ្អែមដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈលើប្រជាជនពេញវ័យ ១ ០០០ នាក់ | ៣.៥ | ៤.០ | ៤.៥ | ៥ | ៥.៥ | <៥.៥ |
| ចំនួននៃករណីជំងឺផ្លូវចិត្តដែលបានរាយការណ៍នៅមូលដ្ឋានសុខាភិបាល | ១៥ ៣២០ | ១៥ ០០០ | ១៨ ០០០ | ១៩ ០០០ | ២០ ០០០ | ២១ ០០០ |

[1] សូចនាករផលប៉ះពាល់ ត្រូវបានបញ្ចូលក្នុង តារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចរបស់ *ផយអជ បច្ចុប្បន្ន ២០០៩-២០១៣*

[2] តម្លៃឆ្នាំគោល

## ៦.៣ ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ

### ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៥៤៧. *រាជរដ្ឋាភិបាលកម្ពុជា* បានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ។ *រាជរដ្ឋាភិបាល* បានអនុវត្តផែនការយុទ្ធសាស្ត្រ *"នារីរតនៈទី២"* ប្រកបដោយជោគជ័យ ។ *រាជរដ្ឋាភិបាលកម្ពុជា* បានជំរុញអនុម័តច្បាប់ និងអនុវត្តច្បាប់ ដើម្បីការពារស្ត្រី ដែលរួមមាន *ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារលើស្ត្រី និងកិច្ចការពារជនរងគ្រោះ* និង *ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ* ។ ក្នុងវិស័យអប់រំ *រាជរដ្ឋាភិបាលកម្ពុជា* បានកាត់បន្ថយគម្លាតយេនឌ័រ តាមរយៈ ការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារី ។ ក្នុងវិស័យសុខាភិបាល *រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើនសេវាសុខភាពបឋម សុខភាពបន្តពូជ អាហារូបត្ថម្ភ ការទប់ស្កាត់នឹងជំងឺគ្រុនចាញ់ និងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ។ ក្នុងវិស័យសេដ្ឋកិច្ច *រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើនតួនាទីភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងបានការពារសិទ្ធិរបស់កម្មការិនី តាមរយៈ ការស្វែងរកការគាំទ្រមតិ និងការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយ ។ លើសពីនេះ ស្ត្រីទទួលបានជំនាញ សមត្ថភាព និងតួនាទី ដើម្បីចូលរួមកាន់តែច្រើនឡើងក្នុងការដឹកនាំ និងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតនៃអភិបាលកិច្ច ។ ជាទូទៅ សមាមាត្រស្ត្រី ដែលបានជាប់ឆ្នោតជាសមាជិការដ្ឋសភា បានកើនឡើងពី ១៩ភាគរយ នៅឆ្នាំ២០០៣ ដល់ ២២ភាគរយ ក្នុងឆ្នាំ២០០៨ ។ នៅឆ្នាំ២០០៧ ក្នុងចំណោមសមាជិកដែលជាប់ឆ្នោតទាំងអស់ក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មាន ១៥ភាគរយជាស្ត្រី ហើយបច្ចុប្បន្ននេះ ៣០ភាគរយ នៃអ្នកដឹកនាំថ្នាក់ភូមិទាំងអស់ជាស្ត្រី ។

៥៤៨. *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* នេះ នឹងបន្តអនុវត្តគោលនយោបាយ បង្កើនកាលានុវត្តភាពដល់សិស្ស-និស្សិតនារី ឱ្យបានចូលរៀនកាន់តែច្រើនថែមទៀត តាមរយៈ ការបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្ស-និស្សិតនារី ការផ្តល់នូវភាពងាយស្រួលក្នុងការប្រើបន្ទប់ទឹកដាច់ដោយឡែក កម្មវិធីបំប៉ននៅសាលារៀន-គ្រឹះស្ថានសិក្សា ការផ្តល់កន្លែងស្នាក់នៅ និងការធានាដឹកជញ្ជូនទៅមកប្រកបដោយសុវត្ថិភាព សម្រាប់សិស្ស-និស្សិតនារី និង ការបង្កើនចំនួនគ្រូបង្រៀន ជាស្ត្រី ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តលើកតម្កើងតួនាទីរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងយកចិត្តទុកដាក់លើការបណ្តុះបណ្តាលមុខជំនាញដល់ស្ត្រី នៅគ្រប់កម្រិត ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រី ឱ្យបានជាអតិបរមា នៅក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ ដោយបន្តពង្រីកកាលានុវត្តភាពការងារសម្រាប់ស្ត្រី និងបណ្តុះបណ្តាលអំពីរបៀបនៃការតស៊ូមតិក្នុងការឈរឈ្មោះ នៅតាមបណ្តាភូមិ-ឃុំ ទូទាំងប្រទេស ព្រមទាំង ការការពារសិទ្ធិធ្វើការងារ របស់ពួកគេ ។

៥៤៩. ដើម្បីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រក្នុងសង្គម *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តគោលការណ៍ផ្តល់ឥណទាន ខ្នាតតូចនិងមធ្យម ដល់ស្ត្រីនិងសហគមន៍ ដើម្បីឱ្យពួកគាត់អាចបង្កើតមុខរបរចិញ្ចឹមជីវិត ដោយខ្លួនឯង ។ ម្យ៉ាងទៀត ដើម្បីទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី និងការជួញដូរមនុស្ស *រាជរដ្ឋាភិបាលកម្ពុជា* នឹងអនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវ *ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ* សម្រាប់ផ្តល់នូវការការពារស្របច្បាប់ យ៉ាងមានប្រសិទ្ធភាព និងទាន់ពេលវេលា ដល់ជនរងគ្រោះ ដែលភាគច្រើនជាស្ត្រី និងកុមារ ដោយមានការចូលរួមសហការ ពីគ្រប់ស្ថាប័នពាក់ព័ន្ធ ជាពិសេស ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៥៥០. ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ក្រសួងកិច្ចការនារី* ដោយមានកិច្ចសហការជាមួយ *ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី* បានរៀបចំ ផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ *"នារីរតនៈទី៣ ២០០៩-២០១៣"* ដែលផ្តោតលើវិស័យជាយុទ្ធសាស្ត្រចំនួន ៥ កម្មវិធីបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងតាមវិស័យ កម្មវិធីកែទម្រង់និងការអនុវត្តអនុសញ្ញាអន្តរជាតិ ព្រមទាំង ការដោះស្រាយការគ្រប់គ្រងជាយុទ្ធសាស្ត្រ ការអភិវឌ្ឍសមត្ថភាព និងប្រសិទ្ធភាពជំនួយ ដែលមានលក្ខណៈអន្តរវិស័យ ។ វិស័យជាយុទ្ធសាស្ត្រទាំង៥ រួមមាន ៖

១. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។
២. ការលើកកម្ពស់ការអប់រំរបស់ស្ត្រីនិងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថនិងអាកប្បកិរិយា ។
៣. ការការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី ។
៤. ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ និងការទប់ស្កាត់ ការរីករាលដាលជំងឺអេដស៍ដល់ស្ត្រី និងក្មេងស្រី ។
៥. ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងវិស័យមុខងារសាធារណៈ និងក្នុងវិស័យនយោបាយ ។

៥៥១. នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី១ *ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្រសួងកិច្ចការនារី* ដោយមានកិច្ចសហការជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ និងភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត នឹងអនុវត្តសកម្មភាពទាំងឡាយ ដូចខាងក្រោម ៖

- គាំទ្រ និងស្វែងរកការគាំទ្រមតិ ដើម្បីពង្រីក និងលើកកម្ពស់ឱកាសការងារសម្រាប់ស្ត្រី រួមទាំង ការប្រកបមុខរបរក្រៅប្រព័ន្ធ តាមរយៈ ការសិក្សាស្រាវជ្រាវពិតម្រូវការ និងឱកាសក្នុងការលើកកម្ពស់លក្ខខណ្ឌសេដ្ឋកិច្ចរបស់ស្ត្រី ការសម្របសម្រួលក្នុងការបង្កើតភាពជាដៃគូរវាងស្ថាប័នរដ្ឋ វិស័យឯកជន និងសង្គមស៊ីវិល

ដើម្បីបង្កើតយន្តការគាំទ្រដល់សហគ្រិនជាស្ត្រី ការជំរុញកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជំនាញមុខវិជ្ជាជីវៈ និងអាហារូបករណ៍ ការបង្កើតយន្តការផ្តល់ការងារសមស្របដល់ស្ត្រី រួមមាន ក្រុមជនងាយរងគ្រោះ ស្ត្រីពិការ និងជនជាតិដើមភាគតិច និង ការបង្កើតមជ្ឈមណ្ឌលផ្តល់ប្រឹក្សានិងព័ត៌មានពីទីផ្សារការងារដល់ស្ត្រី ។

- ពង្រឹងការអភិវឌ្ឍសេវាកម្មជំនួញ ដើម្បីគាំទ្រនិងអភិវឌ្ឍ សហគ្រាសខ្នាតតូចនិងមធ្យម របស់ស្ត្រី តាមរយៈ ការអភិវឌ្ឍ និងកែប្រែ *មជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍបែបប្រពៃណី* ឱ្យទៅជា *មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី* ដើម្បីផ្តល់ ជំនាញមុខវិជ្ជាជីវៈដែលឆ្លើយតបនឹងតម្រូវការទីផ្សារការងារ សេវាប្រឹក្សានិងអភិវឌ្ឍសហគ្រាស និងជំនាញបំណិនជីវិតដល់ស្ត្រី ការរៀបចំកម្មវិធីសាកល្បងក្នុងសហគមន៍នានា ដើម្បីបង្កើនឱកាសការងារសម្រាប់ស្ត្រី ការបង្កើតក្រុមផលិតករនិងបណ្តាញសហគ្រិនជាស្ត្រី និងការផ្តល់ព័ត៌មានពីសេវាមីក្រូហិរញ្ញវត្ថុ និងឥណទានដល់សហគ្រិនជាស្ត្រី ។

៥៥២. នៅក្នុងវិស័យជាយុទ្ធសាស្ត្រទីពីរ ដែលផ្តោតការយកចិត្តទុកដាក់លើ *លើកកម្ពស់ការអប់រំដល់ស្ត្រីនិងក្មេងស្រី និងការផ្លាស់ប្តូរ ឥរិយាបថនិងអាកប្បកិរិយាដល់ស្ត្រីនិងក្មេងស្រី ក្រសួងកិច្ចការនារី* សហការយ៉ាងជិតស្និតជាមួយ ភាគីដែលមានចំណែកពាក់ព័ន្ធ ទាំងអស់ នឹងផ្តោតលើសកម្មភាពសំខាន់ៗ ដូចខាងក្រោម :

- ការលើកកម្ពស់ការអប់រំ ក្នុងនិងក្រៅប្រព័ន្ធ ដល់ស្ត្រី និងក្មេងស្រី តាមរយៈ ការបង្កើនការយល់ដឹងជាសាធារណៈ ពីតម្លៃនិងសារសំខាន់នៃការអប់រំក្មេងស្រីនៅតាមសហគមន៍ និងក្នុងកម្មវិធីផ្សព្វផ្សាយ នានា ការពង្រីកកម្មវិធីអប់រំកុមារតូច និងមត្តេយ្យសហគមន៍នៅតាមតំបន់ដាច់ស្រយាល ការលើកកម្ពស់ការយល់ដឹងពីសារសំខាន់នៃការអប់រំដល់មាតាបិតានិងគ្រួសារ ការពង្រីកកម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលរួមមាន ទាំងកម្មវិធីអក្ខរកម្ម បំណិនជីវិត និងវិជ្ជាជីវៈដល់ស្ត្រីពេញវ័យ និងក្មេងស្រី ដែលគ្មានលទ្ធភាពបន្តការសិក្សា ការផ្តល់មធ្យោបាយសមស្រប និងរក្សាសុវត្ថិភាពដល់សិស្ស-និស្សិតនារី ក្នុងការទទួលបានការអប់រំពេញលេញ និងការពង្រីកកម្មវិធីអាហារូបករណ៍នៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ។
- ការលើកកម្ព*ស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ* ដើម្បីបង្កើនភាពសុខដុមរមនានៅក្នុងគ្រួសារ និងសង្គម តាមរយៈ ការអនុវត្ត*កម្មវិធីជាតិស្តីពី ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ* ការបង្កើនការយល់ដឹងជាសាធារណៈ និងការចាត់វិធានការ ទប់ស្កាត់នូវការរីករាលដាល អំពើពាលាអាវ៉ាសែ និងវីដេអូអាសអាភាស ។

៥៥៣. នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៣ ដែលផ្តោតការយកចិត្តទុកាដាក់លើ *ការការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី ក្រសួងកិច្ចការនារី* ដោយមានសហការយ៉ាងជិតស្និទ្ធ ជាមួយភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់នឹងផ្តោតលើសកម្មភាពសំខាន់ៗ ដូចខាងក្រោម :

- ការពង្រឹងកិច្ចការពារផ្លូវច្បាប់ ដើម្បីប្រឆាំងរាល់ទម្រង់នៃការរើសអើងលើស្ត្រី និងកុមារ រួមទាំង អំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ អំពើអាសអាភាស អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម និងការដាក់ពិន័យអ្នករំលោភបំពាន តាមរយៈ ការអនុវត្ត *ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ* និង *ច្បាប់ប្រឆាំងនឹងការជួញ ដូរមនុស្ស ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី* និង *ផែនការសកម្មភាពជាតិស្តីពី ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ* ការរៀបចំបង្កើតប្រព័ន្ធទិន្នន័យ និងព័ត៌មានស្តីពី រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងកុមារ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មលើកម្លាំងពលកម្មនិងផ្លូវភេទ និងការលើកកម្ពស់ការយល់ដឹង និងការគាំទ្រលើការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ ។
- ការបង្កើនសមត្ថភាពស្ថាប័នពាក់ព័ន្ធ ដើម្បីការការពារតាមផ្លូវច្បាប់ ដល់ជនរងគ្រោះដោយអំពើហិង្សា ការរំលោភផ្លូវភេទ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្ម និងការផ្តន្ទាទោសដល់អ្នកប្រព្រឹត្តបទល្មើស តាមរយៈ ការពង្រឹងសមត្ថភាព និងការបង្កើនការយល់ដឹងដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ត្រីតុលាការ អំពី ច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ និង ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ និងការជួញដូរមនុស្ស ការបង្កើតប្រព័ន្ធទំនាក់ទំនងក្នុងចំណោមអ្នករងគ្រោះ មន្ត្រីនគរបាល មន្ត្រីតុលាការ និងមន្ត្រីសុខាភិបាល ក្នុងការដោះស្រាយនិងឆ្លើយតប នឹងករណីអំពើហិង្សាលើ ស្ត្រីនិងកុមារ និងការជួញដូរមនុស្ស ការបង្កើនចំនួនស្ត្រីជានគរបាល ជាមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងជាមន្ត្រីពន្ធនាគារ ការអភិវឌ្ឍសមត្ថភាពដល់ ភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី និងការជំរុញរៀបចំ និងការអនុវត្តលិខិតបទដ្ឋានចាំបាច់ សម្រាប់អនុវត្ត*ច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី និងកិច្ចការពារជនរងគ្រោះ* តាមរយៈ សេចក្តីសម្រេចរដ្ឋបាល ដីការ ដើម្បីការពារជនរងគ្រោះ ជាដើម ។
- ធ្វើឱ្យប្រសើរឡើងការទទួលបាន និងការផ្តល់សេវាសង្គម និងសុខាភិបាល ដល់ជនរងគ្រោះដោយអំពើហិង្សា ការរំលោភផ្លូវភេទ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម តាមរយៈ ការបង្កើនចំនួនមជ្ឈមណ្ឌលសុវត្ថិភាពនិងជម្រកស្នាក់នៅ និងការអនុវត្ត *ស្តង់ដារជាតិអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស* ការរៀបចំនិងកែសម្រួលឱ្យមានបទដ្ឋានស្តីពីការថែទាំជនរងគ្រោះ និងគោលការណ៍ណែនាំសម្រាប់សេវាសង្គម ដល់ជនរងគ្រោះនៅតាមមជ្ឈ-មណ្ឌល និងការបង្កើនចំនួន និងពង្រឹងសមត្ថភាពមន្ត្រី និងបុគ្គលិកផ្តល់សេវាថែទាំ និងពិគ្រោះយោបល់ ។
- ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្នុងតំបន់ លើការទប់ស្កាត់ និងបង្ក្រាបរាល់ការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងកិច្ចគាំទ្រដល់ជនរងគ្រោះ តាមរយៈ ការអនុវត្តសកម្មភាព និងតាមដានត្រួតពិនិត្យ *ផែនការសកម្មភាពជាតិ* បន្តការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិ និងការប្តេជ្ញាចិត្តនិងផែនការសកម្មភាពថ្នាក់តំបន់ នានា ដូចជា *អនុស្សរណៈនៃការយោគយល់គ្នានៃគណៈកម្មាធិការមហាអនុតំបន់ទន្លេមេគង្គ* ការតាមដានត្រួតពិនិត្យ និងរាយការណ៍ពីការប្តេជ្ញាចិត្តកម្រិត ជាតិនិងអន្តរជាតិ រួមទាំង សម្រាប់អង្គការសហប្រជាជាតិ ។

៥៥៤. នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៤ ដែលផ្តោតការយកចិត្តទុកដាក់លើ *ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ និងទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ដល់ស្ត្រីនិងក្មេងស្រី ក្រសួងកិច្ចការនារី* ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយភាគីដែលមានចំណែកពាក់ពន្ធ័ទាំងអស់ នឹងផ្តោតការយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗ ដូច ខាងក្រោម ៖

- គាំទ្រការធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មាន និងការយល់ដឹងពី សេវាសុខភាពបន្តពូជ នៅតាមសហគមន៍ ជាពិសេស ក្នុងចំណោមស្ត្រីពិការ និងស្ត្រីដែលមានផ្ទៃពោះ ។
- ការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភដល់ស្ត្រី និងកុមារ ឱ្យបានល្អជាងមុន ជាពិសេស ស្ត្រីក្នុងវ័យបន្តពូជ ដោយ ការបង្កើន ការយល់ដឹងពី សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដល់សហគមន៍ តាមរយៈ ការប្រើប្រាស់ឧបករណ៍សម្ភារៈ អប់រំ និងប្រព័ន្ធផ្សព្វផ្សាយ ។
- ការបង្កើនការយល់ដឹងដល់ស្ត្រីនៅសហគមន៍ ក្នុងការបង្ការ ការពារ និងទប់ស្កាត់ជំងឺឆ្លង តាមរយៈ ការអនុវត្តកម្មវិធីផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មានជាមូលដ្ឋាន ពីជំងឺគ្រុនចាញ់ គ្រុនឈាម និងជំងឺផ្សេងទៀត ដែលរាលដាលដោយសារសត្វមូស ដល់អ្នកស្ម័គ្រចិត្ត និងសហគមន៍ គោលដៅ ។
- គាំទ្រ ការឆ្លើយតបនិងទប់ស្កាត់ ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមស្ត្រី និងក្មេងស្រី តាមរយៈ ការសម្របសម្រួល និងសហការក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រស្តីពី ស្ត្រី កុមារី និងមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា និងការបង្កើនការយល់ដឹងនិងការគាំទ្រពីសហគមន៍ ក្នុងការទប់ស្កាត់ការប្រឈមនឹងគ្រោះថ្នាក់របស់ស្ត្រី និងក្មេងស្រី ក្នុងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ។

៥៥៥. នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៥ ដែលផ្តោតការយកចិត្តទុកដាក់លើ *ការជំរុញការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេច នៅក្នុងវិស័យមុខងារសាធារណៈ និងក្នុងវិស័យនយោបាយ ក្រសួងកិច្ចការនារី* ដោយសហការយ៉ាង ជិតស្និត ជាមួយភាគីដែលមានចំណែកពាក់ពន្ធ័ទាំងអស់ នឹងផ្តោតការយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗ ដូចខាងក្រោម ៖

- បង្កើនចំនួនស្ត្រី ក្នុងថ្នាក់ធ្វើសេចក្តីសម្រេច នៃស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ គ្រប់កម្រិត តាមរយៈ ការស្វែងរកការគាំទ្រមតិជាមួយគណបក្សនយោបាយ និងស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនសមាមាត្រស្ត្រីជាបេក្ខជនឈរឈ្មោះ និងមានលំដាប់លេខរៀងខ្ពស់ក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតព្រឹទ្ធសភា តំណាងរាស្ត្រ និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។ ការជំរុញឱ្យមានការពិភាក្សាគោលនយោបាយ និងការបង្កើតយុទ្ធសាស្ត្រ និងសកម្មភាព ស្វែងរកការគាំទ្រមតិក្នុងការអនុវត្តសកម្មភាពជាវិជ្ជមាន និងការកំណត់កូតាសម្រាប់ស្ត្រីនៅគ្រប់កម្រិត ។ ការបង្កើនការយល់ដឹងរបស់សាធារណៈជន ពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅកម្រិតជាន់ខ្ពស់ តំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ។ អភិវឌ្ឍសមត្ថភាពដល់ស្ត្រី ដែលជាប់ឆ្នោត និងដែលត្រូវបានជ្រើសតាំងតំណាងប្រជាពលរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំង ព្រមទាំងបេក្ខនារីដែលនឹងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២ និងតំណាងរាស្ត្រអាណត្តិទី៥ ។

- ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈគ្រប់កម្រិត តាមរយៈ ការជំរុញឱ្យមានការអនុវត្តគោលនយោបាយ និងនីតិវិធីដំឡើងឋានៈ តួនាទី និងជ្រើសរើសមន្ត្រីរាជការ ដែលមានការឆ្លើយតបនឹងសមភាពយេនឌ័រ ។ កិច្ចសហការជាមួយសាលាភូមិន្ទរដ្ឋបាល ក្នុងការរៀបចំកម្មវិធីសិក្សាឆ្លើយតបនឹងយេនឌ័រ និងការបង្កើនចំនួនសិស្សស្ត្រី កិច្ចសហការជាមួយ សមាគមមន្ត្រីរាជការនារី និងដៃគូពាក់ព័ន្ធ ក្នុងការបង្កើនប្រសិទ្ធភាពក្នុងការ បំពេញការងារ និងការការពារសិទ្ធិ និងសុខុមាលភាពរបស់មន្ត្រីរាជការនារី ។ កសាងសមត្ថភាពនិងជំនាញស្តីពី ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ព្រមទាំង ជំនាញពាក់ព័ន្ធនានា ដល់ថ្នាក់ដឹកនាំជាស្ត្រី ។

## កម្មវិធីបញ្ជ្រាបយេនឌ័រ

៥៥៦. *សមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រី* គឺជាគោលដៅអភិវឌ្ឍន៍មួយដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្រសួងកិច្ចការនារី មានតួនាទីយ៉ាងច្បាស់ ក្នុងការស្វែងរកការគាំទ្រមតិ និងតាមដានពីវឌ្ឍនភាពលើការងារទាំងនេះ ប៉ុន្តែ យន្តការ និងវិធីសាស្ត្រ សម្រាប់ជំរុញឱ្យសម្រេចគោលដៅអភិវឌ្ឍន៍នេះ គឺជាការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ពន្ធ័ ទាំងអស់ និងពុំមែនជាភារកិច្ចរបស់ក្រសួងកិច្ចការនារីតែឯកឯងនោះទេ ព្រោះបញ្ហាយេនឌ័រគឺជាបញ្ហាអន្តរវិស័យ ដែលទាមទារឱ្យមានការបញ្ជ្រាបទៅក្នុងគ្រប់ដំណើរការ និងគោលនយោបាយតាមវិស័យទាំងអស់ ។

- *ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយជាតិ និងប្រព័ន្ធស្ថិតិជាតិ* ផ្តោតជាសំខាន់លើ (១) ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការ រៀបចំ តាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយជាតិ និងគោលនយោបាយតាមវិស័យ (២) ការពង្រឹង និងពង្រីកយន្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៣) ការអភិវឌ្ឍសមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រដល់ក្រសួង-ស្ថាប័នពាក់ពន្ធ័ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៤) ការស្វែងរក ការគាំទ្រមតិ ការបញ្ចុះបញ្ចូល ឱ្យធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងដំណើរនៃការរៀបចំផែនការ ការរៀបចំថវិកា និងការរៀបចំរបាយការណ៍ (៥) ពង្រឹងការរៀបចំ និងអនុវត្តផែនការបញ្ជ្រាបយេនឌ័រតាមវិស័យ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធស្ថិតិជាតិ ។
- *ការបញ្ជ្រាបយេនឌ័រក្នុងវិស័យអាទិភាពនានា* ដោយផ្តោតជាពិសេសលើ ការបញ្ជ្រាបយេនឌ័រតាម តាមរយៈ ក្រុមការងារបញ្ជ្រាបយេនឌ័រ និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ នៅក្រសួង-ស្ថាប័នពាក់ពន្ធ័ ។ ការងារបញ្ជ្រាបយេនឌ័រនេះ ដំណើរការតាមវិស័យមួយចំនួន ដូចខាងក្រោម :
  - ➢ *វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* តាមរយៈ ការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្នុងគោលនយោបាយនិងសេវាផ្សេងទៀត សម្រាប់ កាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ការគ្រប់គ្រងវិស័យដីធ្លីនិងធនធានធម្មជាតិ និងការការពារសិទ្ធិនិងសុខុមាលភាពរបស់កម្មការិនី រួមទាំង សេដ្ឋកិច្ចរបស់ស្ត្រី នៅក្នុងវិស័យក្រៅប្រព័ន្ធ ។

- *វិស័យអប់រំ* តាមរយៈ ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការជាតិស្តីពី ការអប់រំសម្រាប់ទាំងអស់គ្នា ដើម្បីកែលម្អនូវប្រសិទ្ធភាពការអនុវត្តគោលនយោបាយនេះ និងឆ្លើយតបនឹងសមាភាពយេនឌ័រ ដូចជា ការបង្កើនសមាសភាពនិងសមត្ថភាពគ្រូបង្រៀនជាស្ត្រី ការបង្កើនអត្រាគង់វង្សរបស់កុមារីនៅក្នុងសាលា ជាពិសេស ចាប់ពីថ្នាក់ទី៩ ឡើងទៅ និងបញ្ចូលបញ្ហាសមភាពយេនឌ័រ ទៅក្នុងការពិភាក្សាពីគោលនយោបាយអប់រំ ដោយរួមទាំង ការអប់រំសម្រាប់កុមារពិការស្ត្រី និងកុមារីជាជនជាតិដើមភាគតិច ជាដើម ។
- *វិស័យច្បាប់* តាមរយៈ (១) ការស្វែងរកការគាំទ្រមតិ ក្នុងការរៀបចំ និងអនុម័ត សេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន និងវិសោធនកម្មច្បាប់ ចាំបាច់នានា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការពារសិទ្ធិស្ត្រី (២) រៀបចំការសិក្សាស្រាវជ្រាវ និងការជំរុញឱ្យមានពិភាក្សាកម្រិតគោលនយោ-បាយ ដើម្បីជំរុញការទទួលបានការការពារផ្លូវច្បាប់ សម្រាប់ស្ត្រីពិការ និងស្ត្រីជនជាតិភាគតិច ។
- *វិស័យសុខាភិបាល* តាមរយៈ ការស្វែងរកការគាំទ្រមតិ និងការតាមដានត្រួតពិនិត្យ ដើម្បីបង្កើនការទទួលបានសេវាសុខភាព និងសុខភាពបន្តពូជ ជាពិសេស បញ្ហាមរណភាពមាតា និងការបង្កើនការទទួលបាននូវសេវាពន្យារកំណើតទំនើប ការបង្កើនការទទួលបានទឹកស្អាតនិងអនាម័យ និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយ ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។

- *ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា* តាមរយៈ ការស្វែងរកការគាំទ្រមតិ និងការតាមដានត្រួតពិនិត្យ ការរៀបចំនិងអនុវត្តកម្មវិធីកំណែទម្រង់ជាតិដែលឆ្លើយតបនឹងយេនឌ័រ រួមទាំងកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ) កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។
- *ការជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និងអនុសញ្ញាផ្សេងៗទៀតក្នុងតំបន់ ដែលទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រនិងសិទ្ធិស្ត្រី* តាមរយៈ ការគាំទ្រការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹងអំពីអនុសញ្ញាទាំងនេះ ការតាមដានត្រួតពិនិត្យ និងរាយការណ៍ពីការអនុវត្ត ហើយចំពោះ*អនុសញ្ញាអន្តរជាតិស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី* ធ្វើការផ្សព្វផ្សាយនូវសេចក្តីសន្និដ្ឋានរួមនានា ដែលមាននៅក្នុងរបាយការណ៍ផ្លូវការផ្តល់ដោយរដ្ឋជាភាគី ។ *ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី* គឺជាស្ថាប័នដឹកនាំ ក្នុងការងារនេះ ។

## ផ្នែកអន្តរវិស័យ នៃការគ្រប់គ្រងយុទ្ធសាស្ត្រផ្ទៃក្នុង ការអភិវឌ្ឍសមត្ថភាព និងការធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពជំនួយ

៥៩៧. ចំពោះផ្នែកអន្តរវិស័យ *ក្រសួងកិច្ចការនារី* នឹងផ្តោតការយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗ មួយចំនួនដូចជា ការអភិវឌ្ឍប្រព័ន្ធទំនាក់ទំនងនិងព័ត៌មានខាងក្នុងនិងខាងក្រៅ ឱ្យមានប្រសិទ្ធភាពនិងមានភាពស័ក្តិសិទ្ធិ ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងការអនុវត្តគោលការណ៍គ្រប់គ្រងដែលផ្តោតលើលទ្ធផល ការរៀបចំផែនការ

ដែលមានគុណភាព ការរៀបចំថវិកានិងរបាយការណ៍ទៅតាម តម្រូវការរបស់ *រាជរដ្ឋាភិបាលកម្ពុជា* និងការប្តេជ្ញាចិត្តក្នុងតំបន់និងអន្តរជាតិ ធ្វើការវាយតម្លៃសមត្ថភាព និងរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពសម្រាប់ *ក្រសួងកិច្ច-ការនារី* ដើម្បីចូលរួមដោយមានប្រសិទ្ធភាពក្នុងការពិភាក្សា នៃ*គណៈកម្មាធិការសម្របសម្រួលរវាងដៃគូអភិវឌ្ឍន៍និងរាជរដ្ឋាភិបាលកម្ពុជា* តាមរយៈ *ក្រុមការងារបច្ចេកទេសយេនឌ័រ* និង ការជំរុញការលើកម្ពស់ ភាពជាដៃគូនិងការសម្របសម្រួលលើការងារលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី ។

៥៥៨. *ក្រសួងកិច្ចការនារី* បានកំណត់សូចនាករនិងចំណុចដៅសំខាន់ៗ សម្រាប់ *ក្រសួងកិច្ចការនារី* ដូចមានបង្ហាញជូន ក្នុងតារាងទី២៣ ខាងក្រោម ៖

**តារាងទី២៣ ៖ សូចនាករនិងចំណុចដៅយេនឌ័រ**

| | គោលដៅសំខាន់ៗ: ចំណុចដៅ/សូចនាករ | ២០០៨ | ២០១០ ចំណុចដៅ | ២០១៣ ចំណុចដៅ |
|---|---|---|---|---|
| **សមធម៌យេនឌ័រ** | | | | |
| **១** | **បញ្ជ្រាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន**[១] | | | |
| ក | ក្រសួង និងស្ថាប័នពាក់ព័ន្ធ បានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ | ១៥ | ២០ | ២៧ |
| ខ | ក្រសួង និងស្ថាប័នពាក់ព័ន្ធបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ | ១០ | ១៥ | ២៧ |
| **២** | **ការចូលរួមរបស់ស្ត្រីនៅក្នុងការងារទទួលប្រាក់កម្រៃគ្រប់វិស័យ**[១] **(ភាគរយ)** | | | |
| | *កសិកម្ម* | ៥២.៥ | ៥០ | ៥០ |
| | *ឧស្សាហកម្ម* | ៥៣.៥ | ៥០ | ៥០ |
| | *សេវាកម្ម* | ២៧ | ៣៧ | ៥០ |
| **៣** | **បង្កើនកម្រិតនៃការយល់ដឹងពីអំពើហិង្សាលើស្ត្រីថាជាឥរិយាបថខុសឆ្គង និងជាបទឧក្រិដ្ឋ**[១] **(%)** | ៣០[២] | ៥០ | ៧០ |
| ក | ចំនួនដីកាការពារ ដែលបានចេញដោយតុលាការ ដោយយោងតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ | - | ៤០[២] | ១២០[២] |
| ខ | ចំនួនជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលបានការប្រឹក្សាយោបល់ពីភ្នាក់ងារជំនាញ | ៦០០[២] | ៩០០[២] | ២០០០[២] |
| **៤** | **ការទប់ស្កាត់អំពើជួញដូរមនុស្ស**[៣] | | | |
| *ក* | *វិធានការគោលនយោបាយ ត្រូវបានអនុម័ត ដើម្បីការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស* | | | |
| | - សមាមាត្រទីជម្រកដែលបានអនុវត្តបទដ្ឋានអប្បបរមា | ០ | ៣០ | ៧០ |
| | - សមមាត្រភ្នាក់ងារសង្គមរបស់មន្ទីរសង្គមកិច្ច ដែលបានទទួលការបណ្តុះ | ០ | ៣០ | ៧០ |

| | គោលដៅសំខាន់ៗ: ចំណុចដៅ/សូចនាករ | ២០០៨ | ២០១០ ចំណុចដៅ | ២០១៣ ចំណុចដៅ |
|---|---|---|---|---|
| | បណ្តុល អំពីការប្រើប្រាស់បទដ្ឋានអប្បបរមាប្រកបដោយប្រសិទ្ធភាព | | | |
| ខ | *ចំនួនភាពជាដៃគូ ដែលបានបង្កើតឡើងដើម្បីប្រឆាំងការជួញដូរមនុស្ស* | | | |
| | - ចំនួនអនុស្សរណៈយោគយល់គ្នា ដែលបានចុះហត្ថលេខាព្រមព្រៀង សម្រាប់កិច្ចសហប្រតិបត្តិការប្រចាំតំបន់ និងឆ្លងប្រទេស | ២ | ៤ | ៥ |
| | - ចំនួនស្ថាប័ននៅក្នុងប្រទេស ដែលបានបង្កើតឡើងដើម្បីទប់ស្កាត់ការជួញដូរមនុស្ស | ០ | - | ៣ |
| | - ចំនួនខេត្តដែលបង្កើតរចនាសម្ព័ន្ធស្ថាប័នពហុភាគី ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស | ៣ | ៨ | ១២ |
| ៥ | **កាត់បន្ថយគម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ ( ភាគរយ)[៤]** | | | |
| ក | សមាមាត្រស្ត្រីជាសមាជិការដ្ឋសភា | ២២ | ២៤ | ៣០ |
| ខ | សមាមាត្រស្ត្រីជារដ្ឋមន្ត្រី | ៧,៧ | ១២ | ១៥ |
| គ | សមាមាត្រស្ត្រីជាគណៈអភិបាលខេត្ត | ១៦,៨ | - | ២៨ |
| ឃ | សមាមាត្រស្ត្រីជាអភិបាលខេត្ត | ០ | ៦ | ១០ |
| ង | សមាមាត្រស្ត្រីជាចៅក្រម | ៦,៩ | ១០ | ១៥ |
| ច | សមាមាត្រស្ត្រីជាប្រធានក្រុមប្រឹក្សាឃុំសង្កាត់ | ៤ | - | ១០ |
| ឆ | សមាមាត្រស្ត្រីជាមន្ត្រីរាជការក្នុងស្ថាបន័សាធារណៈ | ៣៤ | ៣៥ | ៣៨ |

**សម្គាល់ :**

[១] សូចនាករចាស់ដែលមានក្នុងតារាង៣.២ នៃ *របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨ នៃការអនុវត្ត ផយអជ* ។

[២] ចំណុចដៅថ្មី ដែលបានកែសម្រួលដោយមានការព្រមព្រៀងពី *ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌* និង *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* តាមរយៈ កិច្ចប្រជុំក្រុមការងារ បច្ចេកទេសយេនឌ័រនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ។

[៣] សូចនាករនិងចំណុចដៅថ្មី ដែលបានទទួលការព្រមព្រៀងពី *ក្រសួងមហាផ្ទៃ* និង *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* តាមរយៈ កិច្ចប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ។

[៤] សូចនាករថ្មី ដែលបានទទួលការព្រមព្រៀងពីគ្រប់ភាគីទាំងអស់ នៅក្នុង *ក្រុមការងារបច្ចេកទេសយេនឌ័រ* ដើម្បីឱ្យបានស្របតាម *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ។

## ៦.៤ ការអនុវត្តគោលនយោបាយជាតិប្រជាជន

## ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤

៥៥៩. លទ្ធផលចុងក្រោយនៃ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា* ដែលបានរៀបចំឡើង នៅខែមីនា ឆ្នាំ២០០៨ បង្ហាញថា ប្រជាជនកម្ពុជាសរុប មានចំនួន ១៣,៤លាននាក់ ដែលក្នុងនោះ ភាគរយនៃស្ត្រី ក្នុងចំណោមប្រជាជនទាំងអស់មាន ៥១,៤ភាគរយ ប្រជាជនរស់នៅតំបន់ទីប្រជុំជនមាន ១៩,៥ភាគរយ និងប្រជាជនដែលរស់នៅតំបន់ជនបទ មាន ៨០,៥ភាគរយ ។ ទិន្នន័យនេះ បង្ហាញថា អត្រាកំណើនមធ្យមប្រចាំឆ្នាំរបស់ប្រជាជនកម្ពុជា មានកម្រិត ១,៥៤ភាគរយ នៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ។ សមិទ្ធផលចម្បងៗ នៃការការអនុវត្ត

គោលនយោបាយជាតិប្រជាជន រួមមាន (១) ភាគច្រើននៃស្ត្រី មានការយល់ដឹងពីការពន្យារកំណើត (២) អត្រាបង្កើតកូនសរុប បានថយចុះពី ៤,០ ក្នុងឆ្នាំ២០០០ មកត្រឹម ៣,៤ នៅក្នុងឆ្នាំ២០០៥ និង (៣) ចំនួនកូនតាមចំណង់ជាមធ្យមក្នុងស្ត្រីម្នាក់ មាន ៣,៣ ដែលនឹងបណ្តាលឱ្យទំហំគ្រួសារជាមធ្យម មានការថយចុះ ។

៥៦០. នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការបញ្ចូលគោលនយោបាយជាតិប្រជាជន ទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធី សេដ្ឋកិច្ច-សង្គមកិច្ច នៅគ្រប់កម្រិតទាំងអស់ ។

៥៦១. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តដាក់ឱ្យប្រើប្រាស់ នូវ វិធានការចាំបាច់នានា ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន តាមរយៈ ការអភិវឌ្ឍនៅក្នុងវិស័យ អប់រំ សុខាភិបាល សមភាពយេនឌ័រ អភិវឌ្ឍន៍ជនបទ ដែលជាវិស័យអាទិភាព ។ ដោយមានប្រជាជនវ័យក្មេង អាយុតិចជាង ២៤ឆ្នាំ ប្រមាណ ៥៤,១ភាគរយ នោះប្រការសំខាន់ និងចាំបាច់ ត្រូវអនុម័តនូវវិធានការនានា ដើម្បីដាក់បញ្ចូលយុវជនទាំងនោះ ទៅជាកម្លាំងនាំមុខដ៏សំខាន់ សម្រាប់ការអភិវឌ្ឍ នៅគ្រប់វិស័យទាំងអស់ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងពង្រឹងការគ្រប់គ្រង តំបន់ទីប្រជុំជន និងប្រមូលផ្តុំប្រជាជនច្រើន ដើម្បីធ្វើឱ្យទីក្រុងស្អាតគ្មានសំរាម មានអនាម័យពេញលេញ មានអាកាសធាតុបរិសុទ្ធ មានសួនច្បារពណ៌ខៀវស្រងាត់និងមានកន្លែងសម្រាប់ហាត់ប្រាណចម្រុះ និងរៀបចំការកម្សាន្តបែបវប្បធម៌ជាសាធារណៈ ដើម្បីលើកកម្ពស់គុណភាពនៃសុខភាព និងសីលធម៌ ។

## ខ. សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៥៦២. គ្រប់ក្រសួង-ស្ថាប័នទាំងអស់ សុទ្ធតែដើរតួក្នុងការអនុវត្តគោលនយោបាយជាតិប្រជាជនរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្រសួង-ស្ថាប័ន ដែលសកម្ម ក្នុងការអនុវត្តគោលនយោបាយ រួមមាន : *វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ* ដែលមានភារកិច្ចក្នុងការប្រមូលទិន្នន័យប្រជាជនជាប្រចាំ និងរៀបចំវិភាគទិន្នន័យទាំងនោះ *អគ្គនាយកដ្ឋានផែនការ នៃក្រសួងផែនការ* មានភារកិច្ចធានាថា រាល់បញ្ហាប្រជាជន នឹងត្រូវបានដោះស្រាយ នៅក្នុងដំណើរការនៃការរៀបចំផែនការ រួមទាំង បញ្ហាប្រជាជនទាំងឡាយដែលស្ថិតនៅកម្រិតក្រសួង-ស្ថាប័នពាក់ព័ន្ធ *គណៈកម្មាធិការជាតិ ដើម្បីប្រជាជន និងការអភិវឌ្ឍ នៃទីស្តីការគណៈរដ្ឋមន្ត្រី* មានភារកិច្ច គាំទ្រ និងជំរុញ បញ្ហាគោលនយោបាយជាតិប្រជាជន ។ នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នទាំងនោះនឹងផ្តោតជាសំខាន់ លើ :

- ការពង្រឹងសមត្ថភាព អ្នករៀបចំគោលនយោបាយ សមាជិកសភា អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តោតការយកចិត្តទុកដាក់លើ ទិន្នន័យ និងការវិភាគពីបញ្ហាសំខាន់ៗ ទាក់ទងនឹង ប្រជាជន និងភាពក្រីក្រ ។

- ការរៀបចំការណែនាំ សម្រាប់បញ្ចូលអថេរសំខាន់ៗ ទាក់ទងនឹងប្រជាជន និងភាពក្រីក្រ ទៅក្នុងគ្រប់កម្មវិធីអភិវឌ្ឍន៍ទាំងអស់ ។
- ការពង្រឹងសមត្ថភាព ដល់មន្ត្រីរៀបចំផែនការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចូលបញ្ហាប្រជាជន ទៅក្នុងដំណើរការរៀបចំផែនការ ។
- ការពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីកំណត់ឡើងពីបញ្ហាប្រជាជន តាមរយៈ ការវិភាគដោយទ្វេងទាត់ និងតាមដានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម គោលនយោបាយប្រជាជន ។
- ការរៀបចំ និងផ្សព្វផ្សាយ ទិន្នន័យប្រជាជន ដែលបានបំបែក នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ការបន្តការងារ *អង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០១០* និង *អង្កេតពាក់កណ្តាលជំរឿន ឆ្នាំ២០១៣* ទៅតាមពេលវេលាដែលបានកំណត់ ។
- ការបញ្ចូលអថេរ ប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងភាពក្រីក្រ ទៅក្នុងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត*គោលនយោបាយជាតិប្រជាជន ផយអជ គអសគ របាយការណ៍តាមវិស័យ និងផែនការតាមវិស័យ និងផែនការថ្នាក់ក្រោមជាតិ* ។
- ការកសាងសមត្ថភាពដល់ អ្នករៀបចំផែនការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីប្រើប្រាស់ទិន្នន័យស្តីពី ប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងភាពក្រីក្រ ក៏ដូចជា ប្រើប្រាស់ទំនាក់ទំនងរបស់កត្តាទាំងនេះ ជាមួយនឹង ការរៀបចំ កម្មវិធីនិងផែនការអភិវឌ្ឍន៍ និងការធ្វើរបាយការណ៍ស្តីពីការអនុវត្ត ផែនការនិងកម្មវិធីទាំងនោះ ។
- ការរៀបចំគោលការណែនាំ ស្តីពី ការប្រើប្រាស់ទិន្នន័យ និងអថេរប្រជាជន ដែលត្រូវបញ្ចូលទៅក្នុងផែនការ និងកម្មវិធីអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ ការរៀបចំផែនការនិងកម្មវិធីអភិវឌ្ឍន៍ដោយចីរភាព និងដើម្បីរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ផែនការនិងកម្មវិធីអភិវឌ្ឍន៍ទាំងនោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ការរៀបចំកម្រងឯកសារបណ្តុះបណ្តាល និង ឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការបំផុសឱ្យមានការយល់ដឹងពី បញ្ហា ប្រជាជន សុខភាពបន្តពូជ យេនឌ័រ ភាពក្រីក្រ និងទំនាក់ទំនងនៃបញ្ហាទាំងនេះ ជាមួយនឹងការអភិវឌ្ឍ ។
- ការបង្កើនការយល់ដឹង និងការបណ្តុះបណ្តាល ដល់និស្សិតនៅក្នុងសកលវិទ្យាល័យ ពីបញ្ហា ប្រជាជន សុខភាពបន្តពូជ យេនឌ័រ ភាពក្រីក្រ និងទំនាក់ទំនងនៃបញ្ហាទាំងនេះ ជាមួយនឹងការអភិវឌ្ឍ ។
- ការស្រាវជ្រាវ និងការផ្សព្វផ្សាយពី តម្រូវការ និងបញ្ហាផ្សេងៗ ទាក់ទងនឹងបញ្ហាប្រជាជន ដល់ *រាជរដ្ឋាភិបាល* និង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។
- ការស្រាវជ្រាវដើម្បីបំពេញតម្រូវការលើទិន្នន័យស្តីពី បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងភាពក្រីក្រ ។

# ជំពូកទី៥

# តម្លៃដែលត្រូវចំណាយ ធនធាន និង ការកំណត់កម្មវិធីចំណាយ

៥៦៣. *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តពង្រឹងនិងពង្រីក ទំហំនៃភាពជាដៃគូ នៅក្នុងរង្វង់ក្រសួង-ស្ថាប័នរបស់ *រាជរដ្ឋាភិបាល* ជាមួយនឹង ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសនិងអន្តរជាតិ និង អង្គការសង្គមស៊ីវិលផ្សេងៗទៀត ដើម្បីឱ្យប្រជាជនកម្ពុជាទទួលបានផលប្រយោជន៍ជាអតិបរមាពីធនធាន ដែលមានសម្រាប់កម្មវិធីអភិវឌ្ឍន៍ ។ លទ្ធផលដ៏សំខាន់មួយ ដែលជាអាទិភាពចម្បងរបស់ *រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវសម្រេចឱ្យបាននូវ (១) កំណើនយ៉ាងខ្លាំងនៃការផ្ទេរពិត នូវធនធានសម្រាប់អភិវឌ្ឍន៍ ដល់ប្រជាជនដែលជាអ្នកត្រូវទទួលផលប្រយោជន៍ ជាពិសេស ប្រជាជនជនងាយរងគ្រោះ និងគ្រួសារក្រីក្រ នៅជនបទ និង (២) សមត្ថភាពរឹងមាំ នៃស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់នូវ កម្មវិធីនិងសេវាកម្មនានា ប្រកបដោយប្រសិទ្ធភាព* ។

៥៦៤. *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងដំណើរការការងារជាក់ស្តែងមួយចំនួន ដើម្បីពង្រឹងនិងធ្វើឱ្យប្រសើរឡើងនូវ *ដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍* រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់*រាជរដ្ឋាភិបាល* នៅក្នុងក្របខ័ណ្ឌនៃ *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ។ ដើម្បីធានាការលើកកម្ពស់ នូវការបន្សុីធនធានហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ទៅនឹងអាទិភាពរបស់*ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ស្ថាប័នស្នូលរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដែលទទួលបន្ទុក ការងារសម្របសម្រួលជំនួយ និង ការវិភាជ/ការប្រើប្រាស់*ជំនួយអភិវឌ្ឍន៍ផ្លូវការ* នឹងចាត់ចែងអនុវត្តការងារជាក់ស្តែងមួយចំនួន ក្នុងការពង្រឹងបន្ថែមទៀត នូវការងារសម្របសម្រួលជាមួយ ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល នានា ដើម្បីបង្កើនគណនេយ្យភាពនិងតម្លាភាព ក្នុងការប្រើប្រាស់ធនធានហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលអាចមាន ។

## ៥.១ តម្រូវការផ្នែកការវិនិយោគសាធារណៈ

៥៦៥. ដើម្បីប្រមូលព័ត៌មាន តាមវិធីសាស្ត្រ *ពីក្រោមឡើងលើ* ស្តីពីតម្រូវការចំណាយវិនិយោគសាធារណៈសម្រាប់អនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* (គម្រោងកំពុងដំណើរការ និង គម្រោងដែលមានអាទិភាពខ្ពស់) *ក្រសួងផែនការ* បានស្នើសុំឱ្យ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងអស់ផ្តល់ព័ត៌មានអំពី តម្រូវការចំណាយសម្រាប់កម្មវិធីវិនិយោគសាធារណៈ របស់ខ្លួន សម្រាប់ ឆ្នាំ ២០០៩-២០១៣ ។ ប៉ុន្តែជាក់ស្តែង វិធីសាស្ត្រ *ពីក្រោមឡើងលើ* នេះ មិនអាចអនុវត្តបានទេ ដោយហេតុថា មានតែក្រសួងមួយចំនួនតូច

ប៉ុណ្ណោះ ដែលអាចផ្តល់ព័ត៌មានបាន ទៅតាមតម្រូវការ[១] ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹង បន្តពង្រឹង និង កែលម្អ ដំណើរការការងារផែនការនិងការវិភាជធនធាន ហើយ សមត្ថភាពរបស់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងត្រូវ លើកកម្ពស់បន្ថែមទៀត ដើម្បីធានាឱ្យមាននូវទិន្នន័យទាំងឡាយ ដែលចាំបាច់សម្រាប់ ការងារផែនការអភិវឌ្ឍន៍ និងការវិភាជធនធាន សម្រាប់វិនិយោគសាធារណៈ ។ *កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១១-២០១៣* នឹងត្រូវរៀបចំ ដោយផ្អែកលើវិធីសាស្ត្រមួយ ដែលអាចជួយសម្រួលដល់ ការធ្វើសុខដុមនីយកម្ម *កម្មវិធីវិនិយោគសាធារណៈ* ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ។ *កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១១-២០១៣* នឹងត្រូវធ្វើការរៀបចំឱ្យបានចប់សព្វគ្រប់ នៅក្នុងរង្វង់ពេលវេលា ដែល *ក្រសួងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* រៀបចំ *ច្បាប់ថវិកា ឆ្នាំ២០១១* ។

៥៦៦. *ជំពូកទី ៣ : "ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣"* បង្ហាញពី ការវិភាគនិងការព្យាករអំពី កត្តាម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និង *"វិនិយោគមូលធន "* ដែលនឹងបានមកពីវិស័យសាធារណៈ និង វិស័យឯកជន ដើម្បីធ្វើឱ្យសម្រេចបាន នូវអត្រាកំណើនសេដ្ឋកិច្ច ដែលបានគ្រោងទុក ។ ទោះជាដូចនេះក្តី វិធីសាស្ត្រ *ពីលើចុះក្រោម* នេះ មិនបានដាក់បញ្ចូលនូវតម្រូវការទាំងអស់ ទេ : (១) ចំណាយវិនិយោគលើវិស័យសាធារណៈ សម្រាប់វិស័យសង្គមកិច្ច ដែលចាំបាច់សម្រាប់ការធ្វើឱ្យសម្រេចបាននូវ គោលដៅសង្គម-សេដ្ឋកិច្ចទាំងឡាយរបស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* (២) ចំណាយសម្រាប់ការពង្រឹងសមត្ថភាពស្ថាប័នរបស់ *រាជរដ្ឋាភិបាលកម្ពុជា* និង (៣) ចំណាយសម្រាប់ជួយសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចពិភពលោក មកលើ សេដ្ឋកិច្ចកម្ពុជា និង ក្រុមជនងាយរងគ្រោះនិងអ្នកក្រ ។ ទោះជាដូចនេះក្តី ក៏ការប៉ាន់ស្មាននូវតម្រូវការវិនិយោគ "មូលធន" ដោយប្រើប្រាស់ វិធីសាស្ត្រ *ពីលើចុះក្រោម* នេះ ពិតជាអាចរំលេចឡើងនូវតម្រូវការវិនិយោគសរុប សម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខ ។

៥៦៧. ដើម្បីធ្វើឱ្យអ្នកអានទូទៅងាយយល់ព័ត៌មាន ដែលបានបង្ហាញនៅក្នុង*ជំពូកទី៣* ស្តីពីការព្យាករអំពីតម្រូវការវិនិយោគ "មូលធន" សម្រាប់រយៈពេល៥ឆ្នាំ (២០០៩-២០១៣) ខាងមុខ នឹងត្រូវយកមកបង្ហាញ ដោយសង្ខេបជាថ្មីម្តងទៀត ដូចខាងក្រោម ។ ដើម្បីសម្រេចបាននូវចំណុចដៅនៃកំណើនសេដ្ឋកិច្ច ជារួមនិងតាមវិស័យ នៅក្នុងដំណាក់កាល *ផយអជ បច្ចុប្បន្នកម្ម (២០០៩-២០១៣)* ថវិកាវិនិយោគសរុបដែលត្រូវការជាចាំបាច់ មានប្រមាណ ៦២ ០២០,៧ពាន់លានរៀល (ស្មើនឹង ១៥,១២៧ពាន់លានដុល្លារអាមេរិក) ។ ហិរញ្ញប្បទានដល់វិនិយោគមូលធនសរុប មកពីប្រភពវិស័យឯកជននិងវិស័យសាធារណៈ អាចមាន ដូចខាងក្រោម :

- វិនិយោគមូលធនរបស់វិស័យឯកជន អាចមានប្រមាណ ៤៤ ៤៨០,១ ពាន់លានរៀល (ស្មើនឹង ១០,៨៤៨ ពាន់លានដុល្លារអាមេរិក) ហើយ ស្មើនឹង ៧១,៧ ភាគរយ នៃវិនិយោគមូលធនសរុប ។

[១] ការកែលម្អវិធីសាស្ត្រនៃការធ្វើផែនការ ត្រូវបានរំលេច នៅក្នុង កឋាខ័ណ្ឌទី១០ ។

- វិនិយោគមូលធនរបស់វិស័យសាធារណៈ អាចមានប្រមាណ ១៧ ៥៤០,៦ ពាន់លានរៀល (ស្មើនឹង ៤,២៧៨ ពាន់លានដុល្លារអាមេរិក) ហើយ ស្មើនឹង ២៨,៣ ភាគរយ នៃវិនិយោគមូលធនសរុប ។

៥៦៨. ហិរញ្ញប្បទានដល់វិនិយោគមូលធនសរុប មកពីប្រភពក្នុងស្រុកនិងក្រៅប្រទេស អាចមាន ដូចខាងក្រោម ៖

- ហិរញ្ញប្បទានពីប្រភពក្នុងស្រុក អាចមានប្រមាណ ៣៤ ៨៤៩,០ ពាន់លានរៀល (ស្មើនឹង ៨,៤៩៩ ពាន់លានដុល្លារអាមេរិក) ហើយ ស្មើនឹង ៥៦,២ ភាគរយ នៃវិនិយោគមូលធនសរុប ។
- ហិរញ្ញប្បទានពីប្រភពក្រៅប្រទេស អាចមានប្រមាណ ២៧ ១៧១,៧ ពាន់លានរៀល (ស្មើនឹង ៦,៦២៧ ពាន់លានដុល្លារអាមេរិក) ហើយ ស្មើនឹង ៤៣,៨ ភាគរយ នៃវិនិយោគមូលធនសរុប ។

## តារាងទី២៤ ៖ ការវិនិយោគមូលធនចាំបាច់ ដើម្បីសម្រេចបានកំណើនផលិតផលសរុបក្នុងស្រុកដែលបានគ្រោងទុក និង ធនធានដែលអាចមាន សម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ឆ្នាំ ២០០៩-២០១៣

(គិតជា ពាន់លានរៀល)*

| ប្រភពហិរញ្ញប្បទាន | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប ២០០៩-២០១៣ |
|---|---|---|---|---|---|---|
| **វិនិយោគមូលធនសរុប** | **៩ ៩១៤,៦** | **១១ ៣០៧,៥** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦២ ០២០,៧** |
| **• វិនិយោគមូលធនរបស់វិស័យសាធារណៈ** | **២ ៩១៧,១** | **៣ ២៩០,៨** | **៣ ៤៤៨,២** | **៣ ៧៧០,៦** | **៣ ១១៣,៩** | **១៧ ៥៤០,៦** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧៣៧,៧ | ៧៦២,៦ | ៧៩៩,១ | ៨៧៣,៨ | ៩៥៣,៤ | ៤ ១២៦,៧ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ២ ១៧៩,៤ | ២ ៥២៨,១ | ២ ៦៤៩,១ | ២ ៨៩៦,៧ | ៣ ១៦០,៥ | ១៣ ៤១៣,៩ |
| **• វិនិយោគមូលធនរបស់វិស័យឯកជន** | **៦ ៩៩៧,៥** | **៨ ០១៦,៨** | **៨ ៩៤៦,៧** | **៩ ៧៩៣,៩** | **១០ ៧២៥,៣** | **៤៤ ៤៨០,១** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៤ ៨៨៧,២ | ៥ ៥៥៩,៦ | ៦ ១៧៣,៦ | ៦ ៧៤១,១ | ៧ ៣៦០,៧ | ៣០ ៧២២,៣ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ២ ១១០,៣ | ២ ៤៥៧,១ | ២ ៧៧៣,១ | ៣ ០៥២,៧ | ៣ ៣៦៤,៦ | ១៣ ៧៥៧,៨ |
| **វិនិយោគមូលធនសរុប** | **៩ ៩១៤,៨** | **១១ ៣០៧,៥** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦០ ២០០,៧** |
| • វិនិយោគមូលធនរបស់វិស័យសាធារណៈ | ២ ៩១៧,១ | ៣ ២៩០,៨ | ៣ ៤៤៨,២ | ៣ ៧៧០,៦ | ៤ ១១៣,៩ | ១៧ ៥៤០,៦ |
| • វិនិយោគមូលធនរបស់វិស័យឯកជន | ៦ ៩៩៧,៥ | ៨ ០១៦,៨ | ៨ ៩៤៦,៧ | ៩ ៧៩៣,៨ | ១០ ៧២៥,៣ | ៤៤ ៤៨០,១ |
| **វិនិយោគមូលធនសរុប** | **៩ ៩១៤,៦** | **១១ ៣០៧,៥** | **១២ ៣៩៤,៩** | **១៣ ៥៦៤,៤** | **១៤ ៨៣៩,២** | **៦២ ០២០,៧** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៥ ៦២៥,០ | ៦ ៣២២,៣ | ៦ ៩៧២,៧ | ៧ ៦១៤,៩ | ៨ ៣១៤,១ | ៣៤ ៨៤៩,០ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ៤ ២៨៩,៦ | ៤ ៩៨៥,២ | ៥ ៤២២,២ | ៥ ៩៤៩,៥ | ៦ ៥២៥,១ | ២៧ ១៧១,៧ |
| **វិនិយោគមូលធនរបស់វិស័យសាធារណៈ** | **២ ៩១៧,១** | **៣ ២៩០,៨** | **៣ ៤៤៨,២** | **៣ ៧៧០,៦** | **៤ ១១៣,៩** | **១៧ ៥៤០,៦** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧៣៧,៧ | ៧៦២,៦ | ៧៩៩,១ | ៨៧៣,៨ | ៩៥៣,៤ | ៤ ១២៦,៧ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស** | ២ ១៧៩,៤ | ២ ៥២៨,១ | ២ ៦៤៩,១ | ២ ៨៩៦,៧ | ៣ ១៦០,៥ | ១៣ ៤១៣,៩ |

*ប្រភព* ៖ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

* តួលេខជាប្រាក់រៀលនៅក្នុងតារាងនេះ ត្រូវបានគណនាចេញពីការព្យាករជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យម ៤ ១០០រៀល/១ដុល្លារអាមេរិក ។

** គិតតែវិនិយោគមូលធនប៉ុណ្ណោះ ដោយមិនគិតបញ្ចូលនូវ ជំនួយបច្ចេកទេស ។

៥៦៩. ការអនុវត្ត ប្រកបដោយជោគជ័យនិងទាន់ពេលវេលា នូវគោលនយោបាយអាទិភាពទាំងឡាយ របស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ព្រមទាំង ការធ្វើឱ្យសម្រេចបាននូវចំណុចដៅទាំងឡាយរបស់ផែនការនេះ ទាមទារឱ្យមាន ការវិនិយោគបន្ថែមជាច្រើនទៀត ដែលមានសារប្រយោជន៍ និង ដែលមានការតម្រង់ទិសចំគោលដៅ និងការប្រើប្រាស់ ដោយផ្តោតចំទិសដៅ និង ប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ។ ការវិនិយោគបែបនេះ គួរតែត្រូវធ្វើឡើងដោយវិស័យទាំងពីរ គឺ ដោយ*វិស័យឯកជន* ដើម្បីទ្រទ្រង់និងជំរុញ កំណើនសេដ្ឋកិច្ច និង ពិពិធ-ភាវូបនីយកម្មមូលដ្ឋានសេដ្ឋកិច្ច ជាពិសេស ពិពិធភាវូបនីយកម្មសេដ្ឋកិច្ចជនបទ និង ដោយ*វិស័យសាធារណៈ* ដើម្បីផ្តល់នូវការគាំទ្រដែលមានកិច្ចសហការគ្នាល្អ សំដៅពង្រីកនិងធ្វើពិពិធភាវូបនីយកម្ម មូលដ្ឋានសេដ្ឋកិច្ច ជាពិសេសពិពិធភាវូបនីយកម្មសេដ្ឋកិច្ចជនបទ ដើម្បី : (១) កាត់បន្ថយភាពក្រីក្រនៅជនបទ (២) សម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចពិភពលោក ដែលមានទៅលើក្រុមជនងាយរងគ្រោះនិងអ្នកក្រ និងសេដ្ឋកិច្ចជាតិទាំងមូល (៣) គាំទ្រដល់ការពង្រីកនិងការផ្តល់ ប្រកបដោយប្រសិទ្ធភាពនូវសេវាសង្គមកិច្ច សំដៅឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* និង (៤) ពង្រឹងសមត្ថភាពនៃស្ថាប័នរបស់ *រាជរដ្ឋាភិបាលកម្ពុជា*ក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាកម្ម ប្រកបដោយប្រសិទ្ធភាព ។

៥៧០. វិនិយោគមូលធនដោយឯកជនពីបរទេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍនានា ទូទាំងពិភពលោក នៅតែមានភាពមិនច្បាស់លាស់ ដោយសារ វិបត្តិហិរញ្ញវត្ថុពិភពលោក និង ភាពមិនច្បាស់លាស់នៃស្ថានភាពសេដ្ឋកិច្ច របស់បណ្តាប្រទេសជឿនលឿន ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងអនុវត្តវិធានការនានា ដើម្បីលើកទឹកចិត្តដល់ការធ្វើហិរញ្ញប្បទានដោយវិស័យឯកជន ដល់សកម្មភាពសេដ្ឋកិច្ចនានា ពីប្រភពវិស័យហិរញ្ញវត្ថុក្នុងស្រុក ដើម្បីធានាបាននូវតម្រូវការវិនិយោគមូលធនរបស់វិស័យឯកជន ។ កម្រិតនៃកម្ចីពីស្ថាប័នហិរញ្ញវត្ថុ សម្រាប់វិនិយោគរយៈពេលវែង នៅតែមានកម្រិតទាបខ្លាំងនៅឡើយ ។ មួយផ្នែកធំនៃបញ្ញើជាប្រាក់ដុល្លារ តាមបណ្តាធនាគារពាណិជ្ជនៅកម្ពុជា នៅតែមិនទាន់មានទំហំធំល្មម សម្រាប់ការវិនិយោគនៅទូទាំងប្រទេស បាននៅឡើយ ហើយមួយចំនួននៃបញ្ញើទាំងនេះ ត្រូវបានយកទៅវិនិយោគ នៅកន្លែងផ្សេង ថែមទៀត ។ ដូច្នេះ ការប្រើប្រាស់ធនធាននៃវិស័យហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា គឺជាអាទិភាពចម្បងមួយ ហើយ អាចសម្រេចទៅបាន តាមរយៈ ការបង្កើនតម្រូវការនៃការវិនិយោគក្នុងស្រុក ។

៥៧១. ការផ្តោតជាសំខាន់នៃជំពូកនេះ គឺប្រភពធនធានដែលអាចមានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។ តម្រូវការសរុបនៃការវិនិយោគរបស់វិស័យសាធារណៈ រួមបញ្ចូលនូវ :

- តម្រូវការវិនិយោគមូលធន សម្រាប់វិស័យសាធារណៈ ។
- ធនធានដែលត្រូវការជាចាំបាច់ ដើម្បីផ្តល់ការគាំទ្រដែលមានគោលដៅច្បាស់លាស់ ដល់ការអភិវឌ្ឍនិងការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ សំដៅកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និងដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមាន នៃវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចពិភពលោក ទៅលើក្រុមជនងាយរងគ្រោះ និងអ្នកក្រ ។

- ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រីកសេវាសង្គមកិច្ច សំដៅឈានទៅសម្រេចបាននូវ ចំណុចដៅទាំងឡាយនៃ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ។
- ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រឹងសមត្ថភាពនៃស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការបង្កើតកម្មវិធី និងការផ្តល់នូវសេវាកម្ម ប្រកបដោយប្រសិទ្ធភាព ។

៥៧២. *រាជរដ្ឋាភិបាល* បានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈ ដែលអាចមានតម្លៃប្រមាណ *២៥ ៧៤០,៦ ពាន់លានរៀល (ស្មើនឹង ៦,២៧៨ ពាន់លានដុល្លារអាមេរិក)* ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ។ តម្លៃប៉ាន់ស្មាននេះ រួមបញ្ចូលនូវ : *(១)* តម្រូវការវិនិយោគមូលធនសម្រាប់វិស័យសាធារណៈ ដែលអាចមានប្រមាណ *១៧ ៥៤០,៦ពាន់លានរៀល (ស្មើនឹង ៤ ២៧៨,២ ពាន់លានដុល្លារអាមេរិក) (២) ធនធានដែលត្រូវការជាចាំបាច់ ដើម្បីផ្តល់ការគាំទ្រដែលមានគោលដៅច្បាស់លាស់ ដល់ការអភិវឌ្ឍនិងការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ សំដៅកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និង ផ្តល់ការគាំទ្របន្ទាន់ដល់ការសម្រាលផលប៉ះពាល់អវិជ្ជមាន នៃវិបត្តិហិរញ្ញវត្ថុនិងឱនភាព សេដ្ឋកិច្ចពិភពលោក ទៅលើក្រុមជនងាយរងគ្រោះនិងអ្នកក្រ* ដែលអាចមានប្រមាណ *៤ ១០០,០ ពាន់លានរៀល (ស្មើនឹង ១ ពាន់លានដុល្លារអាមេរិក) (៣) ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រីកសេវាសង្គមកិច្ច សំដៅឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលអាចមានប្រមាណ *២ ០៥០,០ ពាន់លានរៀល (ស្មើនឹង ៥០០លានដុល្លារអាមេរិក)* និង *(៤) ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាកម្មប្រកបដោយប្រសិទ្ធភាព* ដែលអាចមានប្រមាណ *២ ០៥០,០ពាន់លានរៀល (ស្មើនឹង ៥០០លានដុល្លារអាមេរិក)* ។

### តារាងទី២៥ : ចំណុចដៅនៃការកៀរគរធនធាន សម្រាប់ការវិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០០៩-២០១៣

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០០៩-២០១៣ | |
|---|---|---|
| | ពាន់លានរៀល | ពាន់លានដុល្លារអាមេរិក |
| ១. វិនិយោគមូលធន របស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ១៧ ៥៤០,៦ | ៤,២៧៨ |
| ២. ការគាំទ្រដែលមានគោលដៅច្បាស់លាស់ ដល់ការអភិវឌ្ឍនិងពិពិធភាវូបនីយកម្មសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និង ដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងឱនភាព សេដ្ឋកិច្ចពិភពលោក ដែលមានផលប៉ះពាល់ ទៅលើជនងាយរងគ្រោះនិងអ្នកក្រ | ៤ ១០០,០ | ១,០០០ |
| ៣. ការពង្រីកសេវាសង្គមកិច្ច ដើម្បីឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ *គអសក* | ២ ០៥០,០ | ០,៥០០ |
| ៤. ការគាំទ្រដល់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការបង្កើតកម្មវិធី និងការផ្តល់នូវសេវាកម្ម ប្រកបដោយប្រសិទ្ធភាព | ២ ០៥០,០ | ០,៥០០ |
| ***សរុប*** | ***២៥ ៧៤០,៦*** | ***៦,២៧៨*** |

## ៥.២ ប្រភពធនធានដែលអាចមាន សម្រាប់ការធ្វើហិរញ្ញប្បទានដល់ចំណាយវិនិយោគសាធារណៈ

៥៧៣. ដោយផ្អែកលើ *ក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម រាជរដ្ឋាភិបាលកម្ពុជា* បានវិភាជថវិកាប្រមាណ *៤ ១២៦,៧ ពាន់លានរៀល (ស្មើនឹង ១,០០៦ ពាន់លានដុល្លារអាមេរិក)* សម្រាប់ចំណាយមូលធនរបស់វិស័យសាធារណៈ ដែលនឹងអាចជួយទាក់ទាញហិរញ្ញប្បទានពី ដៃគូអភិវឌ្ឍន៍ជាប្រពៃណីនិងមិនមែនប្រពៃណី និងវិស័យឯកជន ដើម្បីអនុវត្តបណ្តុំគម្រោងអាទិភាពរបស់ *រាជរដ្ឋាភិបាល* នៅក្នុង *នីតិកាលទី៤នៃរដ្ឋសភា* ។ តម្លៃលម្អៀងនៃតម្រូវការវិនិយោគសរុបរបស់វិស័យសាធារណៈ *(តម្រូវការវិនិយោគសរុប - ហិរញ្ញប្បទានក្នុងស្រុកដោយរាជរដ្ឋាភិបាល = ២៥ ៧៤០,៦ - ៤ ១២៦,៧)* ដែលមានប្រមាណជាង *២១ ៦១៣,៩ ពាន់លានរៀល ស្មើនឹង ៥,២៧១ ពាន់លានដុល្លារអាមេរិក* សម្រាប់រយៈពេលប្រាំឆ្នាំ ២០០៩-២០១៣ ឬ ប្រមាណ *៤ ៣២១ ពាន់លានរៀល (ស្មើនឹង ១,០៥៤ ពាន់លានដុល្លារអាមេរិក)* ក្នុងមួយឆ្នាំ អាចត្រូវបានធ្វើហិរញ្ញប្បទាន ពីប្រភព ដូចខាងក្រោម :

- ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសជាប្រពៃណី (ភាគច្រើន ពីដៃគូអភិវឌ្ឍន៍ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) ។
- កម្ចីសម្បទានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ភាគច្រើនពី *ស្ថាប័នហិរញ្ញវត្ថុពហុភាគី* និងទ្វេភាគី សំខាន់ៗ) ។
- ធនធានពីប្រភពដៃគូអភិវឌ្ឍន៍មិនមែនប្រពៃណី (ជំនួយឥតសំណង និងកម្ចីពាក់កណ្តាលសម្បទាន) ។
- ចំណូលថ្មីៗដែលអាចបានមកពី ការអភិវឌ្ឍឧស្សាហកម្មអាជីវកម្មរ៉ែ (ប្រេង ឧស្ម័ន និងធនធានរ៉ែ) នៅពេលដែលអាជីវកម្មនេះ ត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម ។

៥៧៤. *រាជរដ្ឋាភិបាលកម្ពុជា* មានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដែលមានប្រមាណ *៤ ៣២១ ពាន់លានរៀល (ស្មើនឹង ១,០៥៤ ពាន់លានដុល្លារអាមេរិក)* ក្នុងមួយឆ្នាំ អាចនឹងទទួលបាន ពីការបន្តគាំទ្រពីដៃគូអភិវឌ្ឍន៍ជាប្រពៃណីនិងមិនមែនប្រពៃណី និងពីចំណូលបន្ថែមថ្មីពី ប្រេង ឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះ ត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។

៥៧៥. ដោយផ្អែកលើកិច្ចព្រមព្រៀងនៃភាពជាដៃគូរវាង ប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍ នៅក្នុងវេទិការបស់ *អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍/គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ រាជរដ្ឋាភិបាលកម្ពុជា* ចង់ឃើញដៃគូអភិវឌ្ឍន៍បង្កើតកម្មវិធីសកម្មភាពបន្ទាន់ ក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ តាមរយៈ *"ការគាំទ្រថវិកា"* ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តការងារដែលមានលក្ខណៈអាចវាស់វែងបាន ជាបរិមាណនិងគុណភាពនៅក្នុងវិស័យជ្រើសរើសនីមួយៗ ។ ការប្រកាន់យកនូវវិធីសាស្ត្រ *ការគាំទ្រថវិកា* អាចផ្តល់សារៈប្រយោជន៍ ក្នុងបីរូបភាព : (១) វិធីសាស្ត្រនេះ នឹងបង្កើនភាពជាម្ចាស់និងភាពជាអ្នកដឹកនាំរបស់ *រាជរដ្ឋាភិបាលកម្ពុជា* លើអាទិភាពគោលនយោបាយ និងកម្មវិធី នៃការអភិវឌ្ឍ (២) *ការគាំទ្រថវិកា* នឹងអាចធ្វើឱ្យមាន ការតាមដានត្រឹមត្រូវជាងមុន

និងតម្លាភាពក្នុងការងារគណនេយ្យ ក្នុងការប្រើប្រាស់ជំនួយពីបរទេស និង (៣) *ការគាំទ្រថវិកា* នឹងលើកកម្ពស់ការគ្រប់គ្រងនិងគណនេយ្យភាព តាមរយៈ យន្តការដែលមានលក្ខណៈប្រជាធិបតេយ្យ ក្នុងការទទួលនិងប្រើប្រាស់ថវិកាពីបរទេស ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តផ្តល់សារៈសំខាន់លើ ការឈានទៅរកអនុវត្ត *ការគាំទ្រថវិកា* ដែលជាយន្តការដ៏សមស្របបំផុត សម្រាប់ផ្តល់ការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។

៥៧៦. ដើម្បីពង្រឹង ការតម្រឹមនិងសុខដុមនីយកម្ម នូវកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយនឹង អាទិភាពទាំងឡាយរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ រាជរដ្ឋាភិបាលកម្ពុជា* ជំរុញឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ ផ្តល់ការគាំទ្រដល់ការរៀបចំឱ្យមានការគ្រប់គ្រងតាម *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* នៅក្នុងវិស័យសំខាន់ៗមួយចំនួន និងផ្តល់ជំនួយរបស់ខ្លួន តាមរូបភាពមួយដែលមានកិច្ចសម្របសម្រួលគ្នា ដើម្បីអនុវត្ត *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* សំដៅឈានទៅសម្រេចបាននូវ ការពួតផ្តុំកម្លាំងគ្នាប្រកបដោយសង្គតិភាព និងការចៀសវាងបាននូវការអនុវត្តត្រួតគ្នា ។ *រាជរដ្ឋាភិបាលកម្ពុជា* ទទួលស្គាល់ថា ដំណើរការការងាររបស់ *ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ចាំបាច់ត្រូវតែ ពិនិត្យឡើងវិញនិងពង្រឹង ដើម្បីអនុវត្តភារកិច្ចដ៏សំខាន់ ខាងលើនេះ ។

៥៧៧. *រាជរដ្ឋាភិបាលកម្ពុជា* នឹងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងយន្តការ *ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ដែលមាននៅពេលបច្ចុប្បន្ននេះ សំដៅបង្កើនប្រសិទ្ធភាព ជាពិសេស ប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ព្រមទាំង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ក៏ដូចជា ដើម្បីលុបបំបាត់កង្វល់ពីបន្ទុកបន្ថែមនៃការចូលរួមនៅក្នុង *ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ដោយក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងស្ថាប័នដៃគូអភិវឌ្ឍន៍ ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងពិនិត្យសិក្សាអំពី ជម្រើសទាំងអស់ក្នុងនោះ រួមមាន :

- ការកម្រិតនូវចំនួនសមាជិកនៃដៃគូអភិវឌ្ឍន៍ នៅក្នុង *ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ឱ្យនៅត្រឹមតែដៃគូអភិវឌ្ឍន៍ទាំងឡាយណា ដែលផ្តល់ហិរញ្ញប្បទានដល់វិស័យដែលពាក់ព័ន្ធនឹងក្រុមការងារបច្ចេកទេសនោះ ។ ចំណែកឯដៃគូអភិវឌ្ឍន៍មួយចំនួនផ្សេងទៀត អាចធ្វើការសម្រេចចិត្តចូលរួមកិច្ចប្រជុំរបស់ *ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ក្នុងឋានៈជាអ្នកសង្កេតការណ៍ ។
- ដើម្បីបង្កើនគុណភាពនៃការពិភាក្សា នៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ *រាជរដ្ឋាភិបាលកម្ពុជា* ចង់ឃើញមានការចូលរួមរបស់មន្ត្រី ដែលមានគុណសម្បត្តិផ្នែកបច្ចេកទេសគ្រប់គ្រាន់ ក្នុងការផ្តល់គាំទ្រដល់វិស័យដែលពាក់ព័ន្ធនឹងក្រុមការងារនីមួយៗ ហើយ ការចូលរួមរបស់មន្ត្រីដែលទើបចូលបម្រើការងារថ្មី គ្មានបទពិសោធន៍គ្រប់គ្រាន់ និងមន្ត្រីរដ្ឋបាល មិនមែនជាប្រការ ដែលគួរលើកទឹកចិត្តឱ្យមាន នោះទេ ។

*រាជរដ្ឋាភិបាលកម្ពុជា* លើកទឹកចិត្តយ៉ាងខ្លាំង ដល់ដៃគូអភិវឌ្ឍន៍ ឱ្យទាញយកអត្ថប្រយោជន៍ពី ទីប្រឹក្សាបច្ចេកទេសទាំងឡាយ ដែលត្រូវបានស្វែងរក ឱ្យមកបម្រើការងារ នៅក្នុងវិស័យពាក់ព័ន្ធនឹងក្រុមការងារបច្ចេកទេស ដោយហិរញ្ញប្បទានរបស់ខ្លួន ដោយតម្រូវឱ្យទីប្រឹក្សាបច្ចេកទេសទាំងនោះ មកធ្វើការងារដោយផ្ទាល់ នៅក្នុងប្រទេស ។ អត្ថប្រយោជន៍នៃវិធីសាស្ត្រដែលបានលើក ឡើងសម្រាប់ស្ថាប័នដៃគូអភិវឌ្ឍន៍ គឺធ្វើការលុបបំបាត់បាននូវការចំណាយបន្ថែមទៀតសម្រាប់ ជ្រើសរើសមន្ត្រីបន្ថែម ដើម្បីចូលរួមនៅក្នុងការងារ របស់ក្រុមការងារបច្ចេកទេសចម្រុះ ។

៥៧៨. កិច្ចព្រមព្រៀងកម្រិតខ្ពស់មួយ ថ្នាក់ពិភពលោក ស្ដីពីភាពដៃគូ ត្រូវបានបង្កើតឡើង ដើម្បីជួយដល់បណ្ដាប្រទេសក្រីក្រ ឆ្ពោះទៅសម្រេចបាន *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* និង ដើម្បីផ្ដល់ធនធាន ដែលតម្រូវការសម្រាប់គោលបំណងនេះ ។ នៅក្នុងស្មារតីនៃភាពជាដៃគូកម្រិតសាកលនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តជំរុញដៃគូអភិវឌ្ឍន៍ ឱ្យយកចិត្តទុកដាក់ខ្ពស់ក្នុងការធានាថា ជំនួយរបស់ខ្លួន នឹងត្រូវតម្រឹមយ៉ាងពេញលេញ មកជាមួយនឹង *ផយអជ បច្ចុប្បន្នកម្ម* សំដៅសម្រេចបាននូវគោលនយោបាយអាទិភាពទាំងឡាយរបស់ *រាជរដ្ឋាភិបាល* នៅក្នុងកម្រិតនៃការអនុវត្តជាក់ស្តែង ហើយមិនមែនគ្រាន់តែ នៅក្នុងកម្រិតគោលនយោបាយឬគោលទស្សនៈ រួមៗប៉ុណ្ណោះទេ ។ ទន្ទឹមនឹងនេះ *រាជរដ្ឋាភិបាលកម្ពុជា* ជំរុញដៃគូអភិវឌ្ឍន៍ ឱ្យ (១) ធ្វើការបំបែរឱ្យបានលឿន នូវធនធានទាំងឡាយចេញពី ការងារមានអាទិភាពតិច ដែលឥឡូវនេះកំពុងទទួលហិញ្ញប្បទាន (២) ធ្វើការប្រឹងប្រែងយ៉ាងខ្លាំងដើម្បីកាត់បន្ថយឱ្យបានច្រើននូវរូបភាពខុសៗគ្នានៃ "ជំនួយទោល" ហើយ យកចិត្តទុកដាក់ខ្ពស់ ក្នុងការសម្រេចឱ្យបាននូវ "*ការផ្ទេរពិត* " នៃធនធានអភិវឌ្ឍន៍ ឱ្យបានទៅដល់ អ្នកត្រូវទទួលផលប្រយោជន៍ទាំងឡាយ ជាក្រុមជនងាយរងគ្រោះនិងអ្នកក្រ និង (៣) ធ្វើការពង្រឹងសមត្ថភាពរបស់ស្ថាប័ននៃ*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការបង្កើតកម្មវិធីនិងការផ្ដល់នូវសេវាកម្ម ប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវចំណុចដៅទាំងឡាយរបស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ។

## ៥.៣ ការកំណត់កម្មវិធីចំណាយ : ចំណាយវិនិយោគសាធារណៈ និង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍

៥៧៩. ដូចបានគូសបញ្ជាក់ខាងលើ *រាជរដ្ឋាភិបាល* កំពុងចាត់វិធានការជាក់លាក់មួយចំនួន ដើម្បីពង្រឹង និងកែលម្អ ការធ្វើសុខដុមនីយកម្មនូវ ការងារផែនការ ការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងការបែងចែកនិងប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ។ *ក្រុមការងារដឹកនាំ* កិច្ចការនេះ ដែលមានសមាសភាពមកពីស្ថាប័នកណ្ដាលបួន ហើយដឹកនាំដោយ *ក្រសួងផែនការ* ត្រូវបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌនៃ *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ។ *ក្រុមការងារដឹកនាំ* កិច្ចការនេះ មានភារកិច្ច ដូចខាងក្រោម :

- ពិនិត្យឡើងវិញនូវ តួនាទីរបស់ក្រសួង-ស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* ព្រមទាំង យន្តការនិងនីតិវិធីនានា ដែលពាក់ព័ន្ធនឹង ដំណើរការនៃការងារផែនការសម្រាប់ការគ្រប់គ្រង និងដំណើរការនៃ ការគ្រប់គ្រង ការសម្របសម្រួល និងការអនុវត្ត ចំណាយវិនិយោគសាធារណៈ និងហិរញ្ញប្បទានសហ-ប្រតិបត្តិការអភិវឌ្ឍន៍ ។
- លើកឡើងនូវវិធានការ ក្នុងការធ្វើសុខដុមនីយកម្មនូវ ចំណាយវិនិយោគសាធារណៈ និង ការបែងចែក និងប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់ជាមួយគ្នាទៅវិញទៅមក សំដៅរៀបចំនូវផែនការចំណាយថវិកាជាតិមួយ ឱ្យមាន លក្ខណៈសមស្របនិងទូលំទូលាយគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពជាមួយនឹង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* និង *យុទ្ធសាស្ត្រតាមវិស័យ* ដូចមានចែងនៅក្នុង *ផែនការសកម្មភាពស្តីពី សុខដុមនីយកម្មការតម្រឹម និង លទ្ធផល* និង *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*។

៥៨០. ដូចបានលើកឡើងនៅក្នុងជំពូកទី៣ *រាជរដ្ឋាភិបាលកម្ពុជា* កំពុងពង្រឹងទំនាក់ទំនង រវាងដំណើរការទាំងឡាយដែល : (១) កំណត់តម្រូវការវិនិយោគសាធារណៈដែលមានអាទិភាពខ្ពស់ ដែលបានដាក់បញ្ចូលទៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល (២) កៀរគរធនធានក្រៅប្រទេស ពី ដៃគូអភិវឌ្ឍន៍ប្រពៃណី និងមិនមែនប្រពៃណី (៣) រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រក្នុងការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការរៀបចំកញ្ចប់ថវិកាសម្រាប់វិនិយោគសាធារណៈ ដែលជាឧបករណ៍មួយ សម្រាប់ដំណើរការ និងការផ្តល់ហិរញ្ញប្បទានដល់ ការអនុវត្តគោលនយោបាយអាទិភាព ដែលមានចែងនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ដំណើរការនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល នឹងត្រូវបានពង្រឹង ដើម្បីធានាថា : (១) តម្រូវការចំណាយចរន្តបន្ថែម នៃគម្រោងដែលបានស្នើឡើង ដែលពាក់ព័ន្ធជាមួយថវិកាប្រចាំឆ្នាំ គឺជាផ្នែកដ៏សំខាន់មួយនៃព័ត៌មានដែលបានប្រមូលនៅក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល និង (២) គម្រោងទាំងឡាយដែលដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ត្រូវបានធ្វើចំណាត់ថ្នាក់អាទិភាព (ក្រសួង-ស្ថាប័នទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* នឹងធ្វើចំណាត់ថ្នាក់អាទិភាពចំពោះគម្រោងទាំងឡាយរបស់ខ្លួន ហើយ ក្រសួង-ស្ថាប័នទាំងនោះនឹងស្វែងរកធនធាន សម្រាប់អនុវត្តគម្រោង នៅក្នុងដំណាក់កាលនៃកម្មវិធីវិនិយោគសាធារណៈ ដោយគិតគូរដល់ស្ថានភាពរួមនៃម៉ាក្រូសេដ្ឋកិច្ច និងស្ថានភាពនៃប្រភពធនធានក្រៅប្រទេសដែលត្រូវកៀរគរ ដោយផ្អែកលើស្ថាន-ការណ៍ថ្មីៗ ។

៥៨១. *រាជរដ្ឋាភិបាលកម្ពុជា* នឹងធានាថា មានតែកម្មវិធីនិងគម្រោងទាំងឡាយណា ដែលបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ប៉ុណ្ណោះទេ ដែលត្រូវបានយកទៅពិនិត្យពិចារណា សម្រាប់ការធ្វើហិរញ្ញប្បទាន

ក្នុងដំណាក់កាលនៃការរៀបចំ *ក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា* នៅពេលណាដែលគុណភាពនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ត្រូវបានកែលម្អ ។ *រាជរដ្ឋាភិបាលកម្ពុជា* ក៏ធានាផងដែរថា ការកៀរគរធនធាន នឹងត្រូវផ្តោតលើ ការស្វែងរកហិរញ្ញប្បទាន សម្រាប់គម្រោងនិងកម្មវិធីទាំងឡាយ ដែលបានដាក់បញ្ចូលក្នុង *កម្មវិធីវិនិយោគសាធារណៈ* ។ ដើម្បីធានាឱ្យមានការតម្រឹមប្រសើរជាងមុន នូវធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយនឹងអាទិភាពនៃវិនិយោគសាធារណៈរបស់ *រាជរដ្ឋាភិបាលកម្ពុជា* នោះ ក្រសួង-ស្ថាប័នទាំងឡាយ ត្រូវយកទិន្នន័យស្តីពី ការផ្តល់ថវិកាជាក់ស្តែងនិងការផ្តល់ថវិកាគ្រោងទុកជាមុន ដែលត្រូវបានប្រមូលប្រចាំឆ្នាំ ដោយ *រាជរដ្ឋាភិបាលកម្ពុជា* ពីដៃគូអភិវឌ្ឍន៍ ទៅធ្វើការវិភាគ ។ ទិន្នន័យទាំងនេះ នឹងត្រូវផ្តល់ទៅឱ្យក្រសួង-ស្ថាប័ននីមួយៗ ដើម្បីឱ្យក្រសួង-ស្ថាប័ននោះ : (១) ពិនិត្យមើលឡើងវិញនិងផ្ទៀងផ្ទាត់ថា ព័ត៌មានស្តីពីការផ្តល់ថវិកា ដែលត្រូវបានរាយការណ៍ជាព័ត៌មានសម្រាប់ក្រសួង-ស្ថាប័នផ្ទាល់ពិតមែន និង (២) ផ្តល់ព័ត៌មានត្រឡប់ទៅវិញអំពី កម្មវិធីនិងគម្រោងទាំងឡាយ ដែលត្រូវបានផ្តល់ហិរញ្ញប្បទានរួចហើយ ដោយបញ្ជាក់ពី កម្មវិធីនិងគម្រោងទាំងឡាយដែលត្រូវបានតម្រឹម មកជាមួយនឹងអាទិភាពរបស់ *ផយអជ* និង កម្មវិធីនិងគម្រោងទាំងឡាយដែលមិនត្រូវបានតម្រឹម មកជាមួយនឹងអាទិភាពរបស់ *ផយអជ* ។

៥៨២. ការកែលម្អជាលក្ខណៈវិធីសាស្ត្រទាំងអស់នេះ នឹងធានាឱ្យមាន ទំនាក់ទំនងជិតស្និទ្ធរវាង គោលនយោបាយ អាទិភាព សកម្មភាព កម្មវិធី និង គម្រោង ទាំងឡាយរបស់ *រាជរដ្ឋាភិបាល* ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធមានគម្រោងនឹងចាត់ចែងដំណើរការ ដើម្បីអនុវត្តគោលនយោបាយអាទិភាព និង ធនធានវិនិយោគសាធារណៈ ដែលចាំបាច់ សម្រាប់ការអនុវត្តបណ្តាផែនការសកម្មភាពដែលបានលើកឡើង ។ ម្យ៉ាងវិញទៀត វិធីសាស្ត្រនេះ នឹងធ្វើឱ្យមានទំនាក់ទំនងប្រសើរជាងមុន រវាងតម្រូវការវិនិយោគសាធារណៈ ដែលបានកំណត់នៅក្នុងដំណើរការការងារផែនការ និង ថវិកាវិនិយោគសាធារណៈរបស់ *រាជរដ្ឋាភិបាល* និង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលនឹងបង្ហាញពីស្ថានភាពនៃការធ្វើហិរញ្ញប្បទានរយៈពេលមធ្យម សម្រាប់ *រាជរដ្ឋាភិបាល* ក្នុងការអនុវត្ត *ផយអជ* ។ ប្រការទាំងអស់នេះ ក៏នឹងធានាឱ្យមានការលើកកម្ពស់ ផងដែរ នូវប្រសិទ្ធភាពនិងភាពសក្តិសិទ្ធ នៃការវិភាជធនធាន ដោយផ្សារភ្ជាប់ជាមួយ និង ដើម្បី ការធ្វើឱ្យប្រសើរឡើងនូវភាពគ្រប់ជ្រុងជ្រោយនៃថវិកាជាតិ ដែលគ្របដណ្តប់ទាំង ថវិកាសម្រាប់ចំណាយចរន្ត និងចំណាយមូលធន ។

៥៨៣. សម្រាប់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ការវិភាជចំណាយចរន្ត ដោយក្រសួង-ស្ថាប័ន នៅក្នុង *ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម* គឺបានបង្ហាញ នៅក្នុង *តារាងទី១៤* នៃ *ជំពូកទី៣* ។ ការវិភាជចំណាយមូលធន និងចំណាយសម្រាប់វិធានការពិសេសៗ ដើម្បីសម្រាលផលប៉ះពាល់ នៃវិបត្តិហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចពិភពលោកមកលើ សេដ្ឋកិច្ចកម្ពុជា និង ក្រុមជនងាយរងគ្រោះនិងអ្នកក្រ ត្រូវបានបង្ហាញ នៅក្នុង *តារាងទី២៥* ។

## តារាងទី២៦ : ទិន្នន័យរបស់ជំនួយអេជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ តាមវិស័យ

| វិស័យ | បរិមាណវិភាជន៍ | | ភាគរយ | ជនបទ | ភាគរយ | ទីប្រជុំជន | ភាគរយ |
|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក | | | | | |
| **វិស័យសង្គមកិច្ច** | | | | | | | |
| អប់រំ : (ក្នុងនោះ ការអប់រំមូលដ្ឋាន ៦០%) [២] | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ១ ៨៥៣,៣ | ៦០,០ | ១២៣៥,៦ | ៤០,០ |
| បច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៥១៤,៨ | ៥០,០ | ៥១៤,៨ | ៥០,០ |
| សុខាភិបាល | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ២ ១៦២,២ | ៧០,០ | ៩២៦,៧ | ៣០,០ |
| កម្មវិធីដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុពិភពលោកលើជនងាយរងគ្រោះ | ១០២៩,៦ | ២៥១,១ | ៤,០ | ៨២៣,៧ | ៨០,០ | ២០៥,៩ | ២០,០ |
| **សរុប** | **៨ ២៣៧,០** | **២០០៩,០** | **៣២,០** | **៥៣៥៤,០** | **៦៥,០** | **២៨៨៣,០** | **៣៥,៥** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី : ក្រៅពីដំណាំ [៣] | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៩៧៨,១ | ៩៥,០ | ៥១,៥ | ៥,០ |
| ដំណាំតាមរដូវ : ស្រូវ និង ផ្សេងៗ | ១ ០២៩,៦ | ២៥១,១ | ៤,០ | ១ ០២៩,៦ | ១០០ | ០,០ | ០,០ |
| អភិវឌ្ឍន៍ជនបទ [៤] | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ៣ ០៨៨,៩ | ១០០ | ០,០ | ០,០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម [៥] | ១ ០២៩ ៦ | ២៥១,១ | ៤,០ | ៤១១,៨ | ៤០,០ | ៦១៧,៨ | ៦០,០ |
| **សរុប** | **៦ ១៧៧,៧** | **១ ៥០៦,៨** | **២៤,០** | **៥ ៥០៨,៤** | **៨៩,២** | **៦៦៩,៣** | **១០,៨** |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរ) [៦] | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ១ ៥៤៤,៤ | ៥០,០ | ១,៥៤៤,៥ | ៥០,០ |
| ទឹក និងអនាម័យ (មិនគិតនៅជនបទ) [៧] | ១ ០២៩,៦ | ២៥១,១ | ៤,០ | ២៥៧,៤ | ២៥,០ | ៧៧២,២ | ៧៥,០ |
| ថាមពល និងអគ្គិសនី [៨] | ១ ០២៩ ៦ | ២៥១,១ | ៤,០ | ៥១៤,៨ | ៥០,០ | ៥១៤,៨ | ៥០,០ |
| ប្រៃសណីយ និងទូរគមនាគមន៍ [៩] | ២៥៧,៤ | ៦២,៨ | ១,០ | ១២៨,៧ | ៥០,០ | ១២៨,៧ | ៥០,០ |
| **សរុប** | **៥ ៤០៥,៥** | **១ ៣១៨,៤** | **២១,០** | **២ ៤៤៣,៣** | **៤៥,២** | **២ ៩៦២,២** | **៥៤,៨** |
| **សេវាកម្ម និងកម្មវិធីអន្តរវិស័យ** | | | | | | | |
| ការបញ្ជ្រាបយេនឌ័រ [១០] | ៣៨៦,១ | ៩៤,២ | ១,៥ | ១១៥,៧ | ៣០,០ | ២៧០,៤ | ៧០,០ |
| ទេសចរណ៍ | ៥១៤,៨ | ១២៥,៦ | ២,០ | ១២៨,៧ | ២៥,០ | ៣៨៦,១ | ៧៥,០ |
| បរិស្ថាន និងការអភិរក្ស [១១] | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៩២៦,៨ | ៩០,០ | ១០២,៨ | ១០,០ |
| សហគមន៍ និងសេវាកម្មសង្គម | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៧៧២,២ | ៧៥,០ | ២៥៧,៤ | ២៥,០ |
| វប្បធម៌ និងសិល្បៈ | ៣៨៦,២ | ៩៤,២ | ១,៥ | ១៩៣,១ | ៥០,០ | ១៩៣,១ | ៥០,០ |
| អភិបាលកិច្ច និងរដ្ឋបាល [១២] | ២ ០៥៩,២ | ៥០២,២ | ៨,០ | ៨២៣,៧ | ៤០,០ | ១ ២៣៥,៥ | ៦០,០ |
| **សរុប** | **៥ ៤០៥,៥** | **១ ៣១៨,៤** | **២១,០** | **២ ៩៦២,២** | **៥៤,៨** | **២,៤៤៣,៣** | **៤៥,២** |
| មិនទាន់បែងចែក [១៣] | ៥១៤,៨ | ១២៥,៦ | ២,០ | ២៥៧,៤ | ៥០,០ | ២៥៧,៤ | ៥០,០ |
| **សរុបរួម** [១៤] | **២៥ ៧៤០,៦** | **៦ ២៧៨,២** | **១០០,០** | **១៦ ៥២៥,៤** | **៦៤,២** | **៩ ២១៥,២** | **៣៥,៨** |

**កំណត់ពន្យល់ :**

១. ក. បរិមាណតាមវិស័យនីមួយៗ រួមមាន : ធនធានដែលបានមកពីគ្រប់ប្រភពទាំងអស់ : រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ចំណាយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ឬតាមរយៈរាជរដ្ឋាភិបាលកម្ពុជា) ។

ខ. ចំណាយមូលធន ចំណាយចរន្តបន្ថែម ជំនួយបច្ចេកទេស ចំណាយក្នុងការតាមដានត្រួតពិនិត្យ ប្រមូលទិន្នន័យ ការថែរក្សាគេហទំព័រ ។

គ. តួលេខជនបទ-ទីប្រជុំជន ជាតួលេខចង្អុលបង្ហាញជាកំណត់សម្គាល់ និងត្រូវផ្តោតការយកចិត្តទុកដាក់លើ ។

ឃ. បរិមាណទាំងនេះ ក៏រួមបញ្ចូលផងដែរនូវប្រាក់ឧបត្ថម្ភទាំងអស់ទៅថ្នាក់ខេត្ត ស្រុក និងឃុំ ដែលនឹងត្រូវអនុវត្តដោយថ្នាក់ទាំងនោះ ។

២. ក. រួមបញ្ចូលទាំង យុវជន និងកីឡា ។

ខ. ៦០ភាគរយ នៃចំនួនសរុប នឹងត្រូវបែងចែកសម្រាប់ការអប់រំមូលដ្ឋាន ។

៣. រួមបញ្ចូលទាំង ការនេសាទ ការបោសសម្អាតមីន និងសកម្មភាពផ្សេងៗ លើកលែងតែដំណាំ"តាមរដូវ" ហើយមិនរាប់បញ្ចូលព្រៃឈើ ដែលបានបង្ហាញ នៅក្នុងផ្នែកបរិស្ថាននិងការអភិរក្ស ។

៤. ការអភិវឌ្ឍជនបទ : រួមបញ្ចូលទាំង ផ្លូវលំ ទីផ្សារ ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកនិងអនាម័យ ការងារអនុវត្តដោយ *គ.ជ.អ.ប.*។

៥. រួមបញ្ចូលនូវ : មូលដ្ឋានពិពិធកម្មសេដ្ឋកិច្ច ការបង្កើតការងារ និងបញ្ហាកម្លាំងពលកម្ម ។

៦. ដោយមិនរួមបញ្ចូលនូវ : ផ្លូវជនបទ និង ផ្លូវជាតិនិងផ្លូវខេត្ត មានផលប្រយោជន៍ដល់តំបន់ជនបទ ដូច្នេះផ្លូវទាំងពីរប្រភេទនេះមានសមាមាត្រ ៥០ភាគរយ ដែលនឹងត្រូវរួមចំណែកដោយវិស័យឯកជន និងរួមបញ្ចូលចំណាយបន្ថែមលើការថែទាំ ។

៧. មិនរាប់បញ្ចូលនូវសកម្មភាពនៅតំបន់ជនបទ ដែលបានកំណត់នៅក្នុងការអភិវឌ្ឍជនបទ ។

៨. ភាគច្រើនបំផុតនៃការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

៩. ភាគច្រើនបំផុតការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ។

១០ ជាពិសេស សម្រាប់ការបង្កើតការយល់ដឹងនិងការបញ្ជ្រាប ។ វិស័យនីមួយៗផ្សេងទៀត នឹងបញ្ចូលសកម្មភាពនានាទៅក្នុងការងាររបស់គេ ។

១១ រួមបញ្ចូលទាំងព្រៃឈើ ។

១២ រួមបញ្ចូលទាំង :

ក. កំណែទម្រង់ទាំងអស់ ដូចជា កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់សារពើពន្ធ និងកំណែទម្រង់ផ្សេងៗទៀត ។

ខ. ការសិក្សានិងការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចជា ជំរឿនប្រជាជនឆ្នាំ២០០៨ ការវាយតម្លៃភាពក្រីក្រ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* ។ល។

គ. ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ល។

ឃ. ការបោះឆ្នោតនានា ។

ង. សកម្មភាពរដ្ឋបាលសាធារណៈផ្សេងៗទៀត ។

១៣. បរិមាណបម្រុងទុកសម្រាប់បំពេលបន្ថែមពេលមានតម្រូវការ ។

១៤. ភាពខុសគ្នាបន្តិចបន្តួចក្នុងតួលេខសរុបនានា (ជនបទនិងទីប្រជុំជន) និងតួលេខសរុបរួម អាស្រ័យទៅនឹងការតម្រឹមលេខទសភាគ ។

# ជំពូកទី៦

## ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងសូចនាករ-ចំណុចដៅសំខាន់ៗ

៥៨៤. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជាប្រចាំលើសកម្មភាពនានា ដែលអនុវត្តដោយ ក្រសួងនិងស្ថាប័ននានា គឺជា ការងារដ៏មានសារៈសំខាន់មួយ នៃដំណើរការការងារផែនការ ដើម្បីសម្រេចបាននូវ គោលដៅនិងចំណុចដៅទាំងឡាយនៃ បណ្តាគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា* ។ វិធីសាស្ត្រនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃដ៏មានប្រសិទ្ធភាពមួយ ដែល បង្ហាញពីការវាយតម្លៃនូវវឌ្ឍនភាព ទៅតាមពេលវេលាកំណត់ និង រំលេចឡើងនូវបញ្ហាប្រឈមដែលបង្កភាពរាំងស្ទះ ក្នុងការអនុវត្តសកម្មភាព-កម្មវិធី-គម្រោង នានា ដែលបានកំណត់នៅក្នុងផែនការ គឺជា យន្តការផ្តល់ព័ត៌មាន ដ៏សំខាន់មួយសម្រាប់អ្នករៀបចំគោលនយោបាយ និង ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន (អ្នកទទួលខុសត្រូវក្នុងអនុវត្ត សកម្មភាព-កម្មវិធី-គម្រោង នានា ដែលបានកំណត់នៅក្នុងផែនការ) ដើម្បីធ្វើការ តម្រឹមតម្រង់ និង ការកែតម្រូវ ឡើងវិញទៅតាមដំណាក់កាលនីមួយៗ នូវបណ្តាអាទិភាពនៃកិច្ចប្រឹងប្រែងក្នុងការអភិវឌ្ឍ សំដៅសម្រេចបាននូវ គោលដៅនិងទិសដៅដែលបានកំណត់ ។ ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃដែលត្រូវអនុវត្ត អាចចែកចេញជា ពីរប្រភេទដាច់គ្នា ។ *ប្រភេទទីមួយ* រួមបញ្ចូលនូវ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ យ៉ាងទៀងទាត់ លើការអនុវត្តសកម្មភាព-កម្មវិធី-គម្រោង ទាំងឡាយ ដែលត្រូវធ្វើឡើង ដោយក្រសួង-ស្ថាប័ននីមួយៗ ។ របាយការណ៍ស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃ សម្រាប់ប្រភេទទីមួយនេះ ផ្តល់នូវព័ត៌មានសំខាន់អំពី វឌ្ឍនភាព និង បញ្ហាប្រឈមដែលបង្កភាពរាំងស្ទះ ក្នុងការអនុវត្តសកម្មភាពនានា ដែលបានកំណត់នៅក្នុងផែនការ ។ ការលើកឡើងនៃរបាយការណ៍តាមដានត្រួតពិនិត្យនិងវាយតម្លៃ ទាំងនេះ នឹងផ្តល់នូវព័ត៌មានចាំបាច់ ដែលអ្នកគ្រប់គ្រងកម្មវិធីនានាត្រូវការ សម្រាប់ ការតម្រឹមតម្រង់ និង ការកែតម្រូវ ឡើងវិញ នូវបណ្តាអាទិភាពសម្រាប់សកម្មភាពទាំងឡាយដែលត្រូវធ្វើ ដើម្បីសម្រេចបាន នូវ គោលដៅនិងទិសដៅរបស់ សកម្មភាព-កម្មវិធី-គម្រោង ទាំងឡាយ ដែលកំពុងត្រូវបានអនុវត្ត ។ *ប្រភេទទីពីរ* រួមបញ្ចូលនូវ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់ លើវឌ្ឍនភាពក្នុងការសម្រេចបាន នូវ លទ្ធផលរួមនៃការអភិវឌ្ឍ ដែលទទួលបានពីការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ក៏ដូចជា លើការកំណត់នូវបញ្ហាប្រឈមនានា ដែលបានជួបប្រទះ នៅក្នុងការសម្រេចបាននូវលទ្ធផលរួមដែលបានកំណត់ ដោយផ្អែលលើ "*សូចនាករ-ចំណុចដៅ តាមដានត្រួតពិនិត្យសំខាន់ៗ របស់ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣*" ។

៥៨៥. *រាជរដ្ឋាភិបាល* សូមឱ្យ ក្រសួង-ស្ថាប័ន និង ដៃគូអភិវឌ្ឍន៍ ទាំងអស់ ដែលកំពុងធ្វើហិរញ្ញប្បទានដល់សកម្មភាព-កម្មវិធី-គម្រោង នានា ផ្តល់នូវអាទិភាពខ្ពស់ ដល់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ យ៉ាងទៀងទាត់

លើការអនុវត្តផែនការសកម្មភាព សកម្មភាព-កម្មវិធី-គម្រោង ទាំងនោះ ហើយ ផ្ញើរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ មក *ក្រសួងផែនការ* ដើម្បីឱ្យ *ក្រសួងផែនការ* អាចយក ព័ត៌មានដែលបានបង្ហាញ នៅក្នុងរបាយការណ៍ទាំងនោះ ទៅដាក់បញ្ចូលនៅក្នុង ការវាយតម្លៃរួម លើវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅនិងចំណុចដៅ នៃការអភិវឌ្ឍ ដែលមានចែងនៅក្នុង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។

៥៨៦. ការបង្កើតនូវ "*សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ* "ជាផ្នែកមួយ ដ៏សំខាន់នៃដំណើរការការងារផែនការ របស់*ផយអជ* ។ ក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅនេះ ការពិនិត្យឡើងវិញការពិភាក្សា និង ការពិគ្រោះយោបល់ ជាច្រើន លើ *សូចនាករសម្រាប់ការតាមដានត្រួតពិនិត្យ* របស់ *ផយអជ ២០០៦-២០១០* ត្រូវបានរៀបចំធ្វើឡើង ហើយ បទពិសោធន៍ជាច្រើន ត្រូវដកស្រង់បាន ពីក្នុងការងារតាមដានត្រួតពិនិត្យ ការអនុវត្ត*ផយអជ ២០០៦-២០១០* ។ ឆ្លងតាមការរៀនសូត្រពីបទពិសោធន៍ ដែលកើតមានកន្លងមកប្រការសំខាន់ដែល ត្រូវបានឯកភាពគ្នានោះ គឺត្រូវធានាថា *សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ* របស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបំពេញនូវលក្ខណៈវិនិច្ឆ័យ ចំនួនពីរ គឺថា : (១) សូចនាករនិងចំណុចដៅ ដែលបានស្នើឡើង ត្រូវជាសូចនាករដែលអាចវាស់វែង ហើយត្រូវធានាថា ទិន្នន័យសម្រាប់ការតាមដានត្រួតពិនិត្យលើ សូចនាករនិងចំណុចដៅទាំងនោះ អាចមានទាន់ពេលវេលា សម្រាប់ការប្រើប្រាស់ ឬក៏អាចប្រមូលបាន តាមពេលកំណត់ (២) ក្រសួងឬស្ថាប័នមួយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ត្រូវបានកំណត់ ហើយបានយល់ព្រម ធ្វើជាអ្នកទទួលខុសត្រូវ ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការវិវត្តប្រែប្រួល នៃសូចនាករនិងចំណុចដៅទាំងនោះ ។ ទន្ទឹមនឹងនេះ *អនុក្រុមការងារ* របស់ *ក្រុមការងារបច្ចេកទេសចម្រុះផែនការនិងការកាត់បន្ថយភាពក្រីក្រ* ត្រូវបានបង្កើតឡើង ដើម្បីរៀបចំ តារាងបញ្ជី សូចនាករសំខាន់ៗ សម្រាប់ការតាមដានត្រួតពិនិត្យ ដែលអាចមានសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដោយផ្អែកលើការងារទាំងឡាយដែលបានអនុវត្តកន្លងមក ។ *ក្រសួងផែនការ* បានផ្តល់ការណែនាំ ដល់អនុក្រុមការងារនេះ ដើម្បី ធ្វើការរៀបចំនិង ស្នើឡើង នូវ តារាងបញ្ជីសូចនាករនិងចំណុចដៅ សំខាន់ៗ ដូចខាងក្រោម :

- សូចនាករនិងចំណុចដៅទាំងឡាយរបស់ *ផយអជ ២០០៦-២០១០* រួមបញ្ចូលនូវ សូចនាករនិងចំណុចដៅមួយចំនួន ដែលបានជ្រើសរើសចេញពី *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ព្រមទាំង សូចនាករនិងចំណុចដៅ មួយចំនួនបន្ថែមទៀត ពីកម្មវិធីកំណែទម្រង់ និង អាទិភាព សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់*រាជរដ្ឋាភិបាលកម្ពុជា* ។ ដោយផ្អែកតាមបទពិសោធន៍ជាក់ស្តែងក្នុងការអនុវត្ត ការងារតាមដានត្រួតពិនិត្យសូចនាករទាំងនោះ ដែលបានបង្ហាញថា នៅក្នុងករណីដែលសូចនាករណាមួយ ត្រូវពិនិត្យកែសម្រួលឡើងវិញ ឬ មិនមានលក្ខណៈងាយស្រួលក្នុងការវាស់វែង នោះគួរតែមានការកែលម្អ ឬ ការលុបចេញពីតារាងបញ្ជី (តារាងសូចនាករ សេដ្ឋកិច្ច-សង្គកិច្ចសំខាន់ៗ ឬ តារាងនៅក្នុងអត្ថបទ) នូវសូចនាករ

ទាំងនោះ បើប្រសិនជាចាំបាច់ ។ ទន្ទឹមនឹងនេះ ដោយផ្អែកលើការកែសម្រួលឡើងវិញ ដោយ *អង្គការសហប្រជាជាតិ* លើសូចនាករនិងចំណុចដៅរបស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សាកល* ដែលបានចូលជាធរមានចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០០៨ សូចនាករនិងចំណុចដៅ ទាំងឡាយ របស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* នឹងត្រូវធ្វើ *បច្ចុប្បន្នកម្ម* ដើម្បីសម្របទៅនឹង ការផ្លាស់ប្តូររបស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សាកល* ។

- ការស្នើដាក់បញ្ចូលនូវសូចនាករថ្មីណាមួយ ដែលមិនត្រូវបានបញ្ចូលនៅក្នុងតារាងបញ្ជីសូចនាករ ដូចបានរៀបរាប់នៅក្នុងចំណុចទី១ខាងលើ ត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យមួយចំនួន ដើម្បីទទួលបាន ការពិនិត្យពិចារណា ក្នុងការដាក់បញ្ចូលទៅជា សូចនាករមួយរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដូចខាងក្រោម ៖
    - *ត្រូវកំណត់ថាតើ **ក្រសួងឬស្ថាប័នណា** ជាអ្នកទទួលខុសត្រូវ ក្នុងការតាមដានត្រួតពិនិត្យសូចនាករ* ៖ ក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវ ក្នុងការតាមដានត្រួតពិនិត្យសូចនាករ ត្រូវតែកំណត់ឱ្យបានច្បាស់ ហើយ ការទទួលយល់ព្រមរបស់ក្រសួង-ស្ថាប័ន ដែលត្រូវអនុវត្តការងារនេះ ក៏ត្រូវតែធ្វើការបញ្ជាក់ឱ្យបានច្បាស់ ផងដែរ ។
    - ***ត្រូវមានការធានា*** ថា ទិន្នន័យ ដែលចាំបាច់ សម្រាប់ការតាមដានត្រួតពិនិត្យសូចនាករ ដែលបានលើកឡើង នឹងអាចរកបានពីប្រភព ស្ថិតិរដ្ឋបាល (របាយការណ៍រដ្ឋបាល) ឬ អាចប្រមូលបាន ដោយ *វិទ្យាស្ថានជាតិស្ថិតិ* ។
    - ***ត្រូវមានការធានា*** ថា ក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការងារនេះ មានសមត្ថភាព និងធនធានគ្រប់គ្រាន់ សម្រាប់ការធ្វើវិភាគនិងរៀបចំរបាយការណ៍ ស្តីពីលទ្ធផលនៃការងារតាមដានត្រួតពិនិត្យ ។
- តារាងបញ្ជីសរុបមួយ ស្តីពីសូចនាករទាំងឡាយ ដែលត្រូវបានប្រមែប្រមូល ដោយផ្អែកតាមលក្ខខណ្ឌទាំងឡាយ នៃចំណុចទី១ និង ចំណុចទី២ ខាងលើ នឹងក្លាយជា ***តារាងបញ្ជី សូចនាករតាមដានត្រួតពិនិត្យ*** ដែលនឹងត្រូវអាចដាក់បញ្ចូល ទៅក្នុង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។
- តារាងបញ្ជីសូចនាករចុងក្រោយ ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* នឹងត្រូវកំណត់ឡើង ដោយការសម្រេច របស់ស្ថាប័នកណ្តាលទាំង ៤ រួមមាន *ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* និង *ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ* ដើម្បីធានាឱ្យមាន ***តុល្យភាពសមស្រប*** រវាង *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* គោលដៅនៃកម្មវិធីកំណែទម្រង់នានា និង អាទិភាពចម្បងៗនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ។

៥៨៧. អនុក្រុមការងារនេះ បានយកចិត្តទុកដាក់ខ្ពស់ក្នុងការបំពេញភារកិច្ចនេះ ។ ប៉ុន្តែ គួរឱ្យសោកស្តាយ ក្រុមការងារនេះ ពុំអាចបញ្ចប់កិច្ចការនេះបានចប់សព្វគ្រប់ទាំងស្រុងនៅឡើយទេ ដោយព្រោះពុំមានពេលវេលាគ្រប់គ្រាន់ ។ ដូច្នេះ សម្រាប់ពេលនេះ "*សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ របស់ ផយអជ ២០០៦-២០១០*" ត្រូវបានរក្សាទុក នៅដដែល ដោយមិនមានធ្វើការផ្លាស់ប្តូរ (*តារាងទី ២៧*) ។ ទោះជាដូចនេះក្តី *ក្រសួងផែនការ* នឹងនៅតែបន្តការងាររៀបចំ *សូចនាករនិងចំណុចដៅ សំខាន់ៗ សម្រាប់ការតាមដានត្រួតពិនិត្យ* ដែលនឹងត្រូវធ្វើបច្ចុប្បន្នកម្ម សម្រាប់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ហើយនឹង បញ្ចប់កិច្ចការនេះ មុនពេលដែល ការងារវិភាគវាយតម្លៃរួមលើកទី១ ស្តីពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ចាប់ផ្តើមដំណើរការ ។

៥៨៨. ប្រការទាំងឡាយ ដែលអាចយកមកគិតគូរពិចារណា ក្នុងការកំណត់កាលវិភាគដ៏សមស្រប សម្រាប់ការវិភាគវាយតម្លៃរួមលើវឌ្ឍនភាព ដែលត្រូវធ្វើឡើងដោយ *ក្រសួងផែនការ* រួមមាន : (១) កាលបរិច្ឆេទនៃការផ្តល់ការអនុម័តលើ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ពី *ស្ថាប័ននីតិប្បញ្ញត្តិ* គឺអាចនៅក្នុងត្រីមាសទី១ ឆ្នាំ២០១០ (២) ពេលពាក់កណ្តាលនៃដំណាក់កាលរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺនៅពាក់កណ្តាលឆ្នាំ២០១១ ។ ដូច្នេះ ជាការអនុវត្តជាក់ស្តែង ការវិភាគវាយតម្លៃរួមលើកទី១ ស្តីពីវឌ្ឍនភាព សម្រាប់ឆ្នាំ២០០៩ និង ឆ្នាំ២០១០ នឹងត្រូវអាចរៀបចំធ្វើឡើង នៅក្នុងដើមឆ្នាំ២០១១ ។ ទោះជាដូចនេះក្តី អាស្រ័យដោយហេតុថា របាយការណ៍ពាក់កណ្តាលអាណត្តិមួយ ស្តីពីការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម* ចាំបាច់ត្រូវរៀបចំធ្វើឡើង នៅពាក់កណ្តាលឆ្នាំ២០១១ ផងដែរនោះ នោះ *ក្រសួងផែនការ* បានធ្វើការសម្រេចចិត្ត ផ្តោតទៅលើតែការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ស្តីពីការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដែលមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ ជាង ។ ការងាររៀបចំ របាយការណ៍ពាក់កណ្តាលអាណត្តិ នឹងត្រូវចាប់ផ្តើម នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ ហើយ គ្រោងនឹងបញ្ចប់ នៅចុងខែកញ្ញា ឆ្នាំ២០១១ ។ ការងាររៀបចំការវិភាគវាយតម្លៃវឌ្ឍនភាពបន្ទាប់ នឹងត្រូវចាប់ផ្តើម នៅខែកញ្ញា ឆ្នាំ២០១២ ហើយ គ្រោងនឹងបញ្ចប់ នៅចុងខែធ្នូ ឆ្នាំ២០១២ ។ ការងាររៀបចំ *ផយអជ* ២០១៤-២០១៨ នឹងត្រូវចាប់ផ្តើម ក្នុងខែមករា ឆ្នាំ២០១៣ ហើយ គ្រោងនឹងបញ្ចប់ នៅខែធ្នូ ឆ្នាំ២០១៣ ។

## តារាងទី២៧ : គោលដៅជាតិនិងសូចនាករសំខាន់ៗ (ចំណុចដៅ) របស់ផយអជ ២០០៦-២០១០

### (*)- គោលដៅនិងចំណុចដៅរបស់ គអសក

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០០៨ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|---|
| | **លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (*)** | | | | |
| ១* | ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ | ៣៤,៧ | ៣០,១ | ២៥ | ១៩,៥ |
| ២* | ភាគរយនៃប្រជាជននៅតំបន់ជនបទ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ | ៣៩,២ | ៣៤,៧ | - | - |
| ៣* | ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ - % នៃប្រ/ជ | ១៩,៧ | ១៨ | ១៣ | ១០ |
| | **លើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម** | | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ១,៩៧ | ២,៧៤ | ២,៨ | ៣,០ |
| ៥ | ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រពដោយប្រព័ន្ធ ធារាសាស្ត្រ) (%នៃផ្ទៃដាំស្រូវ) | ២០ | - | ៣៣,៥ | - |
| ៦ | កំណែទម្រង់ដីធ្លី : ចំនួនបណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនកសិករ (%នៃផ្ទៃដីសរុប) | ១២ | ២០ | ២៤ | - |
| | **លើកកម្ពស់ស្ថានភាពសុខភាព (*)** | | | | |
| ៧* | អត្រាមរណភាពទារក ក្នុង ១ ០០០កំណើតរស់ | ៦៦ | ៦៦ | ៦០ | ៥០ |
| ៨* | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង ១ ០០០កំណើតរស់ | ៨២ | ៨២ | ៧៥ | ៦៥ |
| ៩* | មរណភាពមាតា ក្នុង ១០០ ០០០កំណើតរស់ | ៤៧៣** | ៤៦១*** | ៣៥០ | ២៥០ |
| ១០* | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | ៤៤** | ៥៨ | ៧០ | ៨៧ |
| ១១* | អត្រាប្រេវ៉ាឡង់មេរោគហ៊ីវ/ជំងឺអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ | ១,០ | ០,៧ | ០,៧ | <០,៦ |
| ១២* | អត្រាជំងឺគ្រុនចាញ់ស្លាប់ ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ | ២,៧០ | ២,១០ | ១,២០ | ០,៧៨ |
| ១៣* | អត្រាប្រេវ៉ាឡង់ជំងឺរបេងគ្រប់សណ្ឋាន ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ | ៦៧៦ | ៦១៧ | ៥៦៤ | ៤៦៤ |
| ១៤* | ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) | ២០,១ | ២៦ | ៤០ | ៦០ |
| | **លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ** | | | | |
| ១៥ | អត្រាកុមារអាយុពី ០ខែ ដល់ ៥៩ខែ ដែលមានភាពក្រិន មធ្យម (កម្ពស់ធៀបនឹងអាយុ ទាបជាង -២SD) | ៣៧ | ៣៩,៥ | ២៨ | ២២ |
| ១៦ | អត្រាកុមារអាយុ ០ខែ ដល់ ៥៩ខែ ដែលមានភាពស្គមស្គាំង មធ្យម (ទម្ងន់ធៀបនឹងកម្ពស់ ទាបជាង -២SD) | ៧ | ៨,៩ | ១០ | ៩ |
| ១៧* | អត្រាស្ត្រីអាយុពី ១៥ឆ្នាំ ដល់ ៤៩ឆ្នាំ ដែលមានភាពស្លេកស្លាំង | ៤៧ | គ្មានតួលេខ | ៣២ | ១៩ |
| ១៨ | ភាគរយនៃកុមារអាយុពី ៦ ដល់ ៥៩ ខែ ដែលមានភាពស្លេកស្លាំង | ៦២ | គ្មានតួលេខ | ៥២ | ៤២ |
| | **លើកកម្ពស់វិស័យអប់រំ (*)** | | | | |
| ១៩* | អត្រាពិតនៃការសិក្សា : បឋមសិក្សា (សរុប-ប្រុស-ស្រី) | ៩១,៩-៩៣-៩០,៧ | ៩៤,៤-៩៤,៨-៩៤,០ | ៩៦,០-៩៦,០-៩៥,៥ | ១០០ សម្រាប់ទាំងអស់ |

| គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | | ២០០៥ | ២០០៨ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|---|
| ២០* | អត្រាពិតនៃការសិក្សា : មធ្យមសិក្សាបឋមភូមិ ( សរុប-ប្រុស-ស្រី) | ២៦.១-២៧.១-២៤.៨ | ៣៣.៩-៣២.០-៣៥.០ | ៤៣.០-៤១.០-៤៥.០ | ១០០ សម្រាប់ទាំងអស់ |
| ២១* | អត្រាបញ្ចប់ការសិក្សា ថ្នាក់ទី៦ | ៥៣.១ | ៨៥.៦ | ៨៨.០ | ១០០ |
| ២២* | អត្រាបញ្ចប់ការសិក្សា ថ្នាក់ទី៩ | ៣០.១៨ | ៤៩.១ | ៥៣.០ | ១០០ |
| ២៣* | កុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន (%) | ១៨.៧ | ១៧ | ១៥ | ១០ |
| | **ការអភិវឌ្ឍជនបទ** | | | | |
| ២៤* | ផ្លូវជនបទដែលបានស្តារ លើប្រវែងផ្លូវសរុប ២៨ ០០០ គម | ២២ ៧០០ | ២៤ ១៤០ | ២៦ ៦៥៨ | ៣២ ០០០ |
| ២៥* | លទ្ធភាពមានទឹកស្អាតបរិភោគ (%នៃប្រជាជនជនបទ) | ៤១.៦ | ៤០.៤៩ | ៤៣.៤៩ | ៥០.០៩ |
| ២៦* | លទ្ធភាពប្រើប្រាស់សេវាអនាម័យ (%នៃប្រជាជនជនបទ) | ១៦.៤ | ២៣.២៤ | ២៥ | ៣៣ |
| | **ចីរភាពបរិស្ថាន (*)** | | | | |
| ២៧* | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | ៦០ | ៥៩.០៩ | ៥៧.៥៩ | ៦០ |
| ២៨* | ការប្រើប្រាស់អុស-ធ្យូង : គ្រួសារ (%) | ៨៣.៩ | ៧៣ | ៦១ | ៥២ |
| ២៩* | ការទទួលបានប្រភពទឹកស្អាត (%នៃប្រជាជនទីប្រជុំជន) | ៣៥[9] | ៥១ | ៧៥[9] | ៨០ |
| ៣០* | ការទទួលបានការកែលម្អអនាម័យ (%នៃប្រជាជនទីប្រជុំជន) | ៥៥ | - | ៦៧ | ៧៤ |
| | **សមធម៌យេនឌ័រ (*)** | | | | |
| ៣១* | បញ្ជ្រាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន (*) | | | | |
| ក | ក្រសួង និងស្ថាប័នពាក់ពន្ធ័ បានរៀបចំផែនការយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រតាមវិស័យ | ២ | ១៥ | ២០ | ២៧ |
| ខ | ក្រសួង និងស្ថាប័នពាក់ពន្ធ័បានអនុវត្តផែនការយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រតាមវិស័យ | ២ | ១០ | ១៥ | ២៧ |
| ៣២* | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ (កសិកម្ម --ឧស្សាហកម្ម --សេវាកម្ម) % | ៥២.៩-៥៣.៥-២៧.០ | ៥២.៥-៥៣.៥-២៧.០ | ៥០-៥០-៣៧ | ៥០-៥០-៥០ |
| ៣៣* | កម្រិតយល់ដឹងអំពី អំពើហិង្សាប្រឆាំងនឹងស្ត្រី ជាឧក្រិដ្ឋកម្ម % | ៤.៥ | ៣០ | ៥០ | ៧០ |
| ក | ចំនួនដីកាការពារ ដែលបានចេញដោយតុលាការ ដោយ យោងតាមច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ | ០ | គ្មានតួលេខ | ៤០ | ១២០ |
| ខ | ចំនួនជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដែលទទួលបាន ការប្រឹក្សាយោបល់ ពីភ្នាក់ងារជំនាញ | ០ | ៦០០ | ៩០០ | ២ ០០០ |
| | **កំណែទម្រង់** | | | | |
| ៣៤ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | នឹងត្រូវបង្កើតឡើង | | | |
| | **ធ្វើឱ្យមានស្ថិរភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់ (*)** | | | | |
| ៣៥ | កំណើន *ផសស* ប្រចាំឆ្នាំ គិតតាមថ្លៃថេរ (%) | ១៣.៣ | ៦.៧ | ៥.០ | - |
| ៣៦ | *ផសស* សម្រាប់មនុស្សម្នាក់ គិតតាមថ្លៃថេរ (ពាន់រៀល) | ១ ៤០០ | ២ ៩៥៨ | ៣ ២៨៤ | - |
| ៣៧ | អត្រាអតិផរណា (ការប្រែប្រួលជាមធ្យមប្រចាំឆ្នាំ -- %) | ៦.២ | ១៩.៧ | ៦.០ | - |
| | **កែលម្អការប្រើប្រាស់ថវិកា** | | | | |

| គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | | ២០០៥ | ២០០៨ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|---|
| ៣៨ | ចំណូលថវិការដ្ឋសរុប : (%នៃផសស) | ១១.៨ | ១៣.៣ | ១២.៦ | |
| ៣៩ | ចំណាយថវិការដ្ឋសរុប : (%នៃផសស) | ១៤.៩ | ១៥.៧ | ១៥.៤ | |
| | ***បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ*** | | | | |
| ៤០ | កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ (%) | ១០.២ | ៣.១ | ១៤.២ | |
| ៤១* | ពលកម្មកុមារអាយុ ៥-១៧ឆ្នាំ (%) | ២២.៣ | - | ១០.៦ | ៨ |
| | ***ទេសចរណ៍*** | | | | |
| ៤២ | ទេសចរអន្តរជាតិប្រចាំឆ្នាំ (ពាន់នាក់) | ១ ៤២១ | ២ ១២៥ | ២ ២៧៦ | ៤ ៤៥០ |
| | ***ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ (*)*** | | | | |
| ៤៣* | ចំនួនអ្នករងគ្រោះ (ស្លាប់ និងរបួស) | ៧៩៧ | ២៧១ | ២១២ | ១២៥ |
| ៤៤* | *តំបន់ដែលបានបោសសម្អាតមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម -- (%)* | ៣០ | ៤៨ | ៥៨ | ៨៧ |
| | ***ហេដ្ឋារចនាសម្ព័ន្ធ*** | | | | |
| ៤៥ | ផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិនិងផ្លូវខេត្ត) លើប្រវែងផ្លូវសរុប ១១ ៦១៨ -គម | ២ ១០០ | ២ ១៨៦ | ២.៥៨០ | ៤ ១០០ |
| | ***ថាមពល*** | | | | |
| ៤៦ | ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ (គីឡូវ៉ាត់ម៉ោង) | ៥៤ | ១៣៩ | ១៥៣ | ៣៥០ |

**ប្រភព :**

** អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០៥

*** ជំរឿនទូទៅនូវប្រជាពស្ត្ររបស់កម្ពុជា ឆ្នាំ២០០៨

[1] តួលេខរបស់ *របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨ ស្តីពីការអនុវត្ត ផយអជ ២០០៦-២០១០*

# ជំពូកទី៧

## សេចក្តីសន្និដ្ឋាន

៥៨៩. *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្ត គោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ដែលមានចែងនៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២* ។ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវរៀបចំឡើង ដើម្បីសម្រេចគោលដៅចម្បងពីរ ។ *គោលដៅទី១* គឺដើម្បីបន្សុំអាណត្តិកាលរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ជាមួយអាណត្តិរបស់ *រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* សំដៅធានាថា សកម្មភាពដែលបានគ្រោងទុកទាំងឡាយ របស់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលត្រូវបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ។ *គោលដៅទី២* គឺ ដើម្បីធានាថា ការងារដែលត្រូវលើកឡើង ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះ ត្រូវបានរៀបចំ ដោយមានការគិតគូរដល់ ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលអាចមានមកលើសេដ្ឋកិច្ចកម្ពុជា ។ ការវិវត្តប្រែប្រួលជាអវិជ្ជមាននៃកត្តាក្រៅប្រទេសទាំងនេះ បានបណ្តាលឱ្យមានការធ្លាក់ចុះនូវតម្រូវការលើការនាំចេញទំនិញរបស់ *កម្ពុជា* ហើយ បានបង្កើនហានិភ័យ ផ្នែកហិរញ្ញវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច ដោយបាននាំឱ្យ *កម្ពុជា* ជួបនឹងបញ្ហាប្រឈមថ្មីៗ ដែលមិនបានរំពឹងទុកជាមុន ។ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងរៀបចំ ជាប្រព័ន្ធនិងជាលំដាប់លំដោយ នូវវិធានការជាច្រើន ដើម្បីបន្ធូរបន្ថយឥទ្ធិពលអវិជ្ជមាន នៃវិបត្តិហិរញ្ញវត្ថុអន្តរជាតិនិងឱនភាពសេដ្ឋកិច្ចពិភពលោក ដែលមានមកលើប្រព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ *កម្ពុជា* ព្រមទាំង ដើម្បីការពារនូវសមិទ្ធផលដែលយើងសម្រេចបានដោយលំបាក កន្លងមក ។ ការវិវត្តប្រែប្រួលនៃកត្តាខាងក្រៅទាំងនេះ បានតម្រូវឱ្យក្រសួង-ស្ថាប័នទាំងអស់ ធ្វើការពិនិត្យមើលឡើងវិញ នូវផែនការទាំងឡាយរបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយជាអាទិភាព របស់ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ។ ក្នុងន័យនេះ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានរៀបចំឡើង ដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងពីរខាងលើ ។

៥៩០. ដូចដែលបានគូសបញ្ជាក់ ជាច្រើនលើកច្រើនសារ រួចមកហើយ *ផយអជ បច្ចុប្បន្នកម្ម* គឺជា ឧបករណ៍ ឬជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ដែលមានចែងនៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២* ។ *ផយអជ បច្ចុប្បន្នកម្ម* ត្រូវបានរៀបចំឡើង ដោយធ្វើការប្រើប្រាស់វិធីសាស្ត្រមួយ ដែលត្រូវបានធ្វើការកែលម្អបន្ថែមទៀត ដូចបានលើកឡើងនៅក្នុង កឋាខ័ណ្ឌទី ១០ ។ ពិនិត្យជារួម វិធីសាស្ត្រនេះ ត្រូវបានផ្តួចផ្តើមឡើង ដើម្បីធ្វើការប្រមែប្រមូលព័ត៌មាន

តាមរបៀប *ពីក្រោមឡើងលើ* សំដៅធ្វើការកំណត់នូវ *អ្នកទទួលខុសត្រូវ សកម្មភាពសំខាន់ៗ* និង *តម្លៃដែលត្រូវចំណាយ* ក្នុងការអនុវត្តផែនការបណ្តាសកម្មភាព ដែលបានស្នើឡើង ក៏ដូចជា តាមរបៀប *ពីលើចុះក្រោម* ដែលផ្អែកលើការវិភាគជាលក្ខណៈសេដ្ឋកិច្ចមាត្រ អំពីនិន្នាការនៃការវិវត្តជរបស់ស្ថានភាពរួមនៃសេដ្ឋកិច្ច ។ បន្ថែមលើវិធីសាស្ត្រខាងលើនេះ *ក្រសួងផែនការ* បានអនុវត្តការងារជាក់លាក់មួយចំនួន ដើម្បីធានាឱ្យមានការចូលរួមយ៉ាងសកម្ម និងភាពជាម្ចាស់លើធាតុចូល របស់ក្រសួង-ស្ថាប័ន ព្រមជាមួយគ្នានឹងការធានា ផងដែរ ថា ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលដទៃទៀត ត្រូវបានផ្តល់ឱ្យ នូវកាលានុវត្តភាព ដើម្បីចូលរួមយ៉ាងសកម្មក្នុងដំណើរការនៃការរៀបចំ ធាតុចូល របស់បណ្តាក្រសួង-ស្ថាប័ន ។

